ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# វិធីសាស្ត្រនៃការសរសេរ

# តែងសេចក្តី

## សម្រាប់មធ្យមសិក្សាទុតិយភូមិ

## ថ្នាក់ទី១០ ទី១១ និងទី១២



នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៨

# វិធីសាស្ត្រនៃការសរសេរ

# តែងសេចក្តី

## សម្រាប់មធ្យមសិក្សាទុតិយភូមិ

## ថ្នាក់ទី១០ ទី១១ និងទី១២

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៤៩ អយក.ប្រ.ក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## «វិធីសាស្ត្រនៃការសរសេរតែងសេចក្តីសម្រាប់មធ្យមសិក្សាទុតិយភូមិ»
## ថ្នាក់ទី១០ ទី១១ និងទី១២

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងកំណត់ហេតុស្តីពីកិច្ចប្រជុំសេចក្តីព្រាងឯកសារវិធីសាស្ត្រសរសេរតែងសេចក្តីសម្រាប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយ«វិធីសាស្ត្រនៃការសរសេរតែងសេចក្តីសម្រាប់មធ្យមសិក្សាទុតិយភូមិ»ថ្នាក់ទី១០ ទី១១និងទី១២ ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀន និងបង្រៀននៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាទុតិយភូមិ មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

# មុខកថា

«ការពង្រឹងគុណភាពអប់រំ» ជាឃ្លាមួយដែលបានចែងច្បាស់ ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្ស ប្រកបដោយគុណភាពមានចំណេះដឹងជំនាញ និងគុណតម្លៃបរិបូរណ៍ក្នុងការរួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងអន្តរជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ចំណុច រួមមានៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមានការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះពីការងារដោយឡែក តាមជំនាញនីមួយៗ មកជាការងាររួមតាមអនុវិស័យ។ ក្នុងទិដ្ឋភាពនេះ ការពង្រឹងការបង្រៀន និងការរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀត ឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ជាពិសេសសិស្សានុសិស្សនឹងមានចំណេះដឹងជ្រៅជ្រះទូលំទូលាយ ព្រមទាំងមានសមត្ថភាពសម្រាប់អនាគតដែលមានភាពជាអ្នកដឹកនាំប្រកបដោយគុណធម៌ សីលធម៌ សុជីវធម៌ និងមានភាពឈ្លាសវៃ ក្នុងការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព។ សំណេរតែងសេចក្តីក្នុងភាសាខ្មែរ ជាសមត្ថភាពចម្បងមួយដែលកើតឡើង ពីការអាន ស្តាប់ និយាយ ចំណេះដឹងផ្នែកវេយ្យាករណ៍ និងចំណេះដឹងទូទៅជាច្រើនផ្នែកទៀត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា សៀវភៅ**«វិធីសាស្ត្រសរសេរតែងសេចក្តី»** នៅមធ្យមសិក្សាទុតិយភូមិនេះ នឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀន និងបង្រៀនផ្នែកសំណេរតែងសេចក្តីប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# បញ្ជីគណៈកម្មការ

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

ឯកឧត្តមបណ្ឌិត **អ៊ឹម កុច**

លោកជំទាវ **ទន់ សាអ៊ីម**

ឯកឧត្តម **រស់ សាលីន**

## គណៈកម្មការនិពន្ធ

លោក យិន ធី

លោក អោ សៀម

លោក យ៉ង់ កំស៊ាន

លោកស្រី មៅ តាន់ណារី

លោក ព្រៃ សំបូរ

លោក ងិន សុតារា

លោកស្រី វ៉ាន់ សុភី

លោកស្រី ផាន់ សុជាតា

លោក រ៉ិត សុខខេង

លោកស្រី សេង ពិសិដ្ឋនារី

## គណៈកម្មការពិនិត្យ

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

ឯកឧត្តមបណ្ឌិត **អ៊ឹម កុច**

លោកជំទាវ **ទន់ សាអ៊ីម**

ឯកឧត្តម **ពុត សាមិត្ត**

បណ្ឌិត **ម៉ុក សារ៉ុម**

## បច្ចេកទេសកុំព្យូទ័រនិងរចនា

លោក លឹម សុត្ថារិទ្ធ

# អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកសំណេរតែងសេចក្តីប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគណៈកម្មការអភិវឌ្ឍឯកសារ **«វិធីសាស្ត្រសរសេរតែងសេចក្តី»** ដើម្បីជាជំនួយក្នុងការរៀននិងបង្រៀនតែងសេចក្តី ដែលជាមូលដ្ឋានក្នុងការជួយលោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

ក្នុងឯកសារនេះមានបង្ហាញពីៈ

- បញ្ញត្តិនៃតែងសេចក្តី
- ប្រភេទនៃតែងសេចក្តី
- វិធីសាស្ត្រក្នុងការធ្វើតែងសេចក្តី
- ឧទាហរណ៍គំរូនៃតែងសេចក្តីមួយចំនួន ។

នៅក្នុងផ្នែកឧទាហរណ៍គំរូនេះ យើងបានលើកយកវិញ្ញាសារបស់លោកគ្រូ អ្នកគ្រូមួយចំនួនដែលមានស្នាដៃនិងបទពិសោធល្អក្នុងការបង្រៀន ស្នាដៃរបស់សិស្ស ដែលជាប់សញ្ញាបត្រមធ្យមសិក្សានិងវិញ្ញាសាប្រឡងថ្នាក់ជាតិជាដើម។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារ **«វិធីសាស្ត្រសរសេរតែងសេចក្តី»** នេះនឹងបានជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀនផ្នែកសំណេរតែងសេចក្តីព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ ហើយប្រើប្រាស់ភាសាខ្មែរបានត្រឹមត្រូវប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

**គណៈកម្មការនិពន្ធ**

# មាតិកា

ទំព័រ

**បញ្ជីគណៈកម្មការ**------------------------------------------------------------------------------------------------------------------i
**អារម្ភកថា**------------------------------------------------------------------------------------------------------------------ii
**មាតិកា**------------------------------------------------------------------------------------------------------------------iii
**តារាងបែងចែកខ្លឹមសារនិងម៉ោងបង្រៀនវិធីសាស្ត្រសរសេរតែងសេចក្តី**------------------------------ 1
**សេចក្តីផ្តើម** ------------------------------------------------------------------------------------------------------3
**១- ដូចម្តេចដែលហៅថាតែងសេចក្តី?** ------------------------------------------------------------------------3
**២- សារៈសំខាន់នៃការធ្វើតែងសេចក្តី** ---------------------------------------------------------------------4
២.១- ចេះបង្ហាញមតិ គំនិត ----------------------------------------------------------------------------------4
២.២- ចេះស្រាយបញ្ហា ---------------------------------------------------------------------------------------4
២.៣- ចំណេះដឹងទូទៅ ---------------------------------------------------------------------------------------4
២.៤- ជួយពង្រឹងគំនិតប្រាជ្ញា----------------------------------------------------------------------------------4
២.៥- តែងសេចក្តីជួយមុខវិជ្ជាឯទៀត---------------------------------------------------------------------------5
២.៦- តែងសេចក្តីផ្តល់ប្រយោជន៍ក្នុងការស់នៅ ----------------------------------------------------------------5
**៣- ការត្រៀម និងការរៀបចំដំណើរការសរសេរតែងសេចក្តី** ---------------------------------------------5
៣.១- ជំហរសតិអារម្មណ៍ និងចិត្តគំនិតពេលធ្វើតែងសេចក្តី--------------------------------------------------5
៣.២- ការសិក្សាប្រធាន -----------------------------------------------------------------------------------------6
៣.៣- ការធ្វើគម្រោងប្លង់តែង------------------------------------------------------------------------------------6
៣.៤- ចំណុចមួយចំនួនដែលអ្នកសរសេរតែងសេចក្តីគួរយកចិត្តទុកដាក់ -------------------------------- 14
**៤- វិធីសាស្ត្រក្នុងការសរសេរតែងសេចក្តី**----------------------------------------------------------------18
៤.១- ការតាំងចិត្តនិងការប្រមូលគំនិត ------------------------------------------------------------------------ 18
៤.២- ការសិក្សាប្រធាន ---------------------------------------------------------------------------------------- 18
៤.៣- ការធ្វើគម្រោងតែងសេចក្តី ------------------------------------------------------------------------------ 19
៤.៤- ការសរសេរពេញលេញ ---------------------------------------------------------------------------------- 19
៤.៥- ការកែលម្អ---------------------------------------------------------------------------------------------- 19
**៥- ប្រភេទនៃប្រធានតែងសេចក្តី** ------------------------------------------------------------------------ 20
៥.១- ប្រធានអត្ថាធិប្បាយពន្យល់------------------------------------------------------------------------------ 20
៥.២- ប្រធានអត្ថាធិប្បាយពិភាក្សា ---------------------------------------------------------------------------- 23
៥.៣- ប្រធានអត្ថាធិប្បាយប្រៀបធៀប-------------------------------------------------------------------------- 27
**៦- ឧទាហរណ៍ប្រធានតែងសេចក្តី និងគម្រោងតែង** ---------------------------------------------------- 29
៦.១- ប្រធានអត្ថាធិប្បាយពន្យល់------------------------------------------------------------------------------ 29
៦.២- ប្រធានអត្ថាធិប្បាយពិភាក្សា ---------------------------------------------------------------------------- 43
**អត្ថបទគំរូតែងសេចក្តីសម្រាប់ថ្នាក់វិទ្យាសាស្ត្រ**--------------------------------------------------------- 63
១- ប្រធានអត្ថាធិប្បាយពន្យល់ ---------------------------------------------------------------------------------- 63

២- ប្រធានអត្ថាធិប្បាយពិភាក្សា ---------- 65
៣- ប្រធានអត្ថាធិប្បាយប្រៀបធៀប ---------- 70
**អត្ថបទគំរូតែងសេចក្តីសម្រាប់ថ្នាក់វិទ្យាសាស្ត្រសង្គម** ---------- 73
១- ប្រធានអត្ថាធិប្បាយពន្យល់ ---------- 73
២- ប្រធានអត្ថាធិប្បាយពិភាក្សា ---------- 75
**៧- ប្រធានតែងសេចក្តីដកស្រង់ចេញពីអក្សរសិល្ប៍រឿងទុំទាវ រឿងព្រះវេស្សន្តរ រឿងរាមកេរ្តិ៍** 83
៧.១- រឿងទុំទាវ ---------- 83
៧.២- រឿងព្រះវេស្សន្តរ ---------- 89
៧.៣- រឿងរាមកេរ្តិ៍ ---------- 96
**៨- លំនាំសំណេរល្អ** ---------- 103
៨.១- ប្រធានពន្យល់ (ក្នុងរឿងទុំទាវ.ព្រះវេស្សន្តរ.រាមកេរ្តិ៍) ---------- 103
៨.២- ប្រធានពិភាក្សា (ក្នុងរឿងព្រះវេស្សន្តរ) ---------- 108
៨.៣- ប្រធានប្រៀបធៀប (ក្នុងរឿងរាមកេរ្តិ៍) ---------- 110
**៩- ប្រធានតែងសេចក្តីតាក់តែងដោយលោកគ្រូ អ្នកគ្រូអញ្ជើញមកពីខេត្តនានា** ---------- 113
៩.១- ប្រធានអត្ថាធិប្បាយពន្យល់ ---------- 113
៩.២- ប្រធានអត្ថាធិប្បាយពិភាក្សា ---------- 128
៩.៣- ប្រធានអត្ថាធិប្បាយប្រៀបធៀប ---------- 144
**១០- លំនាំបង្រៀនតែងសេចក្តី** ---------- 163
១០.១- លក្ខណៈទូទៅនៃលំនាំបង្រៀនតែងសេចក្តី ---------- 163
១០.២- លំនាំបង្រៀនការអនុវត្តសរសេរតែងសេចក្តី ---------- 164

# តារាងបែងចែកខ្លឹមសារនិងម៉ោងបង្រៀនវិធីសាស្ត្រសរសេរតែងសេចក្ដី
## សម្រាប់មធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ដល់ថ្នាក់ទី១២

| ខ្លឹមសារ | រយៈពេលបង្រៀន | | | | |
|---|---|---|---|---|---|
| | ថ្នាក់ទី១០ | ថ្នាក់ទី១១ | | ថ្នាក់ទី១២ | |
| | | វិ.សាស្ត្រ | វិ.សង្គម | វិ.សាស្ត្រ | វិ.សង្គម |
| **វិធីសាស្ត្រសរសេរតែងសេចក្ដីខ្មែរ**<br>សេចក្ដីផ្ដើម<br>១- ដូចម្ដេចដែលហៅថាតែងសេចក្ដី?<br>២- សារៈសំខាន់នៃការធ្វើតែងសេចក្ដី<br>៣- ការត្រៀម និងការរៀបចំដំណើរការសរសេរតែងសេចក្ដី<br>៤- វិធីសាស្ត្រក្នុងការសរសេរតែងសេចក្ដី<br>៥- ប្រភេទនៃប្រធានតែងសេចក្ដី<br>៦- ឧទាហរណ៍ប្រធានតែងសេចក្ដី និងគម្រោងតែង | ✓ | ✓ | ✓ | ✓ | ✓ |
| **ប្រធានអត្ថាធិប្បាយពន្យល់**<br>ប្រធានអត្ថាធិប្បាយពន្យល់<br>- លក្ខណៈសម្គាល់ប្រធានអត្ថាធិប្បាយពន្យល់<br>- ទម្រង់ទូទៅនៃប្រធានអត្ថាធិប្បាយពន្យល់ | ✓ | ✓ | ✓ | ✓ | ✓ |
| **ប្រធានអត្ថាធិប្បាយពិភាក្សាសុទ្ធ**<br>- ប្រភេទនៃប្រធានពិភាក្សា<br>- លក្ខណៈសម្គាល់ប្រធានពិភាក្សា<br>- ទម្រង់ទូទៅនៃប្រធានពិភាក្សា | ✓ | ✓ | ✓ | 0 | 0 |
| **ប្រធានអត្ថាធិប្បាយពិភាក្សាប្រៀបធៀប**<br>- ប្រភេទនៃប្រធានពិភាក្សាប្រៀបធៀប<br>- លក្ខណៈសម្គាល់ប្រធានពិភាក្សាប្រៀបធៀប<br>- ទម្រង់ទូទៅនៃប្រធានពិភាក្សាប្រៀបធៀប | 0 | 0 | 0 | ✓ | ✓ |
| **ប្រធានអត្ថាធិប្បាយប្រៀបធៀប**<br>- លក្ខណៈសម្គាល់ប្រធានប្រៀបធៀប<br>- គម្រោងទូទៅប្រធានប្រៀបធៀប | ✓ | ✓ | ✓ | ✓ | ✓ |
| **ឧទាហរណ៍ប្រធាន និងគម្រោងលម្អិត**<br>ប្រធានអត្ថាធិប្បាយពន្យល់<br>ប្រធានទី១ | ✓ | ✓ | ✓ | ✓ | ✓ |
| ប្រធានទី២ | 0 | ✓ | ✓ | | |
| ប្រធានទី៣ | 0 | 0 | 0 | ✓ | ✓ |
| ប្រធានទី៤ | 0 | 0 | 0 | ✓ | ✓ |
| ប្រធានទី៥ | 0 | ✓ | ✓ | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ប្រធានទី៦ | ✓ | ✓ | ✓ | 0 | 0 |
| **ប្រធានអត្ថាធិប្បាយពិភាក្សាសុទ្ធ**<br>ប្រធានទី១ | ✓ | ✓ | ✓ | 0 | 0 |
| ប្រធានទី២ | ✓ | ✓ | ✓ | 0 | 0 |
| ប្រធានទី៣ | ✓ | ✓ | ✓ | 0 | 0 |
| ប្រធានទី៤ | ✓ | ✓ | ✓ | 0 | 0 |
| **ប្រធានអត្ថាធិប្បាយពិភាក្សាប្រៀបធៀប**<br>ប្រធានទី១ | 0 | 0 | 0 | ✓ | ✓ |
| ប្រធានទី២ | 0 | 0 | 0 | ✓ | ✓ |
| **ប្រធានអត្ថាធិប្បាយប្រៀបធៀប**<br>ប្រធានទី១ | ✓ | ✓ | ✓ | ✓ | ✓ |
| ប្រធានទី២ | ✓ | ✓ | ✓ | ✓ | ✓ |
| ❖ ប្រធានដកស្រង់ចេញពីរឿងទុំទាវ<br>- ប្រធានអត្ថាធិប្បាយពន្យល់ | ✓ | 0 | 0 | ✓ | ✓ |
| - ប្រធានអត្ថាធិប្បាយពិភាក្សា(សុទ្ធ) | ✓ | 0 | | ✓ | ✓ |
| - ប្រធានអត្ថាធិប្បាយបៀបធៀប | ✓ | 0 | 0 | ✓ | ✓ |
| ❖ ប្រធានដកស្រង់ចេញពីរឿងព្រះវេស្សន្តរ<br>- ប្រធានអត្ថាធិប្បាយពន្យល់ | 0 | ✓ | ✓ | ✓ | ✓ |
| - ប្រធានអត្ថាធិប្បាពិភាក្សា(សុទ្ធនិងប្រៀបធៀប) | 0 | ✓ | ✓ | ✓ | ✓ |
| - ប្រធានអត្ថាធិប្បាយប្រៀបធៀប | 0 | ✓ | ✓ | ✓ | ✓ |
| ❖ ប្រធានដកស្រង់ចេញពីរឿងរាមកេរ្តិ៍<br>- ប្រធានអត្ថាធិប្បាយពន្យល់ | 0 | 0 | 0 | ✓ | ✓ |
| - ប្រធានអត្ថាធិប្បាពិភាក្សា (សុទ្ធនិងប្រៀបធៀប) | 0 | 0 | 0 | ✓ | ✓ |
| - ប្រធានអត្ថាធិប្បាយប្រៀបធៀប | 0 | 0 | 0 | ✓ | ✓ |

**កំណត់សម្គាល់៖**

- ចំពោះខ្ទង់ខ្លឹមសារនៅថ្នាក់ណាដែលមានដាក់ថា ០ម៉ មានន័យថាមិនបង្រៀនទេ
- ប្រធានអត្ថធិប្បាយពន្យល់បែបសុភាសិត គំនិតអប់រំ បង្រៀនថ្នាក់ទី១០។

# សេចក្តីផ្តើម

តែងសេចក្តីជាវិជ្ជាមួយពិបាកសិក្សាឱ្យចេះឆាប់រហ័សទាន់ចិត្តណាស់។ អ្នកចេះធ្វើតែងសេចក្តីល្អមានចំនួនតិចតួចក្នុងចំណោមសិស្សានុសិស្ស។ កាលដើមឡើយគេច្រើនយល់ច្រឡំថា តែងសេចក្តីជាការងាយស្រួល ហើយពុំសូវមានសារសំខាន់ផង។ គេគ្រាន់តែចេះភាសាខ្មែរបន្តិចបន្តួច ចេះចាំរឿងខ្មែរខ្លះៗដែលគេនិយាយតៗគ្នា ពុំចាំបាច់អានអត្ថបទសិក្សារឿង ឱ្យស៊ីជម្រៅឬក៏ពុំចាំបាច់សិក្សាវិធីសាស្ត្រនៃការធ្វើតែងសេចក្តីក៏គេអាចធ្វើតែងសេចក្តីបានល្អដែរ។

នាសម័យអាណានិគមនិយម ប្រធានតែងសេចក្តីជ្រាលជ្រៅបំផុត មានត្រឹមតែប្រធានសុភាសិតប៉ុណ្ណោះ។ ចំពោះសេចក្តីអធិប្បាយក៏តម្រូវឱ្យបកស្រាយតែបន្តិចបន្តួចនូវន័យអត្តានុរូបនិងអត្ថបដិរូបរបស់សុភាសិតពុំតម្រូវឱ្យពិចារណាឬពិភាក្សាវែងឆ្ងាយនាំឱ្យមានការលូតលាស់នៃការគិតឬការពិចារណាភាពឈ្លាសវៃឡើយ។ ចំណែកថ្នាក់ខ្ពស់ៗតែងសេចក្តីខ្មែរ ពុំសូវមានការលើកតម្កើងដូចជាភាសាបារាំងឡើយ។

បច្ចុប្បន្ន តែងសេចក្តីខ្មែរត្រូវបានគេមើលឃើញពីសារប្រយោជន៍និងឱ្យតម្លៃយ៉ាងខ្ពស់ស្របជាមួយនឹងការលើកតម្កើងភាសានិងអក្សរសាស្ត្រជាតិ។ នៅក្នុងសាលារៀនចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សាក្នុងការប្រឡងសញ្ញាបត្រនិងប្រឡងវិជ្ជាជីវៈផ្សេងៗភាគច្រើនបាននិយមឱ្យតម្លៃទៅលើមុខវិជ្ជានេះ។ ពេលវេលាក្នុងកម្មវិធីសិក្សាក៏មានចំនួនច្រើនសម្រាប់ទុកសិក្សា។ ប្រធានតែងសេចក្តី ក៏កាន់តែមានទម្ងន់ស្របទៅតាមទំហំនៃការគិតពិចារណាដ៏ឈ្លាសវៃរបស់សិស្ស គឺសិក្សាពីកម្រិតទាបទៅកម្រិតខ្ពស់ពីងាយទៅពិបាក។

## ១- ដូចម្តេចដែលហៅថាតែងសេចក្តី?

មុននឹងសិក្សាតែងសេចក្តី យើងគប្បីយល់ថា ដូចម្តេចដែលហៅថាតែងសេចក្តី?

តែងសេចក្តីកើតមកពីពាក្យ **តែង** + **សេចក្តី**

- **តែង** មានន័យថា តុបតែងធ្វើឱ្យបានល្អ ពេញចិត្ត ទាក់ទាញ ចាប់អារម្មណ៍ជាដើម។ ឧទាហរណ៍ : តុបតែងផ្ទះមានន័យថា រៀបចំផ្ទះដោយមានគ្រឿងតុ ទូ វាំងនន រូបចម្លាក់ ផ្ទាំងរូបភាព លាបពណ៌ធ្វើឱ្យផ្ទះស្អាត ធ្វើឱ្យផ្ទះមានសោភណភាព ដើម្បីឱ្យអ្នកផងទាំងពួងពេញចិត្ត ចាប់អារម្មណ៍ កោតសរសើរ។ល។ តុបតែងខ្លួនមានន័យថា រៀបចំខ្លួនដោយប្រើគ្រឿងអលង្ការ លាបក្រែម ផាត់ម្សៅ ធ្វើសក់ ស្លៀកពាក់ ធ្វើឱ្យស្អាត ដើម្បីឱ្យគេចាប់អារម្មណ៍ ពេញចិត្ត ចូលចិត្ត មានចិត្តប្រតិព័ទ្ធជាដើម។
- **សេចក្តី** មានន័យថា ដំណើរ ហេតុការណ៍ គតិ លំអាន ផ្ទៃរឿង ដំណើរពាក្យ ខ្លឹមសារ។

ដូច្នេះតែងសេចក្តីមានន័យថា ការរៀបចំតាក់តែងពាក្យពេចន៍ ខ្លឹមសារ ដំណើរ ហេតុកាណ៍ផ្សេងៗឱ្យបានត្រឹមត្រូវល្អប្រកបដោយសោភ័ណ ជាទីចាប់អារម្មណ៍ ពេញចិត្តទៅតាមអ្វីដែលគេលើកមកចោទ។ បើនិយាយឱ្យងាយយល់តែងសេចក្តី គឺជាការសរសេរពិពណ៌នា រៀបរាប់ អំពីមនុស្ស សត្វ វត្ថុ ទីកន្លែង ព្រឹត្តិការណ៍ បាតុភូតធម្មជាតិ និទានរឿង និងការធ្វើអត្ថាធិប្បាយពីគំនិត ទស្សនៈ មតិ ឱ្យបានក្បោះក្បាយ ប្រើប្រាស់ពាក្យពេចន៍ពីរោះត្រឹមត្រូវ មានអត្ថន័យគ្រប់គ្រាន់ មានការរចនាតាមទម្រង់បែបបទត្រឹមត្រូវ ដើម្បីធ្វើឱ្យអ្នកអាន អ្នកស្តាប់ ងាយយល់ មានចំណាប់អារម្មណ៍ និងជាទីពេញចិត្ត។

## ២- សារៈសំខាន់នៃការធ្វើតែងសេចក្តី

តែងសេចក្តីមានសារៈសំខាន់ច្រើនយ៉ាងគឺៈ

### ២.១- ចេះបង្ហាញមតិ គំនិត

តែងសេចក្តីបង្រៀនឱ្យសិស្សចេះយកមតិ គំនិត យោបល់មកបង្ហាញឱ្យបានច្បាស់លាស់។ ដោយមានរបៀបរៀបរយតាមវិធីសាស្ត្រត្រឹមត្រូវ ចេះប្រើពាក្យពេចន៍ ឃ្លាប្រយោគ ស្តាប់ងាយយល់ ស្របតាមក្បួនវេយ្យាករណ៍។ គេអាចមានគំនិតច្រើនយោបល់ល្អប្រកបដោយខ្លឹមសារជ្រាលជ្រៅ។ បើពុំដូច្នោះទេ ការអធិប្បាយពន្យល់នឹងឈានទៅរកភាពច្របូកច្របល់ មិនច្បាស់លាស់ គ្មានសណ្តាប់ធ្នាប់ គឺឃ្លាប្រយោគក៏ពុំបានរចនាឱ្យបានល្អ មតិ ឬគំនិតនោះក៏គ្មានតម្លៃដែរ។ សិស្សមានបំណិនខាងបង្ហាញគំនិតយោបល់ ទស្សនៈរបស់ខ្លួនមានន័យថា មានបំណិនចេះស្រាយបញ្ហា។

### ២.២- ចេះស្រាយបញ្ហា

គោលបំណងក្នុងការបង្រៀនតែងសេចក្តី គឺចង់ឱ្យសិស្សចេះបញ្ចេញមតិ គំនិត យោបល់យល់ស្រប ឬមិនយល់ស្របតាមប្រធាន។ សិស្សចេះដោះស្រាយបញ្ហាស្មុគស្មាញដែលចោទឡើងបានត្រឹមត្រូវសមហេតុផលស្របទៅនឹងការពិតចំពោះមុខ។ ចំណុចសំខាន់ទាំងនេះ គឺជាគុណប្រយោជន៍សម្រាប់មនុស្សគ្រប់រូប ព្រោះមនុស្សតែងតែជួបប្រទះបញ្ហាគ្រប់យ៉ាង។ ដូច្នេះតែងសេចក្តី បានដឹកនាំឱ្យមនុស្សចៀសផុតពីគុណវិបត្តិដែលមានចំពោះមុខ ចេះរកហេតុផលបានសមស្របគឺឱ្យយើងចេះពឹងផ្អែកទៅលើចំណេះដឹងទូទៅជាមូលដ្ឋាន។

### ២.៣- ចំណេះដឹងទូទៅ

ការសរសេរតែងសេចក្តី ជាការបញ្ជាក់ពីសមត្ថភាពចំណេះដឹងទូទៅរបស់អ្នកសរសេរ ដែលអាចសរសេរស៊ីជម្រៅដល់កម្រិតណា ចេះវិភាគដល់កម្រិតណាក្នុងការពិចារណាដើម្បីរកអំណះអំណាងយ៉ាងសមស្របនូវអ្វីដែលគេបានសិក្សានិងបទពិសោធដែលទទួលបានកន្លងមក។ លើសពីនេះទៀត វាក៏ជាការវាស់ស្ទង់ ឆ្លុះបញ្ចាំងពីស្នាដៃនោះដែលបញ្ជាក់ថា អ្នកសរសេរមានចំណេះដឹងផ្សេងៗដូចជាៈ

- ចំណេះដឹងលើផ្នែកអក្សរសាស្ត្រជាតិ ភាសាជាតិ ចំណូលចិត្តក្នុងការអាន ការចងចាំអក្សរសិល្ប៍ ច្បាប់ទូន្មានផ្សេងៗ សុភាសិត និងបញ្ហាសង្គមទូទៅជាដើម។
- ចំណេះដឹងលើផ្នែកវេយ្យាករណ៍ ល្បះ ឃ្លា កន្សោមពាក្យ ។
- ចំណេះដឹងលើមេរៀនផ្សេងៗ ភូមិវិទ្យា ប្រវត្តិវិទ្យា បរិស្ថានវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា។
- ចំណេះដឹងលើបទពិសោធក្នុងការរស់នៅប្រចាំថ្ងៃ និងស្ថានភាពបច្ចុប្បន្ន។

### ២.៤- ជួយពង្រឹងគំនិតប្រាជ្ញា

ការធ្វើតែងសេចក្តី បានអភិវឌ្ឍគំនិតប្រាជ្ញាឱ្យចេះឆ្លើយ ឬបកស្រាយចំប្រធានដែលជាមធ្យោបាយសម្រាប់សិក្សាធ្វើឱ្យគំនិតប្រាជ្ញារីកដុះដាលដោយការចេះគិតពិចារណា ចេះវិនិច្ឆ័យ ចេះរិះគន់ឱ្យបានសមហេតុផល ដោយការសង្កេតពិនិត្យ សិក្សាស្រាវជ្រាវ។ល។ ដូច្នេះតែងសេចក្តីបានពង្រីកអប់រំគ្រឿង វិញ្ញាណ

របស់មនុស្សតាំងពីស្មារតី ឱ្យមានសមត្ថភាពមិនអន់ជាងការសិក្សាមុខវិជ្ជាសំខាន់ៗដទៃទៀតឡើយ។ មិនតែប៉ុណ្ណោះ ការធ្វើតែងសេចក្តីវាអាចជាជំនួយដល់វិជ្ជាផ្សេងទៀតផង។

### ២.៥- តែងសេចក្តីជួយមុខវិជ្ជាឯទៀត

ការសិក្សាតែងសេចក្តី ការសិក្សាវិជ្ជានានាក្តី មានភារៈជួយគ្នាទៅវិញទៅមកដូចជាការសិក្សាវិទ្យាសាស្ត្រធម្មជាតិ ប្រវត្តិវិទ្យា ភូមិវិទ្យាសុទ្ធតែតម្រូវឱ្យសិស្សសង្កេត ពិនិត្យ កត់ត្រាចំណាំ ពណ៌នាពីវត្ថុ ទីកន្លែង មនុស្ស សត្វ ឬហេតុការណ៍ក្នុងសង្គមក្នុងធម្មជាតិ។ លើសពីនេះទៀត សិស្សអាចទាញយកផលប្រយោជន៍ពីការសិក្សាមុខវិជ្ជាមួយទៅជួយបំពេញមុខវិជ្ជាមួយទៀត។

### ២.៦- តែងសេចក្តីផ្តល់ប្រយោជន៍ក្នុងការរស់នៅ

ការសិក្សាតែងសេចក្តីមិនមែនមានផលប្រយោជន៍តែនៅក្នុងសាលាប៉ុណ្ណោះទេ តែក៏បានផ្តល់ដល់មនុស្សក្នុងជីវភាពប្រចាំថ្ងៃផងដែរ។ គេអាចយកទៅប្រើប្រាស់ក្នុងកិច្ចប្រជុំពិភាក្សា សន្និសីទ សន្និបាត ការឃោសនា សុន្ទរកថា សំបុត្រឆ្លើយឆ្លង ផ្សព្វផ្សាយជូនដំណឹងឬលិខិតរដ្ឋបាលផ្សេងៗជាដើម។ មិនតែប៉ុណ្ណោះ តែងសេចក្តីមានប្រយោជន៍បំផុតក្នុងជីវភាពរស់នៅ ជាពិសេសគឺចេះដោះស្រាយបញ្ហាឬទំនាស់ប្រកបដោយវិចារណញ្ញាណ។

## ៣- ការត្រៀម និងការរៀបចំដំណើរការសរសេរតែងសេចក្តី

ដើម្បីសរសេរតែងសេចក្តីឱ្យបានល្អ ជាទីចាប់ចិត្ត ចាប់អារម្មណ៍របស់អ្នកអានឬអ្នកស្តាប់ អ្នកសរសេរតែងសេចក្តីត្រូវប្រកាន់ជំហារ និងធ្វើការចាំបាច់មួយចំនួនដូចខាងក្រោម៖

### ៣.១- ជំហារសតិអារម្មណ៍ និងចិត្តគំនិតពេលធ្វើតែងសេចក្តី

សតិអារម្មណ៍និងចិត្តគំនិតពេលធ្វើតែងសេចក្តីមានសារៈសំខាន់ណាស់ ដើម្បីសរសេរតែងសេចក្តីបានល្អអ្នកធ្វើតែងសេចក្តីត្រូវមានជំហារម៉ឺងម៉ាត់ មិនតក់ស្លុតញញើញញ័រ មិនបាត់ស្មារតី មិនប្រញាប់ប្រញាល់ពេកដើម្បីចៀសវាងការបាត់បង់ភាពម្ចាស់ការនិងការភ្លេចភ្លាំង។ អ្នកធ្វើតែងសេចក្តីត្រូវដកដង្ហើមឱ្យស្រួល មួយៗ ផ្ចង់គំនិតបាញ់ផ្តោះទៅលើការធ្វើតែងសេចក្តី។ ពោលគឺយើងត្រូវពង្រឹងស្មារតី តាំងអារម្មណ៍ឱ្យស្ងប់ គ្រប់គ្រងអារម្មណ៍ឱ្យបានល្អចៀសវាងការបែកអារម្មណ៍ដោយផ្តោតអារម្មណ៍ខ្លាំងលើប្រធានតែងសេចក្តី។ បន្ទាប់ពីរៀបចំខ្លួនបានស្រួលហើយ យើងនឹងចាប់ធ្វើតែងសេចក្តីបានល្អត្រឹមត្រូវមិនខាន។ ក្នុងជំហារដំបូងនេះ អ្នកធ្វើតែងសេចក្តីត្រូវកត់ត្រាប្រធាននៅលើក្រដាសស្អាតដោយសរសេរច្បាស់ៗ ហើយគោរពការដកឃ្លាឬខណ្ឌសញ្ញាទៅតាមប្រធានដែលគ្រូឬសាស្ត្រាចារ្យបានកត់ឱ្យនៅលើក្តារខៀន ហើយត្រូវចៀសវាងការបន្ថែមឬបន្ថយពាក្យសម្តីរបស់ខ្លួនទៅលើប្រធានដែលគេបានកត់ឱ្យរួចហើយ។ ការធ្វើដូច្នេះមានសារៈសំខាន់ដល់ជំហានក្រោយទៀត ដែលវានឹងអាចធ្វើឱ្យមានការខុសឆ្គង ឬភាន់ច្រឡំដល់អ្នកធ្វើតែងសេចក្តីក្នុងករណីមិនយកចិត្តទុកដាក់បញ្ហានេះ។

## ៣.២- ការសិក្សាប្រធាន

### ក- តើត្រូវសិក្សាប្រធានដូចម្ដេច?

ការសរសេរតែងសេចក្ដីអ្នកសរសេរតែងសេចក្ដីមិនមែនគ្រាន់តែឃើញប្រធានតែងសេចក្ដីភ្លាមចាប់សរសេរភ្លាមនោះទេ។ មានសិស្ស និស្សិត និងបេក្ខជនក្នុងការប្រឡងខ្លះបានស្រងាកចិត្ត និងសោកស្ដាយយ៉ាងខ្លាំង ក្រោយពេលខ្លួនសរសេរតែងសេចក្ដីចប់។ ការស្រងាកចិត្តនិងសោកស្ដាយនេះបណ្ដាលមកពីតែងសេចក្ដីរបស់ខ្លួនដែលបានសរសេរហើយនោះ មានន័យឃ្លាតឆ្ងាយពីប្រធានឬបានចាកប្រធានតែម្ដង នាំឱ្យទទួលបានពិន្ទុមិនល្អ។ កំហុសនេះដើមបំផុតគឺ អ្នកធ្វើតែងសេចក្ដីពុំបានសិក្សាប្រធាននិងពុំយល់ប្រធានច្បាស់លាស់។

មុននឹងចាប់ផ្ដើមសរសេរ អ្នកសរសេរតែងសេចក្ដីត្រូវសិក្សាប្រធានជាមុនសិន គឺត្រូវអានប្រធានឱ្យបានច្រើនដង អានហើយអានទៀត គូសពីក្រោមពាក្យសំខាន់ៗពិបាកយល់ និងពាក្យគន្លឹះរបស់ប្រធាន។ ត្រូវចោទសួរក្នុងចិត្តខ្លួនឯងថា តើប្រធាននេះគេចង់និយាយពីអ្វី? គេចង់សួរពីអ្វី? ប្រធានតែងសេចក្ដីនេះជាតែងសេចក្ដីប្រភេទអ្វី? តើពាក្យ ឬឃ្លាត្រង់ណាដែលសម្គាល់ប្រធានប្រភេទនោះ? ការស្គាល់ប្រធានបានច្បាស់ អាចឱ្យអ្នកសរសេរតែងសេចក្ដី ធ្វើគម្រោងតែងបានត្រឹមត្រូវ ហើយគំនិតដែលត្រូវលើកយកមកបរិយាយក៏សម្បូរបែបនិងសមស្រប ឆ្លើយតបនឹងចំណោទបញ្ហារបស់ប្រធាន។

### ខ- ការសិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធានតែងសេចក្ដី

ប្រធានតែងសេចក្ដីមានច្រើនប្រភេទ ហើយប្រភេទនីមួយៗមានលក្ខណៈដូចគ្នាផង ស្រដៀងគ្នាផង និងមានលក្ខណៈពិសេសដោយឡែកពីគ្នាផង។ តែទោះជាយ៉ាងណា ការសិក្សាប្រធានត្រូវផ្ដោតលើលក្ខណៈសម្គាល់សំខាន់ៗដូចខាងក្រោម៖

- សិក្សាបម្រាប់ប្រធាន
- សិក្សាឃ្លាសំណួរ
- សិក្សាពាក្យបង្គាប់បញ្ហា។

## ៣.៣- ការធ្វើគម្រោងប្លង់តែង

ការធ្វើគម្រោងប្លង់តែង ជាការមួយចាំបាច់របស់អ្នកធ្វើតែងសេចក្ដីមុនពេលសរសេរ។ គម្រោងប្លង់តែងមិនខុសពីគម្រោងប្លង់ផ្ទះ ដែលបានគូសវាសទុកជាមុន មុនពេលសង់ផ្ទះនោះឡើយ។ បើយើងត្រូវការផ្ទះមួយ តែយើងពុំមានគម្រោងប្លង់សោះ នោះផ្ទះរបស់យើងពុំអាចសង់បានឡើយ ទោះបីសង់បានក៏សំណង់នោះមិនសូវបានល្អដែរ វានឹងធ្វើឱ្យយើងមិនពេញចិត្តក្រោយពេលសង់រួច ឬធ្វើឱ្យយើងខាតបង់ពេលវេលា និងទ្រព្យសម្បត្តិ ប្រាក់កាសយ៉ាងច្រើនទៀតផង។ ក្នុងការធ្វើតែងសេចក្ដីក៏ដូច្នោះដែរ បើយើងពុំបានធ្វើគម្រោងតែង នោះការសរសេរតែងសេចក្ដីរបស់យើងច្បាស់ជាពុំបានល្អហើយយើងច្បាស់ជានឹងស្ដាយក្រោយយ៉ាងខ្លាំង ក្រោយពេលសរសេររួច។ ដូច្នេះការធ្វើគម្រោងប្លង់តែងសេចក្ដី ជាការចាំបាច់ខានមិនបានចំពោះអ្នកសរសេរតែងសេចក្ដី។

តើអ្នកសរសេរតែងសេចក្ដីត្រូវធ្វើគម្រោងតែងដូចម្ដេច?

ក្រោយពីបានសិក្សាប្រធានតែងសេចក្ដីរួចមក អ្នកធ្វើតែងសេចក្ដីបានយល់ប្រធានរួចហើយ គឺបានយល់ទស្សនៈ ឬបញ្ហាដែលបានលើកឡើងរួច ហើយអ្នកធ្វើតែងសេចក្ដីក៏បានយល់ច្បាស់ថា ប្រធានតែងសេចក្ដីនេះជាប្រភេទតែងសេចក្ដីមួយណារួចហើយដែរ។ ដូច្នេះក្នុងការចាប់ផ្ដើមធ្វើគម្រោងបតែងគប្បីនឹក

ទៅដល់គម្រោងតែងនៃប្រភេទតែងសេចក្តីនីមួយៗ ដែលបានសិក្សារួចហើយ។ តាមធម្មតាតែងសេចក្តីទោះបីប្រភេទណាក៏ដោយសុទ្ធតែចែកចេញជាបីផ្នែកសំខាន់ៗគឺ៖

- សេចក្តីផ្តើម
- តួសេចក្តី
- សេចក្តីបញ្ចប់។

នៅតាមផ្នែកទាំងបីខាងលើនេះ អ្នកធ្វើតែងសេចក្តីត្រូវចុះនូវចំណុចសំខាន់ៗ និងគំនិតសំខាន់ៗ ដែលត្រូវនិយាយទៅតាមផ្នែកនីមួយៗ តែត្រូវរៀបចំលំដាប់លំដោយឱ្យបានសមស្រប តើគំនិតណាគួរដាក់មុន ហើយគំនិតណាគួរដាក់ក្រោយ។ ពេលធ្វើគម្រោងនៅក្នុងការបកស្រាយចំណុចនីមួយៗ អ្នកធ្វើតែងសេចក្តីគួរសរសេរអំណះអំណាង ឬភស្តុតាង ឬឧទាហរណ៍ផ្សេងៗ ដែលអាចបញ្ជាក់សង្កត់បន្ថែមទៅលើគំនិត ដែលយើងត្រូវសរសេរនៅតាមចំណុចនីមួយៗនោះ។ ការធ្វើយ៉ាងនេះ ដើម្បីកុំឱ្យអ្នកធ្វើតែងសេចក្តីភ្លេចភ្លាំងក្នុងពេលសរសេរសម្រេច។ ក្នុងគម្រោងប្លង់តែង អ្នកសរសេរតែងសេចក្តីពុំគួរសរសេរលម្អិតទាំងស្រុងឬទាំងមូលរហូតដល់ចប់ រួចកត់ចម្លងជាសម្រេចនោះទេ ព្រោះការធ្វើបែបនេះវានាំឱ្យខាតពេលវេលា ហើយគំនិតគិតឃើញរបស់អ្នកធ្វើតែងសេចក្តីក៏ពុំអាចទូលំទូលាយនិងគ្រប់ជ្រុងជ្រោយបានឡើយ។ ករណីខ្លះក្នុងពេលប្រឡង មានសិស្សឬបេក្ខជនមួយចំនួនធ្វើគម្រោងប្លង់តែងយ៉ាងគ្រើសគ្រវាស រួចចាប់សរសេរលើក្រដាសព្រាងរហូតដល់ចប់ ហើយចុងក្រោយទើបចាប់ចម្លងឡើងវិញចូលសន្លឹកកិច្ចការបេក្ខជន។ ការធ្វើបែបនេះនាំឱ្យខាតពេលវេលា ហើយភាគច្រើនគឺសរសេរមិនទាន់ពេលតែម្តង។

សរុបសេចក្តីមក គម្រោងប្លង់តែងសេចក្តីមិនមែនជាការរ៉ាយរ៉ាប់នូវឃ្លា ល្បះទាំងអស់នោះទេ តែវាជាគម្រោងប្លង់តែងមានលក្ខណៈជាគ្រោងឆ្អឹងដែលមានតែគំនិតសំខាន់ៗ ដែលនឹងត្រូវនិយាយទៅតាមចំណុចនីមួយៗប៉ុណ្ណោះ។

### ក- សេចក្តីផ្តើម

សេចក្តីផ្តើម គឺជាពាក្យសម្តីដែលអ្នកធ្វើតែងសេចក្តីចាប់ផ្តើមនិយាយដើម្បីប្រាប់អ្នកអាន អ្នកស្តាប់ ឬអ្នកកែដឹងថា ខ្លួនចង់និយាយពីអ្វី? អាចនិយាយម្យ៉ាងទៀតថា សេចក្តីផ្តើមគឺជាពាក្យនាំផ្លូវពាក្យអន្ទងអ្នកអានឱ្យតាមដាន ឬទៅជួបអ្វីដែលគេចង់លើកឡើង។ ដូច្នេះសេចក្តីផ្តើមមានសារៈសំខាន់សម្រាប់អ្នកធ្វើតែងសេចក្តី។ តាមធម្មតាអ្នកដែលពូកែសរសេរតែងសេចក្តីគឺអ្នកដែលពូកែសរសេរសេចក្តីផ្តើមនេះឯង។ សេចក្តីផ្តើមនៃការធ្វើតែងសេចក្តីមានច្រើនបែបច្រើនយ៉ាង អាស្រ័យទៅតាមអ្នកសរសេរតែងសេចក្តី ប្រធានតែងសេចក្តីនិងប្រភេទតែងសេចក្តី។ គេពុំមានសេចក្តីផ្តើមគំរូមួយសម្រាប់គ្រប់ប្រធានតែងសេចក្តី និងគ្រប់ប្រភេទតែងសេចក្តីនោះទេ។ ដូច្នេះក្នុងការធ្វើសេចក្តីផ្តើម អ្នកសរសេរតែងសេចក្តីមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការផ្តល់គំនិតនិងបរិយាយ។ ការនិយាយយ៉ាងនេះពុំមែនមានន័យថា អ្នកសរសេរតែងសេចក្តីអាចធ្វើតាមទំនើងចិត្តនោះទេ តែការសំខាន់គឺអ្នកធ្វើតែងសេចក្តីត្រូវចេះសរសេរយ៉ាងណាឱ្យទាក់ទងទៅនឹងប្រធានដើម្បីឱ្យអ្នកអាន អ្នកស្តាប់ឬអ្នកកែចាប់អារម្មណ៍ ចង់ដឹង ចង់តាមដានទៅលើការបកស្រាយខាងក្រោយទៀត។ អ្នកធ្វើតែងសេចក្តីមិនត្រូវបកស្រាយប្រធាននៅក្នុងសេចក្តីផ្តើមនោះទេ។

ក្នុងការធ្វើសេចក្តីផ្តើមមានរបៀបច្រើនយ៉ាងណាស់ តែធ្វើយ៉ាងណាកុំឱ្យចាកប្រធាន។ ជាការងាយស្រួល គេអាចនិយាយពីប្រធាននិងចោទប្រធានឡើងវិញ ធ្វើជាសេចក្តីផ្តើមក៏បានដែរ។ ការធ្វើយ៉ាងនេះមិនងាយនឹងចាកប្រធានទេ តែធ្វើរបៀបនេះអ្នកអានឬអ្នកកែគេហាក់ដូចជាយល់ថា អ្នកធ្វើតែងសេចក្តីពុំសូវមានគំនិតទូលំទូលាយ។ ក្នុងការធ្វើសេចក្តីផ្តើម អ្នកសរសេរតែងសេចក្តីគួរចៀសវាង៖

- ចៀសវាងផ្តើមសេចក្តីចេញក្រៅប្រធានឬមិនមានទាក់ទងនឹងប្រធាន ទោះបីមតិ គំនិត ដែលអ្នកធ្វើតែងសេចក្តីបានផ្តើមឡើងខ្ពង់ខ្ពស់ សមហេតុផលយ៉ាងណាក៏ដោយ ហើយមិនត្រូវលើកយកបញ្ហាក្រៅប្រធានមកចោទឡើយ។
- មិនគួរគប្បីលើកមតិគំនិតឥតខ្លឹមសារ ឬឥតប្រយោជន៍ដាក់ក្នុងសេចក្តីផ្តើម។
- ចៀសវាងនិយាយដោយប្រើពាក្យបាលី សំស្ក្រឹតជ្រៅៗពេក ប្រសិនបើពាក្យនោះពុំមានតម្លៃចាំបាច់ទេ។
- គប្បីកុំផ្តើមសេចក្តីដូចក្នុងរឿងប្រលោមលោក លន្លង់លន្លោចឥតប្រយោជន៍។
- ចៀសវាងការបកស្រាយបញ្ហានៅក្នុងសេចក្តីផ្តើម។ គប្បីគួរកុំលើកយកឃ្លា ប្រយោគដែលត្រូវប្រើនៅក្នុងតួសេចក្តី មកនិយាយនៅក្នុងសេចក្តីផ្តើម ដើម្បីចៀសវាងការស្ទួនពាក្យឥតប្រយោជន៍។
- ចៀសវាងការសរសេរវែងពេក ឬខ្លីពេកនៅក្នុងសេចក្តីផ្តើម។ សេចក្តីផ្តើម តោងមានកម្រិតវែងឬខ្លីអាស្រ័យទៅតាមទំហំឬប្រវែងនៃសេចក្តីអធិប្បាយនៅក្នុងតួសេចក្តី។ តាមធម្មតា សេចក្តីផ្តើម និងតួសេចក្តី ត្រូវស្របគ្នា។ បើសេចក្តីផ្តើមខ្លីពេកនោះគឺពុំសមស្រប ហើយបញ្ជាក់ថាអ្នកសរសេរតែងសេចក្តីគ្មានគំនិត គ្មានពុទ្ធិតែម្តង។ ផ្ទុយទៅវិញ បើសេចក្តីផ្តើមវែងពេកក៏ពុំមានសារៈសំខាន់ប៉ុន្មានដែរ ព្រោះវានាំឱ្យខាតពេលវេលា។

ជាទូទៅនៅក្នុងសេចក្តីផ្តើមនៃប្រភេទតែងសេចក្តីមានធាតុបីសំខាន់ៗគឺលំនាំបញ្ហាចំណូលបញ្ហា និងចំណោទបញ្ហា។

- **លំនាំបញ្ហា:** លំនាំបញ្ហាគឺជាការនិយាយទូទៅទាក់ទងទៅនឹងខ្លឹមសាររបស់ប្រធាន។ ការនិយាយនៅក្នុងលំនាំបញ្ហាមិនមែនជាការបកស្រាយប្រធាននោះទេ។ ពោលគឺនិយាយយ៉ាងណាដើម្បីទាក់ទាញអារម្មណ៍អ្នកអាន អ្នកកែឱ្យចូលមកបញ្ហារបស់ប្រធាន។
- **ចំណូលបញ្ហា:** ចំណូលបញ្ហាមិនមានអ្វីស្មុគស្មាញសម្រាប់អ្នកសរសេរតែងសេចក្តីនោះទេ គឺគ្រាន់តែលើកយកបញ្ហារបស់ប្រធានមកសរសេរជាការស្រេច។ ចំណូលបញ្ហាគេច្រើនប្រើឃ្លាភ្ជាប់សេចក្តីនិងសរសេរបញ្ហារបស់ប្រធាននៅក្នុងអព្ភន្តរសញ្ញា។ គេច្រើនសរសេរថា ហេតុនេះហើយទើបមានទស្សនៈលើកឡើងថា«...»។
- **ចំណោទបញ្ហា:** ដើម្បីភ្ជាប់សេចក្តីផ្តើមទៅនឹងផ្នែកខាងក្រោយទៀតឱ្យទាក់ទងនិងស៊ីសង្វាក់គ្នា អ្នកធ្វើតែងសេចក្តីត្រូវបញ្ចប់សេចក្តីផ្តើមដោយល្បះមួយទៀត គឺល្បះចោទប្រធានជាបញ្ហាឬយើងហៅថា ចំណោទបញ្ហា។ អ្នកអានឬអ្នកកែ កាលណាគេបានឃើញល្បះនេះ គេនឹងចង់តាមដានចង់ដឹងពីអ្វីៗ ដែលយើងនឹងបរិយាយនៅក្នុងតួសេចក្តីទៀត។ ចំណោទបញ្ហា គឺជាការចោទជាសំណួរទៅលើបញ្ហារបស់ប្រធាន។ ការចោទសួរទៅលើបញ្ហារបស់ប្រធាននេះមានសារៈសំខាន់ណាស់បើអ្នកធ្វើតែងសេចក្តីចោទសួរមិនបានត្រឹមត្រូវទេនោះ នាំឱ្យការសរសេរបកស្រាយក៏មិនបានត្រឹមត្រូវដែរ និងអាចសរសេរបកស្រាយទៅចាកប្រធានតែម្តង។ ខ្លឹមសារចំណោទបញ្ហា គឺមានលក្ខណៈខុសៗគ្នាអាស្រ័យទៅតាមប្រភេទប្រធាន។ ដូច្នេះមុនពេលចោទសួរ អ្នកធ្វើតែងសេចក្តីគប្បីពិនិត្យប្រធានឱ្យបានច្បាស់លាស់ដើម្បីចៀសវាងចោទសំណួរខុស។ គេច្រើនចោទសួរទៅលើបញ្ហាប្រធានដូចខាងក្រោមៈ

- **ប្រធានបែបអត្ថាធិប្បាយពន្យល់៖**
  - តើប្រធាន...មានអត្ថន័យដូចម្តេច?

- តើទស្សនៈដែលបានលើក...មានអត្ថន័យយ៉ាងណា?
- តើពំនោល...មានខ្លឹមសារដូចម្តេច?
- តើតួអង្គនេះមាន...ដូចម្តេច?

❖ **ប្រធានអត្ថាធិប្បាយប្រៀបធៀបៈ**

- តើតួអង្គ...មានលក្ខណៈដូចគ្នា និងខុសគ្នាដូចម្តេច?
- តើទស្សនៈ...ប្រសើរជាង?
- តើតួអង្គ...ប្រសើរជាង។

❖ **ប្រធានបែបអត្ថាធិប្បាយពិភាក្សាៈ**

- តើ...ខាងលើនេះ ត្រឹមត្រូវដែរឬទេ?
- តើ...ទាំងពីរខាងលើមួយណាត្រឹមត្រូវជាង?
- តើ...ត្រូវ ឬខុស?
- តើ...ត្រឹមត្រូវដែរឬទេ?
- តើ...មួយណាត្រឹមត្រូវជាង?
- តើ...មួយណាសមហេតុផលជាង?

**ចំណុចគួរចៀសវាង** : ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្តីចៀសវាងការចោទសួរច្រាសមកវិញនាំឱ្យចាកប្រធាន ឬប្រើពាក្យបង្គាប់បញ្ជាឡើយ។

***ឧទាហរណ៍ៈ***

- តើអ្នកយល់យ៉ាងណា? ចូរស្រាយបំភ្លឺ ដោយលើកឧទាហរណ៍បញ្ជាក់។
- តើអ្នកយល់ដូចម្តេច? ចូរបកស្រាយ។
- តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរពន្យល់។ល។

**ខ- តួសេចក្តី**

តួសេចក្តី អាចហៅម្យ៉ាងទៀតថាសេចក្តីបរិយាយ ដែលប្រៀបបាននឹងខ្លួនរបស់តែងសេចក្តី។ តួសេចក្តី មានលក្ខណៈសំខាន់ណាស់សម្រាប់ការធ្វើតែងសេចក្តី។ តែងសេចក្តីល្អឬមិនល្អ ដោះស្រាយបញ្ហាប្រធានបានឬមិនបាន យល់ប្រធានឬមិនយល់ប្រធាន គឺនៅត្រង់តួសេចក្តីនេះឯង។ ដូច្នេះក្នុងការសរសេរតួសេចក្តីពុំមែនចេះតែសរសេរដោយគ្មានរបៀបឬឥតបច្ចេកទេសនោះទេ។ អ្នកសរសេរតែងសេចក្តីត្រូវមានរបៀបបច្ចេកទេសគួបផ្សំជាមួយនឹងពុទ្ធិទូទៅរបស់ខ្លួន ទាំងពុទ្ធិភាសា អក្សរសាស្ត្រ អក្សរសិល្ប៍ និងទិដ្ឋភាពសង្គមទូទៅថែមទៀត ដើម្បីធ្វើឱ្យការបរិយាយរបស់ខ្លួនក្នុងតួសេចក្តីបានល្អប្រសើរ។

វត្ថុបំណងរបស់អ្នកធ្វើតែងសេចក្តីគឺចង់បាននូវការរៀបរាប់ ការពន្យល់ ការបកស្រាយមួយសមស្របទៅតាមចំណោទរបស់ប្រធានដែលបានលើកឡើង។ ដើម្បីសម្រេចវត្ថុបំណងនេះ អ្នកធ្វើតែងសេចក្តីគួរយល់ដឹងពីចំណុចសំខាន់ៗមួយចំនួនដែលជាគ្រោងឆ្អឹងនៃតួសេចក្តីដូចខាងក្រោមៈ

- **ឃ្លាភ្ជាប់សេចក្តីៈ** អ្នកធ្វើតែងសេចក្តីដែលចេះសរសេរសេចក្តីផ្តើមបានល្អត្រឹមត្រូវពុំទាន់គ្រប់គ្រាន់ទេ តែត្រូវចេះសរសេរឃ្លាភ្ជាប់សេចក្តីថែមទៀត។ ឃ្លាភ្ជាប់សេចក្តី គឺជាឃ្លាសម្រាប់ភ្ជាប់ន័យសេចក្តីពីគំនិត មតិ ទស្សនៈពីវគ្គមួយទៅមួយ ឬពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត ដើម្បីធ្វើឱ្យអត្ថបទមួយមានតម្លៃទាំងអត្ថរូបនិងអត្ថន័យ។ ឃ្លាភ្ជាប់សេចក្តីចែកចេញជាច្រើនផ្នែកគឺ ឃ្លា

ភ្ជាប់សេចក្តីសម្រាប់ភ្ជាប់ពីសេចក្តីផ្តើមទៅតួសេចក្តី ឃ្លាភ្ជាប់សេចក្តីសម្រាប់ភ្ជាប់ពីពន្យល់ន័យប្រធានទៅការបកស្រាយប្រធាននិងឃ្លាភ្ជាប់សេចក្តីភ្ជាប់ពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត ឬការបកស្រាយគំនិតមួយឬការបកស្រាយគំនិតមួយទៀត នៅក្នុងចំណុចការបកស្រាយប្រធាន ដើម្បីធ្វើឱ្យអត្ថបទមួយមានតម្លៃទាំងអត្ថរូបនិងអត្ថន័យ។ ឃ្លាភ្ជាប់សេចក្តីសំខាន់ៗ ដែលគេច្រើនប្រើនៅដើមឃ្លាមានដូចជា៖

- ឃ្លាភ្ជាប់សេចក្តីសម្រាប់ភ្ជាប់ពីសេចក្តីផ្តើមទៅតួសេចក្តី៖
  - ដើម្បីបកស្រាយប្រធាន... យើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
  - ដើម្បីយល់អត្ថន័យរបស់ប្រធាន... យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
  - មុននឹងបកស្រាយប្រធាន... យើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន ។ល។

- ឃ្លាភ្ជាប់សេចក្តីសម្រាប់ភ្ជាប់ពីពន្យល់ន័យប្រធានទៅការបកស្រាយប្រធាន៖
  - ឆ្លងតាមអត្ថន័យនៃប្រធាន... យើងយល់ថា...។
  - ជាការពិតណាស់ ឆ្លងតាមអត្ថន័យនៃប្រធានខាងលើ... យើងឃើញថា... ។
  - តាមរយៈន័យនៃប្រធាន... យើងអាចបកស្រាយ...។ល។

- ឃ្លាភ្ជាប់សេចក្តីសម្រាប់ភ្ជាប់ពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀតនៅក្នុងចំណុចការបកស្រាយប្រធាន៖
  - រួចមកហើយយើងបានអត្ថាធិប្បាយពី... តទៅនេះយើងនឹងលើកយក...មកបកស្រាយ.... ។
  - យើងទើបនឹងនិយាយអំពី... ឥឡូវយើងនិយាយពី... ។
  - កន្លងមកយើងបានឃើញ... ពេលនេះយើងនឹងលើកយក... មកបង្ហាញបញ្ជាក់... ។ល។
  - ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត យើងនឹងលើកយក... មកបញ្ជាក់បន្ថែម។

ឃ្លាភ្ជាប់សេចក្តីត្រឹមត្រូវ លុះត្រាតែយើងខិតខំរៀបចំពាក្យពេចន៍ ឃ្លា ល្បះឱ្យមានន័យ មានខ្លឹមសារ បង្ហាញទំនាក់ទំនងរវាងគំនិតមួយនិងគំនិតមួយទៀត ឬកថាខណ្ឌមួយនិងកថាខណ្ឌមួយទៀត ដើម្បីកុំឱ្យអ្នកអានភ្ញាក់ផ្អើលដោយពុំបានដឹងខ្លួនជាមុនឬពុំយល់ថា ពីព្រោះអ្វីបានជាយើងលើកយកគំនិតថ្មីទៀតមកអត្ថាធិប្បាយ។

ក្នុងភាសាខ្មែរយើងក៏ដូចជាភាសាដទៃទៀតដែរ ឃ្លា ល្បះនៅក្នុងកថាខណ្ឌឬការបកស្រាយគំនិតនីមួយៗ ត្រូវស៊ីសង្វាក់គ្នាផ្ទៃក្នុងថែមទៀត ដោយប្រើពាក្យភ្ជាប់សេចក្តីដូចជា មាន តែ ប៉ុន្តែ យ៉ាងណាមិញ ម្យ៉ាងទៀត ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើ ប្រសិនជា គួរគប្បី ល្អីកណា ជាទូទៅ យ៉ាងហោចណាស់ ជាធម្មតា អាស្រ័យហេតុនេះ ដូច្នេះ យ៉ាងដូច្នេះ មួយវិញទៀត។ល។

- **ពាក្យគន្លឹះរបស់ប្រធាន:** បើមានពាក្យពិបាកជាបាលីឬសំស្ក្រឹត ដែលជាពាក្យគន្លឹះរបស់ប្រធាន អ្នកសរសេរតែងសេចក្តីគប្បីពន្យល់ពាក្យនោះជាមុនសិន តែគួរលើកយកពាក្យមួយ ពីរឬបីបានហើយ ចៀសវាងការលើកយកពាក្យច្រើនមកពន្យល់។ ការពន្យល់ពាក្យពិបាកនេះ មានសំណូមពរចង់ឱ្យអ្នកអានបានយល់មួយកម្រិតពីគំនិតរបស់ប្រធានជាមួយអ្នកធ្វើតែងសេចក្តី។ ចំពោះអ្នកកែតែងសេចក្តីវិញ ពេលគេឃើញអ្នកធ្វើតែងសេចក្តីពន្យល់ពាក្យបានច្បាស់លាស់ គេអាចយល់បានថា មានពុទ្ធិនិងយល់ប្រធានបាន។

តែសូមបញ្ជាក់ថា ការពន្យល់ពាក្យនៅក្នុងជំហានទីមួយនៃតែងសេចក្ដីនេះ មិនមែនជាការមួយត្រូវធ្វើគ្រប់តែតែងសេចក្ដីនោះទេ គឺចាំបាច់ ឬមិនចាំបាច់អាស្រ័យលើប្រធានដែលមានពាក្យពិបាកឬមិនមានឬអាស្រ័យទៅលើភាពជាក់ស្ដែងនៃការធ្វើតែងសេចក្ដី។ យើងសង្កេតឃើញអ្នកធ្វើតែងសេចក្ដីមួយចំនួនបានខិតខំពន្យល់ពាក្យនៅគ្រប់តែងសេចក្ដី ទោះបីជាប្រធានតែងសេចក្ដីនោះពុំមានពាក្យពិបាកក៏ដោយ។ ការធ្វើបែបនេះនាំឱ្យអស់តម្លៃនៃការធ្វើតែងសេចក្ដីទៅវិញទេ ហើយគេអាចវាយតម្លៃថាអ្នកធ្វើតែងសេចក្ដី មានគំនិតគម្ពីរនិយម គំនិតទាប គិតតាំងពីគំនិតកំប៉ិកកំប៉ុកឡើងទៅ ហើយអ្នកអានឬអ្នកកែពុំចង់ដឹងផង ពីព្រោះពាក្យពន្យល់ទាំងអស់នោះជាពាក្យងាយគេបានយល់គ្រប់គ្នាហើយ។ យើងសង្កេតឃើញអ្នកធ្វើតែងសេចក្ដីមួយចំនួនទៀតបានខិតខំពន្យល់ពាក្យស្អេកស្កះចេញពីពាក្យមួយទៅពាក្យមួយទៀត គឺធ្វើយ៉ាងណាឱ្យតែបានវែង។ ការធ្វើបែបនេះពុំសមរម្យដែរ វាបានក្លាយទៅជាការធ្វើតែងសេចក្ដីអំពីការពន្យល់ពាក្យទៅវិញ។

- **ការពន្យល់ន័យប្រធាន:** ការពន្យល់ន័យប្រធាន គឺជាការបង្ហាញអត្ថន័យរួមរបស់ប្រធាន ដោយផ្អែកលើការពន្យល់ពាក្យគន្លឹះ។ ដូច្នេះអ្នកធ្វើតែងសេចក្ដី ត្រូវចេះសំយោគអត្ថន័យនៃខ្លឹមសារពន្យល់ពាក្យគន្លឹះរបស់ប្រធាន។ ការពន្យល់ន័យប្រធាន មិនទាមទារឱ្យធ្វើការបកស្រាយអត្ថន័យលម្អិតនោះទេពោលគឺនិយាយសរុបខ្លឹមសារពន្យល់ពាក្យគន្លឹះឱ្យស្របតាមខ្លឹមសារប្រធាន។
- **ការបកស្រាយប្រធាន៖**
  - ✓ **ការបកស្រាយ:** ក្រោយពីបានពន្យល់ន័យប្រធានរួចហើយ អ្នកធ្វើតែងសេចក្ដីត្រូវបកស្រាយពន្យល់ ឬដោះស្រាយបញ្ហាទៅតាមចំណុចនីមួយៗរហូតដល់ចប់។ នៅចំណុចនេះមានសារៈសំខាន់អាចចាត់ទុកជាខ្លឹមក៏បានដែរ។ អ្នកធ្វើតែងសេចក្ដីត្រូវមានឧទាហរណ៍ អំណះអំណាងភស្តុតាង ឱ្យបានច្បាស់ដើម្បីបញ្ជាក់លើចំណុចនីមួយៗ។ ត្រូវចៀសវាងការនិយាយក្បែរៗប្រធាន ឬការនិយាយចាកប្រធាន។ ជានិច្ចកាលអ្នកធ្វើតែងសេចក្ដីត្រូវមានការប្រុងប្រយ័ត្ននិងក្ដាប់បញ្ហាប្រធានឱ្យបានច្បាស់លាស់ ដើម្បីចៀសវាងសរសេរចាកប្រធាន។ គំនិតណា ឬល្បះណាដែលល្អៀងឃ្លាតចេញពីប្រធាន ឬមិនច្បាស់លាស់ត្រូវដកចេញ។

    ការបរិយាយរបស់អ្នកធ្វើតែងសេចក្ដីត្រូវច្បាស់លាស់ដែលបញ្ជាក់នូវចំណេះដឹងទូលំទូលាយរបស់ខ្លួន។ ដូច្នេះមុនចាប់ផ្ដើមសរសេរឬក្នុងពេលសរសេរ អ្នកធ្វើតែងសេចក្ដីត្រូវប្រមែប្រមូលចំណេះដឹង គួបផ្សំនឹងការត្រិះរិះពិចារណារបស់ខ្លួនមកបរិយាយបញ្ជាក់។ ការផ្ដល់គំនិតច្បោលៗគ្មានមូលដ្ឋានច្បាស់លាស់គួរចៀសវាង។ ការបកស្រាយប្រធានត្រូវគោរពគម្រោងតែងសេចក្ដីដែលបានរៀបចំរួច។ ការធ្វើបែបនេះគឺដើម្បីឱ្យន័យសេចក្ដីនៃការបរិយាយរបស់យើងស៊ីសង្វាក់គ្នា មានលំដាប់លំដោយ មានរបៀបរៀបរយ និងចៀសវាងការនិយាយច្រំដែលៗ ឬភាពច្របូកច្របល់ និយាយសាចុះសាឡើង។

    យើងសង្កេតឃើញថាក្នុងការបកស្រាយនេះមានអ្នកធ្វើតែងសេចក្ដីជាច្រើនសរសេរដោយគ្មានគម្រោង ឬមានអ្នកខ្លះមានគម្រោងដែរ តែមិនគ្រប់គ្រាន់ ពុំទាន់រៀបន័យសេចក្ដីឱ្យស៊ីសង្វាក់គ្នាហើយចាប់សរសេររហូតពាក់កណ្ដាលទៅហើយទើបចាប់ធ្វើគម្រោងតែងក៏មានដែរ។ ទាំងនេះជាការខុសឆ្គងមួយគួរចៀសវាង អាចអនុញ្ញាតឱ្យសរសេរបានក្រោយពេលសរសេរគម្រោងលម្អិតរួចហើយ។

✓ **ការលើកឧទាហរណ៍ និងសេចក្ដីដកស្រង់មកបញ្ជាក់:** ក្នុងការធ្វើតែងសេចក្ដី គេត្រូវការគំនិតច្បាស់លាស់និងសុភវិនិច្ឆ័យដែលទាមទារឱ្យបញ្ជាក់អំណះអំណាងផ្សេងៗ។ បើគ្មានអំណះអំណាងបញ្ជាក់ទេ ការបរិយាយរបស់យើងស្ថិតក្នុងភាពពុំច្បាស់លាស់។ ដូច្នេះក្នុងការបញ្ជាក់លើគោលគំនិតឬយោបល់ណាមួយឱ្យច្បាស់លាស់ អ្នកធ្វើតែងសេចក្ដីត្រូវតែប្រមែប្រមូលលើកយកឧទាហរណ៍ឬសេចក្ដីដកស្រង់ណាមួយមកបញ្ជាក់បន្ថែមទៀត។

**ការលើកឧទាហរណ៍មកបញ្ជាក់:** បើអ្នកធ្វើតែងសេចក្ដីកំពុងសរសេរចំណុចណាមួយ គួររិះរកលើកឧទាហរណ៍ឱ្យបានប្លែកៗមកបញ្ជាក់បន្ថែមចំណុចនោះ។ ការធ្វើបែបនេះដើម្បីឱ្យអ្នកអានឬអ្នកកែកាន់តែពេញចិត្ត និងយល់ថាការបរិយាយរបស់យើងកាន់តែច្បាស់លាស់។ ការលើកឧទាហរណ៍ត្រូវមានមូលដ្ឋានដូចខាងក្រោមនេះ៖

- ឧទាហរណ៍ដែលត្រូវលើកយកមកបញ្ជាក់គប្បីមានលក្ខណៈប្លែកៗ តែត្រូវឱ្យស៊ីគ្នានឹងចំណុចត្រង់ណាមួយឬកថាខណ្ឌណាមួយដែលយើងកំពុងពន្យល់។ គួរចៀសវាងលើកឧទាហរណ៍ដែលពុំសូវមានន័យច្បាស់លាស់ ដែលនឹងអាចឱ្យការបរិយាយរបស់យើងក្លាយទៅជាមិនច្បាស់លាស់ជាមួយដែរ។
- ឧទាហរណ៍លើកយកមកត្រូវប្រើសម្រាប់តែបញ្ជាក់គំនិតសំខាន់ៗ។ ក្នុងកថាខណ្ឌមួយអាចលើកឧទាហរណ៍បានមួយឬពីរជាការគ្រប់គ្រាន់។ គួរចៀសវាងការលើកឧទាហរណ៍ស្អេកស្កះពេក ដែលអាចនាំឱ្យអស់តម្លៃនៃតែងសេចក្ដីរបស់យើង។
- ចៀសវាងការលើកយករឿងណាមួយទាំងមូលមកធ្វើជាឧទាហរណ៍។ បើចង់លើកយករឿងណាមួយមកធ្វើជាឧទាហរណ៍ គួរលើកយកគំនិតសំខាន់ៗនៃរឿង។ សកម្មភាពត្រង់ណាមួយរបស់តួអង្គណាមួយធ្វើជាឧទាហរណ៍ តែគួរចេះនិយាយឱ្យបានខ្លីបំផុត។ ជាការល្អគួរស្រង់យកមកធ្វើជាឧទាហរណ៍ តែរឿងណានៅក្នុងកម្មវិធីសិក្សាឬរឿងដទៃទៀតណា ដែលសាធារណជនធ្លាប់ស្គាល់គ្រប់ៗគ្នា។

**សេចក្ដីដកស្រង់:** សេចក្ដីដកស្រង់ គឺជាពន្លឺឬជាភស្តុតាងសម្រាប់បញ្ជាក់ឬពន្យល់បន្ថែមលើគោលគំនិតណាមួយឬកថាខណ្ឌណាមួយដែលជាការចាំបាច់។ សេចក្ដីដកស្រង់អាចជាសុភាសិត ឬជាពាក្យសម្ដីរបស់អ្នកប្រាជ្ញ កវីនិពន្ធ ទស្សនវិទូឬជាពាក្យសម្ដីរបស់តួអង្គក្នុងស្នាដៃអក្សរសិល្ប៍ណាមួយ។ បើប្រធានតែងសេចក្ដីជាប្រធានទូទៅគេច្រើនស្រង់សុភាសិតឬជាពាក្យសម្ដីរបស់អ្នកប្រាជ្ញ ទស្សនវិទូ សំខាន់ៗយកមកបញ្ជាក់។ ចំពោះប្រធានអក្សរសិល្ប៍គេតែងដកស្រង់សម្ដីរបស់អ្នកនិពន្ធឬសម្ដីរបស់តួអង្គមកបញ្ជាក់ជាភស្តុតាង។

« ... » សេចក្ដីដកស្រង់ដែលយើងលើកយកមកដាក់ក្នុងតែងសេចក្ដីគប្បីសរសេរដាក់ក្នុងអព្ភន្តរ តែពុំតម្រូវឱ្យកាត់បន្ថយពាក្យនិងបាត់ន័យសេចក្ដីរបស់គេឡើយ។ ពោលគឺអ្នកធ្វើតែងសេចក្ដី ត្រូវរក្សាសេចក្ដីដកស្រង់ទាំងស្រុងឱ្យនៅគង់វង្សដូចដើម។ ប៉ុន្តែបើយើងចាំពាក្យសម្ដីគេមិនច្បាស់ យើងអាចរក្សាទុកគំនិតដើមក៏បានដែរ។ ចំណែកឯពាក្យសម្ដីឃ្លា ល្បះ យើងអាចកែប្រែ កាត់បន្ថយតាមចំណូលចិត្តយើងបានខ្លះដែរ។ ក៏ប៉ុន្តែនៅក្នុងករណីបែបនេះ យើងមិនត្រូវសរសេរពាក្យស្រង់ដាក់ក្នុងអព្ភន្តរឡើយ ដើម្បីចៀសវាងកុំឱ្យអ្នកអានឬអ្នកកែយល់ច្រឡំនឹងពាក្យសម្ដីដើមពិតប្រាកដ។

អ្នកធ្វើតែងសេចក្តី ត្រូវចៀសវាងសេចក្តីដកស្រង់ណា ដែលយើងយល់គំនិតដើមរបស់គេពុំច្បាស់ ជាពិសេសសេចក្តីដកស្រង់ណាមិនទាក់ទងនិងមិនស៊ីគ្នាជាមួយសេចក្តីអត្ថាធិប្បាយរបស់យើង។ បើកាលណាយើងចេះតែស្រង់សេចក្តីដែលមិនស៊ីគ្នានឹងសេចក្តីអត្ថាធិប្បាយ វានឹងអាចឱ្យគំនិតរបស់យើងឃ្លាតចេញពីប្រធាន ហើយក៏អាចនឹងបញ្ជាក់ថា យើងយល់ប្រធានពុំច្បាស់លាស់ទៀតផង។ សេចក្តីដកស្រង់មានឃ្លាច្រើន ហើយមានឃ្លាខ្លះឥតប្រយោជន៍ យើងត្រូវកាត់វាចោលខ្លះ គឺយកតែចំណុចណាដែលសមស្រប ស៊ីសង្វាក់គ្នាជាមួយនិងសេចក្តីអត្ថាធិប្បាយបានហើយ។

ត្រូវចេះជ្រើសរើសយកមកប្រើចំពោះសេចក្តីដកស្រង់ណាដែលមានលក្ខណៈច្បាស់លាស់ ស្រួលយល់ ស្រួលអាន ខ្លីល្អ។ គួរចៀសវាងសេចក្តីដកស្រង់ណា ដែលមានពាក្យសម្តីច្រើន មានឃ្លាប្រយោគវែងៗ ពីព្រោះវានឹងអាចធ្វើឱ្យមតិ គំនិតផ្ទាល់របស់ខ្លួនដែលបានបរិយាយ ត្រូវកប់បាត់នៅក្នុងសេចក្តីដកស្រង់នោះឬត្រូវក្លាយទៅជាកម្រងអត្ថបទស្តីពីកម្រងអត្ថបទទៅវិញ។ ការធ្វើរបៀបនេះ អាចឱ្យការធ្វើតែងសេចក្តីអស់តម្លៃ។

ដូច្នេះបញ្ហាសំខាន់បំផុតគឺអ្នកធ្វើតែងសេចក្តីត្រូវចេះពិចារណាចំពោះការជ្រើសរើសសេចក្តីដកស្រង់សម្រាប់ប្រើ។ ពោលគឺសេចក្តីដកស្រង់ណា ពាក្យសម្តីដកស្រង់ណាដែលល្អសឹមប្រើ។ ចំពោះមតិវាយរងពុំចាំបាច់ស្រង់សេចក្តីយកមកបញ្ជាក់នៅក្នុងតែងសេចក្តីទេ។

- **ការសរុបសេចក្តី:** គឺជាការសរសេរឡើងវិញពីខ្លឹមសារនៃការបកស្រាយប្រធាន។ ក្នុងចំណុចនេះមិនទាមទារឱ្យអ្នកធ្វើតែងសេចក្តីបកស្រាយនិងលើកឧទាហរណ៍នោះទេ។ ពោលគឺគប្បីលើកយកតែគំនិតសំខាន់ៗដែលមាននៅក្នុងការបកស្រាយប្រធានមកធ្វើការប្រមូលសរុបប៉ុណ្ណោះ។ ក្នុងប្រធានតែងបែបអត្ថាធិប្បាយពិភាក្សា គេប្រើមតិរួមឬសំយោគឬពិភាក្សាដើម្បីសរុបមតិស្របនិងមតិផ្ទុយ និងអាចមានមតិបន្ថែមទៀតដើម្បីបំពេញបន្ថែមទៅលើមតិទាំងពីរ។

## គ- សេចក្តីបញ្ចប់

សេចក្តីបញ្ចប់គេអាចហៅបានច្រើនយ៉ាងគឺ  យោបល់បញ្ចប់ យោបល់រួម សេចក្តីបង្ហើយ និងសេចក្តីសន្និដ្ឋាន។ តែងសេចក្តីមួយអាចប្រៀបធៀបទៅនឹងខ្លួនមនុស្សមានបីផ្នែកគឺ ក្បាល ដងខ្លួន និងអវយវៈ។ សេចក្តីផ្តើមប្រៀបដូចជាក្បាល តួសេចក្តីប្រៀបដូចជាដងខ្លួន ហើយសេចក្តីបញ្ចប់ប្រៀបដូចជាអវយវៈ។ ផ្នែកទាំងបីរបស់មនុស្សយើងត្រូវសមស្របគ្នាពីផ្នែកមួយទៅផ្នែកមួយទៀត ទើបធ្វើឱ្យរូបរាងមនុស្សមានរូបសម្បត្តិល្អប្រសើរ។ តែងសេចក្តីក៏ដូច្នោះដែរ ផ្នែកទាំងបីរបស់វាត្រូវស៊ីសង្វាក់គ្នាតាំងពីដើមរហូតដល់ចប់ ពោលគឺតួសេចក្តីត្រូវស៊ីសង្វាក់គ្នាជាមួយសេចក្តីផ្តើមនិងសេចក្តីបញ្ចប់។ ដូច្នេះការសរសេរសេចក្តីបញ្ចប់នៃតែងសេចក្តីក៏ជាការមួយចាំបាច់មិនអាចអត់បានដែរ។ បើខ្វះផ្នែកនេះ មានន័យថាការធ្វើតែងសេចក្តីមិនបានចប់សព្វគ្រប់ឡើយ ហើយបើតែងសេចក្តីមិនទាន់ចប់ធ្វើឱ្យអ្នកអានពិបាកយល់ អ្នកកែក៏ពិបាកដាក់ពិន្ទុ។

ជាទូទៅសេចក្តីបញ្ចប់មានចំណុចសំខាន់ៗពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួនឬមតិផ្ទាល់ខ្លួនឬចំណាប់អារម្មណ៍ផ្ទាល់ខ្លួន។

- វាយតម្លៃប្រធាន គឺជាការសរសេរពីតម្លៃអប់រំរបស់ប្រធានតែងសេចក្តី។ ដូច្នេះចំណុចនេះអ្នកធ្វើតែងសេចក្តីមិនទាមទារឱ្យសរសេរបកស្រាយ ឬសរសេរវែងឆ្ងាយពេកនោះទេ។ ការវាយតម្លៃ

ប្រធាន គឺគប្បីសរសេរដោយឆ្លើយនឹងសំណួរថា តើប្រធាននេះមានតម្លៃអប់រំដូចម្ដេច? និងតើតម្លៃអប់រំនោះមានសារៈសំខាន់ដូចម្ដេច?

- យោបល់ផ្ទាល់ខ្លួន គឺជាគំនិតផ្ទាល់ខ្លួន ដែលអ្នកធ្វើតែងសេចក្ដី ត្រូវសរសេរពីចំណាប់អារម្មណ៍របស់ខ្លួនទៅលើប្រធាន និងសរសេរពីការប្ដេជ្ញាចិត្តរបស់ខ្លួនថានឹងធ្វើឱ្យខ្លួនឯងឬបញ្ហាទាំងនោះមានលក្ខណៈវិជ្ជមាន។

ការសរសេរសេចក្ដីបញ្ចប់ អ្នកធ្វើតែងសេចក្ដីគួរគោរពតាមគោលការណ៍មួយចំនួនដូចខាងក្រោម៖

- សេចក្ដីបញ្ចប់ ត្រូវទាក់ទងនឹងសេចក្ដីអត្ថាធិប្បាយតាំងពីដើមរហូតដល់ចុងបញ្ចប់ ពោលគឺតាំងពីសេចក្ដីផ្ដើមរហូតដល់សេចក្ដីបញ្ចប់ខ្លួនឯងនេះ។
- ជូនកាលជាមេរៀនទូទៅសម្រាប់អប់រំមនុស្ស ដែលទាញចេញពីការបរិយាយខាងលើ។
- សេចក្ដីបញ្ចប់ គឺជាយោបល់រួមបំផុតនៃសេចក្ដីបរិយាយខាងលើ ពុំមែនជាការអធិប្បាយឬការបកស្រាយបញ្ហាឡើងវិញឡើយ។
- នៅក្នុសេងចក្ដីបញ្ចប់ អ្នកធ្វើតែងសេចក្ដីគួរចៀសវាងបញ្ចប់សេចក្ដីដោយលើកបញ្ហាថ្មីមួយទៀតមកចោទជាបញ្ហាដែលអាចធ្វើឱ្យមានបញ្ហានៅសល់នោះឡើយ ពីព្រោះវានាំឱ្យខូចអស់នូវឯកភាពនៃការបរិយាយរបស់យើងដែលសរសេររួចហើយ។ ម្យ៉ាងទៀត បើអ្នកសរសេរតែងសេចក្ដីបានចោទបញ្ហាមួយទៀតវានឹងបញ្ជាក់ថាតែងសេចក្ដីរបស់យើងពុំទាន់ចប់ ហាក់ដូចជានៅមានតទៅទៀត។

## ៣.៤- ចំណុចមួយចំនួនដែលអ្នកសរសេរតែងសេចក្ដីគួរយកចិត្តទុកដាក់

ខាងលើនេះយើងបានបង្ហាញពីរបៀបសំខាន់ៗនៃការសរសេរតែងសេចក្ដីរួចហើយ។ ខាងក្រោមនេះយើងនឹងលើកយកចំណុចមួយចំនួនទៀតដែលអ្នកសរសេរតែងសេចក្ដីគួរយកចិត្តទុកដាក់។ ចំណុចទាំងអស់នេះពុំមែនជាបញ្ហាធំប៉ុន្មានទេ ប៉ុន្តែបើអ្នកធ្វើតែងសេចក្ដីមិនយកចិត្តទុកដាក់ឬបើមានការធ្វេសប្រហែសមើលស្រាលនោះ វានឹងធ្វើឱ្យតែងសេចក្ដីរបស់ខ្លួនពុំមានតម្លៃឬពុំសមស្របនឹងការនិយមឬពុំបានទទួលពិន្ទុខ្ពស់។ ចំណុចទាំងនោះរួមមាន៖

### ក- ការសរសេរ

ការសរសេរអក្សរនៅក្នុងតែងសេចក្ដីត្រូវស្អាត មានសណ្ដាប់ធ្នាប់ ច្បាស់ៗ មិនត្រូវសរសេរខ្វើខ្វាក្រវេមក្រវាមដែលធ្វើឱ្យអ្នកអានឬអ្នកកែធុញទ្រាន់នោះទេ។ ការនិយាយយ៉ាងនេះពុំមែនមានន័យថា ទាមទារឱ្យសរសេរអក្សរស្អាតទាំងអស់គ្នានោះទេ ព្រោះមានអ្នកខ្លះសរសេរពុំបានស្អាតតាំងពីកំណើតទោះបីខិតខំពត់ដៃយ៉ាងណាក៏ដោយក៏នៅតែសរសេរពុំបានស្អាតដែរ។ បញ្ហានោះគឺទាមទារឱ្យអ្នកធ្វើតែងសេចក្ដីខិតខំផ្ចិតផ្ចង់លើការសរសេររបស់ខ្លួនឱ្យមានរបៀបរៀបរយត្រឹមត្រូវដោយមិនខ្ជៀក មានសក់ឬជើងច្រងេងច្រងាងធាក់គ្នាទៅវិញទៅមកឬមានស្នាមប្រឡាក់ កោសលុប។ល។ ការសរសេរកខ្វក់ ខ្វីខ្វាបង្ហាញថា អ្នកធ្វើតែងសេចក្ដីមិនយកចិត្តទុកដាក់។ កិច្ចការមិនស្អាត មិនគ្រាន់តែធ្វើឱ្យអ្នកអាន ឬអ្នកកែធុញទ្រាន់ និងខាតពេលវេលាប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យចាប់សេចក្ដីពុំបានច្បាស់ទៀតផង។ ជាការល្អគប្បីប្រិតប្រៀបការសរសេរតួអក្សរ ហើយធ្វើឱ្យកិច្ចការទាំងមូលបានស្អាតល្អតាំងពីដើមដល់ចប់។

កិច្ចការតែងសេចក្ដីអាចជាកញ្ចក់ឆ្លុះមើលពីគុណសម្បត្តិឬពីគុណវិបត្តិរបស់អ្នកធ្វើតែងសេចក្ដី ពុំមែនតែខាងផ្លូវប្រាជ្ញាស្មារតី ចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងអាចឆ្លុះបញ្ចាំងខាងផ្លូវចិត្ត កាយវិកា អាកប្បកិរិយា និងចរិយាសម្បត្តិទៀតផង។ ដូច្នេះអ្នកធ្វើតែងសេចក្ដី ជាពិសេសសិស្សឬនិស្សិតដែលកំពុងរៀននៅសាលា គប្បីប្រុងប្រយ័ត្នរៀបចំខ្លួនឱ្យបានល្អប្រសើរ ដោយគិតចាប់ពីការសរសេរអក្សរ រៀបចំសណ្ដាប់ធ្នាប់ឡើងទៅ ដើម្បីក្លាយជាជនមួយរូបមានតម្លៃទាំងចំណេះដឹងនិងចរិយា។

## ខ- ការប្រើពាក្យពេចន៍

ការគោរពតាមគោលគំនិតខាងលើនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេអ្នកធ្វើតែងសេចក្ដីត្រូវយកចិត្តទុកដាក់លើបញ្ហាមួយចំនួនទៀតដើម្បីធ្វើឱ្យតែងសេចក្ដីរបស់ខ្លួនកាន់តែបានល្អ។ ដំបូងអ្នកធ្វើតែងសេចក្ដីគួរយល់ថា អត្ថបទនីមួយៗកើតឡើងដោយសារពាក្យពេចន៍ ឃ្លា និងល្បះទាំងឡាយ។ អត្ថបទតែងសេចក្ដីដែលល្អនិងមានតម្លៃ គឺអត្ថបទដែលមានពាក្យពេចន៍ ឃ្លា ល្បះសមស្រប ព្រមទាំងស៊ីសង្វាក់គ្នាទៀតផង។ ទោះបីមានគំនិតល្អយ៉ាងណាក៏ដោយ បើសរសេរពាក្យពេចន៍ ឃ្លា ល្បះមិនល្អ អត្ថបទនោះក៏មិនសូវមានតម្លៃល្អឡើយ។

តាមធម្មតាភាសាខ្មែរយើង មានពាក្យដែលមានដើមកំណើតមកពីបាលី សំស្ក្រឹត និងពាក្យខ្មែរសុទ្ធរបស់ខ្លួន។ សព្វថ្ងៃនេះមានពាក្យបច្ចេកទេសថ្មីទៀតជាច្រើនទៀតបានបង្កើតឡើង ហើយពាក្យទាំងនោះពុំទាន់មាននៅក្នុងវចនានុក្រមឡើយ។ ដូច្នេះខ្មែរយើង ក៏មានពាក្យសម្បូរបែបសម្រាប់សម្គាល់ពាក្យសម្ដីរបស់ខ្លួន និងបច្ចេកទេសសម័យទំនើប។

- **ការប្រើពាក្យបាលី-សំស្ក្រឹត:** ពាក្យបាលី-សំស្ក្រឹតខ្មែរយើងនិយមហៅថាពាក្យវប្បធម៌ គឺពាក្យមានតម្លៃ។ ការប្រើពាក្យបាលី-សំស្ក្រឹតនេះជាការប្រសើរណាស់ តែត្រូវយល់ន័យពាក្យនោះឱ្យបានច្បាស់លាស់។ បើយើងយល់ន័យពាក្យនោះពុំបានច្បាស់លាស់ទេ នោះការបរិយាយរបស់យើងត្រឡប់ជាពុំបានល្អទៅវិញ។ ម្យ៉ាងទៀត បើយើងប្រើពាក្យបាលី-សំស្ក្រឹតស្អេកស្កះពេក ក៏ពុំមែនជាការល្អប្រសើរឡើយព្រោះមនុស្សទូទៅពុំមែនសុទ្ធតែចេះពាក្យបាលី-សំស្ក្រឹតទាំងអស់គ្នានោះទេ។ ដូច្នេះការប្រើប្រាស់ពាក្យប្រភេទនេះ គប្បីប្រើក្នុងករណីសមស្រប គឺត្រូវគិតដល់បរិយាកាសសង្គម និងចំណេះដឹងទូទៅរបស់មនុស្សក្នុងសង្គមផងដែរ។
- **ការប្រើពាក្យដែលធម្មតា និងសាមញ្ញពេក:** តាមធម្មតានៅក្នុងភាសារបស់ជនជាតិនីមួយៗនៅលើសកលលោកយើងនេះមានភាសាសរសេរនិងភាសានិយាយ ដែលមានសភាពប្លែកពីគ្នា គឺពាក្យខ្លះសម្រាប់ប្រើក្នុងការនិយាយ ហើយពាក្យខ្លះទៀតសម្រាប់ប្រើក្នុងការសរសេរ។ សភាពប្លែកនេះមិនមែនមានន័យថា ពាក្យដែលប្រើក្នុងភាសានិយាយនិងភាសាសរសេរ ពុំមានទំនាក់ទំនងគ្នាឬត្រូវតែដាច់ពីគ្នានោះទេ។ តាមការពិតភាសានិយាយគឺជាមូលដ្ឋានសម្រាប់ភាសាសរសេរនេះឯង។ អ្នកធ្វើតែងសេចក្ដីគួរចៀសវាងពាក្យអាសគ្រាម ឬពាក្យសាមញ្ញធម្មតាពេកយកមកប្រើក្នុងការសរសេរតែងសេចក្ដី ដែលវានឹងអាចឱ្យតែងសេចក្ដីរបស់យើងអស់តម្លៃ។
- **ការប្រើប្រាស់ពាក្យដែលសមស្របនឹងកាលៈទេសៈ វណ្ណៈ និងឋានៈ:** : ជនជាតិខ្មែរយើងក៏ដូចជាជនជាតិដទៃទៀតដែរ មានភាសាសម្រាប់និយាយស្ដី និងសរសេរដើម្បី បញ្ជាក់មនោសញ្ចេតនារបស់ខ្លួនក្នុងកាលៈទេសៈឬទំនាក់ទំនងជាមួយមនុស្សផ្សេងៗ។ ដូច្នេះក្នុងការសរសេរតែងសេចក្ដី អ្នកធ្វើ តែងសេចក្ដីគួរប្រើពាក្យឱ្យបានសមស្របទៅតាមកាលអាកាសឬប្រើពាក្យឱ្យសមស្របជាមួយស្រទាប់មនុស្សផ្សេងៗដូចជាព្រះសង្ឃរាជវង្សានុវង្ស អ្នកមានគោរមងារផ្សេងៗ មន្ត្រីរាជការ ចាស់

ព្រឹទ្ធាចារ្យ ប្រជាជនសាមញ្ញ។ល។ បញ្ហានេះបើមិនបានយកចិត្តទុកដាក់នោះទេ ចិត្ត គំនិត ឬ អាកប្បកិរិយារបស់អ្នកសរសេរតែងសេចក្ដី ដែលជាសមាសភាពមួយរបស់សង្គមនឹងក្លាយទៅជាមនុស្សគ្មានសីលធម៌និងមានអាកប្បកិរិយាពុំសមសួនស្របជាពលរដ្ឋម្នាក់។ អ្នកសរសេរតែងសេចក្ដីត្រូវចៀសវាងការប្រើពាក្យដដែលៗច្រើនពេកធ្វើឱ្យអ្នកអានឬអ្នកកែធុញទ្រាន់។

### គ- ការប្រើឃ្លា ល្បះក្នុងការសរសេរតែងសេចក្ដី

តែងសេចក្ដី គឺជាមុខវិជ្ជាអនុវត្តមួយដែលឆ្លុះបញ្ចាំងចំណេះដឹងអ្នកសរសេរតែងសេចក្ដី។ បើសរសេរតែងសេចក្ដីបានល្អ គេវាយតម្លៃថាអ្នកធ្វើតែងសេចក្ដីពូកែ មានគំនិតទូលំទូលាយ។ តែផ្ទុយទៅវិញ បើសរសេរតែងសេចក្ដីពុំបានល្អ គេវាយតម្លៃថាអ្នកធ្វើតែងសេចក្ដីនោះខ្សោយមានពុទ្ធិចង្អៀតចង្អល់។ល។

ដូច្នេះក្នុងការធ្វើតែងសេចក្ដីត្រូវយកចិត្តទុកដាក់ក្នុងការប្រើឃ្លា ល្បះឱ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍។ ក្នុងរយៈកាលកន្លងមកនេះយើងសង្កេតឃើញថា មានអ្នកធ្វើតែងសេចក្ដីមិនតិចទេដែលសរសេរតែងសេចក្ដីដោយការប្រើប្រាស់ឃ្លា ល្បះពុំបានត្រឹមត្រូវឬពុំទាន់បានចែកដាច់រវាងឃ្លា ល្បះសម្រាប់និយាយជាមួយនឹងឃ្លា ល្បះសម្រាប់សរសេរ។ តាមធម្មតាឃ្លា ល្បះសម្រាប់និយាយពុំសូវគិតពីក្បួនវេយ្យាករណ៍ តែឃ្លា ល្បះសម្រាប់សរសេរត្រូវគោរពតាមក្បួនវេយ្យាករណ៍ត្រឹមត្រូវច្បាស់លាស់។ មិនតែប៉ុណ្ណោះឃ្លា ល្បះត្រូវមានន័យត្រឹមត្រូវ និងពីរោះស្ដាប់សម្រាប់អ្នកអានឬអ្នកកែ។ ចៀសវាងការប្រើប្រាស់ឃ្លា ល្បះដដែលៗនាំឱ្យបាត់តម្លៃតែងសេចក្ដីនិងធ្វើឱ្យអ្នកអានឬអ្នកកែធុញទ្រាន់។ ដូច្នេះអ្នកធ្វើតែងសេចក្ដីគប្បីចេះប្រើឃ្លា ល្បះប្លែកៗដើម្បីចៀសវាងការធុញពីសំណាក់អ្នកអាន។

### ឃ- អំពីការដកឃ្លា ការប្រើសញ្ញាខណ្ឌ ការប្រើវណ្ណយុត្តនិងការប្រើវណ្ណវាទ

- **ការដកឃ្លា:** ការសរសេរដកឃ្លាមានសារៈសំខាន់ក្នុងការសរសេរអក្សរខ្មែរយើង គឺការធ្វើឱ្យគំនិតនៅតពីគ្នាបន្តិចកុំឱ្យជាប់គ្នារដឹកស្ដាប់មិនបាន។ ចំពោះការសរសេរភាសាអង់គ្លេសនិងភាសាបារាំង ការដកឃ្លាគេមានសញ្ញាសម្គាល់មួយគឺសញ្ញាក្បៀស។ ចំណែកអក្សរខ្មែរយើង គេពុំចាំបាច់ក្បៀសទេ គឺគ្រាន់តែដកឃ្លាជាការស្រេច។ រយៈកាលកន្លងមកនេះមានអ្នកសរសេរតែងសេចក្ដីមួយចំនួនបានសរសេរដកឃ្លាដោយប្រើសញ្ញាក្បៀសជំនួស ប្រៀបបាននឹងការសរសេរភាសាអង់គ្លេស និងភាសាបារាំងដែរ។ ករណីនេះអ្នកធ្វើតែងសេចក្ដីគួរតែចៀសវាង។
- **ការប្រើសញ្ញាខណ្ឌ:** សញ្ញាខណ្ឌ " ។ " ត្រូវប្រើនៅពេលបញ្ចប់ល្បះនីមួយៗ ដើម្បីកុំឱ្យគំនិតឆ្លងពីល្បះមួយទៅល្បះមួយទៀត។ គេអាចប្រើសញ្ញាខណ្ឌនៅលើឃ្លា ប្រយោគឬល្បះ ដែលមានន័យគ្រប់គ្រាន់សមស្របតាមទម្រង់ល្បះ ពោលគឺមានប្រធាន មានកិរិយា និងមានកម្មបទ។

  ការសរសេរតែងសេចក្ដី គួរគោរពសញ្ញាដកឃ្លា និងការប្រើសញ្ញាខណ្ឌបានត្រឹមត្រូវ។ គប្បីចៀសវាងការសរសេរជាប់គ្នារដឹកដោយមិនបានដកឃ្លាពីឃ្លាមួយទៅឃ្លាមួយនិងមិនប្រើសញ្ញាខណ្ឌពីល្បះមួយទៅល្បះមួយទៀត។ ការសរសេររបៀបនេះ ធ្វើឱ្យអ្នកអានឬអ្នកកែពុំអាចយល់ន័យសេចក្ដីរបស់អ្នកសរសេរចង់និយាយ។
- **ការប្រើវណ្ណយុត្ត និងវណ្ណវាទ:** ការសរសេរ អ្នកធ្វើតែងសេចក្ដីត្រូវសរសេរវណ្ណយុត្តនិងវណ្ណវាទឱ្យបានច្បាស់ ចៀសវាងការសរសេរច្រឡំគ្នាដូចជា៖

  ✓ យុគ្គលពិន្ទុឬចុចពីរ«ៈ»
  ✓ វិសជ្ជនីឬរះមុខ«ះ»

- ✓ អព្ភន្តរ «...» ឬ"..."
- ✓ វង់ក្រចក(...)

រយៈកាលកន្លងមកនេះ ក៏ឃើញមានស្មេរមួយចំនួនបានសរសេរច្រឡំគ្នារវាងយុគ្គលពិន្ទុនិងវិសជ្ជនីដូចជាៈ

- ✓ ពាក្យ ខណៈ សរសេរជា ខណះ
- ✓ ពាក្យ នោះ នេះ សរសេរជា នោៈ នេៈ ជាដើម។

ករណីខាងលើនេះ យើងគួរចៀសវាង ពុំគួរឱ្យមានការភាន់ច្រឡំរវាងវណ្ណយុត្តនិងវណ្ណវាទទាំងនេះទេ។ បើពាក្យណាសរសេរនឹងយុគលពិន្ទុត្រូវសរសេរដោយប្រើយុគ្គលពិន្ទុ តែបើពាក្យណាសរសេរនឹងវិសជ្ជនីត្រូវសរសេរដោយប្រើវិសជ្ជនី។

- **ការសរសេរចុះបន្ទាត់:** ការសរសេរចុះបន្ទាត់ មានប្រយោជន៍សម្រាប់បញ្ជាក់ឱ្យឃើញច្បាស់ពីការបែងចែករវាងគំនិតមួយទៅគំនិតមួយឬរវាងកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត។ តាមធម្មតាកាលណាសរសេរអស់គំនិតទី១ឬកថាខណ្ឌទី១ត្រូវចុះបន្ទាត់ដើម្បីឈានចូលទៅគំនិតទី២ឬកថាខណ្ឌទី២ រួចកាលណាចប់គំនិតទី២ឬកថាខណ្ឌទី២ត្រូវចុះបន្ទាត់ដើម្បីឈានចូលទៅគំនិតទី៣ឬកថាខណ្ឌទី៣ទៀត។ គប្បីធ្វើដូច្នេះរហូតអស់គំនិត។

ការសរសេរចុះបន្ទាត់ មានសារៈសំខាន់ឱ្យអ្នកអានងាយយល់ ងាយចាប់សេចក្តីបាន មានពេលឈប់សម្រាក មានពេលគិត កាលណាគេចង់អានកថាខណ្ឌត្រង់ណាមួយនៃតែងសេចក្តី។ ការសរសេរចុះបន្ទាត់ យើងត្រូវគោរពប្លង់គម្រោងតែងសេចក្តី ដែលយើងបានរៀបចំរួចហើយ។ ការសរសេរចុះបន្ទាត់តាមកថាខណ្ឌបានបញ្ជាក់ថា អ្នកធ្វើតែងសេចក្តីបានយល់ប្រធានច្បាស់ហើយចេះរៀបចំគំនិតជាលំដាប់លំដោយ។ ចំពោះអត្ថបទខ្លះ យើងបានលើកយកបញ្ហាឬទស្សនៈមកបរិយាយតែមួយក៏ដោយ ក៏យើងអាចចែកជាកង់ៗឬជាផ្នែកៗដែលយើងត្រូវតែសរសេរចុះបន្ទាត់។

ប៉ុន្តែការសរសេរចុះបន្ទាត់ ពុំមែនអនុញ្ញាតឱ្យយើងចេះតែសរសេរចុះបន្ទាត់ញឹកញាប់ពេកមួយបន្ទាត់ឬពីរបន្ទាត់ចុះម្តងឬចេះតែចុះតាមទំនើងចិត្តនោះឡើយ។ ការសរសេរចុះបន្ទាត់ត្រូវឱ្យសមហេតុផល ឱ្យស្របនឹងគំនិតក្នុងកថាខណ្ឌដែលខ្លួនបានសរសេរ។

- **ការប្រើអក្សរកាត់:** ការសរសេរអក្សរកាត់ ត្រូវហាមឃាត់ទាំងស្រុង ពុំអនុញ្ញាតឱ្យសរសេរនៅក្នុងតែងសេចក្តីឡើយ ព្រោះការសរសេរអក្សរកាត់អាចឱ្យអ្នកអាន ឬអ្នកកែយល់មិនច្បាស់អំពីន័យនិងអក្ខរាវិរុទ្ធរបស់ពាក្យ។ ម្យ៉ាងទៀតអ្នកអានឬអ្នកកែក៏ចង់ត្រួតពិនិត្យចំណេះដឹងផ្នែកភាសា និងសំណេររបស់អ្នកធ្វើតែងសេចក្តីផងដែរ។ អាស្រ័យហេតុនេះ បានជាគេពុំអនុញ្ញាតឱ្យសរសេរអក្សរកាត់ឡើយ។

- **ការដាក់ចំណងជើងតូច ឬធំ និងសញ្ញាគូសមួយ " - ":** ការដាក់ចំណងជើងតូច ធំក្នុងការសរសេរតែងសេចក្តីពុំអនុញ្ញាតឱ្យសរសេរទេ ព្រោះថាតែងសេចក្តីមិនមែនជាមេរៀនឡើយ។ តែងសេចក្តីទាមទារឱ្យអ្នកធ្វើត្រូវតែបរិយាយឱ្យស៊ីសង្វាក់គ្នាតាំងពីដើមដល់ចប់។ ការដាក់ចំណងជើងតូច ធំ វាអាចធ្វើឱ្យន័យសេចក្តីពីកថាខណ្ឌមួយទៅកថាខណ្ឌមួយ ពុំស៊ីសង្វាក់គ្នា ដាច់ពីគ្នា ដែលពុំមែនជាតែងសេចក្តី។ ម្យ៉ាងទៀត ការគូសសញ្ញាគូសមួយ " - " នៅមុខឃ្លា ល្បះ វគ្គ ឬកថាខណ្ឌណាមួយត្រូវហាមឃាត់។ ការគូសសញ្ញានេះក៏ធ្វើឱ្យន័យសេចក្តីពីចំណុចមួយទៅចំណុចមួយទៀតដាច់ៗពីគ្នាដូចជាការប្រើចំណងជើងតូច ឬធំដែរ។

- **ការគូសបន្ទាត់ក្រោមពាក្យណាមួយ ឬឃ្លាណាមួយ:** ការគូសបន្ទាត់ក្រោមពាក្យណាមួយ ឬឃ្លាណាមួយពុំអនុញ្ញាតឱ្យគូសបានឡើយ ទោះបីពាក្យនោះមានសារៈសំខាន់យ៉ាងណាក៏ដោយ ពីព្រោះការគូសវាសហាក់ដូចជាបង្គាប់ឱ្យអ្នកកែចាប់អារម្មណ៍យល់តាមខ្លួន។ តាមធម្មតាអ្នកកែតែងសេចក្ដីគេមានចំណេះដឹងជ្រៅជ្រះអាចយល់ និងវាយតម្លៃកិច្ចការរបស់យើងសព្វគ្រប់ យើងពុំចាំបាច់ព្រួយបារម្ភឡើយ។ ម្យ៉ាងវិញទៀត តែងសេចក្ដីពុំមែនជាមេរៀនដែលត្រូវការគូសបញ្ជាក់លើពាក្យណាមួយឬចំណងជើងណាមួយឡើយ។ ការងារសំខាន់របស់អ្នកធ្វើតែងសេចក្ដី គឺត្រូវតែចេះលើកយកពុទ្ធិ ចំណេះដឹងទូទៅរបស់ខ្លួនមកបរិយាយរ៉ាយរ៉ាប់ឱ្យគេយល់ទៅតាមបញ្ហាដែលគេបានលើកឡើងតែប៉ុណ្ណោះ។
- **ការសរសេរលេខនៅក្នុងតែងសេចក្ដី:** នៅក្នុងតែងសេចក្ដី គេពុំនិយមឱ្យសរសេរជាតួលេខសុទ្ធៗទេ តែត្រូវសរសេរជាអក្សរជំនួសវិញ។ ឧទាហរណ៍ មនុស្សពីរនាក់ ប្រទេសមួយ ប្រជាជនដប់បីលាននាក់ ឆ្នាំពីរពាន់ដប់ប្រាំពីរជាដើម។
- **ការសរសេរពីបញ្ហាផ្សេងៗ:** នៅក្នុងតែងសេចក្ដីមិនត្រូវសរសេរពីរឿងរ៉ាវផ្ទាល់ខ្លួនក្នុងគ្រួសារ និងលើកសរសើរបញ្ជើចបញ្ជើបុគ្គលឥស្សរជនហួសពីការពិត។

## ៤- វិធីសាស្ត្រក្នុងការសរសេរតែងសេចក្ដី

តែងសេចក្ដី ជាសំណេរមួយប្រភេទតម្រូវឱ្យអ្នកសរសេរ មានកម្រិតពុទ្ធិខ្ពស់ផ្នែកចំណេះដឹងទូទៅ ចំណេះដឹងក្នុងការរស់នៅ ផ្លូវច្បាប់ និងចំណេះដឹងផ្នែកអក្សរសិល្ប៍។ ក្នុងការធ្វើតែងសេចក្ដី អ្នកសរសេរមានសេរីភាពគ្រប់គ្រាន់ក្នុងការពណ៌នា ការបកស្រាយ ការពន្យល់ ការបញ្ចេញមតិ ការប្រៀបធៀប... តែសេរីភាពនេះស្ថិតក្រោមក្របខណ្ឌនៃប្រធានតែងសេចក្ដី។

ដូច្នេះដើម្បីសរសេរតែងសេចក្ដីឱ្យបានល្អត្រឹមត្រូវ ពីរោះក្បោះក្បាយ និងជាទីចាប់អារម្មណ៍របស់អ្នកអាន អ្នកស្ដាប់នោះ អ្នកធ្វើតែងសេចក្ដីគប្បីអនុវត្តតាមជំហានដូចខាងក្រោម៖

### ៤.១- ការតាំងចិត្តនិងការប្រមូលគំនិត

ការតាំងចិត្តនិងប្រមូលអារម្មណ៍ជាបម្រុងប្រយ័ត្នដ៏សំខាន់មួយ មុននឹងចាប់ផ្ដើមធ្វើតែងសេចក្ដីមានន័យថា យើងមិនត្រូវប្រញាប់ប្រញាល់ឬតក់ក្រហល់ពេក មិនត្រូវភ័យខ្លាចឬញាប់ញ័រ ខ្លាំងពេកនាំឱ្យយើងភ្លេចភ្លាំងបាត់បង់ភាពម្ចាស់ការនោះទេ។ ពោលគឺយើងត្រូវពង្រឹងស្មារតី តាំងអារម្មណ៍ឱ្យស្ងប់ គ្រប់គ្រងអារម្មណ៍ឱ្យបានល្អចៀសវាងការបែកអារម្មណ៍។ ផ្ដោតអារម្មណ៍ខ្លាំងលើប្រធានតែងសេចក្ដី។ បន្ទាប់ពីរៀបចំខ្លួនបានស្រួលហើយ យើងនឹងចាប់ធ្វើតែងសេចក្ដីបានល្អត្រឹមត្រូវមិនខាន។

### ៤.២- ការសិក្សាប្រធាន

មុននឹងចាប់ផ្ដើមសរសេរត្រូវសិក្សាប្រធានឱ្យបានច្បាស់លាស់និងល្អិតល្អន់ជាមុនសិន។ ដំបូងយើងត្រូវអានប្រធានឱ្យបានច្រើនសា កត់ចំណាំពាក្យគន្លឹះ និងចំណោទសួររបស់ប្រធានថា តើប្រធាននោះជាប្រធានបែបណា? ប្រធានបែបពិពណ៌នា ការនិទាន ការសរសេរសំបុត្រ អត្ថាធិប្បាយពន្យល់ ប្រៀបធៀប ពិភាក្សា។ល។ តើចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថាជាប្រធានបែបនេះឬប្រភេទនោះ? បន្ទាប់ពីស្គាល់ប្រធានច្បាស់លាស់ប្រាកដហើយ ទើបអ្នកអាចចាប់ផ្ដើមធ្វើប្លង់ គម្រោងតែងសេចក្ដី។

## ៤.៣- ការធ្វើគម្រោងតែងសេចក្ដី

ក្រោយពីសិក្សា និងចំណាត់ប្រភេទប្រធានច្បាស់លាស់ហើយ អ្នកធ្វើតែងសេចក្ដីត្រូវធ្វើប្លង់ ឬគម្រោងតែងទៅតាមប្រភេទរបស់ប្រធាននោះ។ តែងសេចក្ដី ទោះជាប្រធានបែបណាក្ដី ក៏ត្រូវឈរលើផ្នែកសំខាន់៣គឺៈ

- ផ្ដើមសេចក្ដី
- តួសេចក្ដី
- បញ្ចប់សេចក្ដី ។

ក្នុងផ្នែកសំខាន់ទាំងបីខាងលើ អ្នកធ្វើតែងសេចក្ដីត្រូវប្រមូលគំនិត យោបល់ អំណះអំណាងដែលជាធាតុចូលសម្រាប់បំពេញទៅតាមតម្រូវការខ្លឹមសារនៃផ្នែកទាំងបីខាងលើ។ ក្នុងគម្រោងតែង ប្លង់មិនតម្រូវឱ្យយើងសរសេរគំនិត យោបល់ ពេញលេញគ្រប់ជ្រុងជ្រោយនោះទេ។ ក្នុងគម្រោងតែង យើងគ្រាន់តែព្រាងគំនិតចម្បងៗនិងអំណះអំណាងតាមលំដាប់លំដោយប៉ុណ្ណោះ។

## ៤.៤- ការសរសេរពេញលេញ

ក្នុងដំណាក់នេះ អ្នកសរសេរត្រូវសរសេរគំនិត យោបល់ទៅតាមចំណុចតូចៗបញ្ចូលទៅក្នុងផ្នែកទាំងបីនៃតែងសេចក្ដី។ នៅពេលនេះ អ្នកសរសេរត្រូវសរសេរយ៉ាងពេញលេញ គ្រប់ជ្រុងជ្រោយ ឱ្យឆ្លើយតបទៅនឹងបញ្ហារបស់ប្រធាន និងទៅតាមគម្រោងដែលបានគិតរួចមកហើយ។ ការសរសេរនោះ ត្រូវគិតទៅលើគំនិត យោបល់ ខ្លឹមសារនៅក្នុងផ្ដើមសេចក្ដី តួសេចក្ដី និងបញ្ចប់សេចក្ដី ឱ្យឆ្លើយតបគ្រប់ចំណុច ភ្ជាប់ជាមួយនឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់។ ក្រៅពីអត្ថន័យនិងខ្លឹមសារ អ្នកសរសេរក៏ត្រូវគិតទៅលើ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងលំដាប់លំដោយគំនិត ខ្លឹមសារផងដែរ។

## ៤.៥- ការកែលម្អ

ដំណាក់ចុងក្រោយនេះ អ្នកសរសេរតែងសេចក្ដីត្រូវពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ភាពត្រឹមត្រូវទៅតាមប្រធានដែលបានចោទ (កុំឱ្យចាកប្រធាន)។
- មានខ្លឹមសារគ្រប់គ្រាន់ឆ្លើយតបនឹងផ្នែកធំៗទាំងបីនៃតែងសេចក្ដី(ផ្ដើមសេចក្ដី តួសេចក្ដី បញ្ចប់សេចក្ដី) ហើយឬនៅ?
- ខ្លឹមសារ និងគំនិតមានលំដាប់លំដោយទៅតាមគម្រោងឬប្លង់ និងស្របទៅតាមចំណោទរបស់ប្រធានហើយឬនៅ?
- មានអំណះអំណាងនិងឧទាហរណ៍ (ជីវភាពជាក់ស្ដែងនិងក្នុងអក្សរសិល្ប៍) មកបញ្ជាក់ច្បាស់លាស់ និងត្រឹមត្រូវគ្រប់ជ្រុងជ្រោយហើយឬនៅ?
- សំណេររបស់ខ្លួនមានកំហុសអក្ខរាវិរុទ្ធ ឃ្លា ល្បះដែរឬទេ?
- តើសំណេរតែងសេចក្ដីរបស់យើងមានឃ្លា ល្បះ ខ្លឹមសារមានលំដាប់ណែងណង ស៊ីចង្វាក់គ្នាជាទីចាប់អារម្មណ៍របស់អ្នកអាន អ្នកស្ដាប់ដែរឬទេ?

នៅពេលពិនិត្យបានហ្មត់ចត់ច្បាស់លាស់រួចហើយនោះ យើងកែលម្អបំពេញបន្ថែមចំណុចដែលមានកំហុស និងខ្វះខាតទាំងនោះឱ្យបានត្រឹមត្រូវឡើងវិញជាការស្រេច។

## ៥- ប្រភេទនៃប្រធានតែងសេចក្តី

- ប្រធានតែងសេចក្តីមានច្រើនប្រភេទដូចជា៖
  - ✓ ប្រធានបែបពិពណ៌នា
  - ✓ ប្រធានបែបនិទានរឿង
  - ✓ ប្រធានបែបអត្ថាធិប្បាយ
- ក្នុងប្រធានអត្ថាធិប្បាយមាន៖
  - ✓ ប្រធានអត្ថាធិប្បាយពន្យល់
  - ✓ ប្រធានអត្ថាធិប្បាយពិភាក្សា
  - ✓ ប្រធានអត្ថាធិប្បាយប្រៀបធៀប
  - ✓ ប្រធានអត្ថាធិប្បាយស្រាយបំភ្លឺ ឬនិទស្សន៍។ល។
- ការសិក្សានៅពេលនេះ គឺសិក្សាប្រធានតែងសេចក្តីបែបអត្ថាធិប្បាយដែលមាន៖
  - ✓ ប្រធានបែបពន្យល់
  - ✓ ប្រធានបែបពិភាក្សា
  - ✓ ប្រធានបែបប្រៀបធៀប។

### ៥.១- ប្រធានអត្ថាធិប្បាយពន្យល់

ប្រធានអត្ថាធិប្បាយបែបពន្យល់ គឺជាសំណេរមួយប្រភេទដែលតម្រូវឱ្យអ្នកតែងធ្វើការបកស្រាយពន្យល់ ឱ្យស្របទៅនឹងគំនិតរបស់ប្រធាន។ ប្រធានបែបនេះតម្រូវឱ្យអ្នកតែងធ្វើការបញ្ចេញពុទ្ធិដោយលើកយកការចេះចាំចំណេះវិជ្ជាទូទៅដែលទាក់ទងនឹងមេរៀនក្នុងថ្នាក់ឬរឿងរ៉ាវដែលយើងបានដឹង បានយល់មកបញ្ជាក់ឱ្យស្របទៅតាមបញ្ហារបស់ប្រធាន។ ប្រធានបែបពន្យល់មិនតម្រូវឱ្យយើងពិភាក្សាវែកញែករកខុសត្រូវទេ។

#### ៥.១.១- ប្រភេទប្រធានអត្ថាធិប្បាយពន្យល់

#### ក- ប្រធានបែបពន្យល់ទស្សនៈ

ប្រធានអត្ថាធិប្បាយបែបពន្យល់ទស្សនៈ គឺជាប្រធានដែលតម្រូវឱ្យលើកយកទស្សនៈណាមួយមកចោទ និងដោះស្រាយ។ ***ឧទាហរណ៍៖***

- **ប្រធានទី១**: ពុទ្ធឱវាទមួយឃ្លាថែងថា «ពៀររំងាប់ដោយការមិនចងពៀរ»។ ចូរពន្យល់ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។
- **ប្រធានទី២**: ពាក្យអប់រំមួយឃ្លាថែងថា «អំពើអហិង្សា គឺជាគុណធម៌ដ៏ប្រសើរបំផុតដែលនាំមកនូវសន្តិភាព»។ ចូរអ្នកពន្យល់ទស្សនៈនេះដោយរកអំណះអំណាងក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមមកបញ្ជាក់។
- **ប្រធានទី៣**: ទស្សនៈមួយថែងថា « អំពើពុករលួយ ធ្វើឱ្យប៉ះពាល់ដល់គុណភាពជីវិតមនុស្សក្នុងសង្គម»។ តើអំពើពុករលួយក្នុងរឿងចៅកែចិត្តចោរបានធ្វើឱ្យប៉ះពាល់គុណភាពជីវិតតួអង្គក្នុងរឿងនេះយ៉ាងណាខ្លះ? ចូរអ្នកធ្វើការបកស្រាយ ដោយភ្ជាប់ឧទាហរណ៍ក្នុងរឿងខាងលើមកបញ្ជាក់។

### ខ- ប្រធានបែបពន្យល់សុភាសិត ពាក្យស្លោក ឬពាក្យអប់រំ

ប្រធានអត្ថាធិប្បាយបែបនេះ គឺជាប្រធានដែលតម្រូវឱ្យអ្នកសរសេរបកស្រាយសុភាសិត ឬពាក្យអប់រំក្នុងច្បាប់ណាមួយ។ ***ឧទាហរណ៍៖***

- **ប្រធានទី១**: សុភាសិតមួយឃ្លាចែងថា «ដើយស្អក ឱនដាក់គ្រាប់»។ តើសុភាសិតមួយឃ្លានេះមានអត្ថន័យដូចម្តេចខ្លះ ? ចូរពន្យល់ដោយរកឧទាហរណ៍មកបញ្ជាក់។
- **ប្រធានទី២**: ពាក្យចាស់បុរាណមួយឃ្លាចែងថា«ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក»។ ចូរពន្យល់ពាក្យបុរាណនេះ ដោយលើកយកឧទាហរណ៍ក្នុងរឿងអាខ្វាក់អាខ្វិនមកបញ្ជាក់។
- **ប្រធានទី៣**: ច្បាប់ពាក្យចាស់មួយវគ្គចែងថា «ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្អុរទឹកឃ្មុំ ពួនសំងំធីម្នាក់ឯង»។ តើពាក្យចាស់ខាងលើនេះ ចង់អប់រំយ៉ាងដូចម្តេច? ចូរបកស្រាយដោយរកឧទាហរណ៍មកបញ្ជាក់។
- **ប្រធានទី៤**: ពាក្យទូន្មានមួយឃ្លាបានចែងថា «កូនកាចបំពេញទុក្ខ ម្តាយឪពុកព្រួយបារម្ភ កូនស្លូតចេះគួរសម មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ»។ ចូរពន្យល់ដោយឆ្លុះបញ្ចាំងតាមរយៈសង្គមនិងអក្សរសិល្ប៍មកបញ្ជាក់។

### គ-ប្រធានបែបពន្យល់អក្សរសិល្ប៍

ប្រធានអត្ថាធិប្បាយបែបពន្យល់អក្សរសិល្ប៍ គឺជាប្រធានដែលតម្រូវឱ្យយើងលើកយកបញ្ហាក្នុងអក្សរសិល្ប៍ណាមួយមកចោទនិងដោះស្រាយ។ ***ឧទាហរណ៍៖***

- **ប្រធានទី១**: ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ សមបានបញ្ជាក់ថា «...ឱ្យតែការងារសុចរិតខ្ញុំបាទអាចធ្វើបានទាំងអស់...»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងរឿងខាងលើមកបញ្ជាក់។
- **ប្រធានទី២**: ទស្សនៈមួយចែងថា «ការសិក្សាអក្សរសិល្ប៍ គឺជាការសិក្សាបញ្ហាមនុស្សនៅសម័យណាមួយ»។ ចូរអ្នកធ្វើការពន្យល់ទស្សនៈនេះដោយលើកយកឧទាហរណ៍ក្នុងអក្សរសិល្ប៍ ដែលអ្នកធ្លាប់បានសិក្សារួចហើយមកបញ្ជាក់។

### ៥.១.២- លក្ខណៈសម្គាល់ប្រធានបែបពន្យល់

គេអាចសម្គាល់បានប្រធានបែបពន្យល់តាមលក្ខណៈ៣យ៉ាង៖

❖ **ស្គាល់តាមរយៈពាក្យបញ្ចេញមតិ៖**

- មានទស្សនៈមួយចែងថា «.........................................................................................»
- តាមទស្សនៈអប់រំមួយឃ្លាចែងថា «..............................................................................»
- អ្នកប្រាជ្ញមួយរូបមានប្រសាសន៍ថា «.......................................................................»
- ក្រុមអ្នកបរិស្ថានវិទ្យាបានរិភាគថា «.......................................................................»
- សេដ្ឋវិទូមួយរូបថ្លែងថា «..............................................................................................»។

❖ **ស្គាល់តាមរយៈពាក្យចោទសួរ៖**

- ...............................មានន័យដូចម្តេចខ្លះ?

- ................................មានលក្ខណៈយ៉ាងណាខ្លះ?
- ................................មានប៉ុន្មានយ៉ាង?
- ................................អត្ថន័យយ៉ាងណាខ្លះ?
- .............................................................?

❖ ស្គាល់តាមរយៈពាក្យបង្គាប់បញ្ហា៖

- ចូរពន្យល់..........................................................................................
- ចូរបកស្រាយ......................................................................................
- ចូរស្រាយបំភ្លឺ.....................................................................................
- ចូរគូសបញ្ជាក់....................................................................................
- ចូរអធិប្បាយ.......................................................................................
- ចូររៀបរាប់..........................................................................................
- ចូរបង្ហាញ ..........................................................................................
- ...........................................................................................................។

៥.១.៣- ទម្រង់ទូទៅនៃប្រធានអត្ថាធិប្បាយពន្យល់

## គម្រោងតែង

ក- ផ្ដើមសេចក្ដី

- **លំនាំបញ្ហា:** ជាខ្លឹមសារ គំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិតឬខ្លឹមសាររបស់ប្រធាន។
- **ចំណូលបញ្ហា (បង្ហាញប្រធាន)** : ជាការលើកយកមតិប្រធានមកបញ្ចូលវិញ។
- **ចំណោទបញ្ហា:** ជាការចោទសួរតាមបែបប្រធានពន្យល់។

  ***ចំណុចគួរចៀសវាង*** : ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្ដីចៀសវាងការចោទសួរច្រាសមកវិញនាំឱ្យចាកប្រធានឬប្រើពាក្យបង្គាប់បញ្ហាឡើយ។ ***ឧទាហរណ៍៖***

  - តើអ្នកយល់យ៉ាងណា? ចូរស្រាយបំភ្លឺដោយលើកឧទាហរណ៍បញ្ជាក់។
  - តើអ្នកយល់ដូចម្ដេច? ចូរបកស្រាយ។
  - តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរពន្យល់។
  - ..........................................................................។

ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី:** ឃ្លាសម្រាប់ជាកិច្ចផ្ដើមដើម្បីភ្ជាប់ពីសេចក្ដីផ្ដើមទៅនឹងការពន្យល់ពាក្យ ឬកន្សោមពាក្យគន្លឹះក្នុងប្រធាន។
- **ពន្យល់ពាក្យគន្លឹះ:** ក្នុងចំណុចនេះអ្នកធ្វើតែងសេចក្ដីត្រូវស្រង់យកពាក្យ កន្សោមពាក្យគន្លឹះ ឬឃ្លាដែលជាគន្លឹះ ប្រធានមកពន្យល់បង្ហាញដោយមិនប្រើវង្គសញ្ញា(-) ឬប្រាប់ថ្នាក់ពាក្យដូចជា

ពន្យល់ពាក្យធម្មតានោះទេ ហើយក៏មិនត្រូវពន្យល់តាមន័យធម្មតានោះដែរ គឺអាស្រ័យនឹងបរិបទនៃប្រធាន។

- **ពន្យល់ន័យប្រធាន:** គឺជាការបង្ហាញទស្សនៈប្រធានបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យឬកន្សោមពាក្យដែលបានពន្យល់រួចហើយឱ្យបានសមរម្យ។
- **បកស្រាយប្រធាន:** ចំណុចនេះអ្នកធ្វើតែងសេចក្តីត្រូវស្រាយបំភ្លឺទៅតាមចំណោទរបស់ប្រធាន ឬបំណងរបស់ប្រធានចង់ដឹងដោយភ្ជាប់នឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់។
- **សរុប:** ជាការសង្ខេបឬប្រមូលបញ្ចូលគ្នានូវគំនិត ដែលបានស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រគំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន:** ជាការបញ្ជាក់ម្តងទៀតទៅលើអត្ថន័យនិងតម្លៃរបស់ប្រធានថាមានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន។
- **យោបល់ផ្ទាល់ខ្លួន:** ជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកសរសេរតែងសេចក្តីចំពោះប្រធានដែលចោទឡើងខាងលើនិងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធឬគោលគំនិតរបស់ប្រធាន។

## ៥.២- ប្រធានអត្ថាធិប្បាយពិភាក្សា

ប្រធានបែបពិភាក្សាជាប្រធានដែលបញ្ចេញមតិ ទស្សនៈឬយោបល់ណាមួយនៅក្នុងនោះ គឺតម្រូវឱ្យយើងពិចារណារកខុសត្រូវ ឬតម្រូវឱ្យយើងរិះគន់វែកញែករកហេតុផល រកល្អអាក្រក់ គុណ ទោស មានប្រយោជន៍ ឬអត់ប្រយោជន៍ជាដើម។

### ៥.២.១- ប្រធានពិភាក្សាមានពីរប្រភេទ

**ក- ប្រធានពិភាក្សាសុទ្ធ** (មតិប្រធានមានតែមួយ)

ប្រធាននេះតម្រូវឱ្យបញ្ជាក់ការខុសត្រូវឱ្យរិះគន់វិនិច្ឆ័យមតិយោបល់តែមួយដូចជា៖

- **ប្រធានទី១:** មានមតិខ្លះពោលថា«ស្នេហា គឺជាប្រភពនៃទុក្ខ»។ តើមតិនេះត្រូវ ឬខុស? ចូរពិភាក្សាដោយរកឧទាហរណ៍មកបញ្ជាក់។
- **ប្រធានទី២:** ដំណើររឿងទុំទាវលើកឡើងថា «ទុំស្លាប់នេះខុសពីព្រោះស្រី សម្លាញ់សង្សារនាលោកិយ លោកអើយគប្បីវេះវាងវៀរ»។ តើមតិនេះត្រឹមត្រូវឬទេ? ចូរពិភាក្សាដោយរកឧទាហរណ៍ក្នុងរឿងទុំទាវមកបញ្ជាក់។
- **ប្រធានទី៣:** មានមតិមួយពោលថា «ការបញ្ចប់រឿងថៅកែចិត្តចោរ ដោយឱ្យថៅកែរួចផុតពីសំណាញ់ច្បាប់មិនត្រឹមត្រូវទេ»។ ចូរពិភាក្សាដោយរកឧទាហរណ៍ក្នុងរឿងខាងលើនេះមកបញ្ជាក់។

**ខ- ប្រធានពិភាក្សាប្រៀបធៀប** (មតិប្រធានមានពីរ)

ប្រធាននេះតម្រូវឱ្យយើងពិចារណាវែកញែករកហេតុផលល្អ អាក្រក់ចំពោះមតិឬយោបល់ពីរដោយប្រៀបធៀបគ្នាក្នុងចំណោមមតិ ឬយោបល់ទាំងពីរនោះដូចជា៖

- **ប្រធានទី១:** មតិខ្លះយល់ថា«វិជ្ជាប្រសើរជាងទ្រព្យ»។ ឯមតិខ្លះទៀតយល់ថា «ទ្រព្យប្រសើរជាងវិជ្ជា»។ តើអ្នកយល់ដូចម្តេចចំពោះមតិទាំងពីរខាងលើនេះ? ចូរពិភាក្សាដោយរកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់។

- **ប្រធានទី២**: ការសិក្សារឿងរាមកេរ្តិ៍ខ្មែរ មានអ្នកសិក្សាខ្លះយល់ថា «ព្រះរាមជាអវតារទីប្រាំពីររបស់ព្រះវិស្ណុ»។ រីឯអ្នកសិក្សាខ្លះទៀតយល់ថា «ព្រះរាមជាមនុស្ស»។ ចូរពិភាក្សាដោយរកឧទាហរណ៍ក្នុងរឿងខាងលើនេះមកបញ្ជាក់។
- **ប្រធានទី៣**: មតិខ្លះចោទថា «ព្រះរាមធ្វើសង្គ្រាមដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន»។ រីឯមតិខ្លះទៀតយល់ថា «ព្រះរាមធ្វើសង្គ្រាមដើម្បីផលប្រយោជន៍សង្គមមនុស្ស»។ ចូរពិភាក្សាដោយបញ្ជាក់អំណះអំណាងក្នុងរឿងខាងលើ។

### ៥.២.២- លក្ខណៈសម្គាល់ប្រធានបែបពិភាក្សា

គេអាចសម្គាល់បានប្រធានបែបពិភាក្សាតាមលក្ខណៈ៣យ៉ាង៖

- **ស្គាល់តាមរយៈពាក្យបញ្ចេញមតិ ឬយោបល់ ៖**
  - គេពោលថា «.........................................................................................................»
  - មានមតិខ្លះថា «.................................................................................................»
  - អ្នកខ្លះចោទថា«.................................................................................................»
  - គេថា «..............................................................................................................»
  - អ្នកខ្លះបានលើកឡើងថា «...........................»។ តែខ្លះទៀតបែជាលើកឡើងថា............»
  - ..........................................................................................................................

- **ស្គាល់តាមរយៈពាក្យចោទសួរ៖**
  - **ពិភាក្សាសុទ្ធ**
    - ✓តើអ្នកយល់ដូចម្តេចដែរ? តើមតិខាងលើត្រឹមត្រូវឬទេ?
    - ✓តើមតិនោះត្រូវ ឬខុស?
    - ✓តើអ្នកមានយោបល់យ៉ាងណាដែរ?
    - ✓តើជាការត្រឹមត្រូវដែរឬទេ?
  - **ពិភាក្សាប្រៀបធៀប**
    - ✓តើមតិទាំងពីរមួយណាត្រឹមត្រូវជាង?
    - ✓តើមតិទាំងពីរមួយណាសមហេតុផលជាង?
    - ✓តើមតិទាំងពីរមួយណាខុស មួយណាត្រូវ?
    - ✓..............................?

- **ស្គាល់តាមរយៈពាក្យបង្គាប់បញ្ជា៖**
  - ចូរពិភាក្សា..................................................។
  - ចូរពិចារណា.................................................។
  - ចូរវែកញែករកខុស ត្រូវ..................................។
  - ចូររិះគន់វិនិច្ឆ័យ............................................។

### ៥.២.៣- ទម្រង់ទូទៅនៃប្រធានអត្ថាធិប្បាយពិភាក្សា

ក្នុងប្រធានបែបពិភាក្សាអាចប្រព្រឹត្តដូចខាងក្រោម៖

# គម្រោងតែង

(ប្រធានពិភាក្សាសុទ្ធ)

## ក- ផ្តើមសេចក្តី

- **លំនាំបញ្ហា:** ជាការពង្រីកគំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិត ឬខ្លឹមសាររបស់ប្រធាន (មិនបកស្រាយនិងមិនប្រើឧទាហរណ៍)។
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** លើកយកមតិប្រធានមកបញ្ចូលដោយមានឃ្លាភ្ជាប់។ ឧទាហរណ៍: អាស្រ័យហេតុនេះទើបមាន.......................................................................
- **ចំណោទបញ្ហា:** ចោទតាមបែបប្រធានពិភាក្សាដែលមានមតិប្រធានតែមួយ។ ឧទាហរណ៍: តើ...ខាងលើនេះ ត្រឹមត្រូវឬទេ? ឬតើ..............................ត្រឹមត្រូវដែរឬទេ?

## ខ- តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី: ដើម្បីវែកញែក......................................................................
- ពន្យល់ពាក្យ: ពន្យល់ពាក្យពិបាកឬពាក្យគន្លឹះ.........................................................
- ពន្យល់ន័យប្រធាន: ទស្សនៈប្រធានកំណត់ន័យថា.................................................
- បកស្រាយៈ

**មតិស្រប** ជាមតិដែលនិយាយ ឬបកស្រាយឱ្យស្របតាមមតិប្រធាន។ក្នុងការបកស្រាយត្រូវរកហេតុផលឬអំណះអំណាងការពារមតិនោះឱ្យឃើញថាពិតជាត្រឹមត្រូវតាមការយល់ឃើញនោះប្រាកដមែន។ ទោះបីមតិផ្ទាល់ខ្លួនផ្ទុយពីមតិកំពុងបកស្រាយនោះក៏ដោយ ក៏គេនៅតែព្យាយាមការពារគោលជំហរខាងដើមរហូតដល់ទីបញ្ចប់ដែរ។

✓សរុបមតិស្រប

✓សំណួរភ្ជាប់សេចក្តី (បើចាំបាច់)

**មតិផ្ទុយ** ជាមតិដែលនិយាយជំទាស់ទៅលើមតិស្របដែលមតិផ្ទុយឬមតិប្រឆាំងនោះមិនត្រូវឃ្លាតចេញពីទស្សនៈប្រធាន។ ពិសេសត្រូវរកគំនិតសំខាន់ឱ្យឃើញទើបបង្ហាញអំណះអំណាងជាគំនិតសំខាន់លម្អិតនិងឧទាហរណ៍ដើម្បីគាំទ្រ។

✓សរុបមតិផ្ទុយ។

**មតិរួម (សំយោគ ឬពិភាក្សា)** ជាការយល់រួមលេចចេញមកពីទំនាស់រវាងមតិស្របនិងមតិផ្ទុយហើយមតិនេះអាចមានសភាពលក្ខណៈច្រើនយ៉ាងៈ

✓ជួនកាលមតិស្រប ជាមតិត្រឹមត្រូវ(ករណីកម្រ)

✓ជួនកាលមតិផ្ទុយ ជាមតិត្រឹមត្រូវ

✓ជួនកាលមតិស្រប និងមតិផ្ទុយ រួមគ្នាទើបត្រឹមត្រូវ

✓ជួនកាលមតិស្រប និងមតិផ្ទុយមិនទាន់ត្រឹមត្រូវទាំងពីរឬរួមគ្នាហើយមិនទាន់គ្រប់ជ្រុងជ្រោយទៀត ត្រូវបន្ថែមគំនិតដទៃទៀតទើបពេញលេញ។

## គ- បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន:** កំណត់វិនិច្ឆ័យវាយតម្លៃប្រធានខាងលើឱ្យបានត្រឹមត្រូវ(ត្រូវឱ្យស៊ីគ្នាជាមួយការវិនិច្ឆ័យមតិស្របក្នុងមតិរួមផង)។ ឧទាហរណ៍: មតិលើកឡើងខាងលើចាត់ទុកត្រឹមត្រូវ...(បញ្ជាក់ហេតុ: តើបង្ហាញពីអ្វី? តើផ្តល់ការអប់រំ ឬពុទ្ធិអ្វី?)

- **មតិផ្ទាល់ខ្លួន**: ជាគំនិត យោបល់ ឬមតិអ្នកសរសេរតែងសេចក្ដីដែលមានប្រតិកម្មចំពោះគំនិតប្រធានខាងលើក្រោយពីបានបកស្រាយរួចរាល់ហើយ។

## គម្រោងតែង

(ប្រធានពិភាក្សាប្រៀបធៀប)

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា**: ជាការពង្រីកគំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិតឬខ្លឹមសាររបស់ប្រធាន(មិនបកស្រាយនិងមិនប្រើឧទាហរណ៍) ដោយត្រូវមានមតិទាំងពីរ។
- **ចំណូលបញ្ហា(បង្ហាញប្រធាន)** : ជាបញ្ហារបស់ប្រធាន ដែលត្រូវបញ្ចូលផ្សារភ្ជាប់នឹងខ្លឹមសារគំនិត ដែលចងក្រងបានក្នុងលំនាំបញ្ហាដោយត្រូវលើកយកមតិទាំងពីររបស់ប្រធានមកបញ្ចូលនិងប្រើឃ្លាភ្ជាប់ផង។ ឧទាហរណ៍: អាស្រ័យហេតុនេះទើបមានមតិពីរខ្វែងគ្នា ដោយមតិទីមួយថា...។ រីឯមតិទីពីរថា...
- **ចំណោទបញ្ហា**: ចោទតាមបែបប្រធានពិភាក្សាដែលប្រធានមានមតិពីរ។ ឧទាហរណ៍: ប្រធានពិភាក្សាប្រៀបធៀប: តើ...ទាំងពីរខាងលើមួយណាត្រឹមត្រូវជាង?

**ខ- តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី**: ដើម្បីវែកញែកមតិទាំងពីរ...
- **ពន្យល់ពាក្យ**: ពន្យល់ពាក្យពិបាកឬពាក្យគន្លឹះក្នុងមតិទាំងពីរ
- **ពន្យល់ន័យប្រធាន**: ទស្សនៈប្រធានមានមតិពីរខុសគ្នាដោយមតិទីមួយថា«...»ឯមតិទីពីរ យល់ថា«...»
- បកស្រាយៈ
  - **ក- មតិទី១** ជាមតិដែលនិយាយ ឬបកស្រាយឱ្យស្របតាមមតិទីមួយប្រធាន។ ក្នុងការបស្រាយត្រូវរកហេតុផល ឬអំណះអំណាងការពារមតិនោះឱ្យឃើញថាពិតជាត្រឹមត្រូវតាមការយល់ឃើញនោះ ប្រាកដមែន។ ទោះបីមតិផ្ទាល់ខ្លួនផ្ទុយពីមតិកំពុងបកស្រាយនោះក៏ដោយ ក៏គេនៅតែព្យាយាមការពារគោលជំហរខាងដើមរហូតដល់ទីបញ្ចប់ដែរ។
    - ✓ សរុបមតិទី១
    - ✓ សំណួរភ្ជាប់សេចក្ដី (បើចាំបាច់)។
  - **ខ- មតិទី២** ជាមតិដែលនិយាយ ឬបកស្រាយមតិទីពីររបស់ប្រធាន ការបកស្រាយប្រព្រឹត្តទៅដោយរកអំណះអំណាង ការពារមតិទីពីរនោះឱ្យរឹងមាំ។
    - ✓ សរុបមតិទី២។
  - **គ- មតិរួម (សំយោគ ឬពិភាក្សា)** ជាយល់រួមលេចចេញមកពីទំនាស់រវាងមតិទី១ និងមតិទី២ ហើយមតិនេះ អាចមានសភាពលក្ខណៈច្រើនយ៉ាងៈ
    - ✓ ជួនកាលមតិស្រប ជាមតិត្រឹមត្រូវ
    - ✓ ជួនកាលមតិផ្ទុយ ជាមតិត្រឹមត្រូវ
    - ✓ ជួនកាលមតិទី១ និងមតិទី២ រួមគ្នាទើបត្រឹមត្រូវ

✓ ជួនកាលមតិទី១ និងមតិទី២ មិនទាន់ត្រឹមត្រូវទាំងពីរ ឬរួមគ្នាហើយមិនទាន់គ្រប់ជ្រុងជ្រោយទៀត ត្រូវបន្ថែមគំនិតដទៃទៀតទើបពេញលេញ។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: កំណត់វិនិច្ឆ័យវាយតម្លៃប្រធានខាងលើដោយកំណត់យកមតិណាមួយក្នុងចំណោមមតិទាំងពីរ (មតិទី១ មតិទី២) ថាត្រឹមត្រូវជាង... ។ ឧទាហរណ៍: រវាងមតិទាំងពីរខាងលើយើងចាត់ទុកមតិទី...ត្រឹមត្រូវជាង...។ (បញ្ជាក់ហេតុ: តើបង្ហាញពីអ្វី? តើផ្ដល់ការអប់រំ ឬពុទ្ធិអ្វី?)
- **មតិផ្ទាល់ខ្លួន**: ជាគំនិត យោបល់ ឬមតិអ្នកសរសេរតែងសេចក្ដីដែលមានប្រតិកម្មចំពោះគំនិតប្រធានខាងលើ ក្រោយពីបានបកស្រាយរួចរាល់ហើយ។

**កំណត់សម្គាល់**

**ក- សំយោគ** : គឺជាការបូកផ្សំរវាងមតិស្រប (មតិទី១) និងមតិផ្ទុយ(មតិទី២)បំពេញន័យឱ្យគ្នាទៅវិញទៅមកឆ្ពោះទៅរកសច្ចភាព (ការពិត) ដែលប្រធានបានកំណត់។ ***ឧទាហរណ៍:*** រួមសេចក្ដីមក ក្រោយពីឃើញមានមតិពីរខ្វែងគ្នាស្ដីអំពី...មក យើងវិនិច្ឆ័យ...។ បើពិនិត្យលើមតិទី១ចាត់ទុកថា...ដោយ...។ ចំណែកមតិទី២វិញ...ដោយ...។ ជាការពិត...(សច្ចភាព មតិទី១និងមតិទី២)។

**ខ- ពិភាក្សា**: ចំណុចនេះគឺយើងរិះគន់លើមតិណាមួយ ឬមតិទាំងពីរហើយរកសច្ចភាព(ការពិត)ថ្មីមួយដែលប្រធានបានកំណត់។ ***ឧទាហរណ៍:*** រួមសេចក្ដីមក ក្រោយពីឃើញមានមតិពីរខ្វែងគ្នាស្ដីអំពី...មក យើងវិនិច្ឆ័យ។ បើពិនិត្យលើមតិទី១ចាត់ទុកថា...ដោយ...។ ចំណែកមតិទី២វិញ...ដោយ...។ ជាការពិត...(សច្ចភាព=ជួនមតិទី១ត្រូវ ជួនមតិទី២ត្រូវ ជួនមតិថ្មីត្រូវ)។

## ៥.៣- ប្រធានអត្ថាធិប្បាយប្រៀបធៀប

ប្រធានបែបប្រៀបធៀប តម្រូវឱ្យយើងរកឱ្យឃើញលាតត្រដាងពន្យល់បង្ហាញនូវលក្ខណៈដូចគ្នានិងខុសគ្នាទៅលើៈ បញ្ហាពីរ តួអង្គពីរ ទស្សនៈពីរ វត្ថុពីរ សកម្មភាពពីរ ស្នាដៃអក្សរសិល្ប៍ពីរជាដើម។

ឧទាហរណ៍៖

- **ប្រធានទី១**: ចូរប្រៀបធៀបរវាងសេចក្ដីស្នេហារបស់ក្រុងរាពណ៍ចំពោះនាងសីតា និងសេចក្ដីស្នេហារបស់ព្រះរាមចំពោះនាងសីតា។
- **ប្រធានទី២**: តួអង្គព្រះវេស្សន្តរ និងតួអង្គព្រះរាមសុទ្ធតែលះបង់រាជសម្បត្តិយាងចេញទៅបួសក្នុងព្រៃដូចគ្នា។ តើតួអង្គទាំងពីរនេះ មានលក្ខណៈដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?
- **ប្រធានទី៣** : ទាំងនាងសីតា និងទាំងនាងមទ្រីសុទ្ធតែជាតួអង្គគាំទ្រឱ្យឧត្តមគតិព្រះស្វាមី។ តើនារីទាំងពីរខាងលើនេះមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

### ៥.៣.១- ទម្រង់ទូទៅប្រធានអត្ថាធិប្បាយប្រៀបធៀប

## គម្រោងតែង

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា** : ជាការពន្រឹកគំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិត ឬខ្លឹមសាររបស់ប្រធាន។
- **ចំណូលបញ្ហា (បង្ហាញប្រធាន)**: ចំណូលមតិប្រធាននិងមានឃ្លាភ្ជាប់ (ឧទាហរណ៍: អាស្រ័យហេតុនេះទើបប្រធានតម្រូវឱ្យយើងប្រៀបធៀប...។)
- **ចំណោទបញ្ហា**: ចោទតាមបែបប្រធានប្រៀបធៀប។ ឧទាហរណ៍: តើ...ទាំងពីរនេះមានលក្ខណៈដូចគ្នានិងខុសគ្នាត្រង់ណាខ្លះ?
  - ***ចំណុចគួរចៀសវាង:*** ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្ដីចៀសវាងការចោទសួរច្រាសមកវិញនាំឱ្យចាកប្រធាន ឬប្រើពាក្យបង្គាប់បញ្ជាឡើយ។ ឧទាហរណ៍៖
    - តើអ្នកយល់ដូចម្ដេច? ចូរប្រៀបធៀបមតិទាំងពីរ។
    - តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរប្រៀបធៀប។
    - .......................................................................... ។

**ខ- តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី**: ឃ្លាសម្រាប់ជាកិច្ចផ្ដើមដើម្បីភ្ជាប់ពីសេចក្ដីផ្ដើមទៅនឹងការពន្យល់ពាក្យ ឬកន្សោមពាក្យគន្លឹះក្នុងប្រធាន។
- **ពន្យល់ពាក្យគន្លឹះ**: ក្នុងចំណុចនេះ អ្នកធ្វើតែងសេចក្ដីត្រូវស្រង់យកពាក្យ កន្សោមគន្លឹះ ឬឃ្លាដែលជាគន្លឹះនៃប្រធានមកពន្យល់បង្ហាញ ដោយមិនប្រើគូសគ្រេ ឬប្រាប់ថ្នាក់ពាក្យ ដូចពន្យល់ពាក្យធម្មតានោះទេ ហើយក៏មិនត្រូវពន្យល់តាមន័យធម្មតានោះដែរ គឺអាស្រ័យនឹងបរិបទនៃប្រធាន។
- **ពន្យល់ន័យប្រធាន**: ជាការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យឬកន្សោមពាក្យគន្លឹះតាមន័យប្រធានខាងលើឱ្យបានសមស្របតាមបែបប្រធានប្រៀបធៀប។
- **បកស្រាយប្រធាន**: ចំណុចនេះ អ្នកធ្វើតែងសេចក្ដីត្រូវប្រៀបធៀបទៅតាមចំណោទរបស់ប្រធាន ឬបំណងរបស់ប្រធានចង់ដឹង ដោយភ្ជាប់នឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់។

  **ក- លក្ខណៈដូចគ្នា**: អ្នកសរសេរត្រូវបង្ហាញលក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាឱ្យអស់គំនិតដោយដាក់ជារួម ទើបលើកឧទាហរណ៍ម្ដងមួយមកបញ្ជាក់។
  - ✓ សរុបលក្ខណៈដូច: ជាការសរុបឡើងវិញនូវលក្ខណៈដូចគ្នាដែលបានបង្ហាញរួចហើយ។ ឧទាហរណ៍ សរុបសេចក្ដីមកចំណុចខាងលើនេះ ជាលក្ខណៈដូចគ្នានៃ......។

  **ខ- លក្ខណៈខុសគ្នា** : អ្នកសរសេរត្រូវបង្ហាញនូវចំណុចខុសគ្នាដោយលើកយកម្ដងមួយៗហើយភ្ជាប់ឧទាហរណ៍តែម្ដង។ ឧទាហរណ៍៖
  - ✓ សកម្មភាព ឬតួអង្គ«ក» ទាំងគំនិតសំខាន់ និងឧទាហរណ៍ឱ្យពិស្ដារ។
  - ✓ សកម្មភាព ឬតួអង្គ«ខ» ទាំងគំនិតសំខាន់ និងឧទាហរណ៍ឱ្យពិស្ដារ។

✓ **សរុបលក្ខណៈខុស** ជាការសរុបឡើងវិញនូវចំណុចខុសគ្នាដែលបានបង្ហាញរួចហើយ។ ឧទាហរណ៍ សរុបសេចក្ដីមកចំណុចខាងលើនេះ ជាលក្ខណៈខុសគ្នានៃ...។

គ- **សរុបរួម** : ជាការសរុបឡើងវិញនូវលក្ខណៈដូចគ្នានិងខុសគ្នាពីក្នុងបំណកស្រាយខាងលើ និងទាញរកចំណុចពិសេសដោយឡែក ឬទំហៀបផ្ដាច់របស់ផ្នែកណាមួយ ដោយមិនលើកអំណះ អំណាងមកបញ្ជាក់ទេ។

- **ឧទាហរណ៍** : រួមសេចក្ដីមក...ទាំងពីរមានលក្ខណៈដូចគ្នាគឺ...។ ឯលក្ខណៈខុសគ្នាគឺ...។

គ- **បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: ទស្សនៈប្រធានដែលឱ្យប្រៀបធៀបមានខ្លឹមសារល្អដោយបានបង្ហាញ...ទន្ទឹមនោះយើងអាចសន្និដ្ឋានបានថា...។
- **មតិផ្ទាល់ខ្លួន**: ជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកសរសេរតែងសេចក្ដី ចំពោះអង្គទំហៀប និងយោបល់ផ្ទាល់ខ្លួនតាមរយៈការប្រៀបធៀបខាងលើ។

# ៦- ឧទាហរណ៍ប្រធានតែងសេចក្ដី និងគម្រោងតែង

## ៦.១- ប្រធានអត្ថាធិប្បាយពន្យល់

ប្រធានទី១: មានទស្សនៈមួយចែងថា «ការសិក្សាអក្សរសិល្ប៍ គឺសិក្សាពីមនុស្សដើម្បីមនុស្ស»។ ចូរពន្យល់ដោយរកឧទាហរណ៍ក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ។

### គម្រោងតែង

ក- **ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា**: អក្សរសិល្ប៍មានមុខងារសំខាន់ក្នុងការផ្ដល់ចំណេះដឹងឱ្យដល់អ្នកអាន អ្នកសិក្សាឱ្យចេះស្វែងយល់ពីជីវភាពរបស់មនុស្ស ឬសង្គមមនុស្សនៅសម័យកាលណាមួយ។
- **ចំណូលបញ្ហា (បង្ហាញប្រធាន)**: ហេតុដូច្នេះហើយ ទើបមានទស្សនៈមួយចែងថា «ការសិក្សាអក្សរសិល្ប៍ គឺសិក្សាពីមនុស្សដើម្បីមនុស្ស»។
- **ចំណោទបញ្ហា**: តើប្រធានខាងលើមានខ្លឹមសារដូចម្ដេចខ្លះ?

ខ- **តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី**: ដើម្បីជាពន្លឺនៃការបកស្រាយគំនិតប្រធានខាងលើនេះយើងគប្បីស្វែងយល់ន័យរបស់ពាក្យគន្លឹះប្រធានជាមុនសិន។
- ពន្យល់ពាក្យ៖
  - ✓ **អក្សរសិល្ប៍** ជាកម្រងអត្ថបទដែលអ្នកនិពន្ធបង្កើតឡើងប្រកបដោយសិល្បៈវិធី។
  - ✓ **សិក្សាពីមនុស្ស** ជាការសិក្សាពីបញ្ហាទាំងឡាយរបស់មនុស្សដែលតែងជួបប្រទះជាប្រចាំ។
  - ✓ **ដើម្បីមនុស្ស** ជាបំណងក្នុងការអប់រំមនុស្សគ្រប់ស្រទាប់ ដែលជាប្រយោជន៍ដល់សង្គម។
- **ពន្យល់ន័យ** កម្រងអត្ថបទរឿងទាំងអស់បានលើកយកបញ្ហាដែលមនុស្សបានជួបហើយក្នុងគោលបំណងផ្ដល់ជាមេរៀនឬបទពិសោធន៍សម្រាប់ទុកជាឯកសារ។
- **បកស្រាយ**: «ការសិក្សាអក្សរសិល្ប៍ គឺសិក្សាពីមនុស្សដើម្បីមនុស្ស»៖

- **គំនិតសំខាន់៖**

ក- សិក្សាអក្សរសិល្ប៍គឺសិក្សាពី៖

- ✓ ជីវភាពមនុស្សក្នុងសម័យកាលណាមួយ
- ✓ របៀបរស់នៅរបស់មនុស្ស
- ✓ សកម្មភាពតស៊ូរបស់មនុស្ស
- ✓ ការព្យាយាមរបស់មនុស្ស
- ✓ ..............................។

ខ- ដើម្បីមនុស្ស គឺអប់រំបណ្ដុះបណ្ដាលដើម្បីប្រយោជន៍មនុស្សក្នុងសង្គម

- ✓ ផ្ដល់ចំណេះដឹង
- ✓ បំណិនវិជ្ជាជីវៈ
- ✓ រៀបចំខ្លួន
- ✓ ចេះរួមរស់ជាមួយគ្នាក្នុងសង្គម
- ✓ ឱ្យចេះពិចារណា
- ✓ ឱ្យមានការទទួលខុសត្រូវ
- ✓ ចេះតស៊ូ
- ✓ បណ្ដុះកំហឹងឈឺចាប់ចំពោះការជិះជាន់
- ✓ ហ៊ានធ្វើពលិកម្មគ្រប់យ៉ាង ដើម្បីប្រយោជន៍រួម
- ✓ ..................។

- **ឧទាហរណ៍៖**

**ក- រឿងទុំទាវ**

- ✓ ដោយសារតែសេចក្ដីស្នេហា (ដើម្បីឱ្យមើលឃើញថា សេចក្ដីស្នេហាអាចធ្វើឱ្យមនុស្សបោះបង់កិត្តិយស ឬពីប្រពៃណីជាតិ)នាងទាវមិនបានគិតដល់ពិធីចូលម្លប់ ដែលខ្លួនកំពុងបំពេញនោះឡើយ នាងបានទទួលទុំចំពេលដែលម្ដាយនាងមិននៅ។
- ✓ នាងហ៊ានចេញមុខប្រឆាំងនឹងម្ដាយនាងដែលបង្ខំឱ្យព្រមរៀបការជាមួយម៉ឺនងួន (ដើម្បីឱ្យចេះទាមទារសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករសម្រាប់អនាគតខ្លួន)។
- ✓ (ដើម្បីឱ្យហ៊ានទទួលស្គាល់ការពិតនិងបញ្ជាក់ពីចិត្តស្មោះរវាងគ្នានឹងគ្នា) នៅចំពោះមុខព្រះរាជាទុំទាវហ៊ាននិយាយការពិតពីប្រវត្តិស្នេហ៍អ្នកទាំងពីរ។
- ✓ (ដើម្បីបង្ហាញពីការគ្រប់គ្រងក្នុងសម័យកាលលង្វែកដែលអនុវត្តអំណាចផ្ដាច់ការតាំងពីថ្នាក់លើរហូតដល់មូលដ្ឋាន) ទុំនិងទាវហ៊ានបូជាអាយុជីវិតរបស់ខ្លួន ដោយឥតស្ដាយស្រណោះ។

**ខ- រឿងរាមកេរ្តិ៍**

- ✓ (អប់រំឱ្យចេះអធ្យាស្រ័យគ្នាទៅវិញទៅមក) សេចក្ដីលោភលន់របស់នាងកៃកេសីបានជំរុញព្រះបាទទសរថប្រព្រឹត្តផ្ទុយពីប្រពៃណីក្សត្រដោយឱ្យព្រះភិរុតដែលកូនប្អូនសោយរាជ្យមុនកូនបងនាំឱ្យគ្រួសារបែកបាក់ធ្វើឱ្យព្រះរាម សីតា ព្រះលក្ស្មណ៍ត្រូវចាកចេញពីនគរ ហើយព្រះបាទទសរថឈឺចាប់រហូតសុគត។

- (ដើម្បីសុភមង្គល និងសន្តិភាពដោយការបញ្ចៀសសង្គ្រាម) ធ្វើសម្បទាននូវរាជបល្ល័ង្ករបស់ព្រះរាមចំពោះព្រះភិរុតជាពលិកម្មដ៏ឧត្តុង្គឧត្តមជាប្រយោជន៍ដល់គ្រួសារនិងសង្គម (ដើម្បីសុភមង្គល និងសន្តិភាពដោយការបញ្ចៀសសង្គ្រាម)។
- (ដើម្បីឱ្យចេះប្រកាន់យកពាក្យសត្យដែលជាតម្លៃរបស់មនុស្ស) ព្រះរាមមិនវិលចូលនគរវិញតាមការយាងរបស់នាងកៃកេសីមុនកំណត់នោះទេ។
- (ដើម្បីស្គាល់បំណងមនុស្សអាក្រក់ដែលតែងតែឈ្នានីសព្យាបាទអ្នកដទៃ) ដោយខ្លួនខកបំណងមិនបានសម្រេចក្នុងការចៃចង់សុំសេចក្តីស្នេហាពីព្រះរាមព្រះលក្ស្មណ៍នាង សូរបនខាបានប្រើវិធីញុះញង់ក្រុងរាពណ៍ជាបងឱ្យមានចិត្តស្រឡាញ់ និងមកចាប់នាងសីតាដែលបង្កជាសង្គ្រាម។
- (ដើម្បីឱ្យចេះស្រាយទំនាស់រវាងបងប្អូនខ្លួនមិនគប្បីយកអ្នកក្រៅ មកដោះស្រាយឱ្យនោះទេ)។ ជម្លោះរវាងពាលីនិងសុគ្រីពត្រូវព្រះរាមបំបែកបំបាក់។
- (ដើម្បីស្គាល់ពីធាតុពិតនៃមហិច្ឆតាមនុស្សអាក្រក់) ព្រះរាមបានប្រើល្បិចឱ្យមហាជម្ពូយល់ព្រមជួយកងទ័ពក្នុងការធ្វើសង្គ្រាម។
- (ដើម្បីស្គាល់ពីយុទ្ធវិធីក្នុងការគ្រប់គ្រងនិងដឹកនាំ) ព្រះរាមបញ្ចុះបញ្ចូលឬបញ្ចើចបញ្ចើដោយផ្តល់រង្វាន់ឱ្យហនុមាន គឺផ្តល់ដល់ជាបុណ្យសក្តិឱ្យពិភេកដែលបានចុះចូលខាងខ្លួនហើយក៏អន្ទងលួងលោមកុម្ភកាណ៌ឱ្យស្ម័គ្រចិត្តខាងខ្លួន។
- ក្រុងរាពណ៍ឱ្យសេនាខ្លួនទៅយាមព្រៃមិនឱ្យទ័ពស្វាចូលបេះផ្លែឈើស៊ីបាន និងយកនាងសីតា ហោះឡើងលើអាកាស (ដើម្បីចេះប្រើយុទ្ធវិធីក្នុងធ្វើការសង្គ្រាមផ្តាច់ស្បៀង សង្គ្រាមចិត្តសាស្ត្រ)។
- ជម្លោះរវាងព្រះរាមនិងមហេសីដោយការប្រច័ណ្ឌនាងសីតា ជាមួយក្រុងរាពណ៍ព្រះរាមលែងស្គាល់ខុសលែងស្គាល់ត្រូវមិនព្រមស្តាប់តាមការពិតដែលសីតាព្យាយាមបកស្រាយ (ដើម្បីបញ្ជាក់ថាសេចក្តីស្រឡាញ់ដ៏លើសលុបអាចបង្កជាអំពើហិង្សា)។
- ទោះបីក្រុងរាពណ៍ខុសឆ្គងយ៉ាងណាក៏ដោយ ក៏កុម្ភកាណ៌នៅតែមានចិត្តស្មោះត្រង់ចំពោះក្រុងរាពណ៍ហើយទោះបីព្រះរាមផ្តល់រង្វាន់ និងបុណ្យសក្តិយ៉ាងណាក៏ដោយ ក៏កុម្ភកាណ៌នៅតែស្មោះត្រង់ធ្វើសង្គ្រាមរហូតបាត់បង់ជីវិត (ដើម្បីឱ្យចេះគិតដល់ផលប្រយោជន៍រួមជាធំមិនក្បត់ជាតិខ្លួន ដើម្បីអំណាចនោះឡើយ)។

**គ- រឿងភូមិតិរច្ឆាន**

- ជួន នៅ អ្នកក្លាហានម្តៃនាក់និងប្រជាជនភូមិក្រាំងលាវបានរួមដៃគ្នា កម្ចាត់រ៉េស៊ីដង់បារាំងបារដេសរហូតបានសម្រេច (ដើម្បីឱ្យមើលឃើញថា សាមគ្គីភាព ឯកភាពគ្នា ជាកត្តានាំមកនូវជ័យជម្នះធ្វើឱ្យបានសម្រេចគ្រប់កិច្ចការ)។
- ក្រោយពីរ៉េស៊ីដង់បារាំងឈ្មោះបារដេសត្រូវស្លាប់រាជការបារាំងក៏កាត់ទោសអ្នកក្រាំងលាវតម្រូវឱ្យប្តូរឈ្មោះភូមិក្រាំងលាវទៅជាភូមិតិរច្ឆានវិញ ហើយក្រុមអ្នកតស៊ូត្រូវសម្លាប់និងចាប់ដាក់គុក (ដើម្បីឆ្លុះបញ្ចាំងពីសារជាតិអាណានិគមនិយម ដែលតែងតែគាបសង្កត់ បំបាក់ស្មារតីប្រជារាស្ត្រក្រោមបង្គាប់ក្នុងការទាមទារសិទ្ធិសេរីភាព)។

- **សរុប:** ដូច្នេះ ការសិក្សាអក្សរសិល្ប៍ពិតជាសិក្សាពីមនុស្សនៅសម័យកាលណាមួយ និងដើម្បីអប់រំមនុស្សគ្រប់រូបឱ្យចេះស្វែងយល់ពីការពិត និងប្រកាន់យកសេចក្តីល្អមកអនុវត្តជាប្រយោជន៍ក្នុងការរស់នៅរបស់ខ្លួនពិតប្រាកដមែន។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន:** ទស្សនៈប្រធានបានបង្កប់អប់រំដល់អ្នកសិក្សា អ្នកអាន ព្រោះឱ្យស្គាល់ពីបញ្ហាមនុស្សគ្រប់យ៉ាងដែលឆ្លុះបញ្ចាំងតាមរយៈស្នាដៃអក្សរសិល្ប៍ក្នុងគោលបំណងអប់រំ។
- **មតិផ្ទាល់ខ្លួន :** ក្នុងនាមជាអ្នកសិក្សា យើងគប្បីចេះស្វែងយល់បញ្ហាសំខាន់ៗដែលបានបង្ហាញតាមរយៈអក្សរសិល្ប៍ដើម្បីដកស្រង់បទពិសោធល្អៗ តាមរយៈតួអង្គក្នុងស្នាដៃនោះ មកអនុវត្តក្នុងជីវភាពជាក់ស្តែងជាប្រយោជន៍ក្នុងការរស់នៅ។

❖ **កំណត់សម្គាល់៖**

**របៀបទី១ :** បង្ហាញគំនិតសំខាន់ទាំងអស់ដោយភ្ជាប់ឧទាហរណ៍គាំទ្រដោយលើកពីសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍ (តាមបម្រាប់ប្រធាន)។

**របៀបទី២ :** លើកគំនិតសំខាន់ម្តងមួយៗដោយភ្ជាប់ឧទាហរណ៍ គាំទ្រដោយលើកពីសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍ (តាមបម្រាប់ប្រធាន)។

**ប្រធានទី២ :** តាមអ្នកសិក្សាបានបញ្ជាក់ថា«ស្ត្រីជាកម្លាំងចលករក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិ»។ ចូរបកស្រាយដោយរកឧទាហរណ៍ក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា:** បើតាមលក្ខណៈជាតិខ្មែរតែងគោរពនិងឱ្យតម្លៃទៅលើរបបមាតាធិបតេយ្យ ដែលនិយមឱ្យតម្លៃទៅលើស្ត្រីជាធំហើយបានប្រកាន់តាំងពីដើមរៀងមកម្ល៉េះ។
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** ដោយផ្អែកទៅតាមលក្ខណៈជាតិដូចខាងលើនេះហើយ ទើបមានអ្នកសិក្សាបានបញ្ជាក់ថា«ស្ត្រីជាកម្លាំងចលករ ក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិ»។
- **ចំណោទបញ្ហា:** តើទស្សនៈខាងលើនេះ មានអត្ថន័យយ៉ាងណាខ្លះ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់:** ដើម្បីរួមចំណែកដល់ការបកស្រាយគំនិតប្រធានខាងលើនេះយើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះដែលមាននៅក្នុងប្រធានជាមុនសិន។
- **ពន្យល់ពាក្យ៖**
  - ✓ **កម្លាំងចលករ** គឺជាកម្លាំងដ៏ចាំបាច់ មិនអាចខ្វះបានក្នុងដំណាក់កាលនីមួយៗ។
  - ✓ **អភិវឌ្ឍ** ធ្វើឱ្យរីកចម្រើន រុងរឿង ឬជឿនលឿន។
- **ពន្យល់ន័យ :** មានន័យថា ស្ត្រីឬនារី គឺជាកម្លាំងដ៏ចាំបាច់ដែលមិនអាចខ្វះបាន ក្នុងការរួមចំណែកកសាងសង្គមឱ្យរីកចម្រើន
- **បកស្រាយ:** «ស្ត្រីជាកម្លាំងចលករ ក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិ» ព្រោះស្ត្រី ៖
  **គំនិតសំខាន់៖**
  - ✓ ជាអ្នកគ្រប់គ្រងសេដ្ឋកិច្ចក្នុងគ្រួសារ

- មើលថែទាំកូនចៅ និងទ្រព្យសម្បត្តិ
- ពូកែច្នៃប្រឌិតកិច្ចការគ្រប់យ៉ាងឱ្យមានភាពល្អប្រសើរ
- ជាអ្នកជួយយិតយោងកិត្តិយសគ្រួសារ
- ជាអ្នកគ្រប់គ្រងដែលស្គាល់ពីអ្នកនៅក្រោមបង្គាប់ច្បាស់លាស់
- ក្នុងព្រលឹងជាតិខ្មែរ និយមគោរពរបបមាតាធិបតេយ្យ។

**ឧទាហរណ៍៖**

**ក- ក្នុងសង្គម** គេតែងសង្កេតឃើញស្ត្រីបានឈានចូលទៅក្នុងគ្រប់វិស័យនានារបស់សង្គមជាតិ ដែលមានសិទ្ធិសេរីភាពគ្រប់យ៉ាងក្នុងការរស់នៅ។

- ចំពោះគ្រួសារ គឺស្ត្រីជាមាតាដ៏ល្អ ដែលបានរក្សាកូនតាំងពីនៅពពោះរហូតដល់កូនធំពេញវ័យ។ ទោះបីឆ្លងកាត់ការលំបាកយ៉ាងណាក៏ដោយ ក៏មាតានៅតែព្យាយាមការពារកូន ព្យាបាលកូនចិញ្ចឹមកូន ពុំដែលមានភាពត្អូញត្អែរដែរ។ ដោយសារតែលោក កូនមានសុខភាពល្អ មានអនាគតល្អ។ គាត់ជាប្រពន្ធល្អដែលចេះរៀបចំទុកដាក់ផ្ទះសម្បែង ផ្គត់ផ្គង់ម្ហូបអាហារដែលធ្វើឱ្យជីវភាពគ្រួសារមានភាពរីកចម្រើន។ មិនតែប៉ុណ្ណោះ ក្នុងនាមជាប្រពន្ធ គាត់ក៏បានលើកកិត្តិយសស្វាមីដោយជំរុញទឹកចិត្តឱ្យដល់ប្តីឱ្យមានអារម្មណ៍ល្អក្នុងការបំពេញការងារ។
- ចំពោះសង្គមវិញស្ត្រីមានតួនាទីសំខាន់ក្នុងការចូលរួមអភិវឌ្ឍភូមិឃុំ គឺជាក្រុមប្រឹក្សាភូមិឃុំ ជាអ្នកតំណាងរាស្ត្រ ជាគ្រូបង្រៀន សាស្ត្រាចារ្យ បណ្ឌិត កវីនិពន្ធជាដើម។ ទាំងនេះជាភស្តុតាងបញ្ជាក់ថា ស្ត្រីមិនត្រឹមតែជាមាតាដ៏ល្អ ភរិយាដ៏ល្អ និងជាកូនដ៏ល្អប៉ុណ្ណោះទេ តែស្ត្រីក៏ជាអ្នកឈានមុខក្នុងការគ្រប់គ្រងដឹកនាំ ឬជាអ្នកធានានិរន្តភាព ស្ថិរភាពសង្គម ទាំងសេដ្ឋកិច្ចទាំងនយោបាយទៀតផង។
- ចំពោះផ្នត់គំនិតសង្គមខ្មែរយើងបានកំណត់ ឬឱ្យតម្លៃទៅលើស្ត្រីជាអ្នកនាំមុខក្នុងរក្សាសុភមង្គល ឬនិមិត្តរូបនៃកិត្តិយសដូចជាលោកបានចងក្រងជាសុភាសិត«សំណាបយោងដី ស្រីយោងប្រុស» ឬក៏«សម្លឆ្ងាញ់ត្បិតគ្រឿង ស្វាមីរុងរឿងត្បិតឧត្តមភរិយា»។ ទន្ទឹមនឹងនេះ ខ្មែរយើងតែងតែបញ្ញត្តិអ្វីដែលធំជាងគេហៅមេ ដូចមេដៃ មេចោរ មេខ្យល់ មេទ្វារជាដើម។ រីឯពាក្យនាំមុខខ្មែរយើងបានយកភេទស្រីដាក់មុខមុនភេទប្រុស ដូចជាជីដូនជីតា មាតាបិតា អ្នកដូនអ្នកតា មីងមាជាដើម។

**ខ- ក្នុងប្រវត្តិសាស្ត្រ៖**

- ព្រះនាងលីវយីជាស្ត្រីនាំមុខនៃប្រវត្តិសាស្ត្រខ្មែរ គឺមានទឹកដី មានប្រជារាស្ត្រ មានមុខរបរតាំងពីមុនពេលព្រះបាទហ៊ុនទៀនយាងមកដល់នគរគោកធ្លកនេះមកម្ល៉េះ។ មានន័យថាខ្មែរយើងសម័យនោះចេះប្រកបរបរចិញ្ចឹមជីវិតអាចទំនាក់ទំនងគ្នាតាមរយៈភាសា ឬក៏មានសកម្មភាពដទៃទៀត ដែលទាក់ទងទៅនឹងវប្បធម៌ជាតិខ្មែរ។
- ព្រះនាងឥន្ទ្រទេវី ក៏ជានារីឆ្នើមពោរពេញទៅដោយ ចំណេះដឹងទាំងខាងព្រះពុទ្ធសាសនា និងទាំងខាងភាសាសំស្ក្រឹតមិនតែប៉ុណ្ណោះព្រះនាងបានចូលរួមជួយបំពេញរាជកិច្ចដល់ព្រះបាទជ័យវរ្ម័នទី៧នោះទៀតផង។

**គ- ក្នុងអក្សរសិល្ប៍:** រឿងតេជោយ៉ត បានបង្ហាញឱ្យឃើញពីតួនាទីស្ត្រី ដែលមាននៅក្នុងសង្គម គឺបានចូលរួមយ៉ាងសកម្មដើម្បីកម្ចាត់សត្រូវនឹងព្រះនគរ។ ជាក់ស្តែងជំទាវស្រែនបានធានា

ចាប់ស្តេចសំរៃដែលមានបំណងបះបោរ ដណ្តើមរាជពីព្រះចៅជ័យចេស្តា។ ដោយនាងប្រើតែល្បិចកលបន្តិចបន្តួចក៏អាចធ្វើឱ្យស្តេចសំរៃធ្លាក់ទៅក្នុងឧបាយកលរបស់នាងយ៉ាងងាយ ហើយទុកឱកាសឱ្យតេជោមាសនិងតេជោយ៉តចាប់យកទៅកាត់ទោសបានដូចបំណង។

ឃ- **រឿងភូមិរឆ្លាន:** នាងនី នាងបី មានសេចក្តីក្លាហានក្នុងគោលបំណងចង់បានសិទ្ធិសេរីភាពពីបារដេស ដែលបានប្រើអំណាចឃោរឃៅមកលើអ្នកជាប់ពន្ធ ដូចជាវាយដំ ទាត់ធាក់បង្អត់បាយ ដាក់ខ្នោះរហូតបង្កើនទឹកចិត្តក្លាហានរបស់ក្រុមអ្នកតស៊ូនៅក្រាំងលាវរហូតកម្ចាត់បារដេសបានដូចបំណង។

- **សរុប:** ដូច្នេះ ស្ត្រីពិតជាកម្លាំងចលករក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិប្រាកដមែនបើគ្មានស្ត្រីទេ សង្គមមិនអាចរីកចម្រើនបានឡើយ។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន:** ទស្សនៈប្រធានមានអត្ថន័យជ្រាលជ្រៅ ព្រោះបានអប់រំឱ្យយើងទទួលស្គាល់សមត្ថភាពស្ត្រីដែលតែងតែចូលរួមយ៉ាងសកម្មក្នុងការរួម ចំណែកកសាងសង្គមជាតិឱ្យរីកចម្រើជាលំដាប់។
- **មតិផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមជាអ្នកសិក្សាយើងគប្បីចេះលើកតម្លៃស្ត្រីឱ្យសមស្របទៅនឹងចរន្តសង្គម ដែលតែងតែគោរពយេនឌ័រគ្រប់សកម្មភាពសង្គម និងគ្រប់វិស័យក្នុងស្ថាប័ននានានោះទើបយើងមានឈ្មោះថាជាពលរដ្ឋល្អ ឬសង្គមនីតិរដ្ឋពិតៗ។

---

**ប្រធានទី២:** មានទស្សនៈមួយចែងថា « សុខដុមរមនា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខេមរនិយម ពុទ្ធនិយម និងព្រាហ្មណ៍និយម»។ ចូរពន្យល់ ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខាងលើមកបញ្ជាក់។

---

## គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា :** ភាពសុខសាន្តនិងសេចក្តីរីករាយ គឺជាបំណងប្រាថ្នារបស់បុគ្គលនីមួយៗដែលនាំមកនូវបរិយាកាស ស្ងប់ស្ងាត់គ្មានទំនាស់ ឬសង្គ្រាម ក្នុងគ្រួសារ និងសង្គមជាតិ។
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** ដោយមើលឃើញនិងបានយល់ពីគុណសម្បត្តិនៃភាពសុខសាន្តនិងរីករាយដូចខាងលើនេះហើយ ទើបមានទស្សនៈមួយចែងថា « សុខដុមរមនា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខេមរនិយម ពុទ្ធនិយម និងព្រាហ្មណ៍និយម»។
- **ចំណោទបញ្ហា:** តើអក្សរសិល្ប៍ខាងលើនេះ បានបង្ហាញពីសុខដុមរមនាយ៉ាងណាខ្លះ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើនេះយើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។
- **ពន្យល់ពាក្យ៖**
  - ✓ សុខដុមរមនា ការរស់នៅផ្តុំគ្នា ឬនៅមូលគ្នាសុខសប្បាយ ឬរីករាយសុខស្រួលជាមួយគ្នា។
  - ✓ អក្សរសិល្ប៍ខេមរនិយម ជាអក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងពីសង្គមខ្មែរ វប្បធម៌ខ្មែរ ឬពីជីវភាពរាស្ត្រខ្មែរ។

✓ អក្សរសិល្ប៍ពុទ្ធនិយម ជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។
✓ អក្សរសិល្ប៍ព្រាហ្មណ៍និយម ជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា។

- **ពន្យល់ន័យ:** មានន័យថាសេចក្តីសុខសប្បាយឬភាពសុខសាន្តត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខ្មែរ ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនានិងព្រាហ្មណ៍សាសនា។
- **បកស្រាយ:** «សុខដុមរមនា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខេមរនិយមពុទ្ធនិយម និងព្រាហ្មណ៍និយម»ព្រោះអក្សរសិល្ប៍៖

❖ ***គំនិតសំខាន់៖***

✓ តែងតែបង្កប់គំនិតអប់រំតាមរយៈតួអង្គក្នុងរឿង
✓ គោលបំណងអ្នកនិពន្ធគឺចង់បណ្តុះស្មារតីអ្នកអានឱ្យចេះរស់នៅក្នុងភាពសុខសាន្ត
✓ បានបង្ហាញផលអាក្រក់នៃអំពើរបស់តួអង្គដែលបានប្រព្រឹត្ត
✓ ឱ្យចេះយោគយល់ សន្តោសប្រណី អធ្យាស្រ័យ គោរពសិទ្ធិ
✓ មិនឱ្យប្រមាថជីវិតសត្វ មនុស្ស ឬប្រើអំពើហិង្សា
✓ ឱ្យចេះចែករំលែកទ្រព្យធន ដល់ជនទុរគត
✓ ឱ្យមានសុទិដ្ឋិនិយមក្នុងជីវិត តស៊ូជឿជាក់លើសមត្ថភាពខ្លួន។

- **ឧទាហរណ៍៖**

ក- **អក្សរសិល្ប៍ខេមរនិយម** បានបង្ហាញឱ្យឃើញពីភាពសុខដុមរមនាតាមរយៈរឿងទុំទាវ។ តួយ៉ាងក្រោយពីព្រះរាជាទ្រង់ជ្រាបថា ទុំនិងទាវជាសង្សារនិងគ្នាព្រះអង្គក៏រំងាប់ព្រះទ័យលើកលែងទោសឱ្យទុំនិងទាវ ជាពិសេសបានរៀបចំមង្គលការឱ្យអ្នកទាំងពីររួមរស់ជាប្តីប្រពន្ធប្រកបដោយភាពសុខសាន្តទៀតផង។ ចំណុចនេះបញ្ជាក់ថាព្រះអង្គជាក្សត្រ ដែលមានទសពិធរាជធម៌ អាណិតអាសូររាស្ត្រដែលធ្វើឱ្យរាស្ត្រកំពុងមានវិបត្តិ មានសេចក្តីរីករាយ ក្រោមព្រះទ័យដ៏ល្អបែបនេះគឺ«ទឹកត្រជាក់ត្រីកុំ»។

ខ- **អក្សរសិល្ប៍ពុទ្ធនិយម៖**

✓ **រឿងព្រះវេស្សន្តរ** ទោះបីព្រះអង្គត្រូវពួកអ្នកស្រុកស្រីពិរាស្ត្របំបរបង់ចេញពីនគរ ដោយសារតែទ្រង់ដាក់ទានដំរីបច្ច័យនាគេន្ទ្រឱ្យទៅពួកព្រាហ្មណ៍នៅកលិង្គរាស្ត្រក៏ព្រះវេស្សន្តរមិនទោមនស្សចំពោះពួកគេដែរ។ ព្រះអង្គចាកចេញដោយព្រះទ័យស្ងប់ ឆ្ពោះទៅរកគិរីវង្កតដើម្បីសាងផ្នួសស្វែងរកធម៌។ ឥរិយាបថរបស់ទ្រង់បែបនេះ បាននាំមកនូវបរិយាកាសក្នុងភាពសុខសាន្តទាំងអ្នកស្រុកស្រីពិរាស្ត្រ ទាំងព្រះបាទស្រីសញ្ជ័យ នាងសុបារសុប្បតី ជាបិតាមាតា គឺនគរមានសន្តិភាព។ ដោយសារតែស្ថិតក្នុងបរិយាកាសនេះដែរ ក៏បានជំរុញឱ្យពួកអ្នកស្រុកស្រីពិរាស្ត្រ ចេះពិចារណាយល់ពីបំណងរបស់ព្រះវេស្សន្តរដែលបានធ្វើកន្លងមក មានធនបរិច្ចាគ អង្គបរិច្ចាគ ជីវិតបរិច្ចាគ បុត្តបរិច្ចាគ និងភរិយាបរិច្ចាគ ដើម្បីត្រាស់ដឹងនាពេលអនាគតជួយស្រោចស្រង់សត្វលោកឱ្យរួចផុតពីអវិជ្ជាឬសេចក្តីល្ងង់ខ្លៅ។ យ៉ាងនេះហើយបានចរន្តពិភពលោកតែងតែអនុវត្តតាមគោលការណ៍ពុទ្ធនិយមនេះក្នុងបំណងស្វែងរកមិត្តកាត់បន្ថយសត្រូវឬជៀសវាងសង្គ្រាម ដើម្បីភាពសុខសាន្តនៃមនុស្សទូទៅ។

✓ **រឿងសុវណ្ណសាម** ព្រះអង្គមិនត្រឹមតែមិនយកទោសកំហុសចំពោះបិលយក្ខ ដែលបានលបបាញ់ប្រហារមកលើព្រះអង្គនោះទេ ថែមទាំងនិយាយអង្វរករផ្អែមល្ហែមធ្វើឱ្យបិល

យក្ខមានក្តីរំភើបចេញសារភាពទទួលខុសត្រូវនូវអំពើដែលខ្លួនបានធ្វើមកលើសុវណ្ណសាមនោះទៀតផង។ មាននន័យថារឿងនេះបានអប់រំដល់មនុស្សគ្រប់រូបមិនឱ្យយកកំហឹង ឬប្រើអំពើហិង្សាជាជាងប្រើសន្តិវិធីដើម្បីភាពសុខសាន្ត ឬធ្វើឱ្យអ្នកប្រព្រឹត្តខុសចេះស្តាល់កំហុសឈប់ប្រព្រឹត្តតទៅទៀត។

**គ- អក្សរសិល្ប៍ព្រាហ្មណ៍និយម** រឿងរាមកេរ្តិ៍ បានបង្ហាញពីភាពសុដុមរមនានៃតួអង្គព្រះរាមដែលបានធ្វើសម្បទានឬលះបង់រាជ្យបល្ល័ង្ក ទោះបីព្រះអង្គមានសិទ្ធិស្របច្បាប់ទៅតាមប្រពៃណីក្សត្រយ៉ាងណាក៏ដោយ ក៏ព្រះអង្គសុខចិត្តធ្វើតាមសំណូមពរនាងកៃកេសីដែរ។ មានន័យថា ទ្រង់បានចេញសាងផ្នួស១៤ឆ្នាំដើម្បីទុករាជ្យសម្បត្តិឱ្យព្រះភិរុតឡើងគ្រងរាជ្យ។ ប្រការនេះគឺជាការបញ្ជាក់ពីគោលជំហរដែលព្រះអង្គចង់បានសន្តិភាពឬសុភមង្គលជូនរាជវង្សនិងប្រជារាស្ត្រ។ ចំណុចនេះ គឺជាបំណងប្រាថ្នារបស់បិតាទ្រង់ដែលចង់ឃើញបុត្រដ៏ល្អ ពោរពេញទៅដោយកតញ្ញូចំពោះអ្នកមានគុណជាម្ចាស់បងដ៏ល្អដែលហ៊ានលះបង់អ្វីៗគ្រប់យ៉ាងដើម្បីប្អូនឬជាអ្នកដឹកនាំដ៏ល្អពោរពេញទៅដោយទសពិធរាជធម៌ចំពោះប្រជារាស្ត្រ។

- **សរុប**: ដូច្នេះភាពសុខដុមរមនាពិតជាត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខេមរនិយមពុទ្ធនិយម និងព្រាហ្មណ៍និយមប្រាកដមែន។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន**: គំនិតប្រធានមានអត្ថន័យសំខាន់ក្នុងការបណ្តុះស្មារតីអ្នកសិក្សា អ្នកអានឱ្យស្គាល់តម្លៃនៃសេចក្តីសុខក្សេមក្សាន្តដែលចាំបាច់ត្រូវតែមានក្នុងគ្រួសារក្តីនិងសង្គមជាតិក្តី។
- **មតិផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមជាយុវជនខ្មែរ យើងគប្បីចេះរួបរួមសាមគ្គីគ្នាដោយភាពស្មោះត្រង់ជាពិសេសត្រូវចេះរស់នៅប្រកបដោយភាពសុខសាន្ត យោគយល់អធ្យាស្រ័យគ្នា មិនបំពារបំពាន ឬប្រមាថមើលងាយគ្នាទៅវិញទៅមកនោះឡើយ។

---

**ប្រធានទី៣**: ពាក្យទូន្មានមួយឃ្លាពោលថា « កូនកាចបំពេញទុក្ខ ម្តាយឪពុកព្រួយបារម្ភកូនស្លូតចេះគួរសម មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ»។ ចូរពន្យល់ ដោយឆ្លុះបញ្ចាំងតាមរយៈសង្គម និងអក្សរសិល្ប៍ដែលអ្នកធ្លាប់បានសិក្សាកន្លងមក។

---

## គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា**: ការចិញ្ចឹមបីបាច់ថែរក្សាកូនជាបន្ទុករបស់មាតាបិតាដើម្បីឱ្យកូនប្រុសកូនស្រីឆ្ពោះទៅរកអនាគតមួយដ៏ភ្លឺស្វាងនិងត្រចះត្រចង់ ប៉ុន្តែបើកូនណាមួយមិនបានប្រតិបត្តិក្នុងផ្លូវគន្លងធម៌នោះទេ មាតាបិតានឹងឈឺចាប់អស់មួយជីវិត។
- **ចំណូលបញ្ហា (បង្ហាញប្រធានបទ)**: ដោយមានបំណងឆ្លុះបញ្ចាំងពីគុណធម៌មាតាបិតាដូចខាងលើនេះហើយ ទើបមានពាក្យអប់រំបុរាណខ្មែរមួយឃ្លាពោលថា «កូនកាចបំពេញទុក្ខ ម្តាយឪពុកព្រួយបារម្ភ កូនស្លូតចេះគួរសម មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ»។
- **ចំណោទបញ្ហា**: តើកូនកាច និងកូនស្លូតនោះ សំដៅទៅលើកូនបែបណា?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីជាគុណប្រយោជន៍ដល់ការបកស្រាយគំនិតប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះ...។
- **ពន្យល់ពាក្យ៖**
  - ✓ កូនកាច ជាកូនមិនប្រកបដោយគន្លងធម៌ តែងតែផ្តល់ការលំបាកគ្រប់យ៉ាងដល់ឪពុកម្តាយ
  - ✓ បំពេញទុក្ខ ជាការបង្កឱ្យមានការលំបាកគ្រប់យ៉ាង មិនចេះឈប់ឈរ
  - ✓ កូនស្លូត ជាកូនដែលចេះដឹងគុណ គោរពឪពុកម្តាយ ប្រកបដោយគន្លងធម៌
  - ✓ ថ្កុំថ្កើងកេរ្តិ៍ឈ្មោះ គឺធ្វើឱ្យកិត្តិយសល្បីរន្ទឺ សុសសាយ រុងរឿង។
- **ពន្យល់ន័យ**: មានន័យថាកូនមិនប្រកបដោយគន្លងធម៌ តែងតែនាំមកការលំបាកគ្រប់យ៉ាងដល់ឪពុកម្តាយ។ រីឯកូនប្រកបដោយកតញ្ញូចេះដឹងគុណគោរពឪពុកម្តាយតែងតែនាំមកនូវភាពរុងរឿង ឬសេចក្តីថ្លៃថ្នូរជូនដល់គ្រួសារ។
- **បកស្រាយ៖**

  **ក- «កូនកាចបំពេញទុក្ខ ម្តាយឪពុកព្រួយបារម្ភ»ព្រោះកូនកាច ជាកូនដែល៖**

  - **គំនិតសំខាន់៖**
    - ✓ មិនស្តាប់តាមដំបូន្មានឪពុកម្តាយ
    - ✓ តែងធ្វើឱ្យឪពុកម្តាយមានកង្វល់
    - ✓ បង្កើតបញ្ហាមិនឈប់ឈរ
    - ✓ នាំមកនូវភាពអាប់ឱនកេរ្តិ៍ឈ្មោះ កិត្តិយស
    - ✓ ធ្វើឱ្យឪពុកម្តាយព្រួយបារម្ភ អស់សង្ឃឹម
    - ✓ ពុំបានលើកស្ទួយជីវភាពគ្រួសារ
    - ✓ បង្កឱ្យគ្រួសារ សង្គមជាតិបាត់បង់ភាពថ្លៃថ្នូរ។
  - **ឧទាហរណ៍៖**
    - **ក្នុងសង្គម** គេតែងសង្កេតឃើញមានកូនប្រុសស្រីមួយចំនួន ដែលពុំបានបំពេញកាតព្វកិច្ចជាកូនល្អក្នុងគ្រួសារឡើយ ព្រោះពួកគេបាន៖
      - ✓ សេពគប់មិត្តមិនល្អ នាំគ្នាសេពគ្រឿងញៀន លួចឆក់ប្លន់
      - ✓ មិនចូលរៀនតាមកាលវិភាគរបស់សាលា មិនគោរពបទបញ្ជាផ្ទៃក្នុងរបស់សាលា
      - ✓ បង្កជម្លោះបងតូច បងធំ រឹករវាសពេញទីសាធារណៈកូនដែលមានចរិតរបៀបនេះបានធ្វើឱ្យគ្រួសារទាំងមូល សហគមន៍ទាំងមូល និងសង្គមទាំងមូលបាត់បង់តម្លៃ ឬសណ្តាប់ធ្នាប់ ព្រមទាំងមានអសន្តិសុខទៀតផង។
    - **ក្នុងអក្សរសិល្ប៍៖**
      - ✓ **រឿងកុលាបប៉ៃលិន**: លោកបាឡាត់ស្រុកជាកូនមិនល្អ ព្រោះខ្លួនមិនបានយកតួនាទីមន្ត្រីរាជការទៅបម្រើសង្គមទេបែរជាបណ្តោយខ្លួនទៅសេពគប់នឹងមេចោរផាន់ ដោយបន្លំទំនាក់ទំនងរវាងពួកខ្លួននិងលោកហ្លួងរតនសម្បត្តិពីន័យរាប់អានមកជាលួចប្លន់ទៅវិញ។
      - ✓ **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់**: នាយសៅ ជាកូនមិនល្អ ដោយបានប្រកបរបរខុសច្បាប់ដែលសង្គមមិនគាំទ្រ គឺលួចឆក់ពីអ្នកដទៃមិនបានប្រកបរបរស្របច្បាប់។

របរបែបនេះ ជាហេតុនាំឱ្យខ្លួនគ្មានតម្លៃ ឪពុកម្តាយត្រូវព្រួយបារម្ភគ្រប់វេលាដោយសារតែអនាគតកូនទៅថ្ងៃមុខងាយទទួលទោសជាប់ពន្ធនាគារជាមិនខាន បើនាយសៅនេះនៅតែប្រព្រឹត្ត។ ជាក់ស្តែងក្នុងពេលដែលសមត្រូវបាត់បង់មុខរបរ ហើយជំពាក់បំណុលតាសានម្ចាស់ខ្ទមនិងអ្នកស្រីគឹមលៀងម្ចាស់ស៊ីក្លូ នាយសៅនេះក៏មកបបួលសមឱ្យរកស៊ីក្នុងផ្លូវទុច្ចរិត។

**ខ- «កូនស្លូតចេះគួរសម មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ»ព្រោះកូនស្លូត ជាកូនដែលៈ**

- **គំនិតសំខាន់៖**
  - ✓ ស្តាប់តាមដំបូន្មានឪពុកម្តាយ
  - ✓ តែងតែធ្វើឱ្យឪពុកម្តាយសប្បាយចិត្ត
  - ✓ មិនបង្កើតបញ្ហាឱ្យលោកដោះស្រាយទេ
  - ✓ តែងតែនាំមកនូវកេរ្តិ៍ឈ្មោះ កិត្តិយស
  - ✓ ធ្វើឱ្យឪពុកម្តាយមានក្តីសង្ឃឹម និងមានសុទិដ្ឋិនិយម
  - ✓ លើកស្ទួយជីវភាពគ្រួសារ
  - ✓ មិនបង្កឱ្យគ្រួសារ សង្គមជាតិបាត់បង់ភាពថ្លៃថ្នូរ។
- **ឧទាហរណ៍៖**
  - **ក្នុងសង្គម** គេតែងសង្កេតឃើញមានកូនប្រុសស្រី ដែលបានបំពេញកាតព្វកិច្ចជាកូនល្អក្នុងគ្រួសារដូចជា៖
    - ✓ សេពគប់មិត្តល្អ នាំគ្នារៀនសូត្រ ស្រាវជ្រាវមុខវិជ្ជានានានៅតាមបណ្ណាល័យ
    - ✓ តែងចូលរៀនតាមកាលវិភាគរបស់សាលា និងគោរពបទបញ្ជាផ្ទៃក្នុងរបស់សាលាបានល្អ មិនបង្កជម្លោះបងតូច បងធំ ឬភាពរឹករពាសពេញទីសាធារណៈនោះទេ
    - ✓ ពួកគេតែងតែបានទទួលជោគជ័យក្នុងការសិក្សា បានសញ្ញាបត្រ ជាសិស្សនិស្សិតឆ្នើមឬរៀនពូកែ កូនដែលមានចរិតល្អបែបនេះបានធ្វើឱ្យគ្រួសារទាំងមូលសហគមន៍ទាំងមូលនិងសង្គមទាំងមូលមានកិត្តិយស ថ្កុំថ្កើង និងភាពរុងរឿង។
  - **ក្នុងអក្សរសិល្ប៍ ៖**
    - ✓ **រឿងកុលាបប៉ៃលិនៈ** ចៅចិត្រជាកូនស្លូតឬជាកូនល្អដែលគោរពតាមឱវាទតាចឹមជាឪពុក «ខ្លួនត្រូវទីពឹងខ្លួន» តាំងពីដើមរឿងមក។ ដូចជាចៅចិត្រខិតខំបំពេញការងារជីកត្បូងចាប់ត្រឹមពីកម្មកររហូតក្លាយជានាយត្រួតអណ្តូងរ៉ែ។ ដោយសារតែឥរិយាបថដ៏ល្អប្រកបដោយសីលធម៌នេះហើយ ទើបបានជំរុញឱ្យលោកហ្លួងរតនសម្បត្តិពេញចិត្តស្រឡាញ់ចៅចិត្រ និងលើកយុននារីជាភរិយាចៅចិត្រ។
    - ✓ **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ៈ** សមជាកូនស្លូតឬជាកូនល្អរបស់ពូសុខនិងមីងសនបានបំពេញកិច្ចការថ្លៃថ្នូរស្របច្បាប់សង្គម។ ដូចជាសមបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការធ្វើកសិកម្មទំនើបគឺអនុវត្តនយោបាយទឹក។ ទីបំផុតសមក៏បានក្លាយទៅជាកសិករគំរូ ហើយត្រូវបានប្រជារាស្ត្រក្នុងភូមិគោរពស្រឡាញ់និងបោះឆ្នោតជ្រើសរើសជាប្រធានគណៈកម្មការកងឃុំសង្គមរាស្ត្រនិយម ជាពិសេសត្រូវបានចាត់តាំងឱ្យចូលរួមសមាជជាតិលើកទីប្រាំបួននៅរាជធានីភ្នំពេញទៀតផង។

- **សរុប:** សរុបមកបុគ្គលនិងតួអង្គដូចខាងលើនេះហើយដែលបញ្ជាក់ថា កូនកាចពិតជាបំពេញទុក្ខលំបាកចំពោះឪពុកម្តាយហើយកូនស្លូត ពិតជានាំមកនូវកិត្តិយសចំពោះមាតាបិតាប្រាកដមែន។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន:** ទស្សនៈប្រធានមានអត្ថន័យសំខាន់ ព្រោះបានអប់រំអ្នកអាន អ្នកសិក្សាស្គាល់ពីចរិតលក្ខណៈនៃកូនកាចនិងកូនស្លូត ដែលតែងតែមាននៅក្នុងគ្រួសារនិងក្នុងសង្គមជាតិ។
- **មតិផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមជាកូនល្អ យើងគប្បីចេះប្រកាន់យកសេចក្តីថ្លៃថ្នូរដោយការគោរពដឹងគុណ ចំពោះមាតាបិតា គ្រូអាចារ្យ ចាស់ព្រឹទ្ធាចារ្យ ដែលបានផ្តល់កំណើតចំណេះដឹងនិងចិញ្ចឹមបីបាច់តាំងពីចាប់កំណើតរហូតធំពេញវ័យនោះទើបសក្តិសម ជាកូនល្អសិស្សល្អ ពលរដ្ឋល្អ រស់ក្នុងគ្រួសារ និងសង្គមមួយដ៏រុងរឿង។

---

**ប្រធានទី៤:** មានគតិបណ្ឌិតមួយឃ្លាថែងថា «ខ្លឹមសារជីវិតពិតប្រាកដ មិនស្ថិតលើជីវិតរស់នៅបានយូរអង្វែងនោះទេ តែជាការច្នៃជីវិតឱ្យមានប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយ»។ ចូរបកស្រាយដោយរកអំណះអំណាងក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មកបញ្ជាក់។

---

## គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា:** ការកើតមកជាមនុស្ស ដើម្បីធ្វើខ្លួនឱ្យក្លាយទៅជាមនុស្សពិតប្រាកដ គឺជាការលំបាកបំផុត ព្រោះមិនគ្រាន់តែមានជីវិតយូរអង្វែងប៉ុណ្ណោះទេ គឺត្រូវចេះធ្វើខ្លួនជាមនុស្សមានប្រយោជន៍ថែមទៀត ទើបជាការប្រសើរ។
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** ដោយមានគោលជំហរបែបនេះហើយ ទើបមានគតិបណ្ឌិតមួយឃ្លាបានថែងថា «ខ្លឹមសារជីវិតពិតប្រាកដ មិនស្ថិតលើជីវិតរស់នៅបានយូរអង្វែងនោះទេ តែជាការច្នៃជីវិតឱ្យមានប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយ»។
- **ចំណោទបញ្ហា:** តើគតិបណ្ឌិតខាងលើនេះ មានអត្ថន័យយ៉ាងណាខ្លះ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ជាជំនួយនៃការបកស្រាយគំនិតប្រធានខាងលើនេះយើងគប្បីស្វែងយល់ន័យនៃ ពាក្យគន្លឹះប្រធានជាមុនសិន។
- ពន្យល់ពាក្យ៖
  - ✓ ខ្លឹមសារជីវិតជាជីវិតដ៏មានន័យមានតម្លៃ ឬជាជីវិតដែលមានប្រយោជន៍ចំពោះគ្រួសារ និងសង្គមជាតិ។
  - ✓ ច្នៃជីវិត គឺជាការយកចំណេះរបស់ខ្លួន បង្កើតជាស្នាដៃណាមួយ ដើម្បីបម្រើសេចក្តីត្រូវការរបស់មនុស្ស។
- **ពន្យល់ន័យ:** មានន័យថា ជីវិតមានន័យពិតប្រាកដមិនស្ថិតនៅលើបុគ្គលដែលរស់នៅបានយូរអង្វែងនោះទេ តែស្ថិតនៅលើបុគ្គលចេះបង្កើតស្នាដៃផ្សេងៗសម្រាប់ជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ ឬជាប្រយោជន៍ដល់សង្គមជាតិ។

- បកស្រាយ៖

ក. ខ្លឹមសារជីវិតពិតប្រាកដមិនស្ថិតលើជីវិតរស់នៅបានយូរអង្វែងនោះទេ ព្រោះ៖

- **គំនិតសំខាន់៖**
  - ✓ ពុំបានបន្សល់ជាស្នាដៃណាមួយឬជាកេរដំណែលជាសីលធម៌ល្អសម្រាប់អប់រំមនុស្សជំនាន់ក្រោយ។
  - ✓ ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ក៏បានបំផ្លិចបំផ្លាញជាតិគ្រប់យ៉ាងដែលធ្វើឱ្យសង្គមជាតិកាន់តែវិនាសហិនហោចបាត់បង់អស់នូវកិត្យានុភាពជាតិ។
  - ✓ គ្មានការភ្ញាក់ផ្អើល ឬអើពើ ឬក៏ភ្ញាក់រលឹក គឺត្រូវបាត់បង់ឧត្តមគតិ ក្បត់សម្បជញ្ញៈ គ្មានមនសិការ មើលមិនឃើញទុក្ខលំបាក របស់រាស្ត្រ។
- **ឧទាហរណ៍៖**
  - ✓ ក្នុងសង្គម គេឃើញមានបុគ្គលខ្លះ ទោះបីមានជីវិតយ៉ាងណាក្តី ក៏គេពុំដែលចេះធ្វើឱ្យជីវិតនោះមានតម្លៃទេ ដូចជាជនពាល ចោរ ឃាតក អ្នកជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ពួកគេតែងតែត្រូវផ្តន្ទាទោសតាមច្បាប់ បាត់បង់កេរ្តិ៍ឈ្មោះ រស់ក៏គ្មានន័យ សង្គមក៏មិនរាប់រក។
  - ✓ ក្នុងប្រវត្តិសាស្ត្រ ព្រះរាជសម្ភារបែរជាមានព្រះទ័យទៅលើរាជទេពីនៃព្រះបិតុលារបស់ទ្រង់ទៅវិញ ដែលបង្កឱ្យមានសង្គ្រាមរហូតត្រូវក្បៀយព្រះជន្ម។
  - ✓ ក្នុងអក្សរសិល្ប៍ៈ តាមរយៈរឿងភូមិតិរច្ឆាន មេឃុំប៉ាល់ និងដៃជើងបារាំង ទោះបីមានជីវិតយ៉ាងណាក៏ដោយ ក៏ពួកគេពុំមានតម្លៃឡើយដោយសារតែពួកគេបានចូលដៃចូលជើងជាមួយពួកអាណានិគមនិយមបារាំងក្នុងការគាបសង្កត់មកលើរាស្ត្រនៅក្រាំងលាវ។

ខ. ខ្លឹមសារជីវិតពិតប្រាកដជាការច្នៃជីវិតឱ្យមានប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយព្រោះ៖

- **គំនិតសំខាន់៖**
  - ✓ បានបន្សល់ទុកស្នាដៃ កេរ្តិ៍ឈ្មោះ ឧត្តមគតិ ជាប្រយោជន៍ជាតិសម្រាប់អ្នកជំនាន់ក្រោយ
  - ✓ ធ្វើពលិកម្មទាំងកាយទាំងចិត្តដើម្បីឯករាជ្យ ប្រជាធិបតេយ្យ សិទ្ធិសេរីភាពជូនជាតិខ្លួន
  - ✓ រក្សាការពារបូរណភាពទឹកដី រក្សាសម្បត្តិវប្បធម៌ សម្បត្តិធម្មជាតិ ប្រជាជន
  - ✓ មិនលក់ឧត្តមគតិជាតិឱ្យពួកអាណានិគមនិយម ឬបរទេស ដើម្បីអំណាចខ្លួន បក្សខ្លួន គ្រួសារខ្លួននោះឡើយ
- **ឧទាហរណ៍៖** គេឃើញមានបុគ្គលជាច្រើន ដែលបានពុះពារគ្រប់ឧបសគ្គ ដើម្បីកសាងស្នាដៃជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ។ ក្នុងនោះមាន៖
  - ✓ **សង្គមៈ**
    - អ្នកស្រាវជ្រាវវិទ្យាសាស្ត្រ លោកខិតខំព្យាយាមស្វែងរកឱសថទំនើបដើម្បីព្យាបាលមេរោគគ្រុនផ្តាសាយបក្សី អេដស៍ ថ្លើម គ្រុនឈាម...។
    - កវីនិពន្ធលោកខិតខំតាក់តែងជាស្នាដៃនានា ដោយផ្សារភ្ជាប់ទៅនឹងតម្លៃអប់រំដូចជាឱ្យមានស្មារតីស្នេហាជាតិ ស្រឡាញ់វប្បធម៌ជាតិ សិក្សាអក្សរសាស្ត្រ ឬប្រពៃណីទំនៀមទម្លាប់...។

- ✓ **ប្រវត្តិសាស្ត្រ៖**
  - វីរក្សត្រនៃព្រះបាទជ័យវរ្ម័នទី៧ ព្រះបាទនរោត្តមសីហនុសុទ្ធតែហ៊ានធ្វើពលិកម្មមិនចុះញ៉មសត្រូវ ដើម្បីទឹកដី ឯករាជ្យ សន្តិភាព ជាពិសេសដើម្បីសេចក្ដីសុខរបស់ប្រជារាស្ត្រ។
  - វីរជនដែលមានអាចារ្យហែមចៀវ អាចារ្យស្វា ពោធិកំបោរ ក្រឡាហោមគង់សុទ្ធតែប្ដូរផ្ដាច់នឹងសត្រូវគឺពួកអាណានិគមនិយមបារាំង ដែលបានគាបសង្កត់មកលើប្រជារាស្ត្រយើង។
  - កវីក្រមង៉ុយភិក្ខុសោមបណ្ឌិតជ័យនន្ទ ព្រះនាងឥន្ទ្រទេវី...ជាបណ្ឌិតកវីដ៏ឆ្នើមដែលបាននិពន្ធជាស្នាដៃទុកឱ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ។
- ✓ **អក្សរសិល្ប៍៖**
  - **រឿងភូមិតិរច្ឆាន:** ជូន នៅ អ្នកក្លាហានម្ដៃនាក់ នាងនី នាងប៊ី និងអ្នកក្រាំងលាវទាំងមូលបានរួបរួមគ្នាកម្ចាត់លោកបារដេសដែលបានជិះជាន់គាបសង្កត់មកលើអ្នកជាប់ពន្ធដោយបង្អត់បាយឬដាក់ខ្នោះ វាយដំ ទាត់ធាក់ជាដើម។ ដោយសារតែកំហឹងឈឺចាប់ដូចខាងលើនេះហើយ ក៏បណ្ដាលឱ្យពួកគេរៀបចំផែនការកម្ចាត់បារដេសបានដូចបំណង។
  - **រឿងគូលីកំណែន:** មានប្រជារាស្ត្រគ្រប់ស្រទាប់បានរួមគ្នាប្រឆាំងនឹងពួកអាណានិគមនិយមបារាំងក្នុងនោះមានលឹមជាកសិករ យឹមជាអ្នកមានបទពិសោធក្នុងការតស៊ូ នូដូងជាមេដឹកនាំ ម៉ឹងជាបញ្ញវន្ត ព្រមទាំងប្រជារាស្ត្រជាច្រើនទៀតបានស្ម័គ្រចិត្តចូលរួមជាមួយចលនាតស៊ូរហូតទទួលបានជោគជ័យគឺឯករាជ្យសន្តិភាព សុភមង្គលជូនជាតិរបស់ខ្លួន។

- **សរុប:** ដូច្នេះខ្លឹមសារជីវិតពិតប្រាកដ ពិតជាស្ថិតនៅលើការច្នៃជីវិតឱ្យមានប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយ ហើយក៏មិនស្ថិតនៅលើជីវិតរស់នៅបានយូរអង្វែងនោះប្រាកដមែន។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន:** ទស្សនៈប្រធានពោរពេញទៅដោយការអប់រំ ព្រោះឱ្យមនុស្សស្គាល់ពីជីវិតពិតប្រាកដជាពិសេសការប្រព្រឹត្តអំពើណាមួយរបស់ខ្លួន។
- **មតិផ្ទាល់ខ្លួន:** គតិបណ្ឌិតខាងលើនេះបានដាស់តឿនដល់កូនខ្មែរឱ្យមានស្មារតីភ្ញាក់រលឹក ចេះប្រកាន់តែអំពើល្អ សច្ចធម៌ គុណធម៌ក្នុងជីវិតដើម្បីអនាគតរបស់ខ្លួន។

---

**ប្រធានទី៥:** មានសុភាសិតមួយឃ្លាថែងថា «ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក»។ ចូរបកស្រាយសុភាសិតនេះ ដោយរកឧទាហរណ៍មកបញ្ជាក់។

---

## គម្រោងតែង

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា:** បុព្វបុរសខ្មែរយើងបានបន្សល់ទុកនូវស្នាដៃជាច្រើនក្នុងគោលបំណងអប់រំកូនចៅជំនាន់ក្រោយឱ្យចេះបំពេញកិច្ចការទាំងឡាយដើម្បីឱ្យបានជោគជ័យស្របទៅតាមនិស្ស័យពីធម្មជាតិរៀងៗខ្លួន។

- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: ដោយមានគោលបំណងអប់រំដូចខាងលើនេះហើយ ទើបបុព្វបុរសយើងបានចងក្រងជាសុភាសិតមួយឃ្លាថែងថា «ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក»។
- **ចំណោទបញ្ហា**: តើសុភាសិតខាងលើនេះ មានអត្ថន័យយ៉ាងណាខ្លះ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។
- **ពន្យល់ពាក្យ៖**
  - ✓ ឈើវៀច ជាឈើដែលមានរំពត់ មានរបត់កោង ឬរមួល វៀចងាកបែរខុសពីប្រក្រតី
  - ✓ កង់ ជាកង់រទេះរាងជារង្វង់ ដែលអាចប្រព្រឹត្តទៅមុខបានដោយសារការរុញឬការអូស
  - ✓ ឈើត្រង់ គឺជាឈើមិនងាក ឬបែរទៅខាងណាមួយឡើយ
  - ✓ ទូក ជាឈើមួយគូសម្រាប់ទ្រតួរទេះឱ្យរឹងមាំ។
- **ពន្យល់ន័យ**: មានន័យថា ឈើដែលមានទម្រង់កោងឬរមួល គេត្រូវយកវាមកធ្វើជាកង់ ព្រោះមានរាងកោងស្រាប់ រីឯឈើត្រង់មានសភាពវែងល្អមិនងាកបែរទៅខាងណាមួយទេ នោះគេត្រូវយកមកធ្វើជាទូក ដែលជាតួសម្រាប់ទ្ររទេះឱ្យរឹងមាំ។
- **បកស្រាយ៖**

  **ក- ន័យចំ**: «ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក» ព្រោះ៖

  - **គំនិតសំខាន់៖**
    - ✓ កង់រទេះ មានរាងជារង្វង់ទាមទារយកឈើដែលមានរាងកោងឬវៀចទៅកែច្នៃផ្សំគ្នាឱ្យទៅជារង្វង់មូល។
    - ✓ ឈើកោង វៀច ឬង រមែងមានសាច់ឈើនិងសរសៃពត់មាំទៅតាមលំនាំធម្មជាតិស្រេចតែម្តងមិនពិបាកក្នុងការកែច្នៃបន្ថែម។
    - ✓ ទូករទេះ  ទាមទារឈើត្រង់ដើម្បីទ្រទ្រង់រទេះទាំងមូលឱ្យរឹងមាំ ហើយគេតែងយកឈើត្រង់ស្រាប់ទៅធ្វើ។
    - ✓ ឈើមានសណ្ឋានវែងត្រង់ល្អ ជាតម្រូវការដ៏ចាំបាច់ក្នុងការធ្វើទូករទេះ ដោយមិនបាច់ចំណាយពេលវេលាច្រើនក្នុងការកែសម្រួលឈើនោះឱ្យត្រឹមត្រង់ស្របតាមបំណងជាងឡើយ។
    - ✓ ដូច្នេះទោះបីជាឈើវៀចក្តី ឬឈើត្រង់ក្តីសុទ្ធតែមានអត្ថប្រយោជន៍ដូចគ្នាគ្រាន់តែមានមុខងារ ផ្សេងគ្នាតែប៉ុណ្ណោះ។

  **ខ- ន័យធៀប** «ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក» ព្រោះ៖

  - ✓ ឈើវៀច គឺសម្គាល់លក្ខណៈមនុស្សខូច កាច លួង់ខ្លៅ រីឯឈើត្រង់សម្គាល់លក្ខណៈមនុស្សស្លូតបូត ទៀងត្រង់មានចំណេះវិជ្ជា។ បុគ្គលទាំងពីរប្រភេទនេះ មាននិស្ស័យនិងទស្សនៈមិនដូចគ្នាទេ ហើយក៏មិនអាចចុះសម្រុងនឹងគ្នាបានដែរ។ ប៉ុន្តែអ្វីសំខាន់នោះ គឺការធ្វើការងារផ្សេងៗរបស់ពួកគេត្រូវមានកិច្ចការខុសពីគ្នា។ ប្រភេទបុគ្គលជាឈើវៀចអាចមានសកម្មភាពការងារ ដោយការប្រើកម្លាំងបាយដូចជាកងទ័ពដែលការពារប្រទេសមិនឱ្យសត្រូវឈ្លានពាន។ ជួនកាលមនុស្សប្រភេទនេះ មានការប៉ិនប្រសប់ក្នុងការបំពេញការងារនិងស្មោះត្រង់ចំពោះកិច្ចការទៀតផង។ ចំណែកមនុស្សប្រភេទ

ជាឈើត្រង់វិញ គឺជាជនស្លូតត្រង់មានចំណេះថ្លៃថ្នូរ សីលធម៌ស្អាតស្អំគប្បីឱ្យគេបំពេញកិច្ចការណាសំខាន់ឬចាំបាច់។ រីឯអ្នកដែលមានចំណេះវិញ គេគប្បីធ្វើជាអ្នកដឹកនាំជាអ្នកទទួលខុសត្រូវកិច្ចការធំៗ ព្រោះគេជាមនុស្សចេះទទួលខុសត្រូវពិតពិតប្រាកដ។ បើគេប្រើមនុស្សបែបនេះ នាំឱ្យសង្គមជាតិមានការរីកចម្រើនឆាប់រហ័ស។

- **ឧទាហរណ៍៖** រឿងអាខ្វាក់អាខ្វិន ដោយអ្នកទាំងពីរពុំបានយកជំនាញរៀងខ្លួនមកអនុវត្តទើបពួកគេមិនអាចសម្រេចក្នុងការអុំទូកទៅត្រើយម្ខាងបានឡើយ ព្រោះពួកគេមិនចេះអុំ ឬគ្មានជំនាញ ដែលធ្វើឱ្យទូកនោះមិនទៅមុខវិលនៅកណ្ដាលបឹង។ លុះក្រោយពីអ្នកទាំងពីរប្រើជំនាញ ដែលខ្លួនមានគឺអាខ្វាក់ជាអ្នកបញ្ជិះអាខ្វិន ហើយអាខ្វិនជាអ្នកចង្អុលបង្ហាញផ្លូវដល់អាខ្វាក់ ។ទីបំផុតអ្នកទាំងពីរបានសម្រេចតាមគោលបំណងខ្លួនដោយពួកគេបានអនុវត្តតាមសុភាសិតរបស់ខ្មែរដែលសុទ្ធតែមានតម្លៃដូចគ្នា ឬដូចជាប្រភេទឈើវៀច ឬក៏ឈើត្រង់ក្ដី។

- **សរុប**: ដូច្នេះឈើវៀចក្ដី ឈើត្រង់ក្ដីសុទ្ធតែមានផលប្រយោជន៍ដូចគ្នា តែការប្រើប្រាស់គឺអាស្រ័យដោយគេចេះយកទៅច្នៃប្រឌិតឱ្យស្របតាមទម្រង់ ឬអត្ថន័យនៃសម្ភារៈទាំងនោះតែប៉ុណ្ណោះ។ ចំណែកមនុស្សដែលមាននិស្ស័យខុសគ្នាក៏គេតម្រូវឱ្យមនុស្សប្រើប្រាស់ជំនាញរៀងៗខ្លួនដើម្បីជាគុណប្រយោជន៍ដល់សង្គមមនុស្ស។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: ឆ្លងតាមការបកស្រាយខាងលើនេះបានបង្ហាញឱ្យឃើញថា ទស្សនៈប្រធានមានអត្ថន័យអប់រំដល់មនុស្សគ្រប់រូប ព្រោះឱ្យយើងមើលឃើញពីតម្លៃនៃមនុស្សគ្រប់ស្រទាប់ជាពិសេសឱ្យគេចេះប្រើមនុស្សទៅតាមជំនាញឬនិស្ស័យដែលគេមានតាំងពីធម្មជាតិមកម្ល៉េះ។
- **មតិផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមជាអ្នកសិក្សាយើងគប្បីចេះស្វែងយល់ពីសមត្ថភាពឬជំនាញរបស់មនុស្សម្នាក់ៗទៅតាមលទ្ធភាពនៃបុគ្គលនោះអាចធ្វើបានទៅតាមជំនាញណាមួយដែលគេមានតាំងពីកំណើតមកម្ល៉េះ។

## ៦.២- ប្រធានអត្ថាធិប្បាយពិភាក្សា

## ប្រធានពិភាក្សាសុទ្ធ

---

ប្រធានទី១: មានមតិខ្លះយល់ថា«មហន្តរាយនៃនគរលង្កា បណ្ដាលមកពីនាងសូរបនខា»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងរឿងរាមកេរ្តិ៍ខ្មែរមកបញ្ជាក់។

---

### គម្រោងតែង

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា**: ក្រោយពីក្រុងខរជាបង ត្រូវបរាជ័យក្នុងសង្គ្រាមទាមទារកិត្តិយសពីព្រះរាមមកវិញ នាងសូរបនខាមានការឈឺចាប់យ៉ាងខ្លាំង រួចក៏ទៅញុះញង់ក្រុងរាពណ៍ជាបងឱ្យមានចិត្តស្រឡាញ់នាងសីតា ដើម្បីលួចឆក់នាងយកមកទុកនៅក្រុងលង្កា។
- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: ដោយមើលឃើញពីឥរិយាបថនៃគំនុំសងសឹកដូចខាងលើនេះហើយ ទើបមានមតិខ្លះយល់ «មហន្តរាយនៃនគរលង្កា បណ្ដាលមកពីនាងសូរបនខា»។

- **ចំណោទបញ្ហា**: តើមតិខាងលើនេះត្រឹមត្រូវឬទេ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីរួមចំណែកដល់ការបកស្រាយមតិប្រធានខាងលើនេះឱ្យកាន់តែស៊ីជម្រៅថែមទៀតនោះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។
- **ពន្យល់ពាក្យ**៖
  - ✓ មហន្តរាយ វិនាស ហិនហោច ខ្ទេចខ្ទី សាបសូន្យ គ្មានសេសសល់អ្វីឡើយ
  - ✓ បណ្តាល ដើមហេតុ បង្កហេតុ មូលហេតុ ដែលនាំឱ្យកើតមានផលណាមួយ
  - ✓ សូរបនខា ជាឈ្មោះស្រីយក្ស ជាប្អូនរបស់ក្រុងរាពណ៍ ដែលសោយរាជ្យនៅក្រុងលង្កា ក្នុងរឿងរាមកេរ្តិ៍ខ្មែរ។
- **ពន្យល់ន័យ**: មានន័យថា សេចក្តីវិនាសហិនហោយនៃនគរលង្កា គឺមកពីនាងសូរបនខា ដែលជាប្អូនក្រុងរាពណ៍មកញុះញង់បងបង្ក ឱ្យមានសង្គ្រាមនេះកើតឡើង។
- **បកស្រាយ**៖

**ក- មតិស្រប** «មហន្តរាយនៃនគរលង្កា បណ្តាលមកពីនាងសូរបនខា» ព្រោះនាងសូរបនខា៖

- **គំនិតសំខាន់**៖
  - ✓ មានចិត្តចេតនាប្រតិព័ទ្ធទៅលើព្រះរាមព្រះលក្ស្មណ៍
  - ✓ រំខានដល់ការតាំងសិល្បរបស់ព្រះរាមព្រះលក្ស្មណ៍
  - ✓ បង្កការឈឺចាប់ដល់ក្រុងខរជាបង ឱ្យធ្វើសង្គ្រាមជាមួយព្រះរាមរហូតបាត់បង់ជីវិត
  - ✓ មានគំនិតសងសឹកចំពោះព្រះរាមព្រះលក្ស្មណ៍ ក៏ញុះញង់ក្រុងរាពណ៍ជាបងឱ្យមានចេតនាប្រតិព័ទ្ធទៅលើសីតា។
- **ឧទាហរណ៍**៖ ក្នុងរឿងរាមកេរ្តិ៍ខ្មែរ បានបង្ហាញដូចតទៅ៖
  - ✓ ដោយដឹងថា ព្រះរាមនិងព្រះលក្ស្មណ៍បានតាំងសិល្បនៅព្រៃភ្នំទណ្ឌការណ្យ នាងសូរបនខាក៏ចូលមកចែចង់អ្នកទាំងពីរក្នុងបំណងសុំសេចក្តីស្នេហា តែត្រូវអ្នកទាំងពីរបដិសេធ។ នៅទីបំផុតនាងសូរបនខា ក៏ប្រើពាក្យមិនសមរម្យជាហេតុធ្វើឱ្យព្រះលក្ស្មណ៍ក្រេវក្រោធ រហូតផ្តលកោរសក់ កាត់ដៃរហូតនាងស្រែករំពងព្រៃ ឮដល់ក្រុងខរជាបងនាំគ្នាលើកទ័ពមកធ្វើច្បាំងនឹងព្រះរាមរហូតត្រូវស្លាប់។
  - ✓ នាងមានចេតនារំខានព្រះរាមព្រះលក្ស្មណ៍ ដែលជាប់ភារៈក្នុងការតាំងសិល្បមិនអាចដោះខ្លួនបានជាហេតុនាំឱ្យព្រះអង្គទាំងពីរ ទាល់ច្រកតម្រូវឱ្យនាងទៅសាកសួរចិត្តម្តងព្រះរាម ម្តងព្រះលក្ស្មណ៍។ ការមិនយល់ពីស្ថានភាពបែបនេះជាប្រការមួយដែលនាំឱ្យនាងខកចិត្តត្បិតស្នេហ៍ដែលខ្លួនកំពុងស្រមើស្រមៃចង់បាននោះ។
  - ✓ នាងក៏បាននិយាយពីសម្ផស្សនាងសីតា ដែលល្អលើសគេហាក់ដូចជំរុញឱ្យក្រុងរាពណ៍ មានចិត្តត្រេកត្រអាលចង់បាននាងសីតាមកធ្វើជាមហេសី ទោះជាដឹងថានាងមានស្វាមីគឺព្រះរាមហើយក៏ដោយ។ បញ្ហានេះ ក៏បណ្តាលឱ្យចិត្តក្រុងរាពណ៍ខិតខំរិះរកវិធីយ៉ាងណា ដើម្បីចាប់នាងសីតាឱ្យបាន។ ចំណែកព្រះរាមវិញ ក៏មិនព្រមចុះញ៉មក៏ខិតខំរិះរកវិធី តបតនឹងក្រុងរាពណ៍វិញតាមយុទ្ធវិធីរៀងៗខ្លួន។
  - ✓ ក្រុងរាពណ៍ទោះបីដឹងថា សង្គ្រាមនេះមានផលវិបាកយ៉ាងណាក៏ដោយ ក៏ខ្លួននៅតែប្តេជ្ញាការពារសីតារហូតត្រូវព្រះរាមវាយកម្ទេចនគរលង្កាឱ្យវិនាសទាំងស្រុង។

- **សរុបមតិស្រប:** សរុបមក មហន្តរាយនៃនគរលង្កា ពិតជាបណ្តាលមកពីនាងសូរបនខា ប្រាកដមែនដែលនាងមានចិត្តថៃចង់មនុស្សប្រុសនោះ។

**ខ-មតិផ្ទុយ** «មហន្តរាយនៃនគរលង្កា បណ្តាលមកពីអ្នកដទៃទៀត»ព្រោះអ្នកទាំងនោះ៖

- **គំនិតសំខាន់៖**
  - ✓ ចូលចិត្តដំណោះស្រាយបញ្ហាដោយប្រើអំពើហិង្សា
  - ✓ ប៉ះពាល់ផលប្រយោជន៍រៀងខ្លួន
  - ✓ ដើម្បីការពារអំណាចរបស់ខ្លួន
  - ✓ ចង់បង្ហាញពីឧត្តមភាពរបស់ខ្លួន។
- **ឧទាហរណ៍៖** ក្នុងរឿងរាមកេរ្តិ៍ខ្មែរ បានបង្ហាញដូចតទៅ៖
  - ✓ គ្រាន់តែនាងសូរបនខាសុំសេចក្តីស្រឡាញ់ ក៏ព្រះលក្សណ៍មិនអនុគ្រោះចំពោះឥរិយាបថដែលប្រព្រឹត្តឆ្គាំឆ្គងចំពោះទ្រង់ដែរ។ ព្រះអង្គហ៊ានកាត់ដៃ កោរសក់ដែលជាលំអរបស់ស្ត្រី ធ្វើឱ្យនាងឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត។ ចំពោះអំពើដ៏ឃោរឃៅនេះជាហេតុនាំឱ្យមានការឈឺចាប់ដល់ក្រុងខរជាបងនាងរហូតធ្វើសង្គ្រាម ត្រូវវិនាសអស់ពលយក្សមួយចំនួន ហើយក្រុងខរខ្លួនឯងត្រូវស្លាប់នៅសមរភូមិទៀតផង។
  - ✓ វិនាសកម្មដ៏ឈឺចាប់នេះក៏បណ្តាលឱ្យក្រុងរាពណ៍ជាបងនាងសូរបនខានិងក្រុងខររួមផ្សំនឹងចិត្តស្រឡាញ់សីតាផងក្រុងរាពណ៍ ក៏រកវិធីដើម្បីចាប់យកនាងសីតាមកទុកនៅក្រុងលង្កាក្នុងសួនអសោក ជាហេតុនាំឱ្យព្រះរាមលើកទ័ពមកធ្វើសង្គ្រាមជាមួយក្រុងរាពណ៍ដោយប្រើល្បិចកលរៀងៗខ្លួនមិនគិតពីសេចក្តីវេទនារបស់អ្នកលង្កាសោះឡើយ។
  - ✓ ព្រះរាមនៅតែតាមប្រមាញ់ទ័ពយក្សដោយឱ្យអ្នកយកការណ៍ដែលមានហនុមានទៅស៊ើបមើលពីពលយក្សឬទីតាំងស្បៀង ព្រមទាំងទីតាំងដ៏ទៃទៀតក្នុងក្រុងលង្កាទាំងមូល។
- **សរុបមតិផ្ទុយ:** ដូច្នេះមហន្តរាយនៃនគរលង្កាបណ្តាលមកពីអ្នកដទៃទៀតប្រាកដមែន។

**គ- សំយោគ:** ជារួមមហន្តរាយនៃនគរលង្កា គឺពិតជាបណ្តាលមកពីនាងសូរបនខាផងនិងអ្នកដទៃទៀតផងដែលមានក្រុងរាពណ៍ ព្រះរាម ព្រះលក្សណ៍ សុទ្ធតែនិយមប្រើអំពើហិង្សាក្នុងការស្រាយបញ្ហាទំនាស់។ បើសិនជាពួកគេចេះរកវិធីដ៏សមស្របណាមួយ ម្ល៉េះសមនគរលង្កានិងប្រជារាស្ត្រដែលរស់នៅក្រុងលង្កានោះនឹងបានសេចក្តីសុខជាមិនខានឡើយ។

## គ- បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន:** មតិប្រធានមិនទាន់ត្រឹមត្រូវទាំងស្រុងទេ ព្រោះជាការដាក់បន្ទុកតែទៅលើនាងសូរបនខាតែម្នាក់ រីឯអ្នកដទៃទៀតបែរជារួចខ្លួនទៅវិញ។
- **មតិផ្ទាល់ខ្លួន:** តែទោះជាយ៉ាងណាក៏ដោយ ក៏មតិខាងលើនេះបានផ្តល់ជាបទពិសោធដល់អ្នកសិក្សាអ្នកអានឱ្យចេះវិភាគទាំងឡាយ ដែលមានក្នុងអក្សរសិល្ប៍ ឬសង្គមជាតិក្តី។

**ប្រធានទី២:** មានមតិខ្លះយល់ថា«មរណភាពរបស់ទុំ បណ្តាលមកពីទុំមិនជឿលើទំនាយគ្រូ»។ ចូរពិភាក្សាដោយរកឧទាហរណ៍ក្នុងរឿងទុំទាវមកបញ្ជាក់ឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ក- ផ្តើមសេចក្តី

- **លំនាំបញ្ហា**: មនុស្សគ្រប់រូប ដែលមានជីវិតលើលោកិយសន្និវាសយើងនេះ ពុំមានបុគ្គលណាមួយដែលមានជីវិតអមតៈនោះឡើយ គឺតែងតែបាត់បង់ជីវិតទៅតាមធម្មជាតិដោយជៀសមិនរួចឡើយ គឺគ្រាន់តែបុគ្គលខ្លះបាត់បង់ជីវិតដោយសារជំងឺបៀតបៀន ខ្លះទៀតបាត់បង់ជីវិតដោយសារតែគ្រោះថ្នាក់ផ្សេងៗ។
- **ចំណូលបញ្ហា(បង្ហាញប្រធាន)** : រីឯរឿងទុំទាវវិញ កវីក៏បានបង្ហាញពីការស្លាប់របស់តួអង្គទុំនេះដែរ ហើយក៏មានមតិខ្លះយល់ថា « មរណភាពរបស់ទុំ បណ្តាលមកពីទុំមិនជឿលើទំនាយគ្រូ»។
- **ចំណោទបញ្ហា**: តើមតិខាងនេះត្រឹមត្រូវ ឬទេ?

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។
- **ពន្យល់ពាក្យ៖**
  - ✓ មរណភាព ជាសេចក្តីស្លាប់ ឬជាការបាត់បង់អាយុជីវិត
  - ✓ ទំនាយគ្រូ ជាទំនាយក្នុងការទស្សន៍ទាយ ពីជោគជតារាសីនៃមនុស្សម្នាក់ៗ ក្នុងការព្យាករណ៍ជាមុនពីដំណើរជីវិតរបស់បុគ្គលណាមួយ។
- **ពន្យល់ន័យ** : មានន័យថា ការបាត់បង់ជីវិតរបស់ទុំក្នុងរឿងទុំទាវ បណ្តាលមកពីទុំខ្លួនឯងមិនជឿតាមជើងលេខដែលលោកគ្រូបានទស្សន៍ទាយពីជោគជតារបស់ខ្លួន។
- បកស្រាយ៖
  - **ក- មតិស្រប** «មរណភាពរបស់ទុំ បណ្តាលមកពីទុំមិនជឿលើទំនាយគ្រូ» គ្រូបានទស្សន៍ទាយទៅឃើញថា៖
    - ▪ **គំនិតសំខាន់និងឧទាហរណ៍៖**
      - ✓ បើសិនជាសឹកក្នុងខែបុស្សនឹងត្រូវបាត់បង់ជីវិត តែបើសឹកក្នុងខែពិសាខនឹងបានឡើងជាធំ ឬបានទទួលបុណ្យសក្តិ។ ដូចលោកគ្រូបានទស្សន៍ទាយឃើញថា «អញវាយលេខលុបគ្រប់ជើងហារ លេខឆ្លើយឡើងថាអាកុំពារ កុំពុះទម្លុះក្រែងវេទនា ឃើញជានេនពេជ្រគេចគ្រាន់បើ។ នេនពេជ្រសឹកចុះខែបុស្សបាន ទុំឯងឈប់ខានទើបប្រសើរចាំដល់ពិសាខសិនសឹមដើរ សឹកហើយត្រូវលើបានជាធំ»។
      - ✓ ពេលវេលាគ្រោះថ្នាក់របស់ទុំពិតជាដូចជើងលេខ ព្រោះ៖
        - បើទុំសឹកក្នុងខែពិសាខ នាងទាវអាចនឹងក្លាយទៅជាប្រពន្ធរបស់ម៉ឺនងួន ដែលជាកូនអរជូនស្តេចត្រាញ់នៅត្បូងឃ្មុំឬជាស្នំឯកនៃព្រះបាទរាមាជើងព្រៃដែលសោយរាជ្យនាសម័យនោះ

- មុននឹងចាកចេញពីរាជវាំង ព្រះរាជាទ្រង់បានរំលឹកជាមុនថា បើសិនជាអរជូនម៉ឺនងួនមិនព្រមស្តាប់តាមបម្រាមរបស់ទ្រង់ទេ ឆាប់វិលមកវិញ។ ព្រះអង្គក៏បានប្រគល់រាជសារដល់ទុំដើម្បីបញ្ជាក់ពីកិច្ចការនេះឱ្យបានច្បាស់លាស់។ ប៉ុន្តែទុំបែរជាភ្លេចតាមបន្ទូលព្រះអង្គ ក៏ត្រូវស្លាប់ក្រោមស្នាដៃអរជូននិងម៉ឺនងួន ព្រមទាំងម្តាយទាវទៅវិញ។ នេះមកពីជោគជតារាសីមិនល្អ ជួបនឹងគ្រោះកំណាចឬត្រូវស្លាប់ដូចទំនាយរបស់លោកគ្រូប្រាកដមែន។

▪ **សរុបមតិស្រប**: ដូច្នេះ មរណភាពរបស់ទុំពិតជាបណ្តាលមកពីទុំខ្លួនឯង មិនជឿលើទំនាយគ្រូប្រាកដមែន។

**ខ- មតិផ្ទុយ** «មរណភាពរបស់ទុំមិនមែនបណ្តាលមកពីទុំមិនជឿលើទំនាយគ្រូទេ» ព្រោះមរណភាពនេះ៖

▪ **គំនិតសំខាន់ និងឧទាហរណ៍៖**

✓ របបសង្គម នាសម័យលង្វែកមានចរិតផ្តាច់ការតាំងពីថ្នាក់លើរហូតថ្នាក់ក្រោម។ សមដូចជាការរៀបរាប់របស់កវីនិពន្ធដោយធ្វើការប្រៀបធៀបថា «ឧកញ៉ាអរជូនមួនមាំពេកធម្មតាក្រោមមេឃ ទាបជាងភ្នំ មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី»។ មានន័យថា អំណាចនាពេល នោះមានបីយ៉ាងគឺ៖

- ចំពោះអំណាចស្តេចផែនដីជាមួយនឹងសកម្មភាពក្រេវក្រោធរបស់ព្រះរាមាចំពោះអរជូនម៉ឺនងួនរហូតទ្រង់សម្រេចព្រះទ័យកាត់ទោសប្រហារជីវិត។ នោះពុំមែនមកពីមរណភាពរបស់ទុំទាវនោះទេ គឺមកពីអរជូនហ៊ានប្រឆាំងនឹងព្រះអង្គព្រោះអ្នកទាំងនោះត្រូវព្រះអង្គសព្វព្រះទ័យបានរៀបការឱ្យពួកគេរស់ជាមួយគ្នាជាប្តីប្រពន្ធ ហើយអរជូនក៏បានដឹងដែរ។ ហេតុនេះហើយទើបព្រះអង្គខ្ញាល់សមដូចកវីបានរៀបរាប់ថា « ហ៊ានហែកដុតចោលបន្ទូលអញ ទោសវាចងបាញ់អាងួនកូន ធ្វើទុក្ខធ្វើទោសឱ្យអស់សូន្យ សន្តានបងប្អូនបញ្ចូលងារ»។
- ចំពោះអំណាចស្តេចត្រាញ់(មានប្រាំ) នៅសម័យលង្វែក ស្តេចត្រាញ់ជាមន្ត្រីជាន់ខ្ពស់មានងារជាចៅហ្វាយស្រុក។ មន្ត្រីនេះមានសក្តិដប់ហ្មឺពាន់ហើយក្រៅពីត្រួតត្រាលើដែនសីមារបស់ខ្លួនចៅហ្វាយស្រុកមានតួនាទីជាមេទ័ពធំ ទទួលរ៉ាប់រងរក្សាការពារប្រទេសជាតិទាំងមូល។ ឯឧកញ៉ាអរជូនក្នុងរឿងទុំទាវ ក៏មានអំណាចខ្លាំងក្លាហើយដោយសារតែមានអំណាចនេះជាហេតុធ្វើឱ្យអរជូនមានចិត្តប្រមាថជីវិតទុំដែលនាំឱ្យមានវិនាសកម្មដ៏រន្ធត់បែបនេះ។
- ចំពោះអំណាចមេគ្រួសារ ការទុកដាក់កូនចៅឱ្យមានគូស្រករ គឺជាភារកិច្ចដ៏ចម្បងចំពោះម្តាយឪពុក។ ផ្នត់គំនិតសង្គមបានដាក់សម្ពាធមកលើផ្លូវចិត្តយុវជនយើងនាំឱ្យកើតមានជាការប្រឆាំងនឹងការសម្រេចចិត្តរបស់ម្តាយឪពុក។ ប្រការនេះហើយជាហេតុជំរុញឱ្យម្តាយទាវបានប្រើប្រាស់សិទ្ធិខ្លួនជាម្តាយបង្ខំឱ្យទាវយល់ព្រមទទួលម៉ឺនងួនជាប្តីដោយនាងមិនស្រឡាញ់បន្តិចសោះឡើយ។ ការប្រើសិទ្ធិក្នុងការកសាងឬជ្រើសរើសគូស្រករនេះ គួរតែទុកឱកាសដល់កូនខ្លួនខ្លះទើបជាការប្រសើរ។ ដោយសារតែការប្រើអំណាចបែបនេះហើយ ទើបម្តាយទាវហ៊ានកុហកទាវជាពិសេសហ៊ានស្រែកបញ្ជាអរជូនឱ្យយកទុំជាប្តីនាងទាវទៅសម្លាប់យ៉ាងព្រៃផ្សៃនោះ។

✓ ទុំខ្លួនឯងក៏ខ្វះសមត្ថភាពមិនព្រមរកវិធីដោះស្រាយចំពោះមុខឡើយ។ សូម្បីតែឯកសណ្ឋានជាមន្ត្រីរាជវាំង ក៏ពេជ្រជាអ្នករៀបចំឱ្យខ្លួនដែរ ព្រោះទុំគិតតែនាងទាវតែប៉ុណ្ណោះ។ ក្នុងស្ថានការណ៍បែបនេះទុំបែរជាទន់ជ្រាយអស់សង្ឃឹមបាត់បង់ស្មារតីវង្វេងព្រោះតែសេចក្ដីស្នេហាប៉ុណ្ណោះ។

- **សរុបមតិផ្ទុយ**: សរុបសេចក្ដីមក មរណភាពរបស់ទុំ ពិតជាមិនមែនបណ្ដាលមកពីទុំមិនជឿលើទំនាយគ្រូនោះទេ។

**គ- ពិភាក្សា**: ការយល់ថា ទុំស្លាប់មកពីមិនជឿតាមការទស្សន៍ទាយរបស់លោកគ្រូមិនត្រឹមត្រូវទេ ព្រោះមនុស្សម្នាក់ៗដែលមានជីវិតលើលោកយើងនេះទាមទារឱ្យមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាណាមួយពុំគប្បីពឹងផ្អែកទៅលើព្រេងវាសនាឬការទស្សន៍ទាយនោះឡើយ។ អ្វីៗដែលកំពុងកើតមានចំពោះមុខនោះគឺជាការពិត ព្រោះសម័យកាលលង្វែក គេនិយមតែប្រើអំណាចផ្ដាច់ការអ្នកទន់ខ្សោយមិនអាចយកជ័យជម្នះលើភាពអយុត្តិធម៌នៃអ្នកមានអំណាចនោះបានឡើយ។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: មតិប្រធានមិនត្រឹមត្រូវទេ ព្រោះជាមតិដែលពុំទាន់មានលក្ខណៈវិទ្យាសាស្ត្រគ្រប់គ្រាន់មិនឱ្យតម្លៃទៅស្មារតីមនុស្សនិយមឡើយ។
- **មតិផ្ទាល់ខ្លួន**: តែទោះជាយ៉ាងណាក៏ដោយក៏មតិប្រធានខាងលើនេះបានផ្ដល់ជាបទពិសោធដល់អ្នកសិក្សាគ្រប់រូបឱ្យមានជំនឿលើខ្លួនឯង ចេះដោះស្រាយបញ្ហាដោយខ្លួនឯងឱ្យអស់ពីសមត្ថភាពនិងលទ្ធភាពជាមុនសិន មុននឹងពឹងពាក់កម្លាំងក្រៅខ្លួននោះ។

---

**ប្រធានទី៣**: មានមតិខ្លះយល់ថា «ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយអត្តទត្តភាព»។ ចូរពិភាក្សា ដោយរកឧទាហរណ៍មកបញ្ជាក់ឱ្យក្បោះក្បាយ។

---

## គម្រោងតែង

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា**: ក្នុងរឿងព្រះវេស្សន្តរបានបង្ហាញពីការធ្វើទានដ៏អស្ចារ្យរបស់ព្រះពោធិសត្វនៅជាតិទីដប់នេះ គឺទ្រង់ធ្វើទានទាំងរបស់គ្មានវិញ្ញាណនិងទាំងមានវិញ្ញាណដើម្បីបានត្រាស់ដឹងដោយឥតស្ដាយស្រណោះអ្វីឡើយ។
- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: ដោយសង្កេតឃើញពីឥរិយាបថនៃការធ្វើទានរបស់ព្រះពោធិសត្វដូចខាងលើនេះហើយ ទើបមានមតិខ្លះយល់ថា «ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយអត្តទត្តភាព»។
- **ចំណោទបញ្ហា**: តើមតិខាងលើនេះត្រឹមត្រូវឬទេ?

**ខ- តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី**: ជាជំនួយដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។

- **ពន្យល់ពាក្យ៖**
  - ✓ ទាន គឺសំដៅទៅលើអំណោយ ឬការឱ្យអ្វីមួយទៅបុគ្គលណាម្នាក់
  - ✓ អត្តទត្ថភាព គឺជាភាពដែលគិតតែពីផលប្រយោជន៍បុគ្គលខ្លួនឯងជាធំ។
- **ពន្យលន័យ**: មានន័យថា ការធ្វើអំណោយរបស់តួអង្គព្រះវេស្សន្តរជាការធ្វើអំណោយដោយគិតពីប្រយោជន៍ផ្ទាល់ខ្លួនជាធំលើសអ្វីៗទាំងអស់។
- **បកស្រាយ៖**

**ក- មតិស្រប** «ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយអត្តទត្ថភាព» ព្រោះព្រះអង្គបានធ្វើការបរិច្ចាគដូចជា៖

- **គំនិតសំខាន់៖**
  - ✓ ដំរីបច្ច័យនាគេន្ទ្រឱ្យជាទានដល់ព្រាហ្មណ៍ដែលជាដំរីតំណាងភាពសម្បូរសប្បាយរបស់ព្រះនគរ
  - ✓ ធនបរិច្ចាគ ជាទ្រព្យសម្បត្តិរបស់ព្រះនគរ
  - ✓ បុត្តបរិច្ចាគ ជាការលះបង់កូនជាទីស្រឡាញ់
  - ✓ ភរិយាបរិច្ចាគ ជាការលះបង់ប្រពន្ធដែលមានភក្តីភាពចំពោះព្រះអង្គ
- **ឧទាហរណ៍៖** ព្រះវេស្សន្តរ បានធ្វើការបរិច្ចាគដោយឥតក្រែងរអែងឡើយ គឺធ្វើយ៉ាងណាឱ្យតែទ្រង់បានសម្រេចក្នុងការត្រាស់ដឹងដូចជា៖
  - ✓ ហ៊ានយកដំរីបច្ច័យនាគ(បច្ច័យនាគេន្ទ្រ) ជាដំរីមង្គលនាំមកនូវភាពសម្បូរសប្បាយដល់ព្រះនគរឱ្យទៅព្រាហ្មណ៍ទាំងប្រាំបីនាក់នៅកលិង្គរាស្ត្រ ធ្វើឱ្យពួកអ្នកស្រុកស្រីពិរាស្ត្រខឹងសម្បានាំគ្នាមកសុំឱ្យព្រះបាទស្រីសញ្ជ័យ ជាបិតាទ្រង់បំបរបង់វេស្សន្តរចេញពីនគរ។
  - ✓ មុនពេលយាងចេញពីព្រះនគរ ព្រះវេស្សន្តរបានយកទ្រព្យសម្បត្តិដែលបិតាទ្រង់ប្រទានឱ្យយកទៅធ្វើសត្តសតកមហាទាន ដែលមានចំនួនសែសិបប្រាំបួនម៉ឺនមុខ មួយមុខៗមានប្រាំពីររយ ដែលជាទានដ៏អស្ចារ្យពុំមានបុគ្គលណាមួយអាចធ្វើបានដូចជាព្រះអង្គឡើយ។
  - ✓ យកជាលីនិងក្រស្នាជាបុត្រ ដែលជាទីស្រឡាញ់ឱ្យទៅជូជកទោះបីជូជកវាយដំកុមារទាំងពីរនៅចំពោះព្រះភក្ត្រទ្រង់យ៉ាងណាក៏ដោយក៏ទ្រង់នៅតែព្យាយាមអង្វរករាជបុត្រទាំងពីរឱ្យទៅតាមជូជកទាល់តែបាន
  - ✓ ព្រះអង្គបានកុហកនាងមទ្រីក្នុងការធ្វើបុត្តបរិច្ចាគ ពេលនាងមកពីបេះផ្លែឈើវិញដោយរករាជកុមារទាំងពីរពុំឃើញ ហើយព្រះអង្គចោទនាងថាទៅសហាយស្មន់ទើបមកដល់អាស្រមទាំងយប់បែបនេះ។ មិនតែប៉ុណ្ណោះព្រះអង្គយកនាងដែលជាមហេសីពេញច្បាប់និងដ៏ល្អទៅប្រទានឱ្យឥន្ទព្រាហ្មណ៍។ ទោះបីព្រះនាងបានជួយទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាបុត្រាបុត្រីនិងតស៊ូទ្រាំទ្រការលំបាកជាមួយទ្រង់យ៉ាងណាក៏ទ្រង់នៅតែដាច់ចិត្ត ហើយយកមនោសញ្ចេតនាជាប្តីប្រពន្ធមកប្រើប្រាស់ដើម្បីបំពេញតាមសំណូមពរទ្រង់ទៅវិញ។
- **សរុបមតិស្រប**: សរុបមកការធ្វើទានរបស់ព្រះវេស្សន្តរគឺពិតជាការដាក់ទានដោយអត្តទត្ថភាពប្រាកដមែន។

- **សំណួរភ្ជាប់សេចក្ដី:** តើទានរបស់ព្រះវេស្សន្តរ ពិតជាទានអត្តទត្ថភាពមែនឬយ៉ាងណា?

**ខ- មតិផ្ទុយ** «ការធ្វើទានរបស់ព្រះវេស្សន្តរ មិនមែនជាការដាក់ទាន ដោយអត្តទត្ថភាព» ព្រោះព្រះអង្គបានការលះបង់ ក្នុងបំណងជួយស្រោចស្រង់មនុស្សគឺ៖

- **គំនិតសំខាន់៖**
  - ✓ ការធ្វើទានរបស់ព្រះអង្គជាទានដោយសុទ្ធចិត្តឥតបង្ខំទាំង៖
    - ធនបរិច្ចាគ
    - បុត្តបរិច្ចាគ
    - ភរិយាបរិច្ចាគ។
  - ✓ ចម្លងសត្វលោកឱ្យរួចផុតពីអវិជ្ជា ឬសេចក្ដីល្ងង់ខ្លៅ
  - ✓ យល់ពីមូលហេតុនៃទុក្ខ
  - ✓ រកធម៌សម្រាប់រំលត់ទុក្ខ
  - ✓ ជួយជាប្រយោជន៍ដល់សង្គមមនុស្ស។
- **ឧទាហរណ៍៖** ព្រះវេស្សន្តរបានធ្វើការបរិច្ចាគដោយទឹកព្រះទ័យជ្រះថ្លា ដើម្បីប្រយោជន៍សាធារណៈ ហើយដោយឥតបង្ខំ៖
  - ✓ ការធ្វើធនបរិច្ចាគ ក្រោយពីបិតាបានប្រទានទ្រព្យធនទាំងនោះគឺមុនពេលព្រះអង្គយាងចូលព្រៃគិរីវង្កត ព្រោះព្រះអង្គមិនចង់បានអ្វីក្រៅពីការស្វែងរកធម៌តែប៉ុណ្ណោះ។ ហេតុនេះហើយបានជាព្រះអង្គដាក់ទានទាល់តែអស់ ហើយសុខចិត្តយាងចេញទៅដោយថ្មើរជើងទទេ
  - ✓ ការធ្វើបុត្តបរិច្ចាគសុទ្ធតែជាការស្ម័គ្រចិត្តដាក់ខ្លួនជាទាន ព្រោះនៅចំពោះមុខព្រះបាទស្រីសញ្ជ័យ ព្រះនាងសុបារសុប្បតី សេនាបតីនិងរាជអាមាត្យ ជាលីនិងក្រស្នាសុទ្ធតែអះអាងថា ខ្លួនមកតាមជូជកនេះបិតាឥតបានបង្ខំទេ។ មានន័យថា រាជកុមារមកដោយការពេញព្រះទ័យ។
  - ✓ ការធ្វើភរិយាបរិច្ចាគ ជាការពេញចិត្តព្រោះនាងមទ្រីបានថ្លែងនៅចំពោះព្រះភក្ត្រព្រះវេស្សន្តរនិងឥន្ទព្រាហ្មណ៍ថា កុំថាឡើយដាក់ទានរូបកាយ ទោះបីព្រាហ្មណ៍នោះប្រាថ្នាសាច់ ថ្លើម ដង្ហើម ប្រមាត់ក៏ព្រះនាងយល់ព្រមឱ្យព្រះអង្គយកព្រះខ័នមកកាត់ដើម្បីបំពេញទានបារមីនោះដែរ។
  - ✓ ចំពោះអត្ថន័យនៃការធ្វើទាននេះ ព្រះវេស្សន្តរមានបំណងស្វែងរកធម៌ ហើយត្រាស់ដឹងក្នុងការជួយដល់មនុស្សសត្វទាំងឡាយឱ្យយល់ពីជីវិតនិងឆ្លងផុតអវិជ្ជា គឺបញ្ជាក់ថាតណ្ហាជាមូលហេតុនៃទុក្ខ។ ដូចករណីអ្នកស្រុកស្រីពិរាស្ត្រដោយមូលហេតុនៃសេចក្ដីវង្វេង ព្រោះតណ្ហានេះហើយទើបការចង់រស់តែឯងមិនគិតពីភាពក្រខ្សត់របស់អ្នកស្រុកកលិង្គរាស្ត្រ ដែលកំពុងប្រឈមនឹងភាពខ្វះខាត ក៏បង្កជាទំនាស់យ៉ាងធំ។ ហេតុនេះហើយ បានជាពិភពលោកទាំងមូលតែងតែបង្កើនចំណងសហការគ្នា រួមគ្នាចែករំលែកបទពិសោធអំណោយស្បៀងអាហារក្នុងផ្លូវមនុស្សធម៌ ដើម្បីរស់ក្នុងសន្តិភាព។
- **សរុបមតិផ្ទុយ:** សរុបមកការធ្វើទានរបស់ព្រះវេស្សន្តរ គឺមិនមែនជាការដាក់ទានដោយអត្តទត្ថភាពនោះទេ តែជាការធ្វើទានដើម្បីប្រយោជន៍មនុស្សទូទៅពិតប្រាកដ។

**គ- ពិភាក្សា**: ជារួមការយល់ឃើញថា ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទាដោយអត្តទត្តភាពមិនត្រឹមត្រូវទេ ព្រោះព្រះអង្គលះបង់អ្វីៗគ្រប់យ៉ាងក៏ដើម្បីប្រយោជន៍មនុស្សទូទៅ។ ទង្វើរបស់ទ្រង់បែបនេះហើយដែលក្នុងបច្ចុប្បន្ននេះត្រូវបានគេយកមកអនុវត្តក្នុងផ្លូវមនុស្សធម៌ទូទាំងសកលលោកទៀតផង។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន**: ឆ្លងតាមការបកស្រាយខាងលើនេះបង្ហាញថាមតិប្រធានមិនត្រឹមត្រូវទេ ព្រោះជាគំនិតចង្អៀតចង្អល់មិនយល់ច្បាស់ពីឧត្តមគតិនិងពីទ្រឹស្តីសាសនាព្រះពុទ្ធពិតប្រាកដ។
- **មតិផ្ទាល់ខ្លួន**: តែទោះជាយ៉ាងណាក៏ដោយ ក៏មតិនេះចាត់ទុកជាបទពិសោធក្នុងការអប់រំអ្នកសិក្សាអ្នកអានឱ្យយល់កាន់តែច្បាស់ពីគោលបំណងនៃតួអង្គព្រះវេស្សន្តរដែលជាពោធិសត្វក្នុងទសជាតក ដែលត្រូវបំពេញទានបារមីនោះដែរ។

---

**ប្រធានទី៤**: មានមតិខ្លះពោលថា « អក្សរសិល្ប៍ប្រជា ប្រិយគ្មានតម្លៃអប់រំ»។ តើជាការត្រឹមត្រូវឬទេ? ចូរពិភាក្សាដោយរកអំណះអំណាងក្នុងរឿងអក្សរសិល្ប៍ខាងលើនេះមកបញ្ជាក់។

---

## គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា**: មនុស្សជាច្រើនជឿថា អក្សរសិល្ប៍មានតួនាទីសំខាន់ក្នុងការឆ្លុះបញ្ចាំងពីតថភាពសង្គមនិងអប់រំមនុស្សឱ្យចេះប្រព្រឹត្តអំពើល្អ។
- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: តែជាមួយនឹងតួនាទីអក្សរសិល្ប៍នេះនាំឱ្យមានមតិខ្លះយល់ថា «អក្សរសិល្ប៍ប្រជាប្រិយគ្មានតម្លៃអប់រំ»ទៅវិញ។
- **ចំណោទបញ្ហា**: តើមតិខាងលើនេះត្រឹមត្រូវឬទេ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីជាជំនួយ ដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះមុនសិន។
- ពន្យល់ពាក្យ៖
  - ✓ អក្សរសិល្ប៍ប្រជាប្រិយ ជាអក្សរសិល្ប៍ទាំងឡាយណាដែលនិយាយតៗគ្នា គ្មានកាលបរិច្ឆេទនិងគ្មានអ្នកនិពន្ធពិតប្រាកដ។
  - ✓ តម្លៃអប់រំ ជាតម្លៃនៃការទូន្មានប្រៀនប្រដៅឱ្យយើងប្រកាន់អាកប្បកិរិយាបែបណា មានគំនិតបែបណា?
- **ពន្យល់ន័យ**: មានន័យថាអក្សរសិល្ប៍ដែលនិយាយតៗគ្នា គ្មានកាលបរិច្ឆេទ និងគ្មានអ្នកនិពន្ធច្បាស់លាស់ពុំមានតម្លៃនៃការអប់រំទូន្មានឡើយ។
- បកស្រាយ៖

  **ក- មតិស្រប** «អក្សរសិល្ប៍ប្រជាប្រិយ គ្មានតម្លៃអប់រំ» ព្រោះអក្សរសិល្ប៍ប្រជាប្រិយ៖

  - **គំនិតសំខាន់៖**
    - ✓ ជារឿងដំណាលតៗគ្នាពីមាត់មួយទៅមាត់មួយមិនមានមូលដ្ឋានច្បាស់លាស់

✓ បានប្រឌិតឡើងដើម្បីបកស្រាយពី៖
- ប្រវត្តិនៃការកកើតទឹកដី
- បាតុភូតធម្មជាតិ
- ទំនៀមទម្លាប់ ប្រពៃណី
- ចំអកវិះគន់
- សម្រាប់បង្កើតភាសាសប្បាយរីករាយមួយគ្រាៗ
- ប្រឌិតឡើងដោយពុំផ្អែកលើការពិត។

▪ **ឧទាហរណ៍៖**

✓ រឿងភ្នំនាងកង្រី បានប្រឌិតពីប្រវត្តិនៃការកកើតភ្នំនាងកង្រីគឺនាងកង្រីរត់តាមពុទ្ធិសែនរហូតដួលស្លាប់ក្លាយជាភ្នំ។ ការប្រឌិតបែបបនេះ គឺគ្រាន់តែមានបំណងបង្ហាញពីមូលហេតុដែលនាំឱ្យកើតមានភ្នំដែលមានសណ្ឋានដូចជារូបមនុស្ស ដួល ដេកយ៉ាងនោះដែរ។ តែតាមការពិតអ្នកនិពន្ធក៏ពុំដឹងថាភ្នំនេះកើតពីអ្វីដែរ។

✓ រឿងព្រះចន្ទ ប្រឌិតឡើងក្នុងបំណងបកស្រាយបាតុភូតធម្មជាតិនៃព្រះចន្ទ ព្រះពាយ ពិរុណនិងព្រះអាទិត្យដែលមានបាតុភូតនិងឥទ្ធិពលមកលើមនុស្សលោកប៉ុណ្ណោះ។ ដូចជាព្រះចន្ទមានការនិយមចូលចិត្តពីគ្រប់មជ្ឈដ្ឋាននៃមនុស្សជាតិ ព្រោះបាតុភូតនេះ មានពន្លឺដ៏ត្រជាក់សមស្របនឹងទឹកចិត្តមនុស្ស។

✓ រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម(បកស្រាយបាតុភូតធម្មជាតិ) ជាពិសេសគឺបញ្ហាអាកាសធាតុដើម្បីបង្កើតសំណើច។ព្រោះជាការនិទាន គ្រាន់តែដើម្បីបកស្រាយព្រឹត្តិការណ៍ដែលមានស្រាប់ហើយដែលពុំមានហេតុផលច្បាស់លាស់

✓ រឿងដើរខ្យល់ (បកស្រាយពីការចំអកវិះគន់នៃសកម្មភាពបុគ្គល)។ ព្រោះជាការនិទាន គ្រាន់តែដើម្បីបកស្រាយព្រឹត្តិការណ៍ដែលមានស្រាប់ហើយដែលពុំមានហេតុផលច្បាស់លាស់។

▪ **សរុបមតិស្រប:** ដូច្នេះ អក្សរសិល្ប៍ប្រជាប្រិយពិតជាគ្មានតម្លៃអប់រំប្រាកដមែន។

**ខ- មតិផ្ទុយ** «អក្សរសិល្ប៍ប្រជាប្រិយ មិនមែនគ្មានតម្លៃអប់រំទេ»ព្រោះអក្សរសិល្ប៍ប្រជាប្រិយបាន៖

▪ **គំនិតសំខាន់៖**

✓ ស្គាល់ពីផ្នត់គំនិតខ្មែរសំខាន់ៗ(ទំនៀមទម្លាប់ប្រពៃណី ជំនឿ)

✓ ឱ្យចេះប្រកាន់ភាពកតញ្ញូចំពោះអ្នកមានគុណ

✓ ឱ្យចេះរួបរួមសាមគ្គីគ្នា ឯកភាពគ្នា

✓ ផ្តល់ចំណេះដឹងអំពីព្រឹត្តិការណ៍អតីត។

▪ **ឧទាហរណ៍៖**

✓ រឿងភ្នំនាងកង្រីបានឱ្យស្គាល់ពីផ្នត់គំនិតខ្មែរសំខាន់ៗ ដែលមានតាំងពីបុរាណមកម្ល៉េះ ដូចជា៖
- ការជឿលើការបន់ស្រន់ គឺសេដ្ឋីបានទៅបន់ស្រន់សុំកូនពីដើមជ្រៃ ក៏បានសម្រេចតាមបំណងដែលមានកូនស្រីដល់ទៅ១២នាក់។

- ជឿកម្មពៀរវេរាក្នុងសង្គមខ្មែរ នាងទាំង១១ត្រូវគេឆ្កៀលភ្នែកទាំងសងខាងមកពីជាតិមុននាងឆ្កៀលភ្នែកត្រីទាំងសងខាងដែរ។ រីឯនាងទី១២ត្រូវគេឆ្កៀលភ្នែកតែម្ខាងមកពីជាតិមុននាងឆ្កៀលភ្នែកត្រីតែម្ខាងដែរ។
- ភាពកតញ្ញូ ពុទ្ធិសែនសុខចិត្តចាកចេញពីនាងកង្រីទៅសង្គ្រោះអ្នកមានគុណដោយទុកស្នេហាមួយអន្លើរហូតធ្វើឱ្យនាងបាត់បង់ជីវិត។ នេះគឺបញ្ជាក់ពីការដឹងគុណចំពោះម្តាយដែលមានក្នុងសង្គមខ្មែរ។
- ភក្តីភាព ដោយសារតែភក្តីភាពនាងកង្រីបានព្យាយាមរត់តាមពុទ្ធិសែនរហូតត្រូវបាត់បង់ជីវិត។

✓ រឿងព្រះចន្ទ អប់រំកូនឱ្យស្គាល់គុណធម៌ ចេះគោរព មាតាបិតា ទើបទៅដល់ទីណាៗមានរាប់អានពីអ្នកដទៃ។

✓ រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្មអប់រំឱ្យយើង ចេះសាមគ្គីគ្នាឯកភាពគ្នាគ្រប់សមាសភាព មិនរើសអើងដើម្បីបំណងប្រាថ្នារួមគ្នា។ ដូចជាគីង្គក់ ត្រីក្រាញ់ ផ្តៅ ឃ្មុំ ត្រសក់... ដើម្បីទាមទារទឹកភ្លៀងពីតាព្រហ្មទីបំផុតក៏បានសម្រេច។

✓ រឿងដើរខ្យល់ អប់រំឱ្យមើលឃើញពីភាពខុសគ្នានៃទស្សនៈឬគំនិតរវាងអ្នកមានអំណាច និងអ្នកគ្មានអំណាចក្នុងសម្តែងមតិឬគំនិតយោបល់។

- **សរុបផ្តុំ**: ដូច្នេះអក្សរសិល្ប៍ប្រជាប្រិយពិតជាមានតម្លៃអប់រំប្រាកដមែន។

**គ- ពិភាក្សា**: ការយល់ថាអក្សរសិល្ប៍ប្រប្រិយគ្មានតម្លៃអប់រំនោះ មិនមែនជាការត្រឹមត្រូវឡើយ ព្រោះថា តួនាទីអក្សរសិល្ប៍តែងតែមានបំណងអប់រំមនុស្សគ្រប់ស្រទាប់តាមរយៈសកម្មភាពតួអង្គក្នុងរឿងដើម្បីជាប្រយោជន៍ឱ្យអ្នកសិក្សា អ្នកអានចេះពិចារណានិងអនុវត្តឱ្យបានត្រឹមត្រូវ។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន**: មតិប្រធានមិនត្រឹមត្រូវទេ ព្រោះជាគំនិតដែលមិនស្គាល់ពីតួនាទីសំខាន់នៃអក្សរសិល្ប៍ពិតប្រាកដ។
- **មតិផ្ទាល់ខ្លួន**: ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មតិខាងលើនេះបានផ្តល់ជាបទពិសោធដល់អ្នកសិក្សាគ្រប់រូបកាន់តែមើលឃើញពីតួនាទីសំខាន់របស់អក្សរសិល្ប៍ក្នុងការឆ្លុះបញ្ចាំងពីតថភាពសង្គម ព្រមទាំងអប់រំថែមទៀតដល់អ្នកអាននិងអ្នកសិក្សា។

## ប្រធានពិភាក្សាប្រៀបធៀប

**ប្រធានទី១:** ក្នុងរឿងគូលីកំណៃនមានមតិខ្លះយល់ថា «បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាស្វាមីនាងពិតជាមានសុភមង្គល»។ តែមតិខ្លះទៀតយល់ថា «បើនាងហេងរួមរស់នៅជាមួយលឹមពិតជាមានសុភមង្គល»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងសង្គមនិងរឿងខាងលើនេះមកបញ្ជាក់។

### គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា:** ការរស់នៅមានគូស្រករនិងអាពាហ៍ពិពាហ៍គឺជាផ្នែកមួយឱ្យស្ត្រីមានសុភមង្គលឬនាំឱ្យគ្មានសុភមង្គល គឺជាការចាំបាច់ចំពោះនារីម្នាក់ៗក្នុងជីវិតអាពាហ៍ពិពាហ៍ ដើម្បីជ្រើសរើសគូស្រករបានរស់នៅរហូតចាស់ព្រឹទ្ធចាស់ព្រេង។
- **ចំណូលបញ្ហា(បង្ហាញប្រធាន):** ដោយក្តីបារម្ភចំពោះការជ្រើសរើសគូអនាគតរបស់ខ្លួនដូចខាងលើនេះហើយ ទើបក្នុងរឿងគូលីកំណៃនមានមតិខ្លះយល់ថា «បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាស្វាមីនាងពិតជាមានសុភមង្គល»។ តែមតិខ្លះទៀតយល់ថា «បើនាងហេងរួមរស់នៅជាមួយលឹមពិតជាមានសុភមង្គល»។
- **ចំណោទបញ្ហា:** តើមតិទាំងពីរខាងលើនេះមួយណាត្រឹមត្រូវជាង?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីរួមចំណែកដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។
- **ពន្យល់ពាក្យ៖**
  - ✓ ស្វាមី ជាប្តីដែលបានរៀបការទៅតាមប្រពៃណីនិងស្របតាមផ្លូវច្បាប់
  - ✓ សុភមង្គល សេចក្តីសុខគ្រប់យ៉ាងរបស់មនុស្សទាំងខាងផ្លូវកាយនិងផ្លូវចិត្ត
  - ✓ រួមរស់ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធអស់មួយជីវិត។
- **ពន្យល់ន័យ:** តាមមតិទីមួយមានន័យថា បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាប្តីនាងពិតជាមានសេចក្តីសុខ។ រីឯមតិទីពីរមានន័យថា បើនាងហេងរស់នៅជាមួយលឹមអស់មួយជីវិតជាប្តីប្រពន្ធនាងពិតជាមានសេចក្តីសុខ។
- **បកស្រាយ៖**
  - **ក- មតិទី១** «បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាស្វាមីនាងពិតជាមានសុភមង្គល» ព្រោះលោកចៅហ្វាយមាន៖
    - ▪ **គំនិតសំខាន់៖**
      - ✓ អំណាចបុណ្យសក្តិ ទ្រព្យសម្បត្តិ
      - ✓ ចំណេះវិជ្ជា សមត្ថភាពគ្រប់គ្រងក្នុងស្រុកកណ្តាលស្ទឹង
      - ✓ ចំណេះវិជ្ជា
      - ✓ ការគោរពពីសំណាក់អ្នកក្រោមបង្គាប់។

- **ឧទាហរណ៍៖** រឿងគូលីកំណែន: លោកថៅហ្វាយជាមនុស្សពោរពេញទៅដោយអំណាច បុណ្យសក្តិនិងមានកិត្តិយសដែលអ្នកផងទាំងពួង ជាពិសេសមេឃុំផាន់ ព្រមទាំងប្រជារាស្ត្រដែលរស់នៅឃុំគោកចំបក់ទាំងអស់តែងគោរពកោតខ្លាច។ លោកមានទាំងអំណាច មានទាំងកម្លាំងប្រដាប់អាវុធដែលនៅចាំការពារលោក ឬរង់ចាំទទួលភារកិច្ចនៅពេលាដែលលោកបញ្ជា។ ហេតុដូច្នេះ បើសិនជានាងហេងយល់ព្រមទទួលលោកនិងរស់នៅជាមួយលោក នាងនឹងបានអ្វីៗគ្រប់យ៉ាង ដែលស្ត្រីទាំងអស់ក្នុងលោកតែងប្រាថ្នាចង់បាន។ មិនតែប៉ុណ្ណោះនាហេងក្តី គ្រួសារនាងក្តីសុទ្ធតែមានអំណាចហើយសត្រូវរបស់នាងមិនហ៊ានមករំខានឬធ្វើបាបដល់ក្រុមគ្រួសារនាងឡើយ ព្រោះនាងមានលោកថៅហ្វាយជាខ្នងបង្អែករួចទៅហើយ។
- **សរុបមតិទី១**: សរុបសេចក្តីមក បើនាងហេងយល់ព្រមទទួលលោកថៅហ្វាយធ្វើជាស្វាមី នាងពិតជាមានសុភមង្គលប្រាកដមែន។
- **សំណួរភ្ជាប់សេចក្តី**: ក្រៅពីលោកថៅហ្វាយ តើអ្នកណាទៀត ដែលនាំមកនូវសុភមង្គលជូនដល់នាងហេង?

**ខ- មតិទី២** «បើនាងហេងរួមរស់នៅជាមួយលឹមពិតជាមានសុភមង្គល»ព្រោះលឹម៖

- **គំនិតសំខាន់៖**
  - ✓ មានចិត្តស្មោះត្រង់
  - ✓ មានសីលធម៌ល្អ
  - ✓ មានចំណេះដឹងទាំងខាងផ្លូវលោក និងទាំងខាងផ្លូវធម៌
  - ✓ ចេះគោរពតាមប្រពៃណីក្នុងការផ្តាប់ចិត្តអនាគតឪពុកក្មេកម្តាយក្មេក
  - ✓ បានបំពេញតាមកិច្ចដែលជាប្រពៃណីខ្មែរ
  - ✓ អ្នកទាំងពីរធ្លាប់បានស្គាល់ចិត្តថ្លើមគ្នាហើយ
  - ✓ ស្នេហាអ្នកទាំងពីរជាស្នេហាយកំលោះក្រមុំតាមបែបបធម្មជាតិពោលគឺការស្រឡាញ់គ្នាទៅវិញទៅមក។
- **ឧទាហរណ៍៖** រឿងគូលីកំណែន លឹមធ្លាប់បានទៅនៅផ្ទះនាងហេងតាមរយៈការផ្តាប់ចិត្តពូស្វាយមីងពត ហើយពូស្វាយក៏មានចិត្តស្រឡាញ់លឹមដែរ។មិនតែប៉ុណ្ណោះ អ្នកទាំងពីរធ្លាប់បានជាន់អង្ករជាមួយគ្នា រែកអាចម៍គោចាក់ ស្រែថ្នាន់ ហើយអ្នកទាំងពីរក៏មានចិត្តស្រលាញ់គ្នាទៅវិញទៅមក។ នាងហេងបានសន្យាជាមួយលឹមថា «ប្តូរផ្តាច់ដូចទាវនឹងឯក ប្រកែកមិនព្រមធ្វើស្នំមហេសីព្រះរាមាឡើយ»។ ក្រៅពីនេះទៀតលឹមជាអ្នកចេះវិភាគបញ្ហាសង្គម ចេះពិចារណាបានត្រឹមត្រូវ រាល់ហេតុការណ៍ ទាំងឡាយដែលបានកើតឡើង។
- **សរុបមតិទី២**: សរុបសេចក្តីមក បើនាងហេងរួមរស់នៅជាមួយលឹម នាងពិតជាមានសុភមង្គលប្រាកដមែន។

**គ- ពិភាក្សា**: ជារួមបើនាងហេងទទួលយកលោកថៅហ្វាយធ្វើជាស្វាមី នាងពិតជាគ្មានសុភមង្គលឡើយ ព្រោះលោកថៅហ្វាយមិនមានមែនជាកំលោះដែលមានចិត្តស្មោះនោះទេ ទោះបីជាគាត់មានទ្រព្យ អំណាច បុណ្យសក្តិយ៉ាងណាក៏ដោយ គឺគាត់មានចរិតពាលាអាវាសែ មានស្នេហ៍មិនស្មោះ។ តែបើសិនជានាងរួមរស់នៅជាមួយលឹម នាងពិតជាមាន

សុភមង្គល ព្រោះអ្នកទាំងពីរមានចាស់ទុំដឹងឮ ហើយបានបំពេញទៅតាមប្រពៃណីជាតិ គឺបានភ្ជាប់ពាក្យរួចហើយ នៅសល់តែមួយខែទៀតនឹងរៀបការ។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: មតិទីមួយរបស់ប្រធានមិនត្រឹមត្រូវទេ ព្រោះជាគំនិត ដែលគាំទ្រចរិតពាលាអាវាសែរបស់លោកចៅហ្វាយដែលគ្មានសីលធម៌ស្អាតស្អំក្នុងការដឹកនាំប្រជារាស្ត្រ។ ចំណែកមតិទីពីរមានភាពស្រមស្របជាង ព្រោះទទួលស្គាល់ការពិតនៃតម្លៃជីវិតដែលពោរពេញទៅដោយសុភមង្គល។
- **មតិផ្ទាល់ខ្លួន**: ដូច្នេះនាមជាអ្នកសិក្សាយើងគប្បី ចេះជ្រើសរើសសុភមង្គលណាមួយ ដែលជាសុភមង្គលយូរអង្វែងពុំមានការបង្ខិតបង្ខំនោះ ទើបជំរុញឱ្យជីវិតរបស់យើងមានតម្លៃនិងប្រកបទៅដោយសេចក្ដីសុខ។

---

**ប្រធានទី២**: មានមតិមួយពោលថា « វិជ្ជាប្រសើរជាងទ្រព្យ »។ តែមតិខ្លះទៀតយល់ថា «ទ្រព្យប្រសើរជាងវិជ្ជា»។ ចូរពិភាក្សា ដោយរកឧទាហរណ៍មកបញ្ជាក់។

---

## គម្រោងតែង

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា**: មនុស្សគ្រប់រូបដែលរស់រានមានជីវិតលើលោកិយសន្និវាសយើងនេះ តែងតែប្រាថ្នាចង់ធ្វើឱ្យជីវិតខ្លួនរស់ក្នុងជីវភាពមួយ ដ៏ប្រសើរសម្រាប់អនាគតរបស់ខ្លួនដ៏រុងរឿង ហើយជាមួយនោះវិជ្ជាសម្បត្តិនិងទ្រព្យសម្បត្តិក៏ត្រូវបានគេចាត់ទុកថា ជាគ្រឿងធ្វើឱ្យជីវិតមានភាពល្អប្រសើរដែរ។
- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: ដោយមានគោលបំណងដូចខាងលើនេះ ទើបជុំវិញនៃការពិចារណាទៅលើអនាគតរបស់ខ្លួនមានមតិមួយពោលថា«វិជ្ជាប្រសើរជាងទ្រព្យ»។ តែមតិខ្លះទៀតយល់ថា«ទ្រព្យប្រសើរជាងវិជ្ជា»។
- **ចំណោទបញ្ហា**: តើមតិទាំងពីរខាងលើនេះ មួយណាត្រឹមត្រូវជាង?

**ខ- តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី**: ដើម្បីជាជំនួយដល់ការបកស្រាយពាក្យចាស់ខាងលើនេះយើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។
- **ពន្យល់ពាក្យ៖**
  - ✓ វិជ្ជា គឺជាចំណេះដឹងគ្រប់យ៉ាង ឬជាជំនាញឯកទេសណាមួយ។
  - ✓ ប្រសើរ  គឺជាការល្អប្រពៃ ឧត្ដុង្គឧត្ដម ថ្លៃថ្លា។
  - ✓ ទ្រព្យ គឺធនធានទាំងឡាយដូចជាមាសពេជ្រ លុយកាក់ ឬប្រដាប់ប្រើប្រាស់គ្រប់យ៉ាង។
- **ពន្យល់ន័យ៖**
  - ✓ មតិទី១ មានន័យថា ចំណេះដឹងឬជំនាញគ្រប់យ៉ាងមានភាពល្អប្រសើរជាងធនធានឬទ្រព្យម្បត្តិ
  - ✓ មតិទី២ មានន័យថា ទ្រព្យធនគ្រប់យ៉ាង ល្អប្រសើរជាងចំណេះឬជំនាញណាមួយ។

- បកស្រាយ៖
  ក- មតិទី១ «វិជ្ជាប្រសើរជាងទ្រព្យ» ព្រោះវិជ្ជា ៖
  - **គំនិតសំខាន់៖**
    - ✓ ចោរលួចមិនបាន ភ្លើងមិនឆេះ
    - ✓ កណ្តៀរក៏មិនកោរ កណ្តុរក៏មិនកាត់
    - ✓ មិនចេះសាបសូន្យ
    - ✓ ធ្វើឱ្យមនុស្សមានជីវភាពធូរធារ
    - ✓ មានកិត្តិយស កេរ្តិ៍ឈ្មោះ
    - ✓ មានការគោរពរាប់អានពីអ្នកដទៃ
    - ✓ នាំមកនូវសុភមង្គលក្នុងជីវិត
    - ✓ ឱ្យចេះវិភាគរាល់បញ្ហាដែលកើតមានឡើងចំពោះមុខ
    - ✓ ចេះស្រាយទំនាស់ដែលកើតមានឡើង។
  - **ឧទាហរណ៍៖**

    ក្នុងសង្គម ការរស់នៅរបស់មនុស្សម្នាក់ៗចាំបាច់ត្រូវមានចំណេះ ឬជំនាញណាមួយពិតប្រាកដទើបធ្វើឱ្យការរស់នៅរបស់ខ្លួនមានភាពប្រសើរដូចជា៖
    - ✓ ជាងឈើ ជាងដែក ជាងអគ្គិសនី ជាងធ្វើផ្ទះ ជាងទង ជាងចម្លាក់ ...
    - ✓ វិស្វករ អ្នកឯកទេសខាងឧស្សាហកម្ម ខាងកសិកម្ម...
    - ✓ អ្នកទីផ្សារ អ្នកគ្រប់គ្រង សេដ្ឋវិទូ ...

    សុទ្ធតែពឹងផ្អែកលើចំណេះវិជ្ជាខ្លួនក្នុងការប្រកបរបរចិញ្ចឹមជីវិត ហើយម្នាក់ៗសុទ្ធតែមានជីវភាពយ៉ាងប្រសើបំផុត។ ដោយសារតែចំណេះរបស់ខ្លួន។
    - ✓ ក្នុងអក្សរសិល្ប៍៖
      - **រឿងទុំទាវ:** ដោយសារតែទុំមានចំណេះវិជ្ជាខាងស្មូត និងពេជ្រមានចំណេះខាងផ្លុំប៉ីអ្នកទាំងពីរអាចចូលធ្វើការនៅក្នុងរាជវាំង បានបុណ្យសក្តិ(ទុំជាម៉ឺនឯក)។
      - **រឿងកុលាបប៉ៃលិន:** ដោយសារតែចៅចិត្រមានចំណេះចេះជួសជុលរថយន្ត ចេះបើកបរ ទើបចៅចិត្រអាចបម្រើការនៅផ្ទះលោកហ្លួងរតនសម្បត្តិ។
      - **រឿងកុមារកំព្រា:** ដោយសារតែកុមារប្អូនចេះ និងយល់ពីរបៀបធ្វើជុច និងដាក់ជុចទើបគេមានជីវភាពប្រសើរ។
  - **សរុបមតិទី១:** សរុបមក ចំណេះវិជ្ជាពិតជាប្រសើរជាងទ្រព្យសម្បត្តិប្រាកដមែន។
  - **សំណួរភ្ជាប់សេចក្តី:** តើចំណេះវិជ្ជា ពិតជាប្រសើរជាងទ្រព្យសម្បត្តិមែន ឬយ៉ាងណា?

  ខ- មតិទី២ «ទ្រព្យប្រសើរជាងវិជ្ជា»ព្រោះទ្រព្យ៖
  - **គំនិតសំខាន់៖**
    - ✓ ជួយសម្រេចគ្រប់បំណងប្រាថ្នារបស់មនុស្ស
    - ✓ នាំមកនូវសុភមង្គល នាំឱ្យមានកិត្តិយស និងនាំឱ្យចំណេះវិជ្ជា
    - ✓ នាំឱ្យមានការរាប់អានពីអ្នកដទៃ
    - ✓ ជួយទ្រទ្រង់សុខភាព។

- **ឧទាហរណ៍៖**
  - ✓ ក្នុងសង្គម ការរស់នៅរបស់មនុស្សម្នាក់ៗចាំបាច់ត្រូវមានទ្រព្យសម្បត្តិ ទើបធ្វើឱ្យការរស់នៅរបស់ខ្លួនមានភាពប្រសើរដូចជា៖ មហាសេដ្ឋី ពាណិជ្ជករ អាជីវករ ឈ្មួញដែលមានទ្រព្យសម្បត្តិច្រើន មានជីវភាពស្តុកស្តម្ភ អាចធ្វើអ្វីៗគ្រប់យ៉ាងតាមចិត្តខ្លួនចង់ (ទិញផ្ទះ រថយន្ត ឬ...)។
  - ✓ ក្នុងអក្សរសិល្ប៍៖
    - **រឿងកុលាបបលិន**: ដោយសារតែលោកហ្លួងរតនសម្បត្តិមានទ្រព្យសម្បត្តិជាច្រើនដែលនាំឱ្យលោកមានកិត្តិយសនិងត្រូវបានទទួលការរាប់អានពីសំណាក់កម្មករ។
    - **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់**: ដោយសារតែថៅកែសេងអានមានទ្រព្យសម្បត្តិក៏អាចបើករោងឧស្សាហកម្មផលិតសាប៊ូ ដោយមានកម្មករជាច្រើននាក់ ដូចជាសម ជាដើម។
- **សរុបមតិទី២**: ទ្រព្យពិតជាប្រសើរជាងចំណេះវិជ្ជាប្រាកដមែន។

**គ- សំយោគមតិ**: ជារួមទ្រព្យសម្បត្តិ និងចំណេះវិជ្ជា មានភាពប្រសើរដូចគ្នា ព្រោះបើមិនមានទ្រព្យ ក៏មិនអាចរកវិជ្ជាបានដែរគឺវិជ្ជា ចាំបាច់ត្រូវមានទ្រព្យសម្បត្តិ លុយកាក់ ទើបអាចបំពេញចំណេះវិជ្ជាបាន។ នៅពេលដែលគេមានចំណេះវិជ្ជាហើយ គេក៏អាចប្រើចំណេះដែលខ្លួនមានយកមកប្រើប្រាស់ ដើម្បីទាក់ទាញយកទ្រព្យនោះមកវិញ។ ដូច្នេះវិជ្ជានិងទ្រព្យសម្បត្តិគឺជាធាតុពីរដែលជួយបំពេញគ្នាទៅវិញទៅមក។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: មតិនីមួយៗរបស់ប្រធាន មានភាពសមហេតុសមផលម្យ៉ាងម្នាក់ តែមិនទាន់គ្រប់ជ្រុងជ្រោយ ព្រោះជាមតិដែលឱ្យតម្លៃទៅតាមគោលជំហរនីមួយៗរបស់បុគ្គលតែប៉ុណ្ណោះ។
- **មតិផ្ទាល់ខ្លួន**: ទោះជាយ៉ាងណាក៏ដោយ ក៏មតិខាងលើនេះអាចចាត់ទុកជាបទពិសោធក្នុងការអប់រំដល់អ្នកសិក្សាឱ្យស្គាល់ពីតម្លៃរបស់ទ្រព្យនិងចំណេះពិតប្រាកដ។

## ប្រធានអត្ថាធិប្បាយប្រៀបធៀប

ប្រធានទី១: ចូរអ្នកធ្វើការប្រៀបធៀបលក្ខណសម្បត្តិនាងសីតាក្នុងរឿងរាមកេរ្តិ៍ និងលក្ខណសម្បត្តិនាងមទ្រីក្នុងរឿងព្រះវេស្សន្តរ។ តើនារីទាំងពីរនេះមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

### គម្រោងតែង

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា**: រូបសម្បត្តិរបស់នារីពិតជាកត្តាសំខាន់ក្នុងការទាក់ទាញឬឱ្យចាប់អារម្មណ៍ពីបុរសទាំងឡាយជាមួយនោះលក្ខណសម្បត្តិខាងក្នុងក៏ជាការចាំបាច់ក្នុងការឱ្យតម្លៃទៅនារីឬស្ត្រីដែលមាននៅក្នុងសង្គមនោះដែរ។
- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: ចំពោះភាពចាំចាច់នៃលក្ខណសម្បត្តិរបស់នារីនេះក៏ត្រូវបានកវីនិពន្ធយើងលើកយកមកបង្ហាញនៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរតាមរយៈរឿងរាមកេរ្តិ៍ គឺនាងសីតានិងរឿងព្រះវេស្សន្តគឺនាងមទ្រីដែរ។

- **ចំណោទបញ្ហា**: តើនារីទាំងពីររូបខាងលើមានលក្ខណសម្បត្តិដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

ខ- **តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីធ្វើជំរុញឱ្យការប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គទាំងពីរខាងលើនេះ យើងគប្បីស្វែងយល់ន័យរបស់ពាក្យលក្ខណសម្បត្តិជាមុនសិន។
- **ពន្យល់ពាក្យ**: លក្ខណសម្បត្តិគឺសំដៅទៅលើចរិតលក្ខណៈគ្រប់យ៉ាងរបស់តួអង្គឬរបស់មនុស្សដែលស្តែងចេញតាមរយៈសកម្មភាព។
- **ពន្យល់ន័យ**: តាមគំនិតប្រធានខាងលើបានតម្រូវឱ្យយើងធ្វើការប្រៀបធៀបរវាងចំណុចដូចគ្នា និងចំណុចខុសគ្នា នៃចរិតលក្ខណៈរបស់នាងសីតាជាមហេសីព្រះរាម និងនាងមទ្រីជាមហេសីរបស់ព្រះវេស្សន្តរ។
- បកស្រាយ៖

**ក- លក្ខណៈដូចគ្នានៃលក្ខណសម្បត្តិនាងសីតា និងនាងមទ្រី៖**

- **គំនិតសំខាន់ និងឧទាហរណ៍៖**
  - ✓ ស្រស់ស្អាតពេញលក្ខណៈជានារី(នាងសីតាជាកំពូលនារីល្អឯក ដែគូនៃអវតារព្រះវិស្ណុ តាមបែបព្រាហ្មណ៍និយម។ នាងមទ្រី ជាកន្សែសារពេជ្ជ ជាដៃគូនៃព្រះពោធិសត្វ តាមបែបពុទ្ធនិយម)
  - ✓ នារីទាំងពីរពោរពេញទៅដោយភក្តីភាពចំពោះស្វាមីរបស់នាង៖
    - ពេលក្រុងរាពណ៍ចាប់នាងសីតា យកទៅលង្កា តែនាងនៅតែរក្សាភាពបរិសុទ្ធ និងពេលដែលព្រះរាមចេញទៅសាងផ្នួសក្នុងព្រៃដប់បួនឆ្នាំ ក៏នាងស្ម័គ្រចិត្តយាងទៅតាមព្រះអង្គដែរ
    - នាងមទ្រីពេលព្រះវេស្សន្តរត្រូវគេបំបរបង់ឱ្យព្រះអង្គចូលព្រៃគិរីវង្កតនាងក៏ចាកចេញតាមព្រះវេស្សន្តរដែរ
  - ✓ នារីទាំងពីរសុទ្ធតែយាងចេញតាមព្រះស្វាមីទៅរស់នៅក្នុងព្រៃ(សីតាយាងចេញតាមព្រះរាមទៅសាងផ្នួសក្នុងព្រៃ នាងមទ្រី យាងចេញតាមព្រះវេស្សន្តរស្វែងរកធម៌ក្នុងព្រៃ)។
- **សរុបលក្ខណៈដូច**: សរុបសេចក្តីមក ចំណុចសំខាន់ៗខាងលើនេះសុទ្ធសឹងជាលក្ខណៈដូចគ្នានៃលក្ខណសម្បត្តិរបស់នាងសីតា និងនាងមទ្រី។

**ខ- លក្ខណៈខុសគ្នានៃលក្ខណសម្បត្តិនាងសីតា និងនាងមទ្រី**

- **គំនិតសំខាន់ និងឧទាហរណ៍៖**
  - ✓ **ចំពោះនាងសីតា៖**
    - នាងជានារីល្អឯកតាមលទ្ធិព្រាហ្មណ៍និយម គឺត្រូវជួយបំពេញកាតព្វកិច្ច ចំពោះអវតាររបស់ព្រះវិស្ណុ
    - នាងត្រូវព្រះរាមសព្វព្រះទ័យយកនាងធ្វើជាមហេសីដោយសមត្ថភាពក្នុងការប្រឡងលើកធ្នូឈ្នះអស់ទេវៈក្នុងឋានទាំងបី
    - ព្រះនាងមានរាជបុត្រតែមួយអង្គគឺរាមលក្សណ៍
    - នាងពោរពេញទៅដោយឆន្ទៈស្មោះត្រង់ គឺម៉ឺងម៉ាត់
    - នាងប្រកាន់យកពាក្យសត្យ

- នាងក្លាហាន និងទទួលខុសត្រូវ ទោះបីនាងស្រឡាញ់ព្រះរាមក៏ដោយក៏នាងមិនខ្លាចចាកចេញពីព្រះរាមទេ។

✓ **ចំពោះនាងមទ្រី៖**

- នាងជានារីស្រស់ស្អាតតាមបែបពុទ្ធនិយម គឺជាកន្សែស្រារពេជ្ជជាអ្នកជួយបំពេញបារមីដល់ព្រះពោធិសត្វ
- នាងស្លូតបូតនិងទន់ភ្លន់ ចេះជួយដោះស្រាយបញ្ហាចំពោះមុខ
- នាងមានព្រះទ័យមេត្តាគោរពតាមព្រះរាជបំណងព្រះស្វាមីជានិច្ច ទោះជាធ្វើបុត្តបរិច្ចាគ ឬភរិយាបច្ចាគក្តី
- នាងពេញព្រះទ័យក្នុងការគាំទ្រឧត្តមគតិសាសនានៃទានបរិច្ចាគរបស់ព្រះវេស្សន្តរជានិច្ច
- នាងមានការតស៊ូរស់នៅក្នុងព្រៃតាំងពីដើមដល់ចប់គឺនៅបម្រើព្រះវេស្សន្តរហូតមកនិងចិញ្ចឹមជាលីក្រស្នា

▪ **សរុបលក្ខណៈខុស:** សរុបសេចក្តីមកចំណុចដែលបង្ហាញខាងលើនេះសុទ្ធសឹងជាលក្ខណៈខុសគ្នានៃលក្ខណសម្បត្តិរបស់នាងសីតា និងនាងមទ្រី។

**គ- សរុបរួម:** ភស្តុតាងខាងលើនេះ ជាចំណុចដូចគ្នានិងចំណុចខុសគ្នារវាងលក្ខណសម្បត្តិនាងសីតានិងនាងមទ្រី។ ថ្វីបើតួអង្គទាំងពីរស្ថិតក្នុងចលនាអក្សរសិល្ប៍ដទៃពីគ្នាក៏ពិតមែន តែនារីទាំងពីរនេះ នេះមានលក្ខណៈរួមមួយគឺសុទ្ធសឹងជាតួអង្គតំណាងឱ្យស្ត្រីខ្មែរគ្រប់រូបដែលពោរពេញទៅដោយភក្តីភាពនិងបានបំពេញកាតព្វកិច្ចល្អចំពោះស្វាមីក្នុងគ្រួសារជានិច្ច។

## គ- បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន:** ឆ្លងតាមការប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញថា ទាំងនាងមទ្រីនិងទាំងនាងសីតាសុទ្ធតែមានលក្ខណសម្បត្តិល្អប្រសើរដូចគ្នា ព្រោះអ្នកទាំងពីរ គឺជាតួអង្គពោរពេញទៅដោយឧត្តមគតិក្នុងការលះបង់អ្វីៗគ្រប់យ៉ាងដើម្បីសម្រេចឬគាំទ្របំណងស្វាមីដូចៗគ្នា។
- **មតិផ្ទាល់ខ្លួន:** ជាមួយគ្នានេះដែរ លក្ខណសម្បត្តិនៃនារីទាំងពីរនេះគឺជាការឆ្លុះបញ្ចាំងអំពីតម្លៃនារីខ្មែរ ក្នុងការគ្រប់គ្រងគ្រួសារឬលើកតម្លៃគ្រួសារគ្រប់កាលៈទេសៈឱ្យឆ្ពោះទៅរកឧត្តមភាពនិងសុភមង្គលពិតប្រាកដ។

---

**ប្រធានទី២:** ចូរអ្នកប្រៀបធៀបខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ និងខ្សែជីវិតតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។ តើមានចំណុចដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

---

# គម្រោងតែង

## ក- ផ្តើមសេចក្តី

- **លំនាំបញ្ហា:** បើនិយាយពីដំណើរជីវិតរបស់មនុស្សក្នុងលោកយើងនេះ មានច្រើនបែបច្រើនយ៉ាងដោយបុគ្គលខ្លះពុះពារនឹងជីវិត តែបន្តិចបន្តួចក៏មានជីវភាពល្អប្រណីតរស់ក្នុងស្ថានភាព

ស្អុកស្អម្ភ រីឯបុគ្គលខ្លះទៀតខិតខំស្រវាស្រទេញ ប្រឈមក្នុងជីវិតគ្រប់បែបយ៉ាង តែជីវភាពបែរជាលំបាកតោកយ៉ាកស្ទើរគ្មានសេចក្ដីសុខក្នុងមួយជីវិតខ្លួនទៅវិញ។

- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: យ៉ាងនេះហើយ ទើបជុំវិញនៃដំណើរជីវិតរបស់មនុស្សនេះ នៅក្នុងរឿងថៅកែចិត្តចោរ និងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធក៏បានឆ្លុះបញ្ចាំពីខ្សែជីវិតតួអង្គហំនិងតួអង្គសមមកបង្ហាញដល់អ្នកអាននិងអ្នកសិក្សាដែរ។
- **ចំណោទបញ្ហា**: តើខ្សែជីវិតរបស់តួអង្គទាំងពីរខាងលើនេះមានចំណុចដូចគ្នានិងចំណុចខុសគ្នាយ៉ាងណាខ្លះ?

ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី**: មុននឹងឈានចូលដល់ការប្រៀបធៀបខ្សែជីវិតតួអង្គទាំងពីរខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។
- **ពន្យល់ពាក្យ**: ខ្សែជីវិត ដំណើរជីវិត ឬការប្រព្រឹត្តទៅក្នុងមួយជីវិតរបស់បុគ្គលម្នាក់ៗ។
- **ពន្យល់ន័យ**: តាមគំនិតប្រធានបានតម្រូវឱ្យធ្វើការបង្ហាញនូវលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នានៃការប្រព្រឹត្តទៅក្នុងមួយជីវិតរបស់តួអង្គហំក្នុងរឿងថៅកែចិត្តចោរនិងតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។
- បកស្រាយ៖

  ក- លក្ខណៈដូចគ្នានៃខ្សែជីវិតតួអង្គហំ និងខ្សែជីវិតតួអង្គសម៖

  - **គំនិតសំខាន់ និងឧទាហរណ៍៖**
    - ✓ ស្ថានភាពក្រីក្រលំបាកដូចគ្នា (ហំជាអ្នកបើកបរឡានឈ្នួលថៅកែចិត្តចោរសមជាកម្មករស៊ីក្លូ )
    - ✓ ត្រូវថៅកែបោកប្រាស់(ថៅកែចិត្តចោរមិនបានធ្វើតាមពាក្យសន្យា ដែលសន្យាថាផ្ដល់ប្រាក់១ម៉ឺនរៀលទៅហំ បើហំធ្វើការបានសម្រេច។ ថៅកែហុកមិនប្រគល់ប្រាក់១ម៉ឺនរៀលទៅសមតាមពាក្យសន្យាក្រោយពីបញ្ចប់ទំនាស់)។
    - ✓ ធ្លាប់បានប៉ូលីសចាប់ខ្លួនពីបទល្មើសច្បាប់ (ហំត្រូវនគរបាលចាប់បញ្ជូនទៅប៉ុស្តិ៍ពីបទបង្កគ្រោះថ្នាក់ក្នុងការបើកបរ។ សមត្រូវសមត្ថកិច្ចចាប់បញ្ជូនទៅពន្ធនាគារពីបទលួចចូលផ្ទះគេខុសច្បាប់ និងឆក់ទ្រព្យអ្នកដទៃ)។
    - ✓ ស្រឡាញ់ភាពយុត្តិធម៌ និងទទួលខុសត្រូវ (ហំចេញសារភាព សមប្រគល់លុយឱ្យម្ចាស់ដើមវិញ)
  - **សរុបលក្ខណៈដូច**: សរុបសេចក្ដីមក ចំណុចសំខាន់ៗខាងលើនេះ សុទ្ធសឹងជាលក្ខណៈដូចគ្នានៃខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ និងតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។

  ខ- លក្ខណៈខុសគ្នានៃខ្សែជីវិតតួអង្គហំ និងខ្សែជីវិតតួអង្គសម៖

  - **គំនិតសំខាន់ និងឧទាហរណ៍៖**
    - ✓ **ខ្សែជីវិតតួអង្គហំ៖**
      - មានតម្រូវការចាំបាច់ក្នុងគ្រួសារ(កូនចូលរៀនអនុវិទ្យាល័យ ប្រពន្ធត្រូវព្យាបាលជំងឺម្ដាយត្រូវធ្វើបុណ្យ)
      - មានជំនាញខាងបើកបររថយន្ត (មានអាជីពជាតៃកុងឡានរបស់ថៅកែចិត្តចោរ)

- មានមិត្តភក្តិរួមអាជីពជួយគាំទ្រអំពើរបស់ខ្លួនក្នុងការទាមទារយុត្តិធម៌ (គង់,សុខ, មាន,ទ្រី និងផានីត) ចេញមុខជួយតវ៉ា
- មានក្រុមគ្រួសារ(ប្រពន្ធមឹងយ៉ាន,កូនគឺមីកាទូច,ម្ដាយគឺយាយចាន់)
- ប្រព្រឹត្តបទល្មើសក្នុងគ្រោះថ្នាក់ចរាចរណ៍ (បើកល្បឿនលឿនហួសកំណត់ បុកឡានថៅកែហុងលីនាំឱ្យមានមនុស្សស្លាប់ចំនួន៣នាក់និងរបួសមួយចំនួនទៀត)
- មិនបានសម្រេចតាមបំណង (ថៅកែមិនប្រគល់ប្រាក់១ម៉ឺនរៀលតាមពាក្យសន្យា)

✓ **ខ្សែជីវិតតួអង្គសមះ**

- មិនមានតម្រូវការចាំបាច់ក្នុងគ្រួសារ (គ្មានកូន គ្មានម្ដាយ ឪពុក ប្រពន្ធសុទ្ធតែត្រូវស្លាប់ចោល)។
- មានជំនាញខាងកសិកម្ម(ជាកសិករនៅឃុំបរវិល ខេត្តបាត់ដំបង)។
- ពុំមានមិត្តភក្តិរួមអាជីពជួយគាំទ្រអំពើរបស់ខ្លួនក្នុងការទាមទារយុត្តិធម៌ទេ (ទទួលខុសត្រូវដោយខ្លួនឯង)
- ពុំមានសាច់ញាតិ ឬក្រុមគ្រួសារ (កំព្រាឪពុកម្ដាយ ប្រពន្ធស្លាប់ចោលអស់)
- ប្រព្រឹត្តបទល្មើសដោយមានបំណង (ចង់សម្លាប់ថៅកែហុកតែត្រូវជាប់គុកអស់៣ខែ ឆក់កាបូបប្រពន្ធឧកញ៉ាសំបូរសម្បត្តិត្រូវជាប់គុក៦ខែ)
- មានជីវភាពធូរធារ (សមក្លាយទៅជាកសិករគំរូ មានកិត្តិយសត្រូវជ្រើសតាំងជាប្រធានគណៈកម្មការកងឃុំ និងបានចូលរួមសមាជជាតិលើកទី៩ទៀតផង)។

▪ **សរុបលក្ខណៈខុស**: សរុបសេចក្ដីមក ចំណុចសំខាន់ៗខាងលើនេះ សុទ្ធសឹងជាលក្ខណៈខុសគ្នា នៃខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ និងតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។

**គ- សរុបរួម** :រួមសេចក្ដីមកខ្សែជីវិតរបស់តួអង្គហំក្នុងរឿងថៅកែចោរ និងខ្សែជីវិតរបស់តួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ដំណើរជីវិតមិនដូចគ្នាទេ តែមានបំណងប្រាថ្នាតែមួយដូចគ្នាគឺចង់ស្វែងរកសុភមង្គលជូនដល់ក្រុមគ្រួសារដូចគ្នា។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: ឆ្លងតាមការប្រៀបធៀបខាងលើនេះបានបង្ហាញឱ្យឃើញថា ខ្សែជីវិតតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ប្រសើរជាងខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ ព្រោះនៅទីបំផុតនៃខ្សែជីវិតរបស់តួអង្គសមទទួលបានជោគជ័យ និងមានសុភមង្គលជាងខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ។
- **មតិផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមជាអ្នកសិក្សា យើងគប្បីចេះពិចារណាឱ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តធ្វើអ្វីមួយទើបយើងទទួលបានសុភមង្គលពិតប្រាកដ។

# អត្ថបទគំរូតែងសេចក្ដីសម្រាប់ថ្នាក់វិទ្យាសាស្ត្រ

**រយៈពេល: ៩០នាទី ពិន្ទុ: ៧៥**

## ១- ប្រធានអត្ថាធិប្បាយពន្យល់

ប្រធាន: មានទស្សនៈអប់រំមួយឃ្លាបានចែងថា «ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប»។ ចូរពន្យល់ឱ្យក្បោះក្បាយ ដោយរកឧទាហរណ៍ក្នុងសង្គមនិងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់ឱ្យក្បោះក្បាយ។

### គម្រោងតែង

**ក- ផ្ដើមសេចក្ដី (១០ពិន្ទុ)**

- **លំនាំបញ្ហា**: តាមទ្រឹស្ដីកម្មផលនៃព្រះពុទ្ធសាសនាបានចែងថា អ្វីដែលយើងបានកសាងរមែងនឹងទទួលបានផលសមតាមអំពើដែលខ្លួនបានសាងនោះជាមិនខាន។ *(៥ពិន្ទុ)*
- **ចំណូលបញ្ហា (បង្ហាញប្រធាន)**: ដោយផ្អែកតាមទ្រឹស្ដីដូចខាងលើនេះហើយ ទើបមានទស្សនៈអប់រំមួយឃ្លាបានចែងថា «ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប»។ *(២ពិន្ទុ)*
- -**ចំណោទបញ្ហា**: តើទស្សនខាងលើនេះ មានអត្ថន័យដូចម្ដេចខ្លះ?*(៣ពិន្ទុ)*

**ខ- តួសេចក្ដី (៥០ពិន្ទុ)**

- **ឃ្លាភ្ជាប់សេចក្ដី**: ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះជាមុន។ *(១ពិន្ទុ)*
- **ពន្យល់ពាក្យ** : *(២ពិន្ទុ)*
  - ✓ បុណ្យ គឺសេចក្ដីល្អខាងផ្លូវកាយ និងវាចាចិត្ត។
  - ✓ បាប គឺជាសេចក្ដី អាក្រក់ដ៏លាមក ពុំគាប់ប្រសើរ។
- **ពន្យល់ន័យ**: មានន័យថា បើយើងធ្វើអំពើល្អ សុចរិតទៀងត្រង់ គេនឹងបានទទួលផលល្អ។ បើគេធ្វើអំពើអាក្រក់ គេនឹងទទួលផលអាក្រក់វិញជាមិនខាន។ *(២ពិន្ទុ)*
- **បកស្រាយ**: «ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប» ព្រោះអំពើគ្រប់យ៉ាងទាំងបុណ្យនិងទាំងបាបៈ
  - **គំនិតសំខាន់** *(២០ពិន្ទុ)*
    - ✓ បានប្រព្រឹត្តទៅហើយមិនសាបសូន្យទេ
    - ✓ បានផ្ដល់ផលគ្រប់យ៉ាងដល់អ្នកប្រព្រឹត្ត
    - ✓ ជាអ្នកកំណត់នូវផលល្អ ផលអាក្រក់
    - ✓ បានឆ្លុះបញ្ចាំងពីទង្វើបុគ្គលម្នាក់ៗ
    - ✓ ជាអំពើពីរដែលចែកដាច់ពីគ្នា មិនអាចយកមកបូកសងគ្នាបានទេ។
  - **ឧទាហរណ៍** *(២០ពិន្ទុ)*

**ក្នុងសង្គម** ការធ្វើបុណ្យ និងធ្វើបាបរបស់បុគ្គលដែលបានប្រព្រឹត្តនឹងត្រូវទទួលផលដូចតទៅៈ

ក- ធ្វើបុណ្យបានបុណ្យៈ

- ✓ អស់លោក លោកស្រី ដែលបានធ្វើទានកសាងផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ អណ្តូងទឹក...នឹងទទួលបានអានិសង្សសម្រាប់បច្ចុប្បន្នឬអនាគតជាតិក្នុងផ្លូវសុចរិតទៀងត្រង់ ធ្វើឱ្យបុគ្គលនោះមានកិត្តិយស  សេចក្តីថ្លៃថ្នូរ  ប្រសើរឧត្តុង្គឧត្តម...។
- ✓ សិស្ស និស្សិត មន្ត្រីរាជការ ...ដែលខិតខំសិក្សា បំពេញកិច្ចការជំនាញដោយយកចិត្តទុកដាក់នឹងទទួលផលល្អក្នុងពេលប្រឡង ឡើងបុណ្យសក្តិ តួនាទី កេរ្តិ៍ឈ្មោះរុងរឿង...។

**ខ- ធ្វើបាបបានបាបៈ**

- ✓ ចោរ អ្នករកស៊ីខុសច្បាប់ ឃាតករ អ្នកជួញដូរគ្រឿងញៀន... សុទ្ធតែត្រូវទទួលទោសតាមអំពើដែលខ្លួនបានប្រព្រឹត្ត...
- ✓ មន្ត្រីរាជការប្រព្រឹត្តអំពើពុករលួយតែងតែត្រូវច្បាប់ផ្តន្ទាទោសតាមទំហំនៃអំពើដែលគេបានប្រព្រឹត្ត។

**ក្នុងអក្សរសិល្ប៍** ការធ្វើបុណ្យ និងធ្វើបាប របស់បុគ្គលដែលបានប្រព្រឹត្តនឹងត្រូវទទួលផលដូចតទៅៈ

**ក- ធ្វើបុណ្យបានបុណ្យៈ**

- ✓ **រឿងកុលាបប៉ៃលិន**: ដោយសារហ្លួងរតនសម្បត្តិមានចិត្តមេត្តាសន្តោសចំពោះចៅចិត្រនិងកម្មករដទៃទៀត ទើបលោកទទួលបានផលល្អដោយចៅចិត្រនិងកម្មករទាំងអស់សុទ្ធតែបានជួយកម្ចាត់ចោរចូលប្លន់ដែលនាំដោយមេចោរផាន់និងបាឡាត់ឱ្យខ្ចាត់ខ្ចាយ។ ជាពិសេសលោកបានកូនប្រសាដ៏ល្អដែលស្មោះត្រង់ចំពោះឃុននារី និងលោក។
- ✓ **រឿងទុំទាវ**: ដោយសារតែព្រះរាជាលើកលែងទោសដល់ទុំនិងទាវ ទើបព្រះអង្គត្រូវបានប្រជារាស្ត្រចាត់ទុកទ្រង់ថា ជាព្រះរាជាមានទសពិធរាជធម៌។
- ✓ **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់**: ដោយសមបានដើរតាមការដឹកនាំរាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយមក្នុងការធ្វើនយោបាយទឹកលើវិស័យកសិកម្មទំនើប ទើបសមត្រូវបានប្រជាពលរដ្ឋក្នុងភូមិជឿទុកចិត្តបោះឆ្នោតជ្រើសតាំងជាប្រធានគណៈកម្មការកងឃុំសង្គមរាស្ត្រនិយម។

**ខ- ធ្វើបាបបានបាបៈ**

- ✓ **រឿងភូមិតិរច្ឆាន**: ដោសារតែលោករ៉េស៊ីដង់បារដេសមិនព្រមគោរពតាមពាក្យសន្យានឹងនាងប៊ីថា នឹងដោះលែងប្តីនាងបើមានលុយយកមកបង់ពន្ធ។ តែពេលនាងបង់ពន្ធហើយក៏មិនព្រមដោះលែង បែរជាថាទាល់តែអ្នកក្រាំងលាវទាំងមូលបង់ពន្ធទើបដោះលែងប្តីនាងទៅវិញ។ នេះជាអំពើបាបមួយរបស់បារដេសដែលនិយាយកុហក«មុសាវាទ» ទីបំផុតក៏ត្រូវអ្នកក្រាំងលាវបះបោរសម្លាប់គាត់និងសហការីពីរនាក់ទៀត។
- ✓ **រឿងកុលាបប៉ៃលិន:** ដោយសារតែលោកបាឡាត់ស្រុកសង្កែឃុបឃិតជាមួយមេចោរផាន់បន្លំខ្លួនជាអ្នករាប់អានគ្រួសារលោកហ្លួងរតនសម្បត្តិ ទីបំផុតក៏ត្រូវស្លាប់ក្រោមកណ្តាប់ដៃចៅចិត្រ។ នេះជាបាបកម្មដែលគាត់កសាងត្រង់ «អទិន្នាទានា» គឺចង់បានទ្រព្យអ្នកដទៃនិង «មុសាវាទ» គឺប្រើទំនាក់ទំនងក្លែងក្លាយកុហកបោកប្រាស់។

- ✓ **រឿងព្រះវេស្សន្តរ**: ដោយជូជកបានចូលមកជួបព្រះវេស្សន្តរ ដែលមានចិត្តចង់បានទ្រព្យមានជីវិតគឺ «អទិន្នាទានា» របស់ព្រះវេស្សន្តរជាពិសេសជូជកបានរំខានដល់បុត្តបរិច្ចាគព្រះវេស្សន្តរគឺវាយដំជាលីក្រស្នានៅចំពោះព្រះភក្ត្ររបស់ព្រះអង្គស្ទើរតែព្រះអង្គបាញ់នឹងធ្នូសរទ្រង់ទៅហើយ។ ដោយសារតែបាបកម្មនេះហើយទើបជូជកត្រូវស្លាប់តាយហោង ព្រោះតែស៊ីច្រើនបែកពោះស្លាប់ ព្រមទាំងត្រូវសរជាតិជាទេត្តនៅនរកវេទនាក្រៃលែងទៀតផង។

- **សរុប**: តាមហេតុផលដូចខាងលើនេះហើយដែលបញ្ជាក់ថាធ្វើបុណ្យពិតជាបានបុណ្យ ហើយធ្វើបាបពិតជាបានបាបប្រាកដមែន។ ***(៥ពិន្ទុ)***

គ- បញ្ចប់សេចក្តី (១០ពិន្ទុ)

- **វាយតម្លៃប្រធាន**: ទស្សនៈប្រធានមានអត្ថន័យសំខាន់ក្នុងការអប់រំមនុស្សគ្រប់រូប ព្រោះឱ្យចេះប្រព្រឹត្តអំពើល្អជាប្រយោជន៍ដល់សង្គម ជៀសវាងការប្រព្រឹត្តខុសឆ្គងដោយប្រការណាមួយទាំងខាងផ្លូវច្បាប់ និងទាំងខាងផ្លូវសាសនានាំឱ្យយើងទទួលផលអាក្រក់។ ***(៦ពិន្ទុ)***
- **មតិផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមជាអ្នកសិក្សា យើងគប្បីចេះប្រកាន់យកសេចក្តីល្អគឺគោរពច្បាប់របស់សង្គម មានសីលធម៌ល្អ មិនបំពារបំពានអ្នកដទៃជាហេតុនាំឱ្យខ្លួនមានកេរ្តិ៍ឈ្មោះមិនល្អ និងទទួលទោសទណ្ឌនោះឡើយ។ ***(៤ពិន្ទុ)***
- **រចនាបថ** (៥ពិន្ទុ)
  - ✓ អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ ***(២ពិន្ទុ)***
  - ✓ លំនាំសំណេរល្អ ***(៣ពិន្ទុ)***

## ២- ប្រធានអត្ថាធិប្បាយពិភាក្សា

### ប្រធានអត្ថាធិប្បាយពិភាក្សាសុទ្ធ

ប្រធាន: មានមតិខ្លះពោលថា «អក្សរសិល្ប៍ប្រជាប្រិយគ្មានតម្លៃអប់រំ»។ តើជាការត្រឹមត្រូវឬទេ? ចូរពិភាក្សាដោយរកអំណះអំណាងក្នុងរឿងខាងលើនេះមកបញ្ជាក់។

### គម្រោងតែង

ក- ផ្តើមសេចក្តី (១០ពិន្ទុ)

- **លំនាំបញ្ហា**: អក្សរសិល្ប៍មានតួនាទីសំខាន់ក្នុងការឆ្លុះបញ្ចាំងពីតថភាពសង្គមនិងអប់រំមនុស្សឱ្យចេះប្រព្រឹត្តអំពើល្អ។ ***(៥ពិន្ទុ)***
- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: តែជាមួយនឹងតួនាទីអក្សរសិល្ប៍នេះនាំឱ្យមានមតិខ្លះយល់ថា« អក្សរសិល្ប៍ប្រជាប្រិយគ្មានតម្លៃអប់រំ»។ ***(២ពិន្ទុ)***
- **ចំណោទបញ្ហា**: តើមតិខាងលើនេះ ត្រឹមត្រូវឬទេ? ***(៣ពិន្ទុ)***

ខ- តួសេចក្តី (៥០ពិន្ទុ)

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីជាជំនួយដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ ***(១ពិន្ទុ)***
- ពន្យល់ពាក្យ ***(២ពិន្ទុ)***

✓ អក្សរសិល្ប៍ប្រជាប្រិយជាអក្សរសិល្ប៍ទាំងឡាយណាដែលនិយាយតៗគ្នា គ្មានកាលបរិច្ឆេទ និងគ្មានអ្នកនិពន្ធពិតប្រាកដ

✓ តម្លៃអប់រំ ជាតម្លៃនៃការទូន្មានប្រៀនប្រដៅដោយស្ដែងចេញតាមរយៈអក្សរសិល្ប៍។

- **ពន្យល់ន័យ:** មានន័យថា អក្សរសិល្ប៍ ដែលនិយាយតៗគ្នា គ្មានកាលបរិច្ឆេទនិងគ្មានអ្នកនិពន្ធច្បាស់លាស់ពុំមានតម្លៃនៃ ការអប់រំទូន្មានឡើយ។ ***(២ពិន្ទុ)***
- **បកស្រាយ៖**

  **ក- មតិស្រប** «អក្សរសិល្ប៍ប្រជាប្រិយគ្មានតម្លៃអប់រំ» ព្រោះអក្សរសិល្ប៍ប្រជាប្រិយ៖

  - **គំនិតសំខាន់** ***(១០ពិន្ទុ)***
    - ✓ ជារឿងដំណាលតៗគ្នាពីមាត់មួយទៅមាត់មួយមិនមានមូលដ្ឋានច្បាស់លាស់
    - ✓ បានប្រឌិតឡើងដើម្បីបកស្រាយពី៖
      - ប្រវត្តិនៃការកកើតទឹកដី
      - បាតុភូតធម្មជាតិ
      - ទំនៀមទម្លាប់ប្រពៃណី
      - ចំអកកិរិះគន់។
  - **ឧទាហរណ៍** ***(៩ពិន្ទុ)***
    - ✓ **រឿងភ្នំនាងកង្រី:** បានប្រឌិតពីប្រវត្តិនៃការកកើតភ្នំនាងកង្រីគឺនាងកង្រីរត់តាមពុទ្ធិសែនរហូតដួលស្លាប់ក្លាយជាភ្នំ។ ការប្រឌិតបែបបនេះ គឺគ្រាន់តែមានបំណងបង្ហាញពីមូលហេតុដែលនាំឱ្យកើតមានភ្នំដែលមានសណ្ឋានដូចជារូបមនុស្សដួលដេកយ៉ាងនោះដែរ។
    - ✓ រឿងព្រះចន្ទ: ប្រឌិតឡើងក្នុងបំណងបកស្រាយបាតុភូតធម្មជាតិនៃព្រះចន្ទ ព្រះពាយ ពិរុណនិងព្រះអាទិត្យដែលមានបាតុភូតនិងឥទ្ធិពលមកលើមនុស្សលោកតែប៉ុណ្ណោះ។ ដូចជាព្រះចន្ទមានការនិយមចូលចិត្តពីគ្រប់មជ្ឈដ្ឋាននៃមនុស្សជាតិព្រោះបាតុភូតនេះមានពន្លឺដ៏ត្រជាក់សមស្របនឹងទឹកចិត្តមនុស្ស។
    - ✓ រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម (បកស្រាយបាតុភូតធម្មជាតិ) ។
    - ✓ រឿងដើរខ្យល់ (បកស្រាយពីការចំអកកិរិះគន់នៃសកម្មភាពបុគ្គល)។

- **សរុបមតិស្រប:** ដូច្នេះអក្សរសិល្ប៍ប្រជាប្រិយពិតជាគ្មានតម្លៃអប់រំប្រាកដមែន។ ***(១ពិន្ទុ)***

  **ខ- មតិផ្ទុយ** «អក្សរសិល្ប៍ប្រជាប្រិយ មិនមែនគ្មានតម្លៃអប់រំនោះទេ» ព្រោះអក្សរសិល្ប៍ប្រជាប្រិយបាន៖

  - **គំនិតសំខាន់** ***(១០ពិន្ទុ)***
    - ✓ ឱ្យចេះប្រកាន់ភាពកតញ្ញូចំពោះអ្នកមានគុណ
    - ✓ ស្គាល់ពីផ្នត់គំនិតខ្មែរសំខាន់ៗ (ទំនៀមទម្លាប់ប្រពៃណី ជំនឿ )
    - ✓ ឱ្យចេះរួបរួមសាមគ្គីគ្នា
    - ✓ ឯកភាពគ្នា។
  - **ឧទាហរណ៍** ***(៩ពិន្ទុ)***
    - ✓ **រឿងភ្នំនាងកង្រី:** បានអប់រំយើងឱ្យស្គាល់ពីផ្នត់គំនិតខ្មែរសំខាន់ៗដែលមានតាំងពីសម័យបុរាណមកម្ល៉េះដូចជា៖

- ការបន់ស្រន់ គឺសេដ្ឋីបានទៅបន់ស្រន់សុំកូនពីដើមជ្រៃ ក៏បានសម្រេចតាមបំណង ដែលមានកូនស្រីដល់ទៅ១២នាក់។
- កម្មពៀរវេរានាងទាំង១១ត្រូវគេឆ្កៀលភ្នែកទាំងសងខាង មកពីជាតិមុននាងឆ្កៀលភ្នែកត្រីទាំងសងខាងដែរ។ រីឯនាងទី១២ត្រូវគេឆ្កៀលភ្នែកតែម្ខាង មកពីជាតិមុននាងឆ្កៀលភ្នែកត្រីតែម្ខាងដែរ។
- ភាពកតញ្ញូ ពុទ្ធិសែនសុខចិត្តចាកចេញពីនាងកង្រីទៅសង្គ្រោះអ្នកមានគុណដោយទុកស្នេហាមួយអន្លើរហូតធ្វើឱ្យនាងបាត់បង់ជីវិត។
- ភក្តីភាព ដោយសារតែភក្តីភាពនាងកង្រីបានព្យាយាមរត់តាមពុទ្ធិសែនរហូតត្រូវបាត់បង់ជីវិត។

✓ **រឿងព្រះចន្ទ:** អប់រំកូនឱ្យស្គាល់គុណធម៌ ចេះគោរពមាតាបិតា ទើបទៅដល់ទីណាៗ មានរាប់អានពីអ្នកដទៃ

✓ **រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម:** អបរំឱ្យយើង ចេះសាមគ្គីគ្នាឯកភាពគ្នាគ្រប់សមាសភាពមិនរើសអើងដើម្បីបំណងប្រាថ្នារួមគ្នា។ ដូចជាគីង្គក់ ត្រីក្រាញ់ ផ្តៅ ឃ្មុំ ត្រសក់... ដើម្បីទាមទារទឹកភ្លៀងពីតាព្រហ្មទីបំផុតក៏បានសម្រេច

✓ **រឿងដើរខ្យល់:** អបរំឱ្យមើលឃើញពីភាពខុសគ្នានៃទស្សនៈឬគំនិតរវាងអ្នកមានអំណាចនិងអ្នកគ្មានអំណាចក្នុងសម្តែងមតិឬគំនិតយោបល់។

- **សរុបផ្តុំ:** ដូច្នេះអក្សរសិល្ប៍ប្រជាប្រិយពិតជាមានតម្លៃអប់រំប្រាកដមែន។ ***(១ពិន្ទុ)***

**គ- ពិភាក្សា:** ការយល់ថាអក្សរសិល្ប៍ប្រប្រិយ គ្មានតម្លៃអប់រំនោះមិនមែនជាការត្រឹមត្រូវឡើយ ព្រោះតួនាទីអក្សរសិល្ប៍តែងតែមានបំណងអប់រំមនុស្សគ្រប់ស្រទាប់តាមរយៈសកម្មភាពតួអង្គក្នុងរឿងដើម្បីជាប្រយោជន៍ឱ្យអ្នកសិក្សាអ្នកអានចេះពិចារណានិងអនុវត្តឱ្យបានត្រឹមត្រូវ។ ***(៥ពិន្ទុ)***

**គ- បញ្ចប់សេចក្តី (១០ពិន្ទុ)**

- **វាយតម្លៃប្រធាន:** មតិប្រធានមិនត្រឹមត្រូវទេ ព្រោះជាគំនិតដែលមិនស្គាល់ពីតួនាទីសំខាន់នៃអក្សរសិល្ប៍ពិតប្រាកដ។ ***(៦ពិន្ទុ)***
- **មតិផ្ទាល់ខ្លួន:** ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មតិខាងលើនេះបានផ្តល់ជាបទពិសោធដល់អ្នកសិក្សាគ្រប់រូបកាន់ តែមើលឃើញពីតួនាទីសំខាន់របស់អក្សរសិល្ប៍ក្នុងការឆ្លុះបញ្ចាំពីតថភាពសង្គម ព្រមទាំងអប់រំថែមទៀតដល់អ្នកអានអ្នកសិក្សាឱ្យទទួលបានគ្រប់ៗគ្នា។ ***(៤ពិន្ទុ)***
- **រចនាបថ (៥ពិន្ទុ)**

✓ អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ ***(២ពិន្ទុ)***

✓ លំនាំសំណេរល្អ ***(៣ពិន្ទុ)***

## ប្រធានអត្ថាធិប្បាយពិភាក្សាប្រៀបធៀប

ប្រធាន: ក្នុងរឿងគូលីកំណែនមានមតិខ្លះយល់ថា «បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាស្វាមី នាងពិតជាមានសុភមង្គល»។ តែមតិខ្លះទៀតយល់ថា «បើនាងហេងរួមរស់នៅជាមួយលឹមពិតជាមានសុភមង្គល»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងសង្គមនិងរឿងខាងលើនេះមកបញ្ជាក់។

### គម្រោងតែង

**ក- ផ្តើមសេចក្តី (១០ពិន្ទុ)**

- **លំនាំបញ្ហា:** សុភមង្គលគឺជាការចាំបាច់ចំពោះនារីម្នាក់ៗក្នុងជីវិតអាពាហ៍ពិពាហ៍ ដើម្បីជ្រើសរើសគូស្រករបានរស់នៅរហូតចាស់ព្រឹទ្ធចាស់ព្រេង។ ***(៥ពិន្ទុ)***
- **ចំណូលបញ្ហា(បង្ហាញប្រធាន):** ដោយក្តីបារម្ភចំពោះការជ្រើសរើសគូអនាគតរបស់ខ្លួនដូចខាងលើនេះហើយ ទើបក្នុងរឿងគូលីកំណែនមានមតិខ្លះយល់ថា« បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាស្វាមីនាងពិតជាមានសុភមង្គល»។ តែមតិខ្លះទៀតយល់ថា « បើនាងហេងរួមរស់នៅជាមួយលឹមពិតជាមានសុភមង្គល»។ ***(២ពិន្ទុ)***
- **ចំណោទបញ្ហា:** តើមតិទាំងពីរខាងលើនេះមួយណាត្រឹមត្រូវជាង? ***(៣ពិន្ទុ)***

**ខ- តួសេចក្តី (៥០ពិន្ទុ)**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីរួមចំណែកដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ ***(១ពិន្ទុ)***
- ពន្យល់ពាក្យ ***(២ពិន្ទុ)***
  - ✓ ស្វាមី ជាប្តីដែលបានរៀបការទៅតាមប្រពៃណីនិងស្របតាមផ្លូវច្បាប់។
  - ✓ សុភមង្គល សេចក្តីសុខគ្រប់យ៉ាងរបស់មនុស្សទាំងខាងផ្លូវកាយនិងផ្លូវចិត្ត។
  - ✓ រួមរស់ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធអស់មួយជីវិត។
- **ពន្យល់ន័យ:** តាមមតិទីមួយមានន័យថា បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាប្តីនាងពិតជាមានសេចក្តីសុខ។ រីឯមតិទីពីរមានន័យថា បើនាងហេងរស់នៅជាមួយលឹមអស់មួយជីវិតជាប្តីប្រពន្ធនាងពិតជាមានសេចក្តីសុខ។ ***(២ពិន្ទុ)***
- បកស្រាយ៖

  ក- **មតិទី១** «បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយជាស្វាមី នាងពិតជាមានសុភមង្គល» ព្រោះលោកចៅហ្វាយមាន៖

  - គំនិតសំខាន់ ***(១០ពិន្ទុ)***
    - ✓ អំណាចបុណ្យសក្តិ ទ្រព្យសម្បត្តិ
    - ✓ ចំណេះវិជ្ជា សមត្ថភាពគ្រប់គ្រងក្នុងស្រុកកណ្តាលស្ទឹង
    - ✓ ចំណេះវិជ្ជា
    - ✓ ការគោរពពីសំណាក់អ្នកក្រោមបង្គាប់។
  - ឧទាហរណ៍ ***(៩ពិន្ទុ)***

- ✓ **រឿងគូលីកំណែន**: លោកចៅហ្វាយជាមនុស្សពោរពេញទៅដោយអំណាចបុណ្យសក្តិ និងមានកិត្តិយសដែលអ្នកផងទាំងពួងជាពិសេសមេឃុំផាន់ ព្រមទាំងប្រជារាស្ត្រដែលរស់នៅឃុំគោកចំបក់ទាំងអស់តែងគោរពកោតខ្លាច។លោកមានទាំងអំណាច មានទាំងកម្លាំងប្រដាប់អាវុធដែលនៅចាំការពារលោកឬរង់ចាំទទួលភារកិច្ចនៅពេលណាដែលលោកបញ្ជា។ ហេតុដូច្នេះ បើសិនជានាងហេងយល់ព្រមទទួលលោកនិងរស់នៅជាមួយលោក នាងនឹងបានអ្វីៗគ្រប់យ៉ាងដែលស្ត្រីទាំងអស់ក្នុងលោកតែងប្រាថ្នាចង់បាន។ មិនតែប៉ុណ្ណោះនាហេងក្តី គ្រួសារនាងក្តីសុទ្ធតែមានអំណាច ហើយសត្រូវរបស់នាងមិនហ៊ានមករំខានឬធ្វើបាបដល់ក្រុមគ្រួសារនាងឡើយ ព្រោះនាងមានលោកចៅហ្វាយជាខ្នងបង្អែករួចទៅហើយ។

- **សរុបមតិទី១**: សរុបសេចក្តីមក បើនាងហេងយល់ព្រមទទួលលោកចៅហ្វាយធ្វើជាស្វាមី នាងពិតជាមានសុភមង្គលប្រាកដមែន។ *(១ពិន្ទុ)*
- **សំណួរភ្ជាប់សេចក្តី**: ក្រៅពីលោកចៅហ្វាយ តើអ្នកណាទៀត ដែលនាំមកនូវសុភមង្គលជូនដល់នាងហេង?

**ខ- មតិទី២** «បើនាងហេងរួមរស់នៅជាមួយលឹមពិតជាមានសុភមង្គល» ព្រោះលឹមៈ

- **គំនិតសំខាន់** *(១០ពិន្ទុ)*
  - ✓ មានចិត្តស្មោះត្រង់
  - ✓ មានសីលធម៌ល្អ
  - ✓ មានចំណេះដឹងទាំងខាងផ្លូវលោក និងទាំងខាងផ្លូវធម៌
  - ✓ ចេះគោរពតាមប្រពៃណីក្នុងការផ្តាប់ចិត្តអនាគតឪពុកក្មេកម្តាយក្មេក
  - ✓ បានបំពេញតាមកិច្ចដែលជាប្រពៃណីខ្មែរ
  - ✓ អ្នកទាំងពីរធ្លាប់បានស្គាល់ចិត្តថ្លើមគ្នាហើយ
  - ✓ ស្នេហាអ្នកទាំងពីរជាស្នេហាវ័យកំលោះក្រមុំតាមបែបបធម្មជាតិ។
- **ឧទាហរណ៍** *(៩ពិន្ទុ)*

  រឿងគូលីកំណែន លឹមធ្លាប់បានទៅនៅផ្ទះនាងហេងតាមរយៈការផ្តាប់ចិត្តពូស្វាយមឹងពត ហើយពូស្វាយក៏មានចិត្តស្រឡាញ់លឹមដែរ។មិនតែប៉ុណ្ណោះ អ្នកទាំងពីរធ្លាប់បានជាន់អង្ករជាមួយគ្នា រែកអាចម៍ គោចាក់ ស្រែថ្ងាន់ ហើយអ្នកទាំងពីរក៏មានចិត្តស្រលាញ់គ្នាទៅវិញទៅមក។ នាងហេងបានសន្យាជាមួយលឹមថា «ប្តូរផ្តាច់ដូចទាវនឹងឯក ប្រកែកមិនព្រមធ្វើស្នំមហេសីព្រះរាមាឡើយ»។ ក្រៅពីនេះទៀតលឹមជាអ្នកចេះវិភាគបញ្ហាសង្គមចេះពិចារណាបានត្រឹមត្រូវរាល់ហេតុការណ៍ទាំងឡាយដែលបានកើតឡើង។
- **សរុបមតិទី២**: សរុបសេចក្តីមក បើនាងហេងរួមរស់នៅជាមួយលឹម នាងពិតជាមានសុភមង្គលប្រាកដមែន។*(១ពិន្ទុ)*

**គ- ពិភាក្សា**: ជារួមបើនាងហេងទទួលយកលោកចៅហ្វាយធ្វើជាស្វាមី នាងពិតជាគ្មានសុភមង្គលឡើយ ព្រោះលោកចៅហ្វាយមិនមានមែនជាកំលោះដែលមានចិត្តស្មោះនោះទេទោះបីជាគាត់មានទ្រព្យ អំណាច បុណ្យសក្តិយ៉ាងណាក៏ដោយ គឺគាត់មានចរិតពាលាអាវាសែ មានស្នេហ៍មិនស្មោះ។ តែបើសិនជានាងរួមរស់នៅជាមួយលឹម នាងពិតជាមាន

សុភមង្គល ព្រោះអ្នកទាំងពីរមានចាស់ទុំដឹងឮ ហើយបានបំពេញទៅតាមប្រពៃណីជាតិ គឺបានភ្ជាប់ពាក្យរួចហើយ នៅសល់តែមួយខែទៀតនឹងរៀបការ។ *(៥ពិន្ទុ)*

គ- បញ្ចប់សេចក្តី (១៥ពិន្ទុ)

- **វាយតម្លៃប្រធាន**: មតិទីមួយរបស់ប្រធានមិនត្រឹមត្រូវទេ ព្រោះជាគំនិតដែលគាំទ្រចរិតពាលាអាវាសែរបស់លោកចៅហ្វាយដែលគ្មានសីលធម៌ស្អាតស្អំក្នុងការដឹកនាំប្រជារាស្ត្រ។ ចំណែកមតិទីពីរ មានភាពស្រមស្របជាង ព្រោះទទួលស្គាល់ការពិតនៃតម្លៃជីវិតដែលពោរពេញទៅដោយសុភមង្គល។ *(៦ពិន្ទុ)*
- **មតិផ្ទាល់ខ្លួន**: ដូច្នេះនាមជាអ្នកសិក្សាយើងគប្បី ចេះជ្រើសរើសសុភមង្គលណាមួយ ដែលជាសុភមង្គលយូរអង្វែងពុំមានការបង្ខិតបង្ខំនោះ ទើបជំរុញឱ្យជីវិតរបស់យើងមានតម្លៃនិងប្រកបទៅដោយសេចក្តីសុខ។ *(៤ពិន្ទុ)*
- **រចនាបថ** (៥ពិន្ទុ)
  - ✓ អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ *(២ពិន្ទុ)*
  - ✓ លំនាំសំណេរល្អ *(៣ពិន្ទុ)*

## ៣- ប្រធានអត្ថាធិប្បាយប្រៀបធៀប

ប្រធាន: ចូរអ្នកធ្វើការប្រៀបធៀបលក្ខណសម្បត្តិនាងសីតាក្នុងរឿងរាមកេរ្តិ៍ និងលក្ខណសម្បត្តិនាងមទ្រីក្នុងរឿងព្រះវេស្សន្តរ។ តើនារីទាំងពីរនេះមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ ?

### គម្រោងតែង

ក- ផ្តើមសេចក្តី (១០ពិន្ទុ)

- **លំនាំបញ្ហា**: រូបសម្បត្តិរបស់នារីពិតជាកត្តាសំខាន់ក្នុងការទាក់ទាញ ឬឱ្យចាប់អារម្មណ៍ពីបុរសទាំងឡាយជាមួយនោះលក្ខណសម្បត្តិខាងក្នុងក៏ជាការចាំបាច់ដែរក្នុងការឱ្យតម្លៃទៅនារី ឬស្ត្រីទាំងឡាយដែលមាននៅក្នុងសង្គមនោះដែរ។ *(៥ពិន្ទុ)*
- **ចំណូលបញ្ហា(បង្ហាញប្រធាន)**: ចំពោះភាពចាំចាច់នៃលក្ខណសម្បត្តិរបស់នារីនេះក៏ត្រូវបានកវីនិពន្ធយើងលើកយកមកបង្ហាញនៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរតាមរយៈរឿងរាមកេរ្តិ៍ គឺនាងសីតានិងរឿងព្រះវេស្សន្តគឺនាងមទ្រីដែរ។ *(២ពិន្ទុ)*
- **ចំណោទបញ្ហា**: តើនារីទាំងពីររូបខាងលើនេះមានលក្ខណៈសម្បត្តិដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ? *(៣ពិន្ទុ)*

ខ- តួសេចក្តី (៥០ពិន្ទុ)

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីធ្វើជំរុញឱ្យការប្រៀបធៀបនៃលក្ខណសម្បត្តិរបស់តួអង្គទាំងពីរខាងលើនេះ យើងគប្បីស្វែងយល់ន័យរបស់ពាក្យលក្ខណសម្បត្តិជាមុនសិន។ *(១ពិន្ទុ)*
- **ពន្យល់ពាក្យ**: លក្ខណសម្បត្តិ គឺសំដៅទៅលើចរិតលក្ខណៈគ្រប់យ៉ាងរបស់តួអង្គ ឬរបស់មនុស្សដែលស្តែងចេញតាមរយៈសកម្មភាព។ *(២ពិន្ទុ)*

- **ពន្យល់ន័យ:** តាមគំនិតប្រធានខាងលើបានតម្រូវឱ្យយើងធ្វើការប្រៀបធៀបរវាងចំណុចដូចគ្នា និងចំណុចខុសគ្នានៃចរិតលក្ខណៈរបស់នាងសីតាជាមហេសីព្រះរាមនិងនាងមទ្រីជាមហេសីរបស់ព្រះវេស្សន្តរ។ ***(០២ពិន្ទុ)***
- **បកស្រាយ៖**

**ក- លក្ខណៈដូចគ្នានៃលក្ខណសម្បត្តិនាងសីតា និងនាងមទ្រី៖**

- **គំនិតសំខាន់ និងឧទាហរណ៍ *(១៩ពិន្ទុ)***
  - ✓ ស្រស់ស្អាតពេញលក្ខណៈជានារី (នាសីតាជាកំពូលនារីល្អឯកជាដៃគូនៃអវតារព្រះវិស្ណុ តាមបព្រាហ្មណ៍និយម។ នាងមទ្រីជាកន្សែស្រារពេជ្ជ ជាដៃគូនៃព្រះពោធិសត្វ តាមបែបពុទ្ធនិយម)
  - ✓ នារីទាំងពីរពោរពេញទៅដោយភក្តីភាពចំពោះស្វាមីរបស់នាង៖
    - ពេលក្រុងរាពណ៍ចាប់នាងសីតាយកទៅលង្កាតែនាងនៅតែរក្សាភាពបរិសុទ្ធ និងពេលដែលព្រះរាមចេញទៅសាងផ្នួសក្នុងព្រៃដប់ឆ្នាំនាងក៏ស្ម័គ្រចិត្តយាងទៅតាមព្រះអង្គដែរ
    - នាងមទ្រីពេលព្រះវេស្សន្តរត្រូវគេបំបរបង់ឱ្យព្រះអង្គចូលព្រៃគិរីវង្កតនាងក៏ចាកចេញតាមព្រះវេស្សន្តរដែរ
    - នារីទាំងសុទ្ធតែយាងចេញតាមព្រះស្វាមីទៅរស់នៅក្នុងព្រៃ (សីតាយាងចេញតាមព្រះរាមទៅសាងផ្នួសក្នុងព្រៃ នាងមទ្រី យាងចេញតាមព្រះវេស្សន្តរស្វែងរកធម៌ក្នុងព្រៃ)។

- **សរុបលក្ខណៈដូច:** សរុបសេចក្តីមក ចំណុចសំខាន់ៗខាងលើនេះសុទ្ធសឹងជាលក្ខណៈដូចគ្នានៃលក្ខណសម្បត្តិរបស់នាងសីតានិងនាងមទ្រី។ ***(១ពិន្ទុ)***

**ខ- លក្ខណៈខុសគ្នានៃលក្ខណសម្បត្តិនាងសីតា និងនាងមទ្រី**

- **គំនិតសំខាន់ និងឧទាហរណ៍ *(១៩ពិន្ទុ)***
  - ✓ **ចំពោះនាងសីតា៖**
    - នាងជានារីល្អឯកតាមលទ្ធិព្រាហ្មណ៍និយម គឺត្រូវជួយបំពេញកាតព្វកិច្ចចំពោះអវតាររបស់ព្រះវិស្ណុ
    - នាងត្រូវព្រះរាមសព្វព្រះទ័យយកនាងធ្វើជាមហេសីដោយសមត្ថភាពក្នុងការប្រឡងលើកធ្នូឈ្នះអស់ទេវៈក្នុងឋានទាំងបី
    - ព្រះនាងមានរាជបុត្រតែមួយអង្គគឺរាមលក្សណ៍
    - នាងពោរពេញទៅដោយឆន្ទៈស្មោះត្រង់ គឺម៉ឺងម៉ាត់
    - នាងប្រកាន់យកពាក្យសត្យ
    - នាងក្លាហាន និងទទួលខុសត្រូវ ទោះបីនាងស្រឡាញ់ព្រះរាមក៏ដោយក៏នាងមិនខ្លាចចាកចេញពីព្រះរាមទេ។
  - ✓ **ចំពោះនាងមទ្រី**
    - នាងជានារីស្រស់ស្អាតតាមបែបពុទ្ធនិយម គឺជាកន្សែស្រារពេជ្ជជាអ្នកជួយបំពេញបារមីដល់ព្រះពោធិសត្វ
    - នាងស្លូតបូត និងទន់ភ្លន់ ចេះជួយដោះស្រាយបញ្ហាចំពោះមុខ

- នាងមានព្រះទ័យមេត្តា គោរពតាមព្រះរាជបំណងព្រះស្វាមីជានិច្ច ទោះជាធ្វើបុត្តបរិច្ចាគ ឬភរិយាបច្ចាគក្តី
- នាងពេញព្រះទ័យក្នុងការគាំទ្រឧត្តមគតិសាសនានៃទានបរិច្ចាគរបស់ព្រះវេស្សន្តរជានិច្ច
- នាងមានការតស៊ូរស់នៅក្នុងព្រៃតាំងពីដើមដល់ចប់គឺនៅបម្រើព្រះវេស្សន្តរហូតមកនិងចិញ្ចឹមជាលីក្រស្នា។

- **សរុបលក្ខណៈខុស:** សរុបសេចក្តីមកចំណុចដែលបង្ហាញខាងលើនេះសុទ្ធសឹងជាលក្ខណៈខុសគ្នានៃលក្ខណសម្បត្តិរបស់នាងសីតានិងនាងមទ្រី។ ***(១ពិន្ទុ)***

**គ- សរុបរួម :** ភស្តុតាងខាងលើនេះ ជាចំណុចដូចគ្នានិងចំណុចខុសគ្នារវាងលក្ខណសម្បត្តិនាងសីតានិងនាងមទ្រី។ ថ្វីបើតួអង្គទាំងពីរស្ថិតក្នុងចលនាអក្សរសិល្ប៍ដទៃពីគ្នាក៏ពិតមែន តែនារីទាំងពីរនេះ នេះមានលក្ខណៈរួមមួយ គឺសុទ្ធសឹងជាតួអង្គតំណាងឱ្យស្ត្រីខ្មែរគ្រប់រូបដែលពោរពេញទៅដោយភក្តីភាព និងបានបំពេញកាតព្វកិច្ចល្អចំពោះស្វាមីក្នុងគ្រួសារជានិច្ច។ ***(៥ពិន្ទុ)***

គ- បញ្ចប់សេចក្តី (១០ពិន្ទុ)

- **វាយតម្លៃប្រធាន**: ឆ្លងតាមការប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញថា ទាំងនាងមទ្រីនិងទាំងនាងសីតាសុទ្ធតែមានលក្ខណសម្បត្តិល្អប្រសើរដូចគ្នា ព្រោះអ្នកទាំងពីរគឺជាតួអង្គពោរពេញទៅដោយឧត្តមគតិក្នុងការលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីសម្រេចឬគាំទ្របំណងស្វាមីដូចៗគ្នា។ ***(៦ពិន្ទុ)***
- **មតិផ្ទាល់ខ្លួន**: ជាមួយគ្នានេះដែរលក្ខណសម្បត្តិនៃនារីទាំងពីរនេះ គឺជាការឆ្លុះបញ្ចាំងអំពីតម្លៃនារីខ្មែរក្នុងការគ្រប់គ្រងគ្រួសារឬលើកតម្លៃគ្រួសារគ្រប់កាលៈទេសៈឱ្យឆ្ពោះទៅរកឧត្តមភាពនិងសុភមង្គលពិតប្រាកដ។ ***(៤ពិន្ទុ)***
- **រចនាបថ** (៥ពិន្ទុ)
  - ✓ អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ ***(២ពិន្ទុ)***
  - ✓ លំនាំសំណេរល្អ ***(៣ពិន្ទុ)***

# អត្រាកំណែតែងសេចក្តីសម្រាប់ថ្នាក់វិទ្យាសាស្ត្រសង្គម

**រយៈពេល: ១៥០នាទី ពិន្ទុ: ១២៥**

## ១- ប្រធានអត្ថាធិប្បាយពន្យល់

ប្រធាន: មានទស្សនៈមួយថែងថា «សុខដុមរមនា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ ខេមរនិយម ពុទ្ធនិយម និងព្រាហ្មណ៍និយម»។ ចូរពន្យល់ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍ ខាងលើមកបញ្ជាក់។

### គម្រោងតែង

**ក- ផ្តើមសេចក្តី (១៥ពិន្ទុ)**

- **លំនាំបញ្ហា:** ភាពសុខសាន្តនិងសេចក្តីរីករាយ គឺជាបំណងប្រាថ្នារបស់បុគ្គលនីមួយៗដែលនាំមកនូវបរិយាកាសស្ងប់ស្ងាត់គ្មានទំនាស់ ឬសង្គ្រាមក្នុងគ្រួសារ និងសង្គមជាតិ។ (***៨ពិន្ទុ***)
- **ចំណូលបញ្ហា(បង្ហាញប្រធាន):** ដោយមើលឃើញនិងបានយល់ពីគុណសម្បត្តិនៃភាពសុខសាន្ត និងរីករាយដូចខាងលើនេះហើយទើបមានទស្សនៈមួយថែងថា« សុខដុមរមនាត្រូវបានឆ្លុះ បញ្ចាំងតាមរយៈអក្សរសិល្ប៍ខេមរនិយម ពុទ្ធនិយម និងព្រាហ្មណ៍និយម»។ (***៣ពិន្ទុ***)
- **ចំណោទបញ្ហា:** តើអក្សរសិល្ប៍ខាងលើនេះ បានបង្ហាញពីសុខដុមរមនាយ៉ាងណាខ្លះ? (***៤ពិន្ទុ***)

**ខ- តួសេចក្តី (៧៥ពិន្ទុ)**

ឃ្លាភ្ជាប់ ពន្យល់ពាក្យ ពន្យល់ន័យ (***១៥ពិន្ទុ***)

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។ (***៣ពិន្ទុ***)
- ពន្យល់ពាក្យ (***៦ពិន្ទុ***)
  - ✓ **សុខដុមរមនា** ការរស់នៅផ្តុំគ្នា ឬនៅមូលគ្នាសុខសប្បាយ ឬរីករាយសុខស្រួលជាមួយគ្នា។
  - ✓ **អក្សរសិល្ប៍ខេមរនិយម** ជាអក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងពីសង្គមខ្មែរ វប្បធម៌ខ្មែរ ឬពីជីវភាពរាស្ត្រខ្មែរ។
  - ✓ **អក្សរសិល្ប៍ពុទ្ធនិយម** ជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។
  - ✓ **អក្សរសិល្ប៍ព្រាហ្មណ៍និយម** ជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា។
- **ពន្យល់ន័យ:** មានន័យថាសេចក្តីសុខសប្បាយឬភាពសុខសាន្ត ត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខ្មែរ ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនានិងព្រាហ្មណ៍សាសនា។ (***៦ពិន្ទុ***)
- **បកស្រាយ:** «សុខដុមរមនា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខេមរនិយម ពុទ្ធនិយម និងព្រាហ្មណ៍និយម»ព្រោះអក្សរសិល្ប៍៖
  - **គំនិតសំខាន់** (***៣០ពិន្ទុ***)
    - ✓ តែងតែបង្កប់គំនិតអប់រំតាមរយៈតួអង្គក្នុងរឿង
    - ✓ គោលបំណងអ្នកនិពន្ធគឺចង់បណ្តុះស្មារតីអ្នកអានឱ្យចេះរស់នៅក្នុងភាពសុខសាន្ត
    - ✓ បានបង្ហាញផលអាក្រក់នៃអំពើរបស់តួអង្គដែលបានប្រព្រឹត្ត
    - ✓ ឱ្យចេះយោគយល់ សន្តោសប្រណី អធ្យាស្រ័យ គោរពសិទ្ធិ
    - ✓ មិនឱ្យប្រមាថជីវិតសត្វ មនុស្ស ឬប្រើអំពើហិង្សា

- ✓ ឱ្យចេះចែករំលែកទ្រព្យធន ដល់ជនទុរគត
- ✓ ឱ្យមានសុទិដ្ឋិនិយមក្នុងជីវិត តស៊ូ ជឿជាក់លើសមត្ថភាពខ្លួន។

- **ឧទាហរណ៍** *(៣០ពិន្ទុ)*

**ក- អក្សរសិល្ប៍ខេមរនិយម:** បានបង្ហាញឱ្យឃើញពីភាពសុខដុមរមនាតាមរយៈរឿងទុំទាវ។ តួយ៉ាងក្រោយពីព្រះរាជាទ្រង់ជ្រាបថា ទុំនិងទាវជាសង្សារនិងគ្នា ព្រះអង្គក៏រំងាប់ព្រះទ័យលើកលែងទោសឱ្យទុំនិងទាវ ជាពិសេសបានរៀបចំមង្គលការឱ្យអ្នកទាំងពីររួមរស់ជាប្តីប្រពន្ធប្រកបដោយភាពសុខសាន្តទៀតផង។ ចំណុចនេះបញ្ជាក់ថាព្រះអង្គជាក្សត្រ ដែលមានទសពិធរាជធម៌ អាណិតអាសូររាស្ត្រដែលធ្វើឱ្យរាស្ត្រកំពុងមានវិបត្តិមានសេចក្តីរីករាយក្រោមព្រះទ័យដ៏ល្អបែបនេះគឺ«ទឹកត្រជាក់ ត្រីកុំ»។

**ខ- អក្សរសិល្ប៍ពុទ្ធនិយមៈ**

- ✓ **រឿងព្រះវេស្សន្តរ** ទោះបីព្រះអង្គត្រូវពួកអ្នកស្រុកស្រីពិរាស្ត្របំបរបង់ចេញពីនគរ ដោយសារតែទ្រង់ដាក់ទានដំរីបច្ច័យនាគេន្ទ្រឱ្យទៅពួកព្រាហ្មណ៍នៅកលិង្គរាស្ត្រ ក៏ព្រះវេស្សន្តរមិនទោមនស្សចំពោះពួកគេដែរ។ ព្រះអង្គចាកចេញដោយព្រះទ័យស្ងប់ឆ្ពោះទៅរកគិរីវង្កតដើម្បីសាងផ្នួសស្វែងរកធម៌។ ឥរិយាបថរបស់ទ្រង់បែបនេះបាននាំមកនូវបរិយាកាសក្នុងភាពសុខសាន្តទាំងអ្នកស្រុកស្រីពិរាស្ត្រ ទាំងព្រះបាទស្រីសញ្ជ័យ នាងសុបារសុប្បតីជាបិតាមាតាគឺនគរមានសន្តិភាព។ ដោយសារតែស្ថិតក្នុងបរិយាកាសនេះដែរ ក៏បានជំរុញឱ្យពួកអ្នកស្រុកស្រីពិរាស្ត្រ ចេះពិចារណាយល់ពីបំណងព្រះវេស្សន្តរ ដែលបានធ្វើកន្លងមកទាំងធនបរិច្ចាគ អង្គបរិច្ចាគ ជីវិតបរិច្ចាគ បុត្តបរិច្ចាគ និងភរិយាបរិច្ចាគ ដើម្បីត្រាស់ដឹងនាពេលអនាគតជួយស្រោចស្រង់សត្វលោកឱ្យរួចផុតពីអវិជ្ជាឬសេចក្តីល្ងង់ខ្លៅ។ យ៉ាងនេះហើយបានចរន្តពិភពលោកតែងតែអនុវត្តតាមគោលការណ៍ពុទ្ធនិយមនេះក្នុងបំណងស្វែងរកមិត្ត កាត់បន្ថយសត្រូវ ឬជៀសវាងសង្គ្រាម ដើម្បីភាពសុខសាន្តនៃមនុស្សទូទៅ។
- ✓ **រឿងសុវណ្ណសាម** ព្រះអង្គមិនត្រឹមតែមិនយកទោសកំហុសចំពោះបិលយក្ខ ដែលបានលបបាញ់ប្រហារមកលើព្រះអង្គនោះទេ ថែមទាំងនិយាយអង្វរករផ្អែមល្ហែមធ្វើឱ្យបិលយក្ខមានក្តីរំភើបចេញសារភាពទទួលខុសត្រូវនូវអំពើដែលខ្លួនបានធ្វើមកលើសុវណ្ណសាមនោះទៀតផង។ មានន័យថារឿងនេះបានអប់រំដល់មនុស្សគ្រប់រូប មិនឱ្យយកកំហឹង ឬប្រើអំពើហិង្សាជាជាងប្រើសន្តិវិធី ដើម្បីភាពសុខសាន្ត ឬធ្វើឱ្យអ្នកប្រព្រឹត្តខុសចេះស្គាល់កំហុសឈប់ប្រព្រឹត្តតទៅទៀត។

**គ- អក្សរសិល្ប៍ព្រាហ្មណ៍និយមៈ** រឿងរាមកេរ្តិ៍ បានបង្ហាញពីភាពសុដុមរមនានៃតួអង្គព្រះរាមដែលបានធ្វើសម្បទានឬលះបង់រាជ្យបល័ង្ក ទោះបីព្រះអង្គមានសិទ្ធិស្របច្បាប់ទៅតាមប្រពៃណីក្សត្រយ៉ាងណាក៏ដោយ ក៏ព្រះអង្គសុខចិត្តធ្វើតាមសំណូមពរនាងកៃកេសីដែរ។ មានន័យថា ទ្រង់បានចេញសាងផ្នួស១៤ឆ្នាំដើម្បីទុករាជ្យសម្បត្តិឱ្យព្រះភិរុតឡើងគ្រងរាជ្យ។ ប្រការនេះគឺជាការបញ្ជាក់ពីគោលជំហរដែលព្រះអង្គចង់បានសន្តិភាព ឬសុភមង្គលជូនរាជវង្សនិងប្រជារាស្ត្រ។ ចំណុចនេះ គឺជាបំណងប្រាថ្នារបស់បិតាទ្រង់ដែលចង់ឃើញបុត្រដ៏ល្អពោរពេញទៅដោយកតញ្ញូចំពោះអ្នកមានគុណជាម្ចាស់បងដ៏ល្អដែលហ៊ានលះបង់

អ្វីៗគ្រប់យ៉ាងដើម្បីប្អូនឬជាអ្នកដឹកនាំដ៏ល្អពោរពេញទៅដោយទសពិធរាជធម៌ចំពោះប្រជារាស្ត្រ។

- **សរុប:** ដូច្នេះ ភាពសុខដុមរមនាពិតជាត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍ខេមរនិយម ពុទ្ធនិយមនិងព្រាហ្មណ៍និយមប្រាកដមែន។ ***(១០ពិន្ទុ)***

**គ- បញ្ចប់សេចក្តី (១៥ពិន្ទុ)**

- **វាយតម្លៃប្រធាន:** គំនិតប្រធានមានអត្ថន័យសំខាន់ក្នុងការបណ្តុះស្មារតីអ្នកសិក្សាអ្នកអានឱ្យស្គាល់តម្លៃនៃសេចក្តីសុខក្សេមក្សាន្តដែលចាំបាច់ត្រូវតែមានក្នុងគ្រួសារក្តីនិងសង្គមជាតិក្តី។ ***(១០ពិន្ទុ)***
- **មតិផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមជាយុវជនខ្មែរ យើងគប្បីចេះរួបរួមសាមគ្គីគ្នាដោយភាពស្មោះត្រង់ ជាពិសេសត្រូវចេះរស់នៅប្រកបដោយភាពសុខសាន្ត យោគយល់អធ្យាស្រ័យគ្នា មិនបំពារបំពាន ឬប្រមាថមើលងាយគ្នាទៅវិញទៅមកនោះឡើយ។ ***(៥ពិន្ទុ)***
- **រចនាបថ** (១០ពិន្ទុ)
  - ✓ អក្សរអក្ខរាវិរុទ្ធ ឃ្លាល្បះ ***(៤ពិន្ទុ)***
  - ✓ លំនាំសំណេរល្អ ***(៦ពិន្ទុ)***

## ២- ប្រធានអត្ថាធិប្បាយពិភាក្សា

### ប្រធានអត្ថាធិប្បាយពិភាក្សាសុទ្ធ

---

ប្រធាន: មានមតិខ្លះយល់ថា «មហន្តរាយនៃនគរលង្កា បណ្តាលមកពីនាងសូរបនខា»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងរឿងរាមកេរ្តិ៍ខ្មែរមកបញ្ជាក់។

---

### គម្រោងតែង

**ក- ផ្តើមសេចក្តី (១៥ពិន្ទុ)**

- **លំនាំបញ្ហា:** ក្រោយពីក្រុងខរជាបងត្រូវបរាជ័យក្នុងសង្គ្រាមទាមទារកិត្តិយសពីព្រះរាមមកវិញ នាងសូរបនខាមានការឈឺចាប់យ៉ាងខ្លាំង រួចក៏ទៅញុះញង់ក្រុងរាពណ៍ជាបងឱ្យមានចិត្តស្រឡាញ់នាងសីតា ដើម្បីលួចឆក់នាងយកមកទុកនៅក្រុងលង្កា។ ***(៨ពិន្ទុ)***
- **ចំណូលបញ្ហា(បង្ហាញប្រធាន):** ដោយមើលឃើញពីឥរិយាបថនៃគំនុំសងសឹក ដូចខាងលើនេះ ហើយទើបមានមតិខ្លះយល់ថា «មហន្តរាយនៃនគរលង្កាបណ្តាលមកពីនាងសូរបនខា»។ ***(៣ពិន្ទុ)***
- **ចំណោទបញ្ហា:** តើមតិខាងលើនេះត្រឹមត្រូវឬទេ? ***(៤ពិន្ទុ)***

**ខ- តួសេចក្តី (៧៥ពិន្ទុ)**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីរួមចំណែកដល់ការបកស្រាយមតិប្រធានខាងលើនេះឱ្យកាន់តែស៊ីជម្រៅថែមទៀតនោះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។ ***(៣ពិន្ទុ)***
- **ពន្យល់ពាក្យ៖**
  - ✓ **មហន្តរាយ** វិនាស ហិនហោច ខ្ទេចខ្ទី សាបសូន្យ គ្មានសេសសល់អ្វីឡើយ
  - ✓ **បណ្តាល** ដើមហេតុ បង្កហេតុ មូលហេតុដែលនាំឱ្យកើតមានផលណាមួយ

- ✓ **សូរបនខា** ជាឈ្មោះស្រីយក្ស ជាប្អូនរបស់ក្រុងរាពណ៍ ដែលសោយរាជ្យនៅក្រុងលង្កា ក្នុងរឿងរាមកេរ្តិ៍ខ្មែរ។ (***៦ពិន្ទុ)***

- **ពន្យល់ន័យ**: មានន័យថាសេចក្តីវិនាសហិនហោចនៃនគរលង្កា គឺមកពីនាងសូរបនខា ដែលជាប្អូនក្រុងរាពណ៍មកញុះញង់បង្កឱ្យមានសង្គ្រាមនេះកើតឡើង។ (***៦ពិន្ទុ)***
- **បកស្រាយ**៖

**ក-មតិស្រប** «មហន្តរាយនៃនគរលង្កា បណ្តាលមកពីនាងសូរបនខា»ព្រោះនាងសូរបនខា៖

- **គំនិតសំខាន់** ***(១៥ពិន្ទុ)***
  - ✓ មានចិត្តចេតនាប្រតិព័ទ្ធទៅលើព្រះរាមព្រះលក្ស្មណ៍
  - ✓ រំខានដល់ការតាំងសិល៍្សរបស់ព្រះរាមព្រះលក្ស្មណ៍
  - ✓ បង្កការឈឺចាប់ដល់ក្រុងខរជាបងឱ្យធ្វើសង្គ្រាមជាមួយព្រះរាមរហូតបាត់បង់ជីវិត
  - ✓ មានគំនិតសងសឹក ចំពោះព្រះរាមព្រះលក្ស្មណ៍ ក៏ញុះញង់ក្រុងរាពណ៍ជាបងឱ្យមានចេតនាប្រតិព័ទ្ធទៅលើសីតា
- **ឧទាហរណ៍** ជាក់ស្តែងក្នុងរឿងរាមកេរ្តិ៍ខ្មែរ បានបង្ហាញដូចតទៅ៖ (***១៣ពិន្ទុ)***
  - ✓ ដោយដឹងថា ព្រះរាមនិងព្រះលក្ស្មណ៍បានតាំងសិល៍្សនៅព្រៃភ្នំទណ្ឌការណ្យ នាងសូរបនខាក៏ចូលមកចែចង់អ្នកទាំងពីរក្នុងបំណងសុំសេចក្តីស្នេហា តែត្រូវអ្នកទាំងពីរបដិសេធ។ នៅទីបំផុតនាងសូរបនខា ក៏ប្រើពាក្យមិនសមរម្យ ជាហេតុធ្វើឱ្យព្រះលក្ស្មណ៍ក្រេវក្រោធរហូតផ្តួលកោរសក់ កាត់ដៃរហូតនាងស្រែករំពងព្រៃ ឮដល់ក្រុងខរជាបងនាំគ្នាលើកទ័ពមកធ្វើចម្បាំងនឹងព្រះរាមរហូតត្រូវស្លាប់។
  - ✓ នាងមានចេតនារំខានព្រះរាមព្រះលក្ស្មណ៍ដែលជាប់ភារៈក្នុងការតាំងសិល៍្សមិនអាចដោះខ្លួនបានជាហេតុនាំឱ្យព្រះអង្គទាំងពីរទាល់ច្រក តម្រូវឱ្យនាងទៅសាកសួរចិត្ត ម្តងព្រះរាម ម្តងព្រះលក្ស្មណ៍។ ការមិនយល់ពីស្ថានភាពបែបនេះជាប្រការមួយដែលនាំឱ្យនាងខកចិត្តឡិតស្នេហ៍ដែលខ្លួនកំពុងស្រមើស្រមៃចង់បាននោះ។
  - ✓ នាងក៏បាននិយាយពីសម្ផស្សនាងសីតា ដែលល្អលើសគេហាក់ដូចជំរុញឱ្យក្រុងរាពណ៍មានចិត្តត្រេកត្រអាលចង់បាននាងសីតាមកធ្វើជាមហេសី ទោះជាដឹងថានាងមានស្វាមីគឺព្រះរាមហើយក៏ដោយ។ បញ្ហានេះក៏បណ្តាលឱ្យចិត្តក្រុងរាពណ៍ខិតខំរិះរកវិធីយ៉ាងណាដើម្បីចាប់នាងសីតាឱ្យបាន។ ចំណែកព្រះរាមវិញ ក៏មិនព្រមចុះញ៉មក៏ខិតខំរិះរកវិធីតបតនឹងក្រុងរាពណ៍វិញតាមយុទ្ធវិធីរៀងៗខ្លួន។
  - ✓ ក្រុងរាពណ៍ទោះបីដឹងថា សង្គ្រាមនេះមានផលវិបាកយ៉ាងណាក៏ដោយ ក៏ខ្លួននៅតែប្តេជ្ញាការពារសីតារហូតត្រូវព្រះរាមវាយកម្ទេចនគរលង្កាឱ្យវិនាសទាំងស្រុង។

- **សរុបមតិស្រប**: សរុបមក មហន្តរាយនៃនគរលង្កាពិតជាបណ្តាលមកពីនាងសូរបនខាប្រាកដមែន ដែលនាងមានចិត្តចែចង់មនុស្សប្រុសនោះ។ (***២ពិន្ទុ)***

**ខ-មតិផ្ទុយ** «មហន្តរាយនៃនគរលង្កា បណ្តាលមកពីអ្នកដទៃទៀត»ព្រោះអ្នកទាំងនោះ៖

- **គំនិតសំខាន់** ***(១៥ពិន្ទុ)***
  - ✓ ចូលចិត្តដំណោះស្រាយបញ្ហាដោយប្រើអំពើហិង្សា
  - ✓ ប៉ះពាល់ផលប្រយោជន៍រៀងខ្លួន
  - ✓ ដើម្បីការពារអំណាចរបស់ខ្លួន

- ✓ ចង់បង្ហាញពីឧត្តមភាពរបស់ខ្លួន។
- **ឧទាហរណ៍** ជាក់ស្ដែងក្នុងរឿងរាមកេរ្តិ៍ខ្មែរ បានបង្ហាញដូចតទៅ ***(១៣ពិន្ទុ)***
  - ✓ គ្រាន់តែនាងសូរបនខាសុំសេចក្ដីស្រឡាញ់ ក៏ព្រះលក្ស្មណ៍មិនអនុគ្រោះចំពោះឥរិយាបថដែលប្រព្រឹត្តឆ្គាំឆ្គងចំពោះទ្រង់ដែរ។ ព្រះអង្គហ៊ានកាត់ដៃ កោរសក់ ដែលជាលំអរបស់ស្ត្រីធ្វើឱ្យនាងឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត។ ចំពោះអំពើដ៏ឃោរឃៅនេះជាហេតុនាំឱ្យមានការឈឺចាប់ដល់ក្រុងខរជាបងនាងរហូតធ្វើសង្គ្រាមត្រូវវិនាសអស់ពលយក្សមួយចំនួន ហើយក្រុងខរខ្លួនឯងត្រូវស្លាប់នៅសមរភូមិទៀតផង។
  - ✓ វិនាសកម្មដ៏ឈឺចាប់នេះ ក៏បណ្ដាលឱ្យក្រុងរាពណ៍ជាបងនាងសូរបនខានិងក្រុងខរ រួមផ្សំនឹងចិត្តស្រឡាញ់សីតាផងក្រុងរាពណ៍ ក៏រកវិធីដើម្បីចាប់យកនាងសីតាមកទុកនៅក្រុងលង្កាក្នុងសួនអសោកជាហេតុនាំឱ្យព្រះរាមលើកទ័ពមកធ្វើសង្គ្រាមជាមួយក្រុងរាពណ៍ដោយប្រើល្បិចកលរៀងៗខ្លួនមិនគិតពីសេចក្ដីវេទនារបស់អ្នកលង្កាសោះឡើយ។
  - ✓ ព្រះរាមនៅតែតាមប្រមាញ់ទ័ពយក្សដោយឱ្យអ្នកយកការណ៍ដែលមានហនុមានទៅស៊ើបមើលពីពលយក្សឬទីតាំងស្បៀង ព្រមទាំងទីតាំងដទៃទៀតក្នុងក្រុងលង្កាទាំងមូល។

- **សរុបមតិផ្ទុយ:** ដូច្នេះ អន្តរាយនៃនគរលង្កាបណ្ដាលមកពីអ្នកដទៃទៀតប្រាកដមែន ***(២ពិន្ទុ)***

**គ- សំយោគ:** ជារួមមហន្តរាយនៃនគរលង្កា គឺពិតជាបណ្ដាលមកពីនាងសូរបនខាផងនិងអ្នកដទៃទៀតផងដែលមានក្រុងរាពណ៍ ព្រះរាម ព្រះលក្ស្មណ៍សុទ្ធតែនិយមប្រើអំពើហិង្សាក្នុងការស្រាយបញ្ហាទំនាស់។ បើសិនជាពួកគេចេះរកវិធីដ៏សមស្របណាមួយ ម៉្លេះសមនគរលង្កានិងប្រជារាស្ត្រដែលរស់នៅក្រុងលង្កានោះនឹងបានសេចក្ដីសុខជាមិនខានឡើយ។ ***(១០ពិន្ទុ)***

គ- បញ្ចប់សេចក្ដី (១៥ពិន្ទុ)

- **វាយតម្លៃប្រធាន :** មតិប្រធាន មិនទាន់ត្រឹមត្រូវទាំងស្រុងទេ ព្រោះជាការដាក់បន្ទុកតែទៅលើនាងសូរបនខាតែម្នាក់ រីឯអ្នកដទៃទៀតបែរជារួចខ្លួនទៅវិញ។ ***(១០ពិន្ទុ)***
- **មតិផ្ទាល់ខ្លួន:** តែទោះជាយ៉ាងណាក៏ដោយ ក៏មតិខាងលើនេះបានផ្ដល់ជាបទពិសោធដល់អ្នកសិក្សាអ្នកអានឱ្យចេះវិភាគទាំងឡាយ ដែលមានក្នុងអក្សរសិល្ប៍ ឬសង្គមជាតិក្ដី។ ***(៥ពិន្ទុ)***
- **រចនាបថ** (១០ពិន្ទុ)
  - ✓ អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ ***(៤ពិន្ទុ)***
  - ✓ លំនាំសំណេរល្អ ***(៦ពិន្ទុ)***

## ប្រធានអត្ថាធិប្បាយពិភាក្សាប្រៀបធៀប

ប្រធាន: តាមរយៈរឿងថៅកែចិត្តចោរមានមតិខ្លះវាយតម្លៃថា «ខ្សែជីវិតហាំពិតជាមានន័យ»។ រីឯ មតិខ្លះទៀតយល់ថា «ខ្សែជីវិតរបស់ហាំពុំមានន័យទេ»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងរឿងខាងលើនេះមកបញ្ជាក់។

### គម្រោងតែង

**១- ផ្ដើមសេចក្ដី (១៥ពិន្ទុ)**

- **លំនាំបញ្ហា:** មនុស្សគ្រប់រូបតែងតែមានបំណងប្រាថ្នាចង់ឱ្យជីវិតខ្លួនមានន័យ ឬមានខ្លឹមសាររស់នៅប្រកបដោយសុភមង្គល។ តែជីវិតជាក់ស្ដែងមិនមែនសុទ្ធតែបំពេញតាមបំណងប្រាថ្នាខាងលើនេះទេ គឺបុគ្គលខ្លះក៏សមប្រកបតាមទឹកចិត្តខ្លួនដែលចង់បាន តែខ្លះទៀតក៏មិនបានសម្រេចទៅវិញ។ ***(០៨ពិន្ទុ)***
- **ចំណូលបញ្ហា (បង្ហាញប្រធាន) :** ដោយសង្កេតឃើញពីភាពជោគជ័យនិងបរាជ័យក្នុងជីវិតបែបនេះហើយ ទើបតាមរយៈរឿងថៅកែចិត្តចោរ មានមតិពីរយល់ផ្សេងគ្នាខ្លះយល់ថា «ខ្សែជីវិតហាំពិតជាមានន័យ»។ រីឯមតិខ្លះទៀតយល់ថា«ខ្សែជីវិតរបស់ហាំ ពុំមានន័យទេ»។***(០៣ពិន្ទុ)***
- **ចំណោទបញ្ហា:** តើមតិទាំងពីរខាងលើនេះ មួយណាត្រឹមត្រូវជាង? ***(០៤ពិន្ទុ)***

**២- តួសេចក្ដី (៧៥ពិន្ទុ)**

- **ឃ្លាភ្ជាប់សេចក្ដី:** ដើម្បីជំរុញឱ្យការវែកញែកកាន់តែស៊ីជម្រៅថែមទៀតនោះយើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។ ***(០៣ពិន្ទុ)***
- ពន្យល់ពាក្យ ***(០៦ពិន្ទុ)***
  - ✓ ខ្សែជីវិត គឺជាដំណើរជីវិត គន្លងជីវិត ឬជោគវាសនានៃដំណើរជីវិតរបស់បុគ្គលម្នាក់ៗ។
  - ✓ មានន័យ គឺមានតម្លៃ មានប្រយោជន៍ បានសម្រេច ឬក៏ជោគជ័យ។
- ពន្យល់ន័យ ***(០៦ពិន្ទុ)***
  - ✓ មតិទី១ ដំណើរជីវិតរបស់តួអង្គហាំ ក្នុងរឿងថៅកែចិត្តចោរ ពិតជាបានសម្រេចជោគជ័យតាមបំណងប្រាថ្នារបស់ខ្លួន។
  - ✓ មតិទី២ ដំណើរជីវិតរបស់តួអង្គហាំ ក្នុងរឿងថៅកែចិត្តចោរ ពុំបានសម្រេចជោគជ័យតាមបំណងប្រាថ្នារបស់ខ្លួនឡើយ។
- បកស្រាយៈ

  ក- មតិទី១ "ខ្សែជីវិតហាំ ពិតជាមានន័យ" ព្រោះហាំៈ

  - ▪ គំនិតសំខាន់ ***(១៥ពិន្ទុ)***
    - ✓ បានបំពេញកាតព្វកិច្ចជាមេគ្រួសារល្អ
    - ✓ ជាឪពុកល្អខិតខំរកប្រាក់ឱ្យកូនបានរៀនសូត្រ
    - ✓ ជាប្ដីល្អខិតខំរកប្រាក់ឱ្យប្រពន្ធព្យាបាលជំងឺ
    - ✓ ជាកូនល្អរកប្រាក់មកឱ្យម្ដាយធ្វើបុណ្យមុននឹងគាត់អនិច្ចកម្ម
    - ✓ ខិតខំរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ។

- **ឧទាហរណ៍** ***(១៣ពិន្ទុ)***

ក្នុងរឿងថៅកែចិត្តចោរ បានបង្ហាញពីដំណើរជីវិតរបស់តួអង្គហំពោរពេញទៅដោយជីវិតមានន័យដោយគាត់បានបំពេញកិច្ចជាមេគ្រួសារល្អ។ ដូចសកម្មភាពគាត់បានឱ្យឃើញថាគាត់បានរកប្រាក់ដើម្បីៈ

✓ កូនបានចូលរៀន កូនលែងលូង់ខ្លៅដូចខ្លួនតទៅទៀត ហើយគាត់ក៏មានឈ្មោះថាជាឪពុកល្អមានព្រហ្មវិហារធម៌ចំពោះកូន ដោយរកអនាគតឱ្យកូន គឺមីកាទូចបានចូលរៀននៅអនុវិទ្យាល័យ។

✓ ប្រពន្ធបានជាសះស្បើយពីជំងឺ ព្រោះមីងយ៉ានឈឺដើមទ្រូង ក្អកខេះៗទៅពេទ្យត្រូវទិញថ្នាំចាក់ ហើយគាត់នឹងមានឈ្មោះថាជាប្តីដ៏ល្អ មានភក្តីភាពចំពោះប្រពន្ធ។

✓ ម្តាយបានធ្វើបុណ្យធ្វើទានមុននឹងគាត់ទទួលអនិច្ចកម្ម ព្រោះយាយចាន់មានវ័យចាស់ណាស់ទៅហើយៗ គាត់នឹងមានឈ្មោះថាជាកូនកតញ្ញូចំពោះអ្នកមានគុណ។

- **សរុបមតិទី១:** ដូច្នេះតាមភស្តុតាងខាងលើបានបញ្ជាក់ថា ខ្សែជីវិតរបស់ហំ ពិតជាមានន័យប្រាកដមែន។ ***(០២ពិន្ទុ)***

**ខ- មតិទី២** «ខ្សែជីវិតរបស់ហំ ពុំមានន័យទេ» ព្រោះហំបានប្រព្រឹត្តអំពើខុសឆ្គងទៅនឹងៈ

- **គំនិតសំខាន់** ***(១៥ពិន្ទុ)***

✓ ផ្លូវច្បាប់ គឺមានចេតនាសម្លាប់មនុស្ស

✓ ផ្លូវសីលធម៌ៈ

- ក្បត់នឹងសម្បជញ្ញៈ
- គ្មានមនសិការ
- គ្មានវិចារណៈ។

✓ ពុំមានមនោសញ្ចេតនាមនុស្សជាតិ

✓ ផ្លូវសាសនា ប្រាសចាកពុទ្ធឱវាទ ដោយសារតែលោភៈហ៊ានប្រព្រឹត្តអំពើអមនុស្សធម៌។

- **ឧទាហរណ៍** ***(១៣ពិន្ទុ)***

ក្នុងរឿងថៅកែចិត្តចោរ បានបង្ហាញពីខ្សែជីវិតរបស់ហំ ដែលរស់នៅគ្មានន័យ ដោយសារតែទង្វើរបស់ខ្លួនពុំមានការទទួលខុសត្រូវៈ

✓ បើកបរហួសល្បឿនកំណត់បង្កគ្រោះថ្នាក់ដោយចេតនា «បើកអាមួយម៉ោងមួយរយព្រលែងចំផ្លឹងជំនីរ» បណ្តាលឱ្យមានមនុស្សស្លាប់អស់បីនាក់និងរបួសមួយចំនួនទៀត។

✓ មានចេតនាចង់គេចវេះពីសំណាញ់ច្បាប់ ក្រោយពីខ្លួនបុនឡានថៅកែអុងប៉ាងហុងលីរួចមក «...ឱ្យតែបានមួយម៉ឺនគេចប្រាវឥឡូវ បន្លំប្តូរឈ្មោះ...»។

✓ ប្រមាថអាយុជីវិតមនុស្ស«បើមិនសម្លាប់គេ គោងទុកឱ្យគ្នាឯងស្លាប់ ... អាយុវាអស់ អ្នកណាដឹងធ្វើម៉េច»។

✓ បំពានត្រង់ «បាណាតិបាតា» ដែលព្រះពុទ្ធអង្គទ្រង់បានហាមប្រាម។

✓ គ្មានមនោសញ្ចេតនាមនុស្សជាតិ បើសិនជាអ្នកស្លាប់នោះជាកូន ប្រពន្ធ និងម្តាយរបស់គាត់វិញ តើគាត់មានអារម្មណ៍សោកស្តាយឬឈឺចាប់ដូចគ្រួសារជនរងគ្រោះជាមិនខាន។

✓ គ្មានមនសិការការងារ ក្បត់ឧត្ដមគតិខ្លួន ខ្វះសម្បជញ្ញៈ ដើម្បីតែប្រាក់រង្វង់បាត់បង់ស្មារតី ហើយបែរជាអះអាងការពារខ្លួនទាំងបំពានថា «ស្រុកឥឡូវអញ្ចឹង! គេកាប់ជ្រូកធ្វើបុណ្យ គេស៊ីសំណូកធ្វើបុណ្យ គេសំពះព្រះសង្ឃឱ្យគេស្រឡាញ់...»។

- **សរុបមតិទី២:** ដូច្នេះ តាមភស្ដុតាងខាងលើបានបញ្ជាក់ថា ខ្សែជីវិតរបស់ហាំពិតជាពុំមានន័យប្រាកដមែន។ ***(០២ពិន្ទុ)***

**គ- ពិភាក្សា:** ជារួមខ្សែជីវិតរបស់ហាំដែលយល់ថា មានន័យមិនត្រឹមត្រូវទេ ព្រោះរាល់ទង្វើរបស់ហាំ ជាទង្វើពោរពេញទៅដោយអមនុស្សធម៌ គិតតែប្រយោជន៍ខ្លួនឯង។ ជាងនេះទៅទៀត អំពើនេះបានប្រមាថអាយុជីវិតមនុស្ស ដោយមានរៀបចំផែនការត្រឹមត្រូវ។ ចំណែកការយល់ថា ខ្សែជីវិតហាំពុំមានន័យ គឺជាការត្រឹមត្រូវ ព្រោះលទ្ធផលចុងក្រោយនៃដំណើរជីវិតរបស់ហាំត្រូវទទួលទោស ធ្វើឱ្យគ្រួសារទាំងមូលបាត់បង់សុភមង្គល ខ្លួនត្រូវទទួលទោសតាមច្បាប់។ ***(១០ពិន្ទុ)***

៣- **បញ្ចប់សេចក្ដី** (១៥ពិន្ទុ)

- **វាយតម្លៃប្រធាន:** មតិទីមួយរបស់ប្រធានមិនត្រឹមត្រូវទេ ព្រោះជាគំនិតអត្តបុគ្គលនិយម រីឯមតិទីពីរត្រឹមត្រូវជាង ព្រោះជាគំនិតដែលចេះវិនិច្ឆ័យបានម៉ត់ចត់ចំពោះអំពើរបស់ហាំ។ ***(១០ពិន្ទុ)***
- **មតិផ្ទាល់ខ្លួន:** តែមតិខាងលើនេះ បានផ្ដល់ជាបទពិសោធដល់អ្នកសិក្សាឱ្យចេះពិចារណារាល់អំពើណាមួយដែលខ្លួនបម្រុងនឹងប្រព្រឹត្តដើម្បីជៀសផុតពីវិបត្តិណាមួយ ដែលនាំឱ្យខ្លួនក្លាយទៅជាមនុស្សបាត់បង់កិត្តិយសក្នុងសង្គម។ ***(០៥ពិន្ទុ)***
- **រចនាបថ** (១០ពិន្ទុ)
  - ✓ អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ ***(០៤ពិន្ទុ)***
  - ✓ លំនាំសំណេរល្អ ***(០៦ពិន្ទុ)***

## ប្រធានអត្ថាធិប្បាយប្រៀបធៀប

---

ប្រធាន: ចូរអ្នកប្រៀបធៀបខ្សែជីវិតតួអង្គហាំក្នុងរឿងថៅកែចិត្តចោរនិងខ្សែជីវិតតួអង្គសមក្នុងរឿងព្រះអាទិត្យ ថ្មីរះលើផែនដីចាស់។ តើមានចំណុចដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

---

### គម្រោងតែង

១- **ផ្ដើមសេចក្ដី** (១៥ពិន្ទុ)

- **លំនាំបញ្ហា:** បើនិយាយពីដំណើរជីវិតរបស់មនុស្សក្នុងលោកយើងនេះមានច្រើនបែប ច្រើនយ៉ាងដោយបុគ្គលខ្លះពុះពារនឹងជីវិតតែបន្តិចបន្តួច ក៏មានជីវភាពល្អប្រណីតរស់ក្នុងស្ថានភាពស្តុកស្តម្ភរីឯបុគ្គលខ្លះទៀត ខិតខំស្រវាស្រទេញប្រឈមក្នុងជីវិតគ្រប់បែបបយ៉ាង តែជីវភាពបែរជាលំបាកតោកយ៉ាកស្ទើរគ្មានសេចក្ដីសុខ ក្នុងមួយជីវិតខ្លួន ទៅវិញ។***(៧ពិន្ទុ)***
- **ចំណូលបញ្ហា (បង្ហាញប្រធាន)** : យ៉ាងនេះហើយ ទើបជុំវិញនៃដំណើរជីវិតរបស់មនុស្សនេះនៅក្នុងរឿងថៅកែចិត្តចោរ និងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធក៏បានឆ្លុះបញ្ចាំពីខ្សែជីវិតតួអង្គហាំ និងតួអង្គសមមកបង្ហាញដល់អ្នកអាន និងអ្នកសិក្សាដែរ។***(៨ពិន្ទុ)***

- **ចំណោទបញ្ហា**: តើខ្សែជីវិតរបស់តួអង្គទាំងពីរខាងលើនេះមានចំណុចដូចគ្នា និងចំណុចខុសគ្នាយ៉ាងណាខ្លះ? ***(៥ពិន្ទុ)***

**២- តួសេចក្តី (៨៥ពិន្ទុ)**

(ឃ្លាភ្ជាប់ពន្យល់ពាក្យពន្យល់ន័យ ***«១៥ពិន្ទុ»***)

- **ឃ្លាភ្ជាប់សេចក្តី**: មុននឹងឈានចូលដល់ការប្រៀបធៀបខ្សែជីវិតតួអង្គទាំងពីរខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។
- **ពន្យល់ពាក្យ៖** ខ្សែជីវិត ដំណើរជីវិត ឬការប្រព្រឹត្តទៅក្នុងមួយជីវិតរបស់បុគ្គលម្នាក់ៗ។
- **ពន្យល់ន័យ**: តាមគំនិតប្រធាន បានតម្រូវឱ្យធ្វើការបង្ហាញនូវលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នានៃការប្រព្រឹត្តទៅក្នុងមួយជីវិតរបស់តួអង្គហាំក្នុងរឿងថៅកែចិត្តចោរនិងតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។
- **បកស្រាយ៖**

  **ក- លក្ខណៈដូចគ្នានៃខ្សែជីវិតតួអង្គហាំ និងខ្សែជីវិតតួអង្គសម *(៣០ពិន្ទុ)***

  - **គំនិតសំខាន់ និងឧទាហរណ៍**
    - ✓ ស្ថិតក្នុងស្ថានភាពក្រីក្រលំបាកដូចគ្នា (ហាំជាអ្នកបើកបរឡានថៅកែចិត្តចោរ សមជាកម្មករស៊ីឈ្នួល)
    - ✓ ត្រូវថៅកែបោកប្រាស់(ថៅកែចិត្តចោរមិនបានធ្វើតាមពាក្យសន្យា ដែលសន្យាថាផ្តល់ប្រាក់១ម៉ឺនរៀលទៅហាំ បើហាំធ្វើការបានសម្រេច។ ថៅកែហុកមិនប្រគល់ប្រាក់១ម៉ឺនរៀលទៅសមតាមពាក្យសន្យាក្រោយពីបញ្ចប់ទំនាស់)។
    - ✓ ធ្លាប់បានប៉ូលីសចាប់ខ្លួនពីបទល្មើសច្បាប់(ហាំត្រូវនគរបាលចាប់បញ្ជូនទៅប៉ុស្តិ៍ពីបទបង្កគ្រោះថ្នាក់ក្នុងការបើកបរ។ សមត្រូវសមត្ថកិច្ចចាប់បញ្ជូនទៅពន្ធនាគារពីបទលួចចូលផ្ទះគេខុសច្បាប់ និងឆក់ទ្រព្យអ្នកដទៃ)។
    - ✓ ស្រឡាញ់ភាពយុត្តិធម៌ និងទទួលខុសត្រូវ(ហាំចេញសារភាព សមប្រគល់លុយឱ្យម្ចាស់ដើមវិញ)

- **សរុបលក្ខណៈដូច**: សរុបសេចក្តីមក ចំណុចសំខាន់ៗខាងលើនេះសុទ្ធសឹងជាលក្ខណៈដូចគ្នានៃខ្សែជីវិតតួអង្គហាំក្នុងរឿងថៅកែចិត្តចោរនិងតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។

  **ខ- លក្ខណៈខុសគ្នានៃខ្សែជីវិតតួអង្គហាំ និងខ្សែជីវិតតួអង្គសម *(៣០ពិន្ទុ)***

  - **គំនិតសំខាន់ និងឧទាហរណ៍៖**

    **ខ្សែជីវិតតួអង្គហាំ៖**
    - ✓ មានតម្រូវការចាំបាច់ក្នុងគ្រួសារ(កូនចូលរៀនអនុវិទ្យាល័យ ប្រពន្ធត្រូវព្យាបាលជំងឺ ម្តាយត្រូវធ្វើបុណ្យ)
    - ✓ មានជំនាញខាងបើកបររថយន្ត(មានអាជីពជាតៃកុងឡានរបស់ថៅកែចិត្តចោរ)
    - ✓ មានមិត្តភក្តិរួមអាជីពជួយគាំទ្រអំពើរបស់ខ្លួនក្នុងការទាមទារយុត្តិធម៌ (គង់ សុខ មាន ទ្រី និងផានីត) ចេញមុខជួយតវ៉ា
    - ✓ មានក្រុមគ្រួសារ (ប្រពន្ធមីងយ៉ាន កូនគឺមីកាទូច ម្តាយគឺយាយចាន់)
    - ✓ ប្រព្រឹត្តបទល្មើសក្នុងគ្រោះថ្នាក់ចរាចរណ៍(បើកល្បឿនលឿនហួសកំណត់ បុកឡានថៅកែហុងលីនាំឱ្យមានមនុស្សស្លាប់ចំនួន៣នាក់ និងរបួសមួយចំនួនទៀត)

- ✓ មិនបានសម្រេចតាមបំណង (ថៅកែមិនប្រគល់ប្រាក់១ម៉ឺនរៀលតាមពាក្យសន្យា)។

**ខ្សែជីវិតតួអង្គសមះ**

- ✓ មិនមានតម្រូវការចាំបាច់ក្នុងគ្រួសារ (គ្មានកូន គ្មានម្តាយ ឪពុក ប្រពន្ធសុទ្ធតែត្រូវស្លាប់ចោល)។
- ✓ មានជំនាញខាងកសិកម្ម (ជាកសិករនៅឃុំបរវិល ខេត្តបាត់ដំបង)។
- ✓ ពុំមានមិត្តភក្តិរួមអាជីពជួយគាំទ្រអំពើរបស់ខ្លួនក្នុងការទាមទារយុត្តិធម៌ទេ (ទទួលខុសត្រូវដោយខ្លួនឯង)
- ✓ ពុំមានសាច់ញាតិ ឬក្រុមគ្រួសារ (កំព្រាឪពុកម្តាយ ប្រពន្ធស្លាប់ចោលអស់)
- ✓ ប្រព្រឹត្តបទល្មើសដោយមានបំណង (ចង់សម្លាប់ថៅកែហុកតែត្រូវជាប់គុកអស់៣ខែ ឆក់កាបូបប្រពន្ធឧកញ៉ាសំបូរសម្បត្តិ ត្រូវជាប់គុក៦ខែ)
- ✓ មានជីវភាពធូរធារ (សមក្លាយទៅជាកសិករគំរូ មានកិត្តិយសត្រូវជ្រើសតាំងជាប្រធានគណៈកម្មការកងឃុំ និង បានចូលរួមសមាជជាតិលើកទី៩ទៀតផង)។

- **សរុបលក្ខណៈខុស** : សរុបសេចក្តីមក ចំណុចសំខាន់ៗខាងលើនេះ សុទ្ធសឹងជាលក្ខណៈខុសគ្នានៃខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ និងតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។

**គ- សរុបរួម** : ដូច្នេះខ្សែជីវិតរបស់តួអង្គហំក្នុងរឿងថៅកែចោរនិងខ្សែជីវិតរបស់តួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ដំណើរជីវិតមិនដូចគ្នាទេ តែមានបំណងប្រាថ្នាតែមួយដូចគ្នា គឺចង់ស្វែងរកសុភមង្គលជូនដល់ក្រុមគ្រួសារដូចគ្នា។ ***(១០ពិន្ទុ)***

**៣- បញ្ចប់សេចក្តី** (១០ពិន្ទុ)

- **វាយតម្លៃប្រធាន**: ឆ្លងតាមការប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញថា ខ្សែជីវិតតួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ប្រសើរជាងខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ ព្រោះនៅទីបំផុតនៃខ្សែជីវិតរបស់តួអង្គសមទទួលបានជោគជ័យ និងមានសុភមង្គលជាងខ្សែជីវិតតួអង្គហំក្នុងរឿងថៅកែចិត្តចោរ។ ***(៦ពិន្ទុ)***
- **មតិផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមជាអ្នកសិក្សា យើងគប្បីចេះពិចារណាឱ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តធ្វើអ្វីមួយទើបយើងទទួលបានសុភមង្គលពិតប្រាកដ។ ***(៤ពិន្ទុ)***
- **រចនាបថ** (១០ពិន្ទុ)
  - ✓ អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ ***(៦ពិន្ទុ)***
  - ✓ លំនាំសំណេរល្អ ***( ៥ពិន្ទុ)***

## ៧- ប្រធានតែងសេចក្តីដកស្រង់ចេញពីអក្សរសិល្ប៍ រឿងទុំទាវ រឿងព្រះវេស្សន្តរ រឿងរាមកេរ្តិ៍

### ៧.១- រឿងទុំទាវ

#### ក- ប្រធានពន្យល់

ប្រធាន: មានទស្សនៈមួយបានពោលថា«រឿងទុំទាវបានបង្ហាញឱ្យឃើញពីជីវភាពរាស្ត្រខ្មែរនាសម័យលង្វែក»។ ចូរពន្យល់ ដោយឆ្លុះបញ្ចាំងតាមរយៈរឿងខាងលើនេះ។

### សេចក្តីអត្ថាធិប្បាយ

គេអាចធ្វើការសិក្សាស្រាវជ្រាវពីអតីតកាល អាស្រ័យដោយពឹងផ្អែកតាមរយៈប្រវត្តិសាស្ត្រ សិលាចារឹក ភូមិសាស្ត្រ ឬមួយតាមរយៈអក្សរសិល្ប៍ជាដើម ព្រោះអក្សរសិល្ប៍មានតួនាទីសំខាន់ក្នុងការលើកយកជីវភាពមនុស្សមកឆ្លុះបញ្ចាំងដើម្បីឱ្យអ្នកអានអ្នកសិក្សាបានស្វែងយល់ពីការពិតនាសម័យកាលនីមួយៗ។ ដោយមានបំណងក្នុងការសិក្សា ស្វែងយល់ដូចខាងលើនេះហើយ ទើបមានទស្សនៈមួយបានពោលថា «រឿងទុំទាវបានបង្ហាញឱ្យឃើញពីជីវភាពរាស្ត្រខ្មែរនាសម័យលង្វែក»។

តើរឿងទុំទាវ បានលើកយកជីវភាពរាស្ត្រខ្មែរ មកឆ្លុះបញ្ចាំងយ៉ាងណាខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយទស្សនៈប្រធានខាងលើ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។ «រឿងទុំទាវ» ជាចំណងជើងរឿងដែលនិពន្ធឡើងដោយភិក្ខុសោម ហើយនិយាយពីប្រវត្តិស្នេហ៍ដ៏ឈឺចាប់របស់យុវជនខ្មែរក្រោមរបបសក្តិភូមិនាសម័យលង្វែក។ រីឯ «ជីវភាព» គឺជាភាពនៃការរស់នៅការចិញ្ចឹមជីវិតរបស់មនុស្ស ហើយ «សម័យលង្វែក» គឺសំដៅទៅលើសម័យកាលមួយដែលមាននៅក្នុងប្រវត្តិសាស្ត្រខ្មែរជាមួយនោះប្រទេសកម្ពុជាកំពុងតែកើតមានចម្បាំងជាច្រើនលើកច្រើនសាទៀតផង។ តាមគំនិតប្រធានមានន័យថា រឿងទុំទាវដែលនិពន្ធដោយព្រះភិក្ខុសោមបានបង្ហាញឱ្យឃើញពីការរស់នៅរបស់ប្រជារាស្ត្រខ្មែរនាសម័យលង្វែក។

ជាការពិតណាស់ រឿងទុំទាវបានបង្ហាញឱ្យឃើញពីជីវភាពរាស្ត្រខ្មែរនាសម័យលង្វែក ព្រោះអក្សរសិល្ប៍មាននាទីសំខាន់ក្នុងការផ្ដិតយកជីវភាពសង្គមនៅសម័យណាមួយមកឆ្លុះបញ្ចាំឬបង្ហាញឱ្យអ្នកសិក្សាបានស្គាល់។ ការឆ្លុះបញ្ចាំងនេះប្រព្រឹត្តទៅដោយផ្អែកលើវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលជាសសរស្តម្ភក្នុងការទ្រទ្រង់សង្គមជាតិនីមួយៗ។ យ៉ាងណាមិញ ក្នុងរឿងទុំទាវកវីនិពន្ធក៏បានលើកយកការគ្រប់គ្រង នៅសម័យលង្វែកមកបង្ហាញឱ្យឃើញថា សម័យនោះប្រព្រឹត្តទៅគេប្រើអំណាចផ្ដាច់ការចាប់តាំពីថ្នាក់កំពូលរហូតដល់មូលដ្ឋាន។ ដូចជាអំណាចព្រះរាជា ឬអំណាចស្ដេចផែនដីគឺព្រះរាមាបានអនុវត្តមកលើអ្នកក្រោមបង្គាប់ជាអំណាចផ្ដាច់ការសុទ្ធសាធ។ ដូចជាក្នុងការកាត់ទោសអរជូនម៉ឺនងួនដោយសារតែអរជូនប្រមាថទ្រង់ គឺហ៊ានយកទុំទៅសម្លាប់ ដែលហាក់ដូចជាមិនគោរពតាមព្រះរាជបញ្ជាទ្រង់ដែរ។ការដាក់ទោសប្រហារជីវិតដោយជីកកប់ត្រឹមកហើយរាស់នឹងរនាស់លើក្បាលទាំងរស់នោះជាអំពើអមនុស្សធម៌មួយហើយ តែទ្រង់បាន «...ធ្វើទុក្ខធ្វើទោសឱ្យអស់សូន្យ សន្តានបងប្អូនបញ្ចូលងារ...» នោះចាត់ទុកជាអំពើដ៏ឃោរឃៅមួយមកលើអ្នកត្បូងឃ្មុំទាំងមូល។ ដោយហេតុថា អ្នកទាំងនោះមិនមែនជាអ្នកផ្សំគំនិតជាមួយម្ដាយ

ទាវអរជូន និងម៉ឺនងួនទេ ហើយអំពើនេះចាត់ទុកជាអំពើព្រៃផ្សៃបំផុត។ទន្ទឹមនឹងអំណាចព្រះរាជា គឺមានអំណាចស្តេចត្រាញ់ឬអំណាចចៅហ្វាយខេត្តត្បូងឃ្មុំ។ ដូចកវីបានពណ៌នា «ឧកញ៉ាអរជូនមួនមាំពេក ធម្មតាក្រោមមេឃទាបជាងភ្នំមានរិទ្ធិអំណាចឥតជំនុំកាប់ចាក់វាយដំពុំប្រណី»។ មានន័យថា អំណាចស្តេចត្រាញ់នៅពេលនោះ គេអាចកាប់សម្លាប់បុគ្គលណាមួយដោយពុំចាំបាច់ជំនុំជំរះក្តីនោះឡើយ ដូចទុំជាដើម។ រីឯអំណាចមេគ្រួសារវិញក៏បានបង្ហាញតាមរយៈម្តាយទាវដែលបង្ខំទាវឱ្យរៀបការជាមួយម៉ឺនងួនថា «មិនដែលសោះឡើយទាវអើយនំ ច្រឡើសបើសធំម្តេចជាងនាឡិ កូនគោកាចកៀចដោយព្រៃវាល រោលរាលឈឺខ្លួនជូនដល់ស្លាប់»។ បានសេចក្តីថាមេគ្រួសារមានសិទ្ធិគ្រប់យ៉ាងក្នុងការសម្រេចទៅលើជោគវាសនាកូន។ ទាំងអស់នេះសុទ្ធតែជាអំណាចផ្តាច់ការ ទោះបីមានរូបភាពផ្សេងគ្នាក៏ដោយ ក៏មានខ្លឹមសារផ្តាច់ការដូចគ្នាដែរ។ ក្រៅពីការគ្រប់គ្រងកវីក៏បានបង្ហាញពីវិស័យសេដ្ឋកិច្ចផងដែរនៅក្នុងស្នាដៃដដែលនេះ គឺប្រជារាស្ត្រនាសម័យលង្វែកបានប្រកបមុខរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ ដូចជានេនទុំ និងនេនពេជ្របាននាំគ្នាយកគោកទៅដូរស្រូវនៅត្បូងឃ្មុំ។ គេអាចនិយាយបានថា ក្រៅពីទុកបរិភោគស្រូវនេះ ក៏ជាផលិតផលមួយដ៏សំខាន់ក្នុងសម័យលង្វែក គឺគេអាចចរាចរជំនួសរូបិយបណ្ណក្នុងវិស័យពាណិជ្ជកម្មផងដែរ។ មិនតែប៉ុណ្ណោះ ការដឹកជញ្ជូននៅសម័យលង្វែក គេអាចធ្វើដំណើរតាមផ្លូវគោកក្នុងការដឹកនាំយកផលិតទៅលក់នៅតាមភូមិស្រុកនីមួយៗប្រព្រឹត្តទៅតាមរយៈរទេះគោឬគេក៏អាចធ្វើដំណើរតាមផ្លូវទឹកដោយមធ្យោបាយទូកបានផងដែរ។ ដូចករណីនាងទាវទៅលង្វែក ឬទុំមកត្បូងឃ្មុំសុទ្ធតែជិះទូកដោយឆ្លងកាត់ភូមិស្រុកមួយចំនួននៅតាមជួរមាត់ទន្លេ។ លើសពីនេះទៀតក្នុងវិស័យដដែលនេះគេសង្កេតឃើញមានផ្សារលក់ដូរជាសម្ភារៈប្រើប្រាស់ផ្សេងៗក្នុងស្រុក។ ដូចជានាងទាវពេលធ្វើដំណើរទៅលង្វែកក៏ឆ្លៀតឡើងផ្សារនៅភ្នំពេញ។ ចំពោះវិស័យវប្បធម៌វិញត្រូវបានកវីលើកយកមកបង្ហាញដែរគឺសម័យនោះរាស្ត្រខ្មែរនិយមជឿទៅលើការទស្សន៍ទាយ កម្មផល និងមន្តអាគម។ ដូចជាទុំពេលវិលមកពីត្បូងឃ្មុំវិញក៏សុំលោកគ្រូសឹក តែគ្រូមិនឱ្យសឹក ព្រោះទំនាយត្រូវស្លាប់ហើយទុំក៏សម្រេចចិត្តលួចសឹកដោយចោទថាស្នេហានេះកើតមកពីកម្មទីបំផុត ក៏ត្រូវស្លាប់ដូចជើងលេខនោះប្រាកដមែន។ មួយវិញទៀតទុំក៏បានសែកប្រេងម្សៅ បន្ទាប់ពីបានទទួលគ្រឿងបរិក្ខារពីនាទាវរួចមក ដោយរំលឹកដល់សារិកា លិនថោងករវីក សម្ពលីមណីចិន្តា។ ចំណែកប្រពៃណីទំនៀមទម្លាប់វិញកវី ក៏បានឆ្លុះឱ្យឃើញបន្ថែមទៀតថាខ្មែរយើងតម្រូវឱ្យកូនស្រីពេញវ័យត្រូវចូលម្លប់ ដើម្បីសិក្សាវិជ្ជាគេហកិច្ចត្រៀមខ្លួនកសាងគ្រួសារនាពេលអនាគត។ ជាក់ស្តែងនាងទាវដែលត្រូវនៅក្នុងម្លប់ ដោយបំពេញកិច្ចនានាតាមការបង្ហាត់បង្រៀនពីម្តាយ។ ចំពោះកូនប្រុសពេញវ័យ ត្រូវបួសរៀននៅតាមវត្តអារាមដែលមានលោកគ្រូឧបជ្ឈាយ៍ជាអ្នកបង្ហាត់បង្រៀន។ ដូចជាទុំនិងពេជ្រត្រូវទៅបួសរៀននៅវត្តវិហារធំនិងត្រូវសិក្សាទាំងធម៌អាថ៌ទាំងអក្សរសាស្ត្រ ព្រមទាំងវិជ្ជាជីវៈដើម្បីឱ្យមានអាជីពនៅក្រោយពេលចាកសិក្ខាបទ។ រីឯពិធីចូលស្តីដណ្តឹងវិញ គឺធ្វើមុនពេលរៀបមង្គលការ ព្រោះខ្មែរយើងតម្រូវឱ្យកូនប្រុសចូលស្តីដណ្តឹងកូនស្រីជាមុនសិន ទោះបីកូនប្រុសស្ថិតក្នុងត្រកូលណាក៏ដោយ។ ដូចជាអរជូនដែលជាចៅហ្វាយខេត្តត្បូងឃ្មុំ បានចាត់ឱ្យអ្នកផ្លូវថៅមហាចូលចែចូវស្តីដណ្តឹងនាងទាវដែលមានបណ្តាការហែហាមទៅជាមួយផង ហើយពិធីមង្គលការបានប្រព្រឹត្តទៅនៅគេហស្ថានខាងស្រីដោយបានធ្វើកិច្ចទៅតាមពិធីផ្សេងៗដែលជាទំនៀមទម្លាប់ខ្មែរ។

សរុបសេចក្តីមករឿងទុំទាវ ពិតជាបានបង្ហាញឱ្យឃើញពីជីវភាពរាស្ត្រខ្មែរនាសម័យលង្វែកប្រាកដមែន ហើយការបង្ហាញបែបនេះ គឺជាការបង្ហាញពីលក្ខណៈជាតិខ្មែរពិតៗ។

ឆ្លងតាមការបកស្រាយខាងលើនេះ បានបង្ហាញឱ្យឃើញថា ទស្សនៈប្រធានផ្សារភ្ជាប់ទៅនឹងតម្លៃតថៈមួយក្នុងអរិយធម៌ដ៏សម្បូរបែបរបស់ជនជាតិខ្មែរដែលមានតាំងពីបុរាណកាលមកម្ល៉េះ។ ជាងនេះទៅទៀត ទស្សនៈខាងលើក៏បានរួមចំណែកអប់រំដល់កូនខ្មែរជំនាន់ក្រោយឱ្យស្គាល់ពីតម្លៃវប្បធម៌ជាតិ និងមោទនភាពជាតិ ព្រមទាំងឱ្យយើងចេះថែរក្សានិងការពារមរតកជាតិនេះឱ្យគង់វង្សស្ថិតស្ថេរ។

## ខ- ប្រធានពិភាក្សា

ប្រធានៈ គេនិយាយថា«ទុំមានកម្ម បានជាត្រូវអរជូនយកទៅសម្លាប់»។ តែតាមដំណើររឿង អ្នកខ្លះយល់ថា«ទុំស្លាប់ ព្រោះទុំមិនប្រើបញ្ញាត្រិះរិះ»។ចូរពិភាក្សា ដោយឆ្លុះបញ្ចាំងតាមរយៈរឿងទុំទាវ។

## សេចក្តីអត្ថាធិប្បាយ

មនុស្សគ្រប់រូប ពុំមានបុគ្គលណាមួយមានជីវិតអមតៈឡើយ គឺតែងតែរូបស្លាប់ទៅវិញជាការធម្មតា គ្រាន់តែការស្លាប់នោះមានមូលហេតុផ្សេងៗគ្នា គឺខ្លះស្លាប់ដោយជំងឺបៀតបៀនខ្លះស្លាប់ដោយចេតនាសម្លាប់ពីសំណាក់បុគ្គលណាម្នាក់។ ជុំវិញនៃការស្លាប់នេះ កវីសោមក៏បានលាតត្រាដាងតាមរយៈតួអង្គទុំក្នុងរឿងទុំទាវដែរ ហើយនាំឱ្យគេនិយាយថា «ទុំមានកម្ម បានជាត្រូវអរជូនយកទៅសម្លាប់»។ តែតាមដំណើររឿង អ្នកខ្លះយល់ថា«ទុំស្លាប់ ព្រោះទុំមិនប្រើបញ្ញាត្រិះរិះ»។

តើមតិទាំងពីខាងលើនេះ មួយណាត្រឹមត្រូវជាង?

ដើម្បីជាជំនួយ ដល់ការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ ពាក្យថា «កម្ម» នៅពេលនេះ គឺសំដៅទៅលើអំពើល្អ ឬអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តកន្លងមកកសាងយ៉ាងណានឹងទទួលផលយ៉ាងនោះ។ រីឯ«បញ្ញាត្រិះរិះ» គឺជាការប្រើប្រាស់គំនិត ឬប្រាជ្ញារបស់ខ្លួន ក្នុងការដោះស្រាយបញ្ហាណាមួយចំពោះមុខ។ តាមមតិទីមួយមានន័យថា ដោយសារតែទុំបានប្រព្រឹត្តអំពើមិនល្អបានជាអរជូនយកទៅទុំសម្លាប់ ហើយមតិទីពីរ មានន័យថាទុំបាត់បង់ជីវិត ដោយសារតែទុំពុំបានប្រើប្រាស់គំនិតឬប្រាជ្ញារបស់ខ្លួនមកដោះស្រាយបញ្ហាចំពោះមុខ។

ជាការពិតណាស់ បើសិនជាផ្អែកតាមសកម្មភាពទុំបានបង្ហាញថា ទុំពិតជាមានកម្មទើបបានត្រូវអរជូនយកទៅសម្លាប់បែបនេះ ព្រោះថាជោគវាសនារបស់ទុំត្រូវបានព្យាករណ៍ជាមុនដោយលោកគ្រូឧបជ្ឈាយ៍នៅវត្តវិហារធំ។ ចំពោះលទ្ធផលនៃការទស្សន៍ទាយនោះមានភាពអវិជ្ជមានច្រើនក្នុងដំណើរជីវិត ទុំប៉ុន្តែទុំមិនត្រឹមតែមិនជឿតាមទំនាយប៉ុណ្ណោះទេតែទុំហ៊ាននមានៈលួចសឹកតែអង្គឯងដោយឥតក្រែងរអែងសោះឡើយ។ តួយ៉ាងក្រោយពីវិលត្រឡប់មកពីត្បូងឃ្មុំវិញទុំក៏កុហកលោកគ្រូថា« គ្រោះថ្នាក់ជំពាក់ញោមស្រីបន់ ថាអន់ឱ្យខ្ញុំលាត្រឡប់ សឹកទៅឱ្យជាស្បើយកុំឱ្យថប់ ជួបចប់ដល់ចាស់ឈ្មុះទាំងព្រម»។ សម្តីរបស់ទុំ បានធ្វើឱ្យលោកគ្រូមានការសង្ស័យយ៉ាងខ្លាំង ទើបលោកគ្រូចាប់ផ្តើមទស្សន៍ទាយ «លោកគ្រូស្តាប់ជាក់កន្ទ្រាក់ក្តារឆ្នួនបូកជើងហារថាតែហោង កុហកអញទេអាកន្ទ្រម ស្រីចោមស្រូតបោលចោលមកលា។ អញវាយលេខលុបគ្រប់ជើងហារ លេខឆ្លើយឡើងថាអាកុំពារ កុំពុះទម្លុះក្រែងវេទនា ឃើញជានេនពេជ្រគេចគ្រាន់បើ។ នេនពេជ្រសឹកចុះខែបុស្សបានទុំឯងឈប់ខានទើបប្រសើរចាំដល់ពិសាខសិនសុំដើរសឹកហើយត្រូវលើបានជាធំ»។ មិនតែប៉ុណ្ណោះ

ទុំមានៈលួចសឹកមិនបារម្ភពីឧបសគ្គចំពោះមុខឡើយ ហើយសារភាពថានោះគឺជាកម្មដែលបណ្តាលឱ្យខ្លួនហ៊ានប្រព្រឹត្តបែបនេះ។ជាក់ស្តែងមុនពេលលួចសឹកទុំក៏បានរៀបរាប់ «រួចថាអញនៅមិនបានឡើយ ព្រះគុណខ្ញុំអើយហេតុតែកម្ម ជាកាលណានឹងប្រឹងទ្រទ្រាំ ម្ល៉េះសមស្លាប់ខ្លួនមួនមែនពិត។ មិនស្តាយផ្ទួសប្រាណបានប៉ុនសក់ កម្មនាំកញ្ឆក់ឱ្យងងឹត មោហ៍បាំងឆ្នាំងគ្របក្រសោបរឹត គ្មានគិតគ្មានគូរលោកគ្រូខ្វាល់»។ ភាពមានៈនេះហើយ ដែលជាដើមហេតុនៃកម្ម ហើយក៏ត្រូវអរជូនសម្លាប់នោះ។ មួយវិញទៀតក្នុងនាមជាបព្វជិតទុំបែរជាបំពានលើព្រះធម៌វិន័យនិងសីលធម៌ គឺមិនបានគោរពតាមឱវាទព្រះពុទ្ធជាម្ចាស់នោះឡើយបានបំពានតាំងពីពេលបានឃើញនាងទាវដំបូងមកម្ល៉េះ។ ដូចជាពេលទៅស្មូតផ្ទះនាងទាវទុំបំភ្លេចពាក្យទូន្មានរបស់ពេជ្រថាក្នុងនាមជាព្រះសង្ឃត្រូវមានការប្រុងប្រយ័ត្នគឺ «ថាដើរមានបួនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ បើដើរទៅក្តីបាសកសោះ កេរកោះថ្លោះធ្លោយឱ្យមានប្រាំ»។ មានន័យថា មិនលុះក្នុងអគតិបួនយ៉ាងមានឆន្ទាគតិគឺលំអៀង ព្រោះស្រឡាញ់ ទោសាគតិគឺលំអៀង ព្រោះស្អប់ ភយាគតិគឺលំអៀង ព្រោះភ័យខ្លាច និងមោហាគតិគឺលម្អៀង ព្រោះមិនដឹងល្ងង់ និងមិនច្បាស់ការណ៍។ ចំណែកប្រាំគឺសំដៅសីលប្រាំដែលមានបាណាតិបាតាគឺហាមប្រមាថជីវិតសត្វ មនុស្ស អទិន្នាទានា គឺហាមចង់បានទ្រព្យអ្នកដទៃ កាមេ គឺហាមមានស្នេហាខុសច្បាប់ មុសាវាទគឺហាមនិយាយកុហក និងសុរាមេរ័យ គឺហាមសេពគ្រឿងញៀនស្រវឹង។ ជាងនេះទៅទៀតនេនទុំមិនអាចកាត់បន្ថយកិលេស ឬតណ្ហាក្នុងនាមជាអ្នកបួសបានបណ្តោយឱ្យមនោសញ្ចេតនាអូសទាញស្នេហាខុសប្រពៃណី។ ដូចជាគ្រាន់តែបានឃើញនាទាវភ្លាម ទុំក៏មានអារម្មណ៍ជ្រួលច្របល់«រួននេនស្តាប់ជាក់ភ្ញាក់ព្រើតប្រឹង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ  យល់ទាវឈរស្ងួបដើររេរា ស្ទុះស្ទាចូលក្នុងស្លុងចេញក្រៅ។... នេនយល់ដូច្នោះក្នុងពោះព្រួចកាន់ក្ដួចកើតទុក្ខចុកឱរា ឱរូបហ្នឹងហើយទាវពុំងា មិនងាកបំពារបំពេរនេ»។

សរុបសេចក្តីមកតាមភ័ស្តុតាងខាងលើនេះហើយ ដែលបញ្ជាក់ថា ទុំពិតជាមានកម្មបានជាត្រូវអរជូនយកទៅសម្លាប់។

តើទុំពិតជាមានកម្មមែន ឬយ៉ាងណា បានជាត្រូវអរជូនសម្លាប់?

ផ្ទុយទៅវិញ បើសិនជាគេធ្វើការវិភាគឱ្យបានស៊ីជម្រៅជាងនេះទៅទៀត ប្រាកដជាឃើញថាទុំស្លាប់ព្រោះទុំមិនប្រើបញ្ញាត្រិះរិះនៅចំពោះមុខស្ថានការណ៍ដ៏តឹងតែងនោះទៅវិញទេ។ ដោយហេតុថាក្នុងកាលៈទេសៈនោះ បើសិនជាទុំស្វែងយល់ពីស្ថានការណ៍កំពុងតឹងតែងហើយប្រើសិទ្ធិអំណាចជាមន្ត្រីរាជវាំងក្នុងឋានៈជាម៉ឺនឯកម្ល៉េះសមទុំក៏មិនស្លាប់ដែរ។ តាមពិតព្រះរាជាមិនគាំទ្រអំពើរបស់អរជូនម៉ឺនងួនទេ គឺក្រោយពីទ្រង់ជ្រាបថា អរជូនយកទាវមករៀបការជាមួយម៉ឺនងួនភ្លាម ព្រះអង្គមានព្រះទ័យក្រេវក្រោធយ៉ាងខ្លាំង «ស្តេចទ្រង់សណ្តាប់សព្វវាចា ទ្រង់មានឱង្ការត្រាស់រួសរាន់ អាចោរអរជូនដូចពងមាន់ វាភ័ន្ត ហ៊ានភព្វនឹងម្លប់ពោធិ៍។ មិនដឹងខុសត្រូវស្រូវស្រងៃ អាចោរដូចឆ្កែស៊ីសាច់គោ វាហ៊ានទទឹងទោសត្រូវស្មោរ អញស្រាវរាវរកស្មោរខ្វះដែក»។ ទន្ទឹមនឹងនោះ ទុំមិនបានបង្ហាញរាជសាររបស់ព្រះរាជា និងមិនគោរពតាមបន្ទូលព្រះរាជា ដែលទ្រង់បានផ្តាំមុនពេលចេញដំណើរ។  ដូចព្រះអង្គមានបន្ទូលផ្តាំមុនពេលចេញដំណើរទៅត្បូងឃ្មុំថា «ឯទុំបើបានបន្ទូលទៅ រួសរាន់ឱ្យត្រូវតាមសន្មត បើវាមិនស្តាប់ឯងឆាប់បត់ វិលមកឈប់អត់ឱ្យមើលវា»។ តាមពិតឱកាសរបស់ទុំមានច្រើន  ទុំអាចប្រើរាជសារប្រើបន្ទូល  ឬប្រើឈ្នួតខ្មៅដែលស្តេចបានប្រទានធ្វើជាសញ្ញាប្រាប់ដល់ពួកអរជូន។ ជាក់ស្តែងពេលមកដល់ត្បូងឃ្មុំទុំបានស្លៀកឯកសណ្ឋានជាមន្ត្រីរាជវាំង « ទុំឮ

ពេជ្រប្រាប់ចាប់សំពត់ ហូលព្រៃទាំងផ្ទត់ទុំមើលទៅ យល់ឈ្នួតជាហ៊ុមសូត្រពណ៌ខ្មៅ សំពត់ព្រះថៅប្រោសប្រទាន។ ទុំស្លៀកហូលចាក់ជរបីជាន់ រូបមាន់សូត្រខៀវសយមាសមាន ពាក់អាវបែតងបំណងធ្យាន ឈោងឈានបត់បែរប្រែស្រដី»។ ក្នុងស្ថានភាពនេះទុំពិតជាមានប្រៀបយ៉ាងខ្លាំងទៅលើគូបដិបក្ខរបស់ខ្លួន ប៉ុន្តែគួរឱ្យស្តាយទុំបែរជាបោះបង់ឱកាសនេះបង្កជាទុក្ខដោយខ្លួនឯងទៅវិញ គឺទុំពេលទៅដល់ផ្ទះនាងទាវបែរជាផឹកស្រាដើម្បីបង្កើនសេចក្តីក្លាហាន ជាហេតុធ្វើឱ្យខ្លួនបាត់បង់ភាពម្ចាស់ការរហូតដល់ថ្នាក់ច្រៀង អន្ទងហៅនាងទាវឱ្យចេញមកចាក់ស្រាឱ្យខ្លួនផឹកទៅវិញ។ សមដូចដំណើររឿងបញ្ជាក់ថា «លើផ្ទះសំពះសួរគួរគាប់ មេបាចាស់ផ្ដាប់មិនជួរឆ្មើង ទុំត្រូវស្រាខ្លាំងតាំងចចើង ឫកពារហាក់ថ្កើងដំឡើងគ្រូ»។ ពេលស្រវឹងទុំបានប្រកៀកប្រឱបនាងទាវបង្កបញ្ហា «ទុំខិតជិតជួបរួមត្រកង បីហើយថើបផងថាទាវអញ ទាវអាងទុំប្ដីឥតគិតកាញ់ ខ្លាចគេចាក់បាញ់ចាញ់នរណា។ ទុំថាមាសបងដងស្រាផឹក បងផឹកសឹមក្រោកនាំកល្យាណ៍ កល្យាណទៅក្រុងគាល់មហាក្សត្រាទ្រង់ប្រោសសន្តោសទុក្ខ»។ អំពើបែបនេះ វាហាក់ដូចជាទុំកំពុងចំអកឱ្យអរជូនម៉ឺនងួននិងម្ដាយទាវកាន់តែខ្លាំងឡើង បណ្ដាលឱ្យម្ដាយទាវទ្រាំលែងបានក៏ «ស្រែកថាអរជូនខ្លួនមានបុណ្យ មិនគិតកែកុនឆាប់រហ័ស ចាប់អាទុំចោរចិត្តមានះ ទាញពីលើផ្ទះទម្លាក់ទៅ។ ហៅអស់ពួកក្រុមនាំវាឆាប់ចាក់បាញ់សម្លាប់កុំឱ្យនៅ ធ្ងន់ផ្ទះធ្ងន់ដីអប្រិយត្រូវ កើតកេរអាស្រូវឥតឡូវហើយ»។ គ្រាន់តែចប់ប្រយោគស្ទើរមិនទាន់ផង អរជូននិងបក្សពួកក៏ចាប់ទុំយកទុំទៅសម្លាប់ភ្លាមដោយគ្មានញើតសោះឡើយ។

សរុបសេចក្តីមក ទុំស្លាប់ ពិតជាទុំមិនប្រើបញ្ញាត្រិះរិះប្រាកដមែន។

ជារួមទុំស្លាប់មកពីទុំមានកម្មផងនិងមកពីខ្លួនខ្វះការពិចារណាផង ព្រោះបើទុំមិនប្រព្រឹត្តអ្វីដែលជាកំហុសក្នុងផ្លូវពុទ្ធចក្រនិងអាណាចក្រ ក៏ទុំមិនអាចទទួលកំហុសដោយការសម្លាប់ពីអរជូនដែរ។ មួយវិញទៀតបើទុំមិនទន់ជ្រាយចំពោះស្ថានការណ៍កំពុងកើតមាននោះ ដោយប្រើបញ្ញាត្រិះរិះទុំក៏មិនស្លាប់ដែរ ហើយបើសិនជាសង្គមសម័យកាលនោះមិននិយមប្រើអំណាចផ្ដាច់ការម្ល៉េះទុំក៏មិនស្លាប់ដែរ។ ដូច្នេះ មរណភាពនេះ សម័យកាលសង្គមជាអ្នកទទួលខុសត្រូវ ព្រោះសម័យនោះ មិនទាន់មានច្បាប់ការពារសិទ្ធិមនុស្សឬការការពារជីវិតមនុស្សដូចសម័យកាលនេះទេ។

ឆ្លងតាមការបកស្រាយខាងលើនេះ បង្ហាញថាមតិនីមួយរបស់ៗប្រធានមិនទាន់ត្រឹមត្រូវទាំងស្រុងនោះទេ ព្រោះជាមតិដែលការពារតែគោលជំហរឬជាការគិតឃើញរៀងៗខ្លួនតែប៉ុណ្ណោះ។ តែទោះជាយ៉ាងណាក្ដី ក៏មតិខាងលើបានផ្ដល់ជាបទពិសោធដល់អ្នកសិក្សាអ្នកអានឱ្យចេះពិចារណារាល់ទង្វើរបស់ខ្លួន ជៀសវាងពីដំណោះស្រាយណាមួយឈានទៅដល់ការបាត់បង់ជីវិត។

### គ- ប្រធានប្រៀបធៀប

ប្រធានៈ ចូរអ្នកធ្វើការប្រៀបធៀបរវាងមរណភាពតួអង្គ ប៉ូល វីរហ្សីនី និងតួអង្គទុំទាវ។ តើមានចំណុចដូចគ្នានិងខុសគ្នាត្រង់ណាខ្លះ?

## សេចក្តីអត្ថាធិប្បាយ

តាមច្បាប់ធម្មជាតិ មនុស្សក្នុងលោកគ្មាននរណាម្នាក់មានជីវិតអមតៈឡើយ គឺតែងតែស្លាប់ទៅវិញជាធម្មតាគ្រាន់តែមូលហេតុនៃសេចក្តីស្លាប់នោះខុសៗគ្នា។ ជុំវិញនៃមូលហេតុនៃការស្លាប់នេះ អ្នកនិពន្ធក៏បានបង្ហាញពីមរណភាពរបស់តួអង្គប៉ូល វីរហ្សីនី និងតួអង្គទុំទាវនេះដែរ។

តើមរណភាពតួអង្គទាំងពីរតួនេះមានចំណុចដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

មុននឹងឈានចូលដល់ការប្រៀបធៀបលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នានៃមរណភាពរបស់តួអង្គខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ មរណភាពគឺសំដៅទៅលើការស្លាប់បាត់បង់ជីវិតដែលលាចាកលោកយើងនេះ។ ដូច្នេះតាមគំនិតប្រធានបានតម្រូវឱ្យយើងធ្វើការបង្ហាញពីចំណុចដូច និងចំណុចខុសគ្នារវាងមូហេតុនៃការបាត់បង់ជីវិតរបស់តួអង្គប៉ូលវីរហ្សីនី និងតួអង្គទុំទាវ។

ជាការពិតណាស់បើគេធ្វើការសិក្សាប្រៀបធៀបទៅលើមរណភាពរបស់តួអង្គប៉ូលវីរហ្សីនីនិងតួអង្គទុំទាវនឹងបានឃើញថានៅទីបំផុតនៃសាច់រឿងពួកគេសុទ្ធតែស្លាប់ដូចៗគ្នា។ ជាក់ស្តែងតួអង្គទាំពីគូនេះពិតមានទឹកចិត្តស្រឡាញ់គ្នាយ៉ាងប្តូរផ្តាច់បំផុត។ ទោះជាត្រូវឆ្លងកាត់ឧបសគ្គ មានទំហំប៉ុណ្ណា ក៏ដោយក៏ពួកគេនៅតែតស៊ូរហូតដល់ទីបំផុតដែរ។ ដូចជាប៉ូលនៅពេលដឹងថា ខ្លួនពុំអាចហែលទឹកសមុទ្រទាំងកំពុងមានព្យុះក៏ដោយ ក៏ប៉ូលនៅតែព្យាយាមខិតខំហែលទៅសង្គ្រោះ នាងវីរហ្សីនីដោយយកខ្សែពួរចងចង្កេះខ្លួនទុកឱ្យអ្នកនៅលើគោកចាំទាញខ្លួនត្រឡប់មកវិញ។ ចំណែកនាងវីរហ្សីនីនៅតែរក្សាភក្តីភាពទាំងកាយទាំងចិត្តមិនព្រមដោះសម្លៀកបំពាក់ហែលមករកកោះនោះឡើយ ទោះបីមានកម្មករជាអ្នកធានាជួយសង្គ្រោះខ្លួនក៏ដោយ។ ចំណែកទុំទាវវិញក៏មានសេចក្តីក្លាហានពុះពារគ្រប់ឧបសគ្គដើម្បីសេចក្តីស្នេហារបស់ខ្លួនដែរ។ យ៉ាងនេះហើយទើបអ្នកទាំងពីរសុទ្ធតែហ៊ានប្រឈមមុខចំពោះអំណាចផ្តាច់ការដែលមានម្តាយទាវ អរជូនម៉ឺនងួននិងព្រះរាជាដែរ។ ម្យ៉ាងវិញទៀតឥទ្ធិពលនៃមរណភាពវីរហ្សីនីនិងទុំសុទ្ធតែបានធ្វើឱ្យប៉ូលក្តី ទាវក្តី ដែលហ៊ានធ្វើពលិកម្មទៅតាមមនុស្សដែលខ្លួនស្រឡាញ់នោះថែមទៀតផង។ ជាងនេះទៀតក្រោយពីមរណភាពតួអង្គទាំងប៉ូលវីរហ្សីនីនិងទុំទាវត្រូវបានបញ្ចប់មានមនុស្សជាច្រើន តែងមានអារម្មណ៍នឹកអាណិតអាសូរនិងចងចាំវីរភាពពួកគេជានិច្ច។

សរុបសេចក្តីមកចំណុចខាងលើនេះសុទ្ធសឹងជាចំណុចដូចគ្នារវាងមរណភាពតួអង្គប៉ូលវីរហ្សីនី និងតួអង្គទុំទាវ។

ទោះជាមានចំណុចដូចគ្នាក៏ពិតមែន ក៏មរណភាពអ្នកទាំងពីរនៅតែមានចំណុចខុសគ្នាដែរ។ ជាក់ស្តែងការស្លាប់របស់ប៉ូលវីរហ្សីនី គឺមូលហេតុមកពីសំពៅចេញដំណើរចំរដូវមានព្យុះដោយសារតែបាតុភូតធម្មជាតិ។ ការបាត់បង់ជីវិតខាងលើនេះគឺស្ថិតនៅសតវត្សទីដប់ប្រាំបីនៅលើនាវា «សាំងហេរ្សរង់» កោះអ៊ីលដឺប្រ្វង្សដែលស្ថិតនៅក្រោមការគ្រប់គ្រងប្រទេសបារាំង។ ដូច្នេះ គឺអ្នកទាំពីរត្រូវប្រឈមមុខនឹងព្យុះពុំមានការគាបសង្កត់ណាមួយធ្វើឱ្យពួកគេទាល់ច្រកនោះឡើយ។ ក្រៅពីនេះទៀតការស្លាប់របស់វីរហ្សីនី ក៏កើតចេញពីចំណែកមួយបណ្តាលមកពីជីដូននាងដែលបានកាត់កាល់នាងមិនចែកកេរមរតកឱ្យនាង ហើយថែមទាំងបណ្តេញឱ្យត្រឡប់មកវិញទាំងរដូវកំពុងមានព្យុះសង្ឃរាតែម្តងទៅ។ ស្ថិតក្នុងស្ថានភាពបង្ខំបែបនេះជាគ្រោះថ្នាក់ដ៏ធំបំផុតសម្រាប់នាងនិងសម្រាប់មនុស្សដែលនាងស្រឡាញ់គឺប៉ូលនេះតែម្តង។

ចំពោះមរណភាពទុំទាវវិញ គឺបណ្តាលមកពីអំណាចផ្តាច់ការតាំងពីថ្នាក់កំពូលរហូតដល់ថ្នាក់ក្រោម។ ដោយហេតុថា ក្នុងសម័យកាលនោះ ជាសម័យកាលលង្វែកស្ថិតក្នុងសតវត្សទីដប់ប្រាំមួយពោរពេញទៅដោយទំនៀមទម្លាប់អភិរក្សនិយម។ មានន័យថា យុវជនយើងពុំមានសិទ្ធិសេរីភាពក្នុងការសម្រេចចិត្តជ្រើសរើសស្រករដោយខ្លួនឯងឡើយ។ ហេតុដូច្នេះហើយទើបតាំងពីដើមដល់ចប់ទុំ

ទាវសុទ្ធតែចេញមុខស្រាយបញ្ហាដោយខ្លួនឯង។ ជាក់ស្តែងទុំ និងទាវទោះបីព្រះរាជ មានព្រះទ័យអាណិតអាសូររៀបមង្គលការឱ្យអ្នកទាំងពីរហើយក៏ដោយក៏ពួកគេមិនមានសេចក្តីសុខដែរ។ ទីបំផុតក៏ត្រូវម្តាយទាវ និងអរជូនម៉ឺនងួនព្រមទាំងបក្សពួកយកទុំទៅសម្លាប់ធ្វើឱ្យនាងទាវសម្រេចចិត្តយកសេចក្តីស្លាប់មកដោះស្រាយជាចំណុចចុងក្រោយក្នុងផ្លូវជីវិតនាងទៅវិញ។ មរណភាពនេះត្រូវបានចារឹកទុកក្នុងអារម្មណ៍យុវវ័យ ជាពិសេសក្នុងផ្នត់គំនិតខ្មែរទៀតផង។

សរុបសេចក្តីមកចំណុចខាងលើនេះ សុទ្ធសឹងជាចំណុចខុសគ្នារវាងមរណភាព តួអង្គប៉ូលវីរហ្សិនីនិងតួអង្គទុំទាវ។ រួមសេចក្តីមកទោះបីស្ថានភាពនៃមរណៈភាពរបស់តួអង្គប៉ូលវីរហ្សិនីក្នុងរឿងប៉ូលវីរហ្សិនីនិងតួអង្គទុំទាវក្នុងរឿងទុំទាវមិនដូចគ្នាក៏ពិតមែនតែតួអង្គទាំងពីរគូនេះ ពិតជាមានការប្តូរផ្តាច់នឹងគ្នារហូតដល់ដំណាក់កាលចុងក្រោយដូចគ្នា។

ឆ្លងតាមការប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញថាមរណភាពប៉ូលវីរហ្សិនីនិងទុំទាវសុទ្ធតែមានតម្លៃដូចគ្នា ព្រោះតួអង្គទាំពីរគូនេះសុទ្ធតែមានភាពស្មោះត្រង់និងវីរភាពដ៏អង់អាចមិនរាថយនឹងឧបសគ្គចំពោះមុខឡើយ។ ដូច្នេះ ក្នុងនាមជាអ្នកសិក្សាយើងគប្បីចេះប្រកាន់យកភាពស្មោះត្រង់រវាងគ្នានឹងគ្នាដែលជាគោលការណ៍សំខាន់របស់បុគ្គលនីមួយៗដើម្បីជំរុញឱ្យដំណើរជីវិតរបស់យើងឈានទៅរកសេចក្តីសុខពិតប្រាកដ ។

## ៧.២- រឿងព្រះវេស្សន្តរ

### ក- ប្រធានពន្យល់

---

ប្រធាន: នាងមទ្រីបានធ្វើការប្រៀបធៀបថា «ទន្លេគ្មានទឹក ហៅថាទន្លេអាក្រាត ដែនគ្មានស្តេចហៅថាដែនអាក្រាត ស្រីមេម៉ាយហៅថា ស្រីអាក្រាត»។ តើសម្តីនេះមានន័យដូចម្តេច? ចូរបកស្រាយដោយរកអំណះអំណាងមកបញ្ជាក់។

---

### សេចក្តីអត្ថាធិប្បាយ

បន្ទាប់ពីព្រះវេស្សន្តរត្រូវប្រជារាស្ត្រនិរទេសទ្រង់ឱ្យយាងចេញពីនគររួចមកព្រះនាងមទ្រីក៏ទូលសុំព្រះមាតាព្រះបិតាក្មេកទៅតាមព្រះស្វាមី តែត្រូវព្រះបាទស្រីសញ្ជ័យនិងនាងសុបារសុប្បតីហាមឃាត់ដោយព្រួយព្រះទ័យថានាងមិនអាចទ្រាំទ្រនឹងការលំបាកក្នុងព្រៃនោះបានឡើយ។ ចំពោះបញ្ហានេះ  នាងមទ្រីបានព្យាយាមអង្វរករមាតាបិតាក្មេកដោយបានធ្វើការប្រៀបធៀបថា «ទន្លេគ្មានទឹក ហៅថាទន្លេអាក្រាត ដែនគ្មានស្តេចហៅថាអាក្រាត ស្រីមេម៉ាយហៅថាស្រីអាក្រាត»។

តើសម្តីនេះបានផ្តល់តម្លៃនៃភារៈទាំងបីយ៉ាងណាខ្លះ?

ការបកស្រាយមួយនឹងមានភាពក្បោះក្បាយទៅបាន គឺអាស្រ័យដោយបានធ្វើការស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ ពាក្យថា «អាក្រាត» នៅទីនេះ គឺសំដៅទៅលើភាពគ្មានតម្លៃគ្មានសណ្តាប់ គ្មានកិត្តិយស ឬគ្មានសម្ផស្ស។ រីឯ «ដែន» គឺជានគរ ទឹកដី ប្រទេស ឬភូមិស្រុកជាដើម។ ចំណែក «ស្រីមេម៉ាយ» គឺជាស្រីដែលបាត់បង់ប្តីឬជាស្រីដែលប្តីឃ្លាតឆ្ងាយមិនបាននៅជាមួយគ្នា។ ដូច្នេះគំនិតប្រធានមានន័យថាលម្អឬតម្លៃរបស់ទន្លេ គឺអាស្រ័យដោយមានទឹក តម្លៃនៃនគរឬទឹដីអាស្រ័យដោយមានអ្នកគ្រប់គ្រងឬអ្នកដឹកនាំប្រកាន់ខ្ជាប់ក្នុងការអនុវត្តច្បាប់បានត្រឹមត្រូវ ហើយតម្លៃរបស់ស្ត្រីអាស្រយដោយមានស្វាមីនៅមើលថែរក្សាជួយគាំពារគ្រប់យ៉ាង។

តាមសម្តីនាងមទ្រីបានបង្ហាញអំពីធម្មជាតិនៃអាក្រាតបីយ៉ាងគឺ «ទន្លេគ្មានទឹកហៅថាទន្លេអាក្រាត» ព្រោះទឹកគឺជាសម្រស់ ឬជាលម្អនៃទន្លេឱ្យមានសោភ័ណដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកទស្សនាទេសភាពនានានៅតាមជួរមាត់ទន្លេ។ មានន័យថា ធម្មជាតិនៃទន្លេចាំបាច់ត្រូវតែមានទឹក ព្រោះទឹកបានជាលម្អនៃទន្លេដែលអាចបង្កើតជាទេសភាពទាក់ទាញមនុស្សម្នាឱ្យមកទស្សនាកម្សាន្តដោយក្តីរីករាយបំផុត។ ទឹកទន្លេបានផ្តល់ជាសារប្រយោជន៍ក្នុងវិស័យគមនាគមន៍អាចដឹកជញ្ជូនផលិផលនាំទៅរកទីផ្សារបានយ៉ាងងាយនិងចំណេញទាំងថវិកាទៀតផង។ មិនតែប៉ុណ្ណោះទឹកទន្លេក៏ជាទីជម្រកនៃមច្ឆជាតិគ្រប់ប្រភេទក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃបានយ៉ាងល្អបំផុត។ ដូចជាក្នុងរឿងទុំទាវបានបង្ហាញពីលំអនៃទន្លេតាមរយៈការធ្វើរបស់ទុំទៅត្បូងឃ្មុំនិងទាវទៅលង្វែកជាដើម។ ជាមួយនឹងការធ្វើដំណើរទូកនេះត្រូវបានកវីពណ៌នាពីសម្រស់នៃដងទន្លេងមេគង្គដែលមានមច្ឆជាតិដូចជា «រ៉ស់ឆ្តោកាហោរាជរាហូ ព្រួលប្រាទីពោព្រុយកន្លង់ ដំរីក្អិតក្អីឫស្សីចង្វាត្អៀងរហង់របស់ហែល។ សណ្តាយក្រុសក្រាយឆ្តិនច្រកែង ផ្ទក់ក្រាញ់អណ្តែងច្រើនក្រាស់ក្រែលសរសៃក្រពតផ្សោតប្របែល ផុសផែលផុលផុងក្នុងគង្គា»។ ជាងនេះទៅទៀតទឹកទន្លេ ក៏បានហូរនាំដីល្បាប់ដ៏មានជីជាតិនិងជាទឹកសម្រាប់ស្រោចស្រពផលដំណាំគ្រប់ប្រភេទក្នុងវិស័យកសិកម្មទៀតផង។ ទឹកទន្លេបាននាំមកនូវការពង្រឹងឬលំនឹងបរិស្ថានធម្មជាតិឱ្យមាននិរន្តរភាពទៅលើការបាក់រេចរឹលច្រាំងទន្លេនៃការស្រុតចុះដីជួរតាមមាត់ទន្លេ ព្រមទាំងបានផ្តល់លក្ខខណ្ឌប្រកបចំពោះធនធានបាតទន្លេអាចរីកដុះដាលស្របទៅតាមកាលនិងពេលវេលាណាមួយក្នុងនោះមានរ៉ែមាសឬប្រេងកាតជាដើម។ ជាពិសេសទឹកទន្លេក៏ជាប្រភពឋាមពលវារីអគ្គិសនីនៅតាមតំបន់ទឹកធ្លាក់ឬទឹកហូរដែលមានចរន្តខ្លាំងហើយក៏បានជួយដល់ការប្រើប្រាស់ទឹកនៅក្នុងជីវភាពមនុស្សសត្វរុក្ខជាតិគ្រប់ប្រភេទទៀតផង។

ចំណែកសម្តីមួយឃ្លាតទៀតដែលនាងបានប្រៀនធៀបគឺ «ដែនគ្មានស្តេចហៅថា អាក្រាត» ព្រោះព្រះរាជាឬអ្នកដឹកនាំ គឺជាអ្នកកំណត់ស្ថិរភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយនិមិត្តរូបនៃការបង្រួបបង្រួមជាតិ ឯកភាពជាតិ ផ្សះផ្សាជាតិ ព្រមទាំងជាអ្នកកំណត់លើការអនុវត្តច្បាប់គោរពសិទ្ធិសេរីភាព ប្រជាធិបតេយ្យ។ លើសពីនេះទៀត អ្នដឹកនាំក៏ជាអ្នកទទួលខុសត្រូវលើជោគវាសនាសង្គមជាតិនិងប្រជាពលរដ្ឋ ហើយក៏ជាគំរូក្នុងការចូលរួមគ្រប់សកម្មភាពសង្គមនៃការអភិវឌ្ឍ។ បើគ្មានអ្នកដឹកនាំល្អនោះទេ សង្គមនោះនឹងប្រែក្លាយទៅសង្គមមួយអនាធិបតេយ្យជាមិនខាន គឺគ្មានអ្នកគោរពច្បាប់ធ្វើឱ្យសង្គមរីកររមានសង្គ្រាម មានអតិផរណា ជីវភាពប្រជារាស្ត្រនឹងធ្លាក់ចុះជាមិនខាន។ យ៉ាងនេះហើយទើបក្នុងរឿងព្រះវេស្សន្តរព្រះបាទស្រីសញ្ជ័យដែលជាមហាក្សត្រដ៏ល្អទ្រង់ទទួលយកពាក្យបណ្តឹងរបស់ពួកអ្នកស្រុកស្រីពិរាស្ត្រដែលស្នើសុំឱ្យព្រះវេស្សន្តរយាងចាកចេញពីនគរទៅបួសក្នុងព្រៃដោយសារតែទ្រង់ធ្វើទានដំរីបច្ច័យនាគេន្ទ្រឱ្យទៅពួកព្រាហ្មណ៍នៅកលិង្គរាស្ត្រ។ ចំណុចនេះសបញ្ជាក់ថា ព្រះអង្គជាមេដឹកនាំប្រកបដោយទសពិធរាជធម៌ចំពោះប្រជារាស្ត្រ។បើសិនជាគ្មានក្សត្រក្នុងនគរដ៏ល្អបែបនេះទេម្ល៉េះសមដែននៃនគរនេះនឹងក្លាយទៅជានគរអនាធិបតេយ្យជាមិនខាន។

ជាមួយនោះដែរនាងមទ្រីក៏បានប្រៀបធៀប«ស្រីមេម៉ាយហៅថា ស្រីអាក្រាត» ព្រោះស្ត្រីត្រូវមានស្វាមីដែលមានភក្តីភាពចំពោះខ្លួន ហើយត្រូវការកិត្តិយសឬតម្លៃដែលស្វាមីផ្តល់ឱ្យខ្លួននោះជានិច្ច។ ជាងនេះទៅទៀត ស្ត្រីមានតួនាទីជាអ្នកនៅរក្សាគាំពារផ្គត់ផ្គង់ស្វាមីនិងគ្រួសារទាំងផ្លូវកាយផ្លូវចិត្ត។ ស្របជាមួយនោះ ស្ត្រីក៏ជាអ្នកជួយសម្របសម្រួលរាល់គ្រប់កិច្ចការចំពោះស្វាមីហើយក៏ជា

អ្នកមានឥទ្ធិពលក្នុងការកំណត់សុភមង្គលនឹងជំរុញឱ្យគ្រួសារមានភាពរុងរឿងដែរ។ ដូច្នេះ នាងចាំបាច់ត្រូវមានស្វាមីល្អចំពោះខ្លួនដែរ បើពុំនោះទេគេប្រាកដជាគ្មានតម្លៃសោះឡើយ។ ដូចជាក្នុងដំណើររឿងបានឱ្យឃើញថា ព្រះនាងមទ្រីជាភរិយាដ៏ប្រពៃស្មោះត្រង់ប្តូរផ្តាច់នឹងស្វាមី។ ពេលព្រះវេស្សន្តរត្រូវនិរទេសព្រះបាទស្រីសញ្ជ័យបានអង្វរនាងមិនឱ្យចេញទៅតាមតែព្រះនាងបានបង្ហាញហេតុផលសព្វគ្រប់ថា នាងត្រូវតែទៅ «ព្រះអង្គដូចជាបាដំរីដើរត្រេចក្នុងព្រៃសព្វជ្រោះជ្រលងដងភ្នំផងទាំងពួងឯខ្ញុំម្ចាស់សោតដូចមេដំរីបណ្តើរកូនទាំងពីរតាម...»។ មួយវិញទៀត ការដែលនាងមទ្រីទូលសុំព្រះមាតាព្រះបិតាក្មេកលាចាកចេញទៅតាមព្រះវេស្សន្តរគឺក្នុងន័យរក្សាតម្លៃខ្លួនជាមហេសីដែលត្រូវផ្គត់ផ្គង់ស្វាមីនិងជួយបំពេញកិច្ចការគ្រប់យ៉ាងដើម្បីឱ្យព្រះអង្គបានស្វែរកធម៌និងបំពេញការបរិច្ចាគបានតាមបំណង។ ជាក់ស្តែងព្រះនាង តែងតែចេញទៅបេះផ្លែឈើរៀងរាល់ថ្ងៃជួយបំពេញការភរិយាបរិច្ចាគដល់ស្វាមីទៀតផង។ ទីបំផុតព្រះវេស្សន្តរក៏បានសម្រេចក្នុងការធ្វើទានបារមីខាងលើនេះដែរ។ មានន័យថា ឧត្តមគតិខាងលើនេះ បើគ្មានការចូលរួមឬបើសិនជានាងមទ្រីមិនចេញទៅតាមព្រះវេស្សន្តរទេ ព្រះអង្គក៏មិនបានសម្រេចបារមីខាងលើនេះដែរ ហើយនាងមទ្រីក៏មិនមានតម្លៃឬកិត្តិយសសក្តិសមជាកន្សែសារពេជ្ជក្នុងពុទ្ធនិយមនេះដែរ។ នាងជាមាតាពោរពេញទៅដោយព្រហ្មវិហារធម៌ដែលស្នេហាបុត្រយ៉ាងជ្រាលជ្រៅ ព្រោះពេលមកពីបេះផ្លែឈើវិញមិនឃើញបុត្រ ហើយសួរស្វាមី មិនឆ្លើយព្រះនាងដើររកបុត្រទាំងយប់កណ្តាលទ្រូងព្រៃ លុះត្រាតែដួលសន្លប់។ មិនតែប៉ុណ្ណោះនាងជាអ្នកជួយគាំទ្រឧត្តមគតិព្រះពោធិសត្វជានិច្ច ទោះបីនាងស្រឡាញ់កូនយ៉ាងណាក៏ដោយ ក៏ព្រះនាងនៅតែអនុមោទនាបុត្តបរិច្ចាគនេះដែរ។ នាងជាស្ត្រីគ្រប់លក្ខណ៍សក្តិសមជាឧត្តមភរិយានៃព្រះពោធិសត្វ។

សរុបសេចក្តីមក តាមហេតុផលដូចខាងលើនេះហើយដែលបញ្ជាក់ថាលម្អរបស់ទន្លេ គឺពិតជាស្ថិតនៅលើទឹកដែលទ្រទ្រង់ទន្លេឱ្យមានសម្ផស្សនិងតម្លៃ។ ចំណែកទឹកដី ឬនគរដែលមានសណ្តាប់ធ្នាប់ល្អគឺពិតជាស្ថិតនៅលើអ្នកគ្រប់គ្រងដឹកនាំល្អ ហើយតម្លៃស្ត្រីពិតជាស្ថិតនៅលើស្វាមីល្អប្រាកដមែន។

ឆ្លងតាមការបកស្រាយទស្សនៈខាងលើនេះ បានបង្ហាញថាប្រធានបង្កប់អត្ថន័យអប់រំយ៉ាងសំខាន់ ដែលបានផ្សារភ្ជាប់ទៅនឹងលក្ខណៈជាតិខ្មែរពិតៗ។ មិនតែប៉ុណ្ណោះទស្សនៈនេះ ក៏បានអប់រំបណ្តុះស្មារតីកូនខ្មែរគ្រប់រូបឱ្យចេះស្រឡាញ់និងថែរក្សាមរតកវប្បធម៌ជាតិឱ្យគង់វង្សតរៀងទៅ។

## ខ- ប្រធានពិភាក្សា

ប្រធាន: មតិខ្លះយល់ថា «ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយ អត្តទត្តភាព»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងរឿងព្រះវេស្សន្តរមកបញ្ជាក់។

### សេចក្តីអន្តាធិប្បាយ

ក្នុងរឿងព្រះវេស្សន្តរបានបង្ហាញពីការធ្វើទាន ដ៏អស្ចារ្យរបស់ព្រះពោធិសត្វនៅជាតិទីដប់គឺទ្រង់ធ្វើទានទាំងគ្មានវិញ្ញាណនិងទាំងទានមានវិញ្ញាណដើម្បីបានត្រាស់ដឹងដោយឥតស្តាយស្រណោះអ្វីឡើយ។ ដោយសង្កេតឃើញពីឥរិយាបថនៃការធ្វើទានរបស់ព្រះពោធិសត្វដូចខាងលើនេះហើយ ទើបនាំឱ្យមានមតិខ្លះយល់ថា «ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយអត្តទត្តភាព»។

តើមតិខាងលើនេះត្រឹមត្រូវឬទេ ?

ជាជំនួយដល់ការវែកញែកមតិប្រធានខាងលើឱ្យកាន់តែក្បោះក្បាយថែមទៀត យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ពាក្យថា «ទាន» នៅពេលនេះ គឺសំដៅទៅលើអំណោយ ឬការឱ្យអ្វីមួយទៅស្មូមយាចកណាម្នាក់។ ចំណែក «អត្តទត្ថភាព» ជាភាពដែលគិតតែពីផលប្រយោជន៍បុគ្គលខ្លួនឯងជាធំ។ ដូច្នេះតាមមតិប្រធានខាងលើមានន័យថា ការធ្វើអំណោយរបស់តួអង្គព្រះវេស្សន្តរជាការធ្វើអំណោយដោយការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនជាធំលើសអ្វីៗទាំងអស់។

ជាការពិតណាស់ បើយើងធ្វើការសិក្សាពីការធ្វើទានរបស់ព្រះវេស្សន្តរក្នុងជាតិទីដប់នេះពិតជាបានឃើញថាការធ្វើទានរបស់ព្រះអង្គប្រព្រឹត្តទៅនេះមានអត្តទត្ថភាពគឺមានច្រើនបែបច្រើនយ៉ាង។ ចំពោះការធ្វើទាននោះ គេឃើញមានទាំងរបស់គ្មានវិញ្ញាណនិងទាំងមានវិញ្ញាណ។ ជាក់ស្តែងព្រះអង្គបានធ្វើការបរិច្ចាគដំរីបច្ច័យនាគេន្ទ្រឱ្យជាទានដល់ព្រាហ្មណ៍ដែលជាដំរីតំណាងឱ្យភាពសម្បូរសប្បាយរបស់ព្រះនគរ ក៏ទ្រង់ហ៊ានធ្វើដោយពុំមានការឆ្លងយោបល់ពីប្រជានុរាស្ត្រក្នុងនគរទ្រង់ឡើយ។ ទង្វើបែបនេះហាក់ដូចជាប្រមាថចំពោះប្រជារាស្ត្របណ្តាលជាហេតុនាំឱ្យអ្នកស្រុកស្រីពិរាស្ត្រនាំគ្នាមកស្នើសុំឱ្យព្រះបាទស្រីសញ្ជ័យឱ្យបំបរបង់ព្រះវេស្សន្តរចេញពីនគរ ដើម្បីជាការព្រមានក្នុងការសម្រេចព្រះទ័យដាក់ទានបែបនេះ។ រីឯការធ្វើសត្តសតកមហាទានដែលជាទានដ៏អស្ចារ្យនោះវិញ ក៏ព្រះអង្គក៏ធ្វើឡើងដើម្បីតែទ្រង់ដែរ ព្រោះនៅមុនពេលយាងចេញពីនគរឆ្ពោះទៅគិរីវង្កត ព្រះអង្គបានធ្វើការបរិច្ចាគដ៏ធំមួយដែលពុំធ្លាប់មានសោះឡើយ លើលោកយើងនេះ គឺជាទានដែលមួយមុខៗមានចំនួនប្រាំពីររយសរុបចំនួនសែសិបប្រាំបួនមុខ។ នេះគឺជាធនបរិច្ចាគដែលជាទ្រព្យសម្បត្តិរបស់ព្រះនគរត្រូវចំណាយអស់ទ្រព្យយ៉ាងច្រើនជាងគេ។ ចំពោះបុត្តបរិច្ចាគវិញ ព្រះវេស្សន្តរក៏ហ៊ានលះបង់ដោយឥតស្តាយស្រណោះដែរគឺហ៊ានលះបង់កូនជាទីស្រឡាញ់ឱ្យទៅជូជកព្រាហ្មណ៍ដ៏កំណាច ដែលបានវាយដំរាជកុមារទាំងពីរនៅចំពោះព្រះភក្ត្រទ្រង់ ក៏ទ្រង់បែរជាអង្វរកររាជបុត្រទាំងបង្ខំឱ្យទៅតាមជូជកទាល់តែបាន។ ក្នុងករណីនេះព្រះអង្គហាក់ដូចជាបាត់បង់ព្រហ្មវិហារធម៌ចំពោះបុត្រឱ្យតែបានសម្រេចតាមបំណងទ្រង់ក្នុងការត្រាស់ដឹងព្រះអង្គហ៊ានធ្វើទាំងអស់។ ជាងនេះទៅទៀត ព្រះអង្គបានក៏បានកុហកនាងមទ្រីក្នុងការធ្វើបុត្តបរិច្ចាគពេលនាងមកពីបេះផ្លែឈើវិញរករាជកុមារទាំងពីរពុំឃើញ។ ព្រះអង្គក៏បង្វែរចោទប្រកាន់ទៅនាងមទ្រីថា ទៅសហាយស្មន់ទើបមកដល់អាស្រមទាំងយប់បែបនេះទៅវិញ។ ព្រះអង្គយកនាងដែលជាមហេសីពេញច្បាប់និងដ៏ល្អទៅធ្វើជាអ្នកបម្រើឥន្ទព្រាហ្មណ៍ទោះបីព្រះនាងបានជួយទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាបុត្រាបុត្រី និងតស៊ូទ្រាំទ្រការលំបាកជាមួយទ្រង់យ៉ាងណាក៏ទ្រង់នៅតែដាច់ចិត្តដោយយកប្រើមនោសញ្ចេតនាជាប្តីប្រពន្ធមកបំពេញតាសំណូមពរទ្រង់ទៅវិញ។

សរុបមក ការធ្វើទានរបស់ព្រះវេស្សន្តរគឺពិតជាការដាក់ទានដោយអត្តទត្ថភាពប្រាកដមែន។

ផ្ទុយទៅវិញការធ្វើទានរបស់ព្រះវេស្សន្តរ មិនមែនជាការដាក់ទានដោយអត្តទត្ថភាពនោះទេ ព្រោះការលះបង់របស់ព្រះអង្គក្នុងបំណងជួយស្រោចស្រង់ជីវិតមនុស្សឱ្យរួចផុតពីអវិជ្ជា។ ចំពោះអត្ថន័យនៃការធ្វើទាននេះព្រះវេស្សន្តរមានបំណងស្វែងរកធម៌ ហើយត្រាស់ដឹងក្នុងជួយដល់មនុស្សសត្វទាំងឡាយឱ្យយល់ពីជីវិតឆ្លងផុតអវិជ្ជាបញ្ជាក់ថាតណ្ហាជាមូលហេតុនៃទុក្ខ។ ដូចករណីអ្នកស្រុកស្រីពិរាស្ត្រដោយមូលហេតុនៃសេចក្តីវង្វេងដោយតណ្ហានេះហើយទើបចង់រស់តែឯងមិនគិតពី

ភាពក្រខ្សត់របស់អ្នកស្រុកកលិង្គរាស្ត្រ ដែលកំពុងប្រឈមនឹងភាពខ្វះខាត។ ហេតុដូច្នេះហើយបាន ជាពិភពលោកទាំងមូលតែងតែបង្កើនចំណងសហការគ្នារួមគ្នាចែករំលែកបទពិសោធអំណោយជា ស្បៀងអាហារក្នុងផ្លូវមនុស្សធម៌ដើម្បីរស់ក្នុងសន្តិភាព។ ម្យ៉ាងទៀត ទ្រង់ស្វែងរកធម៌ដែលជាមូល ហេតុនៃទុក្ខក្នុងនោះមានចតុរារិយសច្ចៈឬអរិយសច្ចៈបួន ដែលមានទុក្ខអរិយសច្ចៈសមុទយអរិយ សច្ចៈ និរោធអរិយសច្ចៈ និងមគ្គអរិយសច្ចៈជួយជាប្រយោជន៍ដល់សង្គមមនុស្ស។ ចំណែកការធ្វើ ទានរបស់ព្រះអង្គវិញជាការធ្វើទាន ដោយសុទ្ធចិត្តឥតបង្ខំ ធនបរិច្ចាគ បុត្តបរិច្ចាគ និងភរិយាបរិច្ចាគ ក្តី។ តួយ៉ាងការធ្វើធនបរិច្ចាគ ក្រោយពីបិតាបានប្រទានទ្រព្យធនទាំងនោះ គឺមុនពេលព្រះអង្គយាង ចូលព្រៃគិរីវង្កត ព្រោះអង្គមិនចង់បានអ្វីក្រៅពីការស្វែងរកធម៌តែប៉ុណ្ណោះ។ ហេតុនេះហើយបាន ជា ព្រះអង្គដាក់ទានទាល់តែអស់ហើយសុខចិត្តយាងចេញទៅដោយថ្មើរជើង។ ការធ្វើបុត្តបរិច្ចាគក៏ សុទ្ធតែជាការស្ម័គ្រចិត្តដាក់ខ្លួនជាទាន ព្រោះនៅចំពោះមុខព្រះបាទស្រីសញ្ជ័យ ព្រះនាងសុបារ សុប្បតី សេនាបតី និងរាជអាមាត្យ ជាលី និងក្រស្នាសុទ្ធតែអះអាងថាខ្លួនមកតាមជូជក គឺបិតាឥត បានបង្ខំទេរាជកុមារមកដោយការពេញព្រះទ័យ។ ការធ្វើភរិយាបរិច្ចាគជាការពេញចិត្ត ព្រោះនាង មទ្រី បានថ្លែងនៅចំពោះព្រះភក្ត្រព្រះវេស្សន្តរ និងឥន្ទព្រាហ្មណ៍ថាកុំថា ឡើយដាក់ទានរូបកាយ ទោះបីព្រាហ្មណ៍នោះប្រាថ្នាសាច់ ថ្លើម ដង្ហើម ប្រមាត់ក៏ព្រះនាងយល់ព្រមឱ្យព្រះអង្គយកព្រះខ័ន មកកាត់ ដើម្បី បំពេញទានបារមីនោះដែរ។

សរុបមកការធ្វើទានរបស់ព្រះវេស្សន្តរ មិនមែនជាការដាក់ទានដោយអត្តទត្ថភាពនោះទេ ដើម្បីប្រយោជន៍មនុស្សទូទៅពិតប្រាកដ។

ជារួមការយល់ឃើញថា ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយអត្តទត្ថភាពមិន ត្រឹមត្រូវទេ ព្រោះព្រះអង្គលះបង់អ្វីៗគ្រប់យ៉ាងក៏ដើម្បីប្រយោជន៍មនុស្សទូទៅ។ ការលះបង់បែប នេះពិតជាកម្រនិងពិបាកក្នុងការលះបង់ តែជាគំរូដល់មនុស្សផងទាំងឡាយឱ្យចេះអត់ធ្មត់ដោយការ បំពេញទាន ចេះអធ្យាស្រ័យ មិនប្រើស្ថិតនៅក្រោមលោភៈ ទោសៈ មោហៈ ដែលនាំទៅរកទុក្ខនោះ ឡើយ។ ម្យ៉ាងវិញទៀតទង្វើទ្រង់បែបនេះហើយដែលបច្ចុប្បន្នត្រូវបានគេយកមកអនុវត្តក្នុងផ្លូវ មនុស្សធម៌ទូទាំងសកលលោកទៀតផង។

ឆ្លងតាមការបកស្រាយខាងលើនេះបង្ហាញថាមតិប្រធានមិនត្រឹមត្រូវទេ ជាគំនិតចង្អៀតចង្អល់ មិនយល់ច្បាស់ពីឧត្តមគតិ និងទ្រឹស្តីសាសនាព្រះពុទ្ធពិតប្រាកដ។តែទោះជាយ៉ាងណាក៏ដោយ ក៏ម តិនេះចាត់ទុកជាបទពិសោធក្នុងការអប់រំ អ្នកអានឱ្យយល់កាន់តែច្បាស់ពីគោលបំណងនៃតួអង្គព្រះ វេស្សន្តរដែលជាពោធិសត្វក្នុងទសជាតកនេះពិតប្រាកដ។

### គ- ប្រធានប្រៀបធៀប

ប្រធានៈ ចូរអ្នកធ្វើការប្រៀបធៀបលក្ខណសម្បត្តិនាងសីតាក្នុងរឿងរាមកេរ្តិ៍ និងលក្ខណសម្បត្តិ នាងមទ្រីក្នុងរឿងព្រះវេស្សន្តរ។ តើនារីទាំងពីរនេះមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាង ណាខ្លះ?

### គម្រោងតែង

បើតាមលក្ខណៈជាតិខ្មែរ នារីគឺជាកត្តាចម្បងដែលជំរុញឱ្យសង្គម គ្រួសារមានសុភមង្គលផង និងអពមង្គលផង។ ចំពោះភាពចាំបាច់នៃលក្ខណសម្បត្តិរបស់ស្ត្រីនេះត្រូវបានកវីនិពន្ធយើងលើក

យកមកឆ្លុះបញ្ចាំងតាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរដែរគឺនាងសីតាក្នុងរឿងរាមកេរ្តិ៍ និងនាងមទ្រីក្នុងរឿងព្រះវេស្សន្តរ។

តើនារីទាំងពីររូបខាងលើនេះ មានលក្ខណៈសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

ដើម្បីធ្វើជំរុញឱ្យការប្រៀបធៀបនៃលក្ខណសម្បត្តិរបស់តួអង្គទាំងពីរខាងលើនេះកាន់តែមានភាពក្បោះក្បាយថែមទៀតនោះ យើងគប្បីស្វែងយល់ន័យរបស់ពាក្យ«លក្ខណសម្បត្តិ»ជាមុនសិន។ ពាក្យថា «លក្ខណសម្បត្តិ»គឺសំដៅទៅលើចរិតលក្ខណៈគ្រប់យ៉ាងរបស់តួអង្គឬរបស់មនុស្សដែលស្ដែងចេញតាមរយៈសកម្មភាព អាកប្បកិរិយាជាដើម។ ដូច្នេះតាមគំនិតប្រធានខាងលើបានតម្រូវឱ្យធ្វើការប្រៀបធៀបរវាងចំណុចដូចគ្នានិងចំណុចខុសគ្នានៃចរិតលក្ខណៈរបស់នាងសីតាជាមហេសីព្រះរាម និងនាងមទ្រីជាមហេសីរបស់ព្រះវេស្សន្តរ។

ជាការពិត ធម្មជាតិបានតាក់តែងជីវិតសត្វលោក តែងមានរូបរាង លក្ខណៈស្រដៀង ឬដូចគ្នានៃឬខុសគ្នាដោយជៀសមិនផុតឡើយ។ រីឯនាងសីតាក្ដី នាងមទ្រីក្ដី សុទ្ធតែមានលក្ខណសម្បត្តិដូចគ្នាឬស្រដៀងគ្នាផងនិងខុគ្នាផង។ ចំពោះលក្ខណៈស្រដៀងឬដូចគ្នានេះ បានបង្ហាញឱ្យឃើញពីរូបសម្បត្តិនារីទាំងពីរសក្ដិសមដូចគ្នា។ ដោយហេតុថា នាងសីតាជាកំពូលនារីល្អឯក ដែលធ្វើឱ្យទេវៈក្នុងឋានទាំងបីបានចូលរួមប្រឡងលើកធ្នូសិល្ប៍ដើម្បីយកនាងធ្វើជាមហេសី។ សមដូចកវីយើងបានអះអាងថា «មហេសី កាលនោះអស់ទេពក្សត្រផង សឹងចូលលើកលង កម្លាំងទីទៃសព្វប្រាណ»។ ចំណែកក្រុងរាពណ៍ ក៏បាន អួតសរសើរលម្អសីតានេះដែរថា «យល់អញមហាភ័ព្វ មហាបុណ្យបានយល់អង្គធ្វើម្ដេចកល់ភ្នែកគិតដ៏យង់មួយសែនសោតនឹងមើលគ្រាន់។ ធ្វើម្ដេចភុលឱស្ន ភុល[1] អណ្ដាតបានមួយសែនពាន់ បងនឹងសរសើរមេរូចន្ទ្រដ៏ប្រាលច្រៃនៃវេហាស៍»។ ចំណែកនាងមទ្រីវិញក៏ជានារីល្អឯកក្នុងពុទ្ធនិយមដែរ គឺព្រះនាងជាកន្សែស្សារពេជ្ជជាគូនឹងព្រះពោធិសត្វ អន្ទោលគ្រប់ជាតិ។ មិនតែប៉ុណ្ណោះ នារីទាំងពីរមានទឹកចិត្តភក្ដីដូចគ្នាចំពោះស្វាមីរៀងៗខ្លួន។ ដោយឡែកនាងសីតា នៅពេលដែលក្រុងរាពណ៍ចាប់នាងសីតាយកទៅលង្កាតែនាងនៅតែរក្សាភាពបរិសុទ្ធនិងពេលដែលព្រះរាមចេញទៅសាងផ្នួសក្នុងព្រៃដប់បួនឆ្នាំនាងក៏ស្ម័គ្រចិត្តយាងចេញទៅតាមព្រះអង្គដែរ ដោយមិនគិតពីរាជ្យបល្ល័ង្កឡើយ។ ចំពោះនាងមទ្រីវិញ ពេលព្រះវេស្សន្តរត្រូវពួកអ្នកស្រុកស្រីពិរាស្ត្រសុំបំបរបង់ឱ្យព្រះអង្គចូលព្រៃគិរីវង្កត ដោយសារតែទ្រង់ដាក់ទានដំរីបច្ច័យនាគេន្ទ្រឱ្យទៅពួកព្រាហ្មណ៍នៅកលិង្គរាស្ត្រនោះ ក៏នាងមទ្រីពេញចិត្តចេញពីនគរទៅតាមព្រះវេស្សន្តរដែរ។ ការចេញដំណើរនេះត្រូវបានព្រះនាងសុបារសុប្បតីឃាត់នាង តែនាងនៅតែព្យាយាមខិតខំទូលថ្វាយអំពី មូលហេតុបីយ៉ាង ដែលត្រូវចេញទៅតាមស្វាមីនោះថា «ទន្លេគ្មានទឹកហៅថាទន្លេអាក្រាត ដែនគ្មានស្ដេច ហៅថាដែនអាក្រាត ស្ដីមេម៉ាយហៅថាស្រីអាក្រាត»។ តាមហេតុផលនេះហើយ ដែលធ្វើឱ្យព្រះនាងសុបារសុប្បតីយល់ព្រមតាមសំណើរបស់នាងក្នុងនាមជាមហេសីល្អ និងភក្ដីភាពនោះ។

សរុបសេចក្ដីមកចំណុចខាងលើនេះ ជាលក្ខណៈដូចគ្នានៃលក្ខណសម្បត្តិនាងសីតាក្នុងរឿងរាមកេរ្តិ៍ និងនាងមទ្រីក្នុងរឿងព្រះវេស្សន្តរ។

រីឯចំណុចខុសគ្នានៃលក្ខណសម្បត្តិនាងសីតានិងនាងមទ្រីនោះ គឺស្ថិតនៅត្រង់នាងសីតាស្ថិតក្នុងព្រាហ្មណ៍និយម គឺជានារីល្អឯកតាមលទ្ធិព្រាហ្មណ៍ គឺត្រូវជួយបំពេញកាតព្វកិច្ចចំពោះអវតារ

1 ភុល (ន.) ស្ងួរព្ទដោយបក្សីស្ទុះហើរព្រមគ្នា ឬស្ងួរទឹកខ្ពុរចេញជាដើម ។

របស់ព្រះវិស្ណុ គឺព្រះរាម។នាងសីតាត្រូវបានព្រះរាមសព្វព្រះទ័យយកនាងធ្វើជាមហេសីដោយសមត្ថភាពក្នុងការប្រឡងលើកធ្នូសិល្ប៍ឈ្នះអស់ទេវៈក្នុងឋានទាំងបី។ ជីវិតក្នុងគ្រួសារវិញ ព្រះនាងជាមាតាដ៏ល្អ ដែលបានចិញ្ចឹមបីបាច់រាជបុត្រមួយអង្គដ៏ខ្លាំងពូកែ គឺរាមលក្សណ៍ ទោះបីព្រះនាងរស់នៅក្នុងព្រៃយ៉ាណាក៏ដោយ។ នាងជានារី ពោរពេញទៅដោយឆន្ទៈស្មោះត្រង់ ម៉ឺងម៉ាត់ ប្តេជ្ញាចិត្តខ្ពស់និងមានការទទួលខុសត្រូវ។ ដូចជានាងបានប្រកាន់យកពាក្យសត្យនៅចំពោះមុខនឹងការប្រច័ណ្ឌរបស់ព្រះរាម ដែលយកនាងទៅសម្លាប់ទាំងមានគតិនោះថា លុះត្រាតែព្រះរាមសុគត ទើបនាងវិលចូលនគរវិញ។ ដោយសារតែការតាំងចិត្តនេះហើយ ទើបធ្វើឱ្យនាងសីតាត្រូវចាកចេញពីព្រះរាមជារៀងរហូត ទោះបីនាងស្រឡាញ់ព្រះរាមក៏ដោយ។

ចំពោះនាងមទ្រីវិញ នាងក៏ជានារីស្រស់ស្អាតតាមបែបពុទ្ធនិយមដែរ គឺកន្សៀសារពេជ្ជជាអ្នកជួយបំពេញបារមីដល់ព្រះវេស្សន្តរក្នុងជាតិទីដប់។ នាងស្លូតបូតនិងទន់ភ្លន់ចេះជួយដោះស្រាយបញ្ហាគ្រប់យ៉ាង តាំងពីជីវភាពប្រចាំថ្ងៃ។ នាងតែងតែបេះផ្លែឈើ ជីកមើមឈើ យកមកផ្គត់ផ្គង់ស្វាមីនិងបុត្រាបុត្រីនៅអាស្រមមិនដែលខកខាន។ ចំពោះលក្ខណសម្បត្តិដ៏ប្រសើរមួយទៀតនោះ គឺការជួយបំពេញទានបារមីរបស់ស្វាមីក្នុងជាតិទីដប់នេះ។ ដូចជានាងបេះផ្លែឈើ ជីកមើមឈើយកមកផ្គត់ផ្គង់ដល់ស្វាមី និងរាជបុត្រទាំងពីរនៅអាស្រម។ នាងបានឆ្លងកាត់ការលំបាកជាច្រើន តែនាងនៅតែតស៊ូ ដូចករណីជាពិសេសនាងមានព្រះទ័យមេត្តាគោរពតាមព្រះរាជបំណងព្រះស្វាមីជានិច្ចទោះជាធ្វើបុត្តបរិច្ចាគឬភរិយាបច្ចាគក្តីក៏នាងមទ្រីមិនរួញរាដែរ។ បើសិនជានាងមទ្រី មិនចេញទៅតាមព្រះវេស្សន្តរទេ ព្រះអង្គក៏មិនបានសម្រេចបារមីខាងលើនេះដែរ ហើយនាងមទ្រីក៏មិនមានតម្លៃឬកិត្តិយសសក្តិសមជាកន្សៀសារពេជ្ជ[2] ក្នុងពុទ្ធនិយមនេះដែរ។ នាងជាមាតាពោរពេញទៅដោយព្រហ្មវិហារធម៌ដែលស្នេហាបុត្រយ៉ាងជ្រាលជ្រៅ ព្រោះពេលមកពីបេះផ្លែឈើវិញមិនឃើញបុត្រហើយសួរស្វាមី មិនឆ្លើយព្រះនាងដើររកបុត្រទាំងយប់កណ្តាលទ្រូងព្រៃ លុះត្រាតែដួលសន្លប់។ មិនតែប៉ុណ្ណោះនាងជាអ្នកជួយគាំទ្រឧត្តមគតិព្រះពោធិសត្វជានិច្ច ទោះបីនាងស្រឡាញ់កូនយ៉ាងណាក៏ដោយក៏ព្រះនាងនៅតែអនុមោទនាបុត្តបរិច្ចាគនេះដែរ។ នាងជាស្ត្រីគ្រប់លក្ខណ៍សក្តិសមជាឧត្តមភរិយានៃព្រះពោធិសត្វ។ ដោយសារតែលក្ខណសម្បត្តិរបស់នាងមទ្រី ដូចខាងលើនេះហើយដែលជំរុញឱ្យព្រះវេស្សន្តរបានសម្រេចក្នុងការស្វែងរកធម៌ព្រមទាំងបានវិលចូលនគរវិញ។

សរុបសេចក្តីមកចំណុចខាងលើនេះ ជាលក្ខណៈខុសគ្នានៃលក្ខណសម្បត្តិនាងសីតាក្នុងរឿងរាមកេរ្តិ៍ និងនាងមទ្រីក្នុងរឿងព្រះវេស្សន្តរ។

រួមសេចក្តីមក ភស្តុតាងខាងលើនេះ ជាចំណុចដូចគ្នានិងចំណុចខុសគ្នារវាងលក្ខណសម្បត្តិនាងសីតានិងនាងមទ្រី។ តួអង្គទាំងពីរនេះសុទ្ធសឹងជាតួអង្គតំណាងឱ្យស្ត្រីខ្មែរគ្រប់រូបដែលពោរពេញភក្តីភាពចំពោះស្វាមី ទោះបីនារីទាំងពីរនេះស្ថិតក្នុងចលនាអក្សរសិល្ប៍ផ្សេងពីគ្នាយ៉ាងណាក្តី។

ឆ្លងតាមការប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញថា ទាំងនាងមទ្រីក្តី និងទាំងនាងសីតាក្តីសុទ្ធតែមានលក្ខណសម្បត្តិល្អប្រសើរដូចគ្នា ព្រោះអ្នកទាំងពីរគឺជាតួអង្គពោរពេញទៅដោយឧត្តមគតិក្នុងការលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីសម្រេចឬគាំទ្របំណងស្វាមីដូចៗគ្នា។ ជាមួយគ្នានេះ

[2] សារពេជ្ជ ឬសព៌េជ្ញ ស័រ-ពេច់ សំ. បា. ( ន. ) (សវ៌ជ្ញ ខ្មែរប្រើ វ > ព = សព៌ជ្ញ; សព្វញ្ញូ) លោកអ្នកត្រាស់ដឹងសព្វ (ព្រះសព្វញ្ញូ) : ព្រះស្រីសព៌េជ្ញ ព្រះសព្វញ្ញូមានស្រីសួស្តី (ព. កា. ប្រើក្លាយឃ្លាតជា សរពេជ្ញ ឬ សារពេជ្ញ ក៏មាន; ប្រើជា សព៌ជ្ញ ត្រឹមត្រូវជាង) ។ សព៌េជ្ញតាញាណ (ស័រ-ពេច់-ជៈដាញាន; សំ. សវ៌ជ្ញតា + ជ្ញាន; បា. សព្វញ្ញុតញ្ញាណ) ញាណឬប្រាជ្ញាដែលដឹងសព្វ (ញាណរបស់ព្រះសព្វញ្ញុពុទ្ធ)។

ដែរ លក្ខណសម្បត្តិនៃនារីទាំងពីរនេះ គឺជាការឆ្លុះបញ្ចាំងអំពីតម្លៃនារីខ្មែរក្នុងការគ្រប់គ្រងគ្រួសារ ឬលើកតម្លៃគ្រួសារគ្រប់កាលៈទេសៈឱ្យឆ្ពោះទៅរកឧត្តមភាពនិងសុភមង្គលពិតប្រាកដ។

## ៧.៣- រឿងរាមកេរ្តិ៍

### ក- ប្រធានពន្យល់

ប្រធានៈ ទស្សនៈមួយលើកឡើងថា «ការទទួលយកពាក្យសត្យរបស់នាងកៃកេសី ជាពលិកម្មដ៏ឧត្តុង្គឧត្តមបំផុតរបស់ព្រះរាម»។ ចូរពន្យល់ ដោយរកឧទាហរណ៍ក្នុងរឿងរាមកេរ្តិ៍មកបញ្ជាក់។

**សេចក្តីអធិប្បាយ**

ក្នុងរឿងរាមកេរ្តិ៍ខ្មែរ បានបង្ហាញពីទំនាស់ដ៏តឹងតែងមួយនៅដើមខ្សែនៃរឿង រវាងនាងកៃកេសី និងព្រះបាទទសរថតម្រូវឱ្យគោរពពាក្យសត្យ គឺឱ្យព្រះភិរុតជាកូនប្អូន សោយរាជ្យមុនព្រះរាមជាកូនច្បងដែលផ្ទុយពីប្រពៃណីក្សត្រ។ ទីបំផុតព្រះរាម ក៏សម្រេចចិត្តយាងចេញពីនគរចំនួនដប់បួនឆ្នាំទៅបួសក្នុងព្រៃតាមសំណូមពរនាងកៃកេសីដើម្បីបញ្ចប់ទំនាស់។ ដោយមើលឃើញពីឥរិយាបថព្រះរាមដូចខាងលើនេះហើយ ទើបមានទស្សនៈមួយលើកឡើងថា«ការទទួលយកពាក្យសត្យរបស់នាងកៃកេសី ជាពលិកម្មដ៏ឧត្តុង្គឧត្តមបំផុតរបស់ព្រះរាម»។

តើពលិកម្មនោះ ស្ថិតនៅលើចំណុចណាខ្លះ?

ដើម្បីជាគុណប្រយោជន៍ដល់ការបកស្រាយគំនិតប្រធានខាងលើនេះឱ្យកាន់តែក្បោះក្បាយថែមទៀត យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ «ពាក្យសត្យ» នៅពេលនេះគឺសំដៅទៅលើពាក្យសន្យាឬពាក្យពិតដែលគេបានប្រកាសរួចហើយអំពីគោលបំណងណាមួយរបស់ខ្លួននៅចំពោះមុខវត្ថុសក្តិសិទ្ធិឬទីអារាមណាមួយ។ រីឯ «ពលិកម្ម» មានន័យថា ជាការបូជាឬមួយជាការលះបង់ទាំងកាយទាំងចិត្តទាំងអាយុជីវិតដើម្បីបុព្វហេតុអ្វីមួយដែលជាប្រយោជន៍ក្នុងគ្រួសារឬសង្គមជាតិក្តី។ ចំណែកពាក្យ «ឧត្តុង្គឧត្តម» ជាភាពប្រសើររុងរឿងថ្លៃថ្លាដែលពុំអាចកាត់ថ្លៃបាន។ ដូច្នេះ តាមគំនិតប្រធានខាងលើមានន័យថា ការទទួលយកពាក្យសន្យារបស់នាងកៃកេសីក្នុងការចាកចេញពីនគរចំនួនដប់បួនឆ្នាំគឺជាការលះបង់ដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះរាមក្នុងរឿងរាមកេរ្តិ៍ខ្មែរ។

ជាការពិតណាស់ បើគេធ្វើការសិក្សាទៅលើផ្ទៃរឿងទាំងមូលប្រាកដជាបានឃើញថា នៅដើមខ្សែនៃរឿងនេះ មានបញ្ហាទំនាស់ក្នុងរាជវង្សបានកើតឡើង ជុំវិញប្រពៃណីក្សត្រ និងពាក្យសត្យរវាងព្រះបាទទសរថនិងនាងកៃកេសី។ ដោយទ្រង់បានសន្យាជាមួយនាងកៃកេសីថានឹងឱ្យព្រះភិរុតជាបុត្ររបស់នាងឡើងសោយរាជ្យ បើច្បាំងឈ្នះព្រះអាទិត្យ។ សមដូចព្រះនាងកៃកេសីបានលើកអះអាង « ថាបពិត្រនាធមិសត្យមត់កាលស្តេចចេញផ្ចត់ សង្គ្រាមសំដែងចេស្តា។ ច្បាំងឈ្នះព្រះអាទិត្យសុរិយា ស្តេចបានប្តេជ្ញា ពាក្យសត្យនឹងអញខ្ញុំហោង។ ថានូវឱ្យរាជ្យព្រះភិរុតគ្រងសោយរាជ្យសម្បត្តិស្នង ព្រះបាទសម្តេចរាជា។ ឥឡូវខ្វៃឱ្យព្រះរាមា យល់ឥតសត្យពុំទៀងមាននៅព្រះអង្គ»។ បើតាមពាក្យសន្យានេះ បានធ្វើឡើងយ៉ាងជាក់ច្បាស់ពីអាចប្រកែកបានឡើយ។ ប៉ុន្តែពេលនេះព្រះបាទទសរថបែរជាមានព្រះទ័យប្រែប្រួលដោយទ្រង់សព្វព្រះទ័យនឹងសមត្ថភាពរបស់ព្រះរាម រហូតមានគំនិតចង់ឱ្យព្រះរាមសោយរាជ្យទៅវិញ ព្រោះម្យ៉ាងព្រះរាមជាកូនច្បង ហើយម្យ៉ាងទៀតក៏មានឫទ្ធិនុភាពពូកែទៀតផង។ ដូចជាកវីបានបញ្ជាក់ថា «ដងនោះ ព្រះបាទក្សត្រា ទសរថរាជា មហា

បរមចក្រពត្តិ។ ស្តេចជំនុំនូវរាជបរិសទ្យ[3] នូវបង្វៃរាជសម្បត្តិ គឺស្វេតច្ឆត្រ[4] សោភា។ ... ឱ្យព្រះរាមរាជបុត្រច្បង សេពសោយរាជ្យគ្រង ពិភពស្នងព្រះបិតា»។ បើគិតតាមប្រពៃណីក្សត្រដែលមានតវង្សតាំងពីដើមរៀងមកចំពោះរាជ្យបល្ល័ង្កនេះតម្រូវឱ្យក្សត្រច្បងឡើងគ្រងរាជ្យមុនក្សត្រប្អូន។ ប៉ុន្តែពេលនេះ បើសិនជាព្រះបាទទសរថគោរពតាមពាក្យសត្យឬពាក្យសន្យា ព្រះអង្គត្រូវប្រគល់រាជបល្ល័ង្កឱ្យព្រះភិរុត។ទំនាស់នេះជាបញ្ហាដ៏សំខាន់មួយនិងជាសម្ពាធដក់ជាប់ក្នុងព្រះទ័យរបស់ព្រះបាទទសរថ គឺពិតជាពិបាកសម្រេចព្រះទ័យខ្លាំងណាស់ ព្រោះបាតដៃក៏សាច់ ខ្នងដៃក៏សាច់ សុទ្ធតែជារាជបុត្រដូចគ្នា។ ស្ថិតក្នុងភាពចម្រូងចម្រាសបែបនេះព្រះអង្គក៏ចង់បែងចែកនគរជាពីរទៀតមួយទុកឱ្យព្រះរាមគ្រងរាជ្យ ស្របទៅតាមប្រពៃណីក្សត្រមួយទៀតទុកឱ្យព្រះភិរុតគ្រងរាជ្យតាមពាក្យសត្យ។ តែដំណោះស្រាយបែបនេះ ក៏ត្រូវបរាជ័យ គឺមិនស្របតាមបំណងនាងកៃកេសីឡើយ នាងនៅតែមានះទាមទារយ៉ាងទទូចឱ្យព្រះភិរុតឡើងគ្រងរាជ្យតាមពាក្យសត្យដដែលដោយគ្មានការបែងចែកនគរជាពីរនោះទេ។ ហេតុផលនេះហើយដែលនាំឱ្យនាងកៃកេសីព្យាយាមស្នើសុំព្រះអង្គម្តងហើយម្តងទៀតរហូតធ្វើឱ្យព្រះបាទទសរថទ័លច្រកពុំមានយោបល់អ្វីក្រៅពីការយំសោកសន្លប់បាត់ស្មារតី «នោះព្រះទសរថស្តេចទ្រង់ ព្រះកន្សែងពិលាបលង់ ដម្រង់ស្មារតីពុំបាន។ ដល់ដួលសន្លប់ប្រះប្រាណ ក្នុងថ្លើមបីរូហាន អ្នកដុតបង្គអគ្គី»។ ទំនាស់ខាងនេះពិតជាមានឥទ្ធិពលខ្លាំងហាក់ដូចជាគំនាបមួយដ៏សែនធ្ងន់បានសង្កត់ទៅលើព្រះទ័យព្រះរាម គឺត្រូវទទួលយកទាំងសញ្ចេតនាផងនិងវិចារណៈផង។ មានន័យថា បើគិតសញ្ចេតនា គឺត្រូវគិតដល់សាច់ឈាមបងប្អូន តែបើគិតពីវិចារណៈត្រូវគិតដល់ច្បាប់ក្នុងព្រះនគរ គឺព្រះរាជាត្រូវគោរព។ ការសម្រេចព្រះទ័យជាចុងក្រោយរបស់ព្រះរាមគឺការទទួលយកពាក្យសត្យរបស់បិតាដោយបន្ថែមពាក្យសត្យរបស់នាងកៃកេសីដែលតម្រូវឱ្យព្រះរាមយាងចេញពីនគរចំនួនដប់បួនឆ្នាំទុករាជ្យបល្ល័ង្កឱ្យព្រះភិរុតគ្រងរាជ្យ។ ពលិកម្មនេះជាពលិកម្មដ៏កម្រដែលបុគ្គលគ្រប់រូបស្ទើរតែពុំមានបុគ្គលណាមួយហ៊ានសម្រេចចិត្តបែបនេះណាស់ ព្រោះខ្មែរយើងតែងតែមានពាក្យទូន្មានក្នុងន័យប្រៀបធៀបថា «មនុស្សនិងប្រាក់ យក្សនិងសាច់ ស្តេចនិងរាជ្យ»។ ប៉ុន្តែព្រះរាមបែរជាបោះបង់ឥតស្តាយស្រណោះនូវឱកាសដ៏ល្អនេះទៅវិញ។ នេះសបញ្ជាក់ថា ព្រះរាមពិតជាហ៊ានធ្វើពលិកម្មមួយដ៏ធំមួយមិនមែនដើម្បីខ្លួនឯងទេគឺដើម្បីប្រយោជន៍គ្រួសារនិងសង្គម។ ជាការពិតក្នុងលោកយើងនេះគ្មានទំនាស់ណាមួយដែលគ្មានមធ្យោបាយ ដើម្បីដោះស្រាយនោះទេ វៀរលែងតែគូទំនាស់ទាំងសងខាង ពុំបានធ្វើសម្បទានរវាងគ្នានឹងគ្នាតែប៉ុណ្ណោះ។ យ៉ាងណាមិញចំពោះព្រះរាមដែលបានធ្វើសម្បទានបែបនេះពិតជាដំណោះស្រាយប្រកប ដោយកតញ្ញូចំពោះអ្នកមានគុណក្នុងនាមជាកូនល្អដែលបានចេញមុខ ទទួលខុសត្រូវរឿងអតីតកាលជារបស់បិតាទ្រង់មកស្រាយប្រកបដោយសន្តិវិធី នាំមកសុភមង្គលក្នុងគ្រួសារ។ ម្យ៉ាងទៀតទង្វើនេះក៏ជាគុណធម៌របស់ព្រះអង្គចំពោះព្រះអនុជក្នុងនាមជាម្ចាស់បងដែលហ៊ានលះបង់ដើម្បីប្អូន គឺអ្វីៗដែលល្អគ្រប់យ៉ាងក្នុងលោកមិនមែនសុទ្ធតែជារបស់បងនោះទេ បងក៏អាចលះបង់ដើម្បីឱ្យប្អូនបានឃើញពីសន្តានចិត្តបង។ ទន្ទឹមនឹងនេះការលះបង់របស់ព្រះរាមក៏ជាគុណធម៌របស់មេដឹកនាំ គឺហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីផលប្រយោជន៍ប្រជារាស្ត្រទូទាំងនគរ។ ដោយហេតុថា បើសិនជាព្រះរាមមិនទទួលយកពាក្យសត្យខាងលើនេះទេ សង្គ្រាមបង្ហូរឈាមនឹងកើតមានឡើងរវាងអ្នកគាំទ្រខាងព្រះអង្គនិងអ្នកគាំទ្រខាងព្រះនាងកៃកេសីជាមិនខាន។ ទន្ទឹមនឹងនោះ អ្នកបរាជ័យប្រាកដជា

3 បរិសទ្យ   បរិស័ត   ដូចគ្នានឹង បរិស័ទ ដែរ ។

4 ស្វេត   ស្វេ-តះ ឬ ស្វែត   សំ.; បា.  ( គុ. )  (គ្វេត; សេត) ស : ព័ណ៌ស្វេត ។ ស្វេតច្ឆត្រ, ស្វេតបុស្ប ។ល។ (ម. ព. សេត) ។

ប្រជារាស្ត្រ ព្រោះរាស្ត្រត្រូវគេកេណ្ឌយកទៅជាធ្វើជាទ័ពច្បាំងគ្នា ដើម្បីការពារអំណាចរបស់បុគ្គលតែប៉ុណ្ណោះ ហើយអំណាចនេះបានកើតឡើងដោយការសាងឈាមនិងទឹកភ្នែកប្រជារាស្ត្រពិតជាគ្មានតម្លៃឡើយ។ មានន័យថាព្រះអង្គចង់ឃើញនគរមានសុខសន្តិភាពប្រជារាស្ត្រសុខសប្បាយ។ គេអាចនិយាយដោយខ្លីថា ការស្រាយបញ្ហាដូចខាងលើនេះជាវិធីសាស្ត្រដ៏ល្អបំផុត ដែលនាំមកនូវបរិយាកាសល្អទាំងក្នុងគ្រួសារនិងទាំងក្នុងសង្គម។ ដោយសារតែការសម្រេចព្រះទ័យត្រូវបែបនេះហើយ ទើបពេលយាងចេញពីនគរនៅតាមផ្លូវព្រះអង្គទតឃើញធម្មជាតិមានការប្រែប្រួលហាក់ដូចជាស្វាគមន៍ គឺព្រៃឈើកំពុងតែឆេះដោយកម្តៅព្រះអាទិត្យ ក៏ប្រែជាមានភាពមនោរម្យហើយបរិយាកាសនៅជើងភ្នំក៏ប្រែប្រួល គឺកូនខ្លាទៅបៅមេប្រើស រីឯកូនប្រើសទៅបៅមេខ្លាវិញជាបរិយាកាសនាំមកសន្តិភាព។ មួយវិញទៀត ដោយសារតែការទទួលយកពាក្យសត្យនេះហើយ បានប្រែក្លាយជាគុណសម្បត្តិមួយទៀតរបស់ព្រះរាម គឺព្រះអនុជទ្រង់កាន់តែមានព្រះទ័យគោរពស្រឡាញ់ សូម្បីតែព្រះភិរុត និងនាងកៃកេសី ក៏មកយាងព្រះអង្គឱ្យវិលចូលនគរមកគ្រងរាជ្យវិញ មុនកាលកំណត់ទៀតផង តែព្រះអង្គបដិសេធ គឺនៅតែរក្សាគោលជំហរទ្រង់បន្តទៅទៀតការប្រកាន់ពាក្យសត្យ។ ជំហរបែបនេះ ពិតជាសមស្រប ព្រោះខ្មែរយើងតែនិយមឱ្យតម្លៃទៅលើ«មនុស្សយកសម្តី ដំរីយកភ្លុក»។ ហេតុនេះហើយ បានជាព្រះអង្គគ្រាន់តែប្រទានព្រះសុពណ៌បាទ ដើម្បីទុកជានិមិត្តរូបនៃការសោយរាជ្យដល់ព្រះភិរុតតែប៉ុណ្ណោះ។

សរុបសេចក្តីមក ភស្តុតាងខាងលើនេះហើយដែលបញ្ជាក់ថា ការទទួលយកពាក្យសត្យរបស់នាងកៃកេសីពិតជាបង្ហាញឱ្យឃើញថា ព្រះរាមមានការលះបង់ខ្ពស់ប្រាកដមែនគឺអ្វីៗដើម្បីប្រយោជន៍រួម ឬប្រយោជន៍ជាតិ។

ឆ្លងតាមការបកស្រាយដូចខាងលើនេះបានបង្ហាញឱ្យឃើញថា ទស្សនៈប្រធានមានអត្ថន័យជ្រាលជ្រៅ ព្រោះបានអប់រំមនុស្សគ្រប់រូបឱ្យចេះលះបង់ឬកាត់បន្ថយអត្តទត្តភាពដែលខ្លួនធ្លាប់មានកន្លងមកដើម្បីជាប្រយោជន៍ដល់សង្គមគ្រួសារនិងសង្គមជាតិ។ ជាងនេះទៅទៀត គំនិតប្រធានក៏បានបណ្តុះស្មារតីមនុស្សធម៌គុណធម៌សប្បុរសធម៌ដល់អ្នកសិក្សាអ្នកអានឱ្យចេះលះបង់អ្វីៗដើម្បីជាប្រយោជន៍រួម គឺឯកភាពគ្នាសាមគ្គីគ្នាមិនគិតតែពីលោភលន់ដណ្តើមអំណាចគ្នាមិនចេះឈប់ឈរដោយសារតែផលប្រយោជន៍ខ្លួន បែរជាក្បត់ពាក្យសន្យាដែលបានសច្ចានោះឡើយ។

## ខ- ប្រធានពិភាក្សា

---

**ប្រធាន:** មានមតិខ្លះយល់ថា «មហន្តរាយនៃនគរលង្កា បណ្តាលមកពីនាងសូរបនខា»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងរឿងរាមកេរ្តិ៍ខ្មែរមកបញ្ជាក់។

---

### គម្រោងតែង

ក្រោយពីក្រុងខរជាបង ត្រូវបរាជ័យក្នុងសង្គ្រាមទាមទារកិត្តិយសពីព្រះរាមមកវិញ នាងសូរបនខាមានការឈឺចាប់យ៉ាងខ្លាំងរួចក៏ទៅញុះញង់ក្រុងរាពណ៍ជាបងឱ្យមានចិត្តស្រឡាញ់នាងសីតាដើម្បីលួចឆក់នាងយកមកទុកនៅក្រុងលង្កា។ ដោយមើលឃើញពីឥរិយាបថនៃគំនុំសងសឹកដូចខាងលើនេះហើយ ទើបមានមតិខ្លះយល់ថា«មហន្តរាយនៃនគរលង្កាបណ្តាលមកពីនាងសូរបនខា»។

តើមតិខាងលើនេះ ត្រឹមត្រូវឬទេ?

ដើម្បីរួមចំណែកដល់ការវែកញែកមតិប្រធានខាងលើនេះឱ្យកាន់តែស៊ីជម្រៅថែមទៀតនោះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន។ ពាក្យថា «មហន្តរាយ» នៅពេលនេះគឺសំដៅទៅលើការវិនាស ហិនហោច ខ្ទេចខ្ទី សាបសូន្យ គ្មានសេសសល់អ្វីឡើយ។ រីឯ«បណ្តាល»មានន័យថា ជាដើមហេតុ បង្កហេតុ មូលហេតុដែលនាំឱ្យកើតមានផលណាមួយឡើង។ ចំណែក«សូរបនខា» ជាឈ្មោះស្រីយក្សជាប្អូនរបស់ក្រុងរាពណ៍ដែលសោយរាជ្យនៅក្រុងលង្កាក្នុងរឿងរាមកេរ្តិ៍ខ្មែរ។ តាមគំនិតប្រធានមានន័យថា សេចក្តីវិនាសហិនហោចនៃនគរលង្កាគឺមកពីនាងសូរបនខា ដែលជាប្អូនក្រុងរាពណ៍មកញុះញង់បងបង្កឱ្យមានសង្គ្រាមនេះកើតឡើង។

ជាការពិតណាស់ មហន្តរាយនៃនគរលង្កាពិតជាបណ្តាលមកពីនាងសូរបនខា ព្រោះនាងមានចិត្តចេតនាប្រតិព័ទ្ធទៅលើព្រះរាមព្រះលក្ស្មណ៍ក្នុងពេលដែលទ្រង់តាំងសិល្ប៍នៅព្រៃព្រៃភ្នំទណ្ឌការណ្យ។មិនតែប៉ុណ្ណោះនាងបានរំខានដល់ការតាំងសិល្ប៍របស់ព្រះរាមព្រះលក្ស្មណ៍ ដោយចូលមកចៃចង់អ្នកទាំងពីរ ក្នុងបំណងសុំសេចក្តីស្នេហា តែត្រូវអ្នកទាំងពីរបដិសេធ។នៅទីបំផុតនាងសូរបនខាក៏ប្រើពាក្យមិនសមរម្យដោយឥតខ្មាសនៅចំពោះព្រះលក្ស្មណ៍ថា « នោះសូរបនខាដើរល្ងេ វិលវឹងកាយកែដល់ព្រះអនុជសោតហោង។ ទូលថាខ្ញុំមកនេះម្តងយកខ្លួនស្លាប់ផង នៅព្រះបាទពុំឃ្លាតឃ្លា។ ទោះព្រះពុំយកខ្ញុំជាភរិយាខ្ញុំស្វា មីយកព្រះជាប្តីឯង»។ ជាហេតុធ្វើឱ្យព្រះលក្ស្មណ៍ក្រេវក្រោធរហូតផ្តួលកោរសក់កាត់ដៃរហូតនាងស្រែករំពងព្រៃព្ទដល់ក្រុងខរជាបងនាំគ្នាលើកទ័ពមកធ្វើច្បាំងនឹងព្រះរាមរហូតត្រូវស្លាប់។ ភស្តុតាងមួយទៀត គឺនាងមានចេតនារំខានព្រះរាមព្រះលក្ស្មណ៍ដែលជាប់ភារៈក្នុងការតាំងសិល្ប៍មិនអាចដោះខ្លួនបានជាហេតុនាំឱ្យព្រះអង្គទាំងពីរទាល់ច្រក តម្រូវឱ្យនាងទៅសាកសួរចិត្តម្តងព្រះរាមម្តងព្រះលក្ស្មណ៍។ ការមិនយល់ពីស្ថានភាពបែបនេះជាប្រការមួយដែលនាំឱ្យនាងខកចិត្តត្បិតស្នេហ៍ដែលខ្លួនកំពុងស្រមើស្រមៃចង់បាននោះ។ ដោយឃើញបងខ្លួនត្រូវបរាជ័យបែបនេះហើយ ជាហេតុនាំឱ្យនាងទៅរកក្រុងរាពណ៍នៅក្រុងលង្កាដែលជាបងនាងដែរនោះ ដោយនិយាយពីសម្ផស្សនាងសីតាល្អលើសគេហាក់ដូចជំរុញឱ្យក្រុងរាពណ៍ មានចិត្តត្រេកត្រអាលចង់បាននាងសីតាមកធ្វើជាមហេសីមួយរំពេច ទោះជាដឹងថានាងមានស្វាមីហើយក៏ដោយ។ បញ្ហានេះក៏បណ្តាលឱ្យចិត្តក្រុងរាពណ៍ខិតខំរិះរកវិធីយ៉ាងណាដើម្បីចាប់នាងសីតាឱ្យបាន។ ចំណែកព្រះរាមវិញ ក៏មិនព្រមចុះញ៉មក៏ខិតខំរិះរកវិធីតបតនឹងក្រុងរាពណ៍វិញតាមយុទ្ធវិធីរៀងៗខ្លួន។ នៅចុងបញ្ចប់សង្គ្រាមស្នេហាក៏កើតមានឡើងរវាងក្រុងរាពណ៍និងព្រះរាម។ ទោះបីដឹងថា សង្គ្រាមនេះមានផលវិបាកយ៉ាងណាក៏ដោយក៏ខ្លួននៅតែប្តេជ្ញាការពារសីតារហូតត្រូវព្រះរាមវាយកម្ទេចនគរលង្កាឱ្យវិនាសទាំងស្រុង។

សរុបសេចក្តីមក មហន្តរាយនៃនគរលង្កា ពិតជាបណ្តាលមកពីនាងសូរបនខាប្រាកដមែនដែលនាងមានចិត្តចៃចង់មនុស្សប្រុសខុសច្បាប់នោះ។

ផ្ទុយទៅវិញបើសិនជាគេពិចារណាម្តងទៀតពិតជាមើលឃើញមូលហេតុពិតនៃវិនាសកម្មក្រុងលង្កានេះជាមិនខាន។ ទោះបីទំនាស់បានកើតឡើងក៏ពិតមែន បើសិនជាគូទំនាស់បានធ្វើសម្បទានឱ្យគ្នាទៅវិញទៅមកម្ល៉េះសមនឹងដោះស្រាយបានជាមិនខានឡើយ។ ទាំងខាងព្រះរាមទាំងខាងក្រុងរាពណ៍សុទ្ធតែចូលចិត្តប្រើអំពើហិង្សាព្រោះរឿងនេះសុទ្ធតែបានប៉ះពាល់ផលប្រយោជន៍រៀងៗខ្លួន គឺព្រះរាមបាត់បង់កិត្តិយសដោយសារក្រុងរាពណ៍ឆក់យកមហេសីខ្លួន រីឯក្រុងរាពណ៍បាត់បង់កិត្តិយសដោយសារព្រះលក្ស្មណ៍បានប្រើហិង្សាមកលើនាសូរបនខាជាប្អូនដោយគ្រាន់តែមកសុំ

ស្នេហាតែប៉ុណ្ណោះ។ តាមពិតគ្រាន់តែសុំក្តីស្រឡាញ់ចំពោះមនុស្សម្នាក់ពុំមែនខុសច្បាប់ឬប៉ះពាល់ដល់អាយុជីវិតដែរ គឺអាចបដិសេធឬរកវិធីជាច្រើនទៀតដោយពុំចាំបាច់ប្រើហិង្សាដូចជាព្រះលក្ស្មណ៍នោះឡើយដែលបង្កការឈឺចាប់ដល់នាងសូរបនខាទាំងផ្លូវកាយទាំងផ្លូវចិត្ត បាត់បង់អស់សម្រស់ដែលស្ត្រីគ្រប់តែងស្រឡាញ់។ ចំពោះអំពើដ៏ឃោរឃៅនេះ ជាហេតុនាំឱ្យមានការឈឺចាប់ដល់ក្រុងខរជាបងនាងរហូតធ្វើសង្គ្រាមត្រូវវិនាសអស់ ពលយក្សមួយចំនួនក្រុងខរខ្លួនឯងត្រូវស្លាប់នៅក្នុងសមរភូមិទៀតផង។ មូលហេតុនេះបានធ្វើឱ្យក្រុងរាពណ៍និងព្រះរាមជ្រើសរើសយកដំណោះស្រាយសង្គ្រាមប្រសើរជាងការចរចារ។ មានន័យថា ម្នាក់ៗសុទ្ធតែការពារអំណាចរបស់ខ្លួន ជាពិសេសចង់បង្ហាញពីឧត្តមភាពរៀងៗខ្លួនមិនចុះញ៉មឡើយ។ វិនាសកម្មដ៏សែនឈឺចាប់នេះ ក៏បណ្តាលឱ្យក្រុងរាពណ៍ជាបងនាងសូរបនខានិងក្រុងខរ រួមផ្សំនឹងចិត្តស្រឡាញ់សីតាផងក្រុងរាពណ៍ក៏រកវិធីដើម្បីចាប់យកនាងសីតា មកទុកនៅក្រុងលង្កាក្នុងសួនអសោកជាហេតុនាំឱ្យព្រះរាមលើកទ័ពមកធ្វើសង្គ្រាមជាមួយក្រុងរាពណ៍ដោយប្រើល្បិចកលរៀងៗខ្លួន មិនគិតពីសេចក្តីវេទនារបស់អ្នកលង្កាសោះឡើយ។ ចំណែកព្រះរាមវិញ នៅតែតាមប្រមាញ់ទ័ពយក្សដោយឱ្យអ្នកយកការណ៍ដែលមានហនុមានទៅស៊ើបមើលពីពលយក្សឬទីតាំងស្បៀងទីតាំងដ៏ទៃទៀតក្នុងក្រុងលង្កាទាំងមូល ព្រមទាំងទិញទឹកចិត្តសត្រូវដូចជាពិភេក ដើម្បីស៊ើបរកទីតាំងពិតប្រាកដរបស់ក្រុងរាពណ៍ក្នុងការកម្ទេចរហូតវិនាសក្រុងលង្កាគ្មានស្ទើរសេសសល់អ្វីឡើយ។

សរុបសេចក្តីមក មហន្តរាយនៃនគរលង្កាពិតជាបណ្តាលមកពីអ្នកដទៃទៀតដែលបង្កសង្គ្រាមប្រាកដមែន។

ជារួមមហន្តរាយនៃនគរលង្កាពិតជាបណ្តាលមកពីនាងសូរបនខាផងនិងអ្នកដទៃផងដែលមានព្រះរាមព្រះលក្ស្មណ៍និងក្រុងរាពណ៍សុទ្ធតែនិយម ប្រើអំពើហិង្សាក្នុងការស្រាយបញ្ហាទំនាស់និងភាពមានះរៀងៗខ្លួន។បើសិនជាពួកគេចេះរកវិធី ដ៏សមស្របណាមួយម្ល៉េះសមនគរលង្កានិងប្រជារាស្ត្រដែលរស់នៅក្រុងលង្កានោះមុខជាបានសេចក្តីសុខមិនខានឡើយ។

ឆ្លងតាមការអធិប្បាយវែកញែក ដូចខាងលើនេះបានបង្ហាញថា មតិប្រធានមិនទាន់ត្រឹមត្រូវទាំងស្រុងទេ ព្រោះជាការដាក់បន្ទុកតែទៅលើនាងសូរបនខាតែម្នាក់ រីឯអ្នកដទៃទៀតបែរជារួចខ្លួនទៅវិញ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មតិខាងលើនេះបានផ្តល់ជាបទពិសោធដល់អ្នកសិក្សាអ្នកអានគ្រប់រូបឱ្យចេះវិភាគបញ្ហានិងស្រាយទាំងឡាយ ដែលមានក្នុងអក្សរសិល្ប៍ក្តីឬសង្គមជាតិក្តី។

### គ- ប្រធានប្រៀបធៀប

ប្រធានៈ ចូរអ្នកធ្វើការប្រៀបធៀបសេចក្តីស្នេហារបស់ព្រះរាមនិងស្នេហារបស់ក្រុងរាពណ៍ដែលមានចំពោះនាងសីតា។ តើសេចក្តីស្នេហាទាំងពីរខាងលើនេះមានចំណុចដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

### សេចក្តីអធិប្បាយ

មនុស្សគ្រប់រូប ដែលបានចាប់បដិសន្ធិលើលោកិយសន្និវាសយើងនេះ តែងតែមានសេចក្តីស្នេហាជាចាំបាច់ ប៉ុន្តែសេចក្តីស្នេហាទាំងនោះពុំមានលក្ខណៈដូចគ្នាទាំងស្រុងទេគឺស្នេហាខ្លះកើតចេញពីការបង្ខិតបង្ខំ ហើយស្នេហាខ្លះទៀត កើតចេញពីចិត្តនិងចិត្តពិតប្រាកដ។ រីឯរឿងរាមកេរ្តិ៍ខ្មែរ

វិញ បុព្វកវីនិពន្ធយើងក៏បានបង្ហាញពីសេចក្ដីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍ដែលមានចិត្តស្រឡាញ់នាងសីតាតែម្នាក់ ដូចគ្នាដែរ។

តើស្នេហារបស់តួអង្គទាំងពីរខាងលើនេះ មានចំណុចដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

ជាបឋមនៃការប្រៀបធៀប សេចក្ដីស្នេហារបស់តួអង្គទាំងពីរខាងលើនេះ យើងគប្បីពន្យល់ពាក្យ «ស្នេហា»ជាមុនសិន។ ពាក្យ «ស្នេហា» គឺសំដៅទៅលើការស្រឡាញ់ដកចិត្តមិនរួចចំពោះអ្វីមួយ ហើយធ្វើឱ្យមនុស្សបានសុខផងនិងបានទុក្ខផង។ ដូច្នេះគំនិតតម្រូវឱ្យយើងបង្ហាញពីចំណុចដូចគ្នា និងចំណុចខុសគ្នានៃក្ដីស្រឡាញ់របស់ព្រះរាមនិងក្រុងរាពណ៍ ដែលមានចំពោះនាងសីតាតែម្នាក់ដូចគ្នា។

បើយើងធ្វើការសិក្សារឿងរាមកេរ្តិ៍ខ្មែរពិតជាបានឃើញថា ក្នុងស្នាដៃនេះកវីបានផ្សារភ្ជាប់បញ្ហាសំខាន់ទៅនឹងសេចក្ដីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍ដែលមានចំពោះនាងសីតាដូចគ្នា ហើយបង្កជាសង្គ្រាមដ៏រ៉ាំរ៉ៃទៀតផង។មានន័យថា ស្នេហានេះជាស្នេហាបុរសពីរនាក់តែស្រឡាញ់ស្រីម្នាក់។ ជាក់ស្ដែងតួអង្គទាំងពីរនេះ សុទ្ធតែតស៊ូចំពោះឧបសគ្គដូចគ្នា គឺព្រះរាមបានឆ្លងកាត់ការលំបាកជាច្រើនគ្រប់យ៉ាងដើម្បីរិះរកវិធីរំដោះនាងសីតាក្រោយពេលក្រុងរាពណ៍ចាប់យកទៅឬការពារនាងសីតា។ ដូចជាទ្រង់បានដឹកនាំធ្វើសង្គ្រាមជាច្រើនលើកជាច្រើនសារនិងរកកងទ័ពជំនួយដែលមានទ័ពស្វាជាដើម។ ឯក្រុងរាពណ៍វិញក៏រិះរកនិងប្រើប្រាស់យុទ្ធវិធីគ្រប់យ៉ាងដើម្បីការពារនាងសីតារក្សានាងទុកធ្វើជាមហេសី។ ដោយក្រុងរាពណ៍បានរៀបចំទ័ពប្រយុទ្ធដោយខ្លួនឯងតាមវិធីសង្គ្រាមផ្ដាច់ស្បៀង សង្គ្រាមចិត្តសាស្ត្រ ព្រមទាំងវិធីដទៃទៀត។ លើសពីនេះទៀត អ្នកទាំងពីរមានបំណងរួមរស់ជាមួយសីតាទៅអនាគត ដោយចាត់ទុកនាងសីតាជាមហេសីពេញលក្ខណៈទៀតផង។ ប៉ុន្តែនៅទីបំផុតទាំងព្រះរាមនិងទាំងក្រុងរាពណ៍សុទ្ធតែខកបំណងដូចគ្នា ព្រោះពួកគេមិនបានរួមរស់ជាមួយនាងសីតាដូចការគ្រោងទុកនោះឡើយ។ ហេតុផលនេះគឺបណ្ដាលមកពីព្រះរាមមានការប្រច័ណ្ឌទៅលើនាងសីតា ហើយនាងក៏គៀសព្រះកាយទៅឋានភជុង្គនាគចោលព្រះអង្គជារៀងរហូត។ រីឯក្រុងរាពណ៍វិញ ក៏ត្រូវស្លាប់ក្នុងសង្គ្រាមរវាងខ្លួននិងព្រះរាម។

សរុបសេចក្ដីមក ចំណុចខាងលើនេះជាលក្ខណៈដូចគ្នានៃសេចក្ដីស្នេហារបស់ព្រះរាម និងសេចក្ដីស្នេហារបស់ក្រុងរាពណ៍ដែលមានចំពោះនាងសីតា។

ដោយឡែក ចំពោះលក្ខណៈខុសគ្នាវិញនៃសេចក្ដីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍ដែលមានចំពោះនាងសីតាបានឱ្យឃើញថា មានចំណុចខុសគ្នាជាច្រើន។ ជាក់ស្ដែងក្នុងរឿងបានបង្ហាញថាព្រះរាមបានរៀបអភិសេកជាមួយនាងសីតាជាមហេសីក៏ដោយសារតែទ្រង់មានសមត្ថភាពលើសគេឯងក្នុងការប្រឡងលើកធ្នូសិល្ប៍ក្នុងចំណោមទេវៈទាំងឡាយនោះដែរ។ ចំណុចនេះចង់បញ្ជាក់ថាព្រះបាទជនកដែលជាបិតាចិញ្ចឹមនាងសីតាបានរៀបការប្រឡងប្រកួតប្រជែងសមត្ថភាពលើកធ្នូសិល្ប៍ ដើម្បីជ្រើសរើសធីតុបតីធ្វើជាស្វាមីនាងសីតា។ ធ្នូសិល្ប៍នោះ មានទម្ងន់ស្មើនឹងបុរសមួយពាន់នាក់ ទើបអាចលើករួច។ នៅពេលនោះមានតែព្រះរាមទេដែលអាចលើកធ្នូសិល្ប៍នោះបានហើយក៏បានទទួលនាងសីតាជាមហេសីនិងរៀបចំអភិសេកស្របតាមប្រពៃណីនៅនគរមិថិលានោះទៀតផង។ ម្យ៉ាងទៀតក្នុងសេចក្ដីស្នេហានេះ ព្រះរាមនិងនាងសីតាសុទ្ធតែស្រឡាញ់គ្នាទៅវិញទៅមក ពោរពេញទៅដោយភក្ដីភាពរវាងគ្នានិងគ្នាជានិច្ច។ ដូចជាក្រោយពេលក្រុងរាពណ៍ចាប់យកនាងសីតាទៅ ព្រះរាមបានយំសោកអាលោះអាល័យចំពោះនាងយ៉ាងខ្លាំង ហើយនាងសីតាវិញក៏

ខិតខំថែរក្សាការពារខ្លួននៅសួនអសោកមិនឱ្យក្រុងរាពណ៍ចូលមកជិត ដើម្បីសុំសេចក្តីស្នេហាពីនាងបានឡើយ។ ទន្ទឹមនឹងនេះក្តីស្រឡាញ់របស់អ្នកទាំងពីរជាក្តីស្រឡាញ់តាមធម្មជាតិគឺតាំងពីវ័យកំលោះនិងក្រមុំមិនមែនលួចលាក់ឬខុសប្រពៃណីនោះទេ។មួយវិញទៀតទោះបីព្រះរាមស្រឡាញ់នាងសីតាយ៉ាងណាក៏ដោយក៏ព្រះអង្គមិនចេះសរសើរសម្រស់នាងសីតានៅចំពោះមុខដែរ។ ក្រោយពេលបាត់បង់នាង ទើបនឹកឃើញសម្រស់របស់នាងឬលម្អរបស់នាងទៅវិញ។ ជាក់ស្តែងព្រះអង្គបានពោលថា«បងចាំកេសីបីខ្មៅញាប់ប្អូនក្រសោបចាប់ចងចារផ្កា កែម[5] ចូតប្រួតមាលាអស់ផ្កាសារពើភ្ញី។... បងចាំចិញ្ចើមទ្រទូយ បីដូចចង្កូយកៅទ័ណ្ឌជ័យកោងស្រួលហ្មត់ក្រៃកាលនៃព្រះពិស្ណុការកាន់គូរតម្រង់វាស។... ចាំធ្មេញខ្មៅជិតដូចអ្នកប្រកិតនីលរ័តន៍ថ្លៃបងគន់សំគាល់នៃអំបាលរូបដ៍ប្អូនបង។ បងចាំសម្បុរប្អូនជិតក្រៃលែងស្រលិត[6]លឿងខៀវដ៏អន្លង[7] វាប្លែកសម្បុរនោះដ៏បីដងមួយថ្ងៃផ្សិង១[8] បំព្រង ទុំ»។ តែដោយមានចិត្តស្រឡាញ់នាងសីតាដ៏លើសលុបរបស់ព្រះរាមនេះហើយជាហេតុនាំឱ្យព្រះរាមកើតមានចិត្តប្រច័ណ្ឌសីតាជាមួយក្រុងរាពណ៍ ដោយសារផ្ទាំងគំនូរមួយផ្ទាំងដែលជាល្បិចកលអាគុល័យនាំឱ្យព្រះអង្គដាច់ចិត្តឱ្យព្រះលក្ស្មណ៍យកនាងសីតាទៅសម្លាប់ទាំងមានគភ៌ទៅវិញ។

ចំណែកសេចក្តីស្នេហាក្រុងរាពណ៍ ចំពោះសីតាវិញក៏ឆ្លុះឱ្យឃើញថា ស្នេហានេះកើតឡើងដោយសារតែការសងសឹកជំនួសនាងសូរបនខានិងក្រុងខរជាប្អូនខ្លួន។ក្រុងរាពណ៍មានបំណងចង់ស្តារកិត្តិយសឡើងវិញ ទើបកើតមានជាក្តីស្រឡាញ់នេះឡើង។ មិនតែប៉ុណ្ណោះស្នេហានេះមិនបានរៀបចំតាមប្រពៃណីទេ គឺក្រុងរាពណ៍បានលួចឆក់សីតាដែលជាមហេសីរបស់ព្រះរាមខុសច្បាប់ ព្រោះក្រុងរាពណ៍បានប្រើវិធីបំបែកព្រះរាមឱ្យចេញពីនាងសីតាដើម្បីទុកឱកាសឱ្យខ្លួនចូលទៅឆក់យកនាងហោះទៅក្រុងលង្កាតែម្តង។ មួយវិញទៀតក្រុងរាពណ៍មានមហេសីរួចទៅហើយ គឺនាងមណ្ឌោគិរី អ្វីដែលខ្លួនប្រព្រឹត្តនៅពេលនេះដើម្បីផ្តល់ការឈឺចាប់ចំពោះព្រះរាមនិងសីតា។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុងរាពណ៍មានចិត្តស្រឡាញ់នាងសីតាដែរ ប៉ុន្តែសីតាមិនព្រមស្រឡាញ់ក្រុងរាពណ៍វិញទេ។ មានន័យថា ការស្រឡាញ់របស់ក្រុងរាពណ៍ចំពោះសីតាជាក្តីស្រឡាញ់ស្ត្រីដែលមានប្តីហើយ ពុំមែនជាស្នេហារវាងកំលោះនិងក្រមុំនោះទេ។ ក្រុងរាពណ៍ចេះអួតសរសើរសម្រស់នាងសីតានៅចំពោះមុខក្នុងពេលដែលខ្លួនបានឃើញសីតាជាលើកដំបូងនៅអាស្រម បន្ទាប់ពីព្រះរាមព្រះលក្ស្មណ៍ចេញទៅតាមប្រើសមាសក្លែងក្លាយ ដែលជាល្បិចកលរបស់ក្រុងរាពណ៍នោះ។ ក្រុងរាពណ៍បានអួតសរសើរនាងថា គេគួរមានភ្នែករាប់សែនអណ្តាតរាប់លានទើបអាចរៀបរាប់ពីសម្រស់របស់នាងសីតា បានសព្វចប់គ្រប់។សមដូចកវីបានបញ្ជាក់ថា «យល់អញមហាភ័ព្វ មហាបុណ្យបានយល់អង្គ ធ្វើម្តេចកល់ភ្នែកគិតដ៏យង់ មួយសែនសោតនឹងមើលគ្រាន់។ ធ្វើម្តេចភុលឱស្ឋភុល[9]អណ្តាតបានមួយសែនពាន់ បងនឹងសរសើរមេរូចន្ទ្រ ដ៏ច្រាលច្រៃនៃវហាស៍»។

---

[5] កែម ( កិ. ) ស៊ែម, ថែមឲ្យបានមាំមួន ឬឲ្យសមរម្យឡើង ។

[6] ស្រលិត --លិុត ស. ( ន. ) (ប្រើជា សលិត អ. ថ. សះលិត) ឈ្មោះវល្លិឡើងទ្រើងមួយប្រភេទផ្កាជាចង្កោមៗ ក្លិនក្រអូបឈ្ងុយឆ្ងាញ់, ផ្លែទ្រវែងជមចុងដើមវេលាទុំស្ងួតបែកជាប៉ុយជាប់នឹងគ្រាប់ ។ ស្រឡិត

[7] អន្លង ( គុ. ) ខៀវឡើងទឹកជមឬឡើងសម្បុររលោង : ខៀវអន្លង ។

[8] ផ្សិង (ម. ព. ផ្សេង) ។

[9] ភុល ( ឧ. ) សូរព្ទដោយបក្សីស្មុះហើរព្រមគ្នា ឬសូរទឹកខ្ពុរចេញជាដើម ។

សរុបសេចក្តីមកចំណុចខាងលើនេះជាលក្ខណៈខុសគ្នានៃសេចក្តីស្នេហារបស់ព្រះរាម និង សេចក្តីស្នេហារបស់ក្រុងរាពណ៍ដែលមានចំពោះនាងសីតា។

រួមសេចក្តីមកសេចក្តីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍ សុទ្ធតែមានទឹកចិត្តស្រឡាញ់សីតាដូចគ្នា។ តែឥរិយាបថនៃក្តីស្រឡាញ់របស់តួអង្គក្រុងរាពណ៍ កើតចេញពីការបង្ខិតបង្ខំលួចប្រពន្ធអ្នកដទៃគឺប្រើល្បិចកលអាក្រក់ដោយគំនុំសងសឹកក្នុងចិត្ត។ រីឯឥរិយាបថនៃក្តីស្រឡាញ់របស់ព្រះរាមចំពោះសីតាវិញជាក្តីស្រឡាញ់តាមបែបមនោសញ្ចេតនាដ៏ជ្រាលជ្រៅក្នុងទឹកចិត្តភក្តីភាពពិតប្រាកដ។

ឆ្លងតាមការប្រៀបធៀបនេះបានបង្ហាញថា សេចក្តីស្នេហាព្រះរាមចំពោះសីតាមានលក្ខណៈគាប់ប្រសើរជាងស្នេហារបស់ក្រុងរាពណ៍ចំពោះសីតា ដែលចូលចិត្តលួចប្រពន្ធអ្នកដទៃ។ តែទោះជាយ៉ាងនេះក្តី ក៏ព្រះរាមមិននៅតែមិនអាចយកចិត្តនាងសីតាបានដែរ ព្រោះនាងត្រូវឃ្លាតចាកឆ្ងាយពីព្រះអង្គជារៀង រហូត។ ជាងនេះទៀត ថ្វីបើស្នេហាត្រូវតែកើតមានសម្រាប់បុគ្គលម្នាក់ៗក៏ពិតមែន តែគេគប្បីជ្រើសរើសស្នេហាណាមួយដែលកើតចេញពីទឹកចិត្តពិតៗគ្មានការបង្ខិតបង្ខំដោយការយោគយល់និងជឿជាក់គ្នាទៅវិញទៅមក នោះទើបមានសុភមង្គលយូរអង្វែង។

## ៨- លំនាំសំណេរល្អ

លំនាំសំណេរល្អ គឺផ្តោតទៅលើការសរសេរសេចក្តីអធិប្បាយដែលមានការដកឃ្លា ការចុះបន្ទាត់ចម្ងាយពីបន្ទាត់ក្រហមគម្លាតបន្ទាត់ក្នុងការសរសេរជាដើម។

សូមពិនិត្យឧទាហរណ៍លំនាំសំណេរល្អក្នុងប្រធានតែងសេចក្តីអត្ថាប្បាយពន្យល់ ពិភាក្សា និង ប្រៀបធៀបដកស្រង់ចេញពីអក្សរសិល្ប៍រឿងទុំទាវ រឿងព្រះវេស្សន្តរ រឿងរាមកេរ្តិ៍ ដូចខាងក្រោមនេះ៖

### ៨.១- ប្រធានពន្យល់ (ក្នុងរឿងទុំទាវ.ព្រះវេស្សន្តរ.រាមកេរ្តិ៍)

ប្រធានៈ ពាក្យស្លោកមួយឃ្លាក្នុងទិវាជាតិអំណានបានថែងថា«អានដើម្បីភាពសុខដុមនៃជីវិត»។ តើការអានរឿងទុំទាវ ព្រះវេស្សន្តរ និងរាមកេរ្តិ៍បានផ្តល់ភាពសុខដុមនៃជីវិតក្នុងការរស់នៅរបស់អ្នកយ៉ាងណាខ្លះ? ចូរអ្នកបកស្រាយពាក្យស្លោកនេះ ដោយរកឧទាហរណ៍ក្នុងរឿងខាងលើមកបញ្ជាក់ឱ្យបានក្បោះក្បាយ។

**សេចក្តីអធិប្បាយ**

មនុស្សគ្រប់រូប ដែលមានកំណើតលើលោកិយសន្និវាសយើងនេះ ពុំមានបុគ្គលណាមួយដែលកើតឡើងចេះឯងនោះទេ គឺទាមទារឱ្យខិតខំស្តាប់ គិត សរសេរ ឬអានដើម្បីសិក្សាស្រាវជ្រាវចំណេះដឹងណាមួយក្នុងគោលបំណងអភិវឌ្ឍសមត្ថភាពខ្លួនបន្ថែមទៀត។ ដោយស្ថិតក្នុងគំនិតអភិវឌ្ឍសមត្ថភាពបុគ្គលដូចខាងលើនេះហើយ ទើបមានពាក្យស្លោកមួយឃ្លាក្នុងទិវាជាតិអំណានបានថែងថា «អានដើម្បីភាពសុខដុមនៃជីវិត»។

តើការអានរឿងទុំទាវ ព្រះវេស្សន្តរ និងរាមកេរ្តិ៍បានផ្តល់ភាពសុខដុមនៃជីវិតយ៉ាងណាខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយទស្សនៈប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ ពាក្យថា «អាន» គឺជាការបន្លឺសូរសំឡេងទៅតាមពាក្យនីមួយៗដែលមាននៅក្នុងអត្ថបទដើម្បីស្វែងរកនិងឈ្វេងយល់ព័ត៌មាននានានៅក្នុងអត្ថបទនោះ។ រីឯ «សុខដុមនៃជីវិត» គឺសំដៅទៅលើភាពសុខសាន្តក្នុងជីវិតទាំងកាយវាចានិងចិត្តឬជាការរស់នៅប្រកបដោយ

ការចុះសម្រុងគ្នាឯកភាពគ្នា ស្មោះត្រង់គ្នា គោរពសិទ្ធិគ្នា អធ្យាស្រ័យគ្នាជាដើម។ តាមគំនិតប្រធានខាងលើនេះមានន័យថា ការអានដើម្បីឈ្វេងយល់ពីព័ត៌មាននានាក្នុងសៀវភៅសិក្សាឬអត្ថបទផ្សេងៗ មានគោលបំណងទាញយកសារប្រយោជន៍ពីការអាននោះមកអនុវត្តក្នុងជីវភាពរស់នៅប្រកបដោយសេចក្តីសុខ។

ជាការពិត ការអានបានធ្វើឱ្យមនុស្សមានការប្រែប្រួល គឺនាំឱ្យជីវិតរស់ក្នុងភាពសុខដុមមួយដែលពោរពេញទៅដោយសុភមង្គល។ ដោយហេតុថា ការអាននាំឱ្យយើងស្គាល់ឋានសួគ៌លោកិយពិតប្រាកដគឺបើកជើងមេឃលំហនៃចំណេះដឹងនៅក្នុងសង្គមដែលមានការប្រែប្រួលឥតឈប់ឈរ។ មិនតែប៉ុណ្ណោះការអាន គឺជាការបំពេញចំណីអារម្មណ៍ក្នុងការកាត់បន្ថយភាពតានតឹងឬស្មុគស្មាញក្រោយពីធ្វើការងារដ៏លំបាកណាមួយឬជាការងារប្រកបទៅដោយការទទួលខុសត្រូវខ្ពស់។ បានសេចក្តីថា ក្រោយពីអាន មនុស្សម្នាក់ៗនឹងមានអារម្មណ៍ភ្លឺថ្លានិងមានភាពរីករាយជាងមុនពេលអាន ហើយនឹងធ្វើឱ្យគេមានសុខភាពផ្លូវចិត្តប្រក្រតីទៀតផង។ ការអានច្រើននាំឱ្យកើនប្រាជ្ញាស្មារតីនូវអ្វីដែលគេពុំធ្លាប់បានជួបប្រទះឬពុំមានបទពិសោធ ក៏អាចកែប្រែទម្លាប់បុគ្គលនោះឱ្យចេះគិតពិចារណា ចេះស្រាវជ្រាវបង្កើតគំនិតថ្មីដែលសង្គមជាតិកំពុងត្រូវការ។ ទន្ទឹមនឹងនេះ អំណានឬការអានគឺជាស្ពានដឹកនាំជីវិតឆ្ពោះទៅរកគោលដៅមួយពិតប្រាកដក្នុងការជ្រើសរើសយកកិច្ចការងារណាមួយដែលសមស្របនឹងនិស្ស័យឬចំណូលចិត្តខ្លួន គឺមិនសម្រេចចិត្តអ្វីតាមតែការអូសទាញឬញុះញង់ពីអ្នកដទៃឡើយ។ សមដូចប្រសាសន៍រដ្ឋមន្ត្រីក្រសួងអប់រំមួយឃ្លាបានពោលថា «អំណាន គឺជាកត្តាដែលធ្វើឱ្យយុវជនរបស់យើងទទួលបានជោគជ័យនៅក្នុងជីវិតនិងកិត្តិយសទៅថ្ងៃក្រោយ»។ បើសិនជាយកពេលវេលាមកប្រើប្រាស់ជាការអានឱ្យកាន់តែច្រើនយុវជនយើងនឹងទទួលបានពុទ្ធិថ្មីៗដែលបទពិសោធឬជាវិធីសាស្ត្រក្នុងកិច្ចការងារផ្សេងៗក្នុងការជួយពង្រឹងសមត្ថភាពរបស់ពួកគេកាន់តែរឹងមាំនិងមានប្រសិទ្ធភាពដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិឱ្យរីកចម្រើនឆាប់រហ័សទៀតផង។ម្យ៉ាងទៀតចំពោះរយៈពេលនៃការអាននេះ គឺមិនបានកំណត់នោះឡើយគេត្រូវអានហើយអានទៀត គឺអានពេញមួយជីវិត ព្រោះអ្វីសុទ្ធតែប្រែប្រួលមិនទៀងទាត់សោះឡើយ។ ក្នុងន័យនេះចង់បញ្ជាក់ថាបើសិនជាយើងមិនប្រព្រឹត្តនូវការអានជាអចិន្ត្រៃយ៍នោះទេ ពេលណាមួយយើងនឹងមានទស្សនៈ ឬការវិភាគយឺតយ៉ាវមិនទាន់បរិបទនៃការវិវឌ្ឍរបស់សង្គមឬការវិវឌ្ឍនៃវិទ្យាសាស្ត្រឡើយ។ ពិសេសជាងនេះទៅទៀតការអានបានបង្កើតគំនិតថ្មីគឺរកឃើញអ្វីដែលថ្មីអាចបម្រើមនុស្សមានសារប្រយោជន៍ដល់សង្គមមនុស្ស និងចេះស្រាយបញ្ហាដែលកើតមានចំពោះមុខទៀតផង។

យ៉ាងណាមិញ បើគេអានរឿងទុំទាវ ពិតជាបានយល់ឬទទួលនូវភាពសុខដុមនៃជីវិត ព្រោះរឿងនេះកវីបានតាក់តែងឡើងក្នុងបំណងឱ្យយើងចេះទាញយកបទពិសោធពីក្នុងជីវិតមួយដែលជាមូលហេតុដែលនាំឱ្យខ្លួនវិនាសដោយសារតែស្នេហា។ ដូចករណីទុំដែលមកតាមនាងទាវនៅត្បូងឃ្មុំដើម្បីយកនាងមករាជវាំងវិញតាមបន្ទូលព្រះរាជាតែទុំបែរជាផឹកស្រាធ្វើឱ្យស្ថានភាពប្រែប្រួលរហូតបង្កឱ្យមានអំពើហិង្សាកើតឡើងភ្លាមៗដោយសារតែខ្លួនមិនបានរិះរកវិធីស្រាយឱ្យបានល្អនោះទេ។ ពេលស្រវឹង«ទុំខិតជិតជួបរូបត្រកងបីហើយថើបផងថាទាវអញទាវអាងទុំប្តីឥតគិតកាញ់[10] ខ្លាចគេចាក់បាញ់ចាញ់នរណា។ ទុំថាមាសបងដងស្រាមកបងផឹកសឹមក្រោកនាំកល្យាណ៍កល្យាណទៅក្រុងគាល់ព្រះមហាក្សត្រាទ្រង់ប្រោស សន្តោសទុក្ខ» គឺទុំផឹកម្តងហើយម្តងទៀតវង្វេងមិនគិតពីប្រពៃណី

[10] កាញ់ (កិ.) គិតខ្មេរដោយពិនិត្យពិច័យ : កាញ់ខ្មេរ, គិតកាញ់ ។

សម័យលង្វែកសោះឡើយ។ ទោះបីទាវជាប្រពន្ធខ្លួនក៏ពិតមែន តែសីលធម៌សង្គមសម័យលង្វែកមិនអាចទទួលយកបានទេនូវភាពស្និទ្ធស្នាលហួសហេតុនៅមុខភ្ញៀវទាំងអស់នោះ។ ការអានមកដល់ត្រឹមវគ្គនេះ យើងនឹងបានយល់ច្បាស់ពីបំណងកវី ចង់រំលឹកអ្នកអានឱ្យចេះគ្រប់គ្រងស្ថានការណ៍នៅចំពោះមុខឧបសគ្គមិនត្រូវយកគ្រឿងស្រវឹងមកដោះស្រាយនោះទេ ព្រោះវាជាគុណវិបត្តិទៅវិញប្រែក្លាយស្ថានភាពល្អទៅជាអាក្រក់។ សមដូចកវីរិះគន់ថា « ស្រឡាញ់ស្នាលស្និទ្ធឥតមានមោះ ទុំស្លាប់នេះខុសពីព្រោះស្រី សម្លាញ់សង្សារនាលោកិយ លោកអើយគប្បីវេះវាងវៀរ»។ ទន្ទឹមនឹងនេះដែរចំពោះអរជូន ម៉ឺនងួន និងម្តាយទាវពោរពេញទៅដោយកំហឹងចំពោះទុំនោះក៏បានបង្ហាញតាមរយៈអំណានក្នុងវគ្គនៃរឿងនេះដែរ។ មានន័យថា មូលហេតុនៃកំហឹងនេះបណ្តាលមកពីលោភៈ ទោសៈនិងមោហៈជាគុណវិបត្តិដ៏ធ្ងន់ធ្ងរបំផុតជាអំពើខុសច្បាប់ អសីលធម៌។ យ៉ាងនេះហើយបានជាម្តាយទាវ ដែលគាត់មានបំណងចង់កែប្រែស្ថានភាពចំពោះមុខនោះគាត់ក៏«ស្រែកថាអរជូនខ្លួនមានបុណ្យមិនគិតកែកុនឆាប់រហ័ស ចាបអាទុំចោរចិត្តមានះ ទាញពីលើផ្ទះទម្លាក់ទៅ។ ហៅអស់ពួកក្រុមនាំវាឆាប់ចាក់បាញ់សម្លាប់កុំឱ្យនៅធ្ងន់ដីធ្ងន់ផ្ទះអប្រិយត្រូវកើតកេរ្តិ៍អាស្រូវឥឡូវហើយ»។ បញ្ហានេះបានជំរុញឱ្យអរជូនហ៊ានចាប់ទុំយកទៅសម្លាប់ ដោយមិនគិតពីអ្វីទាំងអស់ដែលហាក់ដូចជាបង្កផលអាក្រក់ចំពោះខ្លួនឯងទៅវិញ «កាលអើយកាលនោះឯអរជូន ម៉ឺនងួនជាកូនគិតរៀបការបង្កើតអកុសលដល់អាត្មា ឥតមានករុណាមេត្តាទុំ។ ទុក្ខម្នោទោម្នេញក្នាញ់ឆុរឆាវ កន្ត្រាក់បានដាវស្ទុះចូលជុំ ចូលចាក់ចាប់កាក់ឥតជំនុំ ចងទុំក្រញឹតស្លឹតស្លាបសេក»។ លទ្ធផលចុងក្រោយដំណោះស្រាយបែបនេះសុទ្ធតែត្រូវបាត់បង់ជីវិតដោយសារតែពួកគេសុទ្ធតែធ្វើខុសតួនាទីល្មើសព្រះរាជបញ្ជា។ នេះជាស្របជាមួយនេះតាមរយៈការអានអត្ថន័យនៃរឿងខាងលើបានផ្តល់ពុទ្ធិយ៉ាងច្បាស់ថានៅសម័យលង្វែករាស្ត្រខ្មែរនិយមសិល្បៈស្មូតនិងផ្លុំប៉ីណាស់ គឺក្នុងខណៈដែលទុំនិងពេជ្របានយកតោកទៅដូរជាស្រូវនៅត្បូងឃ្មុំ មានអ្នកភូមិជាច្រើនបាននិមន្តទុំឱ្យទៅស្មូតនៅផ្ទះរបស់ខ្លួន។ ម៉្យាងទៀតដោយសារតែវិស័យសិល្បៈនេះហើយ ទើបអ្នកទាំងពីរមានបុណ្យសក្តិអាចធ្វើការក្នុងព្រះរាជវាំងបាន គឺទុំទទួលងារជាម៉ឺនឯកដែលនាំមកនូវកិត្តិយស សុភមង្គលក្នុងជីវិតគឺនាំឱ្យជីវិតខ្លួនមានន័យទៀតផង។ ចំណែកវិស័យជំនឿវិញ ដែលជាផ្នែកមួយនៃវប្បធម៌ ហើយក៏ជាព្រលឹងរបស់ជនជាតិខ្មែរដែរនោះក៏បានបង្ហាញថា ខ្មែរយើងតែងមានជំនឿទៅលើកម្មផលឬមន្តអាគមផ្សេងៗ ហើយពេលខ្លះ គេក៏ជឿលើការទស្សន៍ទាយផងដែរ។ ដូចជាក្នុងបំណងចង់លាចាកសិក្ខាបទទុំត្រូវបានលោកគ្រូបានធ្វើការបន្ទច់បង្អាក់ដោយការទស្សន៍ទាយជាមុនទៅឃើញថា «អញវាយលេខលុបគ្រប់ជើងហារលេខឆ្លើយឡើងថាអាកុំពារ កុំពុះទម្លុះក្រែង វេទនា ឃើញជានេនពេជ្រគេចគ្រាន់បើ។នេនពេជ្រអាចសឹកចុះខែបុស្សបាន ទុំឯងឈប់ខានទើបប្រសើរ ចាំដល់ពិសាខសិនសឹមដើរ សឹកហើយត្រូវលើកបានជាធំ»។ ហេតុផលនេះ ជាក្តីមេត្តារបស់លោកគ្រូចំពោះសិស្សដូចរូបទុំព្រោះលោកមិនចង់ឃើញជោគវាសនា សិស្សរបស់លោកស្ថិតក្នុងស្ថានភាពមិនល្អ នោះទេ តែទុំមិនយល់នៅតែមានះលួចសឹក។ ការអានមកដល់ចំណុចនេះ ខ្លឹមសាររឿងចង់អប់រំឱ្យយើង ដឹងថាក្នុងនាមជាសិស្សគប្បីចេះស្តាប់តាមឱវាទគ្រូ ព្រោះទឹកចិត្តគ្រូចង់ឱ្យសិស្សមានអនាគត ហើយបើសិស្សបានទទួយកឱវាទយកមកអនុវត្តហើយ គេនឹងមានភាពរុងរឿងជាមិនខាន តែទុំមិនយល់ពីបំណាងនេះឡើយ។

ក្នុងវគ្គមួយទៀត ក្រោយពីទុំបានទទួលគ្រឿងបរិក្ខារទុំក៏«...ឈប់អង់បន្តិចសេកប្រេងម្សៅរំលឹកដល់ទៅមន្តសារិកា។ លិនថោងករវីករំលឹករក សិម្ពលីហៅយកមណីចិន្តា»។ តាមផ្នត់គំនិតខ្មែរគេជឿថា សារិកា លិនថោង ករវីក សិម្ពលី មណីចិន្តា ជាឈ្មោះអាគមមេស្នេហ៍ដែលមាននៅក្នុងគម្ពីរអថវវេទ

មានក្នុងសាសនាព្រាហ្មណ៍ដើម្បីដាក់បន្ទន់ចិត្តលើបុគ្គលណាម្នាក់។ ដូច្នេះនេនទុំប្រព្រឹត្តបែបនេះអាចជាទម្លាប់ព្រះសង្ឃនាសម័យនោះតែងសែកប្រេងម្សៅទៅលើគ្រឿងបរិក្ខារ ឬមួយជាចេតនារបស់ទុំ។ បើសិនជាចេតនាវិញនោះបានឆ្លុះបញ្ចាំងឱ្យឃើញថាបុគ្គលម្នាក់ៗដែលមានបំណងណាមួយដែលខ្លួនចង់បានហើយតែងតែមិនគិតពីការប្រព្រឹត្តរបស់ខ្លួននោះឡើយ ទោះតាមវិធីណាក៏ដោយ ក៏ខ្លួនហ៊ានប្រព្រឹត្តដែរ។ គំនិតរបស់រឿងចងអប់រំថាក្នុងនាមជាមនុស្សត្រូវចេះពិចារណាគប្បីនឹងសម្បជញ្ញៈខ្លួនមិនត្រូវធ្វើអ្វីដែលមិនត្រឹមត្រូវនោះទេ គឺត្រូវស្គាល់ពីនាទីរបស់ខ្លួន។ បើសិនជាបុគ្គលប្រកាន់បានដូចគំនិតអប់រំនេះ គេនឹងរស់នៅដោយគ្មានការក្រែងរអែងចិត្តពីអ្នកដទៃឬពីខ្លួនឯងនោះឡើយ។ ជាមួយខ្លឹមសាររឿងដដែលនេះ កវីក៏បានបង្ហាញយ៉ាងច្បាស់ថា ក្នុងពេលដែលទុំកំពុងតែងប់ងល់នឹងស្នេហាចំពោះទាវនិងមានបំណងចង់ចាកសិក្ខាបទនោះ ក៏បានចោទប្រកាន់ថាសេចក្តីស្នេហារបស់ខ្លួនចំពោះនាងទាវកើតមកពីកម្ម។ ដូចទុំបានពោលថា «មិនស្តាយផ្នួសប្រាណបានប៉ុនសក់កម្មមកកញ្ឆក់ឱ្យងងឹត មោហ៍បាំងឆ្នាំងគ្របក្រសោបរឹតគ្មានគិតគ្មានគួរលោកគ្រូខ្វាល់»។ ទុំមានឥរិយាបថបែបនេះ គឺគ្រាន់តែជាឥរិយាបថមួយក្នុងការលួងលោមអារម្មណ៍ខ្លួននិងដើម្បីសម្រេចចិត្តចាកសិក្ខាបទឱ្យបានរហ័សតែប៉ុណ្ណោះ ព្រោះទុំជាសិស្សល្អរបស់លោកគ្រូ តែពេលនេះក្តីស្រឡាញ់ចូលមកក្នុងចិត្តទុំ និងបានធ្វើឱ្យវង្វេងគិតអ្វីៗលែងយល់ មិនស្តាយបព្វជ្ជា[11] ដែលបានសន្សំមកន្លមកនោះឡើយ។ ដូច្នេះយើងអាចវិភាគបានថាកម្មឬមិនកម្មអាស្រ័យបុគ្គលជាអ្នកប្រព្រឹត្ត ហើយបុគ្គលមិនគួរលុះដោយក្តីស្រឡាញ់ហួសហេតុពេកនោះទេ ដែលនាំឱ្យខ្លួនបាត់បង់វិចារណៈបែបនេះ។ ដូច្នេះមានតែវិធីមួយប៉ុណ្ណោះ គឺទុំគួរតែកាត់បន្ថយចំណង់ឱ្យបានដែលក្នុងទ្រឹស្តីព្រះពុទ្ធសាសនាចែងថា ទុក្ខបណ្តាលមកពីតណ្ហាឬចំណង់។

ស្របជាមួយនេះដែរតាមរយៈការអានអក្សរសិល្ប៍ពុទ្ធនិយម ក៏បានបណ្តុះនូវទម្លាប់ចិត្តគំនិតឱ្យចេះកាត់បន្ថយនូវលោភៈទោសៈមោហៈឬភាពទ្រឹស្តិស្នរជាដើម។ តួយ៉ាងតាមរយៈតួអង្គព្រះវេស្សន្តរ ក្នុងរឿងមហាវេស្សន្តរជាតក ព្រះអង្គមិនសោកស្តាយនឹងរាជបល្ល័ង្ក ហ៊ានលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីស្វែងរកធម៌ក្នុងបំណងជួយស្រោយស្រង់ជីវិតមនុស្សឱ្យយល់ពីជីវិតឆ្លងផុតអវិជ្ជា ហើយបញ្ជាក់ថាតណ្ហាជាមូលហេតុនៃទុក្ខ។ សមដូចអ្នកស្រុកស្រីពិរាស្ត្រដោយសារតែសេចក្តីវង្វេងនូវតណ្ហានេះហើយ  ទើបចង់រស់តែឯងមិនគិតពីភាពក្រខ្សត់របស់អ្នកស្រុកកលិង្គរាស្ត្រ ដែលកំពុងប្រឈមនឹងភាពខ្វះខាត។ ហេតុដូច្នេះហើយបានជាព្រះអង្គប្រទានដំរីបច្ច័យនាគេន្ទ្រ ដល់ពួកព្រាហ្មណ៍ឱ្យមានភាពសម្បូរសប្បាយ ព្រោះដំរីនេះតំណាងឱ្យមង្គលនាំមកទឹកភ្លៀងអាចប្រកបការងារស្រែចំការបាន។  មួយវិញទៀត ពិភពលោកទាំងមូលតែងតែបង្កើនចំណងសហការគ្នាក្នុងផ្លូវមនុស្សធម៌នេះដែរ គឺចែករំលែកបទពិសោធឬអំណោយផ្សេងៗ ដើម្បីមនុស្សទាំងអស់រស់ក្នុងសន្តិភាពគ្មានសង្គ្រាម។

ម្យ៉ាងទៀតការអានក៏បានឱ្យយើងយល់ពីក្តីស្រឡាញ់ពិតប្រាកដ ដោយការលះបង់ផលប្រយោជន៍ខ្លួនដើម្បីគ្រួសារនិងសង្គមជាតិទៀតផង។ដូចជាព្រះរាមក្នុងរឿងរាមកេរ្តិ៍បើគិតទៅតាមប្រពៃណីក្សត្រឬតាមវិចារណៈព្រះអង្គជាក្សត្រច្បងមានសិទ្ធិគ្រងរាជ្យមុនក្សត្រប្អូន តែបើយោលទៅតាមពាក្យសត្យវាងបិតាទ្រង់និងនាងកៃកេសីឬសញ្ញាតនាវិញ ព្រះអង្គត្រូវទុករាជ្យបល្ល័ង្កឱ្យព្រះភិរុត

[11] បព្វជ្ជា  ប័ប-ព័ច-ជា   បា.; សំ.   ( ន. )  (ប្រវ្ជ្យា) ការបួស, ផ្នួស : សូមបព្វជ្ជា គឺសូមផ្នួស; ឲ្យបព្វជ្ជា គឺបំបួស (ឲ្យបានជាសាមណេរ) : បានបំពេញបព្វជ្ជា ឬ បានទទួលបព្វជ្ជា ពីថ្ងៃ ... (កុំប្រើថា បានបព្វជ្ជា ...) ។

ជាព្រះអនុជគ្រងរាជ្យមុនទ្រង់ជាក្សត្រច្បងទៅវិញ។ ខ្លឹមសារត្រង់ចំណុចនេះ កវីហាក់ដូចជាចង់ក្រើនរំឭកថា ក្នុងនាមជាកូនគប្បីប្រកាន់ភាពកតញ្ញូចំពោះអ្នកមានគុណ ចេះដោះស្រាយបញ្ហាបានល្អ។ ទន្ទឹមនឹងនេះ ទ្រង់ក៏ជាម្ចាស់បងដ៏ល្អដែលមានគុណធម៌ ហ៊ានធ្វើសម្បទានដល់ប្អូននូវអ្វីដែលល្អដល់ប្អូនដែរ។ រីឯខ្លឹមសារសំខាន់មួយទៀតនោះគឺចង់បញ្ជាក់បន្ថែមថាក្នុងនាមជាអ្នកដឹកនាំព្រះអង្គហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួន គឺដើម្បីផលប្រយោជន៍ប្រជារាស្ត្រទូទាំងនគរ ព្រោះសង្គ្រាមបង្ហូរឈាមនឹងកើតមានឡើងរវាងអ្នកគាំទ្រខាងព្រះអង្គនិងអ្នកគាំទ្រខាងព្រះនាងកែកេសី បើសិនជាព្រះអង្គមិនយាងចេញពីនគរទេ។ ដូច្នេះគុណប្រយោជន៍នៃការអានស្នាដៃនេះពិតជាមានតម្លៃស្ថិតនៅត្រង់ថា រាល់ដំណោះស្រាយទំនាស់គប្បីប្រកាន់យកអហិង្សា ដែលនាំមកនូវសុភមង្គលក្នុងគ្រួសារ និងសង្គមជាតិ។

សរុបសេចក្តីមក ការអាន គឺដើម្បីភាពសុខដុមនៃជីវិតប្រាកដមែន ហើយអានកាន់តែច្រើនជីវិតកាន់តែជោគជ័យ។

ឆ្លងតាមការបកស្រាយខាងលើនេះបានបង្ហាញឱ្យឃើញថា ទស្សនៈប្រធានមានអត្ថន័យជ្រាលជ្រៅ ព្រោះបានទទួលស្គាល់ការពិតនៃការអភិវឌ្ឍសមត្ថភាពបុគ្គលតាមរយៈការអាន។ ដូច្នេះក្នុងនាមជាអ្នកសិក្សាយើងគប្បីចេះឆ្លៀតយកពេលវេលាមួយយ៉ាងសមស្របមកអានសៀវភៅជាប្រចាំដើម្បីតាមដានព័ត៌មានថ្មីដែលតែងកើតមានឡើងជាប្រចាំក្នុងពិភពលោក និងទាញយកប្រយោជន៍ពីការអាននោះទៀតផង។

▪ **កំណត់សម្គាល់ (ប្រធានអត្ថាធិប្បាយពន្យល់)**

**លំនាំសំណេរល្អ** ក្នុងសេចក្តីអធិប្បាយខាងលើនេះត្រូវះ

- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី១ លំនាំបញ្ហា
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី២ ចំណោទបញ្ហា
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៣ ឃ្លាភ្ជាប់សេចក្តី
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៤ បកស្រាយប្រធាន
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៥ សរុបសេចក្តី
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៦ វាយតម្លៃប្រធាន
- ✓ **បកស្រាយប្រធាន** អាចចុះបន្ទាត់ច្រើនដងអាស្រ័យលើការបកស្រាយគំនិតសំខាន់ក្នុងប្រធានតែងសេចក្តីនោះមានតិច ឬមានច្រើន គឺក្នុងមួយកថាខណ្ឌមានគំនិតសំខាន់មួយ និងភ្ជាប់ឧទាហរណ៍ ឬសេចក្តីលម្អិត។

## ៨.២- ប្រធានពិភាក្សា (ក្នុងរឿងព្រះវេស្សន្តរ)

ប្រធាន: មតិខ្លះយល់ថា «ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយ អត្តទត្ថភាព»។ ចូរពិភាក្សា ដោយរកឧទាហរណ៍ក្នុងរឿងព្រះវេស្សន្តរមកបញ្ជាក់។

### សេចក្តីអធិប្បាយ

ក្នុងរឿងព្រះវេស្សន្តរបានបង្ហាញពីការធ្វើទានដ៏អស្ចារ្យរបស់ព្រះពោធិសត្វនៅជាតិទីដប់គឺទ្រង់ធ្វើទានទាំងគ្មានវិញ្ញាណនិងទាំងទានមានវិញ្ញាណដើម្បីបានត្រាស់ដឹងដោយឥតស្តាយស្រណោះអ្វីឡើយ។ ដោយសង្កេតឃើញពីឥរិយាបថនៃការធ្វើទានរបស់ព្រះពោធិសត្វដូចខាងលើនេះហើយទើបនាំឱ្យមានមតិខ្លះយល់ថា«ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយ អត្តទត្ថភាព»។

តើមតិខាងលើនេះ ត្រឹមត្រូវឬទេ ?

ជាជំនួយដល់ការវែកញែក មតិប្រធានខាងលើឱ្យកាន់តែក្បោះក្បាយថែមទៀត យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។ ពាក្យថា «ទាន» នៅពេលនេះ គឺសំដៅទៅលើអំណោយឬការឱ្យអ្វីមួយទៅស្មូមយាចកណាម្នាក់។ ចំណែក «អត្តទត្ថភាព» ជាភាពដែលគិតតែពីផលប្រយោជន៍បុគ្គលខ្លួនឯងជាធំ។ ដូច្នេះតាមមតិប្រធានខាងលើមានន័យថា ការធ្វើអំណោយរបស់តួអង្គព្រះវេស្សន្តរជាការធ្វើអំណោយ ដោយការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនជាធំ លើសអ្វីៗទាំងអស់។

ជាការពិតណាស់ បើយើងធ្វើការសិក្សាពីការធ្វើទានរបស់ព្រះវេស្សន្តរក្នុងជាតិទីដប់នេះពិតជាបានឃើញថាការធ្វើទានរបស់ព្រះអង្គប្រព្រឹត្តទៅនេះមានអត្តទត្ថភាព គឺមានច្រើនបែបច្រើនយ៉ាង។ ចំពោះការធ្វើទាននោះ គេឃើញមានទាំងរបស់គ្មានវិញ្ញាណនិងទាំងមានវិញ្ញាណ។ ជាក់ស្តែងព្រះអង្គបានធ្វើការបរិច្ចាគដំរីបច្ច័យនាគេន្ទ្រឱ្យជាទានដល់ព្រាហ្មណ៍ដែលជាដំរីតំណាងឱ្យភាពសម្បូរសប្បាយរបស់ព្រះនគរក៏ទ្រង់ហ៊ានធ្វើដោយពុំមានការឆ្លងយោបល់ពីប្រជានុរាស្ត្រក្នុងនគរទ្រង់ឡើយ។ ទង្វើបែបនេះហាក់ដូចជាប្រមាថចំពោះប្រជារាស្ត្របណ្តាលជាហេតុនាំឱ្យអ្នកស្រុកស្រីពិរាស្ត្រនាំគ្នាមកស្នើសុំឱ្យព្រះបាទស្រីសញ្ជ័យឱ្យបំបរបង់ព្រះវេស្សន្តរចេញពីនគរ ដើម្បីជាការព្រមានក្នុងការសម្រេចព្រះទ័យដាក់ទានបែបនេះ។ រីឯការធ្វើសត្តសតកមហាទានដែលជាទានដ៏អស្ចារ្យនោះវិញ ក៏ព្រះអង្គធ្វើឡើងដើម្បីតែទ្រង់ដែរ ព្រោះនៅមុនពេលយាងចេញពីនគរឆ្ពោះទៅគិរីវង្កត ព្រះអង្គបានធ្វើការបរិច្ចាគដ៏ធំមួយដែលពុំធ្លាប់មានសោះឡើយលើលោកយើងនេះគឺជាទានដែលមួយមុខៗមានចំនួនប្រាំពីររយ សរុបចំនួនសែសិបប្រាំបួនមុខ។ នេះគឺជាធនបរិច្ចាគដែលជាទ្រព្យសម្បត្តិរបស់ព្រះនគរ ត្រូវចំណាយអស់ទ្រព្យយ៉ាងច្រើនជាងគេ។ ចំពោះបុត្តបរិច្ចាគវិញ ព្រះវេស្សន្តរក៏ហ៊ានលះបង់ដោយឥតស្តាយស្រណោះដែរ គឺហ៊ានលះបង់កូនជាទីស្រឡាញ់ឱ្យទៅជូជកព្រាហ្មណ៍ដ៏កំណាចដែលបានវាយដំរាជកុមារទាំងពីរនៅចំពោះព្រះភក្ត្រទ្រង់ ក៏ទ្រង់បែរជាអង្វររាជបុត្រទាំងបង្ខំឱ្យទៅតាមជូជកទាល់តែបាន។ ក្នុងករណីនេះព្រះអង្គហាក់ដូចជាបាត់បង់ព្រហ្មវិហារធម៌ចំពោះបុត្រឱ្យតែបានសម្រេចតាមបំណងទ្រង់ក្នុងការត្រាស់ដឹងព្រះអង្គហ៊ានធ្វើទាំងអស់។ ជាងនេះទៅទៀត ព្រះអង្គបានក៏បានកុហកនាងមទ្រីក្នុងការធ្វើបុត្តបរិច្ចាគ ពេលនាងមកពីបេះផ្លែឈើវិញរករាជកុមារទាំងពីរពុំឃើញ។ ព្រះអង្គក៏បង្វែរចោទប្រកាន់ទៅនាងមទ្រីថាទៅសហាយស្មន់ទើបមកដល់អាស្រមទាំងយប់បែបនេះទៅវិញ។ ព្រះអង្គយកនាងដែលជាមហេសីពេញច្បាប់និងដ៏

ល្អទៅធ្វើជាអ្នកបម្រើឥន្ទព្រាហ្មណ៍ ទោះបីព្រះនាងបានជួយទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាបុត្រាបុត្រីនិងតស៊ូទ្រាំទ្រការលំបាកជាមួយទ្រង់យ៉ាងណាក៏ទ្រង់នៅតែដាច់ចិត្តដោយប្រើមនោសញ្ចេតនាជាប្តីប្រពន្ធមកបំពេញ តាមសំណូមពរទ្រង់ទៅវិញ។

សរុបមក ការធ្វើទានរបស់ព្រះវេស្សន្តរ គឺពិតជាការដាក់ទានដោយអត្តទត្ថភាពប្រាកដមែន។

តើការធ្វើទាននេះ ពិតជាការដាក់ទានដោយអត្តទត្ថភាព ឬក៏ក្នុងន័យអ្វីផ្សេងទៀត?

ផ្ទុយទៅវិញការធ្វើទានរបស់ព្រះវេស្សន្តរ មិនមែនជាការដាក់ទានដោយអត្តទត្ថភាពនោះទេ ព្រោះការលះបង់របស់ព្រះអង្គក្នុងបំណងជួយស្រោចស្រង់ជីវិតមនុស្សឱ្យរួចផុតពីអវិជ្ជា។ ចំពោះអត្ថន័យនៃការធ្វើទាននេះព្រះវេស្សន្តរមានបំណងស្វែងរកធម៌ត្រាស់ដឹងក្នុងការជួយដល់មនុស្សសត្វទាំងឡាយឱ្យយល់ពីជីវិតឆ្លងផុតអវិជ្ជាបញ្ជាក់ថាតណ្ហាជាមូលហេតុនៃទុក្ខ។ សមដូចករណីអ្នកស្រុកស្រីពិរាស្ត្រដោយមូលហេតុនៃសេចក្តីវង្វេង ព្រោះតណ្ហានេះហើយទើបចង់រស់តែឯងមិនគិតពីភាពក្រខ្សត់របស់អ្នកស្រុកកលិង្គរាស្ត្រដែលកំពុងប្រឈមនឹងភាពខ្វះខាត។ ហេតុដូច្នេះហើយបានជាពិភពលោកទាំងមូលតែងតែបង្កើនចំណងសហការគ្នារួមគ្នាចែករំលែកបទពិសោធអំណោយជាស្បៀងអាហារក្នុងផ្លូវមនុស្សធម៌ដើម្បីរស់ក្នុងសន្តិភាព។ម្យ៉ាងទៀត ទ្រង់ស្វែងរកធម៌ដែលជាមូលហេតុនៃទុក្ខក្នុងនោះមានចតុរារិយសច្ចៈឬអរិយសច្ចៈបួនដែលមានទុក្ខអរិយសច្ចៈសមុទយអរិយសច្ចៈ និរោធអរិយសច្ចៈ និងមគ្គអរិយសច្ចៈជួយជាប្រយោជន៍ដល់សង្គមមនុស្ស។ ចំណែកការធ្វើទានរបស់ព្រះអង្គវិញ ជាការធ្វើទានដោយសុទ្ធចិត្តឥតបង្ខំ ធនបរិច្ចាគ បុត្តបរិច្ចាគ និងភរិយាបរិច្ចាគក្តី។ តួយ៉ាងការធ្វើធនបរិច្ចាគ ក្រោយពីបិតាបានប្រទានទ្រព្យធនទាំងនោះ គឺមុនពេលព្រះអង្គយាងចូលព្រៃគិរីវង្កត ព្រោះអង្គមិនចង់បានអ្វីក្រៅពីការស្វែងរកធម៌តែប៉ុណ្ណោះ។ ហេតុនេះហើយបាន ជាព្រះអង្គដាក់ទានទាល់ តែអស់ហើយសុខចិត្តយាងចេញទៅដោយថ្មើរជើង។ ការធ្វើបុត្តបរិច្ចាគក៏សុទ្ធតែជាការស្ម័គ្រចិត្តដាក់ខ្លួនជាទាន ព្រោះនៅចំពោះមុខព្រះបាទស្រីសញ្ជ័យ ព្រះនាងសុបារសុប្បតី សេនាបតី និងរាជអាមាត្យ ជាលី និងក្រស្នាសុទ្ធតែអះអាងថាខ្លួនមកតាមជូជក គឺបិតាឥតបានបង្ខំទេ រាជកុមារមកដោយការពេញព្រះទ័យ។ ការធ្វើភរិយាបរិច្ចាគជាការពេញចិត្ត ព្រោះនាងមទ្រីបានថ្លែងនៅចំពោះព្រះភក្ត្រព្រះវេស្សន្តរ និងឥន្ទព្រាហ្មណ៍ថា កុំថាឡើយដាក់ទានរូបកាយ ទោះបីព្រាហ្មណ៍នោះប្រាថ្នាសាច់ ថ្លើម ដង្ហើម ប្រមាត់ក៏ព្រះនាងយល់ព្រមឱ្យព្រះអង្គយកព្រះខ័នមកកាត់ដើម្បី បំពេញទានបារមីនោះដែរ។

សរុបមកការធ្វើទានរបស់ព្រះវេស្សន្តរមិនមែនជាការដាក់ទានដោយអត្តទត្ថភាពនោះទេដើម្បីប្រយោជន៍មនុស្សទូទៅពិតប្រាកដ។

ជារួមការយល់ឃើញថា ការធ្វើទានរបស់ព្រះវេស្សន្តរ គឺជាការដាក់ទានដោយអត្តទត្ថភាពមិនត្រឹមត្រូវទេ ព្រោះព្រះអង្គលះបង់អ្វីៗគ្រប់យ៉ាងក៏ដើម្បីប្រយោជន៍មនុស្សទូទៅ។ ការលះបង់បែបនេះពិតជាកម្រ និងពិបាកក្នុងការលះបង់ តែជាគំរូដល់មនុស្សផងទាំងឡាយឱ្យចេះអត់ធ្មត់ដោយការបំពេញទាន ចេះអធ្យាស្រ័យ មិនប្រើស្ថិតនៅក្រោមលោភៈ ទោសៈ មោហៈ ដែលនាំទៅរកទុក្ខនោះឡើយ។ ម្យ៉ាងវិញទៀតទង្វើទ្រង់បែបនេះហើយដែលបច្ចុប្បន្នត្រូវបានគេយកមកអនុវត្តក្នុងផ្លូវមនុស្សធម៌ទូទាំងសកលលោកទៀតផង។

ឆ្លងតាមការបកស្រាយខាងលើនេះបង្ហាញថា មតិប្រធានមិនត្រឹមត្រូវទេជាគំនិតចង្អៀតចង្អល់ មិនយល់ច្បាស់ពីឧត្តមគតិ និងទ្រឹស្ដីសាសនាព្រះពុទ្ធពិតប្រាកដ។តែទោះជាយ៉ាងណាក៏ដោយ ក៏មតិនេះចាត់ទុកជាបទពិសោធក្នុងការអប់រំ អ្នកអានឱ្យយល់កាន់តែច្បាស់ពីគោលបំណងនៃតួអង្គព្រះវេស្សន្តរដែលជាពោធិសត្វក្នុងទសជាតកនេះពិតប្រាកដ ។

- **កំណត់សម្គាល់ (ប្រធានអត្ថាធិប្បាយពិភាក្សាសុទ្ធ និងប្រៀបធៀប)**

**លំនាំសំណេរល្អ** ក្នុងសេចក្ដីអធិប្បាយខាងលើនេះត្រូវះ

- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី១ លំនាំបញ្ហា
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី២ ចំណោទបញ្ហា
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី៣ ឃ្លាភ្ជាប់សេចក្ដី
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី៤ **មតិស្រប** **(មតិទី១)**
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី៥ សរុបមតិស្រប (សរុបមតិទី១)
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី៦ សំណួរភ្ជាប់សេចក្ដី (បើចាំបាច់)
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី៧ មតិផ្ទុយ (មតិទី២)
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី៨ សរុបមតិផ្ទុយ (សរុបមតិទី២)
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី៩ សំយោគ ឬពិភាក្សា (មតិរួម)
- ✓ ចុះបន្ទាត់ចាប់ផ្ដើមបន្ទាត់ទី១០ **វាយតម្លៃប្រធាន**
- ✓ **មតិស្រប**(មតិទី១) និង**មតិផ្ទុយ**(មតិទី២) អាចចុះបន្ទាត់ច្រើនដងអាស្រ័យលើការបកស្រាយគំនិតសំខាន់ក្នុងប្រធានតែងសេចក្ដីនោះ ដែលតម្រូវឱ្យលើកឧទាហរណ៍មកបញ្ជាក់ដែលមានក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍។

## ៨.៣- ប្រធានប្រៀបធៀប (ក្នុងរឿងរាមកេរ្តិ៍)

ប្រធានៈ ចូរអ្នកធ្វើការប្រៀបធៀបសេចក្ដីស្នេហារបស់ព្រះរាមនិងស្នេហារបស់ក្រុងរាពណ៍ដែលមានចំពោះនាងសីតា។ តើសេចក្ដីស្នេហាទាំងពីរខាងលើនេះមានចំណុចដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

### សេចក្ដីអធិប្បាយ

មនុស្សគ្រប់រូប ដែលបានចាប់បដិសន្ធិលើលោកិយសន្និវាសយើងនេះតែងតែមានសេចក្ដីស្នេហាជាចាំបាច់ ប៉ុន្តែសេចក្ដីស្នេហាទាំងនោះ ពុំមានលក្ខណៈដូចគ្នាទាំងស្រុងទេគឺស្នេហាខ្លះកើតចេញពីការបង្ខិតបង្ខំ ហើយស្នេហាខ្លះទៀត កើតចេញពីចិត្តនិងចិត្តពិតប្រាកដ។ រីឯរឿងរាមកេរ្តិ៍ខ្មែរវិញ បុព្វកវីនិពន្ធយើងក៏បានបង្ហាញពីសេចក្ដីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍ដែលមានចិត្តស្រឡាញ់នាងសីតាតែម្នាក់ដូចគ្នាដែរ។

តើស្នេហារបស់តួអង្គទាំងពីរខាងលើនេះមានចំណុចដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

ជាបឋមនៃការប្រៀបធៀបសេចក្ដីស្នេហារបស់តួអង្គទាំងពីរខាងលើនេះ យើងគប្បីពន្យល់ពាក្យ «ស្នេហា» ជាមុនសិន។ ពាក្យ «ស្នេហា» គឺសំដៅទៅលើការស្រឡាញ់ដកចិត្តមិនរួចចំពោះអ្វីមួយ ហើយធ្វើឱ្យមនុស្សបានសុខផងនិងបានទុក្ខផង។ ដូច្នេះគំនិតតម្រូវឱ្យយើងបង្ហាញពីចំណុច

ដូចគ្នានិងចំណុចខុសគ្នានៃក្តីស្រឡាញ់របស់ព្រះរាមនិងក្រុងរាពណ៍ ដែលមានចំពោះនាងសីតាតែម្នាក់ដូចគ្នា។

បើយើងធ្វើការសិក្សារឿងរាមកេរ្តិ៍ខ្មែរ ពិតជាបានឃើញថា ក្នុងស្នាដៃនេះកវីបានផ្សារភ្ជាប់បញ្ហាសំខាន់ទៅនឹងសេចក្តីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍ដែលមានចំពោះនាងសីតាដូចគ្នា ហើយបង្កជាសង្គ្រាមដ៏រ៉ាំរ៉ៃទៀតផង។ មានន័យថា ស្នេហានេះជាស្នេហាបុរសពីរនាក់តែស្រឡាញ់ស្រីម្នាក់។ ជាក់ស្តែងតួអង្គទាំងពីរនេះសុទ្ធតែតស៊ូចំពោះឧបសគ្គដូចគ្នា គឺព្រះរាមបានឆ្លងកាត់ការលំបាកជាច្រើនគ្រប់យ៉ាង ដើម្បីរិះរកវិធីរំដោះនាងសីតាក្រោយពេលក្រុងរាពណ៍ចាប់យកទៅឬការពារនាងសីតា។ ដូចជាទ្រង់បានដឹកនាំធ្វើសង្គ្រាមជាច្រើនលើកជាច្រើនសារនិងរកកងទ័ពជំនួយដែលមានទ័ពស្វាជាដើម។ ឯក្រុងរាពណ៍វិញក៏រិះរកនិងប្រើប្រាស់យុទ្ធវិធីគ្រប់យ៉ាងដើម្បីការពារនាងសីតារក្សានាងទុកធ្វើជាមហេសី។ ដោយក្រុងរាពណ៍បានរៀបចំទ័ពប្រយុទ្ធដោយខ្លួនឯងតាមវិធីសង្គ្រាមផ្តាច់ស្បៀង សង្គ្រាមចិត្តសាស្ត្រ ព្រមទាំងវិធីដទៃទៀត។ លើសពីនេះទៀត អ្នកទាំងពីរមានបំណងរួមរស់ជាមួយសីតាទៅអនាគត ដោយចាត់ទុកនាងសីតាជាមហេសីពេញលក្ខណៈទៀតផង។ ប៉ុន្តែនៅទីបំផុតទាំងព្រះរាម និងទាំងក្រុងរាពណ៍ សុទ្ធតែខក បំណងដូចគ្នា ព្រោះពួកគេមិនបានរួមរស់ជាមួយនាងសីតាដូចការគ្រោងទុកនោះឡើយ។ ហេតុផលនេះគឺបណ្តាលមកពីព្រះរាមមានការប្រច័ណ្ឌទៅលើនាងសីតា ហើយនាងក៏គៀសព្រះកាយទៅឋានភុជង្គនាគចោលព្រះអង្គជារៀងរហូត។ រីឯក្រុងរាពណ៍វិញ ក៏ត្រូវស្លាប់ក្នុងសង្គ្រាមរវាងខ្លួននិងព្រះរាម។

សរុបសេចក្តីមក ចំណុចខាងលើនេះជាលក្ខណៈដូចគ្នានៃសេចក្តីស្នេហារបស់ព្រះរាម និងសេចក្តីស្នេហារបស់ក្រុងរាពណ៍ដែលមានចំពោះនាងសីតា។

ដោយឡែក ចំពោះលក្ខណៈខុសគ្នាវិញនៃសេចក្តីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍ដែលមានចំពោះនាងសីតាបានឱ្យឃើញថា មានចំណុចខុសគ្នាជាច្រើន។ ជាក់ស្តែងក្នុងរឿងបានបង្ហាញថាព្រះរាមបានរៀបអភិសេកជាមួយនាងសីតាជាមហេសីក៏ដោយសារតែទ្រង់មានសមត្ថភាពលើសគេឯងក្នុងការប្រឡងលើកធ្នូសិល្ប៍ក្នុងចំណោមទេវៈទាំងឡាយនោះដែរ។ ចំណុចនេះចង់បញ្ជាក់ថាព្រះបាទជនកដែលជាបិតាចិញ្ចឹមនាងសីតាបានរៀបការប្រឡងប្រកួតប្រជែងសមត្ថភាពលើកធ្នូសិល្ប៍ដើម្បីជ្រើសរើសធីតុបតីធ្វើជាស្វាមីនាងសីតា។ ធ្នូសិល្ប៍នោះ មានទម្ងន់ស្មើនឹងបុរសមួយពាន់នាក់ទើបអាចលើករួច។ នៅពេលនោះមានតែព្រះរាមទេដែលអាចលើកធ្នូសិល្ប៍នោះបាន ហើយក៏បានទទួលនាងសីតាជាមហេសី និងរៀបចំអភិសេកស្របតាមប្រពៃណីនៅនគរមិថិលានោះទៀតផង។ ម្យ៉ាងទៀតក្នុងសេចក្តីស្នេហានេះ ព្រះរាមនិងនាងសីតាសុទ្ធតែស្រឡាញ់គ្នាទៅវិញទៅមកពោរពេញទៅដោយភក្តីភាពរវាងគ្នានិងគ្នាជានិច្ច។ ដូចជាក្រោយពេលក្រុងរាពណ៍ចាប់យកនាងសីតាទៅព្រះរាមបានយំសោកអាលោះអាល័យចំពោះនាងយ៉ាងខ្លាំង ហើយនាងសីតាវិញ ក៏ខិតខំថែរក្សាការពារខ្លួននៅសួនអសោកមិនឱ្យក្រុងរាពណ៍ចូលមកជិតដើម្បីសុំសេចក្តីស្នេហាពីនាងបានឡើយ។ ទន្ទឹមនឹងនេះ ក្តីស្រឡាញ់របស់អ្នកទាំងពីរជាក្តីស្រឡាញ់តាមធម្មជាតិ គឺតាំងពីវ័យកំលោះនិងក្រមុំមិនមែនលួចលាក់ឬខុសប្រពៃណីនោះទេ។ មួយវិញទៀតទោះបីព្រះរាមស្រឡាញ់នាងសីតាយ៉ាងណាក៏ដោយក៏ព្រះអង្គមិនចេះសរសើរសម្រស់នាងសីតានៅចំពោះមុខដែរ។ ក្រោយពេលបាត់បង់នាង ទើបនឹកឃើញសម្រស់របស់នាងឬលម្អរបស់នាងទៅវិញ។ ជាក់ស្តែងព្រះអង្គ

បានពោលថា «បងចាំកេសីបីខ្មៅញាប់ ប្អូនក្រសោបចាប់ចងចារផ្កា កែម[12] ចូតប្រូតមាលា អស់ផ្កាសារពើភ្ញី។...បងចាំចិញ្ចើមទ្រទ្រូយ បីដូចចង្កួយកៅទ័ណ្ឌជ័យ កោងស្រួលហួតក្រៃកាលនៃព្រះពិស្ណុការ កាន់គូរតម្រង់វាស។...ចាំធ្មេញខ្មៅជិត ដូចអ្នកប្រកិតនិលរតន៍ថ្ងៃ បងគន់សម្គាល់នៃអំបាលរូបជំប្អូនបង។បងចាំសម្បុរប្អូនជិត ក្រៃលែងស្រលិត[13]លឿងខៀវជំអន្លង[14] វាប្លែកសម្បុរនោះដ៏បីដងមួយថ្ងៃផ្សិងៗ[15]បំព្រងទុំ»។ តែដោយមានចិត្តស្រឡាញ់នាងសីតា ដ៏លើសលុបរបស់ព្រះរាមនេះហើយជាហេតុនាំឱ្យព្រះរាមកើតមានចិត្តប្រច័ណ្ឌសីតាជាមួយក្រុងរាពណ៍ ដោយសារផ្ទាំងគំនូរមួយផ្ទាំង ដែលជាល្បិចកល អាតុល័យនាំឱ្យព្រះអង្គដាច់ចិត្តឱ្យព្រះលក្ស្មណ៍យកនាងសីតាទៅសម្លាប់ទាំងមានគភ៌ទៅវិញ។

ចំណែកសេចក្ដីស្នេហាក្រុងរាពណ៍ចំពោះសីតាវិញក៏ឆ្លុះឱ្យឃើញថា ស្នេហានេះកើតឡើងដោយសារតែការសងសឹកជំនួសនាងសូរបនខា និងក្រុងខរជាប្អូនខ្លួន។ក្រុងរាពណ៍មានបំណងចង់ស្ដារកិត្តិយសឡើងវិញ ទើបកើតមានជាក្ដីស្រឡាញ់នេះឡើង។ មិនតែប៉ុណ្ណោះ ស្នេហានេះមិនបានរៀបចំតាមប្រពៃណីទេ គឺក្រុងរាពណ៍បានលួចឆក់សីតាដែលជាមហេសីរបស់ព្រះរាមខុសច្បាប់ ព្រោះក្រុងរាពណ៍បានប្រើវិធីបំបែកព្រះរាមឱ្យចេញពីនាងសីតាដើម្បីទុកឱកាសឱ្យខ្លួនចូលទៅឆក់យកនាងហោះទៅក្រុងលង្កាតែម្ដង។ មួយវិញទៀតក្រុងរាពណ៍មានមហេសីរួចទៅហើយគឺនាងមណ្ឌោគិរី អ្វីដែលខ្លួនប្រព្រឹត្តនៅពេលនេះដើម្បី ផ្ដល់ការឈឺចាប់ចំពោះព្រះរាម និងសីតា។ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុងរាពណ៍មានចិត្តស្រឡាញ់នាងសីតាដែរ ប៉ុន្តែសីតាមិនព្រមស្រឡាញ់ក្រុងរាពណ៍វិញទេ។ មានន័យថា ការស្រឡាញ់របស់ក្រុងរាពណ៍ចំពោះសីតាជាក្ដីស្រឡាញ់ស្ត្រីដែលមានប្ដីហើយ ពុំមែនជាស្នេហារវាងកំលោះនិងក្រមុំនោះទេ។ ក្រុងរាពណ៍ចេះអួតសរសើរសម្រស់នាងសីតានៅចំពោះមុខក្នុងពេលដែលខ្លួនបានឃើញសីតាជាលើកដំបូងនៅអាស្រម បន្ទាប់ពីព្រះរាម ព្រះលក្ស្មណ៍ចេញទៅតាមប្រើសមាសក្លែងក្លាយដែលជាល្បិចកលរបស់ក្រុងរាពណ៍នោះ។ ក្រុងរាពណ៍បានអួតសរសើរនាងថា គេគួរមានភ្នែករាប់សែន អណ្ដាតរាប់លានទើបអាចរៀបរាប់ពីសម្រស់របស់នាងសីតាបានចប់សព្វគ្រប់។សមដូចកវីបានបញ្ជាក់ថា «យល់អញមហាភ័ព្វ មហាបុណ្យបានយល់អង្គ ធ្វើម្ដេចកល់ភ្នែកគិតជ័យង់ មួយសែនសោតនឹងមើលគ្រាន់។ ធ្វើម្ដេចភុលឱស្ឋភុល[16] អណ្ដាតបានមួយសែនពាន់ បងនឹងសរសើរមេរូចន្ទ្រ ដ៏ច្រាលច្រៃនៃវេហាស៍»។

សរុបសេចក្ដីមក ចំណុចខាងលើនេះជាលក្ខណៈខុសគ្នានៃសេចក្ដីស្នេហារបស់ព្រះរាមនិងសេចក្ដី ស្នេហារបស់ក្រុងរាពណ៍ដែលមានចំពោះនាងសីតា។

រួមសេចក្ដីស្នេហារបស់ព្រះរាមនិងក្រុងរាពណ៍សុទ្ធតែមានទឹកស្រឡាញ់សីតាដូចគ្នា។ តែឥរិយាបថនៃក្ដីស្រឡាញ់របស់តួអង្គក្រុងរាពណ៍ កើតចេញពីការបង្ខិតបង្ខំលួចប្រពន្ធអ្នកដទៃគឺប្រើល្បិចកលអាក្រក់ ដោយគំនុំសងសឹកក្នុងចិត្ត។ រីឯឥរិយាបថនៃក្ដីស្រឡាញ់របស់ព្រះរាម ចំពោះសីតាវិញជាក្ដីស្រឡាញ់ តាមបែបមនោសញ្ចេតនា ដ៏ជ្រាលជ្រៅក្នុងទឹកចិត្ត ភក្ដីភាពពិតប្រាកដ។

[12] កែម ( កិ. ) សែម, ថែមឲ្យបានមាំមួន ឬឲ្យសមរម្យឡើង ។

[13] ស្រលិត --លិត ស. ( ន. ) (ប្រើជា សលិត អ. ថ. សះលិត) ឈ្មោះវល្លិឡើងទ្រើងមួយប្រភេទផ្កាជាចង្កោមៗ ក្លិនក្រអូបឈ្ងុយឆ្ងាញ់, ផ្លែទ្រវែងជមចុងដើមវលាទុំស្ងួតបែកជាប៉ុយជាប់នឹងគ្រាប់ ។ ស្រឡិត

[14] អន្លង ( គុ. ) ខៀវឡើងទឹកដមឬឡើងសម្បុររលោង : ខៀវអន្លង ។

[15] ផ្សិង (ម. ព. ផ្សេង) ។

[16] ភុល ( ឧ. ) សូរព្ទដោយបក្សីស្លុះហើរព្រមគ្នា ឬសូរទឹកខ្ពុរចេញជាដើម ។

ឆ្លងតាមការប្រៀបធៀបនេះបានបង្ហាញថា សេចក្តីស្នេហាព្រះរាម ចំពោះសីតាមានលក្ខណៈគាប់ប្រសើរជាងស្នេហារបស់ក្រុងរាពណ៍ចំពោះសីតាដែលចូលចិត្តលួចប្រពន្ធអ្នកដទៃ។ តែទោះជាយ៉ាងនេះក្តី ក៏ព្រះរាមមិននៅតែមិនអាចយកចិត្តនាងសីតាបានដែរ ព្រោះនាងត្រូវឃ្លាតចាកឆ្ងាយពីព្រះអង្គជារៀងរហូត។ ជាងនេះទៀត ថ្វីបើស្នេហាត្រូវតែកើតមានសម្រាប់បុគ្គលម្នាក់ៗក៏ពិតមែន តែគេគប្បីជ្រើសរើសស្នេហាណាមួយដែលកើតចេញពីទឹកចិត្តពិតៗគ្មានការបង្ខិតបង្ខំ ដោយការយោគយល់ និងជឿជាក់គ្នាទៅវិញទៅមកនោះទើបមានសុភមង្គលយូរអង្វែង។

▪ **កំណត់សម្គាល់ (ប្រធានអត្ថាធិប្បាយប្រៀបធៀប)**

**លំនាំសំណេរល្អ** ក្នុងសេចក្តីអធិប្បាយខាងលើនេះត្រូវះ

- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី១ លំនាំបញ្ហា
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី២ **ចំណោទបញ្ហា**
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៣ ឃ្លាភ្ជាប់សេចក្តី
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៤ លក្ខណៈដូចគ្នា
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៥ សរុបលក្ខណៈដូចគ្នា
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៦ លក្ខណៈខុសគ្នារបស់តួអង្គ«ក»[17]
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៧ លក្ខណៈខុសគ្នារបស់តួអង្គ«ខ»
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៨ សរុបលក្ខណៈខុសគ្នា
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី៩ សរុបរួម (លក្ខណៈដូចគ្នា លក្ខណៈខុសគ្នា)
- ✓ ចុះបន្ទាត់ចាប់ផ្តើមបន្ទាត់ទី១០ **វាយតម្លៃប្រធាន**
- ✓ **លក្ខណៈខុសគ្នា** អាចចុះបន្ទាត់ច្រើនដងអាស្រ័យលើការបកស្រាយគំនិតសំខាន់ក្នុងប្រធានតែងសេចក្តីនោះ ដែលបានលើកឧទាហរណ៍មកប្រៀបធៀប។

# ៩- ប្រធានតែងសេចក្តីតាក់តែងដោយលោកគ្រូ អ្នកគ្រូអញ្ជើញមកពីខេត្តនានា

## ៩.១- ប្រធានអត្ថាធិប្បាយពន្យល់

ប្រធានទី១: អត្ថកោវិទម្នាក់ពោលថា «រឿងរាមកេរ្តិ៍ ជារឿងមនុស្សវិទ្យា»។ ចូរបង្ហាញ ដោយលើកតឹកតាងក្នុងរឿងនេះមកបញ្ជាក់។

### គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា:** និយាយពីទាក់ទងកម្មវត្ថុអក្សរសិល្ប៍...
- **ចំណូលបញ្ហា** (បង្ហាញប្រធាន): លើកមតិប្រធានយកមកសរសេរ...
- **ចំណោទបញ្ហា:** ចោទតាមបែបប្រធានពន្យល់...

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់ការបកស្រាយ...

[17] តួអង្គពីរ(ក. និងខ.) វត្ថុពីរ(ក.និងខ.) មតិពីរ(ក.និងខ.) ...

- **ពន្យល់ពាក្យ:** «មនុស្សវិទ្យា» ជាវិជ្ជាសិក្សាពីមនុស្ស...
- **ពន្យល់ន័យ:** មានន័យថា រឿងរាមកេរ្តិ៍ បានសិក្សាពីរឿងរ៉ាវរបស់មនុស្សនៅក្នុងសង្គម...
- **បកស្រាយ:** «រឿងរាមកេរ្តិ៍ ជារឿងមនុស្សវិទ្យា» ព្រោះរឿងនេះ បានសិក្សាពីបញ្ហាដែលកើតមានក្នុងសង្គមមនុស្សដូចជា៖
  - **គំនិតសំខាន់៖**

**ក- នយោបាយក្នុងប្រទេស គឺបង្ហាញពីរចនាសម្ព័ន្ធគ្រប់គ្រងប្រទេសនីមួយៗ៖**

✓ ព្រះបាទទសរថគ្រប់គ្រងនៅនគរឰយុធ្យា
✓ ព្រះបាទជនគ្រប់គ្រងនៅនគរមិថិលា
✓ មហាជម្ពូ គ្រប់គ្រងនៅហេមពាន្តបុរី
✓ ក្រុងរាពណ៍គ្រប់គ្រងនៅនគរលង្កា
✓ ពាលីគ្រប់គ្រងនៅនគរខាស់ខិន។

**ខ- នយោបាយក្រៅប្រទេស គឺបង្ហាញពីទំនាក់ទំនងរវាងនគរមួយទៅនគរមួយទៀត៖**

✓ ព្រះរាមមានទំនាក់ទំនងជាមួយសុគ្រីព
✓ ព្រះរាមមានទំនាក់ទំនងជាមួយមហាជម្ពូ
✓ ក្រុងរាពណ៍មានទំនាក់ទំនងជាមួយមូលផលម័មនៅក្រៅចក្រវាឡ។

**គ- សេដ្ឋកិច្ច**

✓ **កសិកម្ម** ឧទាហរណ៍: ព្រះបាទជនកប្រារព្ធពិធីច្រត់ព្រះនង្គ័ល (បុណ្យវប្បមង្គល)
✓ គមនាគមន៍ ព្រះរាមឱ្យទ័ពស្វាសាងសង់ស្ពានទៅលង្កា។

**ឃ- សង្គមកិច្ច**

✓ សន្តិសុខ
- ឧទាហរណ៍ នគរនីមួយៗមានកងការពារហ្មត់ចត់
- ឧទាហរណ៍ នៅលង្កា មាននាងវិកតាសីឈរយាមនៅមាត់ទ្វារលង្កា...

✓ សុខាភិបាល បង្ហាញពីវិធីផ្សំថ្នាំរបួសដោយប្រើឫសឈើ ឬមើមឈើ...
- ឧទាហរណ៍ ពិភេកព្យាបាររបួសឱ្យព្រះលក្ស្មណ៍

✓ ជីវភាពរស់នៅ ការរស់នៅសុខស្រួលឬមិនសុខស្រួលអាស្រ័យអ្នកដឹកនាំ... ឧទាហរណ៍៖
- នគរហេមពាន្ត មហាជម្ពូចេះស្រាយបញ្ហា នាំឱ្យប្រជារាស្ត្របានសុខសាន្ត
- នគរលង្កា ក្រុងរាពណ៍មិនចេះស្រាយបញ្ហា នាំឱ្យលង្កាវិនាស រាស្ត្ររងទុក្ខ
- នគរខាស់ខិនបុរី សុគ្រីពធ្វើឱ្យរាស្ត្រវេទនា ព្រោះនៅក្រោមអំណាចព្រះរាម

**ង- វប្បធម៌**

✓ ការសិក្សាអប់រំ ការមានការសិក្សាសិល្បវិជ្ជាពីសំណាក់ឥសី... ឧទាហរណ៍ ៖
- ព្រះរាម ព្រះលក្ស្មណ៍បានសិក្សាសិល្បសាស្ត្រជាមួយឥសីពិស្វាមិត្រ
- រាមលក្ស្មណ៍ ជបលក្ស្មណ៍ រៀនសិល្ប៍សាស្ត្រជាមួយឥសីវជ្ជប្រិត
- សាសនាមានការគោរពបូជាសាសនាព្រាហ្មណ៍ គោរពអាទិទេពទេវៈ ព្រះនារាយណ៍ ដែលប្រជារាស្ត្រខ្មែរតែងនិយមគោរពទេវៈទាំងនេះមានជារៀងរហូតតមក។
- ឧទាហរណ៍ ព្រះរាមជាអវតារទីប្រាំពីររបស់ព្រះវិស្ណុ...

✓ ជំនឿ ជឿទៅលើសត្វកុកជាសត្វចង្រៃ សម្តីកុកស្មើនឹងពាក្យបណ្តាសា ឬជាពាក្យផ្តន្ទា។

- ឧទាហរណ៍: ព្រះរាមព្រះលក្ស្មណ៍ស្ទើរតែសម្លាប់សត្វកុកក្នុងពេលធ្វើដំណើរស្វែងរកនាងសីតា ព្រោះជឿថាសត្វកុកនាំមកអពមង្គល។

✓ សត្វកុកគ្រាន់តែហើរឆ្វេលនគរលង្កាបីជុំតែប៉ុណ្ណោះ នគរលង្កាក៏អាចរលាយបានដែរ

✓ ជឿទៅលើសត្វខ្លែងស្រាក ថាជាសត្វចង្រៃ

✓ ទំនៀមទម្លាប់ប្រពៃណីមង្គលការត្រូវប្រព្រឹត្តទៅនៅគេហដ្ឋានខាងស្រីនិងប្រកាន់ពាក្យសត្យ ឧទាហរណ៍៖

- ជ្រើសរើសរាជសុណិសាដែលមានសមត្ថភាព ព្រះរាមប្រឡងលើកធ្នូសិល្ប៍ឈ្នះអស់ទេវៈទាំងឡាយ ទើបបានទទួលសីតាជាមហេសី...
- ព្រះរាមបានរៀនអភិសេកជាមួយនាងសីតានៅនគរមិថិលាតំណាងលំនៅដ្ឋានខាងស្រី...
- ព្រះរាមមិនយាងចូលនគរមុនកាលកំណត់ ព្រោះគោរពពាក្យសត្យជាមួយនាងកៃកេសី សន្យាសាងផ្នួសដប់បួនឆ្នាំ...
- សីតាមិនវិលចូលនគរវិញទេ ដរាបណាព្រះរាមមិនទាន់សុគត...
- **សរុប** : សរុបសេចក្តីមក រឿងរាមកេរ្តិ៍ជារឿងមួយ ដែលលើកយកបញ្ហាមនុស្សមកចោទ និងស្រាយដើម្បីមនុស្សដែលគេអាចនិយាយបានថា រឿងនេះជារឿងមនុស្សវិទ្យាប្រាកដមែន។

## គ- បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន**: ទស្សនៈប្រធានពិតជាមានអត្ថន័យជ្រាលជ្រៅ ព្រោះបានអប់រំមនុស្សឱ្យយល់ដឹងជីវិតរស់នៅ និងពីវិធីដោះស្រាយបញ្ហាទាំងឡាយដែលកើតមាននៅក្នុងជីវភាពប្រចាំថ្ងៃ។
- **មតិផ្ទាល់ខ្លួន**: ក្នុងនាមជាអ្នកសិក្សាគប្បីខិតខំសិក្សាស្រាវជ្រាវស្នាដៃទាំងឡាយដែលផ្សាភ្ជាប់នឹងជីវិតពិតៗដើម្បីដកស្រង់បទពិសោធទាំងនោះមកអនុវត្តក្នុងជីវភាពរស់នៅឱ្យបានសមស្រប។

## សេចក្តីអធិប្បាយ

គ្រប់ស្នាដៃអក្សរសិល្ប៍ តែងតែលើកយកបញ្ហាដែលកើតមាននៅក្នុងសង្គមមកចោទ និងស្រាយដើម្បីអប់រំមនុស្សឱ្យមានបទពិសោធ ចំណេះដឹងក្នុងការស្រាយបញ្ហាដែលកើតមានក្នុងជីវភាពរស់នៅរបស់ខ្លួន។ ចំណែករឿងរាមកេរ្តិ៍ កវីនិពន្ធក៏បានលើកយកបញ្ហាមនុស្សជាច្រើនមកចោទនិងដោះស្រាយដែរ។ ដោយសម្អាងទៅលើខ្លឹមសាររបស់រឿងដូច្នេះហើយ ទើបមានអត្ថកោវិទម្នាក់ពោលថា «រឿងរាមកេរ្តិ៍ ជារឿងមនុស្សវិទ្យា»។

តើទស្សនៈអត្ថកោវិទខាងលើនេះ មានអត្ថន័យយ៉ាងណាខ្លះ?

មុននឹងឈានចូលដល់ការបកស្រាយខ្លឹមសាររបស់ប្រធានខាងលើឱ្យបានក្បោះក្បាយនោះ យើង គប្បីយល់នូវន័យនៃពាក្យ«មនុស្សវិទ្យា»។ « មនុស្សវិទ្យា» មានន័យថា វិជ្ជាដែលសិក្សាពីបញ្ហារស់នៅរបស់មនុស្ស។ តាមន័យរបស់ប្រធានចង់ឱ្យយើងបង្ហាញថា រឿងរាមកេរ្តិ៍ជារឿងមួយដែលសិក្សាពីជីវភាពនៃការរស់នៅរបស់មនុស្សក្នុងសង្គម។

តាមដំណើររឿងបានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថា រឿងនេះពិតជាបានលើកយកបញ្ហាដែលកើតមានក្នុងសង្គមមនុស្ស ព្រោះបានបង្ហាញតាំងពីនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ជាក់ស្ដែងក្នុងបញ្ហានយោបាយក្នុងប្រទេស គឺបង្ហាញពីចនាសម្ព័ន្ធនៃការគ្រប់គ្រងនគរឬប្រទេសនីមួយៗដែលមានអ្នកដឹកនាំប្រកបដោយសមត្ថភាព។ ជាអាទិ៍ព្រះបាទទសរថដែលសោយរាជ្យនៅនគរព្វយុធ្យាទ្រង់បានយកព្រះទ័យទុកដាក់លើប្រជារាស្ត្ររបស់ទ្រង់លើរាជវង្ស។ ទ្រង់ប្រកាន់ខ្ជាប់នូវពាក្យសត្យមិនក្បត់នឹងពាក្យសន្យារបស់ទ្រង់និងនាងកៃកេសីឡើយ។ ព្រះអង្គទ្រង់ប្រព្រឹត្តខុសនឹងប្រពៃណីក្សត្រ ឬរបាក្សត្រមិនដោយមិនឱ្យខុសពាក្យសន្យាជាមួយនាងកៃកេសីនោះឡើយ។ ព្រះអង្គបានសម្របសម្រួល គឺតម្រូវឱ្យព្រះរាមយាងចេញពីនគរទៅភ្នំចិត្រកូដ បួសជាឥសីចំនួនដប់បួនឆ្នាំដើម្បីទុកឱកាសឱ្យព្រះភិរុតឡើងគ្រងរាជ្យទាំងទឹកព្រះទ័យក្តុកក្តួលបំផុត។ទង្វើរបស់ទ្រង់បែបនេះជាទង្វើប្រកបដោយវិចារណញ្ញាណអាចទប់ស្កាត់ការបង្ហូរឈាមរវាងរាជវង្សានុវង្ស ដែលកើតឡើងជាយថាហេតុ ដោយបក្សពួកនាងកៃកេសីនិងបក្សពួកខាងព្រះរាម។ ចំពោះព្រះបាទជនកវិញ គឺជាអ្នកដឹកនាំមួយរូបប្រកបដោយទសពិធរាជធម៌ចំពោះប្រជារាស្ត្ររបស់ព្រះអង្គដែរ។ ព្រះអង្គបានជ្រើសរើសយកវេលាមួយយ៉ាងសមស្របក្នុងការប្រារព្ធពិធីបុណ្យវប្បមង្គលនៅឯឆ្នេរទន្លេយមុនា។ ព្រះរាជសកម្មភាពនេះសរបញ្ជាក់ឱ្យឃើញពីទឹកព្រះទ័យរបស់ទ្រង់ចំពោះរាស្ត្រ។ ពោលគឺទ្រង់បានពញ្ញាក់ស្មារតីរាស្ត្រឱ្យដឹងថានឹងដល់រដូវធ្វើស្រែចំការហើយ។រីឯក្រុងរាពណ៍សោយរាជ្យនៅនគរលង្កាវិញ គឺឆ្លុះបញ្ចាំងឱ្យឃើញពីអ្នកដឹកនាំប្រទេសដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនគិតតែពីរឿងស្រីញីមិនស្តាប់មតិយោបល់អ្នកនៅក្រោមឱវាទ គឺធ្វើតាមតែអំពើចិត្តតាមតែសេចក្តីត្រេកត្រអាលរបស់ខ្លួន។ នៅចុងបញ្ចប់ក្រុងរាពណ៍បានធ្វើឱ្យរាស្ត្ររងទុក្ខស្លាប់វិនាសអន្តរាយនគររបស់ខ្លួន។ ចំពោះនយោបាយក្រៅប្រទេសវិញពីនគរមួយទៅនគរមួយឬពីប្រទេសមួយទៅប្រទេសមួយគឺមានទំនាក់ទំនងគ្នាជានិច្ច។ ព្រះរាមបានចងសម្ព័ន្ធមិត្តជាមួយមហាជម្ពូដើម្បីសុំកម្លាំងទ័ពជំនួយក្នុងការជួយសុគ្រីពឲ្យបានសោយរាជ្យ ហើយទទួលយកពិភេគ និងតែងតាំងបុណ្យសក្តិផ្តល់រង្វាន់ដែលសុទ្ធតែជាប្រយោជន៍ទាំងអស់ ដោយសារតែការចងសម្ព័ន្ធភាពនេះហើយ ទើបព្រះរាមមានកម្លាំងទ័ពគ្រប់គ្រាន់សម្រាប់ធ្វើសង្គ្រាមដណ្តើមយកនាងសីតាមកវិញប្រកបដោយជ័យជម្នះនិងអាចជួយដោះស្រាយបញ្ហាចំពោះមុខបានដូចបំណង។ បើនិយាយពីបញ្ហាសេដ្ឋកិច្ចវិញរឿងនេះបានលើកយកពីវិស័យកសិកម្មជាវិស័យមួយ ដែលត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង។ នៅសម័យនោះប្រទេសកម្ពុជាក៏បានយកវិស័យកសិកម្មជាវិស័យចម្បងក្នុងការស្តារសេដ្ឋកិច្ចជាតិយើងដែរ។ ដូច្នេះហើយបានជាព្រះបាទជនកបានប្រារព្ធពិធីច្រត់ព្រះនង្គ័លនេះ ដើម្បីជាការផ្តល់ដំណឹងឱ្យប្រជាកសិករដឹងថា  ដល់រដូវធ្វើស្រែចំការហើយ។ ក្រៅពីនេះទៀត ក្នុងស្នាដៃដដែលក៏បានឆ្លុះបញ្ចាំងបន្ថែមទៀតលើវិស័យគមនាគមន៍ដោយព្រះរាមបានបញ្ជាឱ្យទ័ពស្វាសង់ស្ពានឆ្ពោះទៅលង្កា។ សក្ខីភាពនេះ គឺជាការបង្ហាញឱ្យឃើញថា ស្ពានក្តី ថ្នល់ក្តី សុទ្ធតែមានសារសំខាន់ក្នុងការធ្វើដំណើររបស់កងទ័ព គឺដឹងគ្រឿងសព្វាវុធទៅច្បាំងឬការដឹកជញ្ជូនផលិតផលផ្សេងៗទៀត។ វិស័យគមនាគមន៍គឺជាវិស័យមួយប្រៀនបាននឹងសរសៃឈាមសេដ្ឋកិច្ចដែលមានប្រយោជន៍ដល់សង្គម ពិសេសបានលើកម្ពស់ជីវភាពប្រជារាស្ត្រទៀតផង។

ទន្ទឹមនឹងនេះ ដំណើររឿងក៏បានលើកយកវិស័យសង្គមកិច្ចមកបង្ហាញ ដែលទាក់ទងទៅនឹងបញ្ហាសន្តិសុខរបស់ប្រជារាស្ត្រ រស់នៅចង់បានសន្តិភាព សុភមង្គល  អាស្រ័យទៅលើការដឹកនាំនិងគ្រប់គ្រងរបស់ប្រទេសជាតិនោះ។ តួយ៉ាងមហាជម្ពូដែលគ្រប់គ្រងហេមពាន្តបុរី បានយកចិត្តទុក

ដាក់ពីសុខទុក្ខរបស់ប្រជារាស្ត្រខ្លាំងណាស់។ ព្រះអង្គសុខចិត្តបរិច្ចាគសេនាជំនិតរបស់ខ្លួន គឺខុន និលនិងខុននលឱ្យទៅព្រះរាមក្នុងគោលបំណងឱ្យប្រជារាស្ត្រខ្លួនបានសុខរួចផុតពីការគ្រប់គ្រង របស់ព្រះរាម។នៅនគរខាស់ខិនបុរីវិញ សុគ្រីពហេតុតែចង់ឈ្នះពាលីក៏ទៅពឹងព្រះរាមឱ្យជួយ នៅទី បំផុតក៏ត្រូវស្ថិតនៅក្រោមបញ្ជាព្រះរាមដើម្បីជាការសងគុណដែលព្រះរាមបានជួយខ្លួន។ មិនតែ ប៉ុណ្ណោះប្រជានុរាស្ត្រចិតសិបអក្ខោនី[18] ដែលស្មើនឹងដប់ស្វ័យគុណសែសិបពីរដែលត្រូវធ្វើជា ទាហានចេញទៅជួយច្បាំងព្រះរាមយកនាងសីតានៅនគរលង្កា។ ឥរិយាបថអ្នកដឹកដូចជារូបសុគ្រីព នេះ ប្រជារាស្ត្ររស់នៅពិតជាពុំមានសុភមង្គល ហើយជីវភាពពុំមានភាពធូរធារឡើយ។ ជាមួយ នោះ បើសិនជាក្រឡេកមករកវិស័យសុខាភិបាលវិញពិតជាបានឃើញថា វិធីព្យាបាលរបួសដោយ ប្រើឫសឈើ មើមឈើ ទឹកម៉ូត្រគោឧសភរាជ និងថ្នាំសំរិទ្ធសម្រាប់ព្យាបាល។ ពិភេគ បានបញ្ជាឱ្យ ហនុមានចេញទៅរកថ្នាំមកព្យាបាលព្រះលក្ស្មណ៍ឱ្យបានជាសះស្បើយ។ នេះសរបញ្ជាក់ថា នាម សម័យកាលនោះ ក៏មានគ្រូពេទ្យពូកែៗ ហើយកាលណាមានរបួសឬជំងឺ តែងតែត្រូវការគ្រូពេទ្យព្យា បាលទើបជាសះស្បើយ។

ក្រៅពីវិស័យខាងលើនេះ នៅមានវិស័យមួយទៀត គឺវិស័យវប្បធម៌ដែលជាវិស័យមួយចាំបាច់ ក្នុងសង្គមជាតិដែរ។ ជាក់ស្តែងក្នុងការសិក្សាអប់រំបង្ហាញថា ព្រះរាមដែលជាអវតារទីប្រាំពីរនៃព្រះ វិស្ណុ ក៏នៅតែសិក្សាទោះបីទ្រង់ស្ថិតជាអាទិទេពក៏ដោយ។ ព្រះអង្គបានសិក្សាចប់គម្ពីរវេទជាមួយ ឥសីពិស្វាមិត្រដែលមានសមត្ថភាពអស្ចារ្យអាចលើកធ្នូសហស្សថាមរបស់ព្រះបាទជនកបានដោយ ជោគជ័យ។ ចំណែករាម លក្ស្មណ៍ជបលក្ស្មណ៍ក៏ត្រូវសិក្សារៀនសូត្រពីឥសីវជ្ជប្រិតដែរ។ នេះជា ការបញ្ជាក់ឱ្យឃើញថា ចំណេះវិជ្ជារបស់បុគ្គលអាចរីកចម្រើនទៅបាន អាស្រ័យដោយការខិតខំរៀន សូត្ររបស់បុគ្គលនោះ។ បើនិយាយពីសាសនាវិញ ស្នាដៃខាងលើនេះឮបានឆ្លុះបញ្ចាំងឱ្យឃើញពី ការគោរពបូជាសាសនាព្រាហ្មណ៍ គោរពអាទិទេពទេវៈ ព្រះនារាយណ៍ដែលប្រជារាស្ត្រខ្មែរ តែង និយមគោរពទេវៈទាំងនេះមានជារៀងរហូតមក។ មួយវិញទៀតចំពោះជំនឿក្នុងសាច់រឿងក៏បាន បង្ហាញពីជំនឿទៅលើសត្វកុកថាជាសត្វចង្រៃ។ ឧទាហរណ៍ ក្នុងដំណើរស្វែងរកនាងសីតានៅពេល ដែលព្រះរាមជួបសត្វកុកៗក៏បានប្រាប់ព្រះអង្គពីនាងសីតាត្រូវក្រុងរាពណ៍ចាប់នាងសីតាទៅលង្កា។ ទីបំផុតព្រះរាម ព្រះលក្ស្មណ៍ស្ទើរតែប្រហារសត្វកុកចោលទៅហើយ ព្រោះជឿថាសត្វកុកជាសត្វ ចង្រៃសម្តីកុកស្មើនឹងពាក្យបណ្តាសាឬជាពាក្យផ្តន្ទា។ ទង្វើរបស់ទ្រង់ទាំងពីរក្នុងបំណងទប់ស្កាត់កុក មិនឱ្យនិយាយតទៅទៀតតែប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ សត្វកុកគ្រាន់តែហើរឆ្វេលនគរលង្កាបីជុំ តែប៉ុណ្ណោះ នគរលង្កាក៏អាចរលាយបានដែរ។ ក្រោយមកជំនឿនេះក៏បានគេនិយមជឿទៅលើសត្វ ខ្លែងស្រាកថាជាសត្វចង្រៃ។

ចំពោះផ្នត់គំនិតក្នុងរឿងរាមកេរ្តិ៍ ក៏បង្ហាញពីការលើកយក ការគោរពពាក្យសត្យ មកបង្ហាញ តាមរយៈតួអង្គព្រះរាមដែលមិនវិលត្រឡប់ទៅសោយរាជ្យតាមការយាងរបស់ព្រះភិរុត និងនាងកៃ កេសី។ នាងសីតាមិនព្រមយាងចូលនគរមករួមរស់ជាមួយព្រះរាមវិញដោយសារតែនាងបានសច្ចា ថា ដរាបណាព្រះរាមសុគតទើបនាងយាងចូលនគរវិញ។ ផ្នត់គំនិតនេះត្រូវបានបន្សល់ទុករហូត សព្វថ្ងៃហើយត្រូវបានដូន តាខ្មែរចងក្រងជាពាក្យសុភាសិតថា «មនុស្សគេយកសម្តី ដំរីគេយកភ្លុក»

---

[18] អក្ខោ អ័ក-ខោ ( គុ. ) ពាក្យប្រើកាត់ខ្លីមកពី អក្ខោភិនី សំដៅសេចក្តីថា "ច្រើន, ច្រើនក្រៃ, គរគោក" : មានជាអក្ខោយកទៅ ណាពុំអស់ (ព. សា.) ។

ឬ«វនាបបាក់គេយកវនាបជួសសម្ដីជ្រុលហួសគ្មានអ្វីជួសបានឡើយ»។ ជាមួយនេះ ប្រពៃណីនៃរៀបអាពាហ៍ពិពាហ៍បានស្ដែងឱ្យឃើញថា គេតែងប្រារព្ធឡើងនៅគេហដ្ឋានខាងស្រី។ ដូចជាព្រះបាទជនកបានរៀបចំអភិសេកនាងសីតាជាមួយព្រះរាមនៅនគរមិថិលាដែលតំណាងគេដ្ឋានខាងស្រី។ ប្រពៃណីនេះ ត្រូវបានប្រជារាស្ត្រខ្មែរនិយមប្រកាន់បន្តរហូតបច្ចុប្បន្ននេះ ដែលត្រូវចូលចៃចូវស្ដីដណ្ដឹង និងស៊ើបសួរពីប្រវត្តិកូនប្រុសជាដើម។

សរុបសេចក្ដីមកតាមការរៀបរាប់ដូចខាងលើនេះបានបញ្ជាក់ថា រឿងរាមកេរ្តិ៍ជារឿងមួយដែលលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយដើម្បីមនុស្សដែលគេអាចនិយាយបានថារឿងនេះជារឿងមនុស្សវិទ្យាប្រាកដមែន។

ឆ្លងតាមការបកស្រាយខាងលើយើងអាចសន្និដ្ឋានបានថា ទស្សនៈប្រធានពិតជាមានអត្ថន័យជ្រាលជ្រៅ ព្រោះបានអប់រំមនុស្សឱ្យយល់ដឹងពីជីវិតរស់នៅនិងពីវិធីដោះស្រាយបញ្ហាទាំងឡាយដែលកើតមាននៅក្នុងជីវភាពប្រចាំថ្ងៃ។ ដូច្នេះក្នុងនាមជាអ្នកសិក្សា យើងគប្បីខិតខំសិក្សាស្រាវជ្រាវស្នាដៃទាំងឡាយដែលផ្សារភ្ជាប់នឹងជីវិតពិតៗ ដើម្បីដកស្រង់បទពិសោធន៍ទាំងនោះមកអនុវត្តក្នុងជីវភាពរស់នៅឱ្យបានសមស្រប។

---

**ប្រធានទី២:** ទស្សនៈមួយថា «តួអង្គក្នុងរឿងទុំទាវភាគច្រើនបានជំពាក់នឹងទោសនៃកាមតណ្ហា»។ ចូរបង្ហាញ ដោយរកឧទាហរណ៍មកបញ្ជាក់។

---

## សេចក្ដីអធិប្បាយ

រឿងទុំទាវជាប្រលោមលោកមនោសញ្ចេតនាបុរាណខ្មែរ ដ៏ល្បីល្បាញមួយចំណោមប្រលោមរឿងដទៃទៀតដែលត្រូវបានមហាកវីនិពន្ធខ្មែរសម្រិតសម្រាំងរចនានិពន្ធឡើងប្រកបដោយទេពកោសល្យខ្ពង់ខ្ពស់បំផុតគឺព្រះភិក្ខុសោមក្នុងគ្រិស្តសករាជមួយពាន់ប្រាំបួនរយដប់ប្រាំ នាពុទ្ធសករាជពីពាន់បួនរយហាសិបប្រាំបី។ មូលបញ្ហារឿងដ៏សំខាន់ដែលកវីលើកយកមកបង្ហាញដើម្បីឱ្យទាក់ទាញអារម្មណ៍អ្នកអាន អ្នកសិក្សានោះ គឺបញ្ហាស្នេហាដែលស្ដែងចេញតាមរយៈតួអង្គពោរពេញដោយភាពងប់ងល់ក្នុងផ្លូវតណ្ហាដកខ្លួនមិនរួច។ អាស្រ័យហេតុនេះហើយ ទើបលេចចេញនូវមតិថា «តួអង្គក្នុងរឿងទុំទាវភាគច្រើនបានជំពាក់នឹងទោសនៃកាមតណ្ហា»។

តើតួអង្គណាខ្លះជំពាក់នឹងទោសនៃកាមតណ្ហា?

មុននឹងបង្ហាញបញ្ជាក់បញ្ហាប្រធានកំណត់ឱ្យបានក្បោះក្បាយ គួរយល់ពាក្យខ្លះមានជំពាក់ទោសនិងកាមតណ្ហា។ «ជំពាក់»មានន័យថាទាក់ទាមឬទាក់ទិនហើយពាក្យថា«ទោស» គឺជាកំហុសឬកំហឹងឬការប្រទូស។ ចំណែកពាក្យ «កាមតណ្ហា» គឺសេចក្ដីប្រាថ្នាឬសម្រេកដោយអន្ទះអន្ទែង។ ទស្សនៈប្រធានលើកឡើងថា តួអង្គជាច្រើននៅក្នុងរឿងទុំទាវបានទាក់ទិន នឹងសេចក្ដីប្រាថ្នាឬសម្រេកដោយអន្ទះអន្ទែងនិងប្រកបដោយកំហុស កំហឹង ប្រទូស្តក្នុងជីវិតជាច្រើន។

តាមការសិក្សាខ្លឹមសារនៃរឿងទុំទាវ ពិតជាបញ្ជាក់បង្ហាញឱ្យឃើញដូច្នេះមែន។ ជាដំបូងយើងពិនិត្យលើរូបភាពនិងលក្ខណៈទោសនៃកាមតណ្ហាមានពីរធំៗគឺកិលេសតណ្ហានិងវត្ថុកាមតណ្ហា។ កិលេសតណ្ហា គឺគ្រឿងសៅហ្មងចិត្តដែលនាំឱ្យកើតចេញនូវចំណងឬសម្រេកក្នុងអារម្មណ៍រាគៈការជំពាក់ សេចក្ដីប្រាថ្នា អន្ទះអន្ទែង ឬឆ្អែតឆ្អន់ សេចក្ដីមិនត្រេកអរតាមមានតាមបានសេចក្ដីច្រណែន

ឈ្នានីស ក្តៅ ក្រហាយនឹងគេ និងសេចក្តីមិនត្រេកអរផង។ ចំណែកវត្ថុកាមតណ្ហាសំដៅលើវត្ថុជាចំណង់ គឺរូប ក្លិន រស និងសម្ផស្ស។ កាមតណ្ហានេះហើយជាដើមចមនៃទុក្ខទោសបង្កសេចក្តីទុក្ខសោកដល់មនុស្ស សត្វ ហៅថាសមុទយ។ សេចក្តីថា វាបង្កជាភាពក្រៀមក្រមថប់អារម្មណ៍សោកសៅវិយោគអួលណែនថ្ងូចថ្ងូរសង្រេង តឹងចិត្តផ្អិតទ្រូងជាដើម។ ម្យ៉ាងទៀតទោសនៃកាមតណ្ហានេះនាំឱ្យហ៊ានប្រព្រឹត្តអំពើបាបឬអកុសលក៏សឹងមានករណីរំលោភបំពានអត្តឃាត មានះរឹងរូស អត្តនោម័ត និងឃាតកម្មផងដែរ។ ជាក់ស្តែងតាមដំណើររឿងបានបង្ហាញតាមតួអង្គទុំ និងទាវដែលមានកាមតណ្ហាជំពាក់ទៅនឹងរូប សំឡេង ក្លិន រស និងសម្ផស្សចំពោះគ្នានិងគ្នា ដោយបង្កើតចិត្តរំលោភបំពាន មានះ អត្តនោម័ត និងឈានទៅដល់ការប្រទូស ប្រើអំពើអកុសល ស្រី ស្រា ល្បែង ព្រមទាំងធ្វើអត្តឃាតទៀតផង។ ចំណែកម្តាយនាងទាវផ្តប់ដោយកាមតណ្ហា ប្រាថ្នាឋានៈខ្ពង់ខ្ពស់ ទ្រព្យសម្បត្តិ យសសក្តិ អំណាច ដោយបោះបង់នូវកុសល ចិត្តធម៌ធ្លាប់មានពីមុនមក ហើយបែរងាកមកប្រមាថ ឈ្នានីស ហិង្សាយកឈ្នះចាញ់គ្នាយ៉ាងសាហាវព្រៃផ្សៃបំផុត។ ករណីគាត់ប្រើឧបាយកលបញ្ឆោតទាវមករៀបការជាមួយម៉ឺនងួនកូនស្តេចត្រាញ់អរជូនដែលមានអំណាចទ្រព្យសម្បត្តិធំធេង ទោះបីដឹងថា នាងទាវក្លាយជាប្រពន្ធទុំ ត្រូវបានស្តេចរាមារៀបការឱ្យក៏ដោយ។ ម្យ៉ាងទៀតគាត់បានញុះញង់អរជូនឱ្យកាប់សម្លាប់ទុំគ្មានការពិចារណាឡើយដែលលទ្ធផលត្រូវបានស្តេចកាត់ទោសប្រហារជីវិត។ ចំពោះម៉ឺនងួនកូនអរជូនវិញ គាត់ស្រឡាញ់នាងទាវផ្តាប់មុខដោយមិនជំទាស់ឪពុកម្តាយ គឺងប់ងល់រៀបការជាមួយនាងទាវ ដែលជាប្រពន្ធគេទាំងអាប់យស ហើយហ៊ានលើកដៃកាប់សម្លាប់ទុំទាំងងើលទៀតផង។ ឯអរជូនវិញអាងអំណាចទ្រព្យសម្បត្តិយសសក្តិ ព្រមរៀបការកូនជាមួយនាងទាវ ទោះបីខ្លួនបានដឹង ហើយថាទាវបើមិនបានទុំ ក៏អាចជាស្នំឯកស្តេចរាមាដែរ។ នេះបានសេចក្តីថា អរជូនបំពានទៅលើស្តេចរាមាទាំងស្រុង។ ពិសេសក៏ត្រូវដឹងថា ទុំជាមនុស្សរបស់ស្តេចដែរ ព្រោះទុំជាម៉ឺនឯក។ ជាចុងក្រោយទោសនៃកាមតណ្ហាក៏ត្រូវធ្លាក់មកលើស្តេចរាមាផងដែរ ដោយព្រះអង្គវង្វេងសម្រស់នាងទាវបម្រុងសម្លាប់ទុំពេលទុំច្រៀងសារភាពស្នេហាខ្លួនជាមួយទាវ។ ម្យ៉ាងទៀតការមកកាត់ទោសអរជូន ម្តាយទាវ និងបក្សពួកនៅត្បូងឃ្មុំយ៉ាងសាហាវព្រៃផ្សៃគឺមកពីព្រះអង្គសោកស្តាយទុំទាវ ពិសេសខឹងអរជូនដែលមិនគោរពរាជសារព្រះអង្គដែលឱ្យទុំមកយកទាវវិញពោលគឺខ្លាចនិងលែងទុកចិត្តអរជូនទាក់ទងនឹងរឿងអំណាចតែម្តង។ ដោយប្រការនេះហើយទើបជំរុញស្តេចរាមាបាត់បង់សុភវិនិច្ឆ័យកាត់ទោសទាំងកំហឹងទៅដល់រាស្ត្រនៅត្បូងឃ្មុំដែលមិនដឹងអ្វីសោះទាំងក្មេង ចាស់ ទារកក្នុងផ្ទៃ ក្លាយជាអ្នកងារយ៉ាងទារុណបំផុត។

សរុបសេចក្តីមក តួអង្គជំពាក់ទោសនៃកាមតណ្ហាគឺទុំទាវ ម្តាយទាវ អរជូនម៉ឺនងួន និងស្តេចរាមាដែលធ្លាក់ក្នុងអន្លង់នៃកិលេសតណ្ហាដោយក្តីឈ្នានីស អន្ទះអន្ទែងក្នុងសម្រេកលោភៈ។ ម្យ៉ាងក៏ជំពាក់ វត្ថុកាមតណ្ហាក្រាស់ក្រែលគឺស្នេហាមាតុគ្រាម។ការជំពាក់នេះបានបង្ករជាទុក្ខទោស ហិង្សាអត្តនោម័តមានះរឹងរូស ហើយនាំដល់មហន្តរាយធ្ងន់ធ្ងរ។

តាមការបកស្រាយខាងលើនេះបានបង្ហាញឱ្យឃើញថាទស្សប្រធានមានអត្ថន័យជ្រាលជ្រៅ ព្រោះបានបង្ហាញផលអាក្រក់ផ្សេងៗដែលកើតចេញពីទោសនៃកាមតណ្ហា។ ម្យ៉ាងទស្សនៈនេះក៏បានផ្តល់ជាគតិអប់រំដាស់តឿនជនានុជនទាំងឡាយឱ្យជៀសចេញនូវកាមតណ្ហាប្រកបដោយមនសិការផងដែរ។ដូច្នេះយើងចាំបាច់ត្រូវខិតខំសាងកុសលក្នុងជីវិតឱ្យបានល្អត្រឹមត្រូវ ពិសេសបញ្ចៀសនូវកាមតណ្ហាឱ្យអស់ពីជីវិតដើម្បីឧត្តមភាពវឌ្ឍភាព និងសុភមង្គលក្នុងជីវិត។

**ប្រធានទី៣:** ទស្សនៈមួយយល់ថា « អ្នកសាងអំពើអកុសល រមែងតែងតែជួបក្តីអន្តរាយក្នុងជីវិត»។ ចូរពន្យល់ ដោយរកឧទាហរណ៍មកបញ្ជាក់។

# គម្រោងតែង

## ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** តាមក្រិត្យក្រមធម្មជាតិនៃការរស់នៅរបស់មនុស្សគ្រប់ៗរូបតែងមានការប្រព្រឹត្ត ដោយឡែកៗពីគ្នាមានល្អ មានអាក្រក់ បើកាលណាមនុស្សជ្រុលខ្លួនប្រព្រឹត្តនូវអំពើអាក្រក់ដោយប្រការ ណាមួយ ប្រាកដជារងនូវភាពវិនាសហិនហោច ដែលជាផលតបស្នងវិញមិនខាន។
- **ចំណុចបញ្ហា (បង្ហាញប្រធានបទ) :** ដោយឈរលើហេតុផលនេះហើយ ទើបមានទស្សនៈមួយ យល់ថា « អ្នកសាងអំពើអកុសល រមែងតែងតែជួបក្តីអន្តរាយក្នុងជីវិត»។
- **ចំណោទបញ្ហា:** តើអំពើអាក្រក់គ្រប់យ៉ាងដែលមនុស្សបានសាង និងផ្តល់ក្តីវិនាសដល់មនុស្ស វិញយ៉ាងដូចម្តេចខ្លះ?

## ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីយល់ន័យប្រធានឱ្យកាន់តែស៊ីជម្រៅ និងច្បាស់លាស់យើងគប្បីស្វែង យល់ពាក្យគន្លឹះសំខាន់ៗជាមុនសិន។
- **ពន្យល់ពាក្យ៖**
  - ✓ អំពើអកុសល ជាទង្វើអាក្រក់ឬទង្វើបាប។
  - ✓ អន្តរាយ ជាសេចក្តីវិនាសហិនហោច។
- **ពន្យល់ន័យប្រធាន:** បុគ្គលទាំងឡាយណាដែលបានសាងនូវអំពើអាក្រក់បាបកម្មបុគ្គលនោះ រមែងតែងតែរងនូវក្តីវិនាសហិនហោចដល់ខ្លួនជាក់ជាមិនខាន។
- **បកស្រាយ:** « អ្នកសាងអំពើអកុសល រមែងតែងតែជួបក្តីអន្តរាយក្នុងជីវិត»ព្រោះ៖
  - ▪ **គំនិតសំខាន់**
    - ✓ មនុស្សគ្រប់រូប ក្មេងចាស់ ប្រុសស្រី មានក្រ នាម៉ឺនមន្ត្រីរាស្ត្រ
    - ✓ សាងអំពើអាក្រក់ដោយកាយ វាចា ចិត្ត គឺលួច ឆក់ ប្លន់
    - ✓ សម្លាប់បំពារបំពានកូនប្រពន្ធគេ ពោលពាក្យកុហកបោកប្រាស់
    - ✓ គិតក្នុងផ្លូវអាក្រក់ណាមួយដើម្បីបំផ្លាញអ្នកដទៃបុគ្គលនោះរមែងតែងតែរងនូវក្តីវិនាស ហិនហោចដល់ខ្លួនដោយប្រការផ្សេងៗដូចជាវិនាសទ្រព្យសម្បត្តិ បាត់បង់តួនាទី បែកបាក់ញាតិសន្តាន បាត់បង់កិត្តិយស ស្លាប់ខ្លួនជាដើម។
  - ▪ **ឧទាហរណ៍៖**

    ក- **សង្គមជាក់ស្តែង**ក្រុមយុវជនខិលខូចមួយចំនួន គេចសាលាទៅជក់ថ្នាំញៀនលេងល្បែង ស៊ីសងទៅលួចឆក់ប្លន់ទ្រព្យសម្បត្តិគេ ទីបំផុតត្រូវបាត់បង់ការសិក្សា គេចាប់ដាក់ទោស ឬស្លាប់ខ្លួន។

**ខ- ក្នុងប្រវត្តិសាស្ត្រ** ព្រះរាជសម្ភារបានធ្វើឱ្យខ្លួនធ្លាក់ក្នុងផ្លូវកាមគុណដោយបានទៅលួចសាហាយស្មន់ជាមួយព្រះនាងអង្គបុប្ផាវតីដែលជាមហេសីរបស់ព្រះឧទ័យទីបំផុតត្រូវគេបាញ់ទម្លាក់ពីលើចុងត្នោត។

**គ- ក្នុងអក្សរសិល្ប៍**

- ✓ រឿងទុំទាវ ស្ដេចត្រាញ់អរជូនមានចិត្តខ្មៅតិរច្ឆានបានប្រើអំណាចខ្លួនសម្លាប់ទុំជាប្ដីនាងទាវដើម្បីប្លន់យកនាងទាវជាប្រពន្ធឱ្យម៉ឺនងួនជាកូនទីបំផុតត្រូវស្ដេចកាត់ទោសប្រហាជីវិត។
- ✓ រឿងព្រះវេស្សន្តរ តាជូជកមានចិត្តអាក្រក់ឥតមេត្តា វាយធ្វើបាបក្មេងដូចសត្វធាតុគាត់ត្រូវមានបាបកម្ម គឺស្លាប់ដោយបែកពោះ។
- ✓ រឿងរាមកេរ្តិ៍ ក្រុងរាពណ៍ជាស្ដេចយក្សនគរលង្កា ល្មោភស្រី បានចាប់ពង្រាត់សីតាប្រពន្ធព្រះរាមយកទៅនគររបស់ខ្លួន ទង្វើដ៏អាក្រក់បាននាំនគរលង្កាឱ្យរលាយញាតិសន្តានត្រូវស្លាប់ខ្លួនឯងត្រូវវិនាស។

- **សរុបសេចក្ដី:** សាងអំពើអាក្រក់នឹងទទួលបានផលអាក្រក់។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន:** ទស្សនៈប្រធានមានអត្ថន័យជ្រាលជ្រៅ ដោយបានឆ្លុះបញ្ចាំងឱ្យឃើញពីមហន្តរាយដ៏ធ្ងន់ធ្ងរដែលកើតឡើងពីការសាងអំពើទុច្ចរិត ដើម្បីជាគតិដាស់តឿនមនុស្សឱ្យវៀរចាក ហើយខិតខំសាងអំពើល្អ។
- **មតិផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្ស យើងត្រូវវៀរចាកឱ្យឆ្ងាយពីអំពើអកុសលទាំងឡាយ។

## សេចក្ដីអធិប្បាយ

តាមក្រិត្យក្រមធម្មជាតិនៃការរស់នៅរបស់មនុស្សគ្រប់ៗរូប មានការប្រព្រឹត្តដោយឡែកៗពីគ្នាទៅតាមនិស្ស័យបុគ្គលរៀងៗខ្លួនមានទាំងអំពើល្អសុចរិតទៀងត្រង់ មានទាំងអំពើទុច្ចរិតអាក្រក់ពោរពេញដោយបាបកម្ម។ បើកាលណាមនុស្សជ្រុលខ្លួនប្រព្រឹត្តនូវអំពើអាក្រក់អកុសលដោយប្រការណាមួយហើយប្រាកដជាទទួលបាននូវភាពវិនាសហិនហោចអន្តរាយ ដែលជាផលតបស្នងវិញ មិនខានដោយជៀសមិនផុតឡើយ។ ឈរលើហេតុផលនេះ ទើបមានទស្សនៈមួយយល់ថា« អ្នកសាងអំពើអកុសលរមែងតែងតែជួបក្ដីអន្តរាយក្នុងជីវិត»។

តើអំពើអាក្រក់គ្រប់យ៉ាងដែលមនុស្សបានសាងនិងផ្ដល់ក្ដីវិនាសដល់មនុស្សវិញយ៉ាងដូចម្ដេចខ្លះ?

ដើម្បីជាគុណប្រយោជន៍ដល់ការបកស្រាយឱ្យបានក្បោះក្បាយ យើងគួរគប្បីយល់អត្ថន័យនៃពាក្យគន្លឹះក្នុងប្រធានជាមុនសិន។ ពាក្យ «អំពើអកុសល» សំដៅលើទង្វើអាក្រក់ឬទង្វើបាប ហើយពាក្យ «អន្តរាយ» សំដៅលើសេចក្ដីវិនាសហិនហោច។ ផ្អែកតាមបំណកស្រាយពាក្យគន្លឹះខាងលើទស្សនៈប្រធានយល់ថា អ្នកដែលសាងនូវអំពើអាក្រក់ពោរពេញដោយបាបកម្ម រមែងតែងតែទទួលបាននូវក្ដីវិនាសហិនហោចដល់ខ្លួនវិញជាក់ជាមិនខាន។

ជាការពិតណាស់ក្នុងការរស់នៅមនុស្សគ្រប់ៗរូបមិនថាស្រីប្រុស ចាស់ ក្មេង មាន ក្រ អាក្រក់ ល្អ នាម៉ឺនមន្ត្រី ប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម បើក្នុងជីវិតរស់នៅបាននូវអំពើអាក្រក់ បាបកម្មដោយ កាយវាចា ចិត្ត មានការលួច ឆក់ប្លន់ រំលោភបំពារបំពានប្រពន្ធកូនគេ សម្លាប់ជីវិត ពោលពាក្យកុហកបោក បញ្ឆោត កេងប្រវ័ញ្ច ពុករលួយព្យាបាទ ឈ្នានីសអ្នកដទៃ បុគ្គលនោះនឹងទទួលបាននូវក្តីវិនាសហិនហោចតបស្នងវិញជាក់ជាមិនខានដូចជា វិនាសទ្រព្យធន បាត់បង់តួនាទី មុខរបរការងារ បែកបាក់ញាតិមិត្ត ក្រុមគ្រួសារ បាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ រស់នៅឯកោ ពេលខ្លះត្រូវរងទណ្ឌកម្ម ជាប់គុកច្រវាក់ ស្លាប់ទៅធ្លាក់នរកអវចី។ ជាទឡ្ហីករណ៍បើយើងក្រឡេកមើលក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរ នាសម័យក្រោយអង្គរបានលាតត្រដាងឱ្យឃើញពីការសាងអកុសលកម្មរបស់ព្រះរាជសម្ភារ ដែលបណ្តែតបណ្តោយខ្លួនឱ្យធ្លាក់ក្នុងអំណាចអូសទាញនៃកាមតណ្ហាដោយទ្រង់បានទៅលួចសាហាយស្មន់ជាមួយព្រះនាងអង្គបុប្ផាវតីមហេសីរបស់ព្រះឧទ័យ ទីបំផុតទ្រង់បានរងនូវក្តីវិនាសយ៉ាងធ្ងន់ធ្ងរ គឺត្រូវព្រះឧទ័យនាំទាហានព័រទុយហ្គាល់បាញ់ទម្លាក់ពីលើចុងត្នោត។

មួយវិញទៀត បើយើងបង្វែរចំណាប់អារម្មណ៍មកពិនិត្យមើលតថភាពសង្គម នាបច្ចុប្បន្នកាលនេះយើងឃើញមានក្រុមយុវជនខិលខូចមួយចំនួនតូចគេចសាលាទៅប្រព្រឹត្តអំពើអបាយមុខដូចជាជក់គ្រឿងញៀន លេងល្បែងស៊ីសងទៅលួចឆក់ប្លន់ទ្រព្យសម្បត្តិគេ។ទីបំផុតត្រូវបាត់បង់ការសិក្សា វិនាសទ្រព្យឪពុកម្តាយត្រូវសមត្ថកិច្ចចាប់ទៅផ្តន្ទាទោស។ យ៉ាងណាមិញ បើយើងងាកមកពិនិត្យមើលខ្លឹមសារនៅក្នុងអក្សរសិល្ប៍វិញម្តងក៏បានលាតត្រដាងកាន់តែច្បាស់ថែមទៀតពីមហន្តរាយយ៉ាងធ្ងន់ធ្ងរដែលប្រសូតចេញពីការប្រព្រឹត្តអំពើអកុសលនេះផងដែរ។ ជាក់ស្តែងក្នុងដំណើររឿងទុំទាវដែលជាស្នាដៃរៀបរៀងឡើង ដោយភិក្ខុសោមនាឆ្នាំមួយពាន់ប្រាំបួនរយដប់ប្រាំបានបង្ហាញឱ្យឃើញពីសកម្មភាពរបស់ស្តេចត្រាញ់ អរជូនដែលមានចិត្តខ្មៅតិរច្ឆានដោយប្រើអំណាចឃោរឃៅសម្លាប់ទុំជាប្តីប្លន់យកនាងទាវជាប្រពន្ធយកទៅឱ្យម៉ឺនងួនជាកូន។ ការសាងអំពើបាបរបស់បុគ្គលតិរច្ឆានអរជូនបានហុចផលអាក្រក់តបស្នងវិញគឺត្រូវព្រះរាជា រាមាជើងព្រៃកាត់ទោសប្រហារជីវិតដោយជីកកប់ត្រឹមក ហើយយករនាស់ដែករាស់ផ្តាច់កស្លាប់យ៉ាងវេទនា។ ចំណែកឯក្នុងដំណើររឿងព្រះវេស្សន្តរ ដែលស្ថិតនៅក្នុងសៀវភៅសង្ខេបទសជាតករបស់ឈឹមសុមន៍ បានបង្ហាញពីការសាងអំពើព្រៃផ្សៃរបស់តាជូជកដែលមានចិត្តអាក្រក់វាយធ្វើបាបកុមារជាលីក្រស្នាគ្មានប្រណីអូសកាត់ព្រៃវាលខ្សាច់ក្តៅដោយមិនអាសូរទីបំផុតមានបាបកម្មត្រូវបែកពោះស្លាប់។ បន្ថែមលើនេះទៀត បើយើងពិនិត្យមើលខ្លឹមសាររឿងរាមកេរ្តិ៍ដែលបានរៀបរៀងឡើងវិញដោយព្រះអង្គម្ចាស់វឌ្ឍឆាយាវង្សបានឆ្លុះបញ្ចាំងយ៉ាងពិស្តារពីទង្វើអកុសលរបស់ក្រុងរាពណ៍ស្តេចយក្សនគរលង្កាដែលបានប្រើល្បិចចាប់ពង្រាត់សីតាមហេសីព្រះរាមដើម្បីបំពេញមហិច្ឆតាក្នុងផ្លូវកាមគុណ ចុងក្រោយបុគ្គលកំណាចរូបនេះត្រូវវិនាសអន្តរាយដល់ខ្លួនខ្ទេចខ្ទីនគរ បុត្រ ប្អូន និងញាតិសន្តានត្រូវស្លាប់។

សរុបសេចក្តីមក តាមរយៈការបរិយាយប្រកបដោយឧទាហរណ៍យ៉ាងជាក់ច្បាស់ខាងលើនេះ អាចបញ្ជាក់ថា កាលបើបុគ្គលទាំងឡាយណាបានសាងនូវអំពើអាក្រក់ប្រាសចាកគន្លងទូន្មាននៃលទ្ធិសាសនា ប្រាសចាកសីលធម៌សង្គមល្មើសច្បាប់បង្កឱ្យមានភាពចលាចលដល់សង្គមជននោះប្រាកដជារងនូវភាពវិនាសហិនហោចដល់ខ្លួនទាំងនៅក្នុងជាតិនេះ និងបរលោក។

តាមការអធិប្បាយយ៉ាងពិស្តារកន្លងមកបានឱ្យឃើញថា ខ្លឹមសារប្រធានមានអត្ថន័យអប់រំជ្រាលជ្រៅ ព្រោះបានលាតត្រដាងពីវិនាសកម្មយ៉ាងធ្ងន់ធ្ងរដែលកើតចេញពីការសាងទុច្ចរិតក្នុងជីវិត ដើម្បីដាស់តឿនបុគ្គលស្រីប្រុសក្នុងលោកិយ

ឱ្យវៀរចាកអកុសលសាងតែអំពើល្អជាប្រយោជន៍ដល់សង្គមមនុស្ស។ ដូច្នេះក្នុងនាមយើងជាយុវជនមួយរូបដែលជាទំពាំងស្នងឫស្សីត្រូវខិតខំសាងខ្លួនឱ្យក្លាយជាកូនល្អក្នុងសង្គមដោយប្តេជ្ញាមិនប្រព្រឹត្តទង្វើអកុសលជាដាច់ខាត។

---

**ប្រធានទី៤:** មានទស្សនៈមួយពោលថា «រឿងព្រះវេស្សន្តរឆ្លុះបញ្ចាំងតថភាពសង្គមសម័យបុរាណ»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងរឿងមកបញ្ជាក់។

---

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** គ្រប់ស្នាដៃអក្សរសិល្ប៍ទាំងអស់មិនថាស្នាដៃនោះស្ថិតក្នុងប្រភេទណាក៏ដោយសុទ្ធ តែបានលើកយកបញ្ហារបស់មនុស្សក្នុងសង្គមទៅតាមសម័យកាលនីមួយៗមកបញ្ហាញ។
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** អាស្រ័យហេតុនេះ ហើយទើបមានទស្សនៈមួយយល់ថា «រឿងព្រះវេស្សន្តរឆ្លុះបញ្ចាំងតថភាពសង្គមសម័យបុរាណ»។
- **ចំណោទបញ្ហា:** តើទស្សនៈខាងលើមានអត្ថន័យដូចម្តេច?

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីបកស្រាយទស្សនៈប្រធានឱ្យកាន់តែស៊ីជម្រៅ និងក្បោះក្បាយយើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះជាមុនសិន។
- **ពន្យល់ពាក្យ៖**
  - ✓ អក្សរសិល្ប៍ គឺជាកម្រងអត្ថបទរឿងទាំងឡាយដែលអ្នកនិពន្ធបានតាក់តែងឡើងដោយបញ្ចូលនូវសិល្បវិធីដើម្បីទាក់ទាញអ្នកអាន អ្នកស្តាប់ឱ្យជក់ចិត្តជិតអារម្មណ៍។
  - ✓ ឆ្លុះបញ្ចាំង សម្តែង បង្ហាញឱ្យឃើញច្បាស់ពីអ្វីមួយ។
  - ✓ តថភាព ភាពពិតជាក់ស្តែងដែលមាននៅក្នុងសង្គម។
- **ពន្យល់ន័យប្រធាន:** តាមអត្ថន័យប្រធានចង់បង្ហាញថា រឿងព្រះវេស្សន្តរបានសម្តែងបង្ហាញឱ្យឃើញពីភាពពិតជាក់ស្តែងដែលកើតមានឡើងក្នុងសង្គមតាំងពីសម័យបុរាណម្ល៉េះ ដើម្បីឱ្យអ្នកសិក្សា ចេះដកស្រង់យកបទពិសោធល្អៗទុកជាមេរៀនសម្រាប់បច្ចុប្បន្នកាល។
- **បកស្រាយប្រធាន:** "រឿងព្រះវេស្សន្តរឆ្លុះបញ្ចាំងពីតថភាពសង្គមសម័យបុរាណ" ដោយសារដំណើររឿងបានបង្ហាញពីតថភាពសង្គមសម័យបុរាណដោយសារដំណើររឿងបានបង្ហាញពី៖
  - **គំនិតសំខាន់ និងឧទាហរណ៍**
    - ✓ របបគ្រប់គ្រង កាន់របបរាជានិយម
    - ✓ គំនិតប្រជាធិប្បតេយ្យការយកមតិរាស្ត្រជាធំដូចជា ព្រះបាទស្រីសញ្ជ័យគោរពតាមសំណូមពររាស្ត្រ សុខចិត្តបណ្តេញព្រះរាជបុត្រវេស្សន្តរចេញពីនគរ។

- ✓ ការដាក់ទាន បញ្ជាក់អំពីសប្បុរសធម៌ ចេះជួយគ្នាទៅវិញទៅមកមានសាមគ្គីភាព ជាពិសេសឥតមានការរើសអើងវណ្ណៈជាតិសាសន៍។ ដូចជាព្រះវេស្សន្តរដាក់ទានដំរីឱ្យអ្នកស្រុកកលិង្គរាស្ត្រ
- ✓ ផ្នត់គំនិត ការគោរពពាក្យសច្ចៈ ដូចជាព្រះវេស្សន្តរថាដាក់ទានត្រូវតែធ្វើឱ្យបាន
- ✓ ឆ្លុះបញ្ចាំងពីបរិបទសង្គមដែលមនុស្សទាំងអស់មានតែគំនិតបុគ្គលនិយមហួសហេតុ
- ✓ ជំនឿសាសនា ការជឿលើបុណ្យ បាបកម្មផល ការបួស
- ✓ ប្រពៃណីទំនៀមទម្លាប់ ការអភិសេកគ្រងរាជ្យ អភិសេករបស់ព្រះវេស្សន្តរ និងព្រះនាងមេទ្រី
- ✓ ការសិក្សាអប់រំ: ការសិក្សាធម៌វិន័យរបស់ព្រះវេស្សន្តរនៅក្នុងព្រៃគិរីវង្គត។

- **សរុបសេចក្តី:** សរុបសេចក្តីមករឿងព្រះវេស្សន្តរជាស្នាដៃអក្សរសិល្ប៍កើតតាំងពីសម័យបុរាណ ឆ្លុះបញ្ចាំងពីតថភាពពិតនៅសម័យបុរាណ តែហាក់ដូចជាបង្ហាញពីតថភាពសម័យបច្ចុប្បន្នបានយ៉ាងល្អ។ ដំណើររឿងបានរួមវិភាគទានយ៉ាងសំខាន់ក្នុងការបណ្តុះពុទ្ធិដល់អ្នកសិក្សា។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន:** ទស្សនៈនេះពិតជាមានអត្ថន័យល្អជ្រាលជ្រៅ...។ យល់ពីតម្លៃនៃស្នាដៃអក្សរសិល្ប៍
- **មតិផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមជាអ្នកសិក្សា...។

## សេចក្តីអធិប្បាយ

គ្រប់ស្នាដៃអក្សរសិល្ប៍ទាំងអស់ ទោះបីស្នាដៃនោះស្ថិតក្នុងប្រភេទណាក៏ដោយគឺសុទ្ធតែបានបង្ហាញពីភាពពិតជាក់ស្តែង ដែលតែងតែកើតមានឡើងនៅក្នុងសង្គមសម័យកាលនីមួយៗមកលាតត្រដាងយ៉ាងច្បាស់។ ក្នុងនោះរឿងព្រះវេស្សន្តរក៏បានលើកយកភាពពិតនៃសង្គមសម័យបុរាណមកលាតត្រដាងយ៉ាងច្បាស់។ អាស្រ័យហេតុនេះ ហើយទើបមានទស្សនៈមួយពោលថា «រឿងព្រះវេស្សន្តរឆ្លុះបញ្ចាំងពីតថភាពសង្គមសម័យបុរាណ»។

តើទស្សនៈខាងលើមានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

ដើម្បីបកស្រាយទស្សនៈប្រធានខាងលើឱ្យកាន់តែក្បោះក្បាយនិងស៊ីជម្រៅ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះជាមុនសិន។ ពាក្យនោះគឺ «អក្សរសិល្ប៍» គឺជាកម្រងអត្ថបទរឿងដែលអ្នកនិពន្ធបានតាក់តែងឡើង ដោយបញ្ចូលនូវសិល្បវិធី ដើម្បីទាក់ទាញអ្នកអាន អ្នកស្តាប់ឱ្យជក់ចិត្តជិតអារម្មណ៍។ រីឯពាក្យ«ឆ្លុះបញ្ចាំង»គឺសំដែងបង្ហាញឱ្យឃើញច្បាស់ពីអ្វីមួយ។ ចំណែកពាក្យ«តថភាព» គឺភាពពិតជាក់ស្តែងដែលមាននៅក្នុងសង្គម។ តាមអត្ថបទន័យរបស់ប្រធានចង់បង្ហាញថា រឿងព្រះវេស្សន្តរបានសម្តែងបង្ហាញឱ្យឃើញពីភាពពិត។ ជាក់ស្តែងដែលកើតមានឡើងនៅក្នុងសង្គមតាំងពីសម័យបុរាណដើម្បីឱ្យអ្នកសិក្សាដកស្រង់យកបទពិសោធល្អៗទុកជាមេរៀនសម្រាប់បច្ចុប្បន្នកាល។

ជាការពិតរឿងព្រះវេស្សន្តរបានឆ្លុះបញ្ចាំងពីតថភាពសង្គមសម័យបុរាណបានយ៉ាងច្បាស់មានថា រឿងនេះបានលើកយកភាពពិតជាក់ស្តែងសម័យមុនមកលាតត្រដាងយ៉ាងច្បាស់ក្នុងដំណើរទាំងមូល ។ បើនិយាយពីរឿងព្រះវេស្សន្តរឆ្លុះបញ្ចាំងតថភាពសង្គមសម័យបុរាណឱ្យឃើញពីរបបគ្រប់គ្រងពីការគោរព ប្រជាធិបតេយ្យ ការដាក់ទាន ផ្នត់គំនិតជំនឿសាសនា ប្រពៃណីទំនៀម

ទម្លាប់ សេដ្ឋកិច្ច និងការសិក្សាអប់រំជាដើម។ របបគ្រប់គ្រងនៅក្នុងរឿងព្រះវេស្សន្តរគឺការប្រកាន់យករបបរាជានិយមការឱ្យតម្លៃទៅលើស្តេចជាធំ។ ដូចជានគរត្រូវគ្រប់គ្រងដោយព្រះបាទស្រីសញ្ជ័យក៏ដូចជាព្រះវេស្សន្តរប្រជារាស្ត្ររស់នៅមានសេចក្តីសុខ។ ចំណែកគំនិតប្រជាធិបតេយ្យក៏បានបង្ហាញយ៉ាងច្បាស់ក្នុងដំណើររឿងដែរ គឺសម័យនោះគេប្រកាន់យកគំនិតរាស្ត្រជាធំ ដូចជាព្រះបាទស្រីសញ្ជ័យគោរពតាមសំណូមពររាស្ត្រសុខចិត្តបណ្តេញព្រះរាជាបុត្រវេស្សន្តរចេញពីនគរ។ ជាងនេះទៅទៀត ដំណើររឿងក៏បានឆ្លុះបញ្ចាំងឱ្យឃើញពីការដាក់ទានរបស់ព្រះវេស្សន្តរ ដែលបញ្ជាក់ពីអំពើសប្បុរសធម៌ចេះជួយគ្នាទៅវិញទៅមកប្រកបដោយសាមគ្គីភាពជាពិសេសគឺឥតមានការរើសអើងវណ្ណៈជាតិសាសន៍ដូចជាព្រះវេស្សន្តរដាក់ទានដល់ស្មូមក្រីក្រទូទៅព្រះអង្គដាក់ដំរីបច្ច័យនាគេន្ទ្រទៅឱ្យអ្នកស្រុកគលិង្គរាស្ត្រដែលជាអ្នកស្រុកផ្សេងក្រៅពីរាស្ត្រក្នុងនគររបស់ព្រះអង្គ។ លើសពីនេះទៀតរឿងព្រះវេស្សន្តរបានបង្ហាញពីផ្នត់គំនិតរបស់ខ្មែរសម័យបុរាណដែលនិយមឱ្យតម្លៃទៅលើពាក្យពិតសច្ចៈជាមូលដ្ឋាន ដូចជាព្រះអង្គប្រកាសថាត្រូវធ្វើទានបរិច្ចាគ ព្រះអង្គធ្វើបានមែនដោយរួមមានទាំងធនធាន បុត្រ និងភរិយាជាដើម។ ជាពិសេសរឿងនេះបានឆ្លុះបញ្ចាំងពីបរិបទសង្គមមួយដែលមនុស្សគិតពីប្រយោជន៍ផ្ទាល់ខ្លួន តែត្រូវបានព្រះវេស្សន្តរធ្វើជាគំរូដល់ការគិតប្រយោជន៍មនុស្សជាតិជាធំ។ រីឯជំនឿវិញ គេគោរពជឿលើបុណ្យបាបកម្មផលដែលមានឥទ្ធិពលពីព្រះពុទ្ធសាសនា។ ដូចជាជូជកធ្វើអាក្រក់ធ្វើបាបជាលីក្រស្នា មានចិត្តលោភលន់ជាបច្ច័យនាំឱ្យគាត់ហូបអាហាររហូតដល់ហាល់បែកពោះស្លាប់យ៉ាងវេទនា។ ជំនឿលើការបួសសន្សំកុសលនាំឱ្យឆ្ពោះទៅទីបរមសុខ។ ជាក់ស្តែង ព្រះវេស្សន្តរចេញបួសសន្សំបារមីនាំឱ្យទៅកើតនៅឋានតុសិតទេវលោក។ ក្នុងនោះដែរប្រពៃណីទំនៀមទម្លាប់ ក៏ឆ្លុះបញ្ចាំងក្នុងដំណើររឿងព្រះវេស្សន្តរដូចជាប្រពៃណីអភិសេកគ្រងរាជ្យនិងការអភិសេករៀបការរវាងព្រះវេស្សន្តរ និងព្រះនាងមេទ្រី។ ក្រៅពីនេះ វិស័យសេដ្ឋកិច្ចក៏បានរំលេចឱ្យឃើញយ៉ាងច្បាស់ផងដែរដូចជាការធ្វើកសិកម្ម ធ្វើស្រែចំការ។ អ្នកស្រុកកលិង្គរាស្ត្រជួបគ្រោះទុរភិក្សរាំងស្ងួតខ្វះទឹកធ្វើស្រែ ទើបមកសុំដំរីពីព្រះអង្គវេស្សន្តរដើម្បីឱ្យមានភ្លៀងធ្លាក់អាចបង្កបង្កើនផលធ្វើស្រែចំការបាន។ ក្រៅពីកសិកម្មក៏មានការធ្វើជំនួញផងដែរ ដូចជាព្រះវេស្សន្តរផ្តាំជូជក បើចង់យកបុត្រទៅដោះដូរយកប្រាក់សុំឱ្យទៅរកត្រកូលគ្រួសារណាដែលជាអ្នកធូរធារ។ ក្នុងនោះទៀតសោតការសិក្សាអប់រំ ក៏អ្នកនិពន្ធឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ដែរតាមរយៈការសិក្សាទៅលើធម៌វិន័យការចេញបួសរបស់ព្រះវេស្សន្តរនៅក្នុងព្រៃគិរីវង្កត។

សរុបសេចក្តីមក រឿងព្រះវេស្សន្តរជាស្នាដៃអក្សរសិល្ប៍ដែលកើតតាំងពីសម័យបុរាណឆ្លុះបញ្ចាំងពីតថភាពពិតនៅសម័យបុរាណ តែហាក់ដូចជាឆ្លុះពីតថភាពសម័យបច្ចុប្បន្នបានយ៉ាងល្អ។ ដំណើររឿងបានរួមវិភាគទានយ៉ាងសំខាន់ក្នុងការបណ្តុះពុទ្ធិដល់អ្នកសិក្សា។

ឆ្លងតាមការបកស្រាយយ៉ាងលម្អិតនូវគំនិតប្រធានខាងលើយើងអាចវាយតម្លៃបានថាគំនិតប្រធានពិតជាមានអត្ថន័យល្អ ជ្រាលជ្រៅព្រោះបង្កប់ខ្លឹមសារអប់រំដល់អ្នកសិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរទាំងឡាយឱ្យបានដឹងបានឃើញពីតថភាពសង្គមសម័យកាលដែលមានតាំងពីបុរាណ។ ជាពិសេសរឿងព្រះវេស្សន្តរ មានតម្លៃពិសេសក្នុងរឿងអក្សរសិល្ប៍ជាតិ។ ដូច្នេះក្នុងនាមអ្នកសិក្សាត្រូវព្យាយាមរៀនសូត្រយកចិត្តទុកដាក់លើការសិក្សាវិភាគគ្រប់អត្ថបទអក្សរសិល្ប៍ ដើម្បីទទួលបានចំណេះដឹងបទពិសោធន៍និងចូលរួមថែរក្សាឱ្យស្ថិតស្ថេរគង់វង្ស។

**ប្រធានទី៤:** មានទស្សនៈមួយយល់ថា«រឿងរាមកេរ្តិ៍ជារឿងបែបព្រាហ្មណ៍សាសនាតែទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា»។ ចូរអ្នកពន្យល់ឱ្យបានក្បោះក្បាយដោយលើកឧទាហរណ៍មកបញ្ជាក់ផង។

## សេចក្តីអធិប្បាយ

ប្រភេទអក្សរសិល្ប៍បុរាណស្ទើរតែទាំងអស់តែងតែទទួលនូវឥទ្ធិពលសាសនាក្នុងដំណើររឿង។ រឿងរាមកេរ្តិ៍ក៏ជាប្រភេទអក្សរសិល្បៈបុរាណដែលបានទទួលនូវឥទ្ធិពលសាសនាធំពីរដែរគឺព្រាហ្មណ៍សាសនានិងព្រះពុទ្ធសាសនា។ អាស្រ័យហេតុនេះហើយទើបបន្ទាប់ពីការសិក្សាអត្ថបទខាងលើរួចមកមានទស្សនៈមួយលើកឡើងថា «រឿងរាមកេរ្តិ៍ជារឿងព្រាហ្មណ៍សាសនា តែទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា»។

តើទស្សនៈខាងលើនេះមានខ្លឹមសារយ៉ាងដូចម្តេចខ្លះ?

មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយជាបឋមយើងគួរយល់ពាក្យព្រាហ្មណ៍សាសនា ឥទ្ធិពលនិងពាក្យ ព្រះពុទ្ធសាសនាជាមុនសិន។ ចំពោះពាក្យ«ព្រាហ្មណ៍សាសនា» មានន័យថាការទូន្មានប្រៀនប្រដៅរបស់អាទិទេពធំៗទាំងបីគឺព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរទៅលើពួកព្រាហ្មណ៍។ ដោយឡែកពាក្យ «ឥទ្ធិល» មានន័យថាកម្លាំងគ្របសង្កត់អនុភាពអំណាច។ ចំណែកឯពាក្យ«ព្រះពុទ្ធសាសនា» ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ន័យប្រធានគឺរឿងរាមកេរ្តិ៍ជារឿងដែលទូន្មានប្រៀនប្រដៅរបស់អាទិទេពធំៗទាំងបីទៅលើពួកព្រាហ្មណ៍ផងនិងទទួលកម្លាំងគ្របសង្កត់ពីពាក្យទូន្មានប្រៀបប្រដៅរបស់ព្រះពុទ្ធបរមគ្រូផង។

ជាការពិតណាស់ រឿងរាមកេរ្តិ៍ជារឿងស្ថិតក្នុងចលនាព្រាហ្មណ៍និយមហើយទទួលឥទ្ធិពលពីព្រះពុទ្ធសាសនាមែន។ នៅក្នុងលទ្ធិព្រាហ្មណ៍សាសនា ពួកព្រាហ្មណ៍បុរោហិតយល់ថាមានអាទិទេពធំៗបីសម្រាប់ផ្តល់សេចក្តីសុខដល់មនុស្ស គឺព្រះព្រហ្ម ព្រះនារាយណ៍ និងព្រះឥសូរ។ ចំពោះរឿងរាមកេរ្តិ៍យើងឃើញគេយកតែតួអង្គអវតារ ព្រះនារាយណ៍ ដែលជាអាទិទេពគ្រប់គ្រងថែរក្សាលោកមួយគត់មកបង្ហាញ គឺព្រះរាម។ ព្រះរាមពូកែផង និងផ្តល់សុខដល់មនុស្សសត្វទាំងឡាយផងជាក់ស្តែងពីខ្សែទី១ដល់ខ្សែទីបីព្រះរាមឈ្នះអស់យក្សទេវៈ និងមនុស្ស។ មិនតែប៉ុណ្ណោះព្រះរាមតំណាងសភាវៈល្អ ព្រោះព្រះអង្គសុខចិត្តដកខ្លួនថយចេញពីនគរដើម្បីឱ្យពាក្យសត្យរបស់ព្រះបិតាបានគង់វង្សនិងបញ្ចៀសជម្លោះក្នុងក្រុមគ្រួសារ។ ដោយសារព្រះរាមល្អនិងមានមហិទ្ធិឫទ្ធិពូកែនេះហើយដែលបណ្តាលឱ្យព្រះអាទិត្យឈប់ដើរហើយសុគ្រីពហនុមានពិភេគរត់មកជ្រកកោនធ្វើជាសេនាព្រះរាមមួយរំពេច។ ត្រង់នេះបញ្ជាក់ថាព្រះរាមអាចរកសុខអោយគេគ្រប់គ្នាបាន។ ព្រះរាមអាចកែប្រែធម្មជាតិឱ្យល្អប្លែកពីសភាពដើមផងនិងកែប្រែសត្វទាំងឡាយឱ្យក្លាយទៅជាសម្លាញ់និងគ្នា។ សូម្បីតែស្នេហារបស់ព្រះរាមចំពោះនាងសីតា ក៏ស្ថិតក្នុងលក្ខណៈព្រាហ្មណ៍សាសានាដែរ។ ស្នេហាក្នុងព្រាហ្មណ៍និយមអាចកើតឡើងបាន លុះត្រាតែស្ត្រីជាកំពូលនារីដែលមានគុណសម្បត្តិគ្រប់បែបយ៉ាងហើយបុរសជាគូស្នេហ៍ទៀតសោតជាអវតារ ឬជាបុរសដែលមានឫទ្ធានុភាពដ៏អស្ចារ្យអ្នកទាំងពីរបានអភិសេកដោយការប្រឡងមហិទ្ធិឫទ្ធិលើកធ្នូសរ។ ក្នុងរឿងរាមកេរ្តិ៍នាងសីតាជាកំពូលនារីដែលមានលម្អធ្វើឱ្យប្រុសៗជ្រួលច្របល់ចង់បានគ្រប់ៗគ្នាហើយ នាងកាន់សច្ចៈជាប់ជានិច្ចផង។ សច្ចៈធម៌ដែលនាងសីតាប្រកាន់គឺនាងសីតាស្រលាញ់ព្រះរាមនៅតែស្រលាញ់ដដែល ហើយថ្កោល

ទោសព្រះរាមនៅតែថ្កោលទោសដដែលដោយមិនព្រមរួមរស់ជាមួយព្រះរាមវិញឡើយ។ ក្រៅពីការបង្ហាញខាងលើ យើងឃើញចំណុចព្រាហ្មណ៍និយមជាច្រើនទៀតយ៉ាងណាមិញមានពិធីបូជាយញ្ញហោមពិធី ពីធីតបៈ ឬយោគៈជាទុក្ករកិរិយាតាមផ្លូវកាយ និងផ្លូវចិត្តដែលពួកឥសីទាំងឡាយធ្វើដើម្បីបូជា និងផ្គាប់ចិត្តអាទិទេព។ យ៉ាងនេះហើយបានជានៅក្នុងរឿងរាមកេរ្តិ៍ អ្នកបួសសុទ្ធតែមានឈ្មោះជាឫសី តាបស ឬបស្វី តួយ៉ាងឥសីពិស្វាមិត្រឥសីបញ្ចលិង្គមតង្គបពិតជាដើម។ ដោយព្រះរាមចង់ធ្វើបស្វី ដើម្បីតបៈនិងយោគៈមែនទែន ទើបមិនអនុញ្ញាតិឱ្យក្វខ័នតាមបម្រើ។ ព្រាហ្មណ៍និយមសំខាន់មួយទៀត គឺយុទ្ធវិធីមួយភាគធំពឹងផ្អែកលើធ្នូសរដែលសរទាំងនោះក្លាយជាអាវុធប្លែកៗ។

ដោយឡែកក្រៅពីមានលក្ខណៈព្រាហ្មណ៍សាសនា រឿងរាមកេរ្តិ៍ក៏បានទទួលនូវឥទ្ធិពលព្រះពុទ្ធសាសនាផងដែរ តួយ៉ាងពុទ្ធនិយមត្រូវបានប្រមូលផ្តុំលើតួអង្គព្រះរាម និងនាងសីតាមួយភាគធំដូចជាមានពាក្យពុទ្ធង្កូរកន្សែសារពេជ្ជពុទ្ធង្កូរតែងតែធ្វើអំពើល្អណាមួយដែលគេឱ្យឈ្មោះថាបារមីនិងត្រូវប្រើសន្តិវិធីជានិច្ចផង លះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីប្រយោជន៍រួមផង។ ជាក់ស្តែងក្វខ័នបានទទួលស្គាល់ព្រះរាមមុនគេថា ជាព្រះពោធិសត្វដូចមានឃ្លាកាព្យបញ្ជាក់ថា «ព្រះរាមរូបាកាយ.. ពូជពង្សពុទ្ធង្កូរ»។ សូម្បីតែព្រះរាមខ្លួនឯងក៏និយាយទៅរកសីតាតាមលំនាំព្រះពោធិសត្វនៅក្នុងព្រះពុទ្ធសាសនាដែរ ដូចល្បះកាព្យខាងលើបញ្ជាក់ថា«មេអាចស្វះស្វែងតាមបង ដើរដោយនូវគន្លងកន្សែសាពេជ្ជពោញាណ។...បងនឹងនាំមេមាសទៅដាក់ដល់ស្ថានឥតជំពាក់ គឺមហានិរោធនិព្វាន»។ ទាំងនេះសបញ្ជាក់ឱ្យឃើញថាព្រះរាមជាព្រះពោធិសត្វជាគូនឹងនាងសីតាដែលជាកន្សែសារពេជ្ជ។ លើសពីនេះទៅទៀត យើងឃើញមានទស្សនៈកម្មផលដែលជាទស្សនៈដ៏សំខាន់ក្នុងលទ្ធិព្រះពុទ្ធសាសនា។ តួយ៉ាងពេលព្រះរាមបែកបាក់គ្រួសារ ព្រះរាមពោលថា មកពីកម្មផលដែលព្រះអង្គបានសាង។ ឥសីពារទ្វាឡឱ្យបានលើកទស្សនៈស្តីពីជីវិតមកពន្យល់ព្រះរាមថាជីវិតគឺជាតិជរា មរណៈ អនិច្ចំ ទុក្ខំ អនត្តា។ មួយវិញទៀតពេលក្រុងខរប្រយុទ្ធជាមួយព្រះរាម ព្រះរាមត្រូវក្រុងខរដៀលថាខ្លាចពៀរវេរា។

សរុបសេចក្តីមករឿងរាមកេរ្តិ៍ ពិតជារឿងមានលក្ខណៈព្រាហ្មណ៍សាសនានិងទទួលឥទ្ធិពលពីព្រះពុទ្ធសាសនាមែន ព្រោះរឿងរាមកេរ្តិ៍បានយកលំនាំខ្លះតាមរាមាយណៈឥណ្ឌា តែដោយអ្នកនិពន្ធរឿងនេះជាពុទ្ធសាសនិកជនទើបធ្វើឱ្យរឿងរាមកេរ្តិ៍ទទួលឥទ្ធិពលពុទ្ធសាសនា។

ឆ្លងតាមការបកស្រាយទស្សនៈដែលលើកឡើងថា «រឿងរាមកេរ្តិ៍ជារឿងបែបព្រាហ្មណ៍សាសនាតែទទួលឥទ្ធិពីព្រះពុទ្ធសាសនា» ពិតជាមានខ្លឹមសារជ្រាលជ្រៅណាស់។ សង្គមខ្មែរតាំងពីមុនរហូតមកដល់បច្ចុប្បន្ននេះត្រូវបានជ្រាបចូលនៅសាសនាធំៗពីរគឺព្រាហ្មណ៍សាសនានិងព្រះពុទ្ធសាសនាតែនៅស្ថិតស្ថេរតែព្រះពុទ្ធសាសនាប៉ុណ្ណោះ។ ក្នុងនាមយើងជាពលរដ្ឋខ្មែរត្រូវទទួលស្គាល់សេរីភាពខាងជំនឿដោយមិនត្រូវបង្ខិតបង្ខំបុគ្គលណាអោយជឿលើជំនឿណាមួយឡើយ។

## ៩.២- ប្រធានអត្ថាធិប្បាយពិភាក្សា

### ប្រធានពិភាក្សាសុទ្ធ

ប្រធានទី១: មានមតិមួយពោលថា«រឿងរាមកេរ្តិ៍ជារឿងអច្ឆរិយៈហួសពីការពិតនៃការរស់នៅរបស់មនុស្សខ្មែរ»។ ចំពោះអ្នក តើយល់ដូចម្ដេច? ចូរពិភាក្សាព្រមទាំងលើកឧទាហរណ៍មកបញ្ជាក់ផង។

### សេចក្ដីអធិប្បាយ

រឿងរាមកេរ្តិ៍ជាប្រភេទវីរកថាដែលបានបរិយាយយ៉ាងវែងពីចម្បាំងនេះ ព្រះរាមបានកេណ្ឌទ័ពស្វាដែលមានយុទ្ធសិល្ប៍ខ្លាំងជួយច្បាំង ឯបក្សពួកក្រុងរាពណ៍វិញក៏បានប្រើមេទ័ពយក្ស ដែលមានវេទមន្តអស្ចារ្យទប់ទល់វិញដែរ។ ដោយសាររឿងរាមកេរ្តិ៍មានលក្ខណៈបែបនេះឯង ទើបមានមតិមួយពោលថា«រឿងរាមកេរ្តិ៍ ជារឿងអច្ឆរិយៈហួសពីការពិតនៃការរស់នៅរបស់មនុស្សខ្មែរ»។

តើមតិខាងលើនេះត្រឹមត្រូវដែរ ឬទេ?

មុននឹងឈានចូលដល់ការអធិប្បាយវែកញែកខ្លឹមសារប្រធានខាងលើឱ្យបានស៊ីជម្រៅ ជាដំបូងគួរយល់ពាក្យ«អច្ឆរិយៈ» ដែលមានន័យថាភាពអស្ចារ្យគួរឱ្យកោតស្ញប់ស្ញែងក្រៃពេក។ ប្រធាននេះមានន័យដោយខ្លីថា រឿងរាមកេរ្តិ៍ជារឿងអស្ចារ្យហួសពីការពិតនៃការរស់នៅរបស់មនុស្សខ្មែរ។

ជាការពិតណាស់ រឿងរាមកេរ្តិ៍បានលើកមកលាតត្រដាងនូវរឿងរ៉ាវប្លែកៗដូចជាតួអង្គព្រះឥន្ទ្រ ព្រះឥសូរ ព្រះព្រហ្ម ព្រះពាយ ព្រះភិរុណ ព្រះអាទិត្យ យក្ស សត្វ រុក្ខជាតិដែលតួអង្គទាំងនោះសុទ្ធតែចេះនិយាយប្រែកាឡាខ្លួនហោះហើរជ្រែកដីជ្រែកអាកាសដែលក្នុងសង្គមមនុស្សខ្មែរពុំធ្លាប់ជួបប្រទះទាល់តែសោះ ជាក់ស្ដែងគ្រាន់តែព្រះបាទជនកប្រកាសប្រឡងលើកធ្នូសរជ្រើសរើសធីតុបតី[19] ភ្លាម អាទិទេពនៅឋានត្រៃត្រិង្សទាំងអស់បានចុះមកឋានមនុស្សដើម្បីចូលរួមប្រឡងយកនាងសីតាដែរ។ តួយ៉ាងមានព្រះឥន្ទ្រព្រះឥសូរព្រះព្រាហ្មជាដើម។ បញ្ហាបែបនេះ ពុំមាននៅក្នុងសង្គមខ្មែរទាល់តែសោះ។ ភាពអច្ឆរិយៈមួយទៀត គឺព្រះរាមជាកំពូលអាទិទេពដែលមានព្រៃព្រឹក្សា សត្វសុទ្ធតែបានអបអរសាទរយ៉ាងគគ្រឹកគគ្រេង។ ជាក់ស្ដែង ពេលព្រះរាមយាងទៅកាន់ភ្នំចិត្រកូដព្រៃព្រឹក្សាដែលក្រៀមស្វិតស្រពោន បែរជាស្រស់បំព្រងចេញផ្លែផ្កាកូនខ្លារត់ទៅបៅដោះមេប្រើស ឯកូនប្រើសរត់ទៅបៅដោះមេខ្លា។ លើសពីនេះទៅទៀត ពេលព្រះរាមកំពុងផ្ទុំព្រះអាទិត្យពុំហ៊ានដើរនោះទេ ពោលគឺនៅនឹងថ្កល់តែម្ដង។ ព្រះរាមមានអាវុធដ៏អស្ចារ្យដែលមនុស្សពុំមាន គឺធ្នូសរដ៏តូចមួយអាចបាញ់ឱ្យទឹកសមុទ្រពុះ ឱ្យឆេះផែនដី និងសម្លាប់ជីវិតមនុស្សសត្វ យក្សបានម្ដងរាប់សែននាក់ដោយងាយស្រួល។ អស្ចារ្យនៅក្នុងរឿងរាមកេរ្តិ៍មួយទៀតដែលមនុស្សពុំធ្លាប់ឮនោះ គឺសត្វស្វាចេះនិយាយ មានកម្លាំងខ្លាំងមហិមាដូចជាហនុមានជាដើម។ ហនុមានចេះនិយាយទំនាក់ទំនងជាមួយអ្នកដទៃមានព្រះរាមជាដើម ហើយហនុមានថែមទាំងមានកម្លាំងខ្លាំងមហិមា។ យ៉ាងណាមិញ គ្រាន់តែពិភេកប្រើទៅរកថ្នាំមកព្យាបាលព្រះលក្ស្មណ៍ ហនុមានបានលើកភ្នំមួយទាំងមូលមកតែម្ដង។ ម្យ៉ាងវិញទៀត សង្គមមនុស្សគ្មានហើយរឿងរាមកេរ្តិ៍មាន គឺមហាជម្ពូមានភ្នែកក្រឡេកឆេះអាចការពារមិនឱ្យឆេះបានគឺមានតែអាវព្រះនារាយណ៍មួយប៉ុណ្ណោះ។ ចំណែកក្រុងរាពណ៍វិញហោះហើរ

[19] ធីតុបតី (រាជសព្ទ) កូនប្រសាប្រុស

ជ្រែកមេឃជ្រែកដីជ្រែកអាកាសវេហាស៍អាចប្រែកាឡារូបបានគ្រប់បែបយ៉ាង។ ដូចជាពេលក្រុងរាពណ៍ឆក់នាងសីតា ក្រុងរាពណ៍បានប្រែក្រឡាជាឥសីជាដើម។ ឯតួអង្គពាលីជាស្ដេចស្វាសោយរាជ្យនៅនគរខាស់ខិនបូរី គេមានលក្ខណៈអស្ចារ្យណាស់ដែរគឺអាចចាប់កន្ទុយនាគបោកលេងដោយគ្មានគ្រោះថ្នាក់អ្វីបន្តិចសោះ។ ក្រៅពីលក្ខណៈអស្ចារ្យទាំងនោះ រឿងរាមកេរ្តិ៍នៅមានលក្ខណៈអស្ចារ្យផ្សេងៗជាច្រើនទៀតតួយ៉ាងកុកចេះនិយាយ គ្រុឌចេះនិយាយ ត្រីចេះនិយាយ និងក្របីមានប្រពន្ធច្រើនជាដើម។

ដូច្នេះរឿងរាមកេរ្តិ៍ពិតជារឿងអច្ឆរិយហួសពីការពិតនៃការរស់នៅរបស់មនុស្សខ្មែរប្រាកដមែន។

តើរឿងរាមកេរ្តិ៍ ពិតជាមានភាពអច្ឆរិយហួសពីការពិតនៃការរស់នៅរបស់មនុស្សខ្មែរមែន ឬយ៉ាងណា?

អក្សរសិល្ប៍ជាវិទ្យាស្បង់មួយប្រភេទដែលចោទនិងដោះស្រាយបញ្ហាមនុស្សសង្គមតាមសិល្ប៍វិធីរបស់អ្នកនិពន្ធយ៉ាងណាមិញបញ្ហាអស្ចារ្យនៅក្នុងរឿងរាមកេរ្តិ៍គ្រាន់តែជាសិល្ប៍វិធីរបស់អ្នកនិពន្ធដើម្បីទាក់ទាញអារម្មណ៍អ្នកអាន អ្នកសិក្សាតែប៉ុណ្ណោះ។ តាមពិតរឿងរាមកេរ្តិ៍ជារឿងដែលបានឆ្លុះបញ្ចាំងពីការពិតរបស់មនុស្សនិងរឿងរ៉ាវដែលកើតឡើងនៅក្នុងសង្គមខ្មែរដែលមានតាំងពីមុនរហូតដល់បច្ចុប្បន្ន។ ព្រះរាមថ្វីត្បិតតែមានភាពអស្ចារ្យ ប៉ុន្តែព្រះរាមតំណាងឱ្យមនុស្សចក្រពត្តិល្មោភសង្គ្រាមនិងជាមនុស្សដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន។ ជាងនេះទៅទៀត ព្រះរាមជាតំណាងមនុស្សខ្មែរមួយប្រភេទដែលសាហាវឃោរឃៅ មិនស្គាល់អាក្រក់ល្អ សខ្មៅតួយ៉ាងព្រះរាមបញ្ជាឱ្យព្រះលក្សណ៍ចាប់យកនាងសីតាទៅសម្លាប់ទាំងមានផ្ទៃពោះដោយមិនស្ដាប់ការអង្វរកររបស់នាងឡើយ។ ព្រះរាមជាមនុស្សអន់មួយទៀតគឺត្រូវប្រពន្ធរត់ចោល។ ចំណែកក្រុងរាពណ៍វិញជាតំណាងមេដឹកនាំខ្មែរដែលផ្ដាច់ការល្មោភតណ្ហាមិនចេះស្ដាប់យោបល់អ្នកដទៃ។ យ៉ាងណាមិញ ពិភេកឱ្យយោបល់ល្អតែគេបែរជាដោះស្បែកជើង វាយក្បាលពិភេកកណ្ដាលទីកំពុងប្រជុំទៅវិញ។ រាពណ៍ជាមនុស្សទុទ្ធិដ្ឋិនិយម ព្រោះក្រុងរាពណ៍បានចោទនាងមណ្ឌោគីរី ជាប្រពន្ធថាមានគំនិតក្បត់ ព្រោះបានការពារពិភេក។ នៅក្នុងសង្គមខ្មែរ មានមនុស្សខ្លះជាអ្នកបម្រើគេដោយចង់ផ្គាប់ផ្គុនចៅហ្វាយធ្វើការងារលើសចៅហ្វាយនាយបញ្ជាជាក់ស្ដែងហនុមាន។ ហនុមានតំណាងមនុស្សខ្ញុំបម្រើគេមានចិត្តស្មោះត្រង់ បើចៅហ្វាយនាយឱ្យធ្វើត្រឹមនេះគេបែរជាធ្វើលើសទៅទៀត។ យ៉ាងណាមិញគ្រាន់តែពិភេកឱ្យទៅរកថ្នាំហនុមានបែរជាលើកភ្នំមួយទាំងមូលមកទៅវិញ។ ដោយឡែកពាលីនិងកុម្ភកាណ៌ជាតំណាងមនុស្សខ្មែរប្រកបដោយឧត្តមគតិស្នេហាជាតិ មាតុភូមិមិនព្រមលក់ខ្លួនឱ្យបរទេស។ ជាក់ស្ដែងទោះបីព្រះរាមប្រើវិធីទិញទឹកចិត្តដោយផ្ដល់បុណ្យស័ក្តិយ៉ាងណាក៏ដោយក៏គេពុំព្រម គេស៊ូស្លាប់ប្រសើរជាងរស់នៅជាខ្ញុំបរទេស។ ចំពោះពិភេកនិងសុគ្រីពវិញជាតំណាងជនខ្មែរដែលក្បត់ជាតិ ក្បត់ទឹកដីមាតុភូមិដោយចុះចូលជាមួយសត្រូវដើម្បីបានលុយកាក់បុណ្យស័ក្តិអំណាច។ ពាក្យចាស់បុរាណបានពោលថា «ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់»។ ចំពោះមហិង្សរាជ និងទូភីដែលជាឪពុកនិងកូនក៏មានលក្ខណៈដូចគ្នាដែរ ពោលគឺតំណាងមនុស្សល្មោភកាមតណ្ហាសាហាវឃោរឃៅហើយចូលចិត្តបង្កទំនាស់ជាមួយអ្នកជិតខាងដូចជាទូភីបានទៅរករឿងក្រុងពាលីជាដើម។ ចំណែកមហាជម្ពូជាតំណាងមនុស្សខ្មែរអព្យាក្រឹត្យឯករាជ្យដោយមិនរណបបរទេស។ ដូច្នេះរឿងរាមកេរ្តិ៍ពិតជាបានឆ្លុះបញ្ចាំងពីមនុស្សខ្មែរយ៉ាងសម្បូរបែបប្រាកដមែន។

ជារួមរឿងរាមកេរ្តិ៍ជារឿងមានភាពអច្ឆរិយៈខ្លះៗ ក៏ពិតមែនប៉ុន្តែភាពអច្ឆរិយៈនេះ គ្រាន់តែជាសិល្ប៍ វិធីដ៏ប៉ិនប្រសប់របស់អ្នកនិពន្ធប៉ុណ្ណោះ ការពិតតួអង្គទាំងនោះតំណាងនូវមនុស្សពិតៗដែលមាននៅក្នុងស្រទាប់សង្គមខ្មែរពោល គឺរឿងរាមកេរ្តិ៍ជារឿងរបស់មនុស្ស។

ឆ្លងតាមការវែកញែកមតិដែលពោលថា«រឿងរាមកេរ្តិ៍ជារឿងអច្ឆរិយៈហួសពីការពិតនៃការរស់នៅរបស់មនុស្សខ្មែរ» ជាមតិមិនត្រឹមត្រូវនោះទេ ព្រោះពុំទទួលស្គាល់នូវមុខងារនិងតួនាទីរបស់អក្សរសិល្ប៍ក្នុងការរួមចំណែកជួយសង្គម។ អក្សរសិល្ប៍គឺជាការផ្សំអច្ឆរិយៈនិងលោកិយសច្ចៈដើម្បីទាក់ទាញអ្នកអានអ្នកសិក្សា។ ក្នុងនាមយើងជាពលរដ្ឋខ្មែរត្រូវជួយថែរក្សារឿងរាមកេរ្តិ៍ឱ្យស្ថិតស្ថេរជាអមតៈនៅក្នុងខឿនអក្សរសិល្ប៍ជាតិខ្មែរ ដើម្បីទុកជាមរតកដល់កូនខ្មែរជំនាន់ក្រោយ។

---

**ប្រធានទី២:** គេយល់ថា « រាល់សកម្មភាពរបស់តួអង្គហនុមានក្នុងរឿងរាមកេរ្តិ៍ គ្មានភាពគាប់ប្រសើឡើយ»។ ចូរពិភាក្សាដោយរកឧទាហរណ៍បញ្ជាក់។

---

## គម្រោងតែង

### ក- ផ្ដើមសេចក្ដី

- **លំនាំបញ្ហា:** ស្នាដៃអក្សរសិល្ប៍តែងលើកយកនូវបញ្ហាផ្សេងៗដែលទាក់ទងនឹងជីវភាពរបស់មនុស្សនិងសង្គមមនុស្សមកបង្ហាញទុកជាការសិក្សាវិភាគ។ បញ្ហាទាំងឡាយនោះ គេឃើញសកម្មភាពលក្ខណៈតួអង្គក៏ត្រូវបានចាប់អារម្មណ៍ហើយកំណត់តម្លៃយ៉ាងសកម្មដោយមើលឃើញនូវភាពវិជ្ជមាននិង អវិជ្ជមានផងដែរ។
- **ចំណូលបញ្ហា:** ហេតុនេះហើយ ទើបគេយល់ថា « រាល់សកម្មភាពរបស់តួអង្គហនុមានក្នុងរឿងរាមកេរ្តិ៍គ្មានភាពគាប់ប្រសើរឡើយ»។
- **ចំណោទបញ្ហា:** តើទស្សនៈខាងលើត្រឹមត្រូវឬទេ?

### ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្តី :** មុននឹងវែកញែកពិភាក្សាលើបញ្ហាប្រធាន ឱ្យបានស៊ីជម្រៅត្រូវយល់ពាក្យខ្លះដូចជាសកម្មភាពនិងគ្មានភាពគាប់ប្រសើរ។
- **ពន្យល់ពាក្យ៖**
  - ✓ សកម្មភាព ជាទង្វើគ្រប់យ៉ាងរបស់បុគ្គលដែលស្តែងចេញតាមរយៈផ្លូវកាយនិងផ្លូវចិត្ត។
  - ✓ គ្មានភាពគាប់ប្រសើរ គឺគ្មានសេចក្តីល្អ ឬសេចក្តីថ្លៃថ្នូរ។
- **ពន្យល់ន័យ:** ទស្សនៈប្រធានមានន័យថា ទង្វើគ្រប់យ៉ាងរបស់ហនុមានក្នុងរឿងរាមកេរ្តិ៍ គ្មានសេចក្តីល្អ ឬសេចក្តីថ្លៃថ្នូរឡើយ។
- **បកស្រាយ៖**

ក- **មតិស្រប** « រាល់សកម្មភាពរបស់តួអង្គហនុមានក្នុងរឿងរាមកេរ្តិ៍គ្មានភាពគាប់ប្រសើរឡើយ» ព្រោះហនុមាន៖

- **គំនិតសំខាន់ និងឧទាហរណ៍៖**
  - ✓ មានសកម្មភាពច្រើន គឺធ្វើចាប់ពីផ្តើមរឿងរហូតបញ្ចប់រឿង
  - ✓ មានសកម្មភាពអវិជ្ជមាន បាត់ភាពគាប់ប្រសើរ

- ✓ បាត់បង់ឧត្ដមគតិគ្មានមនសិការស្នេហាជាតិ និងពូជសាសន៍ខ្លួនឯង
- ✓ ឃុបឃិតចូលដៃជាមួយសត្រូវ
- ✓ ធ្វើភាពព្រងើយកន្តើយបង្កភាពងាយស្រួលនិងជ្រោមជ្រែងបរទេសសម្លាប់បងប្អូននិងជាតិឯង
- ✓ គំនិតខ្ញុំគេច្រើនធ្វើជាម្ចាស់ការលើខ្លួនឯងទោះបីខ្លួនមានសមត្ថភាពខ្ពង់ខ្ពស់
- ✓ មោទនភាពលើខ្លួនឯងជ្រុលពេកដោយបាត់បង់នូវវិចារណញ្ញាណ
- ✓ អគុណធម៌ អមនុស្សធម៌ ចូលចិត្តគំរាមប្រមាថ និងបំផ្លាញអ្នកតូចតាចស្លូតត្រង់ទន់ខ្សោយ

- **សរុបមតិស្រប:** ដូច្នេះ សកម្មភាពរបស់ហនុមានពិតជាមិនគាប់ប្រសើរពិតប្រាកដមែន។

**ខ- មតិផ្ទុយ** «សកម្មភាពរបស់ហនុមានក៏មានភាពគាប់ប្រសើរ» ព្រោះហនុមានៈ

- ✓ ស្ថិតនៅត្រង់ជាអ្នកមានភាពស្មោះត្រង់បំផុតជាមួយម្ចាស់
- ✓ ប្រឹងប្រែងយកអស់កម្លាំងកាយចិត្តបញ្ញានិងសមត្ថភាពបម្រើគោរពបញ្ជាចៅហ្វាយនាយ
- ✓ មានសមត្ថភាពមហិទ្ធិរិទ្ធិនិងទេពកោសល្យខ្លាំងពូកែអាចធ្វើសម្រេចបានគ្រប់ការងារធំៗ
- ✓ មានភាពរហ័សរហួន អង់អាចក្លាហាន រឹងប៉ឹង មិនងាយចុះចាញ់ ខ្លាចអំណាច អ្នកដទៃ
- ✓ ជាអ្នកមានមហិទ្ធិរិទ្ធិខ្លាំងពូកែអាចហោះហើរជ្រែកទឹកដី និងក្លាហានធ្វើការងារធំៗបានជោគជ័យ
- ✓ ទៅយកការណ៍នៅក្រុងលង្កាយកថ្មដុះថ្នាំក្រោមក្បាលដំណេក ក្រុងរាពណ៍ និងលើកភ្នំរាប់រយ
- ✓ បានសម្លាប់មេទ័ពយក្សជាច្រើននិងហ៊ានគម្រាមព្រះអាទិត្យមិនឱ្យដើរបំភ្លឺលោក។

- **សរុបមតិផ្ទុយ:** សរុបមកសកម្មភាពហនុមាន ពិតជាមានភាពគាប់ប្រសើរមែន។

**គ- សំយោគ**

ជារួម បន្ទាប់ពីមានមតិពីរខ្វែងគំនិតគ្នាស្ដីពីសកម្មភាពរបស់ហនុមានរួចមកយើងអាចវិនិច្ឆ័យបានថា បើពិនិត្យលើមតិទីមួយចាត់ថាត្រឹមត្រូវម្យ៉ាងដោយទង្វើគ្រប់យ៉ាងបាត់បង់មនសិការឬវិចារណញ្ញាណ និងឧត្ដមគតិ លក់ខ្លួនឱ្យបរទេសទាំងស្រុង។ ឯមតិទីពីរវិញ ហាក់សមហេតុផលដែរ ដោយហនុមានបានបំពេញភារកិច្ចបានល្អ បម្រើប្រយោជន៍ចៅហ្វាយនាយគឺមានភាពស្មោះត្រង់ចំពោះអ្នកដឹកនាំជានិច្ច។ ហនុមានមានសកម្មភាពគាប់ប្រសើរក្នុងករណីណាដែលជាអ្នកបម្រើគេ ចេះស្ដាប់បង្គាប់ស្មោះត្រង់ចំពោះចៅហ្វាយនាយ។ ប៉ុន្តែសកម្មភាពហនុមានមិនគាប់ប្រសើរ ដោយលក់ខ្លួនបំផ្លាញជាតិនិងពូជសាសន៍ឱ្យបរទេស ពិសេសគ្មានមនសិការស្នេហាជាតិពូជសាសន៍និងយកសមត្ថភាពខ្ពង់ខ្ពស់ខ្លួនទៅបម្រើគេ មិនជឿ និងមានម្ចាស់ការលើខ្លួនឯង។

## គ- បញ្ចប់សេចក្ដី

- **វាយតម្លៃប្រធាន:** មតិប្រធានត្រឹមត្រូវម្យ៉ាងដែរ ព្រោះបានបង្ហាញឱ្យឃើញពីសារជាតិអាក្រក់របស់តួអង្គហនុមានក៏ដូចបុគ្គលក្នុងលោកដែលបាត់បង់តម្លៃខ្លួនឯងក្នុងការបង្កវិបត្តិធ្ងន់ធ្ងរចំពោះជាតិនិងពូជសាសន៍ខ្លួនឯង គិតតែប្រយោជន៍សួនតួ។
- **មតិផ្ទាល់ខ្លួន:** ទោះជាយ៉ាងណាក៏ដោយក៏មតិនេះបានផ្ដល់ជាគំនិតដាស់តឿន អប់រំមនុស្សឱ្យធ្វើអ្វីៗប្រកបដោយឧត្ដមគតិជាតិផងដែរ។ ដូច្នេះយើងត្រូវចេះដកស្រង់បទពិសោធ គំរូល្អៗពីស្នាដៃ អក្សរសិល្ប៍យកមកអនុវត្តក្នុងជីវិតដើម្បីឧត្ដមភាពខ្លួនឯងនិងជាតិមាតុភូមិ។

## សេចក្តីអធិប្បាយ

ជាទូទៅស្នាដៃអក្សរសិល្ប៍តែងលើកយកនូវបញ្ហាផ្សេងៗដែលទាក់ទងនឹងជីវភាពរបស់មនុស្សនិងសង្គមមនុស្សមកបង្ហាញទុកជាការសិក្សាវិភាគ។បណ្តាបញ្ហាទាំងឡាយនោះគេឃើញសកម្មភាពលក្ខណៈ តួអង្គក៏ត្រូវបានចាប់អារម្មណ៍ ហើយកំណត់តម្លៃយ៉ាងសកម្មដោយមើលឃើញនូវភាពវិជ្ជមាននិងអវិជ្ជមានផងដែរ។ ដោយឡែកក្នុងរឿងរាមកេរ្តិ៍ដែរជាអក្សរសិល្ប៍បុរាណខ្មែរល្បីល្បាញមួយ ក៏បានលើកយកសកម្មភាពតួអង្គ ដ៏ច្រើនសន្ធឹកសន្ធាប់មកលាតត្រដាងបង្ហាញដែរ ពិសេសតួអង្គហនុមានដែលសកម្មភាពមួយចំនួនហាក់មិនគួរជាទីពេញចិត្តឡើយ។ ហេតុនេះហើយ ទើបគេយល់ថា «រាល់សកម្មភាពរបស់តួអង្គហនុមានក្នុងរឿងរាមកេរ្តិ៍គ្មានភាពគាប់ប្រសើរឡើយ»។

តើទស្សនៈខាងលើត្រឹមត្រូវឬទេ?

មុននឹងវែកញែកពិភាក្សាលើបញ្ហាប្រធានឱ្យបានស៊ីជម្រៅត្រូវយល់ពាក្យខ្លះដូចជាសកម្មភាព និងគ្មានភាពគាប់ប្រសើរ។ «សកម្មភាព»មានន័យថា ជាទង្វើគ្រប់យ៉ាងរបស់បុគ្គលដែលស្តែងចេញតាមរយៈផ្លូវកាយនិងផ្លូវចិត្ត។ ឯ«គ្មានភាពគាប់ប្រសើរ»គឺគ្មានសេចក្តីល្អឬសេចក្តីថ្លៃថ្នូរ។ ទស្សនៈប្រធានមានន័យថា ទង្វើគ្រប់យ៉ាងរបស់ហនុមានក្នុងរឿងរាមកេរ្តិ៍ គ្មានសេចក្តីល្អ ឬសេចក្តីថ្លៃថ្នូរឡើយ។

គេអាចសម្រួបតាមមតិប្រធានបានដែរដោយមានហេតុផលបញ្ជាក់។ តាមដំណើររឿងរាមកេរ្តិ៍បង្ហាញថាហនុមាន មានសកម្មភាពច្រើន គឺធ្វើចាប់ពីផ្តើមរឿងរហូតបញ្ចប់រឿង។ ប៉ុន្តែសកម្មភាពតួអង្គនេះមួយចំនួនធំឈរលើលក្ខណៈអវិជ្ជមានបាត់ភាពគាប់ប្រសើរទៅវិញករណីបាត់បង់ឧត្តមគតិ គ្មានមនសិការស្នេហាជាតិ និងពូជសាសន៍ខ្លួនឯង ដោយឃុបឃិតចូលដៃជាមួយជនបរទេស ធ្វើភាពព្រងើយកន្តើយបង្កភាពងាយស្រួលនិងជ្រោមជ្រែងបរទេសសម្លាប់បងប្អូននិងជាតិឯងធ្ងន់ធ្ងរ។ ទន្ទឹមនេះដែរ ហនុមាន[20] ច្រើនបំពាក់នូវគំនិតខ្ញុំកញ្ជះគេច្រើនធ្វើជាម្ចាស់ការលើខ្លួនឯងទោះបីខ្លួនមានសមត្ថភាពខ្ពង់ខ្ពស់ ក៏ដោយពោលគឺចូលចិត្តបម្រើអ្នកដទៃឬបរទេស។ ជាមួយនេះដែរហនុមានធ្វើអ្វីៗឈរលើភាពស៊ីជោរ ឬមោទនភាពលើខ្លួនឯងជ្រុលពេកដោយបាត់បង់នូវវិចារណញ្ញាណព្រមទាំងជាជនគ្មានគុណធម៌អមនុស្សធម៌ចូលចិត្តគំរាមប្រមាថ និងបំផ្លាញអ្នកតូចតាចស្លូតត្រង់ទន់ខ្សោយជាអាទិ៍ដើម្បីគាំទ្រគំនិតសំខាន់ៗខាងលើនេះឱ្យកាន់តែពិស្តារ យើងមានឧទាហរណ៍តាមដំណើររឿងបញ្ជាក់បន្ថែម។ដើមឡើយហនុមានរស់មានសិទ្ធិសេរីភាពក្នុងព្រៃកន្ទលីវន ប៉ុន្តែពេលជួបព្រះរាម និងព្រះលក្ស្មណ៍កំពុងតាមរកនាងសីតា ដែលត្រូវក្រុងរាពណ៍ចាប់យកទៅហនុមានស្ម័គ្រចិត្តសុំបម្រើព្រះរាមដោយយកអស់កម្លាំងកាយចិត្តជីវិត។ ទន្ទឹមនេះហនុមានបានបណ្តោយឱ្យព្រះរាមបាញ់សម្លាប់ពាលីជាឪពុកមាខ្លួននិងយកនគរខាស់ខិនធ្វើជាអាណានិគមកេណ្ឌទ័ពស្វាទៅស្លាប់រាប់កោដិទៀតផង។ម្យ៉ាងទៀតហនុមានតែងធ្វើអ្វីៗហួសបញ្ជា ព្រះរាមករណី គំរាមមហាជម្ពូស្តេចស្វានៅនគរហេមពាន្តនិងដុតក្រុងលង្កាសម្លាប់យក្សស្លូតត្រង់ជាច្រើន ដែលគ្មានកំហុសជាដើម។ ពិសេសហនុមានសុខចិត្តបោះបង់អំណាចជាស្តេចដែលព្រះរាមរៀបចំឱ្យដោយវិលមកសុំបម្រើព្រះរាមវិញ និងប្រើកលល្បិចយំស្រែកបញ្ឆោតនាងសីតាឱ្យចូលនគរជាដើម។

---

[20] ហនុមាន ហៈនុម៉ាន សំ. (ន.) (ហនុមតិ, ហនុមន្ត, --មានិ, --មាន្តិ ឬ ហនូ--) ឈ្មោះស្តេចពានរមួយជាសេនារបស់ព្រះរាមក្នុងរឿងរាមកេរ្តិ៍ (ហៅ ពាយុបុត្រ ឬ វាយុបុត្រ ក៏បាន) ។ --មាន្ត

សរុបសេចក្តីមក សកម្មភាពរបស់ហនុមានមិនគាប់ប្រសើរពិតប្រាកដមែន។

ផ្ទុយទៅវិញគេឃើញមានទស្សនៈខ្លះទៀតជំទាស់ដោយយល់ផ្សេងថា«សកម្មភាពរបស់ហនុមានក៏មានភាពគាប់ប្រសើរ»ទៅវិញ ដោយការយល់នេះក៏មានហេតុផលបញ្ជាក់ដែរ។ តាមការពិនិត្យសង្កេតភាពគាប់ប្រសើររបស់ហនុមានស្ថិតនៅត្រង់ជាអ្នកមានភាពស្មោះត្រង់បំផុតជាមួយម្ចាស់ឬអ្នកដឹកនាំដោយប្រឹងប្រែងយកអស់កម្លាំងកាយចិត្តបញ្ញានិងសមត្ថភាពបម្រើគោរពបញ្ជាថៅហ្វាយនាយមិនឱ្យល្អក់ចិត្តឡើយ។ ម្យ៉ាងទៀតមានសមត្ថភាពមហិទ្ធិរិទ្ធិនិងទេពកោសល្យខ្លាំងពូកែអាចធ្វើសម្រេចបានគ្រប់ការងារធំៗដែលអ្នកដទៃមិនអាចធ្វើបាន។ ពិសេសជាអ្នកមានភាពរហ័សរហួន អង់អាចក្លាហាន រឹងប៉ឹង មិនងាយចុះចាញ់ ខ្លាចអំណាច ឬឥទ្ធិពលអ្នកដទៃដោយងាយៗឡើយពោលគឺក្នុងការប្រយុទ្ធ។ ជាក់ស្តែងតាមដំណើររឿងរាមកេរ្តិ៍បង្ហាញថា ហនុមានជាអ្នកមានមហិទ្ធិរិទ្ធិ ខ្លាំងពូកែអាចហោះហើរជ្រែកទឹកដី និងក្លាហានធ្វើការងារធំៗបានជោគជ័យដូចជាទៅយកការណ៍នៅក្រុងលង្កាយកថ្មដុះថ្នាំក្រោមក្បាលដំណេក ក្រុងរាពណ៍ និងលើកភ្នំមកឱ្យពិភេកដកថ្នាំ ពិសេសហ៊ានលើកយកមហាជម្ពូមកឱ្យព្រះរាមទៀតផង។ ក្នុងនោះដែរហនុមានបានសម្លាប់មេទ័ពយក្សជាច្រើននិងហ៊ានគម្រាមព្រះអាទិត្យមិនឱ្យដើរបំភ្លឺលោកដើម្បីជួយជីវិតព្រះលក្ស្មណ៍។ ដោយឡែកហនុមានស្មោះត្រង់ ចំពោះព្រះរាមជានិច្ចទោះបីគ្មានគុណធម៌ក៏ដោយ ដូចកាលហ៊ានកោរសក់មួយចំហៀងក្បាលបញ្ឆោតនាងសីតាឱ្យមកចូលរួមមរណសញ្ញាក្នុងរាំង «ព្រះរាមចូលកោដ្ឋ[21] បញ្ឆោតនាងសីតា»។

សរុបមកសកម្មភាពហនុមានពិតជាមានភាពគាប់ប្រសើរមែន។

ជារួម បន្ទាប់មានមតិពីរខ្វែងគំនិតគ្នាស្តីពីសកម្មភាពរបស់ហនុមានមក យើងអាចវិនិច្ឆ័យ[22] បានថាក្នុងមតិទីមួយចាត់ថា ត្រឹមត្រូវម្យ៉ាងដោយទង្វើគ្រប់យ៉ាងបាត់បង់មនសិការឬវិចារណ[23] ញ្ញាណ និងឧត្តមគតិជាតិ ពិសេសលក់ខ្លួនឱ្យបរទេសទាំងស្រុង។ ឯមតិទីពីរវិញ ហាក់សមហេតុផលដែរដោយហនុមានបានបំពេញភារកិច្ចបានល្អ បម្រើប្រយោជន៍ថៅហ្វាយនាយ ពិសេសមានភាពស្មោះត្រង់ចំពោះអ្នកដឹកនាំជានិច្ច។ ជាការពិតហនុមានមានសកម្មភាពគាប់ប្រសើរក្នុងករណីណាដែលជាអ្នកបម្រើគេ ចេះស្តាប់បង្គាប់ ស្មោះត្រង់ចំពោះថៅហ្វាយនាយ។ ប៉ុន្តែសកម្មភាពហនុមានមិនគាប់ប្រសើរដោយលក់ខ្លួនបំផ្លាញជាតិនិងពូជសាសន៍ឱ្យបរទេស ពិសេសគ្មានមនសិការស្នេហាជាតិ ពូជសាសន៍ និងយកសមត្ថភាពដ៏ខ្ពង់ខ្ពស់ខ្លួនទៅបម្រើគេមិនជឿម្ចាស់ការលើខ្លួនឯង។

[21] កោដ្ឋ កោត បា. ( ន. ) ជង្រុក ។ របស់សម្រាប់ដាក់សព, ដាក់ធាតុ ។ ឈ្មោះឈើមួយប្រភេទប្រើជាថ្នាំ ។

[22] វិនិច្ឆយ --និច-ឆៈយ៉ៈ បា.; សំ. ( ន. ) (វិនិឆ្ឆយ; វិនិឝ្ចយ) ការពិចារណាដោយល្អិត, ការពិនិត្យមើលឲ្យឃើញពិត; ដំណើរកាត់សង្ស័យ, ការរម្លីងសេចក្តីឲ្យអស់សង្ស័យ; ការជំនុំជម្រះសេចក្តី, ការកាត់សេចក្តី ។ ខ្មែរច្រើនប្រើជា កិ. "ជំនុំជម្រះអធិករណ៍, ជម្រះក្តី, កាត់ក្តី" : ចៅក្រមវិនិច្ឆ័យសេចក្តីតាមមាត្រាច្បាប់ ។ វិនិច្ឆយដ្ឋាន; វិនិច្ឆយសភា ឬ--សាលា សាលាជម្រះក្តី, សាលាជំនុំក្តី ។ វិនិច្ឆយធម៌ ធម៌សម្រាប់វិនិច្ឆ័យ, ច្បាប់សម្រាប់ជំនុំជម្រះកាត់ក្តី ។ វិនិច្ឆយមហាមាត្យ (--ម៉ាត; បា. វិនិច្ឆយ + មហា + អមត្ត > វិនិច្ឆយមហាមត្ត; សំ. វិនិឝ្ចយ + មហតិ + អមាត្យ) អមាត្យធំអ្នកសម្រេចការជំនុំក្តី, សេនាបតីឬរដ្ឋមន្ត្រីក្រសួងនគរបាល ។ វិនិច្ឆយាមាត្យ (--យ៉ាម៉ាត; បា. វិនិច្ឆយ + អមច្ច > វិនិច្ឆយាមច្ច; សំ. វិនិឝ្ចយ + អមាត្យ > វិនិឝ្ចយាមាត្យ) អមាត្យអ្នកជម្រះក្តី (ចៅក្រម) ។ល។ វិនិច្ឆ័យ

[23] វិចារណ៍ សំ. បា.( ន. ) (វិចារណ) ការពិចារណា, ការរិះរ, ការរំពឹងរកហេតុ, រកទំនង : អ្នកមានវិចារណ៍ច្រើនតែធ្វើការមិនឆ្គង ។ ព. កា. ថា: អ្នកប្រាជ្ញលោកថា ត្រូវមានវិចារណ៍ ក្នុងការផ្គូផ្គង គិតហើយសឹមធ្វើ ការសារពើផង ទើបសមបំណង ពុំដែលខុសខូច ។

ឆ្លងតាមការវែកញែកខាងលើនេះបានឱ្យឃើញថា មតិប្រធានត្រឹមត្រូវម្យ៉ាងដែរ ព្រោះបានបង្ហាញឱ្យឃើញពីសារជាតិអាក្រក់របស់តួអង្គហនុមាន ក៏ដូចបុគ្គលក្នុងលោកដែលបាត់បង់តម្លៃខ្លួនឯងក្នុងការបង្កវិបត្តិធ្ងន់ធ្ងរចំពោះជាតិនិងពូជសាសន៍ខ្លួនឯង គិតតែប្រយោជន៍សួនតួ[24]។ ទោះជាយ៉ាងណាក៏ដោយ ក៏មតិនេះបានផ្តល់ជាគំនិតដាស់តឿនអប់រំមនុស្សឱ្យធ្វើអ្វីៗប្រកបដោយឧត្តមគតិជាតិផងដែរ។ ដូច្នេះយើងត្រូវចេះដកស្រង់បទពិសោធ គំរូល្អៗពីស្នាដៃអក្សរសិល្ប៍យកមកអនុវត្តក្នុងជីវិត ដើម្បីឧត្តមភាពខ្លួនឯងនិងជាតិមាតុភូមិ។

---

**ប្រធានទី៣:** អ្នកសិក្សាមួយចំនួនវាយតម្លៃថា«ស្នេហាទុំទាវជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយ»។ តើអ្នកយល់យ៉ាងណា? ចូរពិភាក្សា។

---

## គម្រោងតែង

**ក- ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា:** អក្សរសិល្ប៍ គឺជាអត្ថបទរឿងដែលអ្នកនិពន្ធតាក់តែងឡើងសម្រាប់អានកម្សាន្តកែអផ្សុកផងនិងអប់រំសង្គមផង។ ស្នាដៃជាច្រើនដែលយើងធ្លាប់សិក្សាកន្លងមកសុទ្ធតែបានបង្ហាញពីគំនិតមនោសញ្ចេតនាស្នេហា ផ្អែមល្ហែមល្វីងជូរចត់ និងផ្តល់គំនិតដល់សង្គមយ៉ាងពិតប្រាកដ។ ពិសេសរឿង ទុំទាវដែល
  ជាស្នាដៃរបស់ភិក្ខុសោមបានលើកយកគំរូស្នេហារបស់ទុំនិងទាវមកបង្ហាញ។
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** ហេតុដូច្នេះហើយ ទើបមានអ្នកសិក្សាមួយចំនួន វាយតម្លៃថា «ស្នេហាទុំទាវជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយ»។
- **ចំណោទបញ្ហា:** តើការវាយតម្លៃបែបនេះ ត្រឹមត្រូវដែរឬទេ?

**ខ- តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីពន្យល់ពិភាក្សាលើប្រធានបទនេះឱ្យកាន់តែស៊ីជម្រៅ និងច្បាស់លាស់ យើងគប្បីស្វែងយល់ពាក្យគន្លឹះទាំងនេះជាមុនសិន។
- **ពន្យល់ពាក្យ៖**
  - ✓ ស្នេហា ជាការស្រឡាញ់ជាប់ចិត្តរវាងគ្នាទៅវិញទៅមក។
  - ✓ គំរូអាក្រក់ សំដៅលើមេរៀន ឬបទពិសោធអាក្រក់។
- **ពន្យល់ន័យប្រធាន:** មតិប្រធានមានន័យថាការស្រឡាញ់ជាប់ចិត្តរវាងគ្នានិងគ្នានៃតួអង្គទុំនិងទាវ ជាមេរៀន ឬបទពិសោធអាក្រក់ដល់មនុស្សជំនាន់ក្រោយ។
- **បកស្រាយ៖**

  **ក- មតិស្រប** « ស្នេហាទុំទាវជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយ»ព្រោះ៖
  - **គំនិតសំខាន់ និងឧទាហរណ៍៖**
    - ✓ អ្នកទាំងពីរមិនគោរពតាមដំបូន្មានអ្នកមានគុណ
    - ✓ ប្រព្រឹត្តខុស រំលងប្រពៃណីខ្មែរ
    - ✓ ទាវស្រឡាញ់ទុំដោយអារម្មណ៍ស្រើបស្រាលទាំងខ្លួនកំពុងចូលម្លប់

---

[24] សួនតួ បុគ្គលដែលគិតប្រយោជន៍ខ្លួនជាធំ មិនគិតអ្នកនៅជុំវិញខ្លួនឡើយ។

- ✓ ធ្វើឱ្យប៉ះពាល់ដល់សីលធម៌រស់នៅ ច្បាប់សង្គម និងសាសនា
- ✓ ទុំស្រឡាញ់ស្រីទាំងខ្លួននៅជាសង្ឃ ធ្វើឱ្យប៉ះពាល់ដល់ផ្នែកសាសនា
- ✓ អ្នកទាំងពីរជាអ្នករួមចំណែកខុសដូចគ្នា
- ✓ ជាកូនអកតញ្ញូមិនគោរពដំបូន្មានឪពុកម្តាយ
- ✓ ជាអ្នកធ្វើឱ្យសីលធម៌ប្រពៃណីខ្មែរធ្លាក់ចុះ។

- **សរុបមតិស្រប**: សរុបមកឃើញថាស្នេហាទុំទាវ គឺពិតជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយពិតប្រាកដមែន ព្រោះស្នេហាអ្នកទាំងពីរបង្ហាញតែពីភាពស្រើបស្រាលត្រេកត្រអាលប្រព្រឹត្តខុសប្រពៃណីតែប៉ុណ្ណោះ។
- **សំណួរភ្ជាប់សេចក្តី**: តើស្នេហាទុំទាវ គឺពិតជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយមែនឬ?

**ខ- មតិផ្ទុយ** «ស្នេហាទុំទាវ ជាគំរូល្អដល់យុវជនជំនាន់ក្រោយ» ព្រោះ៖

- **គំនិតសំខាន់ និងឧទាហរណ៍**
  - ✓ ស្នេហាអ្នកទាំងពីរជាស្នេហាបរិសុទ្ធស្មោះស្ម័គ្រ
  - ✓ មានភក្តីភាព និងទំនួលខុសត្រូវ
  - ✓ ស៊ូស្លាប់ដើម្បីប្រឆាំងនឹងទស្សនៈចាស់គំរិល«នំមិនធំជាងនាឡិ»
  - ✓ តួអង្គទាំងពីរជាអ្នកផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមានឱ្យមកជាផ្នត់គំនិតវិជ្ជមានសម្រាប់មនុស្សជំនាន់ក្រោយ
  - ✓ ជាតួអង្គមានទស្សនៈជឿនលឿន តាមទារសិទ្ធិសេរីភាព ក្នុងការជ្រើសរើសគូស្រករ
  - ✓ ជាអ្នកស្ថាបនាទំនៀមទំលាប់ បុរាណឱ្យមានលក្ខណៈល្អប្រសើរ។

- **សរុបមតិផ្ទុយ**: សរុបមក ស្នេហាទុំទាវ គឺពិតជាគំរូល្អដល់យុវជនជំនាន់ក្រោយប្រាកដមែន ព្រោះយុវជនទាំងពីរនាក់នេះហ៊ានប្រឆាំងនឹងទំនៀមទំលាប់ អភិរក្សនិយមហួសហេតុ ពិសេសបំបិទសិទ្ធិ សេរីភាពរបស់យុវជនក្នុងការជ្រើសរើសគូស្រករ។

**គ- សំយោគមតិ៖**

- ✓ មតិទីមួយគឺមតិស្រប សមហេតុផលម្យ៉ាងដែរ
- ✓ មតិទីពីរគឺមតិផ្ទុយ ក៏មានអំណះអំណាងត្រឹមត្រូវម្យ៉ាងដែរ
- ✓ ក៏ប៉ុន្តែទោះបីមតិទាំងនេះមានអំណះអំណាងរៀងៗខ្លួនក៏ដោយក៏គេអាចនិយាយបានថាមតិទីពីរគឺមតិផ្ទុយត្រឹមត្រូវជាង។

## គ- យោបល់បញ្ចប់

- **វាយតម្លៃប្រធាន**: ទស្សនៈប្រធានមិនទាន់ត្រឹមត្រូវគ្រប់ជ្រុងជ្រោយទេ ព្រោះ...។
- **មតិផ្ទាល់ខ្លួន**: ក្នុងនាមយើងជាអ្នកសិក្សា យើងត្រូវចេះវាយតម្លៃទៅលើអ្វីដែលល្អនិងអាក្រក់ដើម្បីឆ្ពោះទៅរកការសន្និដ្ឋានរួមមួយឱ្យបានត្រឹមត្រូវដើម្បីជួយកែលម្អ ទំនៀមទម្លាប់ប្រពៃណីខ្មែរឱ្យរិតតែល្អថែមទៀត។

# សេចក្តីអធិប្បាយ

អក្សរសិល្ប៍ គឺជាអត្ថបទរឿងដែលអ្នកនិពន្ធតាក់តែងឡើងសម្រាប់អានកម្សាន្តកែអផ្សុកផង និងអប់រំសង្គមផង។ ស្នាដៃជាច្រើនដែលយើងធ្លាប់សិក្សាកន្លងមកសុទ្ធតែបានបង្ហាញពីគំនិត មនោសញ្ចេតនា ស្នេហាផ្អែមល្ហែម ល្វីងជូរចត់ និងផ្តល់គំនិតអប់រំ ដល់សង្គមយ៉ាងពិតប្រាកដ។ ពិសេសរឿងទុំទាវដែលជាស្នាដៃរបស់ភិក្ខុសោមបានលើកយកគំរូស្នេហារបស់តួអង្គទុំនិងទាវមកបង្ហាញ ធ្វើឱ្យអ្នកសិក្សាមួយចំនួនវាយតម្លៃថា «ស្នេហាទុំទាវជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយ»។

តើការវាយតម្លៃបែបនេះត្រឹមត្រូវ ដែរឬទេ?

ដើម្បីពិភាក្សាលើប្រធានបទនេះឱ្យបានស៊ីជម្រៅនិងច្បាស់លាស់យើងគប្បីស្វែងយល់ពាក្យគន្លឹះទាំងនេះជាមុនសិន។ពាក្យថា«ស្នេហា» មានន័យថា ការស្រឡាញ់ជាប់ចិត្តរវាងគ្នាទៅវិញទៅមក។ ឯពាក្យ «គំរូអាក្រក់» សំដៅលើមេរៀនឬបទពិសោធអាក្រក់។ មតិប្រធានខាងលើមានន័យថា ការស្រឡាញ់ជាប់ចិត្តរវាងគ្នានិងគ្នានៃតួអង្គទុំនិងទាវ ជាមេរៀន ឬបទពិសោធអាក្រក់ដល់មនុស្សជំនាន់ក្រោយ។

ពិតមែនហើយស្នេហាទុំទាវជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយ ព្រោះអ្នកទាំងពីរមិនគោរពតាមឪពុកម្តាយដែលជាអ្នកមានគុណ ពិសេសប្រព្រឹត្តខុសរំលងប្រពៃណីខ្មែរទៀតផង។ ជាក់ស្តែងនៅពេលដែលលោកគ្រូចៅអធិការហាមមិនឱ្យសឹកគេលួចសឹកម្នាក់ឯងនៅក្បែរជំហ្វកមិនគោរពអ្នកមានគុណបន្តិចសោះឡើយ។ចំណែកទាវក៏ដូចគ្នាដែរហ៊ានប្រឆាំងនឹងម្តាយស្រឡាញ់ប្រុសដោយចិត្តឯងដោយគ្មានការយល់ព្រមពីអ្នកមានគុណ។ មិនតែប៉ុណ្ណោះ ហ៊ានប្រព្រឹត្តខុសគន្លងប្រពៃណីលួចរួមរក្សជាមួយទុំក្នុងពេលដែលម្តាយមិននៅ។ ហ៊ានស្រឡាញ់ទុំដោយអារម្មណ៍ស្រើបស្រាលទាំងខ្លួនកំពុងចូលម្លប់។ លើសពីនេះអ្នកទាំងពីរមិនបានគិតគូរឱ្យបានវែងឆ្ងាយជាហេតុធ្វើឱ្យប៉ះពាល់ដល់សីលធម៌រស់នៅច្បាប់សង្គមនិងសាសនាទៀតផង។ តួយ៉ាងទុំជាអ្នកបួសហេតុអ្វីស្រឡាញ់ស្រីទាំងខ្លួននៅជាសង្ឃយ៉ាងដូច្នេះ។ នេះជាគំរូអាក្រក់មួយដែលធ្វើឱ្យប៉ះពាល់ដល់ផ្នែកសាសនា។ ចំពោះទាវវិញ ក៏រួមចំណែកខុសដូចគ្នាដែរខ្វះអីប្រុសជាច្រើនមិនស្រឡាញ់ទៅស្រឡាញ់ទុំជាសង្ឃទៅវិញ។ ទាំងនេះគេអាចនិយាយបានថា ទាវគឺជាកូនអកតញ្ញូមិនគោរពតាមដំបូន្មានរបស់ឪពុកម្តាយធ្វើឱ្យគ្រួសារអាប់ឱនកិត្តិយស។ ជាមនុស្សធ្វើឱ្យសីលធម៌ ប្រពៃណីខ្មែរធ្លាក់ចុះដោយសារតែយុវជនពីរនាក់នេះមានអារម្មណ៍ស្រើបស្រាល ទាំងខ្លួននៅក្មេងសាវ បណ្តែតបណ្តោយខ្លួនឱ្យឈ្លក់វង្វេងក្នុងផ្លូវតណ្ហា។

សរុបមកឃើញថា ស្នេហាទុំទាវគឺពិតជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយពិតប្រាកដមែន ព្រោះ ស្នេហារបស់អ្នកទាំងពីរបង្ហាញពីភាពត្រេកត្រអាលប្រព្រឹត្តខុសប្រពៃណីតែប៉ុណ្ណោះ។

តើស្នេហាទុំទាវគឺពិតជាគំរូអាក្រក់ដល់យុវជនជំនាន់ក្រោយមែនឬទេ?

មិនពិតទេ ស្នេហាទុំទាវគឺពិតជាគំរូល្អដល់យុវជនជំនាន់ក្រោយទៅវិញទេ ព្រោះស្នេហារបស់អ្នកទាំងពីរជាស្នេហាមួយបរិសុទ្ធ ស្មោះស្ម័គ្រមួយទល់នឹងមួយ មានភក្តីភាពទៅវិញទៅមក និងទំនួលខុសត្រូវខ្ពស់។ ស្នេហាអ្នកទាំងពីរសុខចិត្តស៊ូស្លាប់ដើម្បីប្រឆាំងនឹងទស្សនៈ «នំមិនធំជាងនាឡិ» ហ៊ានរើបម្រះទាមទារសិទ្ធិសេរីភាពពីអំណាចនិយមរបស់គ្រួសារ។ ការប្រឆាំងទៅលើការឱ្យតម្លៃអំណាច បុណ្យសក្តិ ទ្រព្យសម្បត្តិដែលម្តាយទាវយល់ថាជាប្រភពនៃសុភមង្គល។ លើសពីនេះ

អ្នកទាំងពីរហ៊ានតវ៉ានឹងព្រះរាជា ពេលដែលព្រះរាជាយកនាងទាវមកធ្វើជាស្នំឯក។មិនតែប៉ុណ្ណោះ ពួកគេហ៊ានសារភាពសេចក្តីស្នេហារបស់ខ្លួនថ្វាយព្រះរាជា ជាគូស្នេហ៍ដែលមានភក្តីភាពស្មោះស្ម័គ្រ។ ពិសេសជាងនេះទៀត នៅពេលដែលម្តាយទាវបង្ខំឱ្យរៀបការជាមួយម៉ឺនងួនកូនអរជូន អ្នកទាំងពីរបានជម្នះឧបសគ្គប្រឆាំងនឹងម្តាយរបស់ខ្លួន។ ទង្វើរបស់ម្តាយទាវ បានធ្វើឱ្យទាវប្រឆាំងដាច់ខាតមិនព្រមរៀបការជាមួយម៉ឺនងួនឡើយ។ នាងបានផ្ញើលិខិតទៅឱ្យទុំប្រាប់ពីដំណើររឿងសព្វគ្រប់ ទុំក៏បានធ្វើដំណើរមករកទាវក្នុងបំណងនាំទាវទៅលង្វែកវិញ ប៉ុន្តែមិនដូចបំណងឡើយ។ អរជូននិងបក្សពួកបានចាប់ចងទុំយកទៅសម្លាប់នៅពេលនោះភ្លាម។ ឯទាវគ្រាន់តែឮថាទុំត្រូវគេសម្លាប់ក៏ទៅសម្លាប់ខ្លួនជាមួយទុំដែរនេះបញ្ជាក់ថាស្នេហាអ្នកទាំងពីរជាគំរូល្អមួយសម្រាប់យុវជនជំនាន់ក្រោយ ព្រោះពួកគេហ៊ានប្តូរផ្តាច់ជាមួយគ្នារហូតអវសាននៃជីវិតចុងក្រោយ។ គំរូល្អមួយទៀតដែលគួរឱ្យកត់សម្គាល់ដែរនោះ  គឺតួអង្គទាំងអស់នេះហើយដែលបានផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមានមកជាផ្នត់គំនិតវិជ្ជមានវិញដើម្បីឱ្យកូនចៅជំនាន់ក្រោយទទួលបានសិទ្ធិសេរីភាពពេញបរិបូរក្នុងការជ្រើសរើស គូស្រករ។ មួយវិញទៀត គេអាចនិយាយបានថា តួអង្គទុំទាវ គឺជាតួអង្គបដិវត្តអក្សរសិល្ប៍ ដើម្បីឱ្យយុវជនជំនាន់ក្រោយធ្វើជាគំរូក្នុងការស្តាបនាទំនៀមទម្លាប់មួយចំនួនឱ្យមានលក្ខណៈល្អប្រសើរបំផុត។

សរុបមកស្នេហាទុំទាវគឺពិតជាគំរូល្អដល់យុវជនជំនាន់ក្រោយពិតប្រាកដមែន ព្រោះយុវជនទាំងពីរនាក់នេះហ៊ានប្រឆាំងទំនៀមទម្លាប់អភិរក្សនិយមហួសហេតុ ពិសេសបំបិទសិទ្ធិសេរីភាពរបស់យុវជនក្នុងការជ្រើសរើសគូស្រករ។

ជារួម មតិទីមួយគឺមតិស្របក៏ត្រឹមត្រូវម្យ៉ាងដែររីឯមតិផ្ទុយក៏មានអំណះអំណាងសមហេតុម្យ៉ាងដែរ  ប៉ុន្តែទោះជាមានអំណះអំណាងរៀងៗខ្លួនយ៉ាងណាក៏ដោយ ក៏គេអាចវាយតម្លៃបានថា មតិផ្ទុយត្រឹមត្រូវជាងព្រោះទុំនិងទាវជាយុវជនជឿនលឿនមានគំនិតរីបម្រះទាមទារសេរីភាព ដើម្បីទុកជាមេរៀនដល់យុវជនជំនាន់ក្រោយកុំឱ្យរស់ក្រោមគំនាបសង្កត់ពីប្រពៃណីបែបនេះតទៅទៀត។

ឆ្លងតាមការពិភាក្សាខាងលើយ៉ាងល្អិតល្អន់រួចមកហើយ យើងឃើញថាមតិប្រធានពុំទាន់ត្រឹមត្រូវគ្រប់ជ្រុងជ្រោយទាំងអស់នៅឡើយទេ ព្រោះស្នេហាទុំទាវមិនមែនជាគំរូអាក្រក់ទាំងអស់នោះទេ វាបានជាវិភាគទានមួយចំណែកសម្រាប់ឱ្យអ្នកសិក្សាជំនាន់ក្រោយឱ្យចេះពិចារណារកហេតុផលត្រឹមត្រូវ។ដូចនេះក្នុងនាមជាខេមរជនយើងត្រូវចេះឱ្យតម្លៃទៅលើអ្វីដែលល្អនិងអាក្រក់ដើម្បីឆ្ពោះទៅរកការសន្និដ្ឋានមួយឱ្យបានត្រឹមត្រូវ ដើម្បីជួយកែលម្អទំនៀមទម្លាប់ប្រពៃណីខ្មែរឱ្យរឹតតែល្អថែមទៀត។

## ប្រធានពិភាក្សាប្រៀបធៀប

**ប្រធានទី១:** មតិទីមួយយល់ថា« ដើម្បីបញ្ចប់ទំនាស់គួរយកវិធីហិង្សាមកដោះស្រាយទើបបានលទ្ធផលល្អ»។ ឯមតិទីពីរប្រឆាំងដាច់ខាតថា «ដើម្បីបញ្ចប់ទំនាស់គួរយកវិធីអហិង្សាមកដោះស្រាយទើបបានលទ្ធផលល្អ»។ តើអ្នកមានយោបល់យ៉ាងណា? ចូរពិភាក្សា ដោយលើកយកឧទាហរណ៍ជាក់ស្តែងក្នុងរឿងរាមកេរ្តិ៍រឿងព្រះវេស្សន្តរមកបញ្ជាក់ផង។

### សេចក្តីអធិប្បាយ

ក្នុងជីវភាពរស់នៅ តែងមានទំនាស់កើតឡើងជាយថាហេតុ ប៉ុន្តែដើម្បីបញ្ចប់ទំនាស់គ្រប់ប្រភេទដោយជោគជ័យបាន គេត្រូវមានវិធីដោះស្រាយប្លែកៗ។ វិធីដោះស្រាយខែងវែងនាំឱ្យគេទទួលបានផលល្អ តែវិធីមិនខែងវែងអាចនាំឱ្យគេបរាជ័យក៏មាន។ ក្នុងបណ្តាវិធីទាំងនោះមានការជជែកគ្នាមិនដាច់ស្រេចសោះ ក្នុងនោះមតិទីមួយយល់ថា «ដើម្បីបញ្ចប់ទំនាស់គួរយកវិធីហិង្សា មកដោះស្រាយទើបបានលទ្ធផលល្អ»។ ឯមតិទីពីរប្រឆាំងដាច់ខាតថា «ដើម្បីបញ្ចប់ទំនាស់គួរយកវិធីអហិង្សាមកដោះស្រាយ ទើបបានលទ្ធផលល្អ»។

តើមតិទាំងពីរខាងលើនេះមួយណាត្រឹមត្រូវជាងមួយណា?

ជាបឋមដើម្បីក្នុងការបកស្រាយវែកញែកមតិប្រធានឱ្យបានស៊ីជម្រៅ ជាដំបូងយើងគួរគប្បីយល់ពាក្យ«ទំនាស់»«វិធីហិង្សា»និង«វិធីអហឹង្សា»ជាមុនសិន។ ពាក្យ«ទំនាស់»ក្នុងទីនេះមានន័យថាការប្រឈមមុខដាក់គ្នា ការឈ្លោះទាស់ទែងគ្នា ឯពាក្យ «ហិង្សាវិធី» មានន័យថាការបៀតបៀនដោយកម្លាំងបាយ ការប្រយុទ្ធដោយកម្លាំងបាយ។ ដោយឡែកពាក្យ«វិធីអហិង្សា» មានន័យថាវិធីចរចាដោយសន្តិវិធី។ ន័យមតិទីមួយចង់បង្ហាញថាដើម្បីបញ្ចប់ការប្រឈមមុខដាក់គ្នាគួរយកការប្រយុទ្ធដោយកម្លាំងបាយមកដោះស្រាយទើបបានលទ្ធផលល្អ ឯន័យមតិទីពីរវិញចង់បង្ហាញថាដើម្បីបញ្ចប់ការប្រឈមមុខដាក់គ្នា គួរយកការខន្តីអត់ឱនដោយមិនប្រើកម្លាំងបាយមកដោះស្រាយទើបបានលទ្ធផលល្អ។

ជាការពិតណាស់នៅក្នុងសង្គមមនុស្សតែងតែជួបប្រទះនូវរឿងរ៉ាវនិងទំនាស់វិបត្តិឥតឈប់ឈរ។ ទំនាស់វិបត្តិទាំងឡាយអាចបញ្ចប់ទៅបានព្រមទាំងទទួលលទ្ធផលល្អនោះ ដរាបណាគេប្រើវិធីហិង្សាដោះស្រាយ។ តួយ៉ាងក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត។ តាមរយៈអត្ថបទកំណាព្យមើលផែនដីខ្មែររបស់កវី ជួន ម៉េន ក៏បានបង្ហាញពីការដោះស្រាយទំនាស់ទាំងឡាយដោយអំពើហិង្សាផងដែរ។ យ៉ាងណាមិញពួកប៉ុល ពតតែងចាត់ទុកអ្នកនៅក្នុងទីក្រុងថា ជាមូលធននិយមឬជាខ្មាំងដែលតែងបង្កទំនាស់ជាមួយក្រុមគេ។ ដូច្នេះពួកគេត្រូវយកវិធីហិង្សាមកដោះស្រាយទើបទទួលបានផលល្អលើគូសត្រូវរបស់គេ។ តួយ៉ាងពួកគេបានយកប្រជាជនទៅសម្លាប់ដោយគ្មានញញើតឡើយ។ លើសពីនេះទៅទៀតនៅលើសមរភូមិប្រយុទ្ធវិញ គេពុំអាចយកវិធីអហិង្សាមកដោះស្រាយបាននោះទេ។ ជាក់ស្តែង បើយើងមិនសម្លាប់គេទេ គេនឹងសម្លាប់យើងជាមិនខានព្រោះថាគូបដិបក្ខទំនាស់ គេពុំចេះអត់ឱនឱ្យគូបដិបក្ខម្ខាងទៀតដែរ។ សមដូចទស្សនៈលើកឡើងថា«យកពិសបន្សាបពិសបន្លាមុតយកបន្លាជួសឬសេះដាច់យកសេះតាម» ជាដើម។ ចំណែកនៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ រឿងរាមកេរ្តិ៍បានបញ្ជាក់ដែរថា ដើម្បីបញ្ចប់ទំនាស់គួរយកហិង្សាវិធីមកដោះស្រាយ ទើបបានលទ្ធផលល្អ។ ដូចជាទំនាស់រវាងឥសីពិស្វាមិត្រនិងកាកនាសូរ។ កាកនាសូរគឺជាយក្ខដែលបានកាឡាខ្លួនជាក្អែកបានចូលទៅបំផ្លាញហោមពិធីរបស់ឥសីពិស្វាមិត្រដែលរៀបចំឡើង ដើម្បីបញ្ចប់

ការសិក្សារបស់ព្រះរាម។ ដោយយល់ហេតុការណ៍ ព្រះរាមបានដោះស្រាយទំនាស់នេះដោយវិធីហឹង្សាពោល គឺបាញ់សម្លាប់កាកនាសូរដោយធ្នូសររបស់ព្រះអង្គតែម្តង។ ចំណែកទំនាស់រវាងសុគ្រីពនិងក្រុងពាលីវិញ ក៏ទទួលបានលទ្ធផលល្អដែរដោយព្រះរាមជាអ្នកចេញមុខដោះស្រាយ។ ក្រោមកម្លាំងធ្នូសរដ៏សាហាវរបស់កំពូលអាទិទេពគឺទំនាស់របស់សុគ្រីពនិងក្រុងពាលីបានត្រូវបញ្ចប់ជាស្ថាពរ។ ចំពោះក្រុងរាពណ៍វិញ ជាគូទំនាស់ដ៏ខ្លាំងពូកែម្នាក់ដែលពូកែខាងដើរលួចប្រពន្ធគេ គឺក្រុងរាពណ៍បានលួចនាងសីតាពីព្រះរាម។ ជាមធ្យោបាយបញ្ចប់ទំនាស់នេះ ព្រះរាមពុំបានប្រើវិធីចរចានោះទេ តែព្រះអង្គប្រើវិធីហិង្សាមកដោះស្រាយរហូតធ្វើឱ្យក្រុងរាពណ៍វិនាសអន្តរាយ។ តមកទៀត រាមបរមសូរក្តី ពិរោធក្តី ក្រុងខរក្តីក៏ត្រូវបានព្រះរាមប្រើហឹង្សាវិធី គឺកម្លាំងធ្នូសរមកដោះស្រាយឱ្យក្លាយទៅជាផេះអស់គ្មានសល់ដើបមុខតទល់ជាមួយព្រះអង្គវិញពុំបាន។ ដូច្នេះដើម្បីបញ្ចប់ទំនាស់ពិតជាត្រូវយកវិធីហឹង្សាមកដោះស្រាយយ៉ាងប្រាកដទើបបានលទ្ធផលល្អ។

តើដើម្បីបញ្ចប់ទំនាស់ពិតជាត្រូវយកហិង្សាវិធីមកដោះស្រាយមែន ឬយ៉ាងណា?

ចំពោះមតិទីពីរវិញយល់ថា ដើម្បីបញ្ចប់ទំនាស់គួរយកវិធីហិង្សាមកដោះស្រាយ ទើបទទួលបានលទ្ធផលល្អ ព្រោះថាការដោះស្រាយទំនាស់តាមរបៀបនេះ អាចកាត់បន្ថយបាននូវការស្លាប់បាត់បង់ជីវិតមនុស្សយ៉ាងណាមិញ ដើម្បីបញ្ចប់ទំនាស់រវាងភាគីមួយនិងភាគីមួយទៀតនោះព្រះបាទនរោត្តម សីហនុ និងសម្តេចហ៊ុន សែន បានធ្វើការដោះស្រាយប្រកបដោយសន្តិវិធីពោលគឺការចរចារហូតទទួលលទ្ធផលជាស្ថាពរតាមរយៈកិច្ចព្រមព្រៀងក្រុងប៉ារីសនាថ្ងៃទីម្ភៃបីតុលាឆ្នាំមួយប្រាំបួនរយកៅសិបមួយដោយគ្រប់ភាគីយល់ព្រមឈប់បាញ់ ហើយត្រឡប់ចូលរួមការបោះឆ្នោតវិញ។ ដើម្បីបញ្ចប់ទំនាស់គួរយកវិធីអហិង្សាមកដោះស្រាយ ទើបបានលទ្ធផលល្អ។ ជាក់ស្តែងទំនាស់នៅក្នុងគ្រួសារព្រះរាមត្រូវបានបញ្ចប់ទៅវិញដោយសន្តិវិធី ហើយក៏គ្មានការបែកបាក់ក្នុងរង្វង់គ្រួសារដែរ។ លទ្ធផលល្អបែបនេះ កើតឡើងដោយសារព្រះរាមជារាជបុត្រច្បងប្រកាន់យកអហិង្សាជាគោលពោលគឺយកទឹកទៅរំលត់ភ្លើង មិនមែនយកភ្លើងទៅរំលត់ភ្លើងនោះឡើយ។ ព្រះពុទ្ធសាសនាដែលសម្រេចជោគជ័យនៅក្នុងលោកដោយសារពោធិសត្វជាអ្នកស្វែងរកព្រមទាំងថែងជាទ្រឹស្តីថា «ពៀររំងាប់ដោយការមិនចងពៀរ»។ យ៉ាងណាមិញ ស្នាមប្រឡាក់មិនអាចជ្រះស្អាតដោយសារយកទឹកកខ្វក់ទៅលាងបានទេ។ ដោយគោលទ្រឹស្តីនេះឯង ទើបព្រះវេស្សន្តរសុខចិត្តដោះស្រាយទំនាស់វិបត្តិរវាងព្រះអង្គនិងអ្នកស្រុកស្រីពិរាស្ត្រដោយអហិង្សានិងសន្តិវិធីពោលគឺព្រះអង្គសុខចិត្តទទួលការបោះបង់ដោយរីករាយបំផុត។ នេះប្រសិនបើព្រះវេស្សន្តរប្រើកម្លាំងបាយប្រឆាំងនិងការបះបោរនៃអ្នកស្រុកស្រីពិរាស្ត្រនាពេលនោះព្រះវេស្សន្តរប្រាកដជារកសុខសន្តិភាពមិនឃើញឡើយ ព្រោះគូទំនាស់របស់ព្រះអង្គពិតជាមិនងាយចុះញ៉មឡើយ។ ទីបំផុតអ្នកស្រុកស្រីពិរាស្ត្រទាំងមូលសុខចិត្តទូលសុំយាងព្រះអង្គឱ្យយាងទៅសោយរាជ្យវិញ។

ដូច្នេះ ដើម្បីបញ្ចប់ទំនាស់ពិតជាគួរយកវិធីអហិង្សាមកដោះស្រាយ ទើបទទួលបានលទ្ធផលល្អប្រសើរមែន។

ជារួមមកមតិទាំងពីរសុទ្ធតែមានអំណះអំណាងយកត្រូវរៀងៗខ្លួន ប៉ុន្តែតាមទស្សនៈនៃសង្គមបច្ចុប្បន្នដើម្បីបញ្ចប់ទំនាស់គ្រប់ប្រភេទត្រូវយកអហិង្សាវិធីមកដោះស្រាយ ទើបបានលទ្ធផលល្អ ព្រោះការដោះស្រាយបែបនេះរក្សាបានមិត្តភាព រក្សាបានអាយុជីវិតមនុស្សជាតិ ហើយសង្គមមានស្ថេរភាព។

បន្ទាប់ពីបានបកស្រាយវែកញែកមតិទាំងពីរខាងលើ យើងអាចវាយតម្លៃបានថាមតិទីមួយមិនត្រឹមត្រូវទេ ព្រោះជាមតិដែលឱ្យតម្លៃតែទៅលើភាពហិង្សា ឯមតិទីពីរត្រឹមត្រូវជាង ព្រោះបានផ្តល់គំនិតឈរលើសន្តិភាពអធ្យាស្រ័យគ្នា។ ដូច្នេះ ទោះបីជាអ្នកធំក្តី អ្នកតូចក្តីត្រូវប្រើមធ្យោបាយដោះស្រាយក្រោមគតិ យុត្តិនៃច្បាប់អត់ឱនយោគយល់អធ្យាស្រ័យឬការចរចាប្រកបដោយសន្តិវិធីទើបល្អប្រសើរ។ក្នុងនាមយើងជាខ្មែរត្រូវប្រកាន់យកនូវធម៌អហិង្សាដើម្បីបញ្ចៀសសង្គ្រាម និងទំនាស់គ្រប់បែបយ៉ាងដែលជាបុព្វហេតុនាំជាតិខ្មែរឱ្យអន្តរាយ។

---

**ប្រធានទី២:** មតិទីមួយយល់ថា «ព្រះវេស្សន្តរមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជ្យសម្បត្តិ»។ ឯមតិទីពីរយល់ជំទាស់ថា«ព្រះវេស្សន្តរពុំមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជ្យសម្បត្តិទេ ការដែលព្រះអង្គសុខចិត្តដើរចេញពីព្រះនគរមកពីខ្លាចអ្នកស្រុកពិរាស្ត្រប៉ុណ្ណោះ»។ តើអ្នកយល់ដូចម្តេចចំពោះមតិទាំងពីរនេះ?
ចូរពិភាក្សាព្រមទាំងលើកឧទាហរណ៍បញ្ជាក់។

---

## សេចក្តីអធិប្បាយ

បន្ទាប់ពីបានសិក្សាអក្សរសិល្ប៍ពុទ្ធនិយម រឿងព្រះវេស្សន្តររួចមកឃើញថាព្រះវេស្សន្តរធ្វើទានហួសហេតុរហូតធ្វើឱ្យអ្នកស្រីពិរាស្ត្រកើតក្តីក្តៅក្រហាយយ៉ាងខ្លាំងក្នុងរឿងដែលព្រះអង្គបរិច្ចាគទានដំរីបច្ច័យនាគេន្ទ្រឱ្យទៅអ្នកស្រុកកលិង្គរាស្ត្រ។ ម្ល៉ោះហើយអ្នកស្រុកស្រីពិរាស្ត្របានសំណូមពរឱ្យព្រះបាទស្រីសញ្ជ័យបំបរបង់ព្រះអង្គចេញពីព្រះនគរ។ វិលជុំវិញនៃការចាកចេញរបស់ព្រះវេស្សន្តរនេះមានមតិពីរយល់ផ្ទុយគ្នាក្នុងនោះមតិទីមួយយល់ថា «ព្រះវេស្សន្តរមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជ្យសម្បត្តិ»។ ឯមតិទីពីរយល់ជំទាស់ថា «ព្រះវេស្សន្តរពុំមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជ្យសម្បត្តិទេ ការដែលព្រះអង្គសុខចិត្តដើរចេញព្រះនគរមកពីខ្លាចអ្នកស្រុកស្រីពិរាស្ត្រតែប៉ុណ្ណោះ»។

តើមតិទាំងពីរខាងលើនេះមួយណាត្រឹមត្រូវជាង?

ដើម្បីបកស្រាយរកហេតុផលចម្លើយពិតនោះ ជាដំបូងគប្បីស្គាល់ន័យនៃពាក្យជ្រះថ្លានិងរាជ្យសម្បត្តិជាមុនសិន។ ពាក្យថា «ជ្រះថ្លា»មានន័យថា ជ្រះស្រឡះ បរិសុទ្ធឥតមន្ទិល។ ឯពាក្យ«រាជ្យសម្បត្តិ»មានន័យថាការសោយរាជ្យអំណាចជាព្រះមហាក្សត្រ។ ន័យរបស់មតិទីមួយចង់សំដៅថាព្រះវេស្សន្តរមានទឹកចិត្តជ្រះស្រឡះក្នុងការលះបង់ការសោយរាជ្យអំណាចជាព្រះមហាក្សត្រ។ ឯមតិទីពីរចង់សំដៅថាព្រះវេស្សន្តរពុំមានទឹកចិត្តជ្រះស្រឡះក្នុងការលះបង់ការសោយរាជ្យអំណាចជាព្រះមហាក្សត្រទេ ការដែលព្រះអង្គសុខចិត្តដើរចេញពីព្រះនគរមកពីខ្លាចអ្នកស្រុកស្រីពិរាស្ត្រតែប៉ុណ្ណោះ។

ក្នុងរឿងព្រះវេស្សន្តរបានបង្ហាញពីការធ្វើទានរបស់ព្រះវេស្សន្តរសព្វបែបយ៉ាង ដោយមិនរើសមុខឡើយអ្វីដែលព្រះអង្គមានគឺទ្រង់ឱ្យជាទានទាំងអស់ សូម្បីតែជីវិតក៏ព្រះអង្គពុំស្តាយស្រណោះដែរ។ ដោយសារការឱ្យទានដំរីបច្ច័យនាគេន្ទ្រទៅស្រុកកលិង្គរាស្ត្របានធ្វើឱ្យអ្នកស្រុកស្រីពិរាស្ត្រមានសេចក្តីក្តៅក្រហាយយ៉ាងខ្លាំង ហើយអ្នកស្រុកទាំងនោះក៏បានសុំឱ្យព្រះបាទស្រីសញ្ជ័យឱ្យនិរទេសព្រះវេស្សន្តរចេញពីនគរ។ ចំណែកព្រះវេស្សន្តរវិញសុខចិត្តចាកចេញដោយឥតស្រណោះអ្វីឡើយដូចជាសម្តីរបស់ទ្រង់ទៅកាន់ព្រះបាទស្រីសញ្ជ័យថា «បពិត្របិតា សត្វទាំងឡាយសុទ្ធតែពុំឆ្អែតដោយកាមទាំងអស់»។ ហេតុដូច្នេះសត្វទាំងនោះរមែងទៅកាន់ទីយមរាជ។ ឯទូលលព្រះបង្គំជា

ខ្ញុំចង់ជៀសវាងទីយមរាជបានដោយការឱ្យទាន។ ការឱ្យទានជាអំពើល្អសោះ តែត្រឡប់ជាបានឈ្មោះថាជាការបៀតបៀនអ្នកដែនទៅវិញ។ ទូលព្រះបង្គំ ជាខ្ញុំទោះបីចេញទៅរងទុក្ខក្នុងព្រៃដែលច្របូលច្របល់ដោយម្រឹគសាហាវក៏ឈ្មោះថាបានធ្វើបុណ្យជាគ្រឿងនាំមកនូវសេចក្តីសុខក្នុងអនាគតដែរ»។ ត្រង់នេះបង្ហាញថាព្រះវេស្សន្តរ សុខចិត្តលះបង់រាជសម្បត្តិដោយទឹកចិត្តបរិសុទ្ធ។ លើសពីនេះទៅទៀត ទ្រង់យល់ឃើញថាបើព្រះអង្គមិនចេញទេនោះនឹងកើតនូវចលាចលពេញទាំងនគរ ហើយព្រះអង្គក៏មិនចង់ឱ្យសង្គ្រាមកើតឡើងនៅក្នុងស្រុកដែរមិនមែនមានន័យថា ព្រះអង្គខ្លាចអ្នកស្រុកស្រីពិរាស្ត្រធ្វើអំពើអវិជ្ជមានចំពោះព្រះអង្គនោះទេ។ ម្យ៉ាវិញទៀតការដែលព្រះអង្គចាកចេញពីព្រះនគរ ក៏អាចធ្វើឱ្យអ្នកស្រីពិរាស្ត្រទាំងមូលមានការភ្ញាក់រឭកឡើងវិញដែរ។ ជាពិសេសទៀតនោះរាជសម្បត្តិទ្រង់មិនប្រាថ្នាប៉ងជារបស់ទ្រង់ឡើយព្រោះទ្រង់សុខចិត្តលំបាកវេទនាក្នុងព្រៃភ្នំគិរីវង្កត។ យ៉ាងណាមិញពេលដែលព្រះវេស្សន្តរធ្វើដំណើរកាត់ក្រុងមាតុលនគរ គឺមានក្សត្រប្រាំមួយម៉ឺនអង្គមកទទួលរាក់ទាក់ព្រមទាំងយាងព្រះអង្គឱ្យសោយរាជ្យនៅនគររបស់គេប៉ុន្តែ ព្រះវេស្សន្តរពុំយល់ព្រមឡើយ។ នេះសរបញ្ជាក់ឱ្យឃើញថា ទោះជាគ្មានរាជសម្បត្តិនៅជេតុត្តរៈនគរក៏ដោយ ក៏មានរាជសម្បត្តិនៅមាតុលនគរស្វាគមន៍ព្រះអង្គដែរពោល គឺព្រះអង្គលះបង់រាជ្យសម្បត្តិទាំងអស់  ហើយព្រះអង្គប្រាថ្នាតែម្យ៉ាងគឺត្រាស់ជាព្រះពុទ្ធតែប៉ុណ្ណោះ។

ដូច្នេះព្រះវេស្សន្តរពិតជាលះបង់រាជ្យសម្បត្តិប្រកបដោយទឹកចិត្តជ្រះថ្លាឥតស្តាយស្រណោះ។

តើព្រះវេស្សន្តរពិតជាមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជសម្បត្តិដោយឥតស្តាយស្រណោះមែនឬយ៉ាងណា?

បើបង្វែរអារម្មណ៍មកពិនិត្យមើលលើមតិទីពីរនោះឃើញថា ព្រះវេស្សន្តរពុំមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជសម្បត្តិនោះទេ ព្រោះការលះបង់របស់ព្រះអង្គដោយសារខ្លាចអ្នកស្រុកស្រីពិរាស្ត្រធ្វើបាតុកម្មហិង្សាទៅលើព្រះអង្គនិងអាចធ្វើឱ្យព្រះអង្គសោយទិវង្គតបាន។ ម្យ៉ាងវិញទៀតនៅពេលដឹងថាទ្រង់ត្រូវប្រជារាស្ត្របំបរបង់ឱ្យទៅព្រៃភ្នំគិរីវង្កតព្រះអង្គក៏មានអារម្មណ៍មិនសប្បាយក្នុងព្រះទ័យសោះ។តួយ៉ាងនៅពេលចាកចេញពីព្រះនគរដោយមានព្រះបន្ទូលថា «នុះហ្ន៎! ព្រះរាជវាំងរបស់យើង»។ តាមសម្តីនេះអាចបញ្ជាក់បានថា ព្រះវេស្សន្តរនៅមានចិត្តអាល័យអាលោះស្រណោះនគរនិងរាជ្យសម្បត្តិនេះឯង។ រីឯ ចំណុចមួយទៀតដែលញ្ជាក់ថា ព្រះវេស្សន្តរពុំមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជ្យសម្បត្តិនោះ គឺបន្ទាប់មកពីបានដាក់ទាននាងមទ្រីរួចមកព្រះវេស្សន្តរបានសុំពរប្រាំបីប្រការពីព្រះឥន្ទ្រាធិរាជ ហើយក្នុងចំណោមពរទាំងប្រាំបីប្រការនេះ មានពរមួយប្រការនោះព្រះអង្គបានប្រាថ្នាថា «សុំឱ្យព្រះបាទស្រីសញ្ជ័យជាបីតាមកយាងព្រះអង្គទៅសោយរាជ្យវិញ»។ នេះសរបញ្ជាក់ឱ្យឃើញថា ព្រះវេស្សន្តរនៅមានទឹកចិត្តស្តាយស្រណោះរាជ្យសម្បត្តិ តែដោយខ្លាចអ្នកស្រីពិរាស្ត្រធ្វើគតព្រះអង្គ ក៏ទ្រង់ព្រមលះបង់ទាំងបង្ខំទៅ។

ដូច្នេះព្រះវេស្សន្តរពុំមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជសម្បត្តិនោះឡើយ។

ជារួមមកមតិទីមួយយល់ថា ព្រះវេស្សន្តរមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជសម្បត្តិ ព្រោះព្រះអង្គជាពោធិសត្វ ហើយព្រះអង្គគ្មានត្រូវការអ្វីក្រៅពីការបរិច្ចាគទាន ដើម្បីត្រាស់ដឹងជាព្រះពុទ្ធនោះឡើយ។ ឯមតិទីពីរដែលយល់ថា ព្រះវេស្សន្តរពុំមានទឹកចិត្តជ្រះថ្លាក្នុងការលះបង់រាជ្យសម្បត្តិនោះ  ព្រោះសម្អាងថា ព្រះវេស្សន្តរនៅមានចិត្តជំពាក់និងតណ្ហាលោភលន់នេះឯង។ ឆ្លងតាមការវែកញែករួចមកអាចឱ្យយើងវាយតម្លៃបានថា មតិទីមួយជាមតិត្រឹមត្រូវជាង ព្រោះព្រះវេស្សន្តរជា

បុគ្គលដែលមានការលះបង់ខ្ពស់បំផុត ពោលគឺព្រះអង្គហ៊ានលះបង់រាជ្យសម្បត្តិ ប្រពន្ធ កូន រហូតដល់អាយុជីវិតរបស់ព្រះអង្គក៏ព្រះអង្គសុខចិត្តដាក់ជាទានដែរ។ ដូច្នេះក្នុងនាមយើងជាពលរដ្ឋខ្មែរ យើងត្រូវការមេដឹកនាំទាំងឡាយណាដែលមានការលះបង់ខ្ពស់បីដូចជាព្រះវេស្សន្តរនេះឯង។

**ប្រធានទី២:** មតិខ្លះថា«ការបំពេញបុត្តបរិច្ចាគរបស់ព្រះវេស្សន្តរពុំមានសទ្ធាជ្រះថ្លាឡើយ»។ ឯមតិខ្លះទៀតថា «ការបំពេញបុត្តបរិច្ចាគនេះមានសទ្ធាជ្រះថ្លាបំផុត»។
ចូរពិភាក្សា ដោយរកអំណះអំណាងបញ្ជាក់។

## សេចក្តីអធិប្បាយ

តាមស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមតែងតែលើកយកដំណើរជីវិត និងសកម្មភាពរបស់ព្រះពោធិសត្វដែលបានខិតខំសាងកុសលបារមីក្នុងបំណងស្វែងរកនិងឆ្ពោះទៅរកនិព្វានលោក។ ដោយឡែករឿងវេស្សន្តរ ជារឿងមួយស្ថិតក្នុងគម្ពីរទេសជាតក ក៏បានកំណត់នូវមូលបញ្ហាស្ថិតនៅលើការកសាងទានបារមីដែលជាការបំពេញមហាបរិច្ចាគទាំងប្រាំក្នុងនោះមានបុត្តបរិច្ចាគផងដែរ។ សកម្មភាពនេះគេឃើញព្រះវេស្សន្តរបានធ្វើទៅប្រកបដោយលក្ខណៈវិជ្ជមានគឺជ្រះថ្លា ប៉ុន្តែតាមការសិក្សាឱ្យច្បាស់លាស់ជាងនេះក៏នៅមានដែរថា ការបរិច្ចាគរបស់ព្រះអង្គពុំទាន់ជ្រះថ្លានៅឡើយ។ អាស្រ័យហេតុនេះ ទើបនាំឱ្យមានមតិពីរខ្វែងគ្នា ដោយមតិទីមួយថា «ការបំពេញបុត្របរិច្ចាគរបស់ព្រះវេស្សន្តរពុំមានសទ្ធាជ្រះថ្លាឡើយ»។ ឯមតិទីពីរថា «ការបំពេញបុត្របរិច្ចាគនេះមានសទ្ធាជ្រះថ្លាបំផុត»។

តើរវាងមតិទាំងពីរខាងលើនេះ មួយណាត្រឹមត្រូវជាង?

មុននឹងពិភាក្សាវែកញែកលើមតិទាំងពីរឱ្យបានស៊ីជម្រៅត្រូវយល់ពាក្យខ្លះដូចជា ការបំពេញបុត្របរិច្ចាគ សទ្ធា ជ្រះថ្លា។ ការបំពេញ មានន័យថា ធ្វើឱ្យពេញឬបរិបូរ។ ឯបុត្តបរិច្ចាគគឺការលះបង់កូន។ ចំណែកសទ្ធាជ្រះថ្លាវិញគឺសេចក្តីជឿបុណ្យដែលជ្រះស្រឡះឥតមន្ទិលឬអស់មន្ទិល។ ទស្សនៈប្រធានលេចចេញនូវមតិពីរខ្វែងគ្នាស្តីពីការលះបង់កូនដោយបរិបូររបស់ព្រះវេស្សន្តរដោយមតិមួយថា «ព្រះអង្គពុំមានភាពជ្រះស្រឡះអស់មន្ទិលឡើយ»។ ឯមតិមួយទៀតថា «ព្រះអង្គមានភាពជ្រះស្រឡះហើយ»។

គេឃើញមានទស្សនៈខ្លះយល់ស្របតាមមតិទីមួយរបស់ប្រធាន ដោយមានភ្ជាប់ហេតុផល។ តាមខ្លឹមសាររឿងបញ្ជាក់ពីភាពមិនជ្រះថ្លាក្នុងការបំពេញបុត្តបរិច្ចាគនៅត្រង់ព្រះអង្គមានមនោសញ្ចេតនាស្រឡាញ់អាណិតអាសូរកូនខ្លាំងក្លា គឺពោរពេញដោយព្រហ្មវិហារធម៌។ សេចក្តីថា ព្រះអង្គបានត្រិះរិះមើលឃើញសារជាតិអ្នកមកសុំ ហើយហាក់នៅប្រកាន់វណ្ណៈដែលកត្តានេះជំរុញឱ្យព្រះអង្គប្រមើលមើលពីអនាគតនូវសេចក្តីសុខរបស់កូននិងឈានទៅរកមធ្យោបាយឬវិធីល្អដើម្បីសង្គ្រោះកូន។ ពិសេសដោយសារព្រហ្មវិហារធម៌នេះ បានជំរុញឱ្យព្រះអង្គបម្រុងប្រើហិង្សាប្រហារជូជកនោះទៅហើយ និងចូលទៅអាស្រមយំសោយសោក ស្រណោះអាល័យអនុស្សាវរីយ៍ចំពោះបុត្រដែលធ្លាប់នៅជិត។ ជាក់ស្តែងតាមដំណើររឿងបានរៀបរាប់បង្ហាញថា ពេលជូជកមកសុំបុត្រទាំងពីរគឺជាលីនិងក្រស្នា ព្រះវេស្សន្តរបានឱ្យជននោះនៅរង់ចាំនាងមទ្រីវិលមកពីបេះផ្លែឈើដើម្បីឱ្យកូនបានបៅនិងអាចឱ្យនាងមទ្រីការពារកូនមិនឱ្យជូជកយកទៅ។ ទន្ទឹមនេះព្រះអង្គបានកាត់តម្លៃកូនជាមាសមួយពាន់តម្លឹងក្នុងម្នាក់ៗដើម្បីកុំឱ្យកូនធ្លាក់ក្នុងដៃជនក្រីក្រឬមានទ្រព្យតិចតួច ហើយការកាត់ថ្លៃនេះព្រះអង្គគិតដល់ «ក្រស្នា» ខ្លាំងក្លាថាមានរូបសម្ផស្សល្អស្អាតដាច់គេ។ ម្យ៉ាងការគិតលក់ថ្លៃ

ខ្ពស់នេះក៏ក្នុងបំណងឱ្យជូជកយកបុត្រទាំងពីរទៅជេតុត្តរនគរ ដើម្បីឱ្យបិតាព្រះអង្គលោះយកផង ដែរ ព្រោះតម្លៃនេះមានតែមហារាជដូចជាព្រះបាទស្រីសញ្ជ័យជាបិតាព្រះអង្គទេ ទើបមានលទ្ធភាព ទិញបាន។ ពិសេសជាងនេះទៀត ព្រះវេស្សន្តរខឹងសម្បាចំពោះជូជកដែលវាយដំធ្វើបាបបុត្រទាំង ពីរនៅចំពោះមុខ ហើយបម្រុងបាញ់ប្រហារថែមទៀត តែទប់អារម្មណ៍បានវិញដែលជាសម្មាធិប្រពៃ ណីព្រះពោធិសត្វ។ ប៉ុន្តែព្រះអង្គនៅតែអាល័យយំស្រណោះ ពេលជូជកយកបុត្រចេញផុតទៅគឺព្រះ អង្គបានរំឭកអនុស្សាវរីយ៍ផ្សេងៗកាលបុត្ររស់នៅក្បែរ។

សរុបមកសកម្មភាពទាំងអស់នេះជាការបញ្ជាក់ថា ព្រះវេស្សន្តរបំពេញបុត្តបរិច្ចាគ ពុំជ្រះថ្លា មែន។

ផ្ទុយទៅវិញ គេនៅឃើញមានមតិខ្លះទៀតបែរជាយល់ស្របតាមមតិទីពីររបស់ប្រធានទៅវិញ ដែលការយល់នេះ ក៏មានហេតុផលបញ្ជាក់ដែរ។ បើតាមការពិនិត្យខ្លឹមសាររឿងបានបញ្ជាក់ថា ការ បំពេញបុត្តបរិច្ចាករបស់ព្រះវេស្សន្តរមានលក្ខណៈជ្រះថ្លាគួរកត់សម្គាល់ដូចជា ព្រះវេស្សន្តរបានប្រើ ពាក្យកុហកមហេសីទាក់ទងសុបិនដើម្បីទប់ស្កាត់ឧបសគ្គដែលរាំងស្ទះដល់ការដាក់ទានរបស់ព្រះ អង្គ។ព្រះអង្គក៏មានព្រះទ័យសប្បាយរីករាយដោយប្រមើលដឹងថា មានស្មូមនឹងមកសុំទាន ពោល គឺរង់ចាំដោយចិត្តអន្ទះសាដើម្បីដាក់ទាន។ ម្យ៉ាងទៀតទោះបីព្រះអង្គដឹងស្គាល់សារជាតិអាក្រក់ របស់តាជូជកក៏ដោយ ក៏ព្រះអង្គនៅតែផ្តល់ទានបុត្រទាំងពីរទៅស្មូមនោះដោយពេញចិត្តពិសេស ព្រះអង្គបានអត់ធ្មត់ស៊ូទ្រាំទៅនឹងសម្តីតិះដៀលរបស់ជូជក ហើយចេញទៅអង្វរបុត្រទាំងពីរដែល កំពុងលាក់ខ្លួនសម្ងំក្នុងព្រៃដើម្បីឱ្យចេញមកទៅតាមជូជកជាក់ស្តែងតាមដំណើររឿងបង្ហាញថា ព្រះវេស្សន្តរបានយល់ដឹងជាមុនថាស្អែកនឹងមាន ស្មូមមកសូមទានព្រះអង្គ ហើយលុះវេលាយប់ នាងមទ្រីចូលមកឱ្យជួយកាត់សុបិនរបស់នាង ព្រះវេស្សន្តរដឹងថាសុបិនមិនល្អសម្រាប់នាងមទ្រី ប៉ុន្តែបែរជាពន្យល់ថា ជាសុបិនធម្មតាដែលកើតចេញពីភាពលំបាក ហត់នឿយធ្វើឱ្យអារម្មណ៍មិន ល្អ។ លុះព្រឹកឡើងតាជូជកចូលមកសុំបុត្រព្រះអង្គបានដាក់ទានឱ្យភ្លាម ទោះយល់ និងឃើញថា ជូជកជាបុគ្គអាក្រក់ក៏ដោយ។ ជាមួយនេះដែរពេលបុត្រទាំងពីររត់មកវិញ ហើយជូជកមកតាមដោយ ធ្វើការតិះដៀលធ្ងន់ៗលើព្រះអង្គក៏ព្រះអង្គមិនតបតនិងស្រែកហៅបុត្រទាំងពីរដែលសម្ងំក្បែរស្រះ ក្នុងព្រៃរង់ចាំមាតាមកវិញនោះឱ្យចេញមកទៅតាមតាជូជកម្តងទៀត។

សរុបមក ការបំពេញបុត្របរិច្ចាករបស់ព្រះវេស្សន្តរបញ្ជាក់នូវលក្ខណៈជ្រះថ្លាមែន។

រួមសេចក្តីមក មានមតិពីរខ្វែងគំនិតយោបល់គ្នាស្តីពីការបំពេញបុត្របរិច្ចាករបស់ព្រះវេស្សន្តរ មកយើងចូលរួមវិនិច្ឆ័យ។ បើពិនិត្យលើមតិទីមួយឃើញហាក់សមហេតុផលដែរដោយសកម្មភាព នេះព្រះអង្គនៅមានទឹកចិត្តស្រណោះអាល័យគិតអនាគតបុត្រនិងហៀបប្រើហិង្សាបាញ់តាជូជក ដែលធ្វើបាបបុត្រទាំងពីរ។ ឯមតិទីពីរវិញចាត់ថា ត្រឹមត្រូវម្យ៉ាងដោយគ្រប់ទង្វើ ឬសកម្មភាពបំពេញ ទាននេះ ព្រះវេស្សន្តរសម្រេចបានល្អប្រកបដោយលក្ខណៈព្រះពោធិសត្វពិតៗ។ ជាការពិតការ បំពេញបុត្រទានឬទានដទៃទៀតគឺជាកាតព្វកិច្ចនិងកុសលទានអតីតកាលរបស់ព្រះពោធិសត្វ ក្នុង បំណងស្វែងរកបារមីដើម្បីសម្រេចការត្រាស់ដឹងជាព្រះពុទ្ធ។សកម្មភាពមិនជ្រះថ្លាខ្លះ វាគ្រាន់តែជា សារជាតិរបស់ព្រះអង្គដែលកើតក្នុងលោកិយស្ថិតក្នុងលកខណៈមនុស្សត្រូវជំពាក់នឹងវដ្តសង្សារ។

បញ្ចប់សេចក្តីមក រវាងមតិទាំងពីរដែលយល់ខុសគ្នាខាងលើយើងឱ្យតម្លៃត្រឹមត្រូវទៅលើមតិ ទីពីរជាងមតិទីមួយ ព្រោះមតិនេះយល់ច្បាស់នូវសកម្មភាពអស្ចារ្យរបស់ព្រះពោធិសត្វជាតិទីដប់គឺ

ព្រះវេស្សន្តរ ដែលព្រះអង្គបានលះបង់នូវមហាបរិច្ចាកប្រាំ ប្រកបដោយការតស៊ូមោះមុត។ ម្យ៉ាងទស្សនៈនេះបានផ្តល់ជាគតិអប់រំដល់ជនទូទៅយល់ដឹង និងទទួលយកសកម្មភាពល្អៗរបស់ព្រះអង្គមកអនុវត្តផងដែរ។ ដូច្នេះយើងត្រូវសិក្សាស្វែងយល់នូវស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមឱ្យបានល្អិតល្អន់ដើម្បីដកស្រង់នូវគោលអប់រំល្អៗទុកជាមេរៀននិងការប្រតិបត្តក្នុងជីវិតសម្រាប់ឧត្តមភាព និងវឌ្ឍនភាពនៃជីវិត។

## ៩.៣- ប្រធានអត្ថាធិប្បាយប្រៀបធៀប

ប្រធានទី១: ចូរធ្វើការប្រៀបធៀបតួអង្គម្តាយទាវក្នុងរឿងទុំទាវ និងនាងកែកេសីក្នុងរឿងរាមកេរ្តិ៍។

### គម្រោងតែង

**ក- ផ្តើមសេចក្តី**

- **លំនាំបញ្ហា:** នៅក្នុងអក្សរសិល្ប៍អ្នកនិពន្ធតែងតែលើកយកតួអង្គរបស់ខ្លួនមកបង្ហាញ...
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** ...ចូរធ្វើការប្រៀបធៀបតួអង្គម្តាយទាវក្នុងរឿងទុំទាវនិងនាងកែកេសីក្នុងរឿងរាមកេរ្តិ៍។
- **ចំណោទបញ្ហា:** តើតួអង្គទាំងពីរខាងលើនេះមានលក្ខណៈដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** មុននិងធ្វើការប្រៀបធៀប...
- **ពន្យល់ពាក្យ:** «តួអង្គ»គឺសម្គាល់នៅលើបុគ្គលណាម្នាក់ឬបុគ្គលណាមួយ...
- **ពន្យល់ន័យប្រធាន:** ដូច្នេះគំនិតប្រធានគឺចង់បង្ហាញពីចំណុចដូចគ្នានិងចំណុចខុសគ្នា...។
- **បកស្រាយប្រធានៈ**

**ក- លក្ខណៈដូចម្តាយទាវក្នុងរឿងទុំទាវនិងតួអង្គនាងកែកេសីក្នុងរឿងរាមកេរ្តិ៍**

- **គំនិតសំខាន់ និងឧទាហរណ៍ៈ**
  - ✓ ចង់ឱ្យកូនមានអំណាចបុណ្យសក្តិគេគោរព មានកិត្តិយស...
  - ✓ .............................................................................................។
- សរុបលក្ខណៈដូច...

**ខ- លក្ខណៈខុសម្តាយទាវក្នុងរឿងទុំទាវនិងតួអង្គនាងកែកេសីក្នុងរឿងរាមកេរ្តិ៍**

- គំនិតសំខាន់ និងឧទាហរណ៍
  - ✓ ម្តាយទាវជាប្រជារាស្ត្រ មានធនធានសមល្មម. បំបែកបំបាក់កូន...
  - ✓ នាងកែកេសីជាមហេសីព្រះបាទទសរថ ចង់ឱ្យព្រះបាទទសរថគោរពពាក្យសត្យ...
  - ✓ សរុបលក្ខណៈខុស...

គ- សរុបរួម...។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន:** .............................................................................................
- **មតិផ្ទាល់ផ្ទាល់:** .............................................................................................។

# សេចក្តីអធិប្បាយ

នៅក្នុងអក្សរសិល្ប៍ អ្នកនិពន្ធតែងតែលើកយកតួអង្គរបស់ខ្លួនមកបង្ហាញឱ្យអាន អ្នកស្តាប់ស្គាល់ថាតើតួអង្គដែលមានចរិតល្អ ស្មោះត្រង់ ហើយតួអង្គណាដែលមានចរឹកឫកពាមិនល្អ មិនស្មោះត្រង់និងមិនគួរឱ្យគោរព។

តើតួអង្គម្តាយទាវក្នុងរឿងទុំទាវនិងនាងកៃកេសីក្នុងរឿងរាមកេរ្តិ៍ដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

ដើម្បីជាជំនួយដល់ការប្រៀបធៀបតួអង្គទាំពីរខាងលើនេះឱ្យបានក្បោះក្បាយជាបឋមយើងត្រូវយល់ន័យនៃពាក្យ«តួងអង្គ» ខាងលើនេះជាមុនសិន។ ពាក្យថាតួអង្គគឺសម្គាល់ទៅលើបុគ្គលណាម្នាក់ឬបុគ្គលណាមួយមិនថាប្រុស ស្រី ក្មេង ចាស់ដែលចូលរួមសម្តែងនៅក្នុងរឿង។ ដូច្នេះតាមគំនិប្រធានខាងលើគឺតម្រូវឱ្យយើងធ្វើការប្រៀបធៀបម្តាយទាវនិងនាងកៃកេសី។

ជាការពិតណាស់ទាំងម្តាយទាវទាំងនាងកៃកេសី គឺសុទ្ធតែមានលក្ខណៈដូចគ្នាឬស្រដៀងគ្នា និងខុសគ្នាមួយចំនួនផងដែរ។ ចំពោះចំណុចដូចគ្នាឬស្រដៀងគ្នារបស់អ្នកទាំងពីរគឺជាមនុស្សដែលលោភលន់ចង់មានចង់បានដោយខ្វះការពិចារណាហ៊ានធ្វើអ្វីៗគ្រប់បែបយ៉ាងទោះដឹងថាទង្វើដែលគាត់ធ្វើនោះមហាជនគេស្អប់ខ្ពើម រិះគន់យ៉ាងណាក៏គាត់នៅតែធ្វើ ព្រោះសេចក្តីលោភលន់នេះមកបិទបាំងឱ្យបុគ្គលទាំងពីរលែងស្គាល់អ្វីដែលល្អអ្វីដែលអាក្រក់។ ជាក់ស្តែងម្តាយនាងទាវគាត់ពុំមែនជាមនុស្សដែលមេម៉ាយក្រីក្រតោកយ៉ាកនោះឡើយ។ ហេតុអ្វីបានជាគាត់ចង់ឱ្យនាងទាវបានធ្វើជាប្រពន្ធម៉ឺនងួន ដែលជាកូនរបស់លោកអរជូន នេះមកពីគាត់យល់ថា បើកូនគាត់ក្លាយជាកូនប្រសារបស់អ្នកមានអំណាច មិនខ្វះទេទ្រព្យសម្បត្តិ អ្នកបម្រើឆ្វេងស្តាំជាពិសេសមុខមាត់គាត់ក៏ល្បីពេញខេត្តត្បូងឃ្មុំ។ ក្រោយមកនៅពេលដែលកូនគាត់បានព្រះរាជាជ្រើសរើសជាស្នំឯក គាត់កាន់តែពេញចិត្តទៅទៀត ព្រោះបើបានធ្វើស្នំឯកកិត្តិយសរបស់គាត់កាន់តែល្បីខ្លាំងពេញផ្ទៃប្រទេស។ ម៉្យាងទៀតនៅពេលដែលព្រះរាជាផ្សំផ្គុំទុំនិងទាវ ជាប្តីប្រពន្ធ ម្តាយទាវបានប្រើល្បិចថាខ្លួនគាត់ឈឺជាទម្ងន់ឱ្យនាងទាវមកមើលគាត់នៅវេលាចុងក្រោយ។ ចំណែកឯនាងកៃកេសីក្នុងរឿងរាមកេរ្តិ៍វិញក៏មិនខុសពីម្តាយនាងទាវដែរ គឺគាត់បានបណ្តេញព្រះរាមឱ្យទៅបួសរយៈពេលដប់ឆ្នាំសិនចាំមកគ្រងរាជ្យសម្បត្តិ ហើយចង់ឱ្យកូនខ្លួនឡើងសោយរាជ្យជាស្តេច ព្រោះថាបើកូនគាត់បានឡើងសោយរាជ្យអំណាចនិងកិត្តិយសរបស់គាត់និងត្រូវបានគេស្គាល់ គេគោរពកោតខ្លាចគាត់បានផ្តល់ដំណឹងទៅបុត្ររបស់គាត់ដោយកុហកថា មកចូលរួមពិធីគ្រងរាជ្យរបស់ព្រះរាមនិងនាងសីតាតែ នេះគឺល្បិចកលដ៏អាក្រក់របស់នាងតែប៉ុណ្ណោះ។ និយាយរួមអ្នកទាំងពីចង់ឱ្យកូនមានឋានៈបុណ្យសក្តិខ្ពង់ខ្ពស់។

សរុបសេចក្តីមក ចំណុចខាងលើនេះជាចំណុចសំខាន់ដែលជាលក្ខណៈដូចនៃតួអង្គម្តាយទាវក្នុងរឿងទុំទាវ និងនាងកៃកេសីក្នុងរឿងរាមកេរ្តិ៍។

រីឯចំណុចខុសគ្នារបស់តួអង្គទាំងពីរគឺស្ថិតនៅត្រង់ម្តាយនាងទាវជាប្រជាពលរដ្ឋធម្មតា ហើយជាមនុស្សដែលមើលឃើញទ្រព្យសម្បត្តិជាធំ បំបិទសិទ្ធិ សេរីភាពកូនក្នុងការជ្រើសរើសគូស្រករ ហើយនាងសុខចិត្តធ្វើអ្វីគ្រប់យ៉ាងដើម្បីចង់ឈ្នះចិត្តកូនខ្លួនឯងនៅក្នុងសាច់រឿងយើងឃើញថា នៅពេលព្រះរាជាបានរៀបអាពាហ៍ពិពាហ៍ឱ្យទុំនិងទាវ នាងជាម្តាយកើតទុក្ខមិនសុខចិត្តដេករកល្បិចក្នុងការបំបែកទុំហើយនិងទាវ។ ចំណែកឯនាងកៃកេសីវិញជាមហេសីព្រះបាទទសរថ នាងពុំដែល

បានបំបែកបំបាក់ព្រះរាជបុត្រពីនរណាឡើយ គឺនាងគ្រាន់តែទាមទារនូវពាក្យសត្យប៉ុណ្ណោះ ព្រោះដោយសារនាងសម្អាងថា បើបុត្ររបស់នាងច្បាំងឈ្នះព្រអាទិត្យព្រះបាទទសរថនិងឱ្យកូននាងឡើង គ្រងរាជ្យជាស្ដេច។ ដូច្នេះនាងគ្រាន់តែទាមទាររកយុត្តិធម៌ឱ្យព្រះរាជបុត្រតែប៉ុណ្ណោះ។

សរុបសេចក្ដីខាងលើនេះជាចំណុចខុសគ្នានៃតួអង្គម្ដាយទាវក្នុងរឿងទុំទាវនិងនាងកៃកេសីក្នុងរឿងរាមកេរ្តិ៍។

រួមសេចក្ដីមកកភស្តុតាខាងលើនេះមានចំណុចដូចគ្នានិងចំណុចខុសគ្នារវាងម្ដាយនាងទាវនៅក្នុងរឿងទុំទាវ និងនាងកៃកេសីក្នុងរឿងរាមកេរ្តិ៍។ តួអង្គទាំងពីរខាងលើនេះសុទ្ធតែជាបុគ្គលអាត្មានិយមគិតតែផលប្រយោជន៍ខ្លួនជាធំ បង្ខិតបង្ខំកូនឱ្យយល់ស្របតាមបំណងប្រាថ្នារបស់ខ្លួន។

ឆ្លងតាមការប្រៀបធៀបតួអង្គទាំងពីរខាងលើនេះបានបង្ហាញឱ្យឃើញថា ទាំងតួអង្គម្ដាយទាវនិងតួអង្គនាងកៃកេសីគឺជាតួអង្គដែលធ្វើអំពើអាក្រក់គាបសង្កត់អ្នកទន់ខ្សោយលោភលន់មិនអាចយកជាគម្រូល្អសម្រាប់អប់រំមនុស្សឱ្យមានគំនិតរីចម្រើនឡើយ។ ដូច្នេះយើងទាំងអស់គ្នាមិនត្រូវយកគំនិតរបស់តួអង្គទាំងពីរខាងលើនេះមកអនុវត្តនៅក្នុងសង្គមគ្រួសារឬសង្គមជាតិឡើយ ព្រោះភាពលោភលន់ការចង់មានចង់បានដោយគ្មានគិតការពិចារណានាំឱ្យខ្លួនឯង គ្រួសារ និងសង្គមជាតិវិនាសអន្តរាយ។

---

**ប្រធានទី២:** ចូរអ្នកប្រៀបធៀបស្នេហានាងទាវក្នុងរឿងទុំទាវ និងស្នេហានាងសីតាក្នុងរឿងរាមកេរ្តិ៍ខ្មែរ។ តើស្នេហាទាំងពីរនេះមានចំណុចដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

---

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា:** នៅក្នុងស្នាដៃអក្សរសិល្ប៍ភាគច្រើនតែងតែលើកយកនូវបញ្ហារបស់មនុស្សជាច្រើនមកចោទនិងដោះស្រាយ។ ក្នុងនោះក៏មានបញ្ហាស្នេហារបស់មនុស្សផងដែរ។
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** ចំពោះបញ្ហាស្នេហានេះអ្នកនិពន្ធក៏បានបង្ហាញជាពិសេសនៅក្នុងស្នាដៃរឿងរាមកេរ្តិ៍ និងរឿងទុំទាវដែលជាស្នាដៃមានប្រជាប្រិយភាពខ្លាំងនៅក្នុងការសិក្សា។
- **ចំណោទបញ្ហា:** តើលក្ខណៈស្នេហារបស់តួអង្គក្នុងរឿងទាំងពីរ គឺនាងទាវនិងនាងសីតាមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

### ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី:** ដើម្បីជុំរុញឱ្យការប្រៀបធៀបលក្ខណៈស្នេហារបស់តួអង្គទាំងពីរខាងលើនេះ យើងគប្បីស្វែងយលពាក្យស្នេហាជាមុនសិន។
- **ពន្យល់ពាក្យ:** ស្នេហាក្នុងន័យនេះសំដៅទៅលើសេចក្ដីស្រឡាញ់ ការពេញចិត្តគ្នារវាងបុរសនិងស្ត្រីដើម្បីរស់នៅជាមួយគ្នាជាគូអនាគត។
- **ពន្យល់ន័យ:** តាមគំនិតប្រធានខាងលើបានតម្រូវឱ្យយើងធ្វើការប្រៀបធៀបរវាងចំនុចដូចគ្នានិងចំណុចខុសគ្នានៃសេចក្ដីស្រឡាញ់ពេញចិត្តគ្នាជាគូអនាគតរបស់នាងទាវក្នុងរឿងទុំទាវនិងនាងសីតាក្នុងរឿងរាមកេរ្តិ៍ខ្មែរ។

- បកស្រាយ៖

ក- លក្ខណៈដូចគ្នាស្នេហានាងទាវក្នុងរឿងទុំទាវ និងស្នេហានាងសីតាក្នុងរឿងរាមកេរ្តិ៍ខ្មែរ៖

- **គំនិតសំខាន់ និងឧទាហរណ៍៖**
  - ✓ ជាស្នេហាស្មោះត្រង់ ស្មោះស្ម័គ្របូរផ្តាច់ដូចគ្នា
  - ✓ ជាស្នេហាដែលបានឆ្លងកាត់ការផ្សំផ្គុំតាមគន្លងប្រពៃណីដូចគ្នា
  - ✓ ជាស្នេហាដែលត្រូវបានគេធ្វើឱ្យព្រាត់ប្រាស់ដូចគ្នា
  - ✓ ជាស្នេហាដែលបែកបាក់ ព្រាត់គ្នានៅទីបំផុតដូចគ្នា។

- **សរុបលក្ខណៈដូច**: សរុបសេចក្តីមកចំណុចខាងលើនេះ ជាលក្ខណៈដូចគ្នាស្នេហានាងទាវក្នុងរឿងទុំទាវ និងស្នេហានាងសីតាក្នុងរឿងរាមកេរ្តិ៍ខ្មែរ។

ខ- លក្ខណៈខុសគ្នាស្នេហានាងទាវក្នុងរឿងទុំទាវ និងស្នេហានាងសីតាក្នុងរឿងរាមកេរ្តិ៍ខ្មែរ

- **គំនិតសំខាន់ និងឧទាហរណ៍៖**

  **ចំពោះស្នេហានាងទាវ៖**
  - ✓ ជាស្នេហាកាំរន្ទះ (ទាវស្រឡាញ់ទុំតាំងពីមិនទាន់បានជួបទុំ)
  - ✓ ជាស្នេហាបែបបដិវត្តន៍គឺប្រើសិទ្ធិសេរីភាពរបស់ខ្លួនដើម្បីសុភមង្គល (ប្រឆាំងនិងប្រពៃណីចាស់គំរឹល)
  - ✓ ស្នេហាខុសគន្លងប្រពៃណី (ទាវធ្វើខុសប្រពៃណីបណ្តោយខ្លួនឱ្យទុំមុនរៀបការ)
  - ✓ ស្នេហានាងទាវរងទុក្ខព្រាត់ប្រាស់ ដោយសារម្តាយដែលល្មោភមាសប្រាក់ បុណ្យសក្តិជាអ្នកបំបែក
  - ✓ ស្នេហាទាវជាស្នេហាស្ថិតក្រោមគំនាសង្គមនិងប្រពៃណី«ទស្សនៈនំមិនធំជាងនាឡិ»
  - ✓ ទាវព្រាត់ពីទុំដោយសារសង្គមផ្តាច់ការ និងទ្រព្យសម្បត្តិបុណ្យសក្តិនិយម។

  **ចំពោះស្នេហានាងសីតា**
  - ✓ ស្នេហាតាមបែបការជ្រើសរើសកើតឡើងពីការប្រកួតប្រជែងសមត្ថភាព (នាងសីតាមិនដែលស្គាល់ព្រះរៀមពីមុនមកទេ)
  - ✓ ជាស្នេហាតាមបែបប្រពៃណី គោរពតាមឪពុកម្តាយ ឪពុកម្តាយជាអ្នកជ្រើសរើសគូស្រករឱ្យកូន (ប្រពៃណីបុរាណ)
  - ✓ ជាស្នេហាស្របតាមគន្លងប្រពៃណីត្រឹមត្រូវ
  - ✓ សីតារងទុក្ខព្រាត់ប្រាស់ស្នេហាពីព្រះរាមដោយសារបញ្ហាទំនាស់រវាងព្រះរៀមនិងត្រកូលយក្ស (កាឆេវឆាវរបស់ព្រះរៀមដែលកាត់ត្រចៀក ច្រមុះនិងកោរសក់នាងសូរបនខា)
  - ✓ ស្នេហានាងសីតាពុំមានគំនាបពីសង្គមឬការប្រកាន់វណ្ណៈអ្វីឡើយគឺកើតឡើងពីការព្រមព្រៀងរវាងសាមីខ្លួននិងគ្រួសារទាំងសង្ខាង
  - ✓ នាងសីតាព្រាត់ពីព្រះរៀមដោយសារតែព្រះរាមខ្លួនឯង (ប្រចណ្ឌយកនាងសីតាទៅសម្លាប់ធ្វើបាបកូនខ្លួនឯង បោកបញ្ឆោតនាងសីតាដោយធ្វើពុតជាស្លាប់...)

- **សរុបលក្ខណៈខុស**: សរុបសេចក្តីមកចំណុចខាងលើនេះ ជាលក្ខណៈខុសគ្នាស្នេហានាងទាវក្នុងរឿងទុំទាវ និងស្នេហានាងសីតាក្នុងរឿងរាមកេរ្តិ៍ខ្មែរ។

**គ- សរុបរួម** ទាំងនេះជាភស្តុតាងបញ្ជាក់ពីចំណុចដូចគ្នានិងចំណុចខុសគ្នារវាងស្នេហានាងទាវ និងនាងសីតា។ តួអង្គទាំពីរសុទ្ធសឹងតែជាតួអង្គមានភក្ដីភាពចំពោះស្នេហា លះបង់គ្រប់យ៉ាងដើម្បីស្នេហាដែលជាចរិតលក្ខណៈល្អប្រសើរបំផុតសម្រាប់ជាគំរូដល់ស្ត្រីទូទៅ។

**គ- បញ្ចប់សេចក្ដី**

- **វាយតម្លៃប្រធាន**: ឆ្លងតាមការប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញថា ទាំងនាងទាវ និងទាំងនាងសីតាសុទ្ធតែជានារី ដែលល្អប្រសើរមានស្នេហាស្មោះស្ម័គ្រភក្ដី ព្រោះតួអង្គទាំងពីរជាតួអង្គពោរពេញដោយឧត្ដមគតិហ៊ានធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីសេចក្ដីស្នេហានិងសុភមង្គលរបស់ខ្លួន។
- **មតិផ្ទាល់ខ្លួន**: ជាមួយគ្នានេះដែរទឹកចិត្តភក្ដីភាពនៃនារីទាំងពីរគឺជាការឆ្លុះបញ្ចាំងអំពីតម្លៃនារីខ្មែរដែលតែងតែមានភាពស្មោះស្ម័គ្រស្មោះត្រង់ចំពោះស្វាមីគ្រប់កាលៈទេសៈទាំងអស់។

## សេចក្ដីអធិប្បាយ

នៅក្នុងស្នាដៃអក្សរសិល្ប៍ភាគច្រើនតែងតែលើកយកនូវបញ្ហារបស់មនុស្ស និងសង្គមមនុស្សមកចោទនិងដោះស្រាយ ហើយក្នុងចំណោមបញ្ហាទាំងអស់នេះក៏មានបញ្ហាស្នេហាផងដែរ។ ជាពិសេសបញ្ហាស្នេហាក្នុងរឿងទុំទាវនិងរឿងរៀមកេរ្តិ៍ ដែលតម្រូវឱ្យយើងធ្វើការប្រៀបធៀបស្នេហានាងទាវក្នុងរឿងទុំទាវនិងស្នេហានាងសីតាក្នុងរឿងរៀមកេរ្តិ៍ខ្មែរ។

តើលក្ខណៈស្នេហារបស់តួអង្គក្នុងរឿងទាំងពីរគឺនាងទាវនិងនាងសីតាមានលក្ខណៈដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ?

ដើម្បីជុំរុញឱ្យការប្រៀបធៀបលក្ខណៈស្នេហារបស់តួអង្គទាំងពីរខាងលើនេះមានលក្ខណៈច្បាស់លាស់យើងគប្បីស្វែងយល់ន័យនៃពាក្យស្នេហាជាមុនសិន។ ពាក្យថាស្នេហាក្នុងន័យនេះសំដៅទៅលើសេចក្ដីស្រឡាញ់ការពេញចិត្តគ្នារវាងបុរសនិងស្ត្រីដើម្បីរស់នៅជាមួយគ្នាជាគូអនាគត។ តាមគំនិតប្រធានខាងលើបានតម្រូវឱ្យយើងធ្វើការប្រៀបធៀបរវាងចំនុចដូចគ្នានិងចំណុចខុសគ្នានៃសេចក្ដីស្រឡាញ់ពេញចិត្តគ្នាជាគូអនាគតរបស់នាងទាវក្នុងរឿងទុំទាវជាមួយទុំនិងសេចក្ដីស្រឡាញ់ពេញចិត្តរបស់នាងសីក្នុងរឿងរាមកេរ្តិ៍ជាមួយព្រះរាម។

ជាការពិតស្នេហាជាបញ្ហាធម្មជាតិមួយរបស់មនុស្សលោក ដែលតែងតែមានចំពោះមនុស្សគ្រប់គ្នាមិនថាអ្នកនោះខ្មៅឬសហានៈខ្ពស់ឬទាប មានឬក្រជាដើម។ ស្នេហាមនុស្សនេះទៀតសោតវាមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ឬក៏មានលក្ខណៈខុសគ្នា អាស្រ័យលើស្ថានភាពសង្គមឬចរិតលក្ខណៈមនុស្សដែលជះឥទ្ធិពលដល់លក្ខណៈស្នេហាផងដែរ។ ដោយឡែកសេចក្ដីស្នេហារបស់នាងទាវនិងនាងសីតា ក៏យើងអាចសង្កេតឃើញថាមានចំណុចដូចគ្នាផងនិងខុសគ្នាផង។ ចំពោះលក្ខណៈដូចគ្នានេះបានបង្ហាញឱ្យឃើញថាអ្នកទាំងពីរមានស្នេហាស្មោះត្រង់ស្មោះស្ម័គ្រប្ដូរផ្ដាច់ដូចគ្នា។ ដោយហេតុថាទោះបីជាម្ដាយរកវិធីបំបែកនាងចេញពីទុំយ៉ាងណាក៏ដោយ ក៏នាងទាវនៅតែស្រឡាញ់ទុំមិនដែលប្រែប្រួលចិត្តសូម្បីតែបន្តិច។ បុណ្យសក្តិ មាសប្រាក់ កិត្តិយសដែលម្ដាយនាងខំប្រឹងរកយកមកឱ្យ ក៏នាងមើលមិនចូលភ្នែកសោះឡើយរហូតដល់នាងបដិសេធសេចក្ដីស្នេហារបស់ស្ដេចចំពោះរូបនាងទៀតផង។ រីឯនាងសីតាវិញក៏មានសេចក្ដីស្នេហាស្មោះស្ម័គ្រចំពោះព្រះរាមដែរ នាងសុខចិត្តលះបង់ការរស់នៅដែលមានសេចក្ដីសុខក្នុងរាជវាំងមករស់នៅក្នុងព្រៃតាមព្រះ

រាមស៊ីអត់ស៊ីឃ្លានដោយមិនត្អូញត្អែរឡើយ។ លើសពីនេះទៅទៀត ទោះបីជាក្រុងរាពណ៍ចាប់នាងយកទៅឃុំក្នុងសួនអសោករាប់ឆ្នាំឆ្ងាយពីព្រះរាមហើយប្រើឧបាយកលផ្សេងៗដើម្បីលួងលោមសុំសេចក្តីស្រឡាញ់ពីនាង គឺនាងសីតាមិនដែលមានចិត្តវៀចវេរនោះទេ សេចក្តីស្នេហាចេញពីព្រះរាមបន្តិចឡើយ។ ម្យ៉ាវិញទៀតសេចក្តីស្នេហានៃនារីទាំងពីរសុទ្ធតែបានឆ្លងកាត់ការផ្សំផ្គុំតាមគន្លងប្រពៃណីដូចៗគ្នា។ ដោយនាងទាវត្រូវបានរៀបការជាមួយទុំសមតាមបំណង។ ចំណែកនាងសីតាវិញត្រូវបានព្រះបាទជនក ជាបិតាចិញ្ចឹមរៀបអភិសេកជាមួយព្រះរាមដែលទទួលបានជ័យជម្នះក្នុងការប្រកួតលើកធ្នូសរជ័យរបស់ព្រះបាទជនករជាស្វាមីយ៉ាងអធឹកអធមបំផុត។ ទន្ទឹមនឹងនេះដែលស្នេហានាងទាវ និងទាំងស្នេហានាងសីតាសុទ្ធសឹងជាស្នេហាដែលត្រូវបានគេធ្វើឱ្យព្រាត់ប្រាស់ទាំងអស់។ ទាវព្រាត់ប្រាស់ពីទុំរងទុក្ខខ្លោចផ្សារដោយសារម្តាយនាងមានចិត្តលោភល្មោភបុណ្យសក្តិមាសប្រាក់អំណាច សុខចិត្តយក ទស្សនៈ «នំមិនធំជាងនាឡិ» មកធ្វើជាលេះក្នុងការលើកដាក់កូនឱ្យមានស្វាមី ម្តងលើកឱ្យម៉ឺនងួនម្តងលើឱ្យស្តេច។ ចំណែកឯនាងសីតា គឺខ្លោចផ្សារដោយសារតែយក្សចាប់យកទៅឃុំទុកនៅនគរលង្កា ព្រោះតែការសងសឹកចំពោះព្រះរាមនិងព្រះលក្ស្មណ៍ដែលហ៊ានលេងសើចខុសទំនងជាមួយនាងស្វូរបនខាដែលជាប្អូនក្រុងរាពណ៍។ លើសពីនេះទៅទៀតស្នេហានៃនារីទាំងពីរនាក់ជាស្នេហាបែកបាក់ព្រាត់គ្នានៅទីបំផុតដូចគ្នា។ នាងទាវត្រូវព្រាត់ពីទុំដោយសារគេយកទៅសម្លាប់ចោលអសារបង់នៅពោធិ៍ជើងខាល ហើយនាងទាវក៏ស្លាប់ទៅតាមដើម្បីបញ្ជាក់ពីភក្តីភាព។ ដូចគ្នានេះដែរស្នេហានាងសីតាក៏ដូចនោះគឺដោយសារតែទង្វើអមនុស្សធម៌របស់ព្រះរាម ចំពោះនាងធ្វើឱ្យនាងឆ្អែតចិត្តលែងចង់ជួបមុខព្រះរាមជារៀងរហូត។ ទីបុំផុតនាងសុំឱ្យទេពធីតាគង្ហីងព្រះធរណីបើកផ្លូវទទួលនាងដើម្បីគេចពីព្រះរាម។

សរុបសេចក្តីមកខាងលើនេះជាចំណុចដូចគ្នានៃស្នេហារបស់នាងទាវនិងនាងសីតា។

រីឯចំណុចខុសគ្នានៃសេចក្តីស្នេហានាងទាវនិងនាងសីតានោះគឺស្ថិតនៅត្រង់ស្នេហានាងទាវជា ស្នេហាកាំរន្ទះឃើញភ្លាមស្រឡាញ់ភ្លែត ទាវមានចិត្តប្រតិព័ទ្ធលើទុំតាំងពីមិនទាន់បានឃើញមុខទុំ ដោយគ្រាន់តែឮសម្តីនិយាយអួតរបស់នាងនោតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ស្នេហារបស់នាងជាស្នេហាបែបជឿនលឿន គឺទាវហ៊ានប្រឆាំងនឹងផ្នត់គំនិតសង្គមនាសម័យនោះ «នំមិនធំជាងនាឡិ» ដោយចេះតែប្រើសិទ្ធិរបស់នាងដើម្បីស្វែងរកសុភមង្គលដោយខ្លួនឯងផ្ទាល់។ ជាមួយគ្នានេះដែរស្នេហារបស់នាងទាវគឺជាស្នេហា ដែលខុសគន្លងប្រពៃណី ដោយនាងហ៊ានបណ្តោយខ្លួនឱ្យ«ទុំមុនស្រគៀល»។ ក្នុងករណីនេះស្នេហារបស់នាងត្រូវរងទុក្ខព្រាត់ប្រាស់ដោយសារតែម្តាយរបស់នាងដែលមានគំនិតចាស់គំរឹលល្មោភមាសប្រាក់បុណ្យសក្តិចាប់បំបែកញែកចេញពីគ្នា ហើយម្តាយនាងក៏ជាអ្នកមេផ្តើមគំនិតឱ្យគេម្លាប់ទុំដែលជាប្តីទាវផងដែរ។ ម្យ៉ាងវិញទៀតសេចក្តីស្នេហារបស់នាងទាវជាសេចក្តីស្នេហាដែលស្ថិតនៅក្រោមគំនាបសង្គម និងប្រពៃណីចាស់គំរឹលហេតុនេះហើយទស្សនៈថ្មីរបស់នាងត្រូវបានសង្គមនាសម័យនោះបដិសេធចោលជាដាច់ខាត។ ទីបំផុតទាវត្រូវបានព្រាត់ពីទុំដោយសង្គមផ្តាច់ការរហូតបង្កឱ្យមានសោកនាដកម្មយ៉ាងខ្លោចផ្សារបំផុត។

ចំណែងស្នេហានាងសីតាវិញគឺជាស្នេហាតាមបែបការជ្រើសរើសដោយកើតឡើងពីការប្រកួតប្រជែងលើធ្នូសរជ័យដែលរៀបចំដោយព្រះបាទជនក។ នាងសីតាមិនដែលស្គាល់ព្រះរាមពីមុនមក។ ហេតុដូច្នេះហើយទើបយើងសង្កេតឃើញថា ស្នេហារបស់នាងជាស្នេហាតាមបែបប្រពៃណី គោរពតាមការសម្រេចចិត្តរបស់ឪពុកម្តាយជាអ្នកជ្រើសរើសគូស្រករឱ្យកូនមានន័យថាបើសិនការលើកធ្នូ

សនោះ អ្នកឈ្នះមិនមែនជាព្រះរាមក៏នាងសីតាត្រូវតែទទួលយកជាស្វាមីពុំមានអ្វីមកគត់វាឡើយ។ ដោយហេតុនាងសីតាគោរពតាមជ្រើសរើសនេះហើយទើបធ្វើឱ្យស្នេហារបស់នាងប្រព្រឹត្តទៅដោយរលូនតាមបែបបទនិងគន្លងប្រពៃណី។ លើសពីនេះដែរ ការដែលនាងរងទុក្ខព្រាត់ប្រាស់ស្នេហាពីព្រះរាមពុំដោយបញ្ហាពីសង្គមឡើយ តែផ្ទុយទៅវិញគឺការព្រាត់ប្រាស់នេះកើតឡើងដោយសារតែទំនាស់រវាងព្រះរាមនិងត្រកូលយក្សដែលផ្តើមចេញពីទំនាស់ព្រះរាមជាមួយនាងសូបនខា។ ម្យ៉ាងវិញទៀតស្នេហានាងសីតាជាស្នេហាមួយ គឺមានការព្រមព្រៀងគ្នាជាមុនដោយពុំមានការគាបសង្កត់ពីសង្គមអ្វីឡើយ។ រីឯការដែលនាសីតាព្រាត់ប្រាស់បែកបាក់ពីព្រះរាម ក៏ព្រោះតែព្រះរាមខ្លួនឯងដែលមានគំនិតសង្ស័យលើនាងសីតារហូតធ្វើឱ្យនាងស្អប់លែងជួបមុខជារៀងរហូត។

សរុបសេចក្តីមកខាងលើនេះជាចំណុចខុសគ្នានៃស្នេហារបស់នាងទាវនិងនាងសីតា។

រួមសេចក្តីមកភស្តុតាងទាំងប៉ុន្មានខាងលើនេះបានបង្ហាញពីចំណុចដូចគ្នា និងចំណុចខុសគ្នារវាងស្នេហានាងទាវក្នុងរឿងទុំទាវនិងនាងសីតាក្នុងរឿងរាមកេរ្តិ៍ខ្មែរ។ តួអង្គទាំងពីរសុទ្ធសឹងតែជាតួអង្គ ដែលមានភក្តីភាពចំពោះស្នេហាលះបង់គ្រប់បែបយ៉ាងដើម្បីស្នេហាដែលជាចរិតលក្ខណៈល្អប្រសើរបំផុតសម្រាប់ជាគំរូដល់ស្ត្រីទូទៅ។

ឆ្លងតាមការប្រៀបធៀបខាងលើបានបង្ហាញឱ្យឃើញថា ទាំងនាងទាវនិងទាំងនាងសីតាសុទ្ធតែជានារីដែលល្អប្រសើរមានស្នេហាស្មោះស្ម័គ្រភក្តី ព្រោះតួអង្គទាំពីរជាតួអង្គពោរពេញដោយឧត្តមគតិរៀងៗខ្លួនហ៊ានធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីសេចក្តីស្នេហានិងសុភមង្គលរបស់ខ្លួន។ ជាមួយគ្នានេះដែរទឹក ចិត្តភក្តីភាពនៃនារីទាំងពីរ គឺជាការឆ្លុះបញ្ចាំងអំពីតម្លៃនារីខ្មែរ ដែលតែងតែមានភាពស្មោះត្រង់ស្មោះស្ម័គ្រចំពោះស្វាមីគ្រប់កាលៈទេសៈទាំងអស់។

---

**ប្រធានទី២:** ចូរអ្នកធ្វើការប្រៀបធៀបលក្ខណសម្បត្តិតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ និងតួអង្គព្រះវេស្សន្តរក្នុងរឿងព្រះវេស្សន្តរជាតក។

---

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** លើកយកលក្ខណៈទូទៅភាពដូចគ្នានិងភាពខុសគ្នា របស់តួអង្គទាំងពីរមកបង្ហាញ
- **ចំណូលបញ្ហា (បង្ហាញប្រធាន):** ដោយអាស្រ័យហេតុនេះទើបមានការប្រៀបធៀបលក្ខណៈតួអង្គទាំងពីរ។
- **ចំណោទបញ្ហា:** តើតួអង្គទាំងពីរខាងលើមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណា?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីងាយស្រួលក្នុងការប្រៀបធៀបបញ្ហាប្រធានខាងលើ យើងគប្បីយល់ន័យនូវពាក្យ «លក្ខណៈ»។
- **ពន្យល់ពាក្យ:** «លក្ខណៈ»សំដៅទៅលើទ្រង់ទ្រាយបែបផែនរបស់មនុស្សទាំងអស់ដែលមាន។
- **ពន្យល់ន័យប្រធាន:** ទស្សនៈប្រធានចង់ឱ្យរកលក្ខណៈទ្រង់ទ្រាយបែបផែននៃតួអង្គព្រះរាមនិងវេស្សន្តរដែលមានលក្ខណៈរួមនិងដោយឡែក។

- បកស្រាយៈ

ក- **លក្ខណៈដូចគ្នា:** លក្ខណសម្បត្តិតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ និងតួអង្គព្រះវេស្សន្តរក្នុងរឿងព្រះវេស្សន្តរជាតកៈ

- **គំនិតសំខាន់ និងឧទាហរណ៍ៈ**
  - ✓ ជាបុត្ររបស់ព្រះមហាក្សត្រនៃនគរមួយ
  - ✓ មានមហេសីនិងបុត្រពីរនាក់
  - ✓ ខន្តីមិនក្រេវក្រោធ អហិង្សា
  - ✓ ចាកចេញពីនគរ
  - ✓ ជួបឧបសគ្គ
  - ✓ សោយរាជ្យសម្បត្តិ
- **សរុបលក្ខណៈដូចគ្នា។**

ខ- **លក្ខណៈខុសគ្នា:** លក្ខណសម្បត្តិ តួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ និងតួអង្គព្រះវេស្សន្តរក្នុងរឿងព្រះវេស្សន្តរជាតកៈ

- **គំនិតសំខាន់ និងឧទាហរណ៍ៈ**

  **តួអង្គព្រះរាមៈ**
  - ✓ ជាអវតារ ព្រះវិស្ណុ មានចិត្តលោភលន់ ល្មោភសង្គ្រាម ចិត្តឆេវឆាវ
  - ✓ ប្រើល្បិចក្រោយខ្នង  បោកប្រាស់
  - ✓ ដោះស្រាយទំនាស់ ហិង្សា (ទំនាស់ សម្លាប់)
  - ✓ ព្រាត់ប្រាសប្រពន្ធកូន។

  **តួអង្គព្រះវេស្សន្តរៈ**
  - ✓ ជាព្រះពោធិសត្វ (សាងបារមី)
  - ✓ មិនមានចិត្តលោភលន់ ចិត្តល្អ
  - ✓ ឱ្យបានយូរអង្វែង
  - ✓ ដោះស្រាយទំនាស់ដោយធម៌ អហិង្សា
  - ✓ មិនព្រាត់ប្រាសប្រពន្ធកូន។
- **សរុបលក្ខណៈខុសគ្នា**

គ- **សរុបរួម** រួមសេចក្តីមកតាមរយៈលក្ខណសម្បត្តិនិងតួអង្គទាំងពីរសុទ្ធតែមានចំណុចដូចគ្នានិងចំណុចខុសគ្នាមែន។ តែបើតាមការបកស្រាយខាងលើឃើញថា តួអង្គព្រះវេស្សន្តរមានលក្ខណសម្បត្តិ ប្រសើរជាងព្រះរាមព្រោះចំណុចអវិជ្ជមានរបស់ព្រះរាមច្រើន។

គ- **សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន:** ឆ្លងតាមការបកស្រាយប្រៀបធៀបខាងលើបង្ហាញឱ្យឃើញថាលក្ខណសម្បត្តិរបស់ព្រះវេស្សន្តរប្រសើរជាងលក្ខណសម្បត្តិព្រះរាមដោយហេតុទ្រង់ជាព្រះពោធិសត្វមានសីល ខន្តី សណ្តោស មិនឆេវឆាវនិងដោះស្រាយបញ្ហាដោយសន្តិវិធី។
- **មតិផ្ទាល់ខ្លួន:** ដូច្នេះ ក្នុងនាមជាមនុស្សរស់នៅក្នុងសង្គម គប្បីត្រូវមានចិត្តសន្តោសប្រណី ខន្តី អធ្យាស្រ័យគ្នាដើម្បីទទួលបាននូវសេចក្តីសុខសន្តិភាព។

# សេចក្ដីអធិប្បាយ

នៅក្នុងស្នាដៃនីមួយៗកវីនិពន្ធតែងតែឆ្លុះបញ្ចាំងពីចរិតលក្ខណៈតួអង្គទៅតាមទៅតាមសិល្ប៍វិធីរបស់ខ្លួនក្នុងបំណងឱ្យអ្នកសិក្សា អ្នកអានចេះវិភាគរកគុណសម្បត្តិ គុណវិបត្តិ ដើម្បីដកស្រង់បទពិសោធ ពីតួអង្គទាំងនោះមកអប់រំឱ្យចេះប្រកាន់យកអំពើល្អ។ រីឯក្នុងអក្សរសិល្ប៍បុរាណខ្មែរ គឺរឿងរាមកេរ្តិ៍ និងរឿងព្រះវេស្សន្តរ ក៏បានបង្ហាញពីចរិតលក្ខណៈនិងសកម្មភាពតួអង្គព្រះរាមនិងព្រះវេស្សន្តរដែរ។

តើតួអង្គទាំងពីរខាងលើនេះ មានលក្ខណសម្បត្តិដូចគ្នានិងខុសគ្នាយ៉ាងណា?

ដើម្បីងាយស្រួលក្នុងការប្រៀបធៀបបញ្ហាប្រធានខាងលើយើងគប្បីយល់ន័យនូវពាក្យ «លក្ខណៈ» ជាមុនសិន។ លក្ខណៈមានន័យថាទ្រង់ទ្រាយបែបបទបែបផែន ដែលមនុស្សម្នាក់ៗមាន។ ប្រធានខាងលើចង់ឱ្យរកលក្ខណៈទ្រង់ទ្រាយបែបផែនរបស់តួអង្គព្រះរាមនិងព្រះវេស្សន្តរដែលមានលក្ខណៈដូចគ្នានិងខុសគ្នា។

ជាការពិត មនុស្សគ្រប់រូបកើតមកសុទ្ធតែមានលក្ខណសម្បត្តិរៀងៗខ្លួនដែលបង្ហាញឱ្យឃើញតាមរយៈសកម្មភាពទាំងវិជ្ជាមាននិងទាំងអវិជ្ជមាន។ ចំពោះលក្ខណសម្បត្តិទាំងនោះមានមនុស្សខ្លះដូចគ្នា ឯមនុស្សខ្លះទៀតមិនដូចគ្នា។ តួយ៉ាងតួអង្គព្រះរាមនិងព្រះវេស្សន្តរ គឺមានទ្រង់ទ្រាយបែបផែននៃលក្ខណសម្បត្តិស្រដៀងគ្នាត្រង់ថាជាបុត្រព្រះមហាក្សត្រនៃនគរមួយ។ ព្រះរាមជាបុត្ររបស់ព្រះបាទទសរថដែលសោយរាជ្យនៅនគរពួយុធ្យា ចំណែកព្រះវេស្សន្តរជាបុត្ររបស់ព្រះស្រីសញ្ជ័យនៅនគរជេតុត្តរ។ ទ្រង់ទាំងពីរអង្គមានមហេសីនិងបុត្រពីរដូចគ្នា នាងសីតាមហេសីរបស់ព្រះរាមមានរាមលក្ស្មណ៍និងជប់លក្ស្មណ៍ជាបុត្រ។ ចំណែកនាងមេទ្រីមហេសីព្រះវេស្សន្តរមានជាលីក្រស្នាជាបុត្រផងដែរ។ ទ្រង់ទាំងពីរជាក្សត្រដែលប្រកបដោយសេចក្ដីមេត្តា ខន្តី សន្ដោស។ ជាក់ស្ដែងក្នុងរឿងរាមកេរ្តិ៍នៅនគរពួយុធ្យាមានទំនាស់ ព្រោះការច្រណែនពីនាងកៃកេសី ព្រះលក្ស្មណ៍បម្រុងនឹងសម្លាប់នាងកៃកេសីចោល តែព្រះរាមបានរារាំងព្រោះទ្រង់ប្រកាន់ធម៌ខន្តី មិនក្រោធ មិនប្រកាន់ទោសចំពោះម្ដាយចុង។ ចំណែកព្រះវេស្សន្តរវិញក៏ដូចគ្នាដែរ ដោយទ្រង់ដាក់ទានដំរីបច្ច័យនាគេន្ទ្រដែលជាអំពើល្អសោះតែបែរជាមានឈ្មោះថាជាអ្នកបៀតបៀនដែនអាយទៅវិញ ពេលនោះទ្រង់ខន្តីមិនខឹងនិងប្រជារាស្ត្រទ្រង់ឡើយ។ មួយវិញទៀតនោះ ដំណើរយាងចូលព្រៃព្រះរាមសុខចិត្ត ចាកចេញពីនគរទៅបួសជាតាបសឥសីនៅភ្នំចិត្រកូដ ឯព្រះវេស្សន្តរចាកចេញពីនគរទៅបួសជាឥសីនៅភ្នំគិរីវង្កត។ ការយាងនេះមានស្ថានភាពដូចគ្នា បើនិយាយពីបញ្ហាដែលទ្រង់បានជួបប្រទះស្រដៀងគ្នា ព្រះរាមមានបញ្ហាជាមួយនាងស្វរបនខាប្អូនស្រីក្រុងរាពណ៍ ហើយព្រះវេស្សន្តរជួបជាមួយជូជកនៅពេលកំពុងធ្វើតាំងសិល្ប៍។ នាងយក្ខិនីដែលរំខានការធ្វើពិធីតបៈយោគៈ ចំណែកជូជកមកសុំបុត្រពីព្រះវេស្សន្តរ។បន្ថែមពីនេះទៅទៀត ទ្រង់ទាំងពីរបានសោយរាជ្យដូចគ្នាគឺក្នុងរឿងរាមកេរ្តិ៍ ព្រះរាមបានសោយរាជ្យនៅនគរពួយុធ្យា ហើយព្រះវេស្សន្តរសោយរាជ្យនៅជេតុត្តរនគរ។

សរុបសេចក្តីមក ព្រះរាម ព្រះវេស្សន្តរពិតជាមានលក្ខណសម្បត្តិដូចគ្នាច្រើនមែន។

ទោះបីការបង្ហាញខាងលើរួចមក ទ្រង់ទាំងពីរមានលក្ខណសម្បត្តិដូចគ្នាយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខុសគ្នាដែរ។ ជាក់ស្ដែងព្រះរាមជាអវតារព្រះវិស្ណុមានន័យថាទ្រង់តាងនាមអាទិទេពចុះមកដើម្បីកម្ចាត់រាល់សភាវអាក្រក់។ ជាក់ស្ដែងសម្លាប់រាមបរមេស្វរជាប្អូនរបស់ក្រុងរាពណ៍ពេលជួបនៅតាមផ្លូវទៅនគរពួយុធ្យាធ្វើសង្គ្រាមសម្លាប់កុម្ភកាណ៌ មហារីក ពិរោធ និងក្រុងរាពណ៍

ដែលជាពូជពង្សយក្សដើម្បីរំដោះនាងសីតាយកត្រឡប់មកវិញ។ ម្យ៉ាងទៀត ព្រះរាមពោរពេញដោយសេចក្តីលោភលន់ ទោះបីទ្រង់បានប្រមូលកងទ័ពស្វាពីសុគ្រីពហើយក៏ដោយ ក៏ទ្រង់នៅមិនទាន់អស់ចិត្តដែរ គឺចង់បានទ័ពមហាជម្ពូបន្ថែមទៀតដែលមានមេទ័ពខុននិល ខុននល។ មិនត្រឹមតែប៉ុណ្ណឹងព្រះរាមជាជនល្មោភសង្គ្រាមជាតឹកតាងទ្រង់បានធ្វើសង្គ្រាមជាមួយកូនក្មេង រាមលក្សណ៍ ជបលក្សណ៍ជាកូនខ្លួនឯងតាមចាប់ពីហនុមាន សេនាទ្រង់រហូតដល់បានសម្រេចដាក់គុកម្នាក់ដោយទ្រង់ផ្ទាល់ ទើបបញ្ចប់សង្គ្រាមជាមួយលង្កាថ្មីៗ។ ជានេះទៅទៀតទ្រង់មានគុណវិបត្តិដោយបោកប្រាស់នាងសីតាកុហកថាសុគតដើម្បីឱ្យនាងវិលចូលនគរវិញ។ ទ្រង់ប្រើល្បិចនេះមិនសក្តិសមទាល់តែសោះក្នុងនាមជាអវតារព្រះវិស្ណុ។ លើសពីនេះទៅទៀត ព្រះអង្គបានប្រើល្បិចសម្លាប់ពាលីពីក្រោយខ្នងជាក់ស្តែង ឱ្យសុគ្រីពទៅបបួលពាលីមកប្រយុទ្ធខ្លួនទ្រង់លបបាញ់ពីក្រោយខ្នងនេះត្រូវនឹងឃ្លាមួយថា អ្នកប្រយុទ្ធអន់សម្លាប់សត្រូវដោយសត្រូវគ្មានអាវុធក្នុងដៃ។ បើសម្លឹងទៅលើការដោះស្រាយបញ្ហាវិញនោះទ្រង់ដោះស្រាយដោយធ្វើសង្គ្រាម។ ជាការពិតណាស់ពេលនាងសីតាត្រូវក្រុងរាពណ៍ចាប់ទ្រង់មិនប្រើអហិង្សាវិធីដោយការចរចាទៅដោះស្រាយនោះទេ គឺធ្វើសង្គ្រាមដូចជាឱ្យអង្គទយកសារទៅប្រាប់ក្រុងរាពណ៍ ការសង់ស្ពានទៅនគរលង្កាដែលជាភាពប្រសើរមួយសម្រាប់កងទ័ពព្រះអង្គធ្វើដំណើរ។ ដោយអំពើមិនត្រឹមត្រូវទាំងនេះហើយទើបទ្រង់ព្រាត់ប្រាសមហេសីព្រមទាំងបុត្រ។

ផ្ទុយទៅវិញចំពោះព្រះវេស្សន្តរ ទ្រង់ជាតួអង្គព្រះពោធិសត្វប្រសូតមកដើម្បីកសាងបារមីមួយដែលជាបារមីចុងក្រោយមានឈ្មោះថា ទានបារមីបំពេញគ្រប់ ទ្រង់ក្លាយជាព្រះពុទ្ធស្រោចស្រង់ជីវិតសត្វក្នុងលោកឱ្យរួចផុតពីនគរ។ ជាក់ស្តែងទ្រង់បានដាក់ទានទ្រព្យ បុត្រ  ប្រពន្ធ  ហើយសូម្បីតែអវៈយវៈ ព្រមទាំងជីវិតទៀតដោយមិនស្តាយស្រណោះអ្វីឡើយ។ ទ្រង់ផ្ទាល់មិនមានចិត្តលោភលន់ដូចព្រះរាមឡើយ គឺមានតែឱ្យមិនចង់បានអ្វីពីរាស្ត្រឬនគរតូចតាចជាក់ស្តែងការឱ្យទានដំរីជ័យដល់នគរដទៃបានន័យថាមិនប្រកាន់វណ្ណៈពូជសាសន៍ ពណ៌សម្បុរអ្វីឡើយ ចិត្តនឹកតែពីទានរហូតដល់ក្ស័យជន្មា។ បើនិយាយពីការដោះស្រាយទំនាស់វិញក៏ផ្ទុយពីព្រះរាមដែរ ដូចជាទ្រង់នៅពេលតាជូជកសុំបុត្របានហើយ តាចាស់នោះបានវាយធ្វើបាបកុមារទាំងពីរវាយវាត់និងវល្លិ៍នៅមុខទ្រង់ បើព្រះរាមប្រាកដជាសម្លាប់តាជូជកចោលជាក់ជាមិនខាន តែនេះទ្រង់ព្រះវេស្សន្តរអញ្ជើងហើយទើបតាកញ្ជាស់នោះរួចផុតពីអន្តរាយ។ ដោយសារគុណសម្បត្តិ ព្រះវេស្សន្តរច្រើនបែបនេះហើយ ទើបទ្រង់រស់នៅមិនព្រាត់ប្រាស់ប្រពន្ធកូនដូចព្រះរាមឡើយ។

សរុបមកចំណុចខាងលើនេះ ជាចំណុចខុសគ្នារវាងលក្ខណសម្បត្តិព្រះរាមនិងព្រះវេស្សន្តរ។

រួមសេចក្តីមក  តាមរយៈតួអង្គទាំងពីរសុទ្ធតែមានលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នាមែន។ តែការបកស្រាយខាងលើឃើញថា តួអង្គព្រះវេស្សន្តរមានលក្ខណសម្បត្តិប្រសើរជាងព្រះរាមមានចំណុចអវិជ្ជាមានច្រើន។

ឆ្លងតាមការបកស្រាយប្រៀបធៀបខាងលើបង្ហាញឱ្យឃើញថា លក្ខណសម្បត្តិរបស់ព្រះវេស្សន្តរប្រសើរជាងលក្ខណៈសម្បត្តិព្រះរាម ដោយហេតុទ្រង់ជាអង្គព្រះពោធិសត្វប្រកាន់ធម៌ខន្តីសីល មិនឆេវឆាវ សណ្តោសដោះស្រាយបញ្ហាដោយសន្តិវិធី។ ដូច្នេះក្នុងនាមជាមនុស្សរស់នៅក្នុងសង្គមប្រកាន់យកព្រះពុទ្ធសាសនាគប្បីត្រូវមានចិត្តសណ្តោសប្រណីខន្តី អធ្យាស្រ័យគ្នាដើម្បីទទួលបាននូវសុខសន្តិភាព។

**ប្រធានទី២:** ចូរអ្នកធ្វើការប្រៀបធៀបបញ្ហាអត្តឃាតរបស់នាងទាវនិងនាងនៅក្នុងរឿងទុំទាវ។

## សេចក្តីអធិប្បាយ

បញ្ហាធ្វើអត្តឃាត តែងកើតមានក្នុងជីវភាពសង្គមមនុស្សទូទៅ ហើយត្រូវបានគេលើកយកមកបញ្ចូលនៅក្នុងសិល្បវិធីនិពន្ធបង្កើតជាចលនារស់រវើកក្នុងស្នាដៃអក្សរសិល្ប៍ ពិសេសប្រលោមលោកបែបមនោសញ្ចេតនា។ ដោយឡែករឿងទុំទាវ ជាស្នាព្រះហស្ថមហាកវីនិពន្ធព្រះភិក្ខុសោមតែងក្នុងឆ្នាំមួយពាន់ប្រាំបួនរយដប់ប្រាំដ៏ល្បីល្បាញ ក៏បានពន្លេចនូវបញ្ហាអត្តឃាតនេះផងដែរ តាមរយៈតួអង្គស្ត្រីវ័យក្មេងពីររូប គឺនាងទាវនិងនាងនៅ។ ទោះបីការសម្លាប់ខ្លួនឯងរបស់នាងទាំងពីរដូចគ្នាក៏ពិតមែន ប៉ុន្តែគេនៅឃើញលក្ខណៈខ្លះខុសគ្នាផងដែរ។ អាស្រ័យហេតុនេះទើបគេឱ្យប្រៀបធៀប «បញ្ហាអត្តឃាតរបស់នាងទាវនិងនាងនៅ»។

តើបញ្ហាអត្តឃាតរបស់នាងទាំងពីរមានលក្ខណៈដូចគ្នា និងខុសគ្នាត្រង់ណាខ្លះ?

មុននឹងបកស្រាយបង្ហាញបញ្ហារបស់ប្រធានខាងលើឱ្យបានក្បោះក្បាយគួរយល់ពាក្យខ្លះដូចជា «អត្តឃាត» ដែលមានន័យថា សម្លាប់ខ្លួនឯង។ ឯពាក្យ«បញ្ហា» សំដៅលើពាក្យឬសេចក្តីដែលមានអាថ៌កំបាំងទស្សនៈប្រធានតម្រូវឱ្យរកលក្ខណៈដូចនិងខុសគ្នាទាក់ទងការសម្លាប់ខ្លួនឯងរបស់នាងទាវនិងនាងនៅ។

ជាដំបូងយើងពិនិត្យស្រាវជ្រាវតាមខ្លឹមសាររឿងទុំទាវទៅលើលក្ខណៈដូចគ្នាស្តីពីការសម្លាប់ខ្លួនឯងរបស់តួអង្គនារីទាំងពីរឃើញមានច្រើនករណី តួយ៉ាងនាងទាំងពីរកំពុងពេញវ័យឬក្មេងឈាមរាវមានចិត្តងប់ងល់ស្រើបស្រាលនឹងតណ្ហា ស្រឡាញ់ប្រុសរូបស្អាតសំឡេងពីរោះល្បីល្បាញម្នាក់ដែលបង្កឱ្យបាត់បង់វិចារណញ្ញាណឈានទៅគិតខ្លី។ ម្យ៉ាងទៀតការបាត់បង់ទុំបណ្តាលឱ្យនាងស្តាយស្រណោះអាឡោះអាល័យរហូតអស់សង្ឃឹមដោយបាត់បង់អ្នកជាទីស្រឡាញ់ពេញចិត្ត រួមទាំងរបបសង្គមដែលកំពុងរស់នៅពោរពេញដោយភាពផ្តាច់ការយង់ឃ្នង។ ទន្ទឹមនេះ នាងទាំងពីរហាក់ស្តាយកំហុសឆ្គងបានប្រព្រឹត្តកន្លងមក ពិសេសចំពោះអ្នកមានគុណគឺបង្កការលំបាកដល់លោកដែលខំបីបាច់រក្សាស្រឡាញ់។ មួយវិញទៀតក៏អាចថានាងបានមើលឃើញនូវក្តីវិនាសគ្រួសារទាំងមូលផងដែរ។ ពោលគឺអ្វីៗទាំងនេះកើតចេញពីការឈឺចាប់ខាងផ្លូវចិត្តធ្ងន់ធ្ងរពេក។

ដើម្បីឱ្យកាន់តែពិស្តារយើងមានដំណើររឿងខ្លះបញ្ជាក់បន្ថែមជាឧទាហរណ៍។ តាមដំណើររឿងបង្ហាញថានាងទាវជានារី ទើបពេញវ័យក្រមុំកំពុងចូលម្លប់តាមប្រពៃណី ហើយក្រោយពីទទួលដំណឹងពីនាងនៅថាមានលោកនេនមួយអង្គមានរូបស្អាតសំឡេងពីរោះមកនាងទាវបានចាប់ចិត្តលើនេននោះភ្លាមៗរហូតសុំម្តាយទៅនិមន្តនេននោះមកសូត្រដើម្បីបានឃើញជាក់ច្បាស់។ ខណៈនេនទុំមកដល់នាងទាវស្រឡាញ់ដកចិត្តពុំរួចរហូតហ៊ានប្រគល់ខ្លួនប្រាណដល់ទុំ ជាហេតុជំរុញឱ្យទុំលាចាកសិក្ខាបទនិងមករកជួបនាងនៅត្បូងឃ្មុំ។ ទុំនិងទាវតស៊ូរហូតបានសម្រេចជួបគ្នាជាប្តីប្រពន្ធស្របច្បាប់ដោយព្រះរាជាពាមាផ្សំផ្គុំឱ្យ។ ប៉ុន្តែជីវិតគូស្រករនេះ ត្រូវបែកបាក់រហូតទុំត្រូវអរជូននិងបក្សពួកចាប់សម្លាប់តាមការញុះញង់របស់ម្តាយនាង។ នាងទាវបានលួចចេញពីរោងការទៅទីទួលដែលគេសម្លាប់ទុំរួចនាងក៏សម្លាប់ខ្លួនតាមទៅដែរ។ ចំណែកនាងនៅវិញ ពេលទៅផ្សារឃើញទុំ និងស្តាប់ទុំសូត្រពីរោះនាងបាក់ចិត្តស្រឡាញ់ខ្លាំងក្លា ដោយនាងក៏ពេញវ័យក្រមុំនៅបម្រើនាងទាវដែរ។ ការងប់ងល់នេះជំរុញឱ្យនាងនៅប្រាប់នាងទាវឱ្យសុំម្តាយនិមន្តទុំមកផ្ទះដើម្បីឃើញជាក់។ ក្រោយ

ពេលមានបញ្ហាធំៗកើតឡើងរហូតគេសម្លាប់ទុំបណ្ដាលឱ្យនាងអាល័យខូចចិត្តពិសេសនាងទាវដែលនាងស្រឡាញ់ដែរស្លាប់ចោលទៀតនាងនោបានសម្រេចចិត្តសម្លាប់ខ្លួនតាម។

សរុបមកបញ្ហាអត្តឃាតរបស់នាងទាវ និងនោមានលក្ខណៈដូចគ្នាមែន។

ទោះបីដូច្នេះក្ដី គេនៅសង្កេតឃើញថាបញ្ហាដដែលនេះរបស់នាងទាំងពីរនៅមានចំណែកនិងលក្ខណៈខ្លះផ្សេងពីគ្នាផងដែរ ករណីបញ្ហាសម្លាប់ខ្លួនរបស់នាងទាវមានលក្ខណៈខុសគ្នានៅត្រង់នាងបានគ្នាជាប្ដីប្រពន្ធធ្លាប់រួមរក្ស ស្និទ្ធស្នាលរហូតហ៊ានរំលោភបំពានប្រពៃណីទំនៀមទម្លាប់និងទឹកចិត្តម្ដាយបំផ្លាញកិត្តយសគ្រួសារធ្ងន់ធ្ងរ។ ទន្ទឹមនេះនាងទាវបានផ្សងនិងប្ដេជ្ញានៅជាមួយប្រុសស្នេហ៍រៀងរហូតគ្រប់ជាតិ។ ម្យ៉ាងនាងគិតថាមិនអាចរស់នៅធ្វើជាប្រពន្ធម៉ឺនងួនបានឡើយ គឺនាំឱ្យបាត់តម្លៃស្ត្រីមានប្ដីពីរឬថាជាស្ត្រីចិត្តចើកនោះឡើយ ពិសេសមិនអាចរស់នៅជាមួយឃាតករសម្លាប់ប្រុសដែលនាងស្រឡាញ់ស្មើជីវិតនោះដែរ។ ជាងនេះទៀតបញ្ហាអត្តឃាដនាងជំរុញឱ្យកើតមាននូវភាពរឹករវ មហាន្តរាយ និងទារុណកម្មធ្ងន់ធ្ងរដល់អ្នកដទៃទៀតផង។ ជាក់ស្ដែងដំណើររឿងបង្ហាញថានាងទាវ និងទុំបានរួមរក្សគ្នាខុសឆ្គងមុនពេលរៀបការ ហើយក៏ត្រូវក្លាយជាប្ដីប្រពន្ធស្របច្បាប់ផងដែរ។ ប៉ុន្តែក្រោយនេះបន្តិច  ម្ដាយនាងបំបែកយកមករៀបការជាមួយម៉ឺនងួនកូនអរជូនវិញ ជាងនេះទៀតគឺម្ដាយនាងស្អប់ ញុះញង់អរជូនឱ្យសម្លាប់ទុំដែលជាបណ្ដូលចិត្តនាងថានឹងរស់នៅជាមួយគ្នារៀងរហូត។ សេចក្ដីសង្ឃឹមនេះត្រូវរលាយ ក្រោមស្នាដៃអ្នកមានគុណខ្លួន ជាហេតុធ្វើឱ្យនាងរឹតតែមានទុក្ខទ្វេឡើង ហើយបើនាងតាមម្ដាយរៀបការជាមួយអរជូននោះកាន់តែធ្ងន់ធ្ងរខ្លាំងឡើង ព្រោះម៉ឺនងួនជាឃាតករសម្លាប់ទុំ។ កត្តាទាំងអស់នេះ ទើបនាងធ្វើអត្តឃាតតាមទុំទុកនូវទុក្ខទារុណដល់គ្រួសារនិងអ្នកស្រុកត្បូងឃ្មុំ។

ចំណែកឯអត្តឃាតរបស់នាងនោមានលក្ខណៈខុសពីនាងទាវនៅត្រង់ មិនអាចរស់ព្រោះអ្នកជាទីស្រឡាញ់គាប់ចិត្តបាត់បង់ជីវិតចោលអស់ ហើយក៏បាត់បង់ក្ដីសង្ឃឹមចំពោះខ្លួនឯង ដែលកំព្រាគ្រប់យ៉ាងរស់ជាអ្នកបម្រើគេ លួចមានចិត្តប្រតិព័ទ្ធគេតែម្នាក់ឯង។ ពិសេសនាងនោហាក់យល់ដឹងថាកំហុសឆ្គងរបស់នាងទាវក្ដី មហាទារុណលើគ្រួសារនាងទាវក្ដីគឺនាងជាអ្នកនាំឬប្រភពបង្កឡើង។ ជាក់ស្ដែងតាមដំណើររឿងបង្ហាញថានាងនោលួចស្នេហាទុំម្នាក់ឯងពេលឃើញនូវផ្សារត្បូងឃ្មុំ ហើយអន្ទះសាមកប្រាប់នាងទាវជាម្ចាស់បង្ករឱ្យទាវប្រជែងផ្លូវចិត្តនិងសញ្ចេតនាឆក់ស្នេហាពីនាងនោ។ ទន្ទឹមនេះពេលកើតបញ្ហាឡើងនាងនោតែងនៅជិតនាងទាវជានិច្ចដោយគាត់ស្រឡាញ់ទាវដូចបងប្អូនបង្កើតរហូតពេលនាងទាវសម្លាប់ខ្លួននាងក៏សម្លាប់តាមដែរ។

សរុបសេចក្ដីមក បញ្ហាអត្តឃាតរបស់នាងទាំងពីរមានលក្ខណៈខុសគ្នាមែន។

រួមសេចក្ដីមក បញ្ហាអត្តឃាតរបស់នាងទាវនិងនោដូចគ្នាត្រង់ឈឺចិត្តឬខូចចិត្តដោយបាត់បង់ជនជាទីស្រឡាញ់គឺទុំរស់ទាំងអស់សង្ឃឹមចំពោះអំណាចក្នុងសង្គមពេលនោះផ្ដាច់ការពេក។ ចំណែកលក្ខណៈខុសគ្នាទាក់ទងការសម្លាប់ខ្លួន គឺនាងទាវស្ម័គ្រស្លាប់តាមប្ដីជាទីស្រឡាញ់គឺទុំ។ ឯនាងនោសម្លាប់ខ្លួនដោយបាត់មនុស្សជាទីស្រឡាញ់អស់គឺទុំ និងទាវ។

បញ្ចប់សេចក្ដីមកយើងអាចសន្និដ្ឋានលើទស្សនៈប្រធានដែលកំណត់ឱ្យប្រៀបធៀបបញ្ហាអត្តឃាតរបស់តួអង្គនាងទាវនិងនោ គឺន័យម្យ៉ាងម្នាក់ ព្រោះជាការដោះស្រាយទៅតាមស្ថានភាពចំពោះមុខ។ តែទោះជាយ៉ាងនេះក្ដីរាល់ដំណោះស្រាយបញ្ហានីមួយៗចាំបាច់គួរផ្អែកលើអហិង្សាស្របតាមច្បាប់កំណត់នោះទើបជៀសផុតពីសោកនាដកម្មឬសេចក្ដីសោកស្ដាយទៅថ្ងៃមុខ។

**ប្រធានទី២:** ចូរអ្នកធ្វើការប្រៀបធៀបតួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរ និងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ខ្មែរ។ តើតួអង្គទាំងនេះមានលក្ខណៈដូចនិងលក្ខណៈខុសគ្នាត្រង់ចំណុចណាខ្លះ?

## គម្រោងតែង

### ក- ផ្ដើមសេចក្ដី

- លំនាំបញ្ហា
- បង្ហាញបញ្ហា (បង្ហាញប្រធាន)
- ចំណោទបញ្ហា។

### ខ- តួសេចក្ដី

- ឃ្លាភ្ជាប់
- ពន្យល់ពាក្យ
- ពន្យលន័យ
- បំណកស្រាយ

**ក- បង្ហាញពីលក្ខណៈដូចគ្នានៃតួអង្គទាំងពីរ៖**

- **គំនិតសំខាន់ និងឧទាហរណ៍៖**
  - ✓ កើតក្នុងខត្តិយៈត្រកូល
  - ✓ មានចំណេះដឹងខ្ពង់ខ្ពស់
  - ✓ ជាអ្នកជួយស្វែងរកសេចក្ដីសុខជូនសង្គមមនុស្ស
  - ✓ ជាស្នេហាបរិសុទ្ធ ម្ដាយទុកឪពុកដាក់។

**ខ- បង្ហាញលក្ខណៈខុសគ្នានៃតួអង្គទាំងពីរ៖**

- **គំនិតសំខាន់ និងឧទាហរណ៍៖**

  **តួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរ៖**
  - ✓ ជាអ្នកកសាងសន្សំនូវទានបារមី ព្រះមានចិត្តធ្វើទាន តាំងពីនៅក្នុងផ្ទៃព្រះមាតា
  - ✓ ប្រសូតមកហើយនៅតែមានចិត្តបរិច្ចាគធនធានដោយឥតមានចិត្តប្រែប្រួល
  - ✓ ការធ្វើទានដោយគ្មានការរើសអើង
  - ✓ នៅព្រះអង្គមានកំហឹងនឹងជូជកព្រាហ្មណ៍ វាគ្រាន់តែមាននៅក្នុងចិត្តតែប៉ុណ្ណោះ ពុំបានលេចចេញជារូបរាងនោះឡើយ
  - ✓ មានចិត្តចង់ជួយមនុស្សជាតិឱ្យរួចផុតពីរណ្ដៅនៃទុក្ខ។

  **តួអង្គអាទិទេពនៃតួអង្គព្រះរាម៖**
  - ✓ ព្រះរាមកម្ចាត់កាកនាសូរ ព្រះរាមផ្ចាញ់រាមបរមសូរ
  - ✓ ព្រះរាមបាញ់សម្លាប់ពាលី ហើយយកនាងតារាទេពីមកឱ្យសុគ្រីពវិញ
  - ✓ ព្រះរាមស្គាល់ដើមត្នោតដែលដុះដំណាលគ្នានឹងកំណាកំណើតផែនដី
  - ✓ លក្ខណៈអាទិទេពរបស់ព្រះរាមមានការប្រែប្រួលជាពិសេសពីខ្សែទីបួនដល់ខ្សែទីដប់ ព្រះរាមមានលក្ខណៈជាមនុស្សវិញ ព្រោះពេលនេះព្រះរាមជួបនូវវិបត្តិដូចជាចាញ់កល

យក្ស ហើយព្រះរាមយំសោយសោក...។ លុះមកដល់ខ្សែទីចិតសិបប្រាំដល់ខ្សែទីប៉ែតសិប សូម្បីតែកូនខ្លួនឯងព្រះរាមក៏ពុំស្គាល់ផង

- ✓ ព្រះរាមជាអវតារនៃព្រះវិស្ណុ ចុះមកជួយស្វែងរកយុត្តិធម៌ជូនសង្គមមនុស្សដូចជា...។

**គ- សរុបរួម** : រួមសេចក្តីមកតួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរនិងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍តាមរយៈដំណើររឿងនិងសកម្មភាពរបស់តួអង្គមិនដូចគ្នាទាំងអស់ទេ។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន**: តាមការប្រៀបធៀបរួចមកឱ្យឃើញថា លក្ខណៈនៃតួអង្គពោធិសត្វក្នុងរឿងព្រះវេស្សន្តរ និងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ខ្មែរ។ សកម្មភាពនៃតួអង្គព្រះវេស្សន្តរមានលក្ខណៈល្អប្រសើរ ព្រោះព្រះអង្គពុំមានព្រះទ័យប្រែប្រួលចិត្តតាំងពីដំបូងនៃជីវិត ហើយនឹងទីបំផុតទទួលបានលទ្ធផលធំធេងសម្រាប់ជីវិត។
- **មតិផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមជាសិស្សានុសិស្ស ត្រូវខិតខំសិក្សារៀនសូត្រ ដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅពីបុគ្គលិកលក្ខណៈនៃតួអង្គមនុស្ស សត្វ វត្ថុ ក្នុងបំណងពន្លេចឱ្យឃើញតម្លៃណាដែលគួរយកមកធ្វើជាបទពិសោធសម្រាប់ជីវិតរស់នៅតទៅអនាគត។

## សេចក្តីអធិប្បាយ

មនុស្សដែលរស់នៅក្នុងលោកយើងនេះមានចរិតលក្ខណៈផ្សេងៗគ្នាទៅតាមបែបបទនៃក្រុមគ្រួសារឬបរិយាកាសសង្គមជាដើម។ សភាពប្លែកគ្នាអាចបណ្តាលមកពីឧបនិស្ស័យតាំងពីកំណើតឬក៏មជ្ឈដ្ឋានដែលនៅជុំវិញខ្លួនឬអាចបណ្តាលមកពីការប្រកាន់នូវគោលនិយមណាមួយជាកំណត់។ ទាក់ទងនឹងសភាពមិនដូចគ្នានេះហើយ ទើបមានសំណេរមួយបានបង្គាប់បញ្ជាឱ្យធ្វើការប្រៀបធៀបពីតួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរ និងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ។

តើតួអង្គទាំងពីរនេះ មានលក្ខណៈដូចគ្នា និងខុសគ្នាត្រង់ចំណុចណាខ្លះ?

ដើម្បីជាជំនួយដល់ការប្រៀបធៀបតួអង្គទាំងពីរខាងលើជាដំបូងយើងគួរស្វែងយល់នូវពាក្យគន្លឹះមួយចំនួន។ ក្នុងចំណោមពាក្យទាំងនោះមាន តួអង្គព្រះពោធិសត្វគឺជាអ្នកដែលមានការលះបង់ខ្ពស់ដើម្បីទទួលបាននូវការត្រាស់ដឹងរួចចម្លងសត្វលោកឱ្យរួចផុតពីរណ្តៅនៃទុក្ខ។ ឯលក្ខណៈអាទិទេពវិញ សំដៅទៅលើតួអង្គដែលមានបុគ្គលិកលក្ខណៈពិសេសអស្ចារ្យ។ ស្របតាមន័យរបស់ពាក្យខាងលើនេះ បម្រាប់ប្រធានចង់បង្ហាញថា តួអង្គព្រះវេស្សន្តរដែលជាព្រះពោធិសត្វ ទ្រង់តែងធ្វើការលះបង់ខ្ពស់ ដើម្បីបុព្វហេតុ មនុស្សជាតិ។ព្រះរាមក្នុងរឿងរាមកេរ្តិ៍ក៏ជាតួអង្គមានលក្ខណៈអច្ឆរិយៈប្លែកម្យ៉ាងគួរឱ្យកត់សម្គាល់ផងដែរ។

តាមរយៈការសិក្សាទៅលើដំណើររឿងព្រះវេស្សន្តរនិងរឿងរាមកេរ្តិ៍ខ្មែរនាំឱ្យយើងមើលឃើញពីចំណុចដូចគ្នាមួយចំនួននៃតួអង្គទាំងពីរស្ថិតនៅត្រង់កើតក្នុងខត្តិយៈ[25] ត្រកូល។បានសេចក្តីថា ព្រះវេស្សន្តរជារាជបុត្ររបស់ព្រះបាទស្រីសញ្ជ័យ ឯព្រះរាមជារាជបុត្រព្រះបាទទសរថ។ ពេលធំដឹងក្តីល្មមវ័យសិក្សាទាំងព្រះវេស្សន្តរនិងព្រះរាមតែងស្វះស្វែងរកចំណេះវិជ្ជាក្នុងគោលបំណងជួយ

[25] ខត្តិយៈ ខាត់-តិ-យៈ បា. ( ន. ) មើលពាក្យ ក្សត្រ និង ក្សត្រិយ៍ ។

ស្រោចស្រង់ជីវិតមនុស្សឱ្យរួចផុតពីរណ្ដៅនៃទុក្ខមានអវិជ្ជា និងតណ្ហា។ ដោយឡែកព្រះរាមដែលជាអវតារនៃព្រះវិស្ណុចុះមកលើភពផែនដីក៏បានបំពេញតួនាទីមួយដែរនោះ គឺកម្ចាត់សភាវៈអាក្រក់ឱ្យពីសង្គមមនុស្ស។ ចំពោះបញ្ហាស្នេហាវិញព្រះវេស្សន្តរបានរៀបអភិសេកជាមួយនាងមទ្រីតាមប្រពៃណីទំនៀមទម្លាប់ឬអាចនិយាយបានថាម្ដាយទុកឪពុកដាក់។ ឯព្រះរាមនៅពេលដែលទទួលជ័យជម្នះក្នុងការលើកធ្នូរសិល្ប៍ដែលរៀបចំដោយព្រះបាទជនករួចមកព្រះអង្គក៏បានគោរពទៅតាមប្រពៃណីទំនៀមទម្លាប់ក្នុងពិធីមង្គលការដែរ។

សរុបមក តាមភស្តុតាងខាងលើនេះហើយ ដែលជាចំណុចបញ្ជាក់ថា ជាលក្ខណៈដូចគ្នារវាងតួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរ និងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ។

ថ្វីត្បិតតែមានលក្ខណៈដូចគ្នាក៏តួអង្គទាំងពីរមានលក្ខណៈខុសគ្នាមួយចំនួនដែរ។ចំពោះលក្ខណៈរបស់តួអង្គព្រះពោធិសត្វក្នុងរឿងវេស្សន្តរយើងឃើញតួអង្គព្រះវេស្សន្តរបានកសាងសន្សំនូវទានបារមីតាំងពីចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងផុស្សតីមកម្លេះ។ ប្រសូតមកបានព្រះជន្មប្រាំព្រះវស្សា ព្រះអង្គបានប្រទាននូវគ្រឿងប្រដាប់កុមារលេង មានតម្លៃមួយសែនគហបណៈដល់មេនំគម្រប់ប្រាំបួនផង។ មកដល់ព្រះជន្មប្រាំបីព្រះវស្សាទ្រង់បានប្រាថ្នា ដាក់ទានខ្លួនប្រាណមានសាច់ ឈាម ថ្លើម ប្រមាត់ ដល់ស្មូមទាំងឡាយដោយគ្មានការរើសអើងឡើយ។ សកម្មភាពនៃការដាក់ទានរបស់ព្រះវេស្សន្តរ ពុំមានព្រះទ័យប្រែប្រួលឡើយ។ ចំពោះការធ្វើបុត្តបរិច្ចាគវិញ ពេលឃើញជូជកព្រាហ្មណ៍វាយដំរាជបុត្រនៅចំពោះព្រះភក្ត្រទ្រង់ក៏ក្រេវក្រោធ គឺគ្រាន់តែមានក្នុងចិត្តប៉ុណ្ណោះ ពុំមានសម្ដែងចេញជារូបរាងមកខាងក្រៅឡើយ។

ចំពោះលក្ខណៈអាទិទេពរបស់ព្រះរាមគ្រង់ព្រះរាមជាអវតារចុះមកក្នុងឋានមនុស្សលោកដើម្បីជួយស្វែងរកយុត្តិធម៌ជូនសង្គមមនុស្សឱ្យរួចផុតពីការរាតត្បាតនៃពួករាក្សៈដូចជាព្រះរាមប្រហារកាកនាសូរចូលមកចឹកបំផ្លាញហោមពិធីដែលរៀបចំឡើងដោយព្រះបាទជនក។ ក្នុងករណីមានវិបត្តិទំនាស់ក្នុងនគរ ព្រះអង្គបានព្យាយាមដោះស្រាយដោយអត់ធ្មត់គោរពទៅតាមពាក្យសត្យៈជាគោល ដែលព្រះបិតាបានសន្យាជាមួយនាងកៃកេសីដែលមានបំណងចង់បានរាជសម្បត្តិទៅឱ្យសុត្រុតកូនបង្កើតរបស់នាង។ នៅពេលពាលីនិងសុគ្រីពមានទំនាស់នឹងជាមួយបងប្អូនរបស់ខ្លួនព្រះរាមបានបាញ់សម្លាប់ពាលីបានសម្រេចហើយនឹងយកនាងតារាទេពីមកឱ្យសុគ្រីពវិញ។ មួយវិញទៀតព្រះរាមបានស្គាល់ដើមត្នោតដែលដុះដំណាំលគ្នានឹងកំណើតផែនដីមានអាយុកាលតាំងពីយូរយារណាស់មកហើយ។ លក្ខណៈអាទិទេពរបស់ព្រះរាមមិនស្ថិតស្ថេរពោល គឺមានការប្រែប្រួល។ នៅក្នុងរឿងរាមកេរ្តិ៍ខ្មែរពីខ្សែបួនដល់ខ្សែដប់អាទិទេពរបស់ព្រះរាមមានការធ្លាក់ចុះ ព្រោះសកម្មភាពទាំងនោះវាបញ្ជាក់ពីលក្ខណៈមនុស្សនិយមទៅវិញ។ តួយ៉ាងដូចជាព្រះរាម ចាញ់កលយក្សក្រុងរាពណ៍ចាប់នាងសីតាជាហេតុធ្វើឱ្យព្រះរាមយំសោក ហើយពេលខ្លះគំរាមគេឯងដើម្បីសុំឱ្យគេជួយខ្លួន។ មកដល់ខ្សែទីចិតសិបប្រាំដល់ខ្សែទីប៉ែតសិបទេវភាពរបស់ព្រះរាមកាន់តែធ្លាក់ចុះបន្តរទៅទៀត រហូតដល់កូនខ្លួនឯងក៏មិនស្គាល់ទៀតផង។

សរុបមកទាំងនេះ ជាលក្ខណៈខុសគ្នារវាងតួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរ និងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ។

រួមសេចក្ដីមក ទោះបីជាលក្ខណៈសកម្មភពតួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរនិងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមក្នុងរឿងរាមកេរ្ដិ៍ខ្មែរមានលក្ខណៈមិនដូចគ្នាក៏ពិតមែនតែតួអង្គទាំងពីរនេះសុទ្ធតែមានលក្ខណៈគួរឱ្យកត់សម្គាល់ដូចគ្នាឧត្ដមភាពក្នុងការបម្រើប្រយោជន៍មនុស្សដូចៗគ្នា។

ឆ្លងតាមការប្រៀបធៀបរួចមកនេះ បានជំរុញឱ្យយើងមើលឃើញកាន់តែច្បាស់ពីលក្ខណៈនៃតួអង្គព្រះពោធិសត្វក្នុងរឿងវេស្សន្តរ និងលក្ខណៈអាទិទេពនៃតួអង្គព្រះរាមក្នុងរឿងរាមកេរ្ដិ៍ខ្មែរ។ សកម្មភាពនៃតួអង្គព្រះវេស្សន្តរមានលក្ខណៈល្អប្រសើរ ព្រោះព្រះអង្គពុំមានព្រះទ័យប្រែប្រួលចិត្តតាំងពីដើមដំបូងនៃជីវិត ហើយនឹងទីបំផុតទទួលបានលទ្ធផលធំធេងសម្រាប់ជីវិត។ ដូច្នេះក្នុងនាមជាសិស្សានុសិស្សត្រូវខិតខំសិក្សារៀនសូត្រ ដើម្បីប្រមូលចំណេះដឹងក្នុងការវិភាគបុគ្គលិកលក្ខណៈនៃតួអង្គមនុស្ស សត្វ វត្ថុ ដើម្បីធ្វើពន្លេចឱ្យឃើញតម្លៃណាមួយយកមកធ្វើជាបទពិសោធសម្រាប់ជីវិតរស់នៅរៀងតទៅ។

## សេចក្ដីអធិប្បាយរបស់សិស្ស
## ដកស្រង់ចេញពីការប្រឡងថ្នាក់ជាតិ

---

**ប្រធានទី២:** ប្រធានៈ មានទស្សនៈមួយពោលថា «ការអប់រំ គឺជាសិទ្ធិសេរីភាពដែលបើកផ្លូវឱ្យមនុស្សសម្រេចបានភាពថ្លៃថ្នូរក្នុងជីវិត»។

ចូរអ្នកបកស្រាយទស្សនៈនេះដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

---

## សេចក្ដីអធិប្បាយ

នៅក្នុងជីវិតរស់នៅរបស់មនុស្សនាយុគសម័យបច្ចុប្បន្នឃើញថា តម្រូវការនៃការចង់មានចំណេះដឹងចង់មានចំណេះធ្វើ ហើយកត្តាទាំងអស់គឺផ្ដើមចេញពីការងារដែលយើងចង់បានការអប់រំនេះ មនុស្សម្នាក់ៗតែងមានសិទ្ធិគ្រប់គ្រាន់ក្នុងការអប់រំដើម្បីអភិវឌ្ឍខ្លួនឯងមានគោលដៅ មានចំណេះវិជ្ជា ដែលជាផ្លូវមួយសម្រាប់ចម្លងយើងឱ្យបានសម្រេចជោគជ័យលើផ្លូវមួយនេះធ្វើឱ្យជីវិតរបស់យើងរស់នៅប្រកបដោយភាពថ្លៃថ្នូរក្នុងជីវិត។ យ៉ាងនេះហើយបានជាមានឃ្លាមួយពោលថា «ការអប់រំគឺជាសិទ្ធិសេរីភាពដែលបើកផ្លូវឱ្យមនុស្សសម្រេចបានភាពថ្លៃថ្នូរក្នុងជីវិត»។

តើទស្សនៈប្រធានខាងលើនេះ អត្ថន័យយ៉ាងណាខ្លះ?

ដើម្បីជាជំហានឈានដល់ការបកស្រាយប្រធានខាងលើឱ្យមានន័យគ្រប់គ្រាន់នឹងទូលំទូលាយនោះគប្បីយើងសិក្សាស្វែងយល់នូវពាក្យគន្លឹះជាមុនសិន។ ពាក្យ«ការអប់រំ» គឺជាការបណ្ដុះបណ្ដាល ការបង្ហាត់បង្រៀនប្រៀនប្រដៅ។ «សិទ្ធិសេរីភាព»គឺ ភាពដែលយើងអាចធ្វើអ្វីបានផ្លូវគឺជាវិថីដងផ្លូវ។ «សម្រេច» គឺការស្រេចបាននូវអ្វីៗ «ថ្លៃថ្នូរ» គឺដែលខ្ពង់ខ្ពស់ ថ្កើងថ្កាន ថ្កុំថ្កើង។ តាមរយៈការបកស្រាយរបស់ពាក្យគន្លឹះរួចមក គំនិតប្រធានខាងលើចង់មានអត្ថន័យថា ការបណ្ដុះបណ្ដាលការអប់រំគឺជាអ្វីៗដែរយើងមានសិទ្ធិក្នុងការទទួលយកវាដើម្បីដើរឆ្ពោះទៅលើវិថីមួយដែរអាចឱ្យយើងសម្រេចបានជោគជ័យសម្រេចបានគ្រប់ភារកិច្ចទាំងអស់ដើម្បីអនាគតរបស់យើងរស់នៅប្រកបដោយភាពខ្ពង់ខ្ពស់ ឧត្តុង្គឧត្ដមថ្កុំថ្កើង។

មនុស្សម្នាក់ៗនៅលើពិភពលោកយើងនេះតែងរស់នៅក្នុងភាពមួយដែលហៅថាភាពស៊ីវិល័យទាន់សម័យនិងដើរឆ្ពោះឱ្យទាន់ផ្នែកបច្ចេកវិទ្យានាយុគសម័យ។ បើយើងក្រឡេកទៅលើចក្ខុវិស័យខាងអប់រំយើងឃើញថាប្រព័ន្ធទីផ្សារនៃការអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺមានសម្ទុះជាអន្តន។

បើធៀបទៅនឹងសម័យកាលបុរាណ ឬសម័យកាលផ្សេងៗរបស់ជាតិខ្មែរ។ ដូចជាសម័យកម្ពុជាប្រជាធិបតេយ្យគេឃើញថា សម្ទុះនៃវិស័យអប់រំនៅមានភាពរអាក់រអួល កត្តានេះមកពីការបណ្តុះបណ្តាលវិស័យអប់រំនៅសម័យនោះគ្មានការរីកចម្រើននៅឡើយ ហើយក៏មិនទាន់ស៊ីជម្រៅផងដែរ។ ដោយសារតែមេដឹកនាំខ្មែរនៅសម័យនោះពុំសូវឱ្យតម្លៃឬបង្កើនវិស័យអប់រំនោះទេ។ ដោយសារតែអសមត្ថភាព គ្មានចំណេះដឹង ការមិនយកចំណេះទុកដាក់ចំពោះបញ្ហាការអប់រំនេះហើយទើបធ្វើឱ្យប្រជាពលរដ្ឋទាំងអស់រស់នៅពុំមានសិទ្ធិសេរីភាពក្នុងការទទួលបានការនូវការបណ្តុះបណ្តាលការបង្ហាត់បង្រៀនឬការបើកសិទ្ធិ បើកផ្លូវច្បាប់ឱ្យអ្នកទាំងនោះបានទទួលការអប់រំនោះទេ។ ផ្ទុយទៅវិញ  បើយើងក្រឡេកចក្ខុរបស់យើងឱ្យងាកបែរមករកសម័យកម្ពុជាព្រះរាជាណាចក្រកម្ពុជាទីពីរនេះរហូតមកដល់សម័យបច្ចុប្បន្ន ដែលមានប្រមុខរដ្ឋាភិបាលរបស់យើងតែងតែលើកតម្កើងនិងឱ្យតម្លៃដល់សក្តានុពលដ៏អង់អាចនូវភាពអស្ចារ្យរបស់ប្រទេសខ្មែរ។ ដោយសារតែមានមេដឹកនាំដ៏ល្អវៃឆ្លាត ហើយមានសក្តានុភាពដ៏អង់អាចក្នុងការអភិវឌ្ឍកសាងជាតិមាតុភូមិនៅសម័យកម្ពុជាព្រះរាជាណាចក្រកម្ពុជាអច្ឆរិយៈ រីកចម្រើនជាលំដាប់។ មានន័យថា វិស័យអប់រំមានសម្ទុះរីកចម្រើនលូតលាស់ គឺមិនចាញ់បណ្តាប្រទេសលោកខាងលិចឡើយ។ វិស័យអប់រំនៅកម្ពុជាបច្ចុប្បន្ននេះកំពុងវាយលុកពាសពេញផ្ទៃប្រទេស។ ដោយសារវឌ្ឍនភាពក្នុងវិស័យនេះបានកើនឡើងនូវធនធានមនុស្សកាន់តែឆាប់រហ័ស។ ដូច្នេះហើយទើបរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ទៅលើវិស័យអប់រំនេះយ៉ាងខ្លាំងដោយសារតម្រូវការទីផ្សារប្រកួតប្រជែង និងតម្រូវការអប់រំរបស់មនុស្សនាយុគសម័យនេះតែងតែងដង្ហោយហៅគ្នាចូលរួមក្នុងវិស័យនេះយ៉ាងខ្លាំងក្លាបំផុត។ មនុស្សសម័យឥឡូវកំពុងឈានទៅរកការអភិវឌ្ឍបន្តិចម្តងៗរហូតដល់តម្រូវការវិស័យអប់រំជះឥទ្ធិពលដល់ពួកគេ ដើម្បីធ្វើការសិក្សាស្វែងយល់ការចង់មានចំណេះដឹងតម្រូវការចង់មានការងារធ្វើជាដើម។ ដោយហេតុដូចខាងលើនេះហើយទើបរដ្ឋាភិបាលបច្ចុប្បន្នកំពុងតែយកចិត្តទុកដាក់យ៉ាងស៊ីជម្រៅទៅលើវិស័យនេះដើម្បីបំពេញតម្រូវការរបស់ពួកគេ។ ដោយសារតែមានវត្តមាននៃរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់នឹងការកសាងវិស័យអប់រំនេះទើបបច្ចុប្បន្ននេះឃើញថា ប្រទេសរបស់យើងពេលនេះកំពុងតែមមាញឹកនឹងបំពេញកិច្ចការភារកិច្ចនេះយ៉ាងញាប់ដៃញាប់ជើងជាបន្តបន្ទាប់។ ក្នុងនោះយើងឃើញមានអគារសិក្សា គ្រឹះស្ថានឧត្តមសិក្សាសាលារៀន បណ្ណាល័យកន្លែងបណ្តុះបណ្តាលវិជ្ជាជីវៈគឺច្រើនស្អេកស្កះយ៉ាងច្រើននៅពាសពេញផ្ទៃប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ។ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់នេះហើយ ព្រមទាំងបន្ថែមនៅហេដ្ឋារចនាសម្ព័ន្ធយ៉ាងស្រស់ស្អាតដល់បណ្តាមហាជនឱ្យទាក់ចិត្តទាក់អារម្មណ៍ដើម្បីឱ្យពួកគេងាកមកចាប់អារម្មណ៍នូវសមិទ្ធផលឬការកសាងនូវស្នាដៃដ៏មានតម្លៃទាំងអស់នោះ។ ពិសេសបន្ថែមពីលើការស្ថាបនា ក៏ដូចជាការកសាងនូវវឌ្ឍនភាពហេដ្ឋារចនាសម្ព័ន្ធថែមទាំងជាកន្លែងបណ្តុះបណ្តាលអប់រំមនុស្សទាំងអស់ដែលសុទ្ធតែបានទទួលនូវការអប់រំដោយមានសិទ្ធិគ្រប់គ្រាន់ក្នុងការចូលរួមប្រឡូកក្នុងវិស័យអប់រំនេះ។ ការអប់រំនេះ វាបានផ្តល់នូវគុណភាពយ៉ាងល្អអស្ចារ្យដល់មនុស្សគ្រប់រូប ដូចជាផ្តល់នូវចំណេះដឹងចំណេះធ្វើផ្តល់បទពិសោធមេរៀនគ្រប់បែបបទការអភិវឌ្ឍខ្លួនការទទួលស្គាល់ខ្លួនឯងការបណ្តុះបណ្តាលធនធានមនុស្ស។ ការធ្វើកិច្ចតែងការដើម្បីស្រង់យកនូវគំនិតល្អ មេរៀនបទពិសោធ ការធ្វើអន្តរកម្មលើវិស័យធនធានមនុស្ស ដើម្បីឱ្យពួកគេបានឃើញបានស្គាល់បានដឹង បានឮបានទទួលការយកចិត្តទុកដាក់ស្តាប់បាននិងទទួលបាននូវអ្វីដែលពួកមិនបានជួបប្រទះកន្លងមកឱ្យពួកគេសិក្សាស្វែងយល់រាល់មេរៀនទាំងអស់ក៏ដូចជាទ្រឹស្តីបទពិសោធ ដែលពួកគេមិនធ្លាប់បានទទួលនៅក្នុងឆាកជីវិតរបស់ពួកគេ

នោះ។ ដោយហេតុតែជះឥទ្ធិពលដល់មនុស្សយ៉ាងខ្លាំងបែបនេះហើយ ទើបរដ្ឋាភិបាលកំពុងតែបើកឱ្យមានចលនាលើវិស័យអប់រំនេះយ៉ាងខ្លាំងក្លាដល់ពួកមនុស្សគ្រប់គ្នា។ ការអប់រំវាផ្ដល់អត្ថប្រយោជន៍ក៏ដូចជាគំនិតការយល់ឃើញពីភាពប្រាកដ វិសាលភាពនៃវិស័យអប់រំ ហើយដូចជាពួកនិស្សិត បញ្ញាវន្ត បណ្ឌិតផ្សេងៗទៀតកំពុងតែបង្កភាពចលាចលដល់មនុស្សគ្រប់គ្នាពីការស្ថាបនាខ្លួនក្នុងការអភិវឌ្ឍដើម្បីឱ្យទទួលបានភាពជោគជ័យក្នុងឆាកជីវិតរបស់ពួកគេពោរពេញទៅដោយឧត្តមភាព កិត្យានុភាពដ៏ខ្លាំងក្លានិងបង្ហាញឱ្យឃើញពីជីវិតថ្លៃថ្នូរ ភាពរីកចម្រើនដែលពួកគេបានទទួលការអប់រំនៅក្នុងសាលាក្ដីឬនៅទីកន្លែងផ្សេងៗក្ដី។ ដោយសារតែភាពមើលឃើញត្រូវការទទួលបានចំណេះដឹងជាសាកលយ៉ាងច្រើននិងការតម្រង់ទិសដៅបានត្រឹមត្រូវច្បាស់លាស់។ ការដើរទៅលើភាពជោគជ័យក្នុងវិថីមួយដ៏សែនឆ្ងាយដើម្បីឆ្ពោះទៅរកគោលដៅដ៏អស្ចារ្យគោលដៅដ៏មានន័យនោះគប្បីយើងត្រូវនៃការអភិវឌ្ឍច្បាស់លាស់។ ការឆ្ពោះទៅរកភាពជោគជ័យក្នុងវិថីមួយដ៏សែនឆ្ងាយដើម្បីឆ្ពោះទៅរកគោលដៅដ៏អស្ចារ្យគោលដៅដ៏មានន័យនោះគប្បីយើងត្រូវឈានជើងចេញពីទីកន្លែងចាប់ផ្ដើមពីចំណុចតូចមួយដោយការឈានជើងឡើងពីក្នុងវិស័យអប់រំ។ ការអប់រំត្រូវផ្ដល់ឱ្យមនុស្សអាចឈរឡើងក្នុងភាពមោទនភាពឬអង់អាចដើម្បីឱ្យមានចំណេះដឹងទទួលបាននូវរបកគំហើញថ្មីៗបច្ចេកវិទ្យានិងតម្រុយជាច្រើនទៀតដែលផ្ដល់ឱ្យពួកគេ។ បន្ថែមពីនេះបើយើងក្រឡេកមើលប្រទេសដែលគេមានវិស័យសេដ្ឋកិច្ចជឿនលឿនមានការអភិវឌ្ឍលើវិស័យអប់រំយ៉ាងខ្លាំងក្លាដើម្បីបណ្ដុះបណ្ដាលធនធានមនុស្សរបស់ពួកគេឱ្យមានការរីកចម្រើន ឱ្យមានសក្ដានុពលដល់ខ្លាំងក្លា ទើបគេផ្ដើមចេញពីការពង្រឹងពង្រីកវិសាលភាពនៃការអប់រំដើម្បីឱ្យប្រជាជនរបស់ពួកគេមានចំណេះដឹងគ្រប់គ្រាន់និងធនធានមនុស្សរបស់ពួកគេ សម្បូរទៅដោយអ្នកមានចំណេះដឹងពិតប្រាកដ។ បើកាលណាប្រទេសមួយសម្បូរប្រជាជនដែលមានចំណេះដឹងហើយនោះ សម្ទុះនៃការអភិវឌ្ឍនិរន្តរភាពវិសាលភាពនៃផ្ទៃប្រទេសក៏មានការរីកចម្រើនជាលំដាប់ផងដែរ។ ប្រទេសមួយសម្បូរទៅដោយធនធានមនុស្សមានចំណេះដឹងនោះការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌រីកចម្រើនលូតលាស់ជារៀងរហូត។ ប្រទេសបែបនេះនឹងត្រូវបានគេមើលឃើញពីសក្ដានុពលដ៏អស្ចារ្យ ហើយមានការលើកតម្កើងសង្គមមានមោទនភាព មានកិត្យានុភាពដូចបណ្ដាប្រទេសលើពិភពលោកយើងនេះ។ បើសិនជាសង្គមមួយមិនមានធនធានមនុស្សគ្រប់គ្រាន់មិនមានចំណេះដឹងពិតប្រាកដប្រទេសនោះប្រាកដជាធ្លាក់ទៅក្រោមបាតដីឬការគ្មានរីកចម្រើនការអភិវឌ្ឍលើវិស័យនោះទេ។ ដោយសារតែពួកគេខ្វះនូវធនធានឬខ្វះការយកចិត្តទុកដាក់ទៅលើវិស័យអប់រំជាកត្តាចម្បង ទើបធ្វើឱ្យប្រទេសគ្មានការអភិវឌ្ឍឬការស្ថាបនា ការសាងសង់ កិច្ចសហប្រតិបត្តិការ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ក៏ពុំសូវមានភាពរីចម្រើនលូតលាស់។ ប្រទេសនឹងជួបនូវបញ្ហាវិបត្តិផ្ទៃក្នុងផ្សេងៗជាច្រើនទៀត។ នេះការបាត់បង់និងគ្មានភាពរីកចម្រើនខាងវិស័យអប់រំទេឬខ្វះការយកចិត្តទុកដាក់ទៅលើវិស័យអប់រំជាកត្តាចម្បង ទើបធ្វើឱ្យប្រទេសគ្មានការអភិវឌ្ឍ ការស្ថាបនា ការកសាងហេដ្ឋារចនាសម្ព័ន្ធ ក៏ពុំសូវមានការរីកចម្រើនហើយប្រទេសនឹងជួបប្រទះបញ្ហាវិបត្តិផ្ទៃក្នុងផ្សេងៗជាច្រើនទៀត។ ដូច្នេះការអប់រំ មានសារៈសំខាន់សម្រាប់យើងទាំងអស់គ្នាក្នុងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ តម្រង់ទិសដៅឱ្យត្រឹមត្រូវ ដើម្បីឆ្ពោះទៅរកភាពជោគជ័យ។ ហេតុនេះហើយទើបមនុស្សគ្រប់គ្នានៅលើពិភពលោកយើងនេះ តែងតែយកចិត្តទុកដាក់លើសក្ដានុភាពទៅលើវិស័យអប់រំយើងនេះ ព្រោះថាបើមានការរីកចម្រើនលើវិស័យនេះហើយ ប្រទេសជាតិក៏មានការរីកចម្រើនដែរ។ បើយើងក្រឡេកទៅលើអក្សរសិល្ប៍វិញនឹងឃើញថា នៅក្នុងរឿងកុលាបប៉ៃលិន តួអង្គចៅចិត្រ គឺជាបុគ្គលដែលឆ្នើម គាត់តែងតែ

ខិតខំហាត់រៀនសូត្រខិតខំប្រឹងប្រែងយ៉ាងខ្លាំងរហូតគាត់ក្លាយជាមនុស្សម្នាក់ ដែលមានចំណេះដឹងជ្រៅជ្រះនិងទូលំទូលាយដែរបង្កឱ្យមានភាពជោគជ័យនៅក្នុងឆាកជីវិតរបស់គាត់។ ក្នុងរឿងទុំទាវយើងឃើញថាតួអង្គទុំគឺជាព្រះសង្ឃមួយអង្គដែលគាត់រាល់ថ្ងៃតែងតែខិតខំប្រឹងប្រែងរៀនគម្ពីរបាលីផ្សេងៗរហូតគាត់ក្លាយទៅជាព្រះសង្ឃមួយអង្គដែលមានភាពល្បីល្បាញក្នុងការរៀនឧស្សាហ៍ព្យាយាមនិងខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំង នៅពេលដែលទុំបានបួសរៀនជាមួយគ្រូឧបជ្ឈាយ៍ទើបធ្វើឱ្យជីវិតទុំទទួលបានចំណេះដឹងទាំងផ្លូវលោកនិងផ្លូវធម៌។ លើសពីនេះទៅទៀតបើយើងងាកទៅរករឿងគូលីកំណែននឹងឃើញថា តួអង្គម៉ឹងជាគ្រូបង្រៀនដោយសារតែគាត់បានខិតខំប្រឹងប្រែងនឹងរការព្យាយាមតស៊ូរបស់គាត់រហូតក្លាយជាមន្ត្រីរាជការដ៏ឆ្នើម។ បើយើងក្រឡេកទៅមើលរឿងភូមិតិរិច្ឆានវិញ យើងឃើញថាពួកអ្នកបម្រើបាវាំងសុទ្ធតែធ្វើការល្អដោយសារតែការខិតខំរៀនសូត្ររបស់ពួកគេនូវភាសាផ្សេងៗ។ នៅក្នុងរឿងគ្រូពេទ្យជើងបួន កុម្ភកុមារគាត់ជាមនុស្សពិការតែគាត់ជាមានឆន្ទៈមោះមុតក្នុងការខិតខំរៀនសូត្រកសាងខ្លួនរហូតបានក្លាយទៅជាអ្នកមានចំណេះដឹងនឹងជាគ្រូពេទ្យដ៏ចំណានមួយរូបដោយសារតែភាពជោគជ័យរបស់គាត់។ បើយើងងាកមកមើលនៅក្នុងរឿងធនញ្ជ័យយើងឃើញថាធនញ្ជ័យជាអ្នកប្រាជ្ញ តែដោយសារគាត់កើតក្នុងត្រកូលក្រីក្រ ទើបបណ្តាលឱ្យគាត់មិនបានរៀនសូត្របានច្រើនឡើយ។ ដោយសារតែការតស៊ូរបស់គាត់ ទើបធ្វើឱ្យគាត់ទទួលបានជោគជ័យនិងទទួលនិងក្លាយជាអ្នកប្រាជ្ញល្បីល្បាញម្នាក់ក្នុងប្រទេស។ បើក្រឡេកមកមើលនៅក្នុងរឿងព្រះពុទ្ធវិញយើងឃើញថាតួអង្គព្រះពុទ្ធជាសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងព្រះអង្គកើតមក។ ដោយសារតែសារជាតិព្រះអង្គកើតពីកំណើតមកមានភាពឈ្លាសវៃស្រេចបន្ថែមពីការសិក្សាស្វែងយល់នឹងការព្យាយាមតស៊ូក្នុងការត្រាស់ដឹងផ្សេងទើប ធ្វើឱ្យព្រះអង្គក្លាយទៅជាព្រះអារហន្ត ដែលត្រាស់ដឹងដោយខ្លួនឯងបានរយៈពេលយ៉ាងយូរទើប ព្រះអង្គបានសម្រេចនូវការងារបំពេញជាទ័យទាននេះ ហើយដោយការដើរលើវិថីមួយដ៏សែនពិបាកមិនអាចបកស្រាយពណ៌នារៀបរាប់បានអំពីទុក្ខលំបាកវេទនាពីការតស៊ូឬព្យាយាមតតាំងរហូតមកដល់ពេលដែលព្រះអង្គទទួលបានជោគជ័យក្នុងការត្រាស់ដឹងក្លាយជាព្រះសម្មាសម្ពុទ្ធ ដែលជាមនុស្សមួយរូបក្នុងលោកមិនធ្លាប់មានឬមិនធ្លាប់ជួបប្រទះនោះឡើយ។ មានន័យថាព្រះអង្គទទួលបានភាពជោគជ័យដ៏អស្ចារ្យ ដែលជាអភូតហេតុដ៏អស្ចារ្យមួយក្នុងពិភពលោក ដោយសារតែការបំពេញទានបារមីឬជាការខិតខំប្រឹងប្រែងរៀនសូត្រនោះឯងទើបធ្វើឱ្យព្រះអង្គបានសម្រេចតាមសម្មាសម្ពុទ្ធ។លើសពីនេះទៅទៀត យើងមើលទៅលើរឿងព្រះវេស្សន្តរ  យើងឃើញថាការតាំងសីលការចាកចេញពីព្រះនគររបស់ព្រះអង្គ ដើម្បីស្វែងរកហាត់វិជ្ជាការនិងការបំពេញទានបារមីរបស់ព្រះអង្គទើបឱ្យព្រះអង្គទទួលជោគជ័យក្នុងការទៅតាំងសីលនៅទីព្រៃរហូតព្រះអង្គទទួលបានជោគជ័យក្នុងការបំពេញភារកិច្ចមួយនេះ។ ម៉្យាងទៀត បើយើងវិភាគអំពីតួអង្គព្រះរាមនិងព្រះលក្ស្មណ៍ យើងឃើញថា ការចាកចេញរបស់ទ្រង់ពីរាជវាំងដើម្បីស្វែងរករៀនសិល្ប៍សាស្ត្រក្នុងគោលបំណងឱ្យក្លាយទៅជាអ្នកខ្លាំងពូកែមានមហិទ្ធិឫទ្ធិខ្លាំងកៃ។ ព្រះរាមបានហាត់រៀនជាមួយព្រះលក្ស្មណ៍ដោយការបង្ហាត់បង្រៀនពីឥសីពិស្វាមិត្ររហូតព្រះរាមបានក្លាយទៅជាមនុស្សម្នាក់ដែលមានទេពកោសល្យនឹងមានមហិទ្ធិឫទ្ធិលើអស់មនុស្ស ព្រមទាំងទេវៈជាច្រើនទៀតផងដែរ។ នេះដោយសារតែការខិតខំប្រឹងប្រែងនិងតស៊ូរាល់ឧបសគ្គឬរាល់បញ្ហាទាំងអស់របស់ព្រះអង្គ ដើម្បីឱ្យក្លាយទៅជាមនុស្សដ៏អស្ចារ្យបានដោយជោគជ័យ។ ឯរឿងតេមិយវិញបានបង្ហាញពីការចាកចេញរបស់ព្រះអង្គពីនគរដោយការធ្វើពិការដើម្បីហាត់រៀននូវវិជ្ជាការរហូតព្រះអង្គបានបួសរៀនតាមគោលបំណងទ្រង់ផងដែរ។ នៅទីបំផុតបុគ្គលទាំងអស់សុទ្ធតែ

ទទួលការអប់រំនិងចេញបួសតាមព្រះតេមិយតរៀងទៅ។ ចំណែករឿងតេជោយ៉តបានបង្ហាញថាតួអង្គយ៉តជាមនុស្សមានចំណេះដឹងជ្រៅជ្រះ មានគំនិតវៃឆ្លាតក្នុងការគិតពិចារណារហូតគាត់ក្លាយទៅជាមេទ័ពដ៏ខ្លាំងពូកែម្នាក់ និងឆក់បានបេះដូងរបស់ជំទាវស្រែនដោយសារតែភាពឈ្លាសវៃរបស់គាត់។ នៅក្នុងរឿងគង់ហ៊ានវិញ ដោយសារតែគំនិតវៃឆ្លាតរបស់នាងជាប្រពន្ធទាំងពីរទើបធ្វើឱ្យពួកគេទទួលបានជោគជ័យ។

សរុបសេចក្ដីមកការអប់រំលើគ្រប់ធនធានមនុស្សគឺត្រូវតែទទួលបានសិទ្ធិសេរីភាពគ្រប់ៗគ្នា ទើបធ្វើឱ្យយើងទទួលភាពជោគជ័យក្នុងជីវិតនិងការកសាងអភិវឌ្ឍប្រទេសជាតិ។

ឆ្លងតាមការបកស្រាយគំនិតប្រធានខាងលើនេះ យើងឃើញថាទស្សនៈប្រធានមានអត្ថន័យល្អជ្រាលជ្រៅ ព្រោះបានឱ្យតម្លៃទៅលើការអភិវឌ្ឍវិស័យអប់រំដែលមានគោលដៅអភិវឌ្ឍធនធានមនុស្ស។ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សានិងជាអ្នកស្នងពីបុព្វបុរស យើងគប្បីស្វែងយល់និងសិក្សាឱ្យបានស៊ីជម្រៅដើម្បីពង្រឹងវិស័យអប់រំឱ្យមានការរីកចម្រើន ហើយជាតិរីកចម្រើនទៅមុខ ទើបធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍជឿនលឿនទៅមុខបានដូចប្រទេសដទៃ។

## ១០- លំនាំបង្រៀនតែងសេចក្ដី

### ១០.១- លក្ខណៈទូទៅនៃលំនាំបង្រៀនតែងសេចក្ដី

ការសិក្សាតែងសេចក្ដី គឺជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការរៀនភាសាខ្មែរ។ លំនាំបង្រៀនតែងសេចក្ដី គឺជាល្បិចបង្រៀនដែលគ្រូរៀបចំឡើងសម្រាប់ឱ្យសិស្សធ្វើសកម្មភាពផ្សេងៗ ដើម្បីចាប់យកខ្លឹមសារមេរៀនបានល្អប្រសើរ ហើយធានាថាសិស្សនឹងចេះសរសេរតែងសេចក្ដីបានល្អ។ លំនាំបង្រៀនតែងសេចក្ដីខុសពីវិធីសាស្ត្រនៃការសរសេរតែងសេចក្ដីត្រង់ថា លំនាំបង្រៀនគឺជាគរុកោសល្យ ជាវិធីឬល្បិចនៃការបង្រៀនតែងសេចក្ដី រីឯវិធីសាស្ត្រសរសេរតែងសេចក្ដីវិញ គឺជាក្បួនខ្នាតសម្រាប់យកមកអនុវត្តក្នុងការសរសេរតែងសេចក្ដី។ ចំណុចគន្លឹះក្នុងការសិក្សាតែងសេចក្ដីគឺធ្វើយ៉ាងណាឱ្យសិស្សចេះរៀបរាប់ ពណ៌នា និងចេះពន្យល់ វែកញែក ស្រាយបំភ្លឺ បកស្រាយឱ្យបានយល់ប្បាស់។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យទាំងឡាយគប្បីយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្សយ៉ាងណាធានាឱ្យបានថា សិស្សចេះសរសេរតែងសេចក្ដីបែបពណ៌នា ដោយចេះសរសេររៀបរាប់ ពណ៌នាឱ្យបានក្បោះក្បាយច្បាស់លាស់ដើម្បីឱ្យអ្នកអានហាក់ដូចជាមើលឃើញនឹងភ្នែកផ្ទាល់។ សិស្សចេះសរសេរតែងសេចក្ដីបែបអត្ថាធិប្បាយដោយចេះសរសេរបកស្រាយ ស្រាយបំភ្លឺ ពន្យល់ វែកញែក ប្រកបដោយហេតុផល មានអំណះអំណាង និងចេះលើកជាឧទាហរណ៍មកបញ្ជាក់ឱ្យបានច្បាស់លាស់ដើម្បីឱ្យអ្នកអានយល់ច្បាស់ និងមានភាពជឿជាក់លើការបកស្រាយ។

លំនាំបង្រៀនតែងសេចក្ដី មានន័យទូលំលាយណាស់ ហើយវាពាក់ព័ន្ធខ្លាំងជាមួយនឹងដំណើរការរៀននិងបង្រៀន។ នៅក្នុងឯកសារនេះ យើងនឹងលើកយកលំនាំបង្រៀនទូទៅនៃការសរសេរតែងសេចក្ដីមួយចំនួនមកបង្ហាញ គឺលំនាំបង្រៀនការអនុវត្តសរសេរតែងសេចក្ដី។ អ្នកសិក្សាគប្បីដឹងថា លំនាំបង្រៀនមិនមែនមានតែមួយជាគំរូដែលល្អបណ្ដាច់ជាងគេនោះទេ។ ប៉ុន្តែវាអាចមានលំនាំបង្រៀនល្អជាច្រើនសម្រាប់ជាជម្រើសក្នុងការរៀបចំការរៀននិងបង្រៀនឱ្យបានល្អ។ ក្នុងខ្លឹមសារមេរៀនតែមួយគេអាចរៀបចំលំនាំបង្រៀនបានច្រើនបែបច្រើនយ៉ាងខុសៗគ្នា អាស្រ័យទៅតាមការច្នៃប្រឌិតរបស់អ្នកបង្រៀនម្នាក់ៗ។ ដូច្នេះក្នុងការរៀននិងបង្រៀនតែងសេចក្ដី គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីធ្វើយ៉ាងណាឱ្យសិស្សសម្រេចបាននូវវត្ថុបំណងគឺ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។

## ១០.២- លំនាំបង្រៀនការអនុវត្តសរសេរតែងសេចក្តី

ការរៀននិងបង្រៀនការអនុវត្តសរសេរតែងសេចក្តីនៅមធ្យមសិក្សាបឋមភូមិ ចែកចេញជាបីដំណាក់កាលគឺ៖

### ក- ការសិក្សាអត្ថបទតែងសេចក្តីគំរូ

### លំនាំបង្រៀនការសិក្សាអត្ថបទតែងសេចក្តីគំរូ

អត្ថបទតែងសេចក្តីគំរូនេះមានច្រើនបែប ច្រើនយ៉ាង អាស្រ័យទៅតាមប្រភេទនៃប្រធានតែងសេចក្តីនីមួយៗ។ ការសិក្សាអត្ថបទតែងសេចក្តីគំរូ មានលំនាំបង្រៀនដូចខាងក្រោម៖

#### ក.១- គោលបំណង

អត្ថបទតែងសេចក្តីគំរូ គឺជាអត្ថបទដែលមាននៅក្នុងសៀវភៅសិក្សាគោលឬបើពុំមាននៅក្នុងសៀវភៅសិក្សាគោលទេ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីតាក់តែងអត្ថបទនោះដោយខ្លួនឯងយកមកបង្រៀន។ មុនពេលឈានទៅដល់ដំណាក់កាលអនុវត្តសរសេរតែងសេចក្តី សិស្សត្រូវសិក្សាអត្ថបទតែងសេចក្តីគំរូជាមុនសិន។ ដូច្នេះដើម្បីឱ្យសិស្ស និស្សិតងាយចាប់បានខ្លឹមសារមេរៀន គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីបង្ហាញគោលបំណងក្នុងការសិក្សាអត្ថបទតែងសេចក្តីគំរូនេះឱ្យគេបានដឹងជាមុនសិន។

***ឧទាហរណ៍:*** ការសិក្សាអត្ថបទគំរូនៃប្រធានបែបអត្ថាធិប្បាយពន្យល់ មានគោលបំណងឱ្យសិស្សបានយល់ដឹងពី៖

- ប្រភេទនៃប្រធានតែងសេចក្តី: ក្នុងប្រភេទនៃប្រធានតែងសេចក្តីមានចំណុចសំខាន់ៗគឺលក្ខណ:សម្គាល់របស់ប្រភេទប្រធាន បម្រាប់ប្រធាន និងឃ្លាសំណួរ។
- ទម្រង់នៃប្រភេទតែងសេចក្តីនីមួយៗ ដែលក្នុងនោះមានផ្នែកសំខាន់ៗដូចជា៖
  - ✓ ផ្តើមសេចក្តី: ក្នុងសេចក្តីផ្តើមមានចំណុចសំខាន់ៗគឺ លំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា និងខ្លឹមសារដែលគេបានបរិយាយនៅតាមចំណុចទាំងនោះ។
  - ✓ តួសេចក្តី: ក្នុងតួសេចក្តីមានចំណុចសំខាន់គឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី និងខ្លឹមសារដែលគេបានបរិយាយនៅតាមចំណុចទាំងនោះ។
  - ✓ បញ្ចប់សេចក្តី: ក្នុងសេចក្តីបញ្ចប់មានចំណុចសំខាន់ៗគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន និងខ្លឹមសារដែលគេបានបរិយាយនៅតាមចំណុចទាំងនោះ។

#### ខ.២- ទំនាក់ទំនងមេរៀន

**- ការសិក្សារូបភាព(បើសិនជាមាន)**

ការសិក្សារូបភាពមានគោលបំណងធំៗពីរ ទីមួយគឺបណ្តុះបំណិនសិស្សឱ្យចេះនិយាយរៀបរាប់ ឬពិពណ៌នា និងទីពីរគឺបណ្តុះបំណិនសិស្សឱ្យចេះនិយាយបកស្រាយ ពន្យល់អំពីអត្ថន័យនៃរូបភាពប្រកបដោយលក្ខណ:សមហេតុផល ឡូសិក មានអំណះអំណាង ភស្តុតាង និងមានសក្ខីកម្ម។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យ គប្បីប្រើវិធី ឬល្បិចបង្រៀនបែបណាដើម្បីឱ្យសិស្សគិត ត្រិះរិះ ពិចារណាបានស៊ីជម្រៅ។ សកម្មភាពរៀននិងបង្រៀនការសិក្សារូបភាពផ្តោតលើចំណុចសំខាន់ៗពីរគឺ៖

▪ គ្រូឱ្យសិស្សរៀបរាប់ ឬពិពណ៌នាអំពីរូបភាព៖

- ✓ គោលបំណងនៃការឱ្យសិស្សរៀបរាប់ឬពិពណ៌នាអំពីរូបភាពនេះគឺ ចង់បណ្តុះសិស្សឱ្យមានបំណិនក្នុងការនិយាយរៀបរាប់ឬការពិពណ៌នាពីរូបភាពតាមរយៈការសង្កេតឃើញដោយផ្ទាល់ភ្នែក មានន័យថាអ្វីដែលគេមើលឃើញនោះ គេអាចលើកមកនិយាយរៀបរាប់បានច្បាស់លាស់មានលក្ខណៈរស់រវើកដែរឬទេ។ ចំណុចនេះអាចវាយតម្លៃសមត្ថភាពសិស្សបានតាមរយៈការឆ្លើយនឹងសំណួរថា តើការនិយាយរៀបរាប់ឬការពិពណ៌នារបស់សិស្សអាចធ្វើឱ្យអ្នកស្តាប់ក្តាប់បាន ហើយមានអារម្មណ៍ថាហាក់បីដូចជាឃើញនឹងភ្នែកហើយឬនៅ?
- ✓ ដើម្បីសម្រេចគោលបំណងខាងលើ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាព រៀននិងបង្រៀនយ៉ាងណា ឱ្យសិស្សរៀនសង្កេតផង ហើយអាចនិយាយរៀបរាប់ ឬការពិពណ៌នាពីអ្វីដែលមើលឃើញផង។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្សមានដូចជា តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ? ឬតើនៅក្នុងរូបភាពនេះ មានអ្វីខ្លី? ឬចូរអ្នករៀបរាប់ពីរូបភាពមានអ្វីខ្លះ?។ល។

▪ គ្រូឱ្យសិស្សបកស្រាយ ពន្យល់អំពីអត្ថន័យនៃរូបភាព៖

- ✓ គោលបំណងនៃការឱ្យសិស្សបកស្រាយ ពន្យល់អំពីអត្ថន័យនៃរូបភាពនេះគឺ ចង់បណ្តុះសិស្សឱ្យមានបំណិនក្នុងការនិយាយបកស្រាយ ពន្យល់ពីអត្ថន័យនៃរូបភាព។ ចំណុចនេះវាមានលក្ខណៈស៊ីជម្រៅជាងការរៀបរាប់ឬការពិពណ៌នា ព្រោះសិស្សមិនត្រឹមតែធ្វើការសង្កេតឱ្យឃើញផ្ទាល់ភ្នែក ហើយអាចបកស្រាយ ពន្យល់ វែកញែកបាននោះទេ។ ដើម្បីអាចបកស្រាយ ពន្យល់ពីអត្ថន័យនៃរូបភាពបានគឺសិស្សត្រូវសង្កេតឱ្យឃើញផ្ទាល់ភ្នែក គិត ត្រិះរិះ ពិចារណារកគំនិតយោបល់ឱ្យបានស៊ីជម្រៅដើម្បីធ្វើការបកស្រាយ និងត្រូវរកឧទាហរណ៍ អំណះអំណាង ភស្តុតាង និងសក្ខីកម្មឱ្យបានសមស្របយកមកបញ្ជាក់ ឬអះអាង ដើម្បីធ្វើឱ្យការបកស្រាយមានលក្ខណៈជាក់លាក់ ច្បាស់លាស់ សមហេតុផលឡូសិក។ ដូច្នេះមានន័យថាសិស្សត្រូវចេះនិយាយបកស្រាយផង និងចេះលើកឧទាហរណ៍ឬអំណះអំណាងផង។ ចំណុចនេះ អាចវាយតម្លៃសមត្ថភាពសិស្សបានតាមរយៈការបកស្រាយ ពន្យល់ និងការលើកឧទាហរណ៍ឬការផ្តល់អំណះអំណាងទៅលើសេចក្តីបកស្រាយរបស់សិស្ស។
- ✓ ដើម្បីសម្រេចគោលបំណងនេះបាន គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនយ៉ាងណា ឱ្យសិស្សបានសង្កេត គិត វិភាគ ត្រិះរិះ ពិចារណា ដើម្បីចេះបកស្រាយ និងចេះរកអំណះអំណាងមកបញ្ជាក់។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្សមានដូចជា តើរូបភាពនេះមានអត្ថន័យដូចម្តេច? ចូរផ្តល់អំណះអំណាង។ តើរូបភាពនេះចង់និយាយពីអ្វី? ចូរលើកឧទាហរណ៍។ ចូរអ្នកបកស្រាយពីអត្ថន័យនៃរូបភាពនេះដោយបញ្ជាក់ពីហេតុផល។ល។

- **ការសិក្សាចំណងជើង**

- ✓ ការសិក្សាចំណងជើង មានគោលបំណងសំខាន់ៗពីរគឺ បណ្តុះបំណិនសិស្សឱ្យចេះបកស្រាយអំពីអត្ថន័យនៃចំណងជើង និងបណ្តុះបំណិនសិស្សឱ្យចេះការលើកឧទាហរណ៍ ឬការផ្តល់

អំណះអំណាងទៅលើការបកស្រាយ ដើម្បីឱ្យការបកស្រាយកបដោយភាពច្បាស់លាស់ មានលក្ខណៈសមហេតុផល ឡូសិក មានអំណះអំណាង ភស្តុតាង និងមានសក្ខីកម្ម។ ដូច្នេះមានន័យថាសិស្សត្រូវចេះបកស្រាយផង និងត្រូវចេះផ្តល់អំណះអំណាងផង។ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីប្រើវិធី ឬល្បិចបង្រៀនបែបណាដើម្បីឱ្យសិស្សគិត ត្រិះរិះ ពិចារណាបានស៊ីជម្រៅ។

- ✓ ដើម្បីសម្រេចគោលបំណងនេះបាន គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនយ៉ាងណា ឱ្យសិស្សបានសង្កេត គិត វិភាគ ត្រិះរិះ ពិចារណា ដើម្បីចេះបកស្រាយ និងចេះរកអំណះអំណាងមកបញ្ជាក់។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្សមានដូចជា តើចំណងជើងនេះមានអត្ថន័យដូចម្តេច? ហេតុអ្វីបានជាអ្នកហ៊ានបកស្រាយដូច្នោះ? តើចំណងជើងនេះចង់និយាយពីអ្វី? ចូរលើកឧទាហរណ៍។ ចូរអ្នកបកស្រាយពីអត្ថន័យនៃចំណងជើងនេះដោយបង្ហាញពីអំណះអំណាង។ល។

- **ការផ្សារភ្ជាប់សមត្ថភាពចាំបាច់ទៅនឹងខ្លឹមសារមេរៀនថ្មី**

តើអ្វីទៅជាសមត្ថភាពចាំបាច់?

- ✓ សមត្ថភាពចាំបាច់ គឺជាចំណេះដឹង និងបំណិនមួយចំនួនដែលមាននៅក្នុងសមត្ថភាពស្រាប់។ សមត្ថភាពមានស្រាប់គឺជាចំណេះដឹង បំណិន និងបទពិសោធ ដែលសិស្សទទួលបានពីជីវភាពរស់នៅប្រចាំថ្ងៃ គ្រួសារ សហគមន៍ សង្គម មេរៀនមុន និងពីថ្នាក់រៀនមុនជាដើម។ ចំណេះដឹងនេះ មានខ្លឹមសារជាប់ទាក់ទងជាមួយ ខ្លឹមសារមេរៀនថ្មីដែលយើងនឹងលើកយកមកបង្រៀន។ សមត្ថភាពនេះ គឺជាឈ្នាន់ដែលជាស្ពានឬជាមូលដ្ឋានគ្រឹះសម្រាប់ទៅចាប់ខ្លឹមសារមេរៀនថ្មី។
- ✓ ដើម្បីបំផុសឱ្យបានសមត្ថភាពចាំបាច់នេះ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនយ៉ាងណាឱ្យសិស្សបានសង្កេត ស្រាវជ្រាវ គិត វិភាគ ត្រិះរិះ ពិចារណា អនុវត្ត ដើម្បីបង្ហាញឡើងវិញនូវចំណេះដឹង បំណិនដែលគេមាន ហើយជាប់ទាក់ទៅនឹងខ្លឹមសារមេរៀនថ្មី។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួមសិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលានិងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្ស គឺសួរទៅលើខ្លឹមសារមេរៀនដែលសិស្សបានរៀនរួចហើយជាប់ទាក់ទៅនឹងមេរៀនថ្មី។ ឧទារហណ៍ថា បើមេរៀនតែងសេចក្តីថ្មីដែលនឹងត្រូវលើកយកមកសិក្សា គឺតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត នោះមានន័យថាសិស្សបានសិក្សារួចហើយអំពីតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទស្សនៈ មតិ ឬពំនោល។ សមត្ថភាពចាំបាច់របស់សិស្ស សម្រាប់យកមកភ្ជាប់ជាមួយមេរៀនថ្មីគឺលក្ខណៈសម្គាល់ប្រធាន គម្រោងតែង ទម្រង់សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ជាដើម។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យគប្បីសួរសំណួរផ្តោតលើចំណុចទាំងនេះ។

## ក.៣- ការសិក្សាប្រធាន

ប្រសិនបើមានប្រធានសរសេរនៅខាងលើអត្ថបទតែងសេចក្តីគំរូ យើងគប្បីដឹកនាំសិស្សសិក្សាប្រធានជាមុនសិន។ ការសិក្សាប្រធានមានគោលបំណងឱ្យសិស្សកំណត់បានពីប្រភេទប្រធានតែងសេចក្តី។

ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលានិងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរឱ្យសិស្សឆ្លើយ គឺផ្តោតទៅលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ប្រភេទប្រធានតែងសេចក្តី: តើប្រធាននេះជាប្រភេទប្រធានអ្វី?
- សិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធាន: តើមានលក្ខណៈសម្គាល់ដូចម្តេចដែលអាចបញ្ជាក់ថាជាប្រភេទប្រធាននោះ?
- សិក្សាបម្រាប់ប្រធាន: តើប្រធានប្រភេទនោះមានបម្រាប់ប្រធានដូចម្តេចខ្លះ?
- សិក្សាឃ្លាសំណួរ: តើប្រធានប្រភេទនោះមានឃ្លាសំណួរដូចម្តេចខ្លះ?

### ក.៤- ការសិក្សាពាក្យពិបាកក្នុងអត្ថបទ

ការសិក្សាពាក្យពិបាក មានគោលបំណងយល់ន័យពាក្យពិបាកដែលមាននៅក្នុងអត្ថបទ ព្រោះប្រសិនបើមានពាក្យពិបាកសិស្សមិនយល់ នោះមានន័យថាសិស្សក៏អាចនឹងមិនយល់អត្ថបទដែរ។ ពាក្យពិបាក គឺជាពាក្យដែលពិបាកអាន និងពិបាកយល់ន័យ។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យអាចការរៀបចំដំណើរការរៀននិងបង្រៀន ដោយបំផុសសំណួរឱ្យសិស្សឆ្លើយជារួម សិស្សធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀត អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សកម្មភាពមួយចំនួនដែលគ្រូគប្បីអនុវត្តមានដូចខាងក្រោម៖

- គ្រូឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ និងរហ័សបំផុតឬអំណានត្រួសៗ ដើម្បីរកពាក្យពិបាកអាន និងពិបាកយល់ន័យ។
- គ្រូឱ្យសិស្សឡើងសរសេរពាក្យពិបាកនៅលើក្តារខៀន។
- គ្រូដឹកនាំសិស្សធ្វើការហ្វឹកហាត់អាន និងពន្យល់ន័យនៃពាក្យពិបាក។

*សម្គាល់:* ករណីក្នុងអត្ថបទមិនមានពាក្យពិបាក យើងមិនចាំបាច់អនុវត្តសកម្មភាពសិក្សាពាក្យពិបាកនេះឡើយ។

### ក.៥- ការហ្វឹកហាត់អានឮ

ការហ្វឹកហាត់អានឮ មានគោលបំណងចង់ផ្ទៀងផ្ទាត់ការអានរបស់សិស្សថា តើពួកគេអានអត្ថបទបានត្រឹមត្រូវហើយ ឬនៅ? ការអានឮអត្ថបទបានត្រឹមផ្តោតលើចំណុចបីសំខាន់ៗគឺ ការអានអត្ថបទរួចមិនទើសទាក់ និងការចេះលើកដាក់សំឡេង ការចេះគោរពសញ្ញាវណ្ណវាទ និងការធ្វើកាយវិការបានត្រឹមត្រូវ។ សកម្មភាពដែលគ្រូគប្បីអនុវត្តមានដូចជា៖

- គ្រូ ឬសិស្សអានឮអត្ថបទជាគំរូ
- គ្រូឱ្យសិស្សហ្វឹកហាត់អានឮជារួម ជាបុគ្គល ជាដៃគូ ឬជាក្រុម ដោយផ្តោតលើបែបបទ ការចេះលើកដាក់សំឡេង ការគោរពសញ្ញាសម្ព័ន្ធ និងការធ្វើកាយវិការបានត្រឹមត្រូវ។

*សម្គាល់:* សម្រាប់សិស្សនៅមធ្យមសិក្សាទុតិយភូមិ បើសាស្ត្រាចារ្យយល់ថាសិស្សមិនមានការលំបាកលើការអាននោះទេ អាចមិនចាំបាច់អនុវត្តសកម្មភាពអានឮនេះក៏បាន។

### ក.៦- ការសិក្សាសំណួរ

ការសិក្សាសំណួរ មានគោលបំណងចង់ឱ្យសិស្សស្វែងខ្លឹងសារសំណួរដែលនឹងត្រូវឆ្លើយ ក្រោយពេលអានអត្ថបទរួច និងចង់ឱ្យសិស្សចេះផ្តោតអារម្មណ៍ទៅខ្លឹមសារសំខាន់ៗនៅពេលអានអត្ថបទ។ ខ្លឹមសារសំណួរអាចមាននៅខាងក្រោយអត្ថបទតែងសេចក្តីគំរូ តែងសេចក្តីឬបើអត្ថបទគំរូនៅក្នុងសៀវភៅសិស្សពុំមានសំណួរឬក៏អត្ថបទគំរូតែងសេចក្តីនោះគ្រូតាក់តែងដោយខ្លួនឯង ក្នុងករណីនេះគ្រូត្រូវរៀបចំខ្លឹមសារសំណួរដោយផ្តោតទៅលើផ្នែកសំខាន់ៗគឺការសួរទៅលើខ្លឹសារទូទៅរបស់អត្ថបទ និងការសួរផ្តោតទៅលើទម្រង់តែងសេចក្តីរបស់អត្ថបទ។ គ្រូគប្បីរៀបចំសកម្មភាពរៀននិងបង្រៀនមួយចំនួននៅពេលអានសំណួរដូចខាងក្រោម៖

- គ្រូឱ្យសិស្សម្នាក់ឬក៏ពីរនាក់អានសំណួរ ចំណែកសិស្សដទៃទៀតគ្រូណែនាំឱ្យតាមដានស្តាប់ និងផ្ទៀងផ្ទាត់ ព្រមទាំងត្រិះរិះពិចារណាទៅលើខ្លឹមសារសំណួរ។
- គ្រូសួរសិស្សដើម្បីបញ្ជាក់ពីការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារសំណួរ។ គ្រូអាចសួរសិស្សនៅពេលអានសំណួរចប់: តើសំណួរទី១ចង់និយាយពីអ្វី? តើសំណួរទី២ ទី៣ ទី៤...ចង់និយាយពីអ្វី? ក្នុងករណីបើមានសំណួរណាសិស្សមិនទាន់យល់ឬយល់មិនទាន់ច្បាស់ គ្រូគួរពន្យល់បន្ថែម។

### ក.៧- ការស្ទាត់ដើម្បីយល់ន័យ

ការអានស្ទាត់អានស្ទាត់ មានគោលបំណងឱ្យសិស្សយល់ន័យរបស់អត្ថបទ។ គ្រូគប្បីណែនាំសិស្សឱ្យអានដោយស្ងៀមស្ងាត់ អានដោយផ្តោតលើចំណុចសំខាន់ៗដែលត្រូវឆ្លើយនឹងសំណួរ និងត្រូវកំណត់ពេលវេលាឱ្យបានច្បាស់លាស់សិស្សអាន។ សកម្មភាពរៀននិងបង្រៀនការអានស្ទាត់នេះ ជាទូទៅធ្វើឡើងជាលក្ខណៈបុគ្គល។

### ក.៨- ការឆ្លើយសំណួរ

ការឆ្លើយសំណួរ មានគោលបំណងចង់វាស់ស្ទង់ការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារអត្ថបទ។ សំណួរទាំងនោះ គឺជាសំណួរដែលសិស្សបានអានរួចមកហើយមុនពេលអានស្ទាត់។ នៅពេលឆ្លើយសំណួរគ្រូគួរណែនាំសិស្សកុំឱ្យមើលអត្ថបទ ឬបិទសៀវភៅតែម្តង។ ក្នុងករណីមានសំណួរណាសិស្សឆ្លើយមិនបានត្រឹមត្រូវ គ្រូអាចអនុញ្ញាតឱ្យសិស្សអានអត្ថបទត្រង់ចំណុចនោះឡើងវិញ ដើម្បីធ្វើការផ្ទៀងផ្ទាត់ចម្លើយរបស់ខ្លួន។ គ្រូគប្បីរៀបចំសកម្មភាពរៀននិងបង្រៀនមួយចំនួននៅពេលឆ្លើយនឹងសំណួរមានដូចខាងក្រោម៖

- គ្រូសួរសំណួរទាក់ទងនឹងខ្លឹមសារទូទៅរបស់អត្ថបទឱ្យសិស្សឆ្លើយ ដើម្បីបញ្ជាក់ពីការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារអត្ថបទ។
- គ្រូអាចសួរសំណួរមួយចំនួនដូចខាងក្រោម ដើម្បីទាញខ្លឹមសារអត្ថបទមកបញ្ចូលក្នុងគម្រោងតែងសេចក្តី៖
  - ✓ តើអត្ថបទនេះជាប្រភេទតែងសេចក្តីអ្វី? តើអ្នកមានអំណះអំណាងអ្វីខ្លះ បានជានិយាយថាវាជាប្រភេទតែងសេចក្តីនោះ?
  - ✓ តើអត្ថបទតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (ចែកចេញជាបីផ្នែកគឺ សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់)

▪ តើសេចក្តីផ្តើមមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)។
- តើនៅក្នុងលំនាំបញ្ហាគេនិយាយដូចម្តេចខ្លះ?
- តើនៅក្នុងចំណូលបញ្ហាគេនិយាយដូចម្តេចខ្លះ?
- តើនៅក្នុងចំណោទបញ្ហាគេនិយាយដូចម្តេចខ្លះ?

▪ តើតួសេចក្តីមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)។
- តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយដូចម្តេចខ្លះ?
- តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយដូចម្តេចខ្លះ?
- តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយដូចម្តេចខ្លះ?
- តើនៅក្នុងការបកស្រាយប្រធានគេនិយាយដូចម្តេចខ្លះ?
- តើនៅក្នុងសរុបសេចក្តីគេនិយាយដូចម្តេចខ្លះ?

▪ តើសេចក្តីបញ្ចប់មានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)។
- តើនៅក្នុងវាយតម្លៃប្រធានគេនិយាយដូចម្តេចខ្លះ?
- តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយដូចម្តេចខ្លះ?

### ១.៩- ការពង្រឹងចំណេះដឹង

ការពង្រឹងចំណេះដឹង មានគោលបំណងចង់វាយតម្លៃការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារមេរៀនដែលបានរៀនរួច។ ខ្លឹមសារសំណួរ គប្បីផ្តោតលើចំណុចសំខាន់ៗនៅក្នុងខ្លឹមសារមេរៀន។ ការវាយតម្លៃនេះ គួរធ្វើជាលក្ខណៈបុគ្គលប្រសើជាងធ្វើជាក្រុម ឬធ្វើជារួមព្រោះការធ្វើជារួម ឬជាក្រុម យើងពិបាកកំណត់ណាស់ថា តើសិស្សណាចេះ ឬសិស្សណាមិនចេះ។ ដូច្នេះក្នុងការសួរសិស្ស គប្បីផ្តោតលើសិស្សរៀនយឺត មានន័យថាបើសិស្សរៀនយឺតអាចឆ្លើយបានត្រឹមត្រូវ នោះមានន័យថាសិស្សដទៃទៀតក៏អាចយល់បានដែរ។ គ្រូគួរចៀសវាងសួរសំណួរវាយតម្លៃដូចជា តើអ្នកយល់ឬទេ? តើមែនឬទេ? ជាដើម ព្រោះសំណួរបែបនេះមិនអាចវាយតម្លៃការយល់ដឹងរបស់សិស្សបានច្បាស់លាស់ឡើយ។

### ១.១០- ការដាក់កិច្ចការស្រាវជ្រាវ

ការកិច្ចការស្រាវជ្រាវ មានគោលបំណងឱ្យសិស្សមានបំណិនក្នុងការសិក្សាស្រាវជ្រាវ។ ដូច្នេះ ចំណុចសំខាន់ដែលចង់ឱ្យសិស្សចេះនៅក្នុងចំណុចនេះគឺ សិស្សយល់ដឹងពីវិធីស្រាវជ្រាវ និងសិស្សចេះចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវ។ គ្រូគប្បីដាក់ប្រធានបទ ឬសំណួរ ឬលំហាត់ឱ្យសិស្សសិក្សាស្រាវជ្រាវ។ ខ្លឹមសារសម្រាប់ការសិក្សាស្រាវជ្រាវ គឺទាក់ទៅនឹងខ្លឹមសារមេរៀនដែលបានរៀនរួច ឬខ្លឹមសារមេរៀនខាងមុខ ដើម្បីឱ្យសិស្សមានចំណេះដឹងបន្ថែមកាន់តែទូលំទូលាយ។ក្នុងសកម្មភាពសិក្សាស្រាវជ្រាវនេះ គប្បីរៀបចំសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការរៀបចំប្រធានបទ ឬសំណួរ ឬលំហាត់
- រូបភាពនៃការសិក្សាស្រាវជ្រាវ(ជាបុគ្គល ដៃគូ ក្រុម)
- ការរៀបចំដំណើរការសិក្សាស្រាវជ្រាវ(កំណត់សកម្មភាពសម្រាប់ដំណើរការសិក្សាស្រាវជ្រាវ តើត្រូវធ្វើសកម្មភាពអ្វីខ្លះ? តើសកម្មភាពណាធ្វើមុន សកម្មភាពណាធ្វើបន្ទាប់ សកម្មភាពណាធ្វើក្រោយ?

- ការកំណត់ទីកន្លែង
- ការកំណត់ពេលវេលា
- ការរៀបចំចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវអំពីប្រធានបទ ឬសំណួរ ឬលំហាត់
- ការរៀបចំរបាយការណ៍
- ការបង្ហាញលទ្ធផលស្រាវជ្រាវ។

### ១.១១- ការសង្ខេបសកម្មភាពនិងខ្លឹមសារសំខាន់ៗ

ការសង្ខេប មានគោលបំណងចង់ឱ្យសិស្ស ចេះនិយាយសង្ខេបឡើងវិញនូវសកម្មភាពរៀននិងបង្រៀនមេរៀននេះ និងចេះសង្ខេបខ្លឹមសារសំខាន់ៗដែលបានរៀននៅក្នុងមេរៀននេះ។ ដើម្បីអាចធ្វើសង្ខេបបានលុះត្រាតែយកចិត្តទុកដាក់រៀនសូត្រ ចេះកត់ត្រាពីសកម្មភាព និងខ្លឹមសារសំខាន់ដែលបានរៀននិងបង្រៀន។ ដូច្នេះគ្រូគប្បីណែនាំសិស្សឱ្យកត់ត្រាពីសកម្មភាពរៀននិងបង្រៀននិងណែនាំសិស្សឱ្យយល់ដឹងពីវិធីកត់ត្រាផងដែរ។ ការសង្ខេបនេះ ច្រើនធ្វើជាលក្ខណៈបុគ្គលដោយមានការផ្លាស់ប្ដូរវេនគ្នា ជាពិសេសត្រូវផ្ដោតលើសិស្សរៀនយឺតឱ្យបានអនុវត្តច្រើនជាងគេ។

### ១.១២- ការបូកសរុប

គ្រូធ្វើការបូកសរុបខ្លឹមសារសំខាន់ៗ ដែលតម្រូវឱ្យសិស្សយកចិត្តទុកដាក់ និងអាចណែនាំបន្ថែម ឬពន្យល់បន្ថែម ទៅលើចំណុចមួយចំនួនដែលសិស្សខ្វះខាត ឬចំណុចសិស្សមិនទាន់យល់ច្បាស់។

### ១.១៣- ការកត់ត្រាមេរៀន

សកម្មភាពកត់ត្រាមេរៀននេះ មានគោលបំណងឱ្យសិស្សចេះកត់នូវអ្វីដែលគេបានរៀន។ ការកត់ត្រាមិនមែនរង់ចាំដល់ចប់ទើបកត់នោះទេ ពោលគឺសិស្សត្រូវចេះកត់បណ្ដើរៗនូវខ្លឹមសារផ្សេងៗតាមរយៈការស្ដាប់ ការឆ្លើយសំណួរ ការធ្វើសកម្មភាព ការអាន និងការពន្យល់របស់គ្រូជាដើម។ គ្រូគប្បីណែនាំសិស្សឱ្យកត់ត្រា និងណែនាំសិស្សឱ្យយល់ដឹងពីវិធីកត់ត្រាផងដែរ។

## ២- ការសិក្សាគម្រោងតែងសេចក្ដី

## លំនាំបង្រៀនការសិក្សាគម្រោងតែងសេចក្ដី

ការសិក្សាគម្រោងតែងសេចក្ដី គឺជាការចាំបាច់មួយដ៏មានសារៈសំខាន់ក្នុងដំណើររៀននិងបង្រៀនតែងសេចក្ដី។ ដើម្បីសរសេរតែងសេចក្ដីបានល្អ សិស្សត្រូវចេះធ្វើគម្រោងតែងជាមុនសិន។ ដើម្បីមានសមត្ថភាពអាចធ្វើគម្រោងតែងបាន គឺសិស្សត្រូវយល់ដឹងច្បាស់លាស់ពីវិធីធ្វើគម្រោង។ ដូច្នេះដើម្បីឱ្យយល់ដឹងពីវិធីគម្រោងតែងសេចក្ដីគ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនមួយចំនួនដូចខាងក្រោម៖

### ២.១- គោលបំណង

ការសិក្សាគម្រោងតែងសេចក្ដី គឺជាការចាំបាច់មួយដែលសិស្សត្រូវចេះ មុនពេលឈានទៅដល់ដំណាក់សរសេរតែងសេចក្ដី។ ដូច្នេះដើម្បីឱ្យសិស្ស និស្សិតងាយចាប់បានខ្លឹមសារមេរៀន គ្រូបង្រៀនគប្បីបង្ហាញគោលបំណងនៃការសិក្សាគម្រោងតែងសេចក្ដីនេះឱ្យគេបានដឹងជាមុនសិន។

ឧទាហរណ៍: ការសិក្សាគម្រោងនៃប្រធានបែបអត្ថាធិប្បាយពន្យល់ មានគោលបំណងឱ្យសិស្សបានយល់ដឹងពី៖

- ប្រភេទនៃប្រធានតែងសេចក្ដី: ក្នុងប្រភេទនៃប្រធានតែងសេចក្ដីមានចំណុចសំខាន់ៗគឺ លក្ខណៈ

- សម្គាល់របស់ប្រភេទប្រធាន បម្រាប់ប្រធាន និងឃ្លាសំណួរ។
- ទម្រង់នៃប្រភេទតែងសេចក្តីនីមួយៗ ដែលក្នុងនោះមានផ្នែកសំខាន់ៗដូចជា៖
  - ✓ ផ្តើមសេចក្តី មានចំណុចសំខាន់ៗបីគឺ លំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា
  - ✓ តួសេចក្តី មានចំណុចសំខាន់ៗប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី
  - ✓ បញ្ចប់សេចក្តី មានចំណុចសំខាន់ៗពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន។

## ២.២- ទំនាក់ទំនងមេរៀន

គ្រូសួរសំណួរដើម្បីផ្សារភ្ជាប់សមត្ថភាពចាំបាច់ ឬបទពិសោធរបស់សិស្សទៅនឹងខ្លឹមសារមេរៀនថ្មី។

## ២.៣- ការអានអត្ថបទ

គ្រូឱ្យសិស្សហ្វឹកហាត់អានខ្លឹមសារគម្រោងទាំងមូល។

## ២.៤- គ្រូដឹកនាំសិស្សការសិក្សាប្រធាន

ការរៀបចំសកម្មភាពរៀននិងបង្រៀនគប្បីផ្តោតលើចំណុចមួយចំនួនដូចខាងក្រោម៖

- ប្រភេទប្រធានតែងសេចក្តី: តើប្រធាននេះជាប្រភេទប្រធានអ្វី?
- សិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធាន៖ តើមានលក្ខណៈសម្គាល់ដូចម្តេច ដែលអាចបញ្ជាក់ថា ជាប្រភេទប្រធាននោះ?
- សិក្សាបម្រាប់ប្រធាន: តើប្រធានប្រភេទនោះមានបម្រាប់ប្រធានដូចម្តេចខ្លះ?
- សិក្សាឃ្លាសំណួរ: តើប្រធានប្រភេទនោះមានឃ្លាសំណួរដូចម្តេចខ្លះ?

## ២.៥- ការសិក្សាទម្រង់នៃគម្រោងតែងសេចក្តី

ការសិក្សាទម្រង់នៃគម្រោងតែងសេចក្តី មានគោលបំណងឱ្យសិស្សយល់ដឹងពីទម្រង់នៃគម្រោរបស់ប្រភេទតែងសេចក្តីនីមួយៗ។ ការសិក្សាទម្រង់នេះ គ្រូអាចរៀបចំសកម្មភាពរៀននិងបង្រៀននិងអាស្រ័យទៅតាមប្រភេទតែងសេចក្តីនីមួយៗ ដែលមានទម្រង់ខុសៗគ្នា។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យអាចការរៀបចំដំណើរការរៀននិងបង្រៀន ដោយបំផុសសំណួរឱ្យសិស្សឆ្លើយជារួម សិស្សធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀត អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សកម្មភាពមួយចំនួនដែលគ្រូគប្បីអនុវត្តមានដូចខាងក្រោម៖

### ២.៥.១- ទម្រង់នៃគម្រោងតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទស្សនៈ មតិ ពំនោល

**តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទស្សនៈ មតិ ពំនោល**

- តើគម្រោងតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (ចែកចេញជាបីផ្នែកគឺ ផ្តើមសេចក្តី តួសេចក្តី និងបញ្ចប់សេចក្តី)។
- ការសិក្សាផ្តើមសេចក្តី: តើសេចក្តីផ្តើមនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)
  - ✓ លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(គំនិតទូទៅ...យោបល់ដែលជាលំនាំដើម...)

✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(បញ្ចូលបញ្ហារបស់ប្រធាន...)

✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ចោទសួរទៅលើប្រធាន...)។

- ការសិក្សាតួសេចក្ដី: តើតួសេចក្ដីនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្ដី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្ដី)

✓ ឃ្លាភ្ជាប់សេចក្ដី: តើនៅក្នុងឃ្លាភ្ជាប់សេចក្ដីគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ឃ្លាសម្រាប់ ជាកិច្ចចាប់ផ្ដើម ដើម្បីភ្ជាប់ពីសេចក្ដីផ្ដើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)

✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)

✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)

✓ បកស្រាយប្រធាន: តើនៅក្នុងការបកស្រាយប្រធានគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(អាចបកស្រាយបានជាច្រើនគំនិត អាស្រ័យទៅតាមខ្លឹមសាររបស់ប្រធាន។ ក្នុងការបកស្រាយគំនិតនីមួយៗ អ្នកធ្វើតែងសេចក្ដីគប្បីលើកមកភ្ជាប់ជានូវអំណះអំណាងឬឧទាហរណ៍ ដើម្បីបញ្ជាក់ទៅលើការបកស្រាយឱ្យកាន់តែច្បាស់លាស់...)

✓ សរុបសេចក្ដី: តើនៅក្នុងសរុបសេចក្ដីគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ការប្រមូលបញ្ចូលគ្នានូវគំនិត ដែលបានបកស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រ គំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង...)។

- ការសិក្សាបញ្ចប់សេចក្ដី: តើសេចក្ដីបញ្ចប់នៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)

✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ការឱ្យតម្លៃប្រធានថា មានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)

✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន របស់អ្នកសរសេរតែងសេចក្ដី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

## ២.៥.២- ទម្រង់នៃគម្រោងតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់សុភាសិត

### តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់សុភាសិត

- តើគម្រោងតែងសេចក្ដីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (ចែកចេញជាបីផ្នែកគឺ ផ្ដើមសេចក្ដី តួសេចក្ដី និងបញ្ចប់សេចក្ដី)។
- ការសិក្សាផ្ដើមសេចក្ដី: តើសេចក្ដីផ្ដើមនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)

- ✓ លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(គំនិតទូទៅ...យោបល់ដែលជាលំនាំដើម...)
- ✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(បញ្ចូលបញ្ហារបស់ប្រធាន...)
- ✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ចោទសួរទៅលើប្រធាន...)

- ការសិក្សាតួសេចក្តី: តើតួសេចក្តីនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)
  - ✓ ឃ្លាភ្ជាប់សេចក្តី: តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ឃ្លាសម្រាប់ ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)
  - ✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)
  - ✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)
  - ✓ បកស្រាយប្រធាន: តើការបកស្រាយប្រធានមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ៗចំនួនពីគឺ ការបកស្រាយន័យអត្ថានុរូបឬន័យត្រង់ និងបកស្រាយអត្ថបដិរូបឬន័យធៀប)

- បកស្រាយន័យអត្ថានុរូបឬន័យត្រង់: តើនៅក្នុងការបកស្រាយន័យអត្ថានុរូបឬន័យត្រង់គេនិយាយផ្តោតទៅលើអ្វីខ្លះ?(បកស្រាយពីខ្លឹមសារត្រង់ៗរបស់ប្រធានដែលបានលើកមកនិយាយតែម្តងដោយភ្ជាប់នឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់...)
- បកស្រាយអត្ថបដិរូបឬន័យធៀប: តើនៅក្នុងការបកស្រាយអត្ថបដិរូបឬន័យធៀបគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ស្រាយបំភ្លឺពីន័យបង្កប់ឬន័យប្រៀបប្រដូចរបស់ប្រធាន ដោយភ្ជាប់នឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់...)
  - ✓ សរុបសេចក្តី: តើនៅក្នុងសរុបសេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការប្រមូលបញ្ចូលគ្នានូវគំនិត ដែលបានបកស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រ គំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង...)។

- ការសិក្សាបញ្ចប់សេចក្តី: តើសេចក្តីបញ្ចប់នៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)
  - ✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការឱ្យតម្លៃប្រធានថា មានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)
  - ✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ចំណាប់អារម្មណ៍របស់អ្នកសរសេរតែងសេចក្តី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

### ២.៩.៣- ទម្រង់នៃគម្រោងតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

## តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

- តើគម្រោងតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ?(ចែកចេញជាបីផ្នែកគឺ ផ្តើមសេចក្តី តួសេចក្តី និងបញ្ចប់សេចក្តី)។
- ការសិក្សាសេចក្តីផ្តើម: តើសេចក្តីផ្តើមនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)
  - ✓ លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(គំនិតទូទៅ ... យោបល់ដែលជាលំនាំដើម...)
  - ✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(បញ្ចូលបញ្ហារបស់ប្រធាន...)
  - ✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ចោទសួរទៅលើប្រធាន...)។
- ការសិក្សាតួសេចក្តី: តើតួសេចក្តីនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)
  - ✓ ឃ្លាភ្ជាប់សេចក្តី: តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ឃ្លាសម្រាប់ ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)
  - ✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)
  - ✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)
  - ✓ បកស្រាយប្រធាន: តើនៅក្នុងការបកស្រាយប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(អាចបកស្រាយបានជាច្រើនគំនិត អាស្រ័យទៅតាមខ្លឹមសាររបស់ប្រធាន។ ក្នុងការបកស្រាយគំនិតនីមួយៗ អ្នកធ្វើតែងសេចក្តីគប្បីលើកមកភ្ជាប់ជានូវអំណះអំណាងឬឧទាហរណ៍ ដើម្បីបញ្ជាក់ទៅលើការបកស្រាយឱ្យកាន់តែច្បាស់លាស់...)
  - ✓ សរុបសេចក្តី: តើនៅក្នុងសរុបសេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការប្រមូលបញ្ចូលគ្នានូវគំនិត ដែលបានបកស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រ គំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង...)។
- ការសិក្សាបញ្ចប់សេចក្តី: តើសេចក្តីបញ្ចប់នៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)
  - ✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការឱ្យតម្លៃប្រធានថា មានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)
  - ✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន របស់អ្នកសរសេរតែងសេចក្តី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

## ២.៩.៤- ទម្រង់នៃគម្រោងតែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប

### តែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប

- តើគម្រោងតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ?(ចែកចេញជាបីផ្នែកគឺ ផ្តើមសេចក្តី តួសេចក្តី និងបញ្ចប់សេចក្តី)។
- ការសិក្សាសេចក្តីផ្តើម: តើសេចក្តីផ្តើមនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)
  - ✓ លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(គំនិតទូទៅ ... យោបល់ដែលជាលំនាំដើម...)
  - ✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(បញ្ចូលបញ្ហារបស់ប្រធាន...)
  - ✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ចោទសួរទៅលើប្រធាន...)។
- ការសិក្សាតួសេចក្តី: តើតួសេចក្តីនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)
  - ✓ ឃ្លាភ្ជាប់សេចក្តី: តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ឃ្លាសម្រាប់ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)
  - ✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)
  - ✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)
  - ✓ បកស្រាយប្រធាន: តើការបកស្រាយប្រធានមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ៗចំនួនពីរគឺ លក្ខណ:ដូចគ្នា និងលក្ខណ:ខុសគ្នា)
- លក្ខណ:ដូចគ្នា: តើនៅក្នុងលក្ខណ:ដូចគ្នាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(បកស្រាយបង្ហាញលក្ខណ:ដូចគ្នា ឬប្រហាក់ប្រហែលគ្នាត្រង់ចំណុចណាខ្លះទៅតាមចំណោទរបស់ប្រធាន ដោយភ្ជាប់នឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់...)
- លក្ខណ:ខុសគ្នា: តើនៅក្នុងលក្ខណ:ខុសគ្នាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(បកស្រាយបង្ហាញពីចំណុចខុសគ្នា ឬប្រឈមគ្នានៃចំណោទរបស់ប្រធានដែលបានចោទដោយភ្ជាប់នឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់...)
  - ✓ សរុបសេចក្តី: តើនៅក្នុងសរុបសេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ?(សរុបឡើងវិញនូវលក្ខណ:ដូចគ្នា និងខុសគ្នាពីក្នុងការបកស្រាយខាងលើ និងទាញរកចំណុចពិសេសដោយឡែក ឬទំហៀបផ្តាច់របស់ផ្នែកណាមួយ...)។
- ការសិក្សាបញ្ចប់សេចក្តី: តើសេចក្តីបញ្ចប់នៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)

- ✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការឱ្យតម្លៃប្រធាន ថា មានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)
- ✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ចំណាប់អារម្មណ៍របស់អ្នកសរសេរតែងសេចក្តី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

## ២.៦- ការពង្រឹងចំណេះដឹង

ការពង្រឹងចំណេះដឹងនេះក៏ដូចគ្នាទៅនឹងការពង្រឹងចំណេះដឹងមុនដែរ គឺមានគោលបំណងចង់វាយតម្លៃការយល់ដឹងរបស់សិស្ស។ ការវាយតម្លៃនេះគប្បីផ្តោតលើសិស្សរៀនយឺត មានន័យថាបើសិស្សរៀនយឺតអាចធ្វើបានត្រឹមត្រូវ នោះមានន័យថាសិស្សដទៃទៀតក៏អាចធ្វើបានដែរ។

## ២.៧- ការដាក់កិច្ចការស្រាវជ្រាវ

ការកិច្ចការស្រាវជ្រាវនេះក៏ដូចគ្នាទៅនឹងការកិច្ចការស្រាវជ្រាវមុនដែរ គឺមានគោលបំណងឱ្យសិស្សយល់ដឹងពីវិធីស្រាវជ្រាវ និងសិស្សចេះចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវ។ គ្រូគប្បីដាក់ប្រធានបទ ឬសំណួរ ឬលំហាត់ឱ្យសិស្សសិក្សាស្រាវ។ ក្នុងសកម្មភាពសិក្សាស្រាវជ្រាវនេះ គប្បីរៀបចំសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការរៀបចំប្រធានបទ ឬសំណួរ ឬលំហាត់
- រូបភាពនៃការសិក្សាស្រាវជ្រាវ(ជាបុគ្គល ដៃគូ ក្រុម)
- ការរៀបចំដំណើរការសិក្សាស្រាវជ្រាវ
- ការកំណត់ទីកន្លែង
- ការកំណត់ពេលវេលា
- ការរៀបចំចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវអំពីប្រធានបទ ឬសំណួរ ឬលំហាត់
- ការរៀបចំរបាយការណ៍
- ការបង្ហាញលទ្ធផលស្រាវជ្រាវ។

## ២.៨- ការសង្ខេបសកម្មភាព និងខ្លឹមសារសំខាន់ៗ

ចំណុចនេះក៏ដូចគ្នាទៅនឹងការសង្ខេបមុនដែរ គឺមានគោលបំណងឱ្យសិស្ស ចេះនិយាយសង្ខេបឡើងវិញនូវសកម្មភាពរៀននិងបង្រៀនមេរៀននេះ និងចេះសង្ខេបខ្លឹមសារសំខាន់ៗដែលបានរៀននៅក្នុងមេរៀននេះ។ ការសង្ខេបនេះច្រើនធ្វើជាលក្ខណៈបុគ្គលដោយមានការផ្លាស់ប្តូរវេនគ្នា ជាពិសេសត្រូវផ្តោតលើសិស្សរៀនយឺតឱ្យបានអនុវត្តច្រើនជាងគេ។

## ២.៩- ការបូកសរុប

គ្រូធ្វើការបូកសរុបខ្លឹមសារសំខាន់ៗ ដែលតម្រូវឱ្យសិស្សយកចិត្តទុកដាក់ និងអាចណែនាំបន្ថែម ឬពន្យល់បន្ថែម ទៅលើចំណុចមួយចំនួនដែលសិស្សខ្វះខាត ឬចំណុចសិស្សមិនទាន់យល់ច្បាស់។

## ២.១០- ការកត់ត្រាមេរៀន

ការកត់ត្រាមេរៀននេះ មានគោលបំណងឱ្យសិស្សចេះកត់ត្រានូវអ្វីៗដែលគេកំពុងរៀន។ ការកត់ត្រានេះ មិនមែនរង់ចាំរហូតដល់ចប់ទើបកត់នោះទេ ពោលគឺសិស្សត្រូវចេះកត់បណ្តើរៗនូវខ្លឹមសារផ្សេងៗ

តាមរយៈការស្តាប់ ការឆ្លើយសំណួរ ការធ្វើសកម្មភាព ការអាន និងការពន្យល់របស់គ្រូជាដើម។ គ្រូគួរណែនាំសិស្សឱ្យកត់ត្រា និងយល់ដឹងពីវិធីកត់ត្រាផងដែរ។

## ៣- ការអនុវត្ត

### លំនាំបង្រៀនការអនុវត្តសរសេរតែងសេចក្តី

ការអនុវត្តសរសេរតែងសេចក្តីក៏មិនខុសពីការអនុវត្តធ្វើកិច្ចការឬលំហាត់ដទៃទៀតដែរ។ សកម្មភាពអនុវត្តនេះ ពុំមែនមានន័យថាឱ្យសិស្សធ្វើកិច្ចការដោយខ្លួនឯងទាំងស្រុងគ្រប់ពេលវេលានោះទេ ពោលគឺសកម្មភាពអនុវត្តនេះគប្បីធ្វើឡើងក្រោមការដឹកនាំរបស់គ្រូ។ គ្រូបង្រៀនអាចរៀបចំសកម្មភាពរៀននិងបង្រៀនតាមលំនាំមួយចំនួនដូចខាងក្រោម៖

### ៣.១- គោលបំណង

ការអនុវត្តសរសេរតែងសេចក្តី គឺជាដំណាក់កាលមួយដែលសិស្សបានយល់ដឹងច្បាស់លាស់រួចហើយពីវិធីសរសេរតែងសេចក្តី។ ដូច្នេះដើម្បីឱ្យសិស្ស និស្សិតងាយចាប់បានខ្លឹមសារមេរៀន គ្រូបង្រៀនសាស្ត្រាចារ្យ គប្បីបង្ហាញគោលបំណងក្នុងការអនុវត្តសរសេរតែងសេចក្តីនេះឱ្យគេបានដឹងជាមុនសិន។

ឧទាហរណ៍: ការអនុវត្តសរសេរតែងសេចក្តីប្រធានបែបអត្ថាធិប្បាយពន្យល់ មានគោលបំណងឱ្យសិស្សចេះកំណត់ប្រភេទតែងសេចក្តី និងសរសេរតែងសេចក្តីបានត្រឹមត្រូវនូវ៖

- ប្រភេទនៃប្រធានតែងសេចក្តី : ក្នុងប្រភេទនៃប្រធានតែងសេចក្តីមានចំណុចសំខាន់ៗគឺ លក្ខណៈសម្គាល់របស់ប្រភេទប្រធាន បម្រាប់ប្រធាន និងឃ្លាសំណួរ
- ទម្រង់នៃប្រភេទតែងសេចក្តីនីមួយៗ ដែលក្នុងនោះមានផ្នែកសំខាន់ៗដូចជា៖
  - ✓ ផ្តើមសេចក្តី: ក្នុងសេចក្តីផ្តើមមានចំណុចសំខាន់ៗគឺលំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា
  - ✓ តួសេចក្តី: ក្នុងតួសេចក្តីមានចំណុចសំខាន់ៗគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី
  - ✓ បញ្ចប់សេចក្តី: ក្នុងសេចក្តីបញ្ចប់មានចំណុចសំខាន់ៗគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន។
- ការប្រមូលគំនិត សរសេរព្រាង កែលម្អ និងសរសេរសម្រេច។

### ៣.២- ទំនាក់ទំនងមេរៀន

គ្រូសួរសំណួរដើម្បីផ្សារភ្ជាប់សមត្ថភាពចាំបាច់ ឬបទពិសោធរបស់សិស្សទៅនឹងខ្លឹមសារមេរៀនថ្មី។

### ៣.៣- គ្រូដឹកនាំសិស្សការសិក្សាប្រធាន

ការរៀបចំសកម្មភាពរៀននិងបង្រៀនគប្បីផ្តោតលើចំណុចមួយចំនួនដូចខាងក្រោម៖

- ប្រភេទប្រធានតែងសេចក្តី: តើប្រធាននេះជាប្រភេទប្រធានអ្វី?
- សិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធាន: តើមានលក្ខណៈសម្គាល់ដូចម្តេច ដែលអាចបញ្ជាក់ថាជាប្រភេទប្រធាននោះ?
- សិក្សាបម្រាប់ប្រធាន: តើប្រធានប្រភេទនោះមានបម្រាប់ប្រធានដូចម្តេចខ្លះ?
- សិក្សាឃ្លាសំណួរ: តើប្រធានប្រភេទនោះមានឃ្លាសំណួរដូចម្តេចខ្លះ?

## ៣.៤- ការប្រមូលគំនិត

- ការប្រមូលគំនិតមានគោលបំណងឱ្យសិស្សរៀបចំឱ្យបានជាគម្រោងតែងសេចក្ដីស្របតាមប្រភេទនៃប្រធានតែងសេចក្ដីដែលបានដាក់ឱ្យ។ ក្នុងការប្រមូលគំនិតនេះសិស្ស និស្សិតត្រូវបង្កើតឱ្យបានជាគម្រោងតែង។ គម្រោងតែង ទាមទារឱ្យអ្នកសរសេររកគំនិតទាំងឡាយណាដែលទាក់ទងជាមួយនឹងអត្ថន័យរបស់ប្រធានមកសរសេរ ហើយការសរសេរនេះមិនទាមទារឱ្យសរសេរជាល្បះពេញលេញនោះទេ ពោលគឺសរសេរតែគោលគំនិតសំខាន់ និងមានបញ្ជាក់ឧទាហរណ៍ ឬអំណះណាងជាគោលៗបានហើយ។
- ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្ដែង។
- **ឧទាហរណ៍មួយចំនួនដែលជាលទ្ធផលបានមកពីសកម្មភាពប្រមូលគំនិត**

**ឧទាហរណ៍ទី១** : **តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់ពាក្យស្លោក**

**ប្រធាន** : ពាក្យស្លោកមួយបានលើកឡើងថា៖ "សេចក្ដីព្យាយាមគង់បានសម្រេច"។ ចូរប្អូនពន្យល់ពាក្យស្លោកនេះឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

### គម្រោង

**ក- ផ្ដើមសេចក្ដី**

- លំនាំបញ្ហា: បុព្វបុរសយើងតែងចង់ទូន្មានកូនចៅ.... រស់នៅបានសុខ...
- ចំណូលបញ្ហាឬបង្ហាញបញ្ហា: ...សេចក្ដីព្យាយាមគង់បានសម្រេច...
- ចំណោទបញ្ហា: តើពាក្យស្លោកនេះ មានអត្ថន័យដូចម្ដេច ...។

**ខ- តួសេចក្ដី**

- ឃ្លាភ្ជាប់សេចក្ដី: ដើម្បីជាជំនួយ... គប្បីយល់នូវន័យ នៃពាក្យគន្លឹះរបស់ប្រធាន ...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ ព្យាយាម: ...ព្យាយាម គឺខិតខំប្រឹងប្រែង សង្វាត...
  - ✓ សម្រេច : ... គឺធ្វើឱ្យរួចស្រេច ធ្វើឱ្យហើយស្រេច ធ្វើឱ្យបានដាច់ស្រេច...។
- ពន្យល់ន័យប្រធាន: ប្រធានខាងលើមានន័យថា ការខិតខំប្រឹងប្រែងធ្វើកិច្ចការអ្វីមួយនឹងធ្វើឱ្យកិច្ចការនោះបានសម្រេច ...។
- បកស្រាយប្រធាន៖
  - ✓ ព្យាយាមដោយកម្លាំងកាយ ... គឺមានន័យថាការខិតខំប្រឹងប្រែងដោយប្រើប្រាស់កម្លាំងកាយក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច...។ ឧទាហរណ៍...ដូចជាក្នុងរឿងចចកនិងកំពឹសនៅពេលក្រុមរបស់ចចក បាចទឹកជិតរីងត្រីក្រាញ់ខំនឿលទៅរកព្រះឥន្ទ្រជួយ....
  - ✓ ព្យាយាមដោយកម្លាំងចិត្ត ... គឺមានន័យថាការមានទឹកចិត្តមោះមុត មានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច ...។ ឧទាហរណ៍ ...ដូចជាក្នុងរឿងកុលាបប៉ៃលិន តួអង្គចៅចិត្រមានទឹកចិត្តក្លាហានប្រយុទ្ធតទល់នឹងចោរប្លន់ ....
  - ✓ ព្យាយាមដោយកម្លាំងប្រាជ្ញា...គឺមានន័យថាការខិតខំត្រិះរិះ គិតពិចារណារិះរកវិធីផ្សេងៗក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេចដោយបញ្ញា ...។ ឧទាហរណ៍ ... តួយ៉ាងដូចជា

សិស្សានុសិស្សគ្រប់រូបត្រូវខិតខំព្យាយាមរៀនសូត្រតាំងពីតូចក្រូចឆ្មាររហូតដល់ធំទើបទទួលបានចំណេះវិជ្ជា...។

- សរុបសេចក្តី: ការសិក្សារៀនសូត្រ ការធ្វើកិច្ចការអ្វីមួយ ការដោះស្រាយបញ្ហាគ្រប់បែបយ៉ាងទាំងអស់កាលណាយើងខិតខំប្រឹងប្រែងទាំងផ្លូវកាយ ទាំងផ្លូវចិត និងទាំងផ្លូវប្រាជ្ញា នោះទើបបានសម្រេច...។

**គ- បញ្ចប់ សេចក្តី**

- វាយតម្លៃប្រធាន: ....ពាក្យស្លោកដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅសម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូប ...
- យោបល់ផ្ទាល់ខ្លួន: ...ក្នុងនាមជាសិស្ស ត្រូវខិតខំព្យាយាមរៀនសូត្រ ដើម្បីសម្រេចបានគោលដៅជីវិត...។

**ឧទាហរណ៍ទី២ : តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត**

**ប្រធាន** : សុភាសិតមួយចែងថា "ងើយស្កក ឱនដាក់គ្រាប់"។ ចូរពន្យល់សុភាសិតខាងលើឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍ជាក់ស្តែង និងក្នុងអក្សរសិល្ប៍មកបញ្ជាក់ផង។

## គម្រោង

**ក- សេចក្តីផ្តើម**

- លំនាំបញ្ហា: ខ្មែរយើងបានបន្សល់ទុកនូវសុភាសិត ដើម្បីអបរំកូនចៅ...
- ចំណូលបញ្ហាឬបង្ហាញបញ្ហា: ...ងើយស្កក ឱនដាក់គ្រាប់ ....
- ចំណោទបញ្ហា: តើសុភាសិតនេះមានអត្ថន័យដូចម្តេច ...។

**ខ- តួសេចក្តី**

- ឃ្លាភ្ជាប់សេចក្តី: ...ដើម្បីជាជំនួយដល់ការបកស្រាយ... គប្បីយល់ន័យពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ ងើយ: ឈរប្រាស់ឡើងទៅលើ ...
  - ✓ ស្កក: កួរស្រូវដែលមិនមានគ្រាប់ ...ឬសាច់អង្ករ ...
  - ✓ ឱន: ...ទន់ចុះក្រោម បន្ទន់ទៅមុខ សំយុងចុះ ....
  - ✓ ដាក់គ្រាប់: ...ស្រូវមានគ្រាប់ពេញ ឬមានគ្រាប់អង្ករ....។
- ពន្យល់ន័យប្រធាន: ប្រធានមានន័យថា កួរស្រូវដែលឈរត្រង់ទៅលើ ... ប្រៀបដូចមនុស្សមានចរិតអួតក្អេងក្អាង... តែងមិនទទួលបាននូវផលល្អ ... ផ្ទុយទៅវិញកួរស្រូវដែលទន់ចុះ ... ប្រៀបដូចមនុស្សដែលចេះដាក់ខ្លួនឱ្យទាប... តែងទទួលបាននូវបានផលល្អ ...។
- បកស្រាយប្រធាន៖
  - ✓ បកស្រាយអត្ថន័យ"ងើយស្កក"៖
    - អត្ថានុរូបឬន័យត្រង់: "ងើយស្កក" គឺសំដៅលើស្រូវដែលកួររបស់វាមានផ្លែតែគ្មានដាក់គ្រាប់ ...
    - អត្ថបដិរូបឬន័យធៀប: គេចង់ប្រៀបធៀបទៅនឹងមនុស្ស ដែលមានឥរិយាបថ ឆ្កាំឆ្កង ...
    - ឧទាហរណ៍ក្នុងសង្គមជាក់ស្តែង មនុស្សមានឫកពាក្អេងក្អាង ... មិនទទួលបានផលល្អ...

- ឧទាហរណ៍ក្នុងអក្សរសិល្ប៍រឿងកុលាបប៉ៃលិន ...លោកបាឡាត់មានឫកពាក្អេងក្អាង ... ទទួល បរាជ័យ... ។

✓ បកស្រាយអត្ថន័យ"ឱនដាក់គ្រាប់"៖

- អត្ថានុរូបឬន័យត្រង់ : "ឱនដាក់គ្រាប់" គឺសំដៅទៅលើរុក្ខជាតិដែលមានទងកួរដាក់គ្រាប់ពេញធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះ...
- ឧទាហរណ៍តួយ៉ាងដូចជាដំណាំស្រូវទុំដាក់គ្រាប់ពេញ ធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះ...
- អត្ថបដិរូបឬន័យធៀប: លោកចង់ធ្វើការប្រៀបធៀបកួរស្រូវទៅនឹងការប្រព្រឹត្តរបស់មនុស្ស... ការរស់នៅ ការធ្វើការងារ ចេះដាក់ខ្លួនឱ្យទាប ទទួលបានជោគជ័យ...
- ឧទាហរណ៍ក្នុងសង្គមជាក់ស្តែង មនុស្សចេះឱនលំទោន ... ទទួលបានផលល្អ...
- ឧទាហរណ៍ក្នុងអក្សរសិល្ប៍រឿងកុលាបប៉ៃលិន ចៅចិត្រចេះឱនលំទោន...ទទួលបានជោគជ័យ...។

- សរុប: កួរដែលងើយឈរត្រង់គឺជាកួរដែលស្កកមិនបានផល ប្រៀបដូចមនុស្សដែលមានចរិតក្អេងក្អាងតែងទទួលរងការរិះគន់... និងមិនទទួលបាននូវលទ្ធផលល្អ ...ផ្ទុយពីកួរទន់ចុះគឺ ... ដាក់គ្រាប់ទទួលបានផលល្អ ប្រៀបដូចមនុស្សដែលអាកប្បកិរិយាទន់ភ្លន់តែងទទួលបាននូវសេចក្តីថ្លៃថ្នូរ...។

**គ- បញ្ចប់ សេចក្តី**

- វាយតម្លៃប្រធាន: សុភាសិតនេះពិតជាមានអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅសម្រាប់អប់រំកូនចៅ...
- យោបល់ផ្ទាល់ខ្លួន: ក្នុងនាមអ្នកសិក្សាត្រូវ... ខិតខំសិក្សាស្វែងយល់ ...។

## ៣.៥- ការសរសេរព្រាង

- គ្រូដឹកនាំសិស្សធ្វើសំណេរព្រាងដោយ៖
  - ✓ សរសេរពង្រីកគំនិតនីមួយៗ ជាលក្ខណៈពង្រីកគំនិតដើម្បីផ្តល់សេចក្តីពន្យល់ជាលក្ខណៈបកស្រាយគំនិតឱ្យគេយល់ ជាលក្ខណៈបកស្រាយបញ្ហា ជាលក្ខណៈរៀបរាប់ពិពណ៌នា។ល។
  - ✓ នៅក្នុងការបកស្រាយ ឬការពន្យល់ចំណុចនីមួយៗ ត្រូវលើកឧទាហរណ៍ ផ្តល់ភស្តុតាង និងផ្តល់អំណះអំណាងជាដើម ដែលទាញយកមកពីសង្គមជាក់ស្តែង និងក្នុងអក្សរសិល្ប៍ ដើម្បីឱ្យការបកស្រាយ ឬការពន្យល់ចំណុចនីមួយៗនោះ មានភាពច្បាស់លាស់ ឡូសីក មានហេតុផលត្រឹមត្រូវ។
- ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។

## ៣.៦- ការកែលម្អ

- គ្រូដឹកនាំសិស្សធ្វើការកែលម្អដោយ៖
  - ✓ ពិនិត្យកែលម្អលើទម្រង់តែងសេចក្តី មានគ្រប់ចំណុចនៃគម្រោងទៅតាមប្រភេទប្រធានហើយឬនៅ។
  - ✓ ពិនិត្យមើលគំនិតដែលបានលើកយកមកនោះគ្រប់គ្រាន់ អាចគាំទ្រដល់ការបកស្រាយបានហើយ ឬនៅ។

- ✓ ពិនិត្យលើខ្លឹមសារនៃការបកស្រាយ ឬការពន្យល់បានត្រឹមត្រូវសមហេតុផលហើយ ឬនៅ។
- ✓ ពិនិត្យលើការលើកឧទាហរណ៍ ការផ្តល់ភស្តុតាង និងការផ្តល់អំណះអំណាងត្រឹមត្រូវសមហេតុផលហើយ ឬនៅ។
- ✓ ពិនិត្យកែលម្អលើទម្រង់ឃ្លា ល្បះ វេយ្យាករណ៍។
- ✓ ពិនិត្យកែលម្អលើអក្ខរាវិរុទ្ធ។

- ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។

### ៣.៧- ការសរសេរសម្រេច

ការសរសេរសម្រេច គឺជាដំណាក់កាលចុងក្រោយនៃការសរសេរតែងសេចក្តី។ ដូច្នេះសិស្សសរសេរកិច្ចការរបស់ខ្លួនឡើងវិញឱ្យបានស្អាត បន្ទាប់ពីមានយោបល់កែលម្អ។

### ៣.៨- ការពង្រឹងចំណេះដឹង

ការពង្រឹងចំណេះដឹងនេះក៏ដូចគ្នាទៅនឹងការពង្រឹងចំណេះដឹងមុនដែរ គឺមានគោលបំណងចង់វាយតម្លៃការយល់ដឹងរបស់សិស្ស។ ការវាយតម្លៃនេះគប្បីផ្តោតលើសិស្សរៀនយឺត មានន័យថាបើសិស្សរៀនយឺតអាចធ្វើបានត្រឹមត្រូវ នោះមានន័យថាសិស្សដទៃទៀតក៏អាចធ្វើបានដែរ។

### ៣.៩- ការដាក់កិច្ចការស្រាវជ្រាវ

ការកិច្ចការស្រាវជ្រាវនេះក៏ដូចគ្នាទៅនឹងការកិច្ចការស្រាវជ្រាវមុនដែរ គឺមានគោលបំណងឱ្យសិស្សយល់ដឹងពីវិធីស្រាវជ្រាវ និងសិស្សចេះចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវ។ គ្រូគប្បីដាក់ប្រធានបទ ឬសំណួរ ឬលំហាត់ឱ្យសិស្សសិក្សាស្រាវ។ ក្នុងសកម្មភាពសិក្សាស្រាវជ្រាវនេះ គប្បីរៀបចំសកម្មភាពមួយចំនួនដូចមេរៀនមុនៗ។

### ៣.១០- ការសង្ខេបសកម្មភាព និងខ្លឹមសារសំខាន់ៗ

ចំណុចនេះក៏ដូចគ្នាទៅនឹងការសង្ខេបមុនដែរ គឺមានគោលបំណងឱ្យសិស្ស ចេះនិយាយសង្ខេបឡើងវិញនូវសកម្មភាពរៀននិងបង្រៀនមេរៀននេះ និងចេះសង្ខេបខ្លឹមសារសំខាន់ៗដែលបានរៀននៅក្នុងមេរៀននេះ។ ការសង្ខេបនេះ ច្រើនធ្វើជាលក្ខណៈបុគ្គលដោយមានការផ្លាស់ប្តូរវេនគ្នា ជាពិសេសត្រូវផ្តោតលើសិស្សរៀនយឺតឱ្យបានអនុវត្តច្រើនជាងគេ។

### ៣.១១- ការប្រមូលសរុប

គ្រូធ្វើការប្រមូលសរុបខ្លឹមសារសំខាន់ៗ ដែលតម្រូវឱ្យសិស្សយកចិត្តទុកដាក់ និងអាចណែនាំបន្ថែមឬពន្យល់បន្ថែម ទៅលើចំណុចមួយចំនួនដែលសិស្សខ្វះខាត ឬចំណុចសិស្សមិនទាន់យល់ច្បាស់។

## ឯកសារពិគ្រោះ

១- វិធីសាស្ត្រនៃតែងសេចក្ដីខ្មែរសម្រាប់មធ្យមសិក្សាដោយលោក«គង់ នឿន» គ.ស១៩៦៩ ព.ស២៥១៣
២- ភាសិតអធិប្បាយសម្រាយយបំភ្លឺសម្រាប់ថ្នាក់ទំនើបរៀបរៀងដោយលោក«សែម សូរ»និង «អ៊ ីន សារុន»
៣- វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧
៤- បរមាធិប្បាយពិសេស សំរាប់សិក្សាអក្សរសាស្ត្រខ្មែរទូទៅ ដោយលោក«សែម សូរ» ព.ស ២៥១៣ គ.ស១៩៧០
៥- សិក្សាអត្ថបទទំទាវ រាមកេរ្ដិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ឆ្នាំ១៩៨៨
៦- បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ ឆ្នាំ១៩៨៩ លោកស្រី «យិន វ៉ាន់ថា»
៧- មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សទី១៩ លោក «ឃីង ហុកឌី» ឆ្នាំ២០០៣
៨- សិក្សាអក្សរសាស្ត្រខ្មែរបទុមត្ថេរសោម កវីសតវត្សរ៍ទី១៩ ទុំទាវ ឆ្នាំ១៩៧១ ដោយគង់ សម្ភារ
៩- រឿងទុំទាវ និពន្ធដោយ ព្រះបទុមត្ថេរសោម ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស២៥១៤
១០- ប្រវត្តិសាស្ត្រខ្មែរភាគ១-២(ត្រឹង ងា)សម្រាប់មធ្យមសិក្សានិងឧត្តមសិក្សាព.ស.២៥១៧ គ.ស.១៩៧៣
១១- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ បោះពុម្ពដោយគ្រឹស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១១
១២- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១ បោះពុម្ពដោយគ្រឹស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១២
១៣- ភាសាខ្មែរ ថ្នាក់ទី១០ បោះពុម្ពដោយគ្រឹះស្ថាន និងចែកផ្សាយ ឆ្នាំ២០១៤
១៤- រាមកេរ្តិ៍ ខ្សែ១ដល់ខ្សែ១០ ខ្សែ៧៥ដល់ខ្សែ៨០ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៣៩ គ.ស១៩៩៥
១៥- កម្រងតែងសេចក្ដី ជ្រើសរើស ថ្នាក់ទី១១ (សាធារណរដ្ឋប្រជាមានិតកម្ពុជា)ថ្ងៃទី២០ សីហា ១៩៨៧
១៦- តែងសេចក្ដីសម្រាប់ថ្នាក់ទី១២ និពន្ធនិងរៀបរៀងដោយលោក ព្រៃ សំបូរ ឆ្នាំ២០១៥
១៧- សង្គមវិជ្ជាខ្មែរ សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តមសិក្សា ដោយលោក«សរ សារុន ) ឆ្នាំ ១៩៧៣-៧៤
១៨-ប្រជុំវប្បធម៌ វិទ្យាស្ថានជាតិខេមរយានកម្ម ដោយលោក ឡុច ផ្លែង ឆ្នាំ១៩៧៣
១៩- សេចក្ដីណែនាំស្ដីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ថ្នាក់ទី១២ លេខ០៣ អយក.សណន. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៦